# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ចេតិយបុរាណលើខ្នងភ្នំយ៉ាត (ក្រុងប៉ៃលិន)

ឆ្នាំ ទី ៥៨ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស. ២៥៤៧ គ.ស. ២០០៤

ភ្នំពេញ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ;

នាយកការផ្សាយ : ខូន វ៉ាន់ចន្ទី
និពន្ធនាយក : ខៀវ បញ្ញាឧត្តម

គណៈកម្មការនិពន្ធ
លោកបណ្ឌិតទស្សនវិជ្ជា ឆយ យីហ៊ាង លោក ខង់ សុធារ៉ា
លោក ធន់ ហ៊ិន លោក មៀច ប៉ុណ្ណ

ការីកុំព្យូទ័រ
លោក ឡិម ទីរៈ លោក ឡាច ញ៉ីន
លោក គង់ សំអេច លោក សំ ធា

# គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈេង អឿម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **ឆេត ឆារ៉ុម** សាកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( **WCRP** ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# ជីវិតមនុស្ស និង បញ្ហា (ត)

បណ្ឌិត **ក.ស្រីធម្មានន្ទ នាយកមហាថេរ**
បកប្រែ **ឈន_អឿម**

## ចលនារំដោះស្ត្រី និងឥទ្ធិពលរបស់វាលើជីវភាពគ្រួសារ

*នៅក្នុងអតីតកាលដ៏យូរលង់ហើយ មនុស្សប្រុសបានចេញទៅបរបាញ់សម្រាប់យកអាហារមកចិញ្ចឹមគ្រួសារ ហើយមនុស្សស្រីបាននៅផ្ទះដើម្បីដាំស្ល ថែទាំកូន ហើយនិងមើលផ្ទះសម្បែងៗ ដូច្នេះទើបមានប្រកពដើម នៃឃ្លាប្រជាប្រិយថា "ទីតាំងរបស់ស្ត្រីគឺនៅក្នុងផ្ទះ"ៗ*

*ក្នុងសម័យបុរាណ ស្ត្រីបានពេញចិត្តពេញថ្លើម ជាអ្នកថែទាំផ្ទះសម្បែងៗ ពួកគេមិនចេញទៅក្រៅដើម្បីធ្វើការងារ ឬបំពេញមុខរបរទេៗគំរូជាធម្មតា* (stereotype) *នៃស្ត្រីភេទ ដែលមានជីវភាពវិវត្តជុំវិញកូននិងចង្ក្រានត្រូវបានរិចរិលទៅហើយអស់ច្រើនទសវត្សកន្លងទៅ ដោយសារតែស្ត្រីកាន់តែច្រើនឡើងៗបានបម្រើមុខរបរៗ ប៉ុន្តែសង្គមជនបទជាទូទៅ នៅតែលើកស្ទួយភាពជាមាតានៅឡើយហើយមិនជ្រោងការមានមុខរបរទេ* (careerism)*ៗ សង្គមទទួលយកស៊ើរតែជាទូទៅនូវហេតុពិតដែលថា ពលកម្មស្ត្រីនៅលីវតាមធម្មតាឧបត្ថម្ភខ្លួនឯងបាន ហើយនាងធ្វើកាគទានយ៉ាងទូលំទូលាយដល់ការឧបត្ថម្ភ*

ឪពុក-ម្តាយចាស់ជរា និងសមាជិកក្មេងៗនៃគ្រួសារ។ ស្ត្រីជាច្រើនស្វែងរកការងារធ្វើ ដោយសារសេចក្តីត្រូវការខាងសេដ្ឋកិច្ច និងអាកប្បកិរិយាប្រែប្រួលអំពីការបំពេញភារកិច្ចផ្ទាល់ខ្លួន។

ប៉ុន្តែជាមួយនឹងសេចក្តីអំពាវនាវដើម្បីការរំដោះស្ត្រី មានស្ត្រីជាច្រើនហាក់បានគិតថា ដំណោះស្រាយបញ្ហា គឺការប្រណាំងប្រជែងជាមួយបុរសនៅខាងក្រៅផ្ទះ។ ពួកស្ត្រីដូចនេះគប្បីពិចារណាដោយល្អិតល្អន់បន្តិច ថាតើពួកគេចង់ថែទាំកូន ឬចង់បំពេញមុខរបរ។ វាជាអំពើមិនទទួលខុសត្រូវចំពោះម្តាយម្នាក់ដែលបង្កើតជីវិតមួយក្នុងលោកនេះហើយ ហើយបន្ទាប់មកដោះដៃ ទុកឲ្យជីវិតនេះស្ថិតនៅក្រោមការថែទាំរបស់អ្នកដទៃ ដោយមិនបានយកចិត្តទុកដាក់ត្រឹមត្រូវចំពោះសុខមាលភាពរបស់កូន។ អ្នកត្រូវទទួលខុសត្រូវចំពោះអ្វីដែលអ្នកបង្កើត។

មានកំណើនស្ត្រីមានប្តីហើយចេញធ្វើការងារច្រើន គួរឲ្យកត់សម្គាល់។ សព្វថ្ងៃពួកគេបាននាំមុខជាស្ត្រីមានអាជីព ជាញឹកញយពួកគេដើរតួទ្វេគឺជាស្ត្រីធ្វើការងារផង ជាម្តាយផង។ ម្តាយមានការងារធ្វើកាន់តែច្រើនតែងរវល់រក រវាងទោសកំហុសទុកកូនរបស់ខ្លួនឲ្យនៅផ្ទះជាមួយអ្នកបម្រើ ហើយនិងសម្រេកហៅនៃអាជីពរបស់ខ្លួន។

ដោយការតែមានស្ត្រីសិក្សាថ្នាក់ខ្ពស់ៗច្រើនឡើងៗ ចំនួនស្ត្រីជាម្តាយធ្វើការងារកំពុងតែកើនឡើង។ ប៉ុន្មានឆ្នាំកន្លងទៅ ស្ត្រីទាំងឡាយបានឈានទៅមុខយ៉ាងលឿនក្នុងវិជ្ជាជីវៈ ហើយសព្វថ្ងៃកំពុង

កាន់កាប់ឋានៈគ្រប់គ្រងខ្ពស់នៅក្នុងក្រសួងរដ្ឋាភិបាល និងនៅក្នុងផ្នែកឯកជន។ ទំនោរនេះកំពុងលេចធ្លោខ្លាំងបំផុតនៅក្នុងតំបន់ទីក្រុង។ នៅក្នុងវិស័យនយោបាយ ស្ត្រីទាំងឡាយបានឡើងកាន់តំណែងជានាយករដ្ឋ-មន្ត្រី រហូតដល់ពួកគេមើលឃើញ ខ្លួនគេកាន់តែលេចធ្លោនៅក្នុងជីវ-ភាពសាធារណៈ ចំណែកឯប្តីរបស់ពួកគេដែលនៅក្នុងទីតាំងក្រោយពេញចិត្តពេញថ្លើមនឹងស្ថិតនៅក្នុងម្លប់នៃប្រពន្ធរបស់ខ្លួន។

រីឯនាយកប្រតិបត្តិជាស្ត្រី (woman execusives) ដែលកំពុងស្រវាឡើងជណ្តើរសាជីវកម្មទៅកាន់តំណែងគ្រប់គ្រងខ្ពស់ៗ ក៏កំពុងប្រឈមមុខនឹង ទម្រង់រើសអើងខាងភេទដ៏ស្រួចស្រាល់នៅឡើយ។ គម្លាតយេនឌ័រ (the gender gap) ដែលស្ត្រីទាំងឡាយមានធនុះខ្លាំងក្លាកំពុងប្រឈមមុខជាពិសេសពួកស្ត្រីអ្នកមានវិជ្ជាជីវៈ គឺជាព្រឹត្តិ-ការណ៍ដ៏ខ្ជូរខ្ជារបំផុត នៅកំពូលនៃកាំជណ្តើរសាជីវកម្ម។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុមហ៊ុន តាមទម្លាប់តែងបញ្ចប់ដោយពាក្យកត់សម្គាល់ថា " *យើងខកចិត្តចំពោះការងារបណ្តុះបណ្តាលពួកគេ (ស្ត្រី) សម្រាប់ការងារដឹកនាំ ពីព្រោះការវិនិយោគរបស់យើង នឹងខាតបង់ ប្រសិនបើពួកគេ(ស្ត្រី) ចាកចោលដើម្បីក្លាយខ្លួនជាម្តាយ (មេផ្ទះ)។*

ប៉ុន្តែការរើសអើងយេនឌ័រ (Gender discrimination) នៅថ្នាក់នាយកប្រតិបត្តិពិបាកបញ្ជាក់ភស្តុតាងណាស់ ដូច្នេះហើយ ទើបគេបង្កើតពាក្យ "ពិដានកញ្ចក់" (glass ceiling) ដើម្បីពិពណ៌នារបាំងមើល

មិនឃើញ ប៉ុន្តែរឹងមាំដែលរាំងផ្លូវរបស់ស្ត្រីមិនត្រូវឲ្យឡើងទៅកាន់ថ្នាក់ខ្ពស់ៗនៃអំណាចសាជីវកម្មៗ ទោះបីមានមនុស្សខ្លះបដិសេធយ៉ាងដាច់ខាតនូវអត្ថិភាពនៃរបាំងបែបនេះក្តី ក៏មាគ៌ារបស់ស្ត្រីទៅកាន់ថ្នាក់កំពូលត្រូវបានរាំងខ្ទប់ដោយអ្វីដែលគេហៅថា " ពិដានកញ្ចក់ " រួចស្រេចទៅហើយៗ ដូច្នេះដើម្បីឡើងទៅដល់កំពូលបាន ស្ត្រីត្រូវជ្រើសរើសរវាងអាជីពនិងគ្រួសារៗ មានម្តាយអ្នកធ្វើការប្រកបដោយមនសិការខ្លះ ទោះបីមានអ្នកជួយធ្វើការងារផ្ទះថែទាំកូនៗក្តី បានដឹងច្បាស់ថា ពួកគេមិនអាចទុកកូនៗរបស់គេឲ្យស្ត្រីផ្សេងថែទាំឡើយ ថ្វីបើគេសប្បាយនឹងធ្វើការនៅការិយាល័យរបស់គេយ៉ាងណាក៏ដោយ ក៏គេបានសម្រេចចិត្តបោះបង់ចោលអាជីពដែរៗ តាមពិតវាមានរឿងគួរឲ្យសោកស្តាយ ដែលមានស្ត្រីខ្លះ បានជ្រើសយកការបន្តអាជីពរបស់ខ្លួនជាជាងការរស់នៅថែទាំគ្រួសារៗ

ក្មេងម្នាក់មានសិទ្ធិសប្បាយរីករាយខាងសម្ភារៈ ប៉ុន្តែសប្បាយខាងស្មារតីនិងផ្លូវចិត្តមានសារសំខាន់ជាងៗ ការផ្តត់ផ្គង់សុខមាលភាពជាសម្ភារៈគឺបន្ទាប់បន្សំ បើគេប្រៀបធៀបទៅនឹង ការផ្តត់ផ្គង់សេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមរបស់ឪពុកម្តាយៗ យើងស្គាល់មនុស្សជាច្រើនមកពីគ្រួសារក្រីក្រដែលមានប្រាក់ចំណូលតិចតួច ប៉ុន្តែបានចិញ្ចឹមបីបាច់កូនយ៉ាងល្អជាមួយនឹងសេចក្តីស្រឡាញ់ យ៉ាងទូលំទូលាយៗ

ផ្ទុយទៅវិញ មនុស្សជាច្រើនមានទ្រព្យសម្បត្តិបានផ្តល់សុខ-

មាលភាពខាងសម្ភារៈសព្វបែបយ៉ាង សម្រាប់កូនៗរបស់គេ ប៉ុន្តែដោយហេតុតែខ្វះសេចក្តីស្រឡាញ់ថ្នាក់ថ្នមរបស់ឪពុកម្តាយ ក្មេងទាំងនោះបានធំឡើងប្រែក្លាយជាមនុស្សពិការខាងផ្លូវចិត្ត និងខាងសីលធម៌។

មានស្ត្រីខ្លះ អាចមានអារម្មណ៍ថា ការទូន្មានឲ្យពួកគេប្រមូលផ្តុំយកចិត្តទុកដាក់លើការចិញ្ចឹមថែរក្សាគ្រួសារ គឺជាការបន្ទាបសេចក្តីថ្លៃថ្នូរឬជាការបន្ទុះបង្អាប់ ហើយដំបូន្មាននេះធ្លុះបញ្ចាំងគំនិតចាស់គំរិលនិងអភិរក្ស។ ជាការណ៍ពិតហើយ នៅក្នុងអតីតកាល ស្ត្រីទាំងឡាយត្រូវបានគេចាត់ទុកជាភេទទន់ខ្សោយ និងថោកទាប ប៉ុន្តែនេះបណ្តាលមកពីភាពល្ងង់ខ្លៅរបស់បុរស ច្រើនជាងភាពទន់ខ្សោយដែលមាននៅក្នុងស្ត្រីភេទ។ ពាក្យសំស្ក្រឹតសម្រាប់សម្គាល់មេផ្ទះគឺគ្រហិនី ដែលមានន័យថា"អ្នកដឹកនាំផ្ទះ"។ តាមពិតពាក្យនេះមិនមានន័យថាស្ត្រីអន់ថយទេ។ ផ្ទុយទៅវិញ វាមានន័យថាការចែករំលែកភារកិច្ចទទួលខុសត្រូវសម្រាប់បុរសនិងស្ត្រី។

ស្ត្រីទាំងឡាយបានប្រយុទ្ធអស់ច្រើនសតវត្សហើយទាមទារសមភាពស្មើនឹងបុរសក្នុងវិស័យអប់រំ មុខរបរ នយោបាយ និងវិស័យទាំងឡាយដទៃទៀត។ ឥឡូវពួកគេបានស្មើមុខមាត់ជាមួយបុរសបានមួយចំនួនធំហើយ។ ជាទូទៅ បុរសមានទំនោរទៅរកអំពើឈ្លានពាន (ឃោរឃៅ)ដោយធម្មជាតិ ឯស្ត្រីមានទំនោរទៅរកចិត្តវេត ឬសេចក្តីរំជួលចិត្ត (emotion) ច្រើនជាង។ ក្នុងធាកគ្រួសារ ជាពិសេសនៅក្នុង

កូមិកាគប្ញូពាក់ទិស បុរសមានតួនាទីគ្របសង្កត់លើគេច្រើនក្នុងឋានៈជាមេគ្រួសារ ចំណែកស្ត្រីទោរទន់ទៅកាន់ភាពជាដៃគូ ចាំតែទទួលរ៉ាប់រងអំពើ (a passive partner) ។ សូមបងចាំថា 'passive' (=អកម្ម ឬឥតប្រកែកតវ៉ា) ក្នុងទីនេះមិនមានន័យថា (Weak)=ទន់ខ្សោយទេ។ ផ្ទុយទៅវិញ ពាក្យនេះគឺជាគុណសម្បត្តិវិជ្ជមានមួយនៃ 'modesty' គឺ ហិរិ ឬសេចក្ដីអៀនខ្មាស និង 'gentleness' គឺ មុទុតា ឬភាពទន់ភ្លន់ៗ ប្រសិនបើបុរស និងស្ត្រីរក្សាបាននូវគុណសម្បត្តិជាបុរស និងជាស្ត្រីរបស់ផងខ្លួនផ្ដល់មកពីធម្មជាតិ ហើយទទួលស្គាល់ពលានុភាព និងឋានៈរបស់ខ្លួនរៀងៗខ្លួន នោះឥរិយាបថបែបនេះអាចផ្ដល់វិភាគទានចំពោះការយោគយល់គ្នាទៅវិញទៅមក កើតមានតាំងពីកំណើតរហូតគេទាំងពីរ។

នៅក្នុងរឿងនេះការកត់សម្គាល់របស់លោកគន្ធី មានទំនាក់ទំនងត្រូវល្អណាស់៖ *"ខ្ញុំជឿក្នុងការអប់រំត្រឹមត្រូវសម្រាប់ស្ត្រី។ ប៉ុន្តែខ្ញុំជឿជាក់ថា ស្ត្រីនឹងមិនធ្វើវិភាគទានរបស់ខ្លួនដល់ពិភពលោកដោយគ្រាប់តាមបុរសឬរត់ប្រណាំងជាមួយបុរសទេ។ ស្ត្រីអាចរត់ប្រណាំងបាន ប៉ុន្តែគេនឹងមិនឡើងទៅកាន់កម្ពស់ដ៏ខ្ពស់ដែលគេអាចធ្វើបាន ដោយគ្រាប់តាមបុរសទេ "* ។ ក្នុងទីនេះ យើងអាចក្រឡេកមើល គតិបណ្ឌិតរបស់ចិនបុរាណ ពេលដែលគេបង្កើត និមិត្តរូប *យិន* (yin) និង *យ៉ាង* (yang) (បុរសនិងស្រី)។ ខ្សែបន្ទាត់កោងដែលខ័ណ្ឌពណ៌

ក្រមៅទិនិងពណិសជាតិរផ្នែកបង្ហាញថា ភាពផ្ទុយគ្នាមិនចាំបាច់ប្រកាន់យកជំហរប្រឈមមុខគ្នាទេ។ កាលណាភាគីណាមួយខ្លាំងជាង គ្របសង្កត់ជាង ភាគីមួយទៀតថយ។ កាលណា ភាគីណាមួយថយភាគីមួយទៀតឈានចូល ដូច្នេះផ្នែកទាំងពីរស្ថិតនៅស្មើគ្នា។ ស្ត្រីត្រូវតែជាអ្នកបំពេញ ឬបង្គ្រប់របស់បុរស។

នៅក្នុងប្រទេសទាំងឡាយខ្លះ ប្ដីជាច្រើនតែងប្រគល់ប្រាក់បៀវត្ស ឬប្រាក់ឈ្នួលរបស់ខ្លួនទៅឲ្យប្រពន្ធ ដែលជាអ្នកគ្រប់គ្រងចាត់ចែងកិច្ចការផ្ទះសម្បែង។ នេះធ្វើឲ្យប្ដីទំនេរ ដើម្បីប្រមូលផ្ដុំចិត្តគំនិតទៅលើអ្វីមួយដែលគេអាចធ្វើឲ្យបានល្អប្រសើរសម្រាប់គ្រួសារ។ដោយហេតុថាភាគីនីមួយៗដឹងច្បាស់នូវអ្វីដែលជាកិច្ចការទទួលខុសត្រូវរបស់ខ្លួន នោះវាគ្មានការប៉ះទង្គិចណាមួយរវាងគេទាំងពីរនាក់កើតឡើងទេ។ បរិយាកាសនៅផ្ទះមានសេចក្ដីសប្បាយនិងសុខក្សេមក្សាន្តដែលនៅក្នុងបរិយាកាសបែបនេះកូនៗរបស់ពួកគេបានដុះដាលធំធាត់យ៉ាងប្រពៃ។

មែនហើយ ប្ដីត្រូវយកចិត្តទុកដាក់មើលការខុសត្រូវចំពោះកិច្ចការនេះ។ ករិយារបស់គេត្រូវបានថែទាំត្រឹមត្រូវ នាងត្រូវបានប្ដីសាកសួរយោបល់លើរាល់សេចក្ដីសម្រេចចិត្តរបស់គ្រួសារ។ នាងត្រូវមានសេរីភាពគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍអត្តភាពរបស់នាងផ្ទាល់ ហើយនាងក៏ត្រូវការពេលវេលាទំនេរផ្ទាល់ខ្លួន ដើម្បីបំពេញអត្ថប្រយោជន៍សម្រាប់នាងផងដែរ។ ក្នុងន័យនេះ ប្ដីនិងប្រពន្ធទាំងពីរនាក់មានការកិច្ចទទួលខុសត្រូវ ស្មើគ្នាសម្រាប់សុខមាលភាពរបស់គ្រួសារ

ខ្លួន។ គេមិនត្រូវតាំងខ្លួនជាអ្នកប្រណាំងប្រជែងគ្នាទៅវិញទៅមកទេ។

ស្ត្រីជាម្តាយ ត្រូវពិចារណាឲ្យបានល្អិតល្អន់ ថាតើនាងត្រូវបន្តជាម្តាយធ្វើការងារម្នាក់ ដោយមានសេចក្តីលំបាកសព្វបែបយ៉ាង តាមជាប់ជាមួយ ឬជាស្ត្រីមេផ្ទះម្នាក់ដែលផ្តល់ការយកចិត្តទុកដាក់យ៉ាងស្និតស្នាញ, សេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមដល់កូនៗកំពុងធំធាត់ឡើងរបស់នាង ឬយ៉ាងណា។ វាជារឿងចម្លែក មានស្ត្រីជាម្តាយសម័យថ្មីខ្លះជាពិសេសនៅក្នុងប្រទេសមួយចំនួនដែលប្រកាន់របបយោធាហើយត្រូវប្រឈមនឹងកង្វះកម្លាំងមនុស្សប្រុស កំពុងត្រូវបានគេបង្ហាត់ឲ្យកាន់កាំភ្លើង ឬសញ្ញាវុធសម្លាប់មនុស្សដទៃទៀត ក្នុងពេលដែលស្ត្រីជាម្តាយទាំងនោះ ត្រូវឪបកូន ហើយបង្ហាត់កូនឲ្យទៅជាកូនល្អ ឬពលរដ្ឋដែលគោរពច្បាប់។ នៅក្នុងប្រទេសខ្លះទាហានស្រីៗ ជាញឹកញយមានកាន់កាំភ្លើងទោះបីតាមទម្លាប់សម្រាប់តែការពារខ្លួន ហើយពួកទាហានស្រីទាំងនោះ ក៏មិនត្រូវបានគេកំណត់ឲ្យនៅតែថ្នាក់ទាបនោះទេ។ នៅក្នុងកងទ័ពអាកាស ស្ត្រីសព្វថ្ងៃ បើកបរយន្តហោះប្រយុទ្ធ និងបើកឧទ្ធម្ភាគចក្រវាយប្រហារ មិនមែននៅត្រឹមតែជាអ្នកបើកបររថយន្តយោធាដឹកជញ្ជូនប៉ុណ្ណោះទេ ប៉ុន្តែនៅផ្ទះវិញ នៅតែបង្ហាញភាពទន់ភ្លន់របស់គេ និងចរិតថ្នាក់ថ្នមជាពិសេសជាមួយកូនៗ។

## កុមារ និងការអប់រំផ្លូវភេទ

ការបង្រៀនកុមារ អំពីរឿងប្រឌិតនៃភេទ និងការវិវឌ្ឍន៍ផ្លូវ

ភេទ ត្រូវធ្វើឡើងដោយប្រុងប្រយត្ន័, ដោយស្ទាបស្ទង់, និងតាមបែបបទជារួមទូទៅ។ ការប្រកាន់យកឥរិយាបថប្រែប្រួលនៅក្នុងការអភិវឌ្ឍន៍ផ្លូវភេទ គឺជារឿងមួយដែលក្មេងគ្រប់រូបត្រូវប្រឈមមុខកាន់តែពិបាកជាងទៀតសម្រាប់ក្មេងៗ ក្នុងអំឡុងឆ្នាំដំបូងៗ នៃការពេញរូបពេញរាង។ ដោយហេតុនេះ អ្នកអប់រំ និងឪពុក-ម្តាយត្រូវចាត់ទុករឿងភេទ ឬការសេពកាម (sexuality) ជាផ្នែកនៃតម្រេកតណ្ហា និងសេចក្តីត្រូវការរបស់មនុស្ស ដែលគេត្រូវតែតម្រែតម្រង់ឲ្យបានត្រឹមត្រូវ។

កាពចាំបាច់ ដើម្បីផ្តល់ពត៌មានត្រឹមត្រូវអំពីការវិវឌ្ឍន៍ ផ្លូវភេទដល់កុមារគឺមានសារសំខាន់យ៉ាងក្រៃលែង។ កុមារសព្វថ្ងៃកំពុងទទួលចំណេះដឹងអំពីរឿងភេទ តាមរយៈប្រពន្ធ័ផ្សព្វផ្សាយពត៌មាន (ជាញឹកញាយ ជាមួយរឿងប្រយុទ្ធបង្ហូរឈាម) តាមរយៈការអានសៀវភៅ, តាមរយៈបណ្តាញអ៊ីនធឺណែត (Internet) និងអំពីមិត្តភក្តិរបស់គេផងដែរ ហើយប្រសិនបើក្មេងៗទាំងនោះ មិនមានអ្នកជួយបង្រៀនឲ្យចេះវែកញែករវាងអ្វីដែលសមស្រប និងអ្វីដែលមិនសមស្របផងទេ ពួកគេមុខតែបញ្ចប់ត្រឹមការសម្តែងឬកពាត្តាំត្តង មិនខានឡើយ។ គ្មានឪពុកម្តាយណាចង់ឲ្យកូនៗរបស់ខ្លួន ទទួលយកពត៌មានស្តីពីការអភិវឌ្ឍន៍ផ្លូវភេទ អំពីក្រុម ឬបរិដ្ឋានអនាធិបតេយ្យឡើយ។

ឪពុកម្តាយ អាចចែករំលែកចំណេះដឹងនៃរឿងភេទទៅឲ្យកូន

*របស់ខ្លួន ប៉ុន្តែពត៌មានបែបនេះ ចាំបាច់ត្រូវតែបានកាត់កង តម្រឹម តម្រង់ទៅតាមកម្រិតយល់ដឹងរបស់ក្មេង ក្នុងករណីនេះវ័យខួរក្បាល ចិត្តាយុកាល* (the mental age) *ដែលអាចមិនសមស្របទៅនឹងលំដាប់វ័យ ឬវ័យប្បវត្តិ* (thechronogical age) *របស់ក្មេងៗ កុមារៗនៅចោត ល្ងង់ណាស់ ហើយពួកគេអាចងាយរងគ្រោះ ដោយសារការបំពារ បំពានផ្លូវភេទ ក្នុងកណ្តាប់ដៃពួកមនុស្សពេញវ័យឥតសេចក្តីអៀន ខ្មាសខ្វះសីលធម៌ៗ ក្មេងមិនទាំងដឹងថា ខ្លួនវាកំពុងត្រូវបានគេប្រើជាវត្ថុមួយសម្រាប់បំពេញចំណង់សេពកាមបញ្ឆោតទិសរបស់មនុស្សពេញវ័យផងទេៗ*

*វិស័យដ៏មានសារសំខាន់មួយ គឺសេចក្តីត្រូវការចាំបាច់ផ្តល់ពត៌មានឲ្យក្មេងៗដឹងអំពីអ្វីដែលកផ្តុំជា "ចំណុចប៉ះពាល់ត្រឹមត្រូវនិងចំណុចប៉ះពាល់មិនត្រឹមត្រូវ"ៗសារសំខាន់នៃការផ្តល់ឲ្យមានស្មារតីភ្ញាក់រឭកដល់កុមារ គឺជាបន្ទុករបស់ឪពុកម្តាយៗ ក្មេងចាំបាច់ត្រូវដឹងថាអ្នកណាត្រូវបានអនុញ្ញាតឲ្យប៉ះពាល់ឬស្ទាបអង្អែលខ្លួនប្រាណ ហើយនៅពេលណា និងនៅទីណានោះ អ្វីដែលវេជ្ជបណ្ឌិតអាចប៉ះពាល់ ឬស្ទាបកាន់បាន ស្ថានភាពទាំងឡាយដែលកុមារត្រូវចៀសវាង ហើយធ្វើយ៉ាងម៉េចដើម្បីបញ្ឈប់ការប្រព្រឹត្តិមិនត្រឹមត្រូវនៅក្នុងថ្នាក់រៀនៗ*

*ឪពុក-ម្តាយខ្លួនឯងផ្ទាល់ចាំបាច់ត្រូវដឹងថា ការប៉ះពាល់ស្ទាប*

អន្ត្ត្រលមិនត្រឹមត្រូវអាចកើតមានក្នុងចំណោមបងប្អូនសាច់ញាតិផង ដែរ។ ឧទាហរណ៍ តាមធម្មតា ឪពុក-ម្ដាយតែងប្រាប់កូនៗរបស់ខ្លួន ឲ្យប្រយ័ត្នចំពោះមនុស្សខាងក្រៅ (strangers) ប៉ុន្តែការសិក្សាបាន បង្ហាញថាក្នុងករណីរំលោភបំពានសេពកាមកុមារ ភាគច្រើននៃអ្នក រំលោភតាមភាពជាក់ស្តែង គឺជាមនុស្សដែលកុមារបានស្គាល់ ឬជា សមាជិកនៃគ្រួសារផ្ទាល់របស់កុមារ។

ចំពោះទំនាក់ទំនងជាមួយកុមារដទៃទៀតនៅក្នុងសង្គម កុមារ ទាំងឡាយ ត្រូវតែហ៊ាននិយាយប្រាប់ពត៌មានដោយស្មោះត្រង់ ដល់ ឪពុកម្ដាយរបស់ខ្លួន។ ប្រការនេះនឹងរួមបញ្ចូលភាពបើកចំហក្នុងការ ពិភាក្សាបញ្ហា ទាក់ទងជាមួយរឿងភេទផងដែរ។ ប្រសិនបើមានការ ប៉ះពាល់ខ្លួនប្រាណកន្លែងមិនសមរម្យ កុមារទាំងឡាយនោះ ត្រូវហ៊ាន និយាយប្រាប់ឪពុកម្ដាយខ្លួន អំពីរឿងនេះជាជំនួសសភាពដែលខ្លួន ខ្មាសអៀន ឬខ្លាចរអែង មិនហ៊ានបង្ហាញរឿងអាស្រូវឲ្យបានក្បោះ ក្បាយ។

ការអប់រំរឿងភេទមានសារសំខាន់ ពីព្រោះគេមិនអាចសង្ឃឹម អនីតិជនដើរតាមក្រឹត្យក្រមវិន័យដោយងងឹតងងុល ដោយមិនដឹងថា ព្រោះហេតុអ្វីពួកគេប្រតិបត្តិតាមក្រឹត្យវិន័យទាំងនោះទេ។ រឿងមួយ ក្នុងបណ្ដារឿងទាំងឡាយដែលពួកគេត្រូវបានគេអប់រំនោះ គឺព្រោះ ហេតុអ្វីពួកគេត្រូវតម ឬជៀសវាងការសេពកាមរហូតដល់ក្រោយ ពេលរៀបអាពាហ៍ពិពាហ៍រួច។ មនុស្សជាច្រើនជំទាស់នឹងការអប់រំ

រឿងភេទដល់កុមារ ពីព្រោះមនុស្សទាំងនោះយល់ថា“កាលណាអ្នកឯងនិយាយប្រាប់កុមារអំពីរឿងភេទនេះ ពួកគេនឹងចេញទៅក្រៅហើយបំពារបំពានផ្លូវភេទនេះ”។ វាជារឿងសំខាន់ដើម្បីកត់សម្គាល់ថានៅក្នុងប្រទេសស៊ុយអែត ការអប់រំរឿងភេទ ត្រូវបានគេបង្រៀននៅក្នុងសាលាមត្តេយ្យ ហើយប្រទេសនេះ មានចំនួនអនីតិជនមានផ្ទៃពោះតិចជាងគេបំផុតនៅក្នុងពិភពលោក។ អ្វីដែលវាមាន សារសំខាន់ជាអាយុជីវិតនោះគឺក្មេងៗត្រូវបានគេបង្រៀនឲ្យប្រកាន់ឥរិយាបថទទួលខុសត្រូវក្នុងការរួមសង្វាស តាំងពីពេលពួកគេត្រៀមខ្លួន សម្រាប់ទទួលសេចក្តីណែនាំបែបនេះ។ ការអប់រំអំពីរឿងរួមសង្វាសដ៏ល្អនឹងជួយសង្គ្រោះកុមារឲ្យផុតពីទោសកំហុស សេចក្តីភ័យខ្លាច វិប្ប-ដិសារី និងពៀរវេរាក្នុងកាលអនាគត។

(នៅមានត)

# ប្រវត្តិរបស់អដ្ឋកថា (ត)

*ដោយ* **អ៊ាន់ ចាន់សារ៉េន**

*នៅក្នុងអដ្ឋកថានេះ ព្រះពុទ្ធឃោសាចារ្យ បានពោលដល់ពាក្យថា មហាអដ្ឋកថា មហាបច្ចរី កុរុន្ទី និងថែមទាំងពោលថា ការរចនានូវអដ្ឋកថារបស់លោកគឺកាន់យកមហាអដ្ឋកថាជាធំក្នុងការរចនា និងមិនលះបង់នូវអដ្ឋកថាដែលព្រះថេរៈក្នុងសម្នាក់មហាវិហារបានពោលឡើង និងអដ្ឋកថាមហាបច្ចរី និងកុរុន្ទីដែលព្រះថេរៈជាលជ្ជីភិក្ខុពោលឡើងនោះដែរ។ នៅក្នុងសមន្តប្បាសាទិកា ក៏ពោលដល់អដ្ឋកថាមួយប្រភេទទៀត គឺអន្ធកដ្ឋកថាដែលរចនាជាភាសាតេលគូក្នុងដែនអន្ធកៈ ដែលព្រះពុទ្ធឃោសាចារ្យបានរៀនរួចហើយមុនមកកាន់ប្រទេសស្រីលង្កា តែលោកលើកយកមកដើម្បីបញ្ជាក់ដល់គម្ពីរអដ្ឋកថានោះមានការខុសក្លាំងក្លាត់ច្រើនណាស់ ខុសពីសម្នាក់មហាវិហារដែលជានិកាយថេរវាទវង្សព្រះមហិន្ទត្ថេរ។*

*នៅក្នុងគម្ពីរព្រះពុទ្ធសាសនា បានសម្ដែងពីការមករបស់អដ្ឋកថាដូចមានសាធកៈថា ៖*

**សីហឡដ្ឋកថា សុទ្ធា មហិន្ទេន មតិមតា**
**សង្គីតិត្តយមារុឡ្ហំ សម្មាសម្ពុទ្ធទេសិតំ**
**សារីបុត្តាទិគីតំ ច កថាមគ្គំ សមេក្ខិយ**
**កតា សីហឡភាសាយ សីហឡេសុ បវត្តតិ**

*ព្រះមហិន្ទត្ថេរជាអ្នកមានបញ្ញាបានប្រព័ន្ធអដ្ឋកថា*
*សីហឡៈដែលបរិសុទ្ធិដោយភាសាសីហឡៈបានរួបរួមព្រះ*
*តម្រាស់ព្រះសម្មាសម្ពុទ្ធដែលទ្រង់ត្រាស់សម្តែងនិងពុទ្ធម-*
*តញ្ញូមានព្រះសារីបុត្រជាដើមពោលទុក ដែលជាអដ្ឋកថា*
*បានធ្វើការសង្គាយនា បី ដង មានប្រាកដក្នុងលង្កាទ្វីប ។*

**ទីឃស្ស ទីឃសុត្តង្កិ- តស្ស និបុណ្ណស្ស អាគមវរស្ស**
**ពុទ្ធានុពុទ្ធសំវណ្ណិ- តស្ស សទ្ធាវហគុណស្ស**
**អត្ថប្បកាសនត្ថំ អដ្ឋកថា អាទិតោ វសីសតេហិ**
**បញ្ចហិ យា សង្គីតិ អនុសង្គីតា ច បច្ឆាបិ**

*ព្រះអរហន្ត ប្រាំរយអង្គបានសង្គាយនាគម្ពីរអដ្ឋកថាជាដំបូង*
*និងបន្ទាប់មកដើម្បីសម្តែងសេចក្តីទីឃនិកាយ ដែលប្រសើរ*
*ដ៏ជ្រៅទើបកំណត់សេចក្តីទុកដោយសូត្រខ្នាតវែង ដែលព្រះ*
*ពុទ្ធជាម្ចាស់និងព្រះសាវ័កអធិប្បាយទុក មានគុណតម្លៃក្នុង*
*កាលបណ្តុះសទ្ធាឲ្យកើតឡើង ។*

**សីហឡទីបំ បន អា- ភតាថ វសិនា មហាមហិន្ទេន**
**ឋបិតា សីហឡភាសាយ ទីបវាសីនមត្ថាយ ។**

*ខាងក្រោយមកព្រះមហិន្ទត្ថេរនាំគម្ពីរអដ្ឋកថានោះ មក*
*កោះសីហឡៈ ត មកបានរៀបរៀងជាភាសាសីហឡៈដើម្បី*
*ប្រយោជន៍ដល់ជនជាតិសីហឡៈទាំងឡាយ ។*

**អបនេត្វាន តតោហំ សីហឡភាសំ មនោរមំ ភាសំ**
**តន្តិនយានុច្ឆវិកំ អារោបេន្តោ វិគតទោសំ**
**សមយំ អវិលោមេន្តោ ថេរានំ ថេរវំសប្បទិបានំ**

**សុនិបុណត្ថវិនិច្ឆយានំ មហាវិហារេ និវាសិនំ**
**ហិត្វា បុនប្បុនាគត- មត្ថំ អត្ថំ បកាសយិស្សាមិ**

*ដូច្នោះខ្ញុំព្រះនាមពុទ្ធឃោសាចារ្យទើបប្រែភាសាសីហឡៈជាភាសាមគធៈដ៏ពីរោះ ត្រឹមត្រូវតាមគោលភាសា ប្រាសចាកទោសមិនឲ្យខុសចាកពីមតិរបស់ព្រះថេរៈ ក្នុងសម្នាក់មហាវិហារអ្នកមានវិនិច្ឆ័យដ៏ល្អិតល្អន់ ខ្ញុំនឹងកាត់សេចក្តីជាន់គ្នាដដែលៗ ចេញ ហើយសម្តែងសេចក្តី ដែលចាំបាច់ដើម្បីបាមោជ្ជៈដល់សាធុជន និងដើម្បីតាំងមាំយឺនយូរនៃព្រះសទ្ធម្ម ។*

*(សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ ១|១-២)*

**សម្មាសម្ពុទ្ធេនេវ ហិ តិណ្ណម្បិ បិដកានំ អត្ថសំវណ្ណនាក្កមោ ភាសិតោ, យា បកិណ្ណកទេសនាតិ វុច្ចតិ ឥ**

*មែនពិតព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះឯង ទ្រង់បានត្រាស់លំដាប់នៃការអធិប្បាយសេចក្តីក្នុងបិដកទាំង បី ដែលហៅថា* **បកិណ្ណកទេសនា** *។*

*(លីនត្ថប្បកាសិនី ដីកាទីឃនិកាយ ១|១៦)*

**បឋមសង្គីតិយំ យា អដ្ឋកថា សង្គីតាតិ វចនេន សាតគវតោ ធរមានកាលេបិ អដ្ឋកថា សំវិជ្ជតិ ឥ**

*គម្ពីរអដ្ឋកថានោះមានទៅស្ទួម្បីក្នុងកាលដែលព្រះដ៏មានព្រះភាគទ្រង់ព្រះធរមានទៅម្ល៉េះ ព្រោះពាក្យពេចន៍ (ក្នុងអដ្ឋកថា) ថាព្រះសង្គីតិកាចារ្យបានសង្គាយនាគម្ពីរអដ្ឋកថាណា ក្នុងបឋមសង្គាយនា... ។*

*(អនុដីកាអភិធម្ម ១|១៧)*

*នៅក្នុងអដ្ឋកថា សមន្តប្បាសាទិកា ១/៨៥ ខ្ញុំទងឯងបានពោលដល់រឿងព្រះមហិន្ទត្ថេរថា ៖*

**អថ មហិន្ទត្ថេរោ ឧបសម្បន្នកាលតោ បភុតិ អត្តនោ ឧបជ្ឈាយស្សេវ សន្តិកេ ធម្មញ្ច វិនយញ្ច បរិយាបុណន្តោ ទ្វេបិ សង្គីតិយោ អារុឡ្ហំ តិបិដកសង្គហិតំ សាដ្ឋកថំ សព្វំ ថេរវាទំ...។**

*គ្រានោះ ព្រះមហិន្ទត្ថេរចាប់តាំងពីឧបសម្បទាមកក៏បានរៀនយកនូវធម៌ និងព្រះវិន័យក្នុងសម្នាក់ព្រះឧបជ្ឈាយ៍របស់ខ្លួននោះឯង គឺបានរៀនយកនូវថេរវាទគឺព្រះត្រៃបិដកទាំងអស់ ព្រមទាំងអដ្ឋកថាដែលសង្គ្រោះដោយព្រះត្រៃ-បិដក ដែលបានឡើងកាន់សង្គាយនាសូម្បីពីរដងមកហើយ ។*

*នេះជាសាធកៈមួយ ដែលព្រះពុទ្ធឃោសាចារ្យ បានបញ្ជាក់ដល់អដ្ឋកថានេះថាសង្គ្រោះចូលជាព្រះត្រៃបិដក ហើយក៏បានបញ្ជាក់ដែរថាអដ្ឋកថានេះ បានឡើងកាន់សង្គាយនាមកពីរដងរួចហើយ គឺបឋមសង្គាយនាមានព្រះមហាកស្សបៈជាប្រធាន និងទុតិយសង្គាយនា មានព្រះយសកាកណ្ឌកបុត្តត្ថេរ និងព្រះសព្វកាមី ជាដើមបានធ្វើសង្គាយនាមកហើយ ពេលនេះព្រះមហិន្ទត្ថេរ ក៏បានរៀនយកនូវព្រះត្រៃបិដក និងអដ្ឋកថានេះហើយ ក្រោយមកក៏បាននាំព្រះត្រៃបិដក និងអដ្ឋកថាទាំងនេះចូលមកកាន់កោះលង្កាទ្វីប។*

*ការលើកយកគម្ពីរមកជាគ្រឿងអាងប៉ុណ្ណេះគ្រាន់បានបញ្ជាក់ថាគម្ពីរអដ្ឋកថានោះ មិនមែនជាការរចនារបស់បុគ្គលណាមួយឡើយ ឬជាការរចនារបស់ព្រះពុទ្ធឃោសាចារ្យដោយអត្តនោមតិនោះទេ។*

*ខ-សំដៅដល់* **មហាអដ្ឋកថា** *ឬ* **មូលអដ្ឋកថា** *ឬនិយមហៅថា* **សីហឡអដ្ឋកថា** *ដែលបានទទួលការប្រែទុកជាភាសាសីហឡៈ ជាខាង*

ក្រោយៗ អាចារ្យខ្លះមិនបានដឹងពិតប្រាកដនូវប្រភពនៃការមករបស់អដ្ឋកថា ក៏បានពោលជំទាស់នូវអដ្ឋកថា ថាជាការរចនារបស់បុគ្គលណាម្នាក់ ឬពោលថាជាអដ្ឋកថារបស់ព្រះពុទ្ធឃោសាចារ្យតែង ដោយអត្តនោមតិ ដោយជឿតាមពួកខាងអឺរ៉ុប ឬការពោលពីប្រវត្តិព្រះពុទ្ធឃោសាចារ្យរបស់ពួកមហាយាន ដែលបាននិយាយថាព្រះពុទ្ធឃោសាចារ្យនិកាយហីនយាន បានរចនានូវអដ្ឋកថាឡើងដោយការបញ្ចេញបញ្ចូលមតិរបស់ខ្លួនឯង... នោះជា អដ្ឋកថារបស់ព្រះពុទ្ធឃោសាចារ្យៗ

## ២-អភិនវអដ្ឋកថា

សំដៅដល់អដ្ឋកថាដែលព្រះពុទ្ធឃោសាចារ្យតែងទុក និងប្រែពី **មហាអដ្ឋកថា** និង **មូលអដ្ឋកថា** ដែលចារឹកទុកជាភាសាសីហឡៈ ។ អភិនវអដ្ឋកថា ចែកជាពីរភាសាគឺ ៖

### -មគធអដ្ឋកថា

គឺអដ្ឋកថាដែលតែងដោយ ភាសាមគធៈបានដល់៖

**ក**-អដ្ឋកថាដែលមានមកតាំងតែសម័យព្រះពុទ្ធអង្គទ្រង់ធរមាននៅ និងអដ្ឋកថាដែលព្រះមហាមហិន្ទត្ថេរនាំមកកាន់ប្រទេសស្រីលង្កាខាងក្រោយសង្គាយនាទីបី (វជិរពុទ្ធិដីកា, សារត្ថទីបនីដីកា សីលក្ខន្ធវគ្គដីកា)ៗ

**ខ**-អដ្ឋកថាដែលព្រះពុទ្ធឃោសាចារ្យ ព្រះពុទ្ធទត្តត្ថេរៈព្រះធម្មបាលត្ថេរៈ ព្រះឧបសេនត្ថេរៈ ព្រះមហានាមត្ថេរៈជាដើម ប្រែពីភាសាសីហឡៈទៅជាភាសា មគធៈម្តងមួយៗ (គម្ពីរមហាវំស) ៗ

**_សីហឡអដ្ឋកថា**

គឺអដ្ឋកថាភាសាសីហឡ:បានដល់៖

**ក_មូលអដ្ឋកថា** ដែលនាំមកអំពីជម្ពូទ្វីប ដោយព្រះមហាមហិន្ទត្ថេរ: ហើយព្រះមហាថេរ:ជនជាតិស្រីលង្កា បានប្រែទុកជាភាសាសីហឡ:ដើម្បីជៀសវាងពីការបន្ទំអំពីលទ្ធិកាយដទៃនិងដើម្បីសម្រួលដល់ការសិក្សារបស់ជនជាតិសីហឡ: (សុមង្គលវិលាសិនី)។

**ខ_មហាអដ្ឋកថា** សំដៅដល់អដ្ឋកថាចាស់ ដែលព្រះពុទ្ធឃោសាចារ្យ កាន់ជាគោលបែបក្នុងការតែង **អភិនវអដ្ឋកថា** ។

**គ_មហាបច្ចរីអដ្ឋកថា** គឺអដ្ឋកថារចនាបន្ថែមទៀត។

**ឃ_កុរុន្ទីអដ្ឋកថា** អដ្ឋកថារចនាត្រង់កុរុន្ទីវល្លិវិហារ។

**ង_អន្ធកអដ្ឋកថា** អដ្ឋកថាដែលរចនាដោយភាសាតេលគូ ក្នុងដែនអន្ធក:។

**ច_សង្ខេបអដ្ឋកថា** អដ្ឋកថាដែលសង្ខេបមហាបច្ចរីអដ្ឋកថា។

**ឆ_ចូឡបច្ចរីអដ្ឋកថា** គឺសង្ខេបអដ្ឋកថានោះឯង។

**ជ_អរិយអដ្ឋកថា** អដ្ឋកថាដែលរចនាដោយភាសាអរិយ:។

**ឈ_បន្ធរា:** អដ្ឋកថាដែលប្រមូលសេចក្តីវិនិច្ឆ័យអំពីមហាអដ្ឋកថា។

ក្នុងគម្ពីរអដ្ឋកថាទាំងនេះ ឈ្មោះគម្ពីរអដ្ឋកថាមហាបច្ចរី កុរុន្ទី អន្ធកៈ និងសង្ខេបៈ ជួបញយៗក្នុងអដ្ឋកថាសមន្តបាសាទិកា ដែលព្រះពុទ្ធឃោសាចារ្យតែងឡើង និងក្នុងដីកាព្រះវិន័យគឺ សារត្ថទីបនីដីកា វិមតិវិនោទនីដីកា តែគម្ពីរចូឡបច្ចរី អរិយៈ និង បន្ទភារៈ មានជួបតែក្នុងវជិរពុទ្ធិដីកាប៉ុណ្ណោះ (វជិរពុទ្ធិដីកា /២៤)។

ដែលពោលមកនេះត្រឹមតែសេចក្ដីសង្ខេប ដែលបោរាណាចារ្យលោកបានសម្ដែងទុកក្នុងគម្ពីរផ្សេងៗ ដែលល្មមនាំមកនូវប្រយោជន៍ក្នុងការស្រាវជ្រាវតាមសមគួរដល់អ្នកសិក្សាបានខ្លះ។

លំដាប់អំពីនេះតទៅ នឹងពោលចំពោះការមកដល់អដ្ឋកថាដែលមានប្រាកដក្នុងសម័យបច្ចុប្បន្នកាលនេះ។ សូម្បីដឹងហើយពីប្រភពមករបស់អដ្ឋកថានោះក៏ដោយចុះ តែក៏សូមពោលទុកដើម្បីជាមូលដ្ឋានក្នុងការសិក្សាប្រៀបធៀបតទៅ ៖

(នៅមានត)

# គោលការណ៍ ប្រាំ គួរ

ដោយ : ព្រឹទ្ធាចារ្យ ឆេង ផុន

១- ទស្សនៈ គួរ មាន

២- បញ្ហា គួរ ស្គាល់

៣- វិធី គួរ មាន

៤- ផ្លូវ គួរ ដើរ

៥- ផល គួរ ទទួលបាន

**I- ទស្សនៈគួរមានៈ**

- *រកខ្លួនឯងឲ្យឃើញ*
- *ស្គាល់ខ្លួនឯងឲ្យច្បាស់*
- *មានខ្លួនឯងជាទីពឹង*
- *រកព្រះឲ្យឃើញ ទើបមានព្រះជាទីពឹង*
- *ព្រះនៅក្នុងខ្លួន ប្រសើរជាងព្រះនៅក្រៅខ្លួន*
- *ព្រះជួយបុគ្គលណា ដែលចេះជួយខ្លួនឯងតែប៉ុណ្ណោះ*
- *ស្វែងយល់ខ្លួនឯងឲ្យបានច្រើន ទើបលើកលែងទោសអ្នកដទៃបានល្អ។*
- *បញ្ញាខន្ធ ជាផ្ទះសម្នាក់ គ្រាន់តែស្នាក់នៅជាបណ្ដោះអាសន្ន មិនមានគំនិតហួងហែងតុបតែងជួសជុលអ្វីទេ ព្រោះបម្រុងនឹងដើរចោល*

- ជីវិត គឺជាការធ្វើដំណើរដោយផ្លាស់ប្តូរវិថី និងយានយន្ត ប្លែកៗគ្នាប៉ុណ្ណោះ
- អ្វីនៅលើលោកនេះ បីដូចជារបស់បញ្ឆោតទាំងអស់ កើតលេត់ៗ  ឃើញបាត់ៗ(មាយា)។

**-ជីវិតគឺជាការ :**

- ឈ្លោះគ្នាផង ត្រូវគ្នាផង
- សម្លាប់គ្នាផង បង្កើតគ្នាផង
- ស៊ីគ្នាផង ចិញ្ចឹមគ្នាផង
- ជួយគ្នាផង បំផ្លាញគ្នាផង
- កេងប្រវ័ញ្ចគ្នាផង អាជីវកម្មគ្នាផង
- ជេរសេរសើរ បន្ទោស លួងលោម បោកបញ្ឆោត ប្រើប្រាស់គ្នាជាវដ្ដ:។

**វដ្ដ: គឺ ជាអ្វីទាំងអស់ៗគឺជាវដ្ដ:**

- វដ្ដ: ជាផ្លូវដ៏វែងឆ្ងាយ មានឧបសគ្គច្រើនអនេក
- វដ្ដ: មិនដឹងការចាប់ផ្ដើម និងទីបញ្ចប់ឡើយ
- វដ្ដ: គឺល្អ និងអាក្រក់ វដ្ដ: គឺត្រូវនិងខុស
- វដ្ដ: គឺពេញចិត្ត និងមិនពេញចិត្ត
- វដ្ដ: គឺស្រឡាញ់ ស្អប់ ភ័យ ខ្លាច
- វដ្ដ: គឺ ឈឺ ជា និង សុខ ទុក្ខ ។

**II - បញ្ហាគួរយល់ :**

- *កាពសៅហ្មងនៃចិត្ត(តណ្ហា ១០៨ កិលេស ១៥០០) ។*

**អកុសលធម៌ ៩កង :**

*១- អាសវៈ៤ (គ្រឿងត្រាំក្នុងខន្ធ សន្តាន)*

*២- ឱឃៈ ៤ (ដូចអន្លង់ទឹកគួច-សត្វលង់ក្នុងវដ្ដៈ)*

*៣- យោគៈ ៤ (គ្រឿងប្រកបសត្វទុកជាប់ក្នុងវដ្ដៈ)*

*៤- គន្ថៈ ៤ (គ្រឿងជោតក្រងសត្វទុកក្នុងវដ្ដៈ)*

*៥- ឧបាទាន ៤ ( គ្រឿងប្រកាន់មាំ មិនរបេះ)*

*៦- នីវរណៈ ៦ (គ្រឿងរាំងរាំងកចិត្តមិនឲ្យទៅកាន់សេចក្ដីល្អ សេចក្ដី ស្ងប់)*

*៧- អនុសយ ៧ ( កិលេសល្អិត ដេកសម្ងំត្រាំ ក្នុងខន្ធ សន្ដាន)*

*៨- សំយោជនៈ ១០ (គ្រឿងរួបរឹត សត្វទុកក្នុងវដ្ដៈ)*

*៩- កិលេស ១០ (គ្រឿងសៅហ្មងចិត្ត)*

**មន្ទិល ៩ យ៉ាង** : *(មៈលៈ -មន្ទិលឬសង្ស័យ ៩ យ៉ាង)*

*១- កោធៈ = ក្រោធ ខឹង ព្រោះមន្ទិល-មន្ទិលធ្វើឲ្យខឹង មានកម្លាំង។*

*២- មក្ខៈ =មើលគុណ ព្រោះមន្ទិល- មន្ទិលធ្វើមើល គុណមានកម្លាំង។*

*៣-ឥស្សា = ឫស្យា-ប្រណែន ព្រោះមន្ទិល- មន្ទិលធ្វើឲ្យ*

ប្រណែនមានកម្លាំង

៤-មច្ឆរិយៈ= កំណាញ់ ព្រោះមន្ទិល - មន្ទិលធ្វើឲ្យ កំណាញ់ មានកម្លាំង

៤- មាយា= លាក់ទុកព្រោះមន្ទិល-មន្ទិលធ្វើឲ្យលាក់ពុត មានកម្លាំង

៦- សាថេយ្យ = ពោលអួត ព្រោះមន្ទិល - មន្ទិលធ្វើឲ្យ ពោលអួត មានកម្លាំង

៧- មុសា = កុហក ព្រោះមន្ទិល - មន្ទិលធ្វើឲ្យកុហក មានកម្លាំង

៨- បាបិច្ចៈ = ប្រាថ្នាអាក្រក់ព្រោះមន្ទិល - មន្ទិលធ្វើឲ្យ ប្រាថ្នាអាក្រក់មានកម្លាំង

៩-មិច្ឆាទិដ្ឋិៈ = ឃើញខុស ព្រោះមន្ទិល - មន្ទិលធ្វើឲ្យ ឃើញខុសមានកម្លាំង

**អាភោគៈ ៩ (ការមិនខឹង ៩ យ៉ាង )**

១- សេចក្តីខឹងក្រោធ ធ្វើឲ្យខូចសម្រស់

២-ខឹងធ្វើឲ្យរំខាន សេចក្តីស្ងប់ស្ងាត់ ស្ងប់កាយ ស្ងប់វាចា ស្ងប់ចិត្ត (បេះដូង លែងជម្មតា)

៣- ខឹងជាប្រធាននៃសេចក្តីវិនាស

៤- ខឹងជាលក្ខណៈពាល ជាលក្ខណៈបុគ្គល (កាន់តែ បុគ្គល កាន់តែ ខឹងច្រើន កាន់តែពាលខ្លាំង )

៥- គ្មានភ្លើងណា ក្តៅស្មើនឹងភ្លើងទោសៈឡើយ
៦- គ្មានទារុណកម្មណា ស្មើនឹងទារុណកម្មទោសៈឡើយ
៧- គ្មានវេទនាណាស្មើនឹងវេទនាទោសៈឡើយ
៨- ពេលខឹងខ្លាំងគ្មានស្គាល់ហេតុផលឡើយ ធ្វើឲ្យទុក្ខផ្លូវចិត្តកាន់តែមានកម្លាំង
៩- កំហឹងធ្វើឲ្យលោកខ្លួនឯង មុនអ្នកដទៃ ។

**ឧបកិលេស ១៦ :** (ឬការលះនូវឧបកិលេស ១៦ យ៉ាង )

១- លះគំនិតដែលគិតតែពីចង់បាន
២- លះគំនិតដែលគិតតែពីចង់ព្យាបាទ
៣- លះគំនិតដែលគិតតែពីចង់ប្រទូសរ៉ាយនឹងគេ
៤- លះគំនិតដែលចងគំនុំ នឹងគេ
៥- លះគំនិតរមើលគុណគេ មួលបង្កាច់អំពើល្អរបស់គេ
៦- លះគំនិតលើកកម្ពស់ខ្លួនឯង
៧- លះប្រណែនទិន្នាឈ្នានីសគេ
៨- លះកំណាញ់ដែលគិតតែពីអាត្មាខ្លួន
៩- លះល្បិចកិច្ចកលមាយាលាក់ពុត
១០- លះការអួតអាង
១១- លះចចេសរឹងរូស
១២- លះចង់តែឈ្នះ ឥតគិតហេតុផល រហូតដល់បំផ្លាញដើម្បីឈ្នះ

១៣- លះប្រកាន់ខ្លួន

១៤- លះថាមានតែខ្លួនឯងខ្លាំងជាងគេ

១៥- លះស្រវឹងស្រីស្រា ល្បែងស៊ីសង

- ស្រវឹងយសសក្តិ បុណ្យអំណាច

- ស្រវឹងពាក្យពោលសរសើរ បញ្ចើច

- ស្រវឹងលាភសក្ការៈ

- ស្រវឹងសុខ ក្នុងទុក្ខ

១៦- លះប្រមាថ ប្រហែស ខ្ជិល ។

**ស្រទីទ ៤០ :**

១- ស្រវឹងលោកធម៌ គឺស្រវឹងថ្នាំពុល

២- សប្បាយលោកធម៌ គឺសប្បាយនឹងអសិរពិស

៣- ប្រលែងលោកធម៌ គឺប្រលែងនឹងភ្លើង

៤- ចាញ់បោកលោកធម៌ គឺចាញ់បោកសត្រូវ

៥- ស្រវឹងនឹងបានលាភ ប្រទូស្តនឹងបាត់លាភ

៦- ស្រវឹងនឹងកិត្តិយស ប្រទូស្តនឹងបាត់យស

៧- ស្រវឹងនឹងពាក្យសរសើរ ខ្លាចពាក្យនិន្ទា

៨- ស្រវឹងនឹងសុខ ព្រួយនឹងទុក្ខ

៩- ស្រវឹងនឹងកេរ្តិ៍ឈ្មោះ

១០- ស្រវឹងនឹងបរិវារយស (ឥស្សរយស)

១១- ស្រវឹងនឹងហែរហម

១២- ស្រើនទីនវណ្ណៈ (ហ៊ានៈ)

១៣- ស្រើនទីនសក្ការៈ (ការគោរព)

១៤- ស្រើនទីនអាយុវែង

១៥- ស្រើនទីនគុរការ (ការបូជាគ្រូ)

១៦- ស្រើនទីនបានធ្វើប្រធាន-បានធ្វើប្រមុខ-បាននាំគេ និងបានគេតាមច្រើន

១៧- ស្រើនទីនទ្រព្យ

១៨- ស្រើនទីនពហុសូត្រ (រៀនសូត្រច្រើន)

១៩- ស្រើនទីនការឈ្លាសវៃ (វាងវៃ)

២០- ស្រើនទីនបានបួសមុនគេ

២១- ស្រើនទីនគ្មានគេមើលងាយ (គ្មានគេប្រមាថ)

២២- ស្រើនទីនបិណ្ឌបាតជាវត្តៈ (បានបិណ្ឌបាតរាល់ថ្ងៃ)

២៣- ស្រើនទីនមានឥរិយាបថបួនសមរម្យ

២៤- ស្រើនទីនឫទ្ធិ (បានអភិញ្ញា )

២៥- ស្រើនទីនជោគជ័យ (ជ័យជំនះ)

២៦- ស្រើនទីនបដិសណ្ឋារកិច្ច

២៧- ស្រើនទីនអញ (អាត្មា)

២៨- ស្រើនទីនរូបស្អាត

២៩- ស្រើនទីនវណ្ណៈថ្លើងថ្កាន (ខ្ពង់ខ្ពស់ កិត្តិយសច្រើន រុងរឿង )

៣០- ស្រវឹងនឹងកម្លាំងខ្លាំង

៣១- ស្រវឹងនឹង អត់ធ្មត់

៣២- ស្រវឹងនឹងស្តាប់

៣៣- ស្រវឹងនឹងមើល

៣៤- ស្រវឹងនឹងស្ទាប

៣៥- ស្រវឹងនឹងល្បែង

៣៦- ស្រវឹងនឹងភាពប្លែក (និយមចម្លែក)

៣៧- ស្រវឹងនឹងសប្បាយ រីករាយ ត្រេកត្រអាល

៣៨- ស្រវឹងនឹងព្រួយ ទុក្ខសោក វិវេក

៣៩- ស្រវឹងនឹងរស់

៤០- ស្រវឹងនឹងស្លាប់ ។

III- **វិធីគួរមាន :**

**ធម៌គួរដល់ការប្រតិបត្តិ ១១ យ៉ាង :**

១- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ប្រាសចាកតម្រេកផុយនឹងធម៌ ដែលបង្កើតតម្រេក

២- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ទុក្ខ ផុយនឹងធម៌ ដែលប្រកបដោយទុក្ខ

៣- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ធ្វើឲ្យកិត្តិយសស្តើង ផុយនឹងធម៌សន្សំកិត្តិយស

៤- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ប្រាថ្នាតិច ផុយនឹងធម៌

ដែលប្រាថ្នាធំ

៥- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី សណ្ដោសចំពោះវត្ថុកាមតាមមានតាមបានផុយនឹងធម៌ ដែលមិនសណ្ដោសតាមមាន តាមបាន

៦- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ស្ងាត់ចាកពួកគណៈផុយនឹងធម៌ ដែលច្រឡូកច្រឡំពួកគណៈ

៧- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី សេចក្ដីព្យាយាម ផុយនឹងធម៌ ដែលនាំឲ្យកើតសេចក្ដីខ្ជិលច្រអូស

៨- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ចិញ្ចឹមជីវិតងាយ ផុយនឹងធម៌ ដើម្បីចិញ្ចឹមជីវិតក្រ

៩- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី នឿយណាយ ផុយនឹងធម៌ ដែលប្រព្រឹត្តទៅដើម្បីត្រៀនត្រាម

១០- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី លះបង់ ផុយនឹងធម៌ ដែលជំពាក់

១១- ធម៌ណាដែលប្រព្រឹត្តទៅដើម្បី ត្រាស់ដឹង ផុយនឹងធម៌ ដែលនាំឲ្យវង្វេងវង្វក់ ។

**រៀបរូបឱ្យរួច : ៦ ចំណុច**

១- រួចផុតពីទាសករនៃជីវិត

- រួចផុតពីកញ្ចះកាមគុណ ពីកញ្ចះតណ្ហា
- រួចផុតពីគំនាបសង្គម

២- រូបផុតពីទាសភាពសង្គម (គឺរស់មិនមានទោសដល់ខ្លួនឯង ដល់អ្នកដទៃ ដល់សង្គម )

៣- រួចពីសំណាញ់លោកធម៌ (រួចផុតពីប្រកាន់អគតិ )

៤- លោសបោលទូវការយល់ខុសទាំងឡាយ រស់នៅធូរស្រាល មិនមានអ្វីជាប់ជំពាក់ មិនមានអ្វីធ្វើជាទម្ងន់ យល់ច្បាស់ពីច្បាប់ធម្មជាតិ

៥- សតិជាអ្នកបើកបរដ៏ចំណានបំផុត ជាការលើកត្រូវជាប្រចាំសម្បជញ្ញៈជាការឃើញត្រូវធ្វើឲ្យខុសរត់បាត់អស់

៦- ជីវិតកើតពីល្អង់ ខំប្រឹងណាស់ទើបរស់ត្រូវ ។

**រស់ត្រូវគឺ :**

- យល់មិនឲ្យខុស
- គិតមិនឲ្យខុស
- និយាយមិនឲ្យខុស
- ធ្វើមិនឲ្យខុស
- ចិញ្ចឹមជីវិតមិនឲ្យខុស
- ព្យាយាមមិនឲ្យខុស
- រលឹកមិនឲ្យខុស
- តម្កល់ចិត្តមិនឲ្យខុស ។

**កែវឧម្លាប់ : ៤ ចំណុច**

*១-ទម្លាប់ធ្វើទាន :*

*- ជាទម្លាប់គិតគ្នាទៅវិញទៅមក*

*- ជាទម្លាប់ធ្វើឲ្យមនុស្សដឹងគុណគ្នាទៅវិញទៅមក*

*- ជាទម្លាប់ធ្វើឲ្យមនុស្សស្មោះត្រង់នឹងគ្នាទៅវិញទៅមក*

*- បន្ថយភាពជាសត្រូវ*

*- បន្ថយភាពអត្តទត្តបុគ្គលរវាងគ្នានឹងគ្នា ។*

*២-ទម្លាប់មានសីល :(រក្សាសីលវិន័យ)*

*- ធ្វើឲ្យចេះគោរពខ្លួនឯង នឹងចេះគោរពអ្នកដទៃ*

*- ធ្វើឲ្យគេទុកចិត្ត នឹងមានជំនឿ*

*- ធ្វើឲ្យមានសណ្តាប់ធ្នាប់ខាងក្នុង និងខាងក្រៅ*

*- វិន័យនាំឲ្យសម្រេចការងារធំៗបាន ។*

*៣-ស្មារតីពលី ទម្លាប់ពលី :*

*- អ្នកហ៊ានហាត់ ទើបហូបហាល់*

*- អ្នកហ៊ានខុស ទើបក្លីស្វាង*

*- អ្នកហ៊ានបាត់ ទើបបានបាន ។*

*៤-ជីវិតលោកីយ៍ ជាការប្រយុទ្ធអចិន្ត្រៃយ៍ :*

*- រវាងល្អ និងអាក្រក់*

*- រវាងបុណ្យ និងបាប*

*- រវាងកុសល និងអកុសល*

- ផ្ដើមចូលជាអកុសលចិត្ត ផ្ដើមចេញជាអកុសលកម្ម
- ជីវិតលោកីយ៍ ជាបន្ទប់ពិសោធន៍ (ជំងឺកាន់តែកាច ថ្នាំកាន់តែពូកែ )
- ជីវិតលោកីយ៍ ជាការលះហើយទៅ ទៅហើយលះ(គ្មានអ្វីនៅទីផង គ្មានជារបស់ខ្លួន គ្មានអ្វីជាខ្លួនឡើយ )

**ខន្តី និងវីរិយៈ : ១៩ ចំណុច**

១- ខន្តីលះទីងក្រោធ លះទោសៈ
២- ខន្តីជាធម៌ស្ងប់(ចូលខន្តី ចូលសមាធិ )
៣- ខន្តីនាំឲ្យសម្រេចធម៌ឯទៀតៗ
៤- ខន្តីជាទីពឹងឯងខ្លួន
៥- ខន្តីបារមី ឈ្នះរាល់អកុសល
៦- ខន្តីឈ្នះរាល់ការលំបាក
៧- ខន្តីជាកម្លាំង
៨- ខន្តីជាពល
៩- ខន្តីឈ្នះភាពតានតឹង
១០- ខន្តីឈ្នះភាពចង្អៀតចង្អល់
១១- ខន្តីឈ្នះភាពក្ដៅ ត្រជាក់
១២- ខន្តីឈ្នះភាពស្រេកឃ្លាន
១៣- អ្នកធំជេរអាចទ្រាំបាន ព្រោះខ្លាចគេ
១៤- អ្នកតូចជេរ   លំបាកទ្រាំណាស់ ព្រោះបុគ្គលក្រាស់

អញក្រាស់

១៥- ខឹងទឹងអ្នកធ្វើខុស ទោសៈ អាណិតអ្នកធ្វើត្រូវ លោភៈ

១៦- អកុសលអ្នកដទៃ អូសទាញយកកុសលខ្លួនបាត់

១៧- ពេលខឹងខ្លាំង ក្ដៅខ្លាំង ទឹងដល់កើតនរក

១៨- ពេលឃ្លានខ្លាំង លោភខ្លាំង នឹកដល់ប្រេតឃ្លាន

១៩- ពេលស្រវឹងខ្លាំង វង្វេងខ្លាំង បាត់សតិ នឹកដល់តិរច្ឆាន ។

**ចម្រើន : ១៣ ចំណុច**

១- ចម្រើនវិជ្ជា សម្រាប់លះអវិជ្ជា

២- ចម្រើនបញ្ញា លះល្ងង់

៣- ចម្រើនសតិ លះវង្វេង

៤- ចម្រើនដឹង លះមិនដឹង

៥- ចម្រើនកុសល លះអកុសល

៦- ចម្រើនត្រូវ លះខុស

៧- ចម្រើនគុណ លះទោស

៨- ចម្រើនបុណ្យ លះបាប

៩- ចម្រើនល្អ លះបង់អាក្រក់

១០- ចម្រើនមេត្តា លះខឹង

១១- ចម្រើនវិមុត្តិ លះទុក្ខ

១២- ចម្រើនមុទិតា លះច្រណែន

១៣- ចម្រើនឧបេក្ខា លះប្រកាន់ ។

ត្រូវឱ្យប្រាប់ គឺ កែចរិត គឺ កែធម្មជាតិ ត្រូវតែកែឱ្យប្រាប់

រស់នៅបរិសុទ្ធស្អាតត្រង់:

- រស់នៅពោរពេញដោយមេត្តា(plein d'amour universel)
- រស់នៅពោរពេញដោយករុណា(plein de compassion)
- រស់នៅពោរពេញដោយអំពើល្អ (plein de bonté )
- រស់នៅពោរពេញដោយការរាប់អាន (plein de sympathie)
- រស់នៅពោរពេញដោយការយោគយល់ (plein de compréhension)
- រស់នៅពោរពេញដោយចិត្តសណ្ដាស(plein de tolérance)
- ប្ដូរពីពហុចិត្តច្រើន មកនៅយ៉ាងណាយ៉ាងហ្នឹង
- ប្ដូរពីប្រកាន់ច្រើន មកលះបង់ច្រើន
- ប្ដូរពីមួរម៉ៅ មករីករាយ
- ប្ដូរពីអំនួត មកធម្មតា
- ប្ដូរពីស្មុគស្មាញ មកធូរស្រាល
- ប្ដូរពីល្ងង់ មកមានបញ្ញា
- ប្ដូរពីជោរជូរ មកធម្មតា
- ប្ដូរពី ចង្អៀតចង្អល់ មកធំទូលាយ ។

-ផ្លូវគួរដើរ : មជ្ឈិមប្បដិបទា ៨

១- សម្មាទិដ្ឋិ

- *យល់ត្រូវតាមអរិយសច្ច ៤ ត្រៃលក្ខណ៍ បដិច្ចសមុប្បាទ យល់នូវធម៌ជាកុសល និងអកុសល ការយល់ឃើញក្នុងបន្ទោះទិដ្ឋិទាំង២ (សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ) គឺយល់ថា ការស្លាប់និងកើតមានទំនាក់ទំនងនឹងគ្នា ។*

២-សម្មាសង្កប្បៈ

- *ត្រិះរិះនូវកុសលវិតក្កៈ ៣(នេក្ខម្មៈ-អព្យាបាទ-អវិហិង្សា)។*

៣-សម្មាវាចា

- *វចីសុចរិត ៤ គឺវាចាដែលផុយអំពី មុសា - បិសុណាផរុសៈ-សម្ផប្បលាបៈ ។*

៤-សម្មាកម្មន្តៈ

- *ការងារដែលប្រកបដោយសុចរិត ៣ (កាយសុចរិត ៤ ដែលផុយពីបាណា-អទិន្នា-កាមេសុមិច្ឆាចារ-វចីសុចរិត ៤ ដែលផុយពីមុសា-បិសុណា-ផរុសៈ-សម្ផប្បលាបៈ-មនោសុចរិត ៣ ដែលអនភិជ្ឈា-អព្យាបាទ-សម្មាទិដ្ឋិ) ។ ម្យ៉ាងទៀតគឺឥទ្ធិបាទ៤ (ឆន្ទ-វិរិយៈ-ចិត្ត-វិមង្សា) ។*

៥-សម្មាអាជីវៈ

- *សម្មាជីវធម៌ ៤ (សមសទ្ធា-សមសីលា-សមចាគា-សមបញ្ញា ) ។*

**៦_សម្មាវាយាមៈ**

- បធានគឺព្យាយាម ៤ (សំវរៈ-បហានៈ-ភាវនា-អនុរក្ខនា)។

**៧_សម្មាសតិ**

សតិប្បដ្ឋាន ៤ (កាយានុបស្សនា គឺសតិកំណត់នូវអនាបានស្សតិ ១ ឥរិយាបថ ១ សម្បជញ្ញៈ គឺដឹងនូវចលនាកាយ និងចិត្ត ១ បដិកូលមានសិការៈ ១ ធាតុមនសិការៈ ១ នវសីវថិកា គឺការពិចារណាសាកសពមានភាពនានា ហើយខុសគ្នាក្នុងរយៈពេលប្រាំបួន ១ វេទនានុបស្សនា គឺសតិកំណត់នូវវេទនាថា គ្រាន់តែជាសុខ-ទុក្ខ-ឧបេក្ខា ចិត្តានុបស្សនា គឺការកំណត់នូវចិត្តថា មានរាគៈឥតមានរាគៈមានទោសៈ-ឥតមានទោសៈ-ចិត្តអណ្តែត ឬជាសមាធិធម្មានុបស្សនា គឺសតិកំណត់ដឹងនូវការប្រព្រឹត្តទៅនៃធម៌ទាំងឡាយ គឺនីវរណៈ ៥, ខន្ធ៥, អាយតនៈ ១២ ពោជ្ឈង្គៈ ៧ អរិសច្ច៤)។

**៨_សម្មាសមាធិ**

- ឈាន ៤(បឋមជ្ឈាន វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ទុតិយជ្ឈាន បីតិ សុខៈ ឯកគ្គតា តតិយជ្ឈាន សុខៈ ឯកគ្គតា តតិយជ្ឈាន សុខៈ ឯកគ្គតា បតុត្ថជ្ឈាន ឧបេក្ខា ឯកគ្គតា ) ។

**_ផលដែលគួរទទួលបាន :**

-ចិត្តដែលបានអប់រំហើយ រមែងតែមានសេចក្តីស្ងប់ ចាក-នីវរណៈកិលេស ។

-ចិត្តស្ងប់ត្រជាក់នឹងហ្នឹ មិនចាប់ខឹង ចៅចៅ ។

-សតិរឹងមាំ ប្រាជ្ញាជ្រះថ្លា មិនងាយភ្លេច មិនងាយវង្វេង ធាប់បានត្រាស់ដឹង អរិយសច្ច ។

-រស់ប្រកបដោយសច្ចធម៌ និងមេត្តាធម៌ជានិច្ច ។

**មេត្តាធម៌**

**ក_អវិជ្ជា :**

-មនុស្សកើតពីអវិជ្ជា រស់ក្នុងអវិជ្ជា ធំធាត់ដោយអវិជ្ជា គេចមិនផុតពីប្រឡាក់អវិជ្ជាទេ នេះជាសច្ចៈ

-មនុស្សឥតល្ងង់បញ្ញាគ្រប់ជប់ មិនចេះខុស ឥតមានទេ នេះជាសច្ចៈ

-កម្មជាអ្នកចាត់ចែងជីវិត កម្មខុសៗគ្នាវិបាករបស់កម្ម ក៏ខុសៗគ្នាដែរ

-បំណងចង់ឲ្យគេដូចយើង ជាអសច្ចៈ

-កិលេស (ល្ងង់) ជាអ្នកញុះញង់ ឲ្យមនុស្សឈ្លោះគ្នាសម្លាប់គ្នា

-កិលេសជាអ្នកនាំឲ្យមនុស្សប្រកាន់វណ្ណៈ ប្រកាន់ឋានៈ

-កិលេសជាអ្នកនាំឲ្យមនុស្សមើលងាយមនុស្ស ប្រមាថមនុស្សទៅវិញទៅមក

-កិលេស (ល្ងង់) ជាមេអសច្ចៈ ។

**ខ_មេត្តាធម៌ :** ជាមូលដ្ឋាននៃសច្ចធម៌

-មេត្តាធម៌ជួយរំដោះបុគ្គល ឲ្យរួចផុតពីពហុចិត្តទាំងឡាយ

(Complexe )

-មេត្តាធម៌ជួយរំដោះបុគ្គល ឲ្យរួចផុតពីបញ្ហាពីការលំបាកពីកង្វល់(Problème,Difficulté tracas)

- មេត្តាធម៌ជួយរំដោះបុគ្គល ឲ្យរួចផុតពីការប្រកាន់ទាំងឡាយ (Obsession)

-មេត្តាធម៌ជួយរំដោះបុគ្គល ឲ្យរួចផុតពីចំណង់ប្រាថ្នាបុគ្គល (Dèsir égoiste)

-មេត្តាធម៌ជួយរំដោះបុគ្គល ឲ្យរួចផុតពីអំនួត និងភាពធ្មើងឆ្មៃ (Vanité et Orgueil)

-មេត្តាធម៌ជួយរំដោះបុគ្គល ឲ្យរួចផុតពីឧបសគ្គទាំងឡាយ (Empêchement)

-មេត្តាធម៌ជួយឲ្យបុគ្គលរស់នៅ សប្បាយរីករាយ ធូរស្រាល សុខ ស្ងប់ សន្តិភាព បរិសុទ្ធ (Joyeux , Jouissant, Satisfait ,Calme ,paisible, Serein et Pur)

-មេត្តាធម៌ជួយឲ្យបុគ្គលរស់នៅ ពោរពេញទៅដោយចិត្តអធ្យាស្រ័យ និងសណ្តាសប្រណី (Viver plein depardon et de tolérance) នេះជាសុខភាពផ្លូវចិត្តដ៏សុក្រិតបំផុត (Une Santé mentale parfaite) ។

---

-មានអត្តា មានអញ មានឯង គឺមានទុក្ខ ។

-ចង់ឈ្នះអញ ចង់ឈ្នះឯង

-ឯងគ្រាន់ជាងអញ អញគ្រាន់ជាងឯង

-អញល្អជាង អញប្រសើរជាង

-អញខ្លាំងជាង អញធំជាង អញល្បីជាង អញមានជាង ក៏សុទ្ធជាទុក្ខដែរ

-ប្រកួតប្រណាំងគ្នាគ្មានទីបញ្ចប់ ក៏ជាទុក្ខដែរ

-ប្រឡងប្រជែងយកចាញ់ឈ្នះ រហូតដល់សម្លាប់គ្នា (ចាញ់ក៏ស្លាប់ ឈ្នះក៏ស្លាប់ ស្លាប់ក៏ជាសច្ចៈ ហាមស្លាប់មិនបាន ព្រោះអសច្ចៈ)

-កុំសោកស្ដាយអតីតកាលពេក ក៏ពុំគួរព្រួយនឹងអនាគតកាលពេករស់នៅបច្ចុប្បន្ននិយម ប្រាកដនិយម ធូរៗស្រាលៗ ស្មើៗ រីករាយ សប្បាយគ្រប់គ្រាន់បរិសុទ្ធ ភ្លឺថ្លា ចេះព្រម ចេះល្មម ប្រាសចាកអគតិធម៌ទាំង ៤ (មោហាគតិ-ឆន្ទាគតិ-ភយាគតិ-ទោសោគតិ )

-រស់នៅនឹងន មិនញាប់ញ័រ មិនស្ទន់ស្ទោ និងលោកធម៌នេះជាសភាពផ្លូវចិត្តសុក្រិតបំផុត ។

# ពុទ្ធសាសនា និង បញ្ហាអប់រំ

Le Religion Bouddhique Et Le Problème De L'éducation

*ដោយបណ្ឌិត* **ឆយ យីហាង**

## សេចក្តីផ្តើម

*ព្រះពុទ្ធ* (bouddha) *ដែលមានព្រះនាមដើមថា* **សិទ្ធាថ៌គោតម** (Siddhartha Gautama) *ឬ សក្យមុនី* (Çakyamouni) *ដែលមានន័យថា វិញ្ញូនៃកុលសម្ព័ន្ធសក្យ* (sage du clan des Çakyas) *ប្រសូតនៅពាក់កណ្តាលសតវត្សទី៦ មុនគ្រិស្តសករាជ នៅក្រុង កបិលពស្តុ* (kapilavastu) *នៅខាងជើងភ្នំ ហិមាល័យ* (Bénarès)*។ ក្សត្រអង្គនេះពោរពេញទៅដោយព្រះបញ្ញាវាងវៃ។ នៅក្នុងយុវកាលប្រកបដោយភាពប្រណីត និងសេចក្តីរីករាយ ព្រះអង្គទ្រង់រៀបអភិសេកជាមួយព្រះនាង* **យសោធរា** (Yashodhara) *ដែលត្រូវជាប្អូនជីដូនមួយ។* **រាហុល** (Rahula) *ជាព្រះរាជបុត្ររបស់ព្រះអង្គ។*

*លុះព្រះអង្គមានព្រះជន្ម២៩ព្រះវស្សា ព្រះអង្គសម្រេចព្រះទ័យចាកចោល ព្រះរាជវាំងបន្ទាប់ពីបានពិចារណាលើធាតុកូត៤យ៉ាង គឺ: សេចក្តីក្រខ្សត់* (pauvreté) *សេចក្តីឈឺចាប់* (souffrance) *សេចក្តីស្លាប់* (mort) *និងគុណធម៌នៃជីវិតស្មារតី* (vertus de la vie spirituelle)*។*

ក្នុងការធ្វើសមាធិ អំពីការឈឺចាប់ នៃជីវិត នៅក្រោមដើមពោធិព្រឹក្ស **ព្រះសិទ្ធាថ៌** (Siddhartha) ទ្រង់បានត្រាស់ដឹង។ គឺពេលនោះហើយដែលព្រះអង្គបានក្លាយជាព្រះពុទ្ធ ដែលមានន័យថាអ្នកត្រាស់ដឹង(éveillé)។ ព្រះអង្គរកឃើញ *សង្សារៈ* (Samsara) ជាវដ្តអមតៈនៃសេចក្តីស្លាប់ និងសេចក្តីកើត (cycle infernal des morts et renaissances) និងរកឃើញផ្លូវកណ្តាលមួយ ដែលឈានទៅរកព្រះនិព្វាន (voie moyenne qui mème au nirvana)។ "*និព្វាន* មានន័យថាការសម្រាកដាច់ខាត និងការស្ថិតនៅលាយឡំជាមួយចក្រវាឡ" (Le nirvana est le repos absolu et la fusion avec le cosmos)[១]។

មុនដំបូង ពុទ្ធលទ្ធិដែលមិនបែរទៅរកការគោរពបូជាចំពោះទេវតាពណាមួយ បានចងសម្ព័ន្ធជាមួយទស្សនវិជ្ជាមុនពេលចងសម្ព័ន្ធជាមួយសាសនា។ ចាប់ពីពេលដែលព្រះពុទ្ធចូលបរិនិព្វាន សាវ៉កទាំងឡាយបានចងក្រងឡើងវិញ នូវលទ្ធិដែលព្រះអង្គបានបង្រៀន។ ក្បួនច្បាប់ត្រូវបានកំណត់នៅក្នុងសង្គាយនាលើកទី១(premier concile) នាឆ្នាំ៤៧៧ មុនគ្រិស្តសករាជ។

ការបែកបាក់គ្នាបានកើតឡើងយ៉ាងឆាប់រហ័ស នៅក្នុងសហគមន៍ពុទ្ធសាសនា ហើយការផ្តាច់ចេញពីគ្នាត្រូវបានបញ្ជាក់ច្បាស់នៅ

---

១- Borda, *L'ENCYCLO*, Paris, 1990, p.145.

ក្នុងសង្គាយនាលើកទី២ (deuxième concile) នាឆ្នាំ៣៧៧ មុនគ្រិស្តសក-រាជ។ អត្ថបទចុងក្រោយនៃគម្ពីរសាសនា ដែលមានឈ្មោះថា ព្រះត្រៃបិដក (les Tipitakas) បានសម្រេចនៅក្នុងសង្គាយនាលើកទី៣ (troisième concile) នាឆ្នាំ២៤៥មុនគ្រិស្តសករាជ។ គំនិតបកស្រាយយ៉ាងទូលំទូលាយ និងពោរពេញទៅដោយ សប្បុរសធម៌នៃពុទ្ធលទ្ធិ បានបង្កើតឲ្យមាននិកាយមហាយាន ហើយបន្ទាប់មកមានជំនឿ តន្ត-ត្រានិយម (Tantrisme)[២]។ និកាយថ្មីៗនេះបានបង្កើតពហុទេវៈ ពហុពុទ្ធ និងពហុពោធិសត្វ (les Dieux, les Bouddhas et les Bodhisattvas) ដោយសង្កត់ធ្ងន់លើសេចក្តីអាណិត (compassion) ជំនឿស៊ប់ (dévotion) និងភាពតឹងរ៉ឹង (mystique)។

ក្នុងសាកលលោក ពុទ្ធសាសនាចែកចេញជានិកាយសំខាន់ៗ បីគឺ និកាយ ហីនយាន (Hinayana) និកាយ មហាយាន (Mahayana) និង និកាយ វជ្រយាន (Vajrayana)។ "ហីនយាន (ស្រើលភ្លាំ កម្ពុជា ភូមា ថៃ) ប្រមូលផ្តុំសាវកទាំងឡាយដែលគោរពលទ្ធិដើមនៃព្រះពុទ្ធ។លទ្ធិនេះផ្អែកលើទស្សនៈដែលថាមនុស្សមិនយល់ដឹងពីអ្វីដែលមានលក្ខណៈ

២-ជំនឿតន្តត្រានិយម (tantraisme) ជំនឿ និងពិធីបុណ្យដែលមានចែងនៅក្នុងគម្ពីរតន្ត្រា (tantra) ដែលដកចេញពី ហិណ្ឌូនិយម ចេននិយម និងពុទ្ធនិយម។ គោលបំណងនៃជំនឿតន្តត្រានិយម គឺការយល់ជ្រៅជ្រះអំពីក្រឹត្យក្រមធម្មជាតិ។

អស្មិរូប និងផ្អែកលើទស្សនៈបុគ្គលនិយមនៃការរំដោះខ្លួន។ មហាយាន (ចិន កូរ៉េ ជប៉ុន) ប្រឆាំងចំពោះចំណង់អត្តទត្តនិយម (aspirations égoïstes) នៃហីនយាន ដែលមានគោលបំណង ចាកចេញដោយខ្លួនឯងពីវដ្តអមតៈនៃការចាប់កំណើតជាថ្មី (វដ្តអាក្រក់នៃការចាប់កំណើតជាថ្មី)។ ហេតុនេះ និកាយមហាយានក្លាយជា សាសនាមួយដែលទាំងអស់គ្នាអាចប្រព្រឹត្តបានព្រោះព្រះពោធិសត្វទាំងឡាយ (les bodhisattvas) ដែលជាការៈប្រកបដោយករុណាធម៌ (êtres compatissants) បដិសេធថា ព្រះអង្គមិនចូលបរិនិព្វានទេ ដើម្បីនៅជួយនិងស្រោចស្រង់ការៈរស់ទាំងឡាយ។ វីរៈយាន (Vajrayana) ត្រូវបានហៅម្យ៉ាងទៀតថា និកាយពេជ្រ (véhicule de diamant) ឬ និកាយតន្ត្រនិយម (Tantrisme) (ទីបេ និងម៉ុងហ្គោលី) មានប្រភពពីមហាយាន ដោយផ្អែកលើពិធីបុណ្យអាថ៌កំបាំងពិបាកយល់ (rituels ésotériques) ផ្អែកលើការប្រតិបត្តិដែលស្តែងឲ្យឃើញនៅក្នុងគម្ពីរតន្ត្រ (Tantra) និងផ្អែកលើយោគៈ (Yoga) ពិធីបុណ្យដែលត្រូវគោរពបូជា ត្រូវបានដកចេញពីគ្រប់សពេ្វតនាសាសនា (de tous sentiments religieux) ព្រះសង្ឃ ដែលជាជនជាតិទីបេ រស់នៅលាយឡំជាមួយសង្គមគ្រហស្ថ (la société laïque) ដោយមានការឧបត្ថម្ភពីសម្នាក់អ្នកជឿទាំងឡាយ" [៣]។

---

៣-Bordas, ***L'ENCYCLO***, Paris, 1990, page 145.

ក្នុងការប្រតិបត្តិជាក់ស្តែង លទ្ធិហីនយាននៅកម្ពុជាមិនមានលក្ខណៈបុគ្គលនិយមដូចពោលខាងលើនោះឡើយ។ លទ្ធិនេះបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវគោលធម៌របស់ព្រះពុទ្ធ សំដៅឲ្យមនុស្សគ្រប់រូបដើរក្នុងផ្លូវត្រូវគ្រប់ៗគ្នា។ ហេតុនេះ និកាយហីនយាននៅកម្ពុជាមានបំណងស្វែងរកសុខៈជូនដល់សង្គមមនុស្ស។ ម្យ៉ាងទៀតនិកាយនេះបានបង្រៀនឲ្យមនុស្សយល់ពីបរមត្ថវិជ្ជា(អស្តិរូបវិជ្ជា)។

គឺមិនមែនឲ្យមនុស្សយល់តែពីអ្វីៗ ដែលមានរូបពិតប្រាកដប៉ុណ្ណោះទេ។ ហេតុនេះហើយបានជាលទ្ធិហីនយាននៅកម្ពុជាមានអត្ថិភាពយូរអង្វែង បន្ទាប់ពីបានជំនួសនិកាយមហាយាន និងព្រហ្មញ្ញសាសនា។

## I-គ្រឹះនៃពុទ្ធលទ្ធិ (Les Fondements De La Doctrine Du Bouddha)

ធម្មៈ (dhamma) ជាបញ្ញត្តិមួយយ៉ាងល្បីល្បាញ ដែលបានសង្ខេបខ្លឹមសារនៃពុទ្ធលទ្ធិ តាំងពីលទ្ធិនេះបានចាប់កំណើតឡើង។ ធម្មៈ អះអាងពីអ្វីដែលមានពិត និងអះអាងពីអ្វីដែលត្រូវបញ្ឈប់។ ការគិតតាមបែបពុទ្ធលទ្ធិ ជាការគិតដែលមានសហេតុធម៌ (une pensée causale) ដែលធ្វើឲ្យមាន ប្រត្យក្សភាពនូវទំនាក់ទំនងរវាងហេតុ និងផល។ ការគិតតាមបែបពុទ្ធិលទ្ធិ (la pensée boubhique) ខុសពីការគិតតាមបែបវេទលទ្ធិ ( la pensée védique) ដែលមាននៅក្នុង Brahmana

និង Upanisad ។ ការគិតតាមបែបវេទលទ្ធិ ហោះឡើងដូចក្នុងប្រព័ន្ធសមីការ (système d'équations) សមីការរវាងមីក្រូចក្កវាឡនិងម៉ាក្រូចក្កវាឡ រវាងពិធីបុណ្យនិងទេវកថា រវាងមនុស្សនិងទេព្ដា រវាងព្រះព្រហ្មនិងអាត្ម័ន ដូចដែលមានរូបមន្ដមួយថែងថា "គាត់គឺខ្ញុំ (Lui c'est moi)។

ផ្ទុយទៅវិញ បើតាមលទ្ធិពុទ្ធនិយម បាតុភូតទាំងឡាយមានតជភាព លុះត្រាតែបាតុភូតទាំងនោះមានបន្សំសហេតុធម៌ (combinaison causale) ដែលហៅថាសង្ខារ ដែលអាចបានមកពីទ្រឹស្ដីកម្មផលដែលដែលគេមិនអាចដឹង ក្រៅពីគោលការណ៍សហេតុធម៌ឡើយ (principe de causalité)។ ពុទ្ធលទ្ធិថែងថា "អ្វីៗដែលមាន អត្ថិភាពសុទ្ធសឹងមានលក្ខខណ្ឌ" (Tout ce qui existe est conditionné)។ គ្រឹះនៃពុទ្ធលទ្ធិគឺ អរិយសច្ចទាំងបួន (Les Quatre Nobles Vérités) ដូចខាងក្រោម÷

**១_ ទុក្ខសច្ច ឬអ្វីៗទាំងអស់តែងមានទុក្ខ** (Tout est douleur)

បាតុភូតចិត្តរូប (phénomènes psychophysiques) នៃអត្ថិភាពសុទ្ធសឹងមានការឈឺចាប់។ ហេតុនេះ ជីវិតគឺ៖ មិនឋិតថេរមិនចំពោះមុខ និងពោរពេញដោយក្ដីឈឺចាប់។ ការយល់ជ្រៅជ្រះនូវលក្ខណៈពិសេសទាំងបីនៃអត្ថិភាព គឺជាបណ្ដើមសេចក្ដីនៃសមុច្ច័យពុទ្ធសាសនា (quête boudhique)។ ទុក្ខសច្ចត្រូវបកស្រាយដោយកត្ដាសំខាន់បីគឺ÷

ក.ភង្គៈភាពមិនថេរ (L'impermanence) មិនគ្រាន់តែជាគ្រឹះនៃជីវិតទេ តែមានលក្ខណៈសាកលទៀតផង។ "អ្វីដែលជាប្រធាននៃការចាប់កំណើត អ្វីនោះក៏ជាប្រធាននៃការរលត់រលាយវិញដែរ" (Tout ce qui est sujet à la naissance, tout cela est sujet à la disparition)[៤]។ អ្វីដែលមានទំនាក់ទំនង និងមានលក្ខខណ្ឌសុទ្ធសឹងធាប់រលាយទៅវិញ ដូចជា រាងកាយ ឥន្ទ្រិយារម្មណ៍ សញ្ញាណញាណ ហំមពលសាងសង់ជាដើម។ហេតុនេះ ពុទ្ធលទ្ធិមិនធ្វើដំណើរពីអតិសេដ្ឋភាព ពីអាទិទេព ឬសារធាតុ (Dieu ou substance) ឡើយ តែធ្វើដំណើរពីភាពមិនស្ថិតស្ថេរដ៏ចម្បងពីអវត្តមាននៃនិច្ចភាពដែលគួរឲ្យកត់សម្គាល់។ ប៉ុន្តែនិយាយបែបនេះ មិនមែនមានន័យថា ពុទ្ធសាសនិកត្រូវធ្លាក់ចូលទៅក្នុងទុទិដ្ឋិនិយមទេ។ ការយល់ពិតប្រាកដ ថាជាអ្វីៗសុទ្ធសឹងមិនទៀងទាត់ ពិតជាធ្វើឲ្យពុទ្ធសាសនិកមានសេចក្ដីស្ងប់ក្នុងសតិអារម្មណ៍។

ខ.ការរលំរលាយជាអចិន្ត្រៃយ៍ខាងលើនេះមិនអាចសម្របសម្រួលជាមួយខ្លួនឯង ឬ អត្ត: (Son Soi) ដែលជាសារធាតុរបស់បុគ្គលបានឡើយ។ លក្ខណៈទីពីរនៃការគិតតាមបែបពុទ្ធលទ្ធិ គឺការអះអាងអំពីអនត្ត: (NonSoi)។ គ្មានខ្ញុំដែលឋិតនៅ ជាអចិន្ត្រៃយ៍អមតៈ

---

៤ -Mahavagga Vinaga Pitaka, I, 6, 29.

ឡើយ។ ហេតុនេះទ្រឹស្តីអនត្តៈបែងចែកអត្ថិភាពជាធាតុដែលគ្មានសារជាតិ។ គ្មានធម្មជាតិបរិសុទ្ធទេ។ ម្នាក់ៗ ចំណុះសកម្មភាពរបស់ខ្លួន។

ទស្សនៈនេះផ្តោតទៅលើបុគ្គលិកលក្ខណៈរបស់មនុស្ស។ យើងកើតឡើង ដោយសារខន្ធដែលកត់សម្គាល់ ដោយការកើតការចាស់ជរាសេចក្តីស្លាប់ រយៈពេល និងការប្រែប្រួល។ ខន្ធនោះមានចំនួនប្រាំគឺៈ រូបក្ខន្ធ វេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ។ កត្តាទាំងនេះរៀបរាប់អំពីទំនាក់ទំនងរវាង ញាណ អង្គវិញ្ញាណ និងសកម្មភាពជាមួយនឹងបរិស្ថានខាងក្នុងនិងខាងក្រៅ។ ធាតុទាំងនោះក៏រលំរលាយមិនឋិតថេរដែរ។ ហេតុនេះ ហើយបានជាមានសេចក្តីទុក្ខព្រួយ។

គ-ដោយចាប់ផ្តើមពីដំណើរនៃតថភាពទាំងពីរ ខាងលើទើបឈឺចាប់ និងការវិលវល់ នៃចិត្តគំនិត (La souffrance et le tournement mental) បានចាប់កំណើតឡើង។ ម្យ៉ាងទៀតពាក្យទុក្ខក៏មាននៅក្នុងសតិអារម្មណ៍រីករាយផងដែរ ព្រោះយូរ ឬឆាប់សេចក្តីរីករាយនោះត្រូវបាត់បង់ទៅវិញមិនខានឡើយ។ សាកលភាពនៃទុក្ខ មិនមែនជាឧបធារណ៍ទេ (postulat)។ សាកលភាពនៃទុក្ខ ទាញយកហេតុផលពីអបុគ្គលិកលក្ខណៈ (impersonnalité) របស់មនុស្ស និងពីអនិច្ចភាព

(impermanence) តាំងពីប្រភពរបស់វាមកម្ល៉េះ។ ហេតុនេះសេចក្ដីព្រួយបារម្ភជាគន្លឹះមួយក្នុងចំណោមគន្លឹះសំខាន់ទាំងឡាយ ដែលធ្វើឲ្យពុទ្ធលទ្ធិកើតឡើង។

## ២-សមុទយសច្ច ឬ ចំណង់ជាប្រធាននៃសេចក្ដីទុក្ខ

( Le désir est l'origine de la douleur)

ព្រះពុទ្ធទ្រង់ប្រើពាក្យ តណ្ហា ឬចំណង់ខ្លាំងឬការស្រេកឃ្លាន (soif)។ តណ្ហា ឬសេចក្ដីលោភលន់ នេះអាចជាចំណង់កាមគុណ (désir sensuel) ចំណង់អត្ថិភាព (désir d'existence) ឬចំណង់អនត្ថិភាព (désir d'inexistence)។ ដើម្បីយល់ច្បាស់នូវប្រភពនៃសេចក្ដីទុក្ខ លទ្ធិនេះរៀបរាប់អំពី ប្រព័ន្ធនៃការគិតតាមលំដាប់ថ្នាក់ ពោលគឺលំដាប់ថ្នាក់នៃកត្តាតថភាពដែលធ្វើឲ្យយល់យន្តការនៃវត្ថុ និយាយជាទូទៅ និងធ្វើឲ្យយល់វាសនារបស់មនុស្ស និយាយដោយឡែក។ គឺផ្ដើមពីចំណុចនេះហើយ ដែលមានការវិភាគជាប្រព័ន្ធនូវលក្ខណៈចិត្តរបស់មនុស្ស (psychisme humain) ។ នោះហើយ ជាចំណែកដ៏សំខាន់នៃការការស្រាវជ្រាវចិត្តវិជ្ជា។ ម្យ៉ាងទៀត ពុទ្ធលទ្ធិពន្យល់អំពីការលេចឡើងនៃទុក្ខ (ការកើតទុក្ខ) តាមរយៈ នៃផលិតកម្មអនិស្សរភាព [(Production en Dépendance) (ការបង្កើតផលិតផល ដែលស្ថិតនៅក្នុងភាពចំណុះគ្នា) ដែលជាការបន្តគ្នានៃលក្ខខណ្ឌនានា ហើយដែលមានឈ្មោះជាផលិតកម្មលក្ខខណ្ឌ (Production Conditionnée)។ កត្តានេះលើក

ឡើង នូវគោលការណ៍ដែលថែងថា បាតុភូតទាំងអស់ដែលមានជីវិត បុគ្គល សុទ្ធសឹងឋិតនៅក្នុងផលិតកម្មអនិស្សរភាព ពីមួយទៅមួយ ដែលមានលក្ខណៈតភ្ជាប់គ្នាគឺ៖

- សេចក្ដីល្ងង់ ( ignorance)
- កម្ម (karma)
- ញាណ (conscience)
- បាតុភូតចិត្តរូប ( phénoménes psychophysiques)
- មូលដ្ឋានរបស់ញាណ ( bases de la conscience )
- ការប៉ះពាល់រវាងវត្ថុខាងក្នុង និងវត្ថុខាងក្រៅ ( contact entre les choses internes et les choses externes )
- ឥន្ទ្រិយារម្មណ៍ (sensations)
- តណ្ហា (soif)
- ការផ្សារភ្ជាប់ជាមួយអត្ថិភាព ( attachement à l'existence )
- ការប្រែក្លាយ (devenir)
- ជាតិ (naissance)
- ជរា និង មរណៈ (vieillesse et mort)

ការតភ្ជាប់ប្រកបដោយលក្ខខណ្ឌ ដែលកើតឡើងព្រមៗគ្នាផង និងផ្ដាច់ចេញពីគ្នាផង ប្រៀបដូចជាពាក្យ " ជំងឺ " និងពាក្យ

"គ្រឿងក្តៅ" គឺជាសំយោគគ្រប់សភាព តាំងពីអតីតកាលមកដល់បច្ចុប្បន្នកាល និងឈានទៅអនាគតកាល។ ហេតុចម្បងគឺ អវិជ្ជា តែចំណង់ និងតណ្ហា ជាកត្តាដែលធ្វើឲ្យមានការចាប់កំណើត ឬការចាប់ជាតិឡើងវិញឥតឈប់ឈរ។

**៤. និរោធសច្ច ឬ ការលុបបំបាត់ទុក្ខៈ** ( La suppression de la douleur )

ការបំបាត់ទុក្ខអាចប្រព្រឹត្តទៅបាន។ សច្ចភាពទាំងពីរខាងលើ (ទុក្ខសច្ច និងសមុទយសច្ច) ទាក់ទងនឹងការប្រែក្លាយ ឯសច្ចភាពទីបី មានលក្ខណៈផ្ទុយទៅវិញ គឺស្ថិតនៅក្នុងវិស័យឥតលក្ខខណ្ឌ។ សច្ចភាពនេះ ទាក់ទងនឹងការបញ្ឈប់ ឬបញ្ចប់ (arrêt, nirodha) ហេតុផលរបស់ទុក្ខដែលជាហេតុនៃតណ្ហា ការស្រេកឃ្លាន និងការឈឺចាប់។ចំណុចនេះ ឆ្លើយតបចំពោះការបញ្ចប់នៃផលិតកម្មអនិស្សរភាព ក៏ដូចជាការបញ្ចប់ចំណង់ និងតណ្ហា ហើយនៅទីបំផុត គឺការបញ្ចប់នៃជាតិ និងមរណៈ។ ដោយយល់ថាការដោះលែង ប្រសើរជាងការស្រោចស្រង់ លទ្ធិនេះអះអាងថា សត្វលោក អាចចាកចេញពីពិភពលោកដែលពោរពេញដោយសេចក្តីទន្ទេញព្រួយបារម្ភ និងសេចក្តីវិលវល់ដោយសារការរំលត់តណ្ហាដែលជាហេតុមួយដ៏សំខាន់។ "នេះជាអរិយសច្ចស្តីពីការលុបបំបាត់ទុក្ខ" ដែលជាការបញ្ឈប់ទាំងស្រុង នូវតណ្ហាជាការមិនទាក់ទាញ ជាការបដិសេធការសម្រាល និងការផ្តាច់

បេញ" (Voici... la noble vérité sur la surppression de la douleur : C'est l'arrêt complet de la soif, la non-attraction, le renoncement, la délivrance, le détachement)[៥]។ រយៈពេល ធ្វើដំណើរទៅរកនិព្វាន (nirvana) មានលក្ខណៈវែងឆ្ងាយ។ នៅទីនោះ គ្មានជាតិ គ្មានអ្នកស្វែងរកអត្តភាព គ្មានសមាសភាពឡើយ។

នៅក្នុងពុទ្ធនិយមបុរាណ និព្វានមានន័យជាបឋមថា ការចាកផុតពីការចាប់កំណើត ការឈ្នះលើចំណង់ការឈ្នះលើសេចក្ដីប្រណែន និងកំហុស ឬជាអវត្តមាននៃការប៉ងប្រាថ្នាធ្វើសកម្មភាព។ និយាយបែបនេះ មិនមែនមានន័យថា ពុទ្ធលទ្ធិជាលទ្ធិបដិសេធនិយមទេ (nihilisme) តែជាលទ្ធិដែលពិចារណា ពីសភាពផង និងដំណើរផង។

## ៣-មគ្គសច្ច ឬ វិធីលុបបំបាត់ទុក្ខ

(méthode de la suppression de la douleur )

ការអនុវត្តជារៀយៗនូវពាក្យមគ្គ ឬពាក្យប្រតិបត្តិ អាចឆ្លងផុតពាក្យប្រៀបសាមញ្ញ។ នោះជាការធ្វើដំណើរមួយ ដែលពុទ្ធលទ្ធិបានស្នើឡើង។ ផ្លូវដែលត្រូវដើរមានប្រាំបីបែបគឺ៖

- សេចក្ដីយល់ត្រូវ ( vision parfaite)
- សេចក្ដីត្រិះរិះត្រូវ ( intention partfaite)

---

៥ -Emmanuel Guillon, ***Les Philosophies bouddhistes***, Presses universitaires de France, 1995, p.20.

BUDDHIST IN... LIBRA...

- ការពោលពាក្យត្រូវ ( parole parfaite )
- ការប្រកបការងារត្រូវ (activité parfaite )
- ការចិញ្ចឹមជីវិតត្រូវ ( moyens d'existence parfaite)
- ការព្យាយាមត្រូវ ( effort parfaite)
- ការរឭកត្រូវ (mémoire parfaite)
- ការតម្កល់ចិត្តត្រូវ (méditation parfaite) ។

ផ្លូវទាំងប្រាំបីយ៉ាងនេះឈ្មោះជាផ្លូវកណ្ដាល(voie moyenne)។ ការជ្រើសយកផ្លូវកណ្ដាលមួយ ដែលស្ថិតនៅចន្លោះផ្លូវចុងទាំងពីរត្រូវបកស្រាយតាមកម្រិតបីបែប៖ ជាបឋម ស្ថិតនៅចន្លោះ សេចក្ដីត្រេកត្រអាលនិងតបកម្ម (entre la volupté et l'ascèse) បន្ទាប់មកស្ថិតនៅចន្លោះការបន្ធូរបេស់ញាណ និងការបន្តឹងហួសហេតុរបស់វា (entre le relachement de la conscience et son extrême tension) ហើយជាចុងក្រោយស្ថិតនៅចន្លោះសូន្យ និងអត្ថិភាពអមតៈ (entre le néant et l'existence éternelle)។ **អឺ.ឡាម៉ុត** (E. Lamotte) អះអាងថា មាគ៌ាទាំងប្រាំបីខាងលើមានធាតុសំខាន់បីយ៉ាងគឺ សីលភាព (moralité) សមាធិ (concentration) និងគតិវិញ្ញូ (sagesse) ...។ រីឯសមាធិនៃពុទ្ធលទ្ធិ ខុសពីសមាធិហិណ្ឌូនិយម។ សមាធិ ហិណ្ឌូនិយមជាវិធីលុបបំបាត់កំហុសធ្ងន់។ សមាធិពុទ្ធនិយម ជាវិធីធ្វើឲ្យការយល់ឃើញ មានលក្ខណៈ

បរិសុទ្ធ។ សមាធិ (samadhi) ដែលជាលក្ខខណ្ឌចាំបាច់ សម្រាប់គ្រប់ការពិចារណាទាំងអស់ មិនមែនជាសភាពញាណទិកនិយមឡើយ។

ជាទូទៅ ពុទ្ធលទ្ធិមិនមានលក្ខណៈទិកនិយមដូចទ្រឹស្តីដេកាតទេ (théorie de Descarte)។ លទ្ធិនេះ ឥតបែងចែកនៅក្នុងចំណាត់ថ្នាក់នៃតថៈផង និងនៅក្នុងការធ្វើជំរេណីផង ពោលគឺគ្មានការបែងចែករវាងរូបធាតុ និងស្មារតីឡើយ។ ពុទ្ធលទ្ធិក៏មិនមានលក្ខណៈស្មារតីនិយមដែរ ព្រោះទិដ្ឋភាពសំខាន់មួយ ក្នុងចំណោមទិដ្ឋភាពសំខាន់ទាំងឡាយនៃពុទ្ធលទ្ធិ គឺការបដិសេធគោលការណ៍ស្មារតីអចិន្ត្រៃយ៍។ ម្យ៉ាងទៀត ដើម្បីឈានទៅដល់តថភាព ត្រូវរៀបចំកសាងប្រកបដោយសុភនិច្ច័យ ពោលគឺគ្មានសារជាតិទេ តែគ្រាន់តែមានអត្ថិភាពប៉ុណ្ណោះ គឺអំពើដែលជាអ្នកកសាងភាវៈ។ ឯអនាគតនៃភាវៈនេះ មិនផ្អែកលើធម្មជាតិរបស់វាដែលគ្មានអត្ថិភាពឡើយ តែផ្អែកលើសកម្មភាពរបស់វាទាំងស្រុង។ ចំណុចនេះហាក់ដូចជាគូសបញ្ជាក់ពីអត្ថន័យញាណមួយក្នុងចំណោមអត្ថន័យញាណចម្បងទាំងឡាយនៃព្រះពុទ្ធ គឺការយល់អំពីភាពដាច់បាត់បង់នៃការប្រែក្លាយ និងការវិភាគធាតុដោយឡែកៗដែលចំណុះគ្នាទៅវិញទៅមក។

អរិយសច្ចទាំងបួនខាងលើ ប្រៀបដូចជា "ជំងឺ" ហេតុនៃជំងឺ ថ្នាំព្យាបាល និងវិធីព្យាបាល"។ ទុក្ខសច្ច ជាជំងឺដែលមនុស្សមិនអាច

ចៀសផុតៗ សមុទយសច្ច ជាហេតុដែលបណ្ដាលឲ្យមានជំងឺៗ និរោធសច្ច ជាថ្នាំព្យាបាលសម្រាប់ឲ្យអ្នកជំងឺជាសះស្បើយៗ មគ្គសច្ច ជាវិធីព្យាបាលជំងឺ ជាវិធីស័ក្តិសិទ្ធិក្នុងការប្រើថ្នាំព្យាបាលៗ

ទឹកល្អក់ ព្រោះកករធូលីដី
ចិត្តល្អក់ ព្រោះអវិជ្ជា,
ទឹកថ្លា ព្រោះតម្រង
ចិត្តថ្លា ព្រោះវិជ្ជា ៗ

ព្រះឧត្តមមុនី អ៊ុម ស៊ូ

# ព្រះពុទ្ធសាសនាជាឫសគល់មួយនៃវប្បធម៌ខ្មែរ

(តចប់)

*អ្នកស្រីបណ្ឌិត* **ខួត ធីតា**

**ឧបសគ្គ:**

*តាមលក្ខណៈទូទៅ យើងសង្កេតឃើញថា ការរីកចម្រើននៃសង្គម និងសាសនា គេអាចឲ្យឈ្មោះតាមលក្ខណៈនៃការរីកចម្រើន ឬការជឿនលឿននៃផ្លូវគំនិតការបង្កើតអង្គការថ្មី និងការបែកធ្លាយនៃអង្គការរបស់សង្គមដែលស្របទីងឧត្តមគតិទាំងឡាយ ទោះជាច្បាស់លាស់ក្តីមិនច្បាស់លាស់ក្តី នៃជីវិតសង្គម និងសាសនា។ ការពិសោធន៍ក្នុងជីវិតគឺជាសត្រូវនៃមនុស្សលោក ក៏ត្រូវបាត់បង់ទៅវិញ ប៉ុន្តែវាអាចជាជំនួយដល់គំនិតថ្មីដែរ។ ម្យ៉ាងទៀតការឆ្លងគ្នានៃវប្បធម៌ក៏ជាសភាវៈធម្មតានៃមនុស្សលោកដែរ។ ទ្រឹស្តីបដិសំយោគអះអាងថា ការរីកចម្រើនគឺជាចលនាឈានឡើង លក្ខណៈពិសេសរបស់វា គឺការឈានឡើងដោយមានការទទួលបន្ត និងមានការសោចុះសាឡើងនៃអ្វីដែលចាស់លើមូលដ្ឋានខ្ពស់ជាង ហើយមានការលេចចេញអ្វីដែលថ្មី ដោយកម្ទេចចោលអ្វីដែលចាស់នោះ ។*

*ប៉ុន្តែ ទោះជាការរីកចម្រើននៃវិទ្យាសាស្ត្រ និងមនោគមវិជ្ជាមានល្បឿនយ៉ាងណាក៏ដោយ ក៏ជំនឿនេះមិនរលុបសោះសូន្យឡើយ គ្រាន់តែមានឥទ្ធិពលតិចតួច ឬខ្សោយប៉ុណ្ណោះ ព្រោះទ្រឹស្តីនៃជំនឿនិងការប្រតិ-*

បត្តិមានលក្ខណៈប្រកបដោយ ហេតុផលគួរណាស់ដែរ បើមានការពិតច្រើនៗ ពេលមនុស្សត្រូវការជំនឿក៏នៅមានជីវិតរស់នៅដែរតែបើសង្គមលោក លែងមានមនុស្សត្រូវការជំនឿក៏បាត់ទៅដែរ។ ម្យ៉ាងទៀតបញ្ញត្តិទាំងអស់នេះតែងទាក់ទងជានិច្ចជាមួយទីងឧត្តមគតិនៃហេតុ(Causation)។ “ស្ថានហេតុនេះមិនមែនកើតឡើងតែក្នុងខេត្តនៃអាទិទេវប្បញ្ញត្តិទេ សូម្បីក្នុងខេត្តនៃនិព្វានបញ្ញត្តិ ឬមោក្ខប្បញ្ញត្តិក៏កើតមានដែរ”[១]។ គ្រោះថ្នាក់ដែលមានដូច្នេះ ព្រោះសាវកនៃសាសនានោះពុំបានចេះដឹង ពាក្យប្រៀនប្រដៅឲ្យច្បាស់លាស់ ហើយគ្មានការប្រឹងអនុវត្តពាក្យប្រៀនប្រដៅនេះឲ្យកើតជាផលឡើង។ មិនតែប៉ុណ្ណោះគ្រោះថ្នាក់នេះ ក៏បណ្តាលមកពីអ្នកកាន់សាសនាផ្ទាល់ ឬអ្នកបួសដែរបើអ្នកទាំងអស់នេះពុំបានអនុវត្តពាក្យប្រៀនប្រដៅនៃសាសនា ដែលខ្លួនកាន់នោះទៅតាមសម័យប្រទេស។ ជាពិសេសទៅទៀត “ ពួកគេពុំបានសិក្សាឲ្យច្បាស់លាស់ អំពីចលនសាសនា និងអចលនសាសនាតាមបែបវិទ្យាសាស្ត្រទៀតផង”[២]។

ព្រះពុទ្ធសាសនា ជាសាសនាមួយមានគោលធម៌យ៉ាងច្រើន អាចប្រើប្រាស់គ្រប់សម័យកាល ទោះជាការរស់នៅក្នុងសង្គមទំនើបទាមទារការពិចារណាច្រើនយ៉ាងណាក៏ដោយ ចំពោះគំនិតនីមួយៗ វិស័យនីមួយៗ រួមបម្រុះល្អនិងអាក្រក់ លាយឡំក៏ដោយ។ ជូនកាលសាសនាតែមួយ

១-ប៉ែន សាអឿន សាសនាប្រៀបធៀប វប្បធម៌-អរិយធម៌ខ្មែរ និងទស្សនវិជ្ជា ភ្នំពេញឆ្នាំ១៩៦៩។
២-ប៉ែន សាអឿន សាសនាប្រៀបធៀប វប្បធម៌-អរិយធម៌ខ្មែរ និងទស្សនវិជ្ជា ភ្នំពេញឆ្នាំ១៩៦៩។

តែការប្រព្រឹត្តខុសទីកន្លែងខុសកូមិសាស្ត្រអាចថា ខុសគ្រួសារត្រកូល ក៏សើងថាបាន ក៏អាចប្រព្រឹត្តប្លែកគ្នាខ្លះដែរ។

តើគួរយល់បែបណា?

នៅប្រទេសអាស៊ី"កាន់សាសនាព្រះពុទ្ធថេរវាទ"តួយ៉ាង ស្រីលង្កា ភូមា ថៃ លាវ កម្ពុជា ជាដើម ក៏គេសង្កេតឃើញភិក្ខុសង្ឃពុទ្ធសាសនិក នៅប្រទេសតែមួយ ឬក្នុងប្រទេសផ្សេងគ្នាបានប្រកាន់យកការប្រព្រឹត្ត ការស្លៀកដណ្ដប់ ការសូត្រធម៌ការនិយមមិនត្រូវគ្នាខ្លះៗដែរ។ ឧទាហរណ៍ "លោកសង្ឃឆាន់បារីនៅក្នុងប្រទេសកម្ពុជាទោះទីណា ពេលណាក៏គ្មានទោស គ្មានការរិះគន់ទេ ប៉ុន្តែនៅប្រទេសខ្លះវិញ ដូចជាប្រទេសស្រីលង្កា ជាដើម លោកឆាន់បារីជាកំហុសធ្ងន់ នៅពេលណា ទីណាក៏ដោយ"[៣]។ នៅប្រទេសកម្ពុជា ការថ្វាយផ្កាព្រះ គេប្រយ័ត្នប្រយែង យកផ្កាណាគ្មានហែក រៀបចំដាក់ថូសមរម្យ អុជធូប អុជទៀន។ នៅស្រីលង្កាវិញ ការថ្វាយផ្កាព្រះ គេនិយមហែកច្រៀកតូចៗ មិនរើសមុខផ្កា តាំងពីផ្កាចំប៉ីជាដើមអាចរាយបាចផ្ទាល់លើកម្រាលនៅមុខព្រះពុទ្ធរូប មានដាក់ថូតិចតួចណាស់ អុជធូបតិចតួច (ធូបតូចៗ ប្រវែង១តឹកជាង) គេនិយមអុជប្រេងដូងជាង។ នេះហាក់ដូចជាស្មុគស្មាញណាស់ បើគ្រាន់តែឃើញរូបភាព និងទម្រង់ផ្សេងៗ ។

៣-ឈន អៀម គ្រឹះអប់រំរបស់ព្រះពុទ្ធសាសនា សមាជជាតិស្រាវជ្រាវសិក្ខមវប្បធម៌អំពីកម្ពុជា លើកទី៣ ថ្ងៃ១៧ ខែវិច្ឆិកា ឆ្នាំ២០០០ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២។

ផ្អែកលើព្រះត្រៃបិដកព្រះពុទ្ធសាសនាមានកម្លាំងគ្រប់គ្រាន់ដើម្បីប្រឈមមុខនឹងទស្សនៈថ្មីៗ ហើយអាចទប់ស្កាត់ជម្លោះសាសនា បានទៀតផង។ ព្រះពុទ្ធសាសនា គឺជាប្រព័ន្ធដ៏ខ្ពស់ត្រដែត និងប្រសើរបំផុតដែលក៏អាចត្រូវបានគេអនុវត្ត ដោយមនុស្សប្រុសនិងមនុស្សស្រីធម្មតានៅក្នុងការងារពិភពលោកប្រចាំថ្ងៃ។ មនុស្សដូចគ្នាទាំងអស់នេះគិតថា មនុស្សម្នាក់ ត្រូវតែចូលនិវត្តពីការងារទៅកាន់វត្តមួយ ឬទៅកាន់កន្លែងស្ងៀមស្ងាត់មួយចំនួន ប្រសិនបើមនុស្សម្នាក់មានបំណងប្រាថ្នាចង់ក្លាយជាពុទ្ធសាសនិកដ៏ពិតប្រាកដមួយ នោះគឺជាការកាន់ច្រឡំដ៏ធំនិងខុសដែលមកពីការយល់ដឹងលើទ្រឹស្តីព្រះពុទ្ធ។ មនុស្សខ្លះបានឈានទៅដល់ការសន្និដ្ឋានច្រើនបែបច្រើនយ៉ាង ការអាន ការស្តាប់អ្វីមួយយ៉ាងធម្មតាអំពីព្រះពុទ្ធសាសនា។ មនុស្សខ្លះបង្កើតនូវការចាប់អារម្មណ៍របស់ពួកគេស្តីពីព្រះពុទ្ធសាសនា បន្ទាប់ពីការអានអត្ថបទ ឬសៀវភៅទាំងឡាយដែលគ្រាន់តែផ្តល់ឲ្យនូវទស្សនៈមួយផ្នែក ឬក៏មួយចំរៀកស្តីពី ព្រះពុទ្ធសាសនា។ អត្ថបទអ្នកនិពន្ធនិងសៀវភៅជាច្រើន គ្រាន់តែមានដែនកំណត់នៃការយល់ដឹងស្តីពីការបង្រៀនទ្រឹស្តីព្រះពុទ្ធ។ ការបង្រៀនរបស់គាត់គឺមិនមែនមានន័យថា គ្រាន់តែសម្រាប់ព្រះសង្ឃនៅក្នុងវត្តប៉ុណ្ណោះទេ។ ការបង្រៀនគឺសម្រាប់មនុស្សសាមញ្ញទាំងពីរភេទផងដែរ ដែលរស់នៅផ្ទះជាមួយនឹងគ្រួសាររបស់ពួកគេ។ មគ្គអរិយសច្ចដែលមានផ្លូវរំលត់ទុក្ខទាំង៨គឺ អដ្ឋង្គិកមគ្គ ជាមធ្យោបាយនៃជីវិតរបស់ពុទ្ធសាសនិកចង់បានសេចក្តីសុខត្រឹមត្រូវ។ "*មធ្យោបាយនៃជីវិតនេះ ផ្តល់ឲ្យទៅមនុស្សជាតិ*

*ទាំងអស់ ដោយគ្មានការខុសប្លែកគ្នាឡើយ*[៤]។ មនុស្សដ៏សម្បើមភាគច្រើននៅក្នុងពិភពលោកមិនអាចប្រែក្លាយជាព្រះសង្ឃ ឬក៏លាលែងនៅក្នុងរូងភ្នំ ឬព្រៃព្រោងព្រាតបានឡើយ។ អាចមានអ្នកបួស ឬអ្នកគ្រហស្ថធម្មតា។ ទោះជាយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាដ៏ប្រសើរទិងបរិសុទ្ធប្រហែលជាអាចគ្មានប្រយោជន៍ ចំពោះចំនួនដ៏ច្រើននោះ ប្រសិនបើពួកគេមិនអាចធ្វើតាមវិន័យព្រះធម៌បាននៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ នៅក្នុងពិភពលោកសម័យទំនើប ប៉ុន្តែប្រសិនបើគេយល់ស្មារតីនៃព្រះពុទ្ធ-សាសនាយ៉ាងត្រឹមត្រូវ អ្នកអាចធ្វើតាមបានយ៉ាងប្រាកដ ទិងអនុវត្តក្នុងខណៈពេលជីវិតនៃការរស់នៅរបស់មនុស្សធម្មតាបាន។ "នេះគឺជាការកាន់ប្រឡដ៏គួរទទួលអារម្មណ៍មួយ ដែលពិតជាមកពីកង្វះខាតមិនបានយល់ដឹងពីការបង្រៀនរបស់ព្រះពុទ្ធ"[៥]។

តើអំពើល្អដែលមនុស្សជាច្រើនអាចទទួលប្រយោជន៍បាននោះគឺអ្វី? ព្រះសង្ឃមិនអាចផ្តល់ការជួយសម្រាលទុក្ខខាងសម្ភារៈដល់ ឧបា-សកឡើយ ប៉ុន្តែ ព្រះសង្ឃអាចផ្តល់នូវមគ្គុទ្ទេសក៍ខាងផ្លូវចិត្ត ដល់អ្នកដែលមានបញ្ហាខាងលោកីយ៍គឺ បញ្ហាសម្រួលចិត្តខាងគ្រួសារ ហើយទីងប្រការផ្សេងៗទៀត។ ព្រះសង្ឃបូជាព្រះជន្មរបស់ព្រះអង្គចំពោះការស្វែងរកពុទ្ធិ (ព្រះធម៌) ដែលបានបង្រៀនដោយព្រះពុទ្ធមានគម្ពីរធម៌អាចវិន័យជាដើម។ ព្រះអង្គអាចពន្យល់ពីការបង្រៀន នៅក្នុងទម្រង់ដ៏ងាយស្រួល

---

៤-K.Sri Dhammananda ,What Buddhists believe, Taiwan p.40.

៥- K.Sri Dhammananda ,What Buddhists believe, Taiwan p.40.

ដល់ឧបាសកដែលគ្មានអ្នកបង្រៀន (untutored)។ ហើយប្រសិនបើឧបាសកនោះទទួលការអប់រំល្អ គាត់អាចពិភាក្សាលើកម្រិតនៃការបង្រៀននោះកាន់តែជ្រៅថែមទៀតដើម្បីឲ្យមានបញ្ញាសាថ្មីពីការពិភាក្សានោះ។ សូម្បីតែនៅក្នុងប្រទេសដែលកាន់លទ្ធិពុទ្ធសាសនា ព្រះសង្ឃមានទំនួលខុសត្រូវយ៉ាងធំធេងចំពោះការអប់រំមនុស្សក្មេងៗ ដូចជាលទ្ធផលមួយនៃការធ្វើទានរបស់ព្រះអង្គ គឺប្រទេសកាន់ព្រះពុទ្ធសាសនា មានប្រជាជនជាច្រើនដែលចេះអាន ចេះសរសេរ និងមានការបន្ទឹកបន្ទឹនយ៉ាងល្អនៅលើតម្លៃនានាខាងផ្លូវចិត្ត។ ព្រះសង្ឃក៏បានជួយសម្រាលទុក្ខដល់អ្នកដែលគេស្អប់ចោល និងការនាំចិត្តឲ្យរំដើបរំជួល ដោយពន្យល់ពីរបៀបដែលមនុស្សគ្រប់ៗរូប មានការរំខានបែបនេះប្រហាក់ប្រហែលគ្នា (all mankind is subject to similar disturbances)។ ផ្ទុយទៅវិញ ឧបាសកបានសង្ឃឹមថានឹងមើលថែទាំសុខមាលភាព ខាងសម្ភារៈដល់ព្រះសង្ឃដែល មិនអាចរកចំណូល មិនរកចង្ហាន់ ជម្រក ឱសថ និងស្បង់ចីវរបាន ដើម្បីឲ្យមានភាពងាយស្រួលដល់ព្រះសង្ឃ ដើម្បីនឹងបន្តជួយផ្តល់ផ្តង់ តម្រូវការខាងផ្លូវចិត្តរបស់ប្រជាជន និងសម្រាប់បន្សុទ្ធិកម្មខាងខួរក្បាល។

ឧបាសក ⇄ ព្រះសង្ឃ

(សម្ភារៈ) (តម្រូវការខាងផ្លូវចិត្ត មនុស្សទុក្ខ កម្ម)

## សន្និដ្ឋាន

ការគិតគូរបែបខាងលើនេះ មិនមែនមើលស្រាលនូវវប្បធម៌ ប្រពៃណី ជំនឿ សាសនារបស់យើងទេ។ ការថែរក្សាដោយខ្វះខាតការ

អភិវឌ្ឍន៍ គឺបានស្ថិតនៅក្នុងសារមន្ទីរ ឬគម្ពីរក្បួនខ្នាតតែប៉ុណ្ណោះ វាពុំអាចជ្រួតជ្រាប និងទទួលយកដោយប្រជាជនសកលលោកដែលរចេះតែវិវត្តបានឡើយ។ ជាងនេះទៅទៀតសេចក្តីត្រូវការចំពោះមុខគឺ ត្រូវការយល់ដឹង ដោយអាកប្បកិរិយាវិទ្យាសាស្ត្រទន់ភ្លន់ (វិទ្យាសាស្ត្រប្រកបដោយសីលធម៌ថ្លៃថ្នូរ) ហើយនិងសកម្មភាព ទស្សនៈវិស័យ ដែលសមស្របទៅនឹងតថភាពនាពេលបច្ចុប្បន្ន។ ប៉ុន្តែក្នុងនោះទាល់តែឯកភាពផ្ទៃក្នុងការងារតាមតួនាទីភារកិច្ចផងដែរ ទើបល្អប្រសើរ បើពុំនោះទេ មុខជាឈានទៅរកផលអាក្រក់ច្រើនជាងល្អ។ ប៉ុន្តែ រាល់ការបកស្រាយដ៏ទូលំទូលាយវែងអន្លាយខាងលើនោះគឺ បំណងបង្ហាញពីបុព្វហេតុនៃសេចក្តីពេញចិត្តរបស់មនុស្សពីជំនឿ ពីតម្រូវការ ពីអ្វីដែលចាំបាច់ ពីអ្វីមិនចាំបាច់គួរទទួលយកទាំងកម្រោលឬកែច្នៃកម្រិតណា? ត្រង់នេះហើយដែលលំបាកព្រោះអ្វីៗសុទ្ធតែត្រូវឆ្លងកាត់មនុស្ស មនុស្សជាអ្នកជ្រើសរើស មនុស្សជាអ្នកទទួលយក។ មនុស្សមានទំនោរច្រើន ព្រោះមនុស្សមានភាពស្មុគស្មាញច្រើន នេះក៏អាស្រ័យមនុស្សជាសភាវៈរស់ផង សភាវៈសង្គមផង និងជាសភាវៈមានចិត្តផង។ តាមការសិក្សាទស្សនវិជ្ជា មនុស្សមានទំនោរ៥កងធំៗ គឺទំនោរសេរីភាព ទំនោរអត្តបុគ្គល ទំនោរសង្គម ទំនោរឧត្តមគតិ និងទំនោរផ្ទាល់ខ្លួន។ ដូច្នេះហើយ គ្រប់សកម្មភាពរបស់មនុស្សទោះតាមផ្លូវចិត្តក្តី ផ្លូវកាយក្តី ផ្លូវបញ្ញាក្តី សុទ្ធតែមានបុព្វហេតុទាំងអស់។ បុព្វហេតុទាំងនោះ តែងជាប់ជំពាក់ជានិច្ចទៅនឹងទំនោររបស់មនុស្ស។

យ៉ាងណាមិញ ទោះបីជាប្រទេសកម្ពុជាបានទទឹងកំពុងដើរតាមផ្លូវព្រះពុទ្ធសាសនា *"ព្រះពុទ្ធសាសនាជាសាសនាជាតិ"* ក៏ដោយ ក៏ប៉ុន្តែការគោរព និងការប្រតិបត្តិនៅមានកម្រិតៗ ការប្រព្រឹត្តក្នុងក្រុមវណ្ណជាតិក្តី អន្តរជាតិក្តី បុគ្គលក្តី គឺកំពុងស្ថិតក្នុងការកែលំអឡើង និងត្រៀមកែលំអថែមទៀតៗ ជាងនេះទៅទៀត បើយើងពិនិត្យតាម រដ្ឋធម្មនុញ្ញ និងបំណែងចែកនៃការអនុវត្តន៍របស់អង្គការកំពូលនីមួយៗរបស់រដ្ឋ ធ្វើឲ្យយើងឃើញថាប្រទេសកម្ពុជា ជាប្រទេសមួយដែលមានច្បាប់គ្រប់គ្រាន់សម្រាប់គ្រប់គ្រងប្រទេសផងដែរ ដែលជាក្តីសង្ឃឹមរបស់យើងៗ


ឯកសារពិគ្រោះ

ក-ជាភាសាខ្មែរ

១-យ៉ង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, ប្រទេសបារាំង១៩៨៧ៗ

២-ឈន អៀម, គ្រឹះអប់រំរបស់ព្រះពុទ្ធសាសនា, សមាជស្រាវជ្រាវសង្គម-វប្បធម៌អំពីកម្ពុជាលើកទី៣ថ្ងៃទី១៧វិច្ឆិកាឆ្នាំ២០០០នៅសាកល-វិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ៗ

៣-ប៉ែន-សាអឿន,សាសនាប្រៀបធៀបវប្បធម៌-អរិយធម៌ខ្មែរនិងទស្សនវិជ្ជា, ភ្នំពេញ ឆ្នាំ១៩៦៩ៗ

៤-ទាវ-ឆៃសុក ព្រះពុទ្ធសាសនានិងសង្គមខ្មែរ វប្បធម៌ អរិយធម៌ខ្មែរ ឥណ្ឌា ភ្នំពេញ ឆ្នាំ១៩៧១-៧២ៗ

ខ-ជាភាសាបរទេស

1- BRADD SHORE Culture in Mind New York Oxford 1996

2- K. Sri Dhammananda what Buddhists Believe,Tainwan

3- World Book

# សិលាចារឹកទួលចាម K 939
## បច្ចុប្បន្ន ទួលសាលាឃុំព្រែកផ្ទោល ស្រុកអង្គរបុរី
## Inscription K 939 at Tuol Cham
## Currently Tuol Sala Khum Prek Phtol, Angkor Borei district

*ដោយ* **ទង់ សុធាវី**
*សាស្ត្រាចារ្យសិលាចារឹកសាស្ត្រនិងប្រវត្តិសាស្ត្រខ្មែរ*
*ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា,សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

*សិលាចារឹកនេះត្រូវបានលោក ព្យែរ ឌុយប៉ុង រកឃើញនៅលើទួលចាមកាលពីឆ្នាំ១៩៤៥[១] ដែលបច្ចុប្បន្ន ក្លាយជាទួលសាលាឃុំព្រែកផ្ទោល ស្រុកអង្គរបុរី ដែលស្ថិតនៅខាងត្បូងជាប់មាត់ស្ទឹងអង្គរបុរី ទន្ទឹមអតីតវត្តជ្រោយដែលសព្វថ្ងៃជាសាលាស្រុក។ អត្ថបទត្រូវបានចារឹកនៅផ្ទាំងសិលាស្តម្ភ ឬស៊ីមទ្វាររាងចតុកោណកែង ទំហំកម្ពស់១,៥៣ម៉ែត្រ ទទឹង០,៩៥ម៉ែត្រ និងកម្រាស់០,១៦ម៉ែត្រ។ ផ្ទាំងសិលាស្តម្ភនេះ ត្រូវបានគេកាត់ច្នៃរូបរាងរបស់វា ធ្វើបែបដូចជាទម្រសិវលិង្គនៅពេលបន្ទាប់ ដែលជាហេតុធ្វើឲ្យដាច់ អក្សរ៤បន្ទាត់ខាងលើទាំងផ្នែកដើម និងចុងបន្ទាត់ ហើយអក្សរនៅជួរទី៥ ក៏ត្រូវដាច់បាត់អស់ជាច្រើនព្យាង្គនៅខាងដើម និងខាងចុងបន្ទាត់ដែរ។ ទោះជាយ៉ាងណាអក្សរនៅប៉ែកខាងចុងបន្ទាត់ ចាប់ពីបន្ទាត់ទី៥ដល់ទី៩ ត្រូវ*

១-Cf, George Coedès, (1953). *Inscriptions du Cambodge*, vol. V, EFEO, Paris, p. 56.

រលុបបាត់ស្ទើរគ្មានសល់ ដែលមិនអាចអានបាន។

លោក មីសែល ត្រាណេ បានរកឃើញជាថ្មីម្តងទៀត ខណៈដែលអ្នកស្រុកយកវាទៅប្រើធ្វើជាថ្មកំណាល់។ បន្ទាប់មក លោកក៏បានលោះយកនិងប្រគល់ឲ្យទៅលោក ហោ ស្រូ ប្រធានសាលាស្រុកអង្គរបុរីតាំងពីឆ្នាំ១៩៩៤។ មន្ត្រីស្រុកក៏បានថែរក្សាទុកនៅក្នុងសារមន្ទីរស្រុករហូតដល់សព្វថ្ងៃ។ មិនត្រឹមតែប៉ុណ្ណោះ គាត់បានចុះលេខសិលាចារឹកនេះ នៅក្នុង "បញ្ជីជំរឿនសិលាចារឹកទើបរកឃើញថ្មីៗរបស់គាត់" ក្រោមលេខ Ka 5 ។

លោក សឺជេស បានបោះពុម្ពផ្សាយសិលាចារឹកនេះរួចហើយនៅក្នុងសៀវភៅបំណកប្រែ "សិលាចារឹកនៃប្រទេសកម្ពុជា" ភាគទី៥ ទំព័រ៥៦ ប៉ុន្តែលោកមិនបានបកប្រែវាទេ ដោយគ្រាន់តែអានរួចប្រាប់ថាវាជាអត្ថបទ រាយការណ៍ស្តីអំពីអំណោយរបស់កម្រតាងអញ គ្រីស្នាមិចាតុរវិទ្យ និងសរសេរជាអក្សររ៉ូម៉ាំង (Roman transliteration) ដោយមានខុសនៅអន្លើខ្លះ។ ពីព្រោះតែលោកអានលើក្រដាសដែលគេផ្តិតស្រោប (estampage/rubbing) ប្រកបដោយគុណភាពមិនសូវល្អ និងមានស្នាមរលុបច្រើន ឬអក្សរជាមជាប់គ្នា។

អត្ថបទចារឹកមាន៩បន្ទាត់ជាអក្សរខ្មែរសតវត្សទី៧ (ប្រហែលនៅក្នុងរាជ្យព្រះបាទជ័យវម៌្មទី១) ពីព្រោះតែអក្សរត្រូវរលុបដោយអន្លើ ធ្វើឲ្យយើងមិនអាចសន្និដ្ឋានអត្ថន័យចម្បងរបស់វា ឲ្យបានប្រទាក់គ្នាឡើយ។ គ្រាន់តែដឹងថា មានមហាមន្ត្រីម្នាក់ហៅទន្ទរនាមជា

*"កម្រតាងអញ"* (Kamratān añ) *នាម"ស្វាមិចាតុរវិទ្យ"* (Svāmi Cāturvvidya) *បានប្រើឲ្យក្រុមជនជាតិពីរ គឺ "ព្រៅ" និង "មលេង" លួចចាកចេញទៅ "ឃោសនា" ទាំង៨ទិស ដកបដល់ "ស្រុកករបុរៈ" ដែលគេស្គាល់ថា នៅពាក់កណ្តាលទី២នៃសតវត្ស ទី៦ ជាទឹកដីគ្រប់គ្រងដោយព្រះបាទភវវម៌្មទី១។ ត្រង់នេះធ្វើឲ្យយើងឆ្ងល់ថាតើមហាមន្ត្រីនេះឲ្យជាតិសាសន៍ពីរនេះ"ឃោសនា"រឿងអ្វីទាំង ៨ទិស? តើ "ករបុរៈ" ជាទឹកដីដូចម្តេច មានទំនាក់ទំនងបែបណាជាមួយអង្គរបុរីនៅពេលនោះ?*

*ក្រៅពីនេះ មានរៀបរាប់អំពីការធ្វើអំណោយ ដើម្បីផ្គត់ផ្គង់អ្នកធ្វើការកសាង "ប្រាសាទ៤ ធ្វើពីឥដ្ឋ"*[២] *នៅទីងប្រាសាទនៃព្រះស្រីត្រិភុវនញ្ជយ (ត្រីត្រិភុវនំជយ* Çrī Tribhuvanamjaya)។

**អត្ថបទដើមជាអក្សរកំពុងធំ**

១-..........[illegible]..........

២-..............[illegible]....[illegible]............

៣-.............[illegible].......

៤-.....[illegible].....

៥-...[illegible]..[illegible] ..

---

២-ត្រង់នេះលោក សឺដេសស្ទើថា"គោបុរៈ៤ធ្វើអំពីឥដ្ឋ?" Cf, *Ibid.*

..យស្រ...

៦-..នារី ក្រិ ព្រះ វែយ កេត គោក៏ ព្រះកម្រតាង៑ អញ បុ ណ្យ នោត្ន វ៉ៃង

ព្រះកម្រតាង៑ អញ ឞោចេន...ឞា ស្រុក...កម្រតាង៑

៧-អញ ស្រី ស្វាមី ជាក្យ ស្និក្ប្រ ប្រប្រ ស្រី ឞពេង ក្ម្យក៏ គោ ឃិ កិ ឃ៍ ឞណា

អញ ឞ្ឌ ឱ គ គ កិ ស្រុក៏ រាង បុ ក គ....

៨-ឧឃិ ក ស្លាង ល្បះ ង សែ ពោង ស្លំ ឱ ក្ក ពោង ស្លំ ស្គក្ក គ ព្រះកម្រតាង៑

អញ ស្រី ត្រិ ក្យ ចំ ឌេយ ក...ព្រះ កិ ណះ....

៩-.ង សំ ក្រិ ឃ ឆា ឞាក ក្លោង ណោ ឃិ ក្លៃ ក កិ គ ដ ង ជោង កិ ណះ

កញ្លោង ឆក គ ឃោរ គោ ឃ្យ គ ព្រះកម្រតាង៑ អញ ស្រី ត្រិ ក្យ ចំ ឌេយ

**អត្ថបទដើមជាអក្សរសម័យថ្មី**

១---------ជ្យេម្ន ជ្យេម្ន(នក្សត្រចន្ទ្រ) ទិវសវារ--------------------

២---------ម្រតា(ញ្ញ៉ក្លោ) ញ៉ភវបុរ---(ធ្មុំ) ទិក៑[៣] --------------------

៣----------វ្នុមនិ ប្រះកម្រតាង៑អញ ទិក្ញុំ លេយ៑ រ(គ) ------------------

៤---------------តេលិ តេក ម្រតាង៑អញ ស្រី ស្វាមិ ចាត្វ ឱ្យ----------------

៥-----អរិ---ប្រះកម្រតាង៑អញ ស្រីត្រិភុវនំជយ ប្លេតេ ប្រេរោះ ទោ(ង) ---------

៣- លោក សឺដេស អានថា វ្បិ—vvaṃ pi

មព្រ---

៦-(គ) មានិវ[៤]គិរោះទោមគេតគោក[៥] វ្រះកម្រតាងអញ្ញបុរមោត្តមទោងវ្រះកម្រតាង

អញ(ម) ហាវេរ----ហស្រគេ-----(កម្រតាង)

៧-អញគ្រីស្វាមិចាតុវ៌ិទ្យប្រេវ្រៅមលេងក្សក[៦] គោយគិឃោមណា[៧] អម្ពិទិគគិស្រុក

ភវបុរគេត១--ប

៨-ឱយគេស្វាងប្លេជ្ញងសោ[៨] ទោងថ្ងំទិក្កទោងថ្ងំស្វក្កតវ្រះកម្រតាងអញគ្រីត្រិភុ(វនំ)

ជយគេ--(រោះ)គិនេះប---

៩--ងសំរតិបញ្ចភាគត្លោង១មោយត្វៃគេគិត១ង[៩] ចោងគិនេះកន្លោងឥតតបោន(គោ)

យ្យ[១០]ត(វ្រះកម្រតាង) អញគ្រីត្រិ(ភុវនំជយ)

## អត្ថបទជាអក្សរឡាំង

1- ------------jyeṣṭha jyeṣṭha [nakṣatra candra]divasavāra-- --------------

2- ------------mratā[ñ klo]ñ bhavapura ----- [cmaṃ] dik----- --------------

---

៤-លោក សឺដេស បានស្នើថាប្រហែលជាពាក្យ មាស—mās

៥-លោក សឺដេស អានថា ទោក—dok

៦-លោក សឺដេស ថាឬមួយជា "ក្សក"—ksak ឬ មួយជា "ក្សេក"—ksek

៧- លោក សឺដេស អានថា បោមនា—posanā

៨- លោក សឺដេស អានថា "ជ្ញងសោំ"—jnaṅ soṃ ដោយពិតទៅ នៅខាងក្រោមព្យញ្ជនៈ "ជ" មានស្នាមបែក និងរលុប ។ ចំណែក នៅពីលើព្យាង្គ "សោ" ក៏គ្មានស្រៈ " " (aṃ) ដែរ ។

៩- លោក សឺដេស អានថា "ទោង"—doṅ តែយើងពិនិត្យមើលមិនឃើញមានស្រៈ "ោ-ា" សោះ ។

១០- លោក សឺដេស អានរំលងពាក្យ "គោយ្យ"? នេះបាត់តែម្តង ។

3- ------------va nu man vraḥ kamratāṅ añ dik kñuṃ ley ge--
-------------

4- -----------tel ge kamra[tāṅ] añ çrī svāmicāturvvidya-------
-------------

5- - aṃvi -- vraḥ kamratāṅ añ çrī tribhuvana[ṃ]jaya ple ge pre roḥ do[ṅ]--ṣa bra--

6- [g] mān ra gi roḥ doṣa ge ta tok vraḥ kamratāṅ añ puruṣottama doṅ vraḥ kamra tāṅ añ [ma]hāveva-----hasra ge---[kamratāṅ]

7- añ çrī svāmicāturvvidya pre vrau maleṅ ksak toy gi ghoṣaṇā aṣṭadiça ta gi sruk bhavapura ge ta daṅ --------

8- oy ge smāṅ ple j[n]aṅ so doṅ cmaṃ dikk doṅ cmaṃ sñakk ta vraḥ kamratāṅ añ çrī tribhu[vanaṃ]jaya ge -----[ro]ḥ gi neḥ p-------

9- -ṅ saṃrat pañcabhāga tloṅ I moy tṅai ge gi ta daṅ coṅ gi neḥ kanloṅ it ta pon [to]yy ta vra[ḥ kamra]tāṅ añ çrī tri[bhuvanaṃjaya]

## អត្ថបទបកប្រែ

*(១-)- ... ខែជេស្ឋ នក្សត្រជេស្ឋ ថ្ងៃច័ន្ទ ... ម្រតាញក្លោញ ភវបុរៈ[១១] ... ឆ្នាំទឹក ... និងមានព្រះ (កម្រតាងអញ) ទិកខ្ញុំ[១២]ឡើយ ... ដែលពួកគេ កម្រតាងអញស្រី[១៣]ស្វាមិចាតុរវិទ្យ ... អំពី ... ព្រះ*

---

១១- ពាក្យ "ម្រតាញក្លោញ" ជាឋានន្តរនាមសម្គាល់ "ចៅហ្វាយក្រុង" ។ តែបើឋានន្តរនាមជា "ព្រះកម្រតាងអញ" នោះនាម "ភវបុរ" ប្រហែលជាត្រូវនឹង "ព្រះបាទភវវម៌" ដោយកន្សោមនាម "ព្រះកម្រតាង អញ ភវបុរ" គឺជាទម្រង់មរណនាមរបស់ ព្រះអង្គ ។ (ពៅ សាវរស. មានប្រសាសន៍នៅក្រេតី រសៀល ថ្ងៃទី ២០ សីហា ២០០៣) ។

១២- គឺពាក្យ "ទិក"——ទឹក ឬកនិង "ក្ញុំ"——ខ្ញុំបម្រើ. អ្នកបម្រើ = ទឹករបស់អ្នកបម្រើ ។ យ៉ាងណាក៏ដោយ យើងនៅតែ មិនអាច កំណត់ន័យនៃពាក្យនេះបាន ។ ព្រោះវាប្រហាក់ប្រហែលនឹងឈ្មោះរបស់អាទិទេព ។

ស្រីត្រិកុវនេញយ មាធ្យោបាយ សម្រាប់ចិញ្ចឹមជីវិត[14]របស់ពួកគេ ប្រើដូចគ្នាទីង[15]... មាននៅទីនេះឯង ដូចទោសរបស់ពួកគេ ដែលបានដកបំផ្លាញ ព្រះ[16]បុរុសោត្តម[17] និង ព្រះមហាវេវ ... ពួកគេ ... ព្រះកម្រតាងអញស្រីស្វាមិចាតុរវិទ្យ បញ្ជាឲ្យ(ពួកជនជាតិ) ព្រៅ[18] និង(ពួកជនជាតិ)មលេង[19] លួចចាកចេញ[20] ទៅយោសនាគ្រប់ទិសទាំងប្រាំបី[21] រហូតដល់ស្រុកកវបុរៈ។ ពួកគេ

---

១៣-ជាឋានន្តរនាម មន្ត្រីជាន់ខ្ពស់បំផុតរបស់ព្រះរាជា នៅសម័យមុនអង្គរ។

១៤-ពាក្យ "ប្លេ" មានន័យផ្លាស់ប្ដូរមិនទៀងទាត់ ដោយអនុលោមតាមឃ្លាប្រយោគ និងបរិបទ។ តាមធម្មតា វាមានន័យថា "ផ្លែ ឬ ផល" តែពេលខ្លះទៀត មានន័យថា "មធ្យោបាយនានា ក្នុងការចិញ្ចឹម ជីវិត" (les Subsistances) ទៅវិញទេ Cf. George Cœdès, (1952). Inscriptions de Sambor Prei Kuk—Piédroit sud de la tour $N_{18}$ K. 149: 3-4. *Inscriptions du Cambodge,* Vol. IV, EFEO, Paris, pp. 28-30 ឬ "គ្រឿងផ្គត់ផ្គង់-វត្ថុបន្ទាប់បន្សំ" (Fournitures). Cf., George Cœdès, (1952). Inscriptions de Chamnom K. 30: 23., *op. cit.*, vol. II, EFEO, Hanoi, pp. 27-8. ។

១៥-ពាក្យ "រោះ ទោង"——រោះ--រុ. រូ. រុរ. រូរ = ដូច. ដូច្នេះ. អញ្ចឹង + ទោង——ទង. ទាង.ទាំង. ជាមួយ. រួម. ព្រមរួម. និង។ សូមមើល. POU Saveros, (1992). *Dictionnaire Vieux Khmer-Français-Anglais,* Cedoreck, Paris, p. 408.

១៦- ពាក្យ "គោកវ្រះ" ដែលអាចប្រែតាមន័យចំថា "ដកព្រះ" ឬ "បំផ្លិចបំផ្លាញព្រះ" ។Cf., *Ibid*, p. 220.

១៧-"វ្រះកម្រតាងអញបុរុសោត្តម"——បុរុសៈ + ឧត្តម : ជានាមមួយរបស់ព្រះវិស្ណុ។Cf., POU Saveros, (1994). Viṣṇu/ Nārāy au Cambodge. *Orientalia Lovaniensia Periodica,* Universitaire Stichting Van Belgie, Leuven, 1994: 25, pp. 175-195.

១៨-Cf, George Cœdès, (1942) *Inscriptions du Cambodge*, vol. II, EFEO, Hanoi, pp. 116-7. ។

១៩- សូមមើល. វង់ សុធារ៉ា និង ឡឹក សាវណ្ណ (២០០០) "សិលាចារឹកថ្មី១ សម័យមុនអង្គរ Ka 64 នៅភូមិមេលប់ ក្បែរស្វាយ ពល និង បញ្ហានៃជាតិពន្ធុនាមពីរ គឺ "ខ្មែរ" និង "មលេង"" ក្នុង *ទស្សនាវដ្ដីកម្ពុជសុរិយា*. ឆ្នាំទី ៥៤ លេខ១-២. ឆ្នាំ២០០០. ពុទ្ធសាសនបណ្ឌិត្យ. ភ្នំពេញ. ទំព័រ ៤១-៥៨ និង ៣១-៤៧. និង POU Saveros, (2001). *Nouvelles Inscriptions du Cambodge*. II-III, EFEO, Paris, pp. 200-202.

*(កុំបម្រើ) ដែល ... ឲ្យពួកគេជាអ្នកសាង[២២] មាធ្យោបាយបិញ្ចឹមជីវិតរបស់ជនសោ[២៣] រួមជាមួយធ្នាំទឹក និង ធ្នាំស្ងូក[២៤] របស់ព្រះស្រីត្រិកុវនញយ។ ពួកគេ ... ដូចបានរៀបរាប់ទាំងនេះ (ត្រូវផ្តល់ជាអង្ករ?)សម្រិត[២៥]ប្រាំភាគ ១ត្លោង(សម្រាប់)មួយថ្ងៃ[២៦]។ ពួកគេទាំងនេះ រួបរួមគ្នា[២៧]កសាង[២៨]នៅទីនេះ នូវប្រាសាទបួនធ្វើអំពីឥដ្ឋ[២៩] នៅទីង[៣០]ព្រះស្រី ត្រិ(កុវនញយ)។*

---

២០- ពាក្យស័ព្ទដើមថា "ក្សក--ksak" ដែលមកពីពាក្យថា "សក--sak" មានន័យថា "លួចយកចេញ បាត់--steal, or take away without permission"។ នៅពេលគេប្រើបន្ថែមជាមួយផ្នត់ ដើម "ក-" វាធ្វើឱ្យកិរិយាស័ព្ទកាន់តែសង្កត់ន័យឱ្យសកម្ម ឬ ធ្ងន់ជាងធម្មតា ។

២១- តោយគិឃោសណាអស្តទិស——តោយគិ = នៅទីនេះឯង + ឃោសណា ghoṣaṇā = ឃោសនា, ការផ្សព្វផ្សាយបញ្ចុះបញ្ចូល (propaganda, promotion) + អស្តទិស aṣṭadiça = ៨ទិស ។

២២- ពាក្យ "ស្មាង"——មកពី "សាង" + (-ម-) = អ្នកសាង ។

២៣-ជាអសាធារណនាមមួយ ដែលគេមិនដឹងថាជា "ឈ្មោះជនជាតិមួយ" ឬក៏ជា "ឈ្មោះទីកន្លែងមួយ" ។

២៤-ពាក្យ "ស្ងូក" មិនទាន់មានអ្នកណារកន័យឃើញនៅឡើយ។ ក្នុងចារឹកព្រះឥន្ទកោសីយ៍ K. 263 បន្ទាត់៥៣ គេឃើញពាក្យ នេះសម្គាល់អំណោយមួយប្រភេទ ដែលគេផ្តល់ជារៀងរាល់ថ្ងៃដល់ព្រះទិវ្យជេន្ទ្របុរៈ ជាមួយនឹង "អុស" និង "ស្នឹកតចសារព្រឹក្ស"។Cf., George Cœdès, (1952). *Inscriptions du Cambodge*, vol. IV, EFEO, Paris, p. 138.

២៥- ពាក្យ "សំរត" យើងប្រែពាក្យនេះ ដោយសន្មតថា វាត្រូវស្មេរដើមសរសេរភ្លេចដាក់ស្រៈ "ិ" គឺ សរិត = សម្រិត( ប្រភេទនៃ អង្ករសម្រាប់យកមកដាំបាយហូប )។ Cf., George Coedès, (1942). Inscription de Chamnom K. 30: 27. *Inscriptions du Cambodge*, Vol. II, EFEO, Hanoi, p. 27-8.

២៦-ត្លោង១មោយតៃ= ១ ត្លោង ( រង្វាស់រង្វាល់ ) + មួយថ្ងៃ។

២៧- ពាក្យ "គេគិ--ge gi" មានន័យថា : គេគិ——ពួកគេទាំងនេះ។

២៨-ពាក្យ "ចោង" មានន័យថា ចង ឬ សាង ឬ សង់ ។ ខ្មែរចាស់ប្រើពាក្យនេះមានលក្ខណៈតក្កភាព ដោយសារការសាងប្រាសាទ នីមួយៗរបស់គាត់មិនមែនប្រើប្រាស់តែថ្មមួយដុំឡើយ។ ផ្ទុយទៅវិញ គាត់ប្រើប្រាស់ដុំថ្មតូចៗជាច្រើនដុំផ្គុំគ្នា ចងភ្ជាប់គ្នាជារូបរាង រចនាសម្ព័ន្ធនៃប្រាសាទមួយឡើង។ ម្ល៉ោះហើយ




ស្ទើរគ្រប់សិលាចារឹកដែលផ្តល់ពតិមានស្តីពី "ការស្ថាបនា" ប្រាសាទ គេតែងតែប្រើ ពាក្យថា "ចោង" បែបនេះឯង ។

២៩- ពាក្យ "កន្លោងឥតតបោន" — កន្លោង = ប្រាសាទ. គោបុរៈ. ប្រាង្គបណ្ណាល័យ + ឥត=ឥដ្ឋ + តបោន=ចំនួនបួន ឬដែលមានបួន ។ យ៉ាងណាក៏ដោយ លោកសឺដេសបានស្នើថា "គោបុរៈបួនធ្វើពីឥដ្ឋ" ។ Cœdès, G. (1953). loc. cit.

៣០- ពាក្យ "គោយ គ" — ដោយ. តាម ឬ ផ្នែក ( នៃទីកន្លែង និង ឥរិយាបថ) ។ POU Saveros, (1992). *Dictionnairc Vicux Khmer Français Anglais,* Cedoreck, Paris, p. 221 ។ នៅទីនេះមានលក្ខណៈប្លែកពីប្រយោគនៃអត្ថបទចារឹក ដទៃ ដែលចារឹកខ្លះ ពេលណាស្មេរ ចង់បញ្ជាក់ប្រាប់យើងអំពី "ទិស" ដូចជា "នេះគោយឧត្តរនេះតិ..." ( នេះនៅទិសឧត្តរ នេះតី...) Cf., George Coedès, (1942). K. 554: 1, op.cit., p. 14.

# អំពីការដាក់អន្ទាក់[១]

ដោយ **មៀច ប៊ុណ្ណ**

ដោយឋិតនៅក្នុងតំបន់ ដែលមានធាតុអាកាសក្ដៅ ហើយសើមផងនោះ ប្រទេសកម្ពុជាយើងសម្បូរទៅដោយព្រៃព្រឹក្សាដែលជាលំនៅដ៏ពិសិដ្ឋរបស់ម្រឹគីម្រឹគា បក្សាបក្សី។ បណ្ដាជនដែលមានភូមិឋានទៅក្បែរតំបន់នេះ ឆ្លៀតឱកាសទំនេរពីការងារកសិកម្ម ពិសេសអ្នកដែលមានចំណង់ចំណូលចិត្តខាងការបរបាញ់ ទាក់ ចាប់សត្វ តែងតែឆ្លៀតទាញយកផលប្រយោជន៍ ពីអនុផលព្រៃឈើ ដោយនាំគ្នាដាក់អន្ទាក់បង្កាត់ ដើម្បីចាប់សត្វផ្សេងៗយកមកធ្វើអាហារ។ នៅតំបន់ព្រៃដីរាបទិងនៅតំបន់ព្រៃភ្នំ សត្វម្រឹគនានាមាន ឈ្លូស ប្រើស ក្ដាន់ ទន្សោង រមាំង ជ្រូកព្រៃ ចូលចិត្តរស់នៅខាំងណាស់ ព្រោះទីនោះជាជម្រកដ៏ប្រសើររបស់ពួកវា ព្រមទាំងមានរុក្ខជាតិប្លែកៗផ្ដល់ស្លឹក ផ្កា ផ្លែ ឫស មើម.. ជាចំណីដ៏ឆ្ងាញ់ដល់ពួកវាទៀតផង។

នៅរដូវដើមឆ្នាំ កសិករដែលមានជំនាញ បានត្រៀមលក្ខណៈដើម្បីដាក់អន្ទាក់យកសត្វ។ អន្ទាក់មានច្រើនប្រភេទ គឺអន្ទាក់សម្រាប់

---

១-ក្រុមស្រាវជ្រាវពុទ្ធសាសនបណ្ឌិត្យ បានជួបសម្ភាសន៍ជាមួយលោកតូ ឡុងយ៉េម អាយុ៥៦ឆ្នាំ និងអ៊ុម អូន អាយុ ៥៧ ឆ្នាំ នៅស្រុក គិរីវង្សខេត្តតាកែវ ដែលសុទ្ធតែជាអ្នកធ្លាប់មានជំនាញខាងការដាក់អន្ទាក់ព្រមទាំងបានបង្ហាញផ្ទាល់ដល់ព្រៃភ្នំឲ្យយើងបានឃើញជាក់ស្ដែង។

ម្រឹគមាន ឈ្លូស ប្រើស ក្តាន់ រមាំង ជ្រូកព្រៃ ខ្លា... និងអន្ទាក់សម្រាប់បក្សាបក្សីដូចជា មាន់ព្រៃ ក្ងោក ជាដើម ។

**អំពីការដាក់អន្ទាក់ម្រឹគ**

ដំបូង គេត្រូវកាប់កូនឈើតូចមែកមានបន្លា ដើមឫស្សីរៀបគរធ្វើជាសម្រាស់ ឲ្យបានឆ្ងាយប្រហែលជាមួយពាន់ម៉ែត្រ។ សម្រាស់ដែលផ្សំដោយមែកឈើ កូនឈើ និងឫស្សីនេះ ត្រូវគេដាក់គរ បង្កើតជាឧបសគ្គមិនឲ្យសត្វពារ ឬផ្លោះ រំលងបាន។ ក្នុងចន្លោះពីដប់ប្រាំទៅម្ភៃម៉ែត្រ គេទុកច្រកបញ្ចោតមួយទំហំប្រហែលមួយម៉ែត្រ ជាច្រកសម្រាប់ឲ្យសត្វចូល នៅពេលដែលវាជួបនឹងសម្រាស់មិនអាចទៅរួច ។

១ -អន្ទាក់ ក

អន្ទាក់ ក ជាប្រភេទអន្ទាក់ដែលព្រានដាក់ ហៃ ឲ្យមានកម្ពស់ស្មើនឹងកសត្វ[២]។ ខ្សែអន្ទាក់ច្រើនយកខ្សែល្អួសប្រហ៊ុងកង់ ឬប្រហ៊ុងម៉ូតូដែលជាប់ស្វិតមិនងាយដាច់ ហើយទន់រូសថែមទៀតផង។ ខ្សែអន្ទាក់មានកងក្រវិលសម្រាប់រូតរឹត យ៉ាងរហ័សនៅពេលដែលក្ជាត់គន្លឹះ។ នៅត្រង់កំណាត់ខ្សែក្បែរជើង គេចងកំណាត់ឫស្សីមួយតូចខ្លី ហើយម៉ាធ្វើជាកន្លាស់ខ្ទាស់ភ្ជាប់ទៅនឹងតម្កក់គន្លឹះសម្រាប់ឲ្យផ្ទោះ នៅពេលដែលមានអ្វីទាញតឹងទៅលើឆ្វេងជើង។ ចុងខ្សែអន្ទាក់ម្ខាង ត្រូវយកទៅចងនៅចុងដងអន្ទាក់។

ដងអន្ទាក់មានពីរយ៉ាងគឺ :

---

២- ឈ្លូស ប្រើស ក្តាន់ រមាំង ជ្រូកព្រៃ។ អន្ទាក់បែបនេះមិនសំដៅទៅលើខ្ទីង ទន្សោង ឬដំរីទេ។

*ក- ជងរស់*

*ខ- ជងងាប់*

ក-*ជងអន្ទាក់រស់* ជាដើមឈើរស់ មានទំហំ ធំជាងកំភួនជើង ប្រវែងប្រមាណបួន ឬប្រាំម៉ែត្រ។ ជាប្រភេទឈើដែលទន់អាចពត់បាន ហើយមិនងាយគ្រេចបាក់។ នៅពេលដាំឡើងអន្ទាក់ ព្រានត្រូវយិតទាញ យកចុងឈើនេះឲ្យទាបចុះមកដល់ក្រោម(ប៉ប្រះនឹងដី) រួចចងចុងខ្សែអន្ទាក់ នៅចុងឈើនេះ ដែលគេកាត់លួសមែកឲ្យអស់។ ពេលគេខ្ទាស់គន្លឹះរួច ហើយ ចុងជងនេះពត់កោងមកនៅជិតអន្ទាក់នោះ។ កាលណាសត្វស៊ក ក្បាលចូលក្នុងរង្វង់អន្ទាក់ ហើយធ្វើឲ្យភ្លាត់គន្លឹះនោះ ជងអន្ទាក់ក៏រាត់ឡើង ទៅលើយ៉ាងខ្លាំង ហើយហើសមើលមិនទាន់។ ក្នុងស្ថានភាពបែបនេះ សត្វត្រូវព្យួរ ក ហើបឡើងផុតពីដី ហើយនឹងដាច់ខ្យល់ស្លាប់ក្នុងរយៈ ពេលខ្លីបំផុត។ ប៉ុន្តែបើសត្វនោះមានទំហំធំ ហើយមានទម្ងន់ធ្ងន់ខ្លាំងនោះ ជងអន្ទាក់មិនអាចរាត់យោងសត្វឲ្យហើបជើងផុតពីដីបានឡើយ។ ក្នុង ករណីបែបនេះ សត្វត្រូវហើបជើងមុខបន្តិច ដែលជាហេតុពុំមានកម្លាំង គ្រប់គ្រាន់សម្រាប់ស្ទុះរើបម្រះឲ្យរបូត ឬដាច់ខ្សែអន្ទាក់រួចខ្លួនបាន ឡើយ។

ខ-*ជងអន្ទាក់ងាប់* ប្រសិនបើនៅទីជិតខាងនោះ ពុំមានឈើ សម្រាប់ធ្វើជាជងរស់នោះទេ គេត្រូវរកឈើមួយកំណាត់ ទំហំមុខកាត់ ខាងគល់ពី ពីរតឹក ទៅ ពីរតឹកកន្លះ ដែលមានប្រវែងពី បួនម៉ែត្រ ទៅ ប្រាំម៉ែត្រ។ នៅជិតច្រកដាក់អន្ទាក់នោះ គេយកឈើមានចម្ងាមមួយកំណាត់

ប្រវែងប្រហែលមួយម៉ែត្រកន្លះ មកជីកកប់ជម្រៅប្រាំពីរតឹកទៅក្នុងដី បង្អាប់ឲ្យរឹងណែនល្អ។ បន្ទាប់មកគេយកដងអន្ទាក់ឈើងាប់ ដាក់ខាងចុងមកគងលើចម្អាម ហើយយកចុងខ្សែអន្ទាក់ម្ខាងទៅចងភ្ជាប់នៅចុងដងអន្ទាក់នោះ។ គេទាញចុងដងអន្ទាក់នោះឲ្យងោកទាបមកជិតដល់ដី ធ្វើឲ្យគល់អន្ទាក់នោះ បះឡើងលើកម្ពស់ប្រហែលពីរម៉ែត្រ ឬពីរម៉ែត្រកន្លះ។ ដើម្បីឲ្យមានទម្ងន់ និងបង្កើនកម្លាំងវាត់ឲ្យបានខ្លាំងហើយរហ័ស គេយកថ្មមួយដុំធំល្មម ឬគល់ឈើមួយកំណាត់ ទៅចងផ្អោបត្រង់គល់ដងអន្ទាក់នោះ ដូចដងថ្លឹង[៣] នៅពេលសត្វជាប់ហើយរបោះគន្លឹះអន្ទាក់នោះ ដងអន្ទាក់ខាងគល់ក៏ធ្លាក់ចុះយ៉ាងរហ័ស។ រីឯផ្នែកខាងចុងដងអន្ទាក់ ក៏បះឡើង ធ្វើឲ្យខ្សែអន្ទាក់រួតរឹត ក សត្វ ហើយយួរហើបជើងពីដី ដាច់ខ្យល់ស្លាប់ក្លាមដូចគ្នានឹងដងអន្ទាក់ឈើរស់ដែរ។

២- អំពីអន្ទាក់ជើង

នៅក្នុងចំណោមអន្ទាក់ទាំងអស់ ដែលដាក់ជាជួរហូរហែតាមបណ្ដោយសម្រាស់នោះ ព្រានច្រើនដាក់ឆ្លាស់អន្ទាក់ ក មួយ និងអន្ទាក់ជើងមួយ។ ធ្វើបែបនេះសត្វអាចប្រឈមមុខនឹងគ្រោះថ្នាក់ពីរបែប គឺបើរួចខ្លួនពីអន្ទាក់ក វានឹងត្រូវជាប់ អន្ទាក់ជើង។ របៀបដាក់អន្ទាក់ជើងខុសប្លែកពីអន្ទាក់ក។ មុនដំបូងគេជីករណ្ដៅបួនជ្រុងទ្រវែង ទទឹងប្រវែងពីរតឹក បណ្ដោយបីតឹក។ នៅក្នុងរណ្ដៅនោះ មានថ្នៃដាក់អន្ទាក់គន្លឹះឲ្យក្លាត់

---

៣- នៅស្រុកខ្លុះ គេហៅថា អន្ទាក់ថ្លឹង។

កាលណាមានទម្ងន់អ្វីជាន់ទៅលើបន្ទះក្តារនោះ[៤]។ ដាក់គន្ទឹះរួចគេគ្របក្តារបំត្រង់រណ្តៅនោះ សម្រាប់បិទគន្ទឹះផង និងទុកសម្រាប់ឲ្យសត្វជាន់មកលើផង។ បន្ទាប់មកគេយកខ្សែអន្ទាក់ មកលាជារង្វង់ធំល្មម ដាក់ពីលើក្តារនោះ រួចយកចុងខ្សែអន្ទាក់ម្ខាងទៀតទៅចងនៅចុងដងរស់(ដងវ៉ាត់) ឬដងថ្នឹងនោះទៅ។ ធ្វើបែបនេះ កាលណាសត្វមកជាន់ត្រង់រង្វង់ រងក អន្ទាក់ដែលដាក់ពីលើក្តារនោះ ទម្ងន់សត្វធ្វើឲ្យប៉ោះគន្ទឹះ រួចហើយរង្វង់អន្ទាក់ដែលមានក្រវិល និងរូតរួបយ៉ាងរហ័សដូចផ្លេកបន្ទោររឹតជើងសត្វជាប់ ហើយត្រូវដងយោងវ៉ាត់យួរឡើងទៅលើ។ គប្បីជ្រាបថាអន្ទាក់ជើងមិនធ្វើឲ្យសត្វជាប់អន្ទាក់ងាប់ភ្លាមៗនោះទេ។ ពេលដែលជាប់ក្នុងអន្ទាក់បែបនេះ សត្វអាចបើបម្រះក្នុងអាកាសតែកតោកៗទាំងបន្ទឺ សម្រែកឈឺចាប់ និងកិតក័យឮសូររំពងព្រៃផង ។

**២_អំពីអន្ទាក់អន្ទប់**

ក្រៅពីអន្ទាក់ពីរប្រភេទដូចបានជម្រាបខាងលើ នៅមានអន្ទាក់ប្លែកមួយបែបទៀត ដែលគេតែងហៅថា“អន្ទាក់អន្ទប់”។ ដើម្បីដាក់អន្ទាក់ប្រភេទនេះ គេត្រូវរកឈើមួយកំណាត់ប្រវែងប្រមាណបួនម៉ែត្រ ឲ្យមានទម្ងន់យ៉ាងតិចណាស់ពីររយគីឡូក្រាម ដាក់គងបន្ទេរចន្លោះបង្គោលឈើពីរនៅអមសង្ខាងច្រកដាក់អន្ទាក់។ នៅខាងក្រោម ជាប់នឹងដីក៏មានឈើមួយកំណាត់ដែរ ដាក់ទទឹងច្រកចេញចូលផងដែរ។ តែឈើនេះមានទំហំតូចល្មម (មុខកាត់ពីរតឹក) នៅត្រង់ច្រកនោះ គេដាក់គន្ទឹះមួយទាក់ទង

៤-ទម្ងន់ចាប់ពី ប្រាំគីឡូក្រាមឡើងទៅ។

ទៅទីងអន្ទប់ខាងលើ។ កាលណាសត្វមកពារលើគន្ទឹះខាងក្រោមធ្វើគន្ទឹះនេះឲ្យភ្លាត់នោះ ឈើអន្ទប់ធំខាងលើនឹងធ្លាក់យ៉ាងរហ័សបំផុតមកសង្កត់លើសត្វបាក់ខ្នង បាក់ក ស្លាប់ភ្លាមនៅនឹងកន្លែង។

### ៣_អំពីបង្កាត់[៥]

បង្កាត់ជាប្រភេទអន្ទាក់មួយ៉ាង ធ្វើអំពីសរសៃក្រចៅ ឬធ្មៃស្វិតជាប់ល្អ។ គេវេងក្រងវាបៀបជាក្រឡាអង្រឹងដែរ ប៉ុន្តែបង្កាត់មានប្រវែងទទឹងនិងបណ្តោយវែងជាងអង្រឹង (ទំហំ: កម្ពស់ពីរម៉ែត្រ បណ្តោយពីរម៉ែត្រកន្លះ ឬបីម៉ែត្រ) ចងសន្ធឹងនៅចំមាត់ច្រកសម្រាប់ទុកឲ្យសត្វចេញចូល។ នៅចុងបង្កាត់ទាំងសង្ខាង មានក្រវិលសម្រាប់រូតរូបខ្លោបសត្វដែលចូលមកក្នុងបង្កាត់ តាមបណ្តោយខ្សែ ដែលចងសន្ធឹងទៅភ្ជាប់នឹងបង្គោលយ៉ាងមាំនៅអមសង្ខាងច្រកនោះដើម្បីកុំឲ្យសត្វរបែម្រះរួច។ ប៉ុន្តែបង្កាត់មិនមែនដាក់ត្រាំត្រែង ជាអចិន្ត្រៃយ៍ដូចអន្ទាក់ឡើយ។ គេដាក់វាម្តងម្កាលនៅពេលដែលគេដេញល្បើកសត្វតែប៉ុណ្ណោះ។

#### *១- អំពីការល្បើកសត្វ[៦]*

មុនដំបូងព្រានទាំងឡាយ ដែលមានគ្នា ម្តៃ ឬសាមសិបនាក់ត្រូវដំឡើងបង្កាត់ឲ្យបានមុនទុកជាស្រេច។ បើគេមានបង្កាត់ច្រើនអាចលាតសន្ធឹងអស់ដីតាមបណ្តោយភ្នំនោះ កាន់តែប្រសើរថែមទៀត។ តាមធម្មតាគេតែងដំឡើងបង្កាត់នៅត្រង់ចន្លោះសម្រាស់ គឺនៅត្រង់កន្លែងច្រក

---

៥- ដូចជាបន្ទឹងមួយយ៉ាងធំដូច្នោះឯង។

៦- ការដេញបន្លើលសត្វព្រៃឲ្យរត់ទៅចំអន្ទាក់ ឬបង្កាត់ដែលគេដាក់ត្រៀមទុក ឲ្យជាប់សត្វ។

ដាក់អន្ទាក់នោះឯង។ កាលណាដំឡើងរួចសព្វគ្រប់ហើយ គេចាត់គ្នាជាពីរក្រុមៈ

ក-ក្រុមទីមួយ ហៅថាក្រុមល្បែក មានគ្នាយ៉ាងតិចម្ភៃនាក់ ប្រដាប់ដោយកាំបិតផ្គាក់ ពូថៅ ឬលំពែង ព្រមទាំងមានខ្លែទៀតផង។ ក្រុមនេះមានភារកិច្ចដើរគ្រាសតាមបណ្តោយភ្នំ ចាប់ពីកំពូលភ្នំចុះមកជើងភ្នំ ហើយត្រូវស្រែកបង្អើលសត្វ ដោយគោះគល់ឈើ ព្រមជាមួយទីងសម្លេងខ្លែកោះលាន់ឮរំពងពេញព្រៃ។ អាស្រ័យ ដោយសម្លេងទ្រហឹងអឺងអាប់ទាំងនេះ សត្វទីងផ្អើលរត់ត្រោះទៅកាន់ទិសមួយផុយពីកន្លែងដែលបន្លឺសម្លេង ពោលគឺរត់ចុះមកក្រោមសំដៅជំនីរភ្នំប៉ែកខាងក្រោម។

ខ-ក្រុមទីពីរ ហៅថាក្រុមឆ្មាំ មានគ្នាតិច ឬច្រើនទៅតាមចំនួនបង្កាត់។ គេតែងចាត់ឆ្មាំម្នាក់ ឲ្យឃ្លាំមើលបីទៅបួនបង្កាត់។ បើគេមានគ្នាច្រើន គេអាចចាត់ឆ្មាំម្នាក់ឲ្យមើលបង្កាត់ពីរ។ ពួកឆ្មាំទាំងនេះ ត្រូវតែជាមនុស្សប៉ិនប្រសប់ ក្លាហាន មិនញញើតក្នុងការតស៊ូប្រយុទ្ធប្រហារសត្វនោះឡើយ។ គេមានពូថៅកាំបិតផ្គាក់ និងលំពែងជាអាវុធដ៏សំខាន់។ ពួកឆ្មាំលាក់ខ្លួន ពួនអាត្មាយ៉ាងស្ងៀមស្ងាត់ នៅទីក្បែរៗបង្កាត់ រង់ចាំមើលហេតុការណ៍ ដែលនឹងមកដល់។

## ២- សកម្មភាពល្បែកសត្វ និងប្រហារសត្វ

ក្រុមល្បែកស្រែកវ៉ូវហ៊ាសផង គោះគល់ឈើខ្លាំងៗផង ពន្យុះបង្អើឲ្យខ្លែកោះលាន់ឮទ្រហឹងពេញព្រៃ ហើយនាំគ្នាដើរលៃល្បឿនតិចៗស្មើៗគ្នាពីចុងខ្សែម្ខាងទៅចុងខ្សែម្ខាងទៀត។ ពេលនោះ សត្វជ្រូកព្រៃ

ក្ដាន់ ប្រើស ឈ្លូស... ផ្អើលភិតភ័យ រត់ចុះមកខាងក្រោមតាមជម្រាលភ្នំ ព្រោះខ្លាចមានគ្រោះអន្តរាយដល់ជីវិត។ កាលបើឃើញចន្លោះប្រកត្រង់ណាអាចរត់ទៅមុខបាន វាទីងស្ទុះទៅតាមនោះ ពុំមានគិតពិចារណាអ្វីឡើយ។ ប្រសិនបើពិនិត្យឃើញសត្វរត់នៅចំពោះមុខខ្លួន ពួកល្បើកស្រែកប្រកួកប្រាប់គ្នីគ្នាឲ្យបានដឹង។ ឧបមាថាបើគេឃើញជ្រូកព្រៃគេទីងស្រែកប្រាប់ពួកគេថា "ជ្រូកទៅហើយរើយធំណាស់! អ្នកឆ្មាំខាងក្រោមប្រុង!" យ៉ាងនេះជាដើម។ សម្រែកឲ្យដំណឹងបែបនេះ ត្រូវបានស្ដាប់ឮទាំងអ្នកល្បើកទាំងឆ្មាំគ្រប់គ្នា។ ឮដូច្នេះហើយពួកឆ្មាំ ខំប្រុងខ្លួនភ្នែករំពៃសម្លឹងមើលបង្កាត់ ក្រែងមានសត្វចូលមកជាប់។ សត្វដែលផ្អើលនឹងសម្រែក ស្ទុះរត់ចុះមកខាងក្រោមតាមជម្រាលភ្នំ។ ដោយក្ដីភិតភ័យហួសប្រមាណ វាពុំមានពេលពិនិត្យមើលបង្កាត់ដែលសន្ទឹងរង់ចាំទទួលវានោះឡើយ។ ទីបំផុតវាក៏ស្ទុះចូលទៅជាប់ក្នុងសំណាញ់បង្កាត់ត្រូវក្ដោបរឹតរូបជាប់រមួ រើបម្រះពុំរួចឡើយ។ ទោះបីវាខំរើបម្រះយ៉ាងណា ក៏ខ្សែរនេងយ៉ាងមាំនោះមិនដាច់ដែរ។ លុះឃើញដូច្នោះ ឆ្មាំដែលទទួលបន្ទុកត្រង់នោះ ក៏ស្រែកប្រាប់គ្នាថា "ជាប់ហើយៗ ជាប់ហើយៗ ប្រើសធំណាស់ៗ ឬជ្រូកធំណាស់ៗ[៧]"។ ស្រែកហើយរត់យ៉ាងលឿនទៅរកទីដែលសត្វជាប់បង្កាត់ ឆ្មាំក៏ប្រហារសត្វនឹងពូថៅឲ្យស្លាប់នៅក្នុងសំណាញ់បង្កាត់។ បើជាជ្រូកព្រៃ ហើយមានមាឌធំផងនោះ ឆ្មាំមិនសូវហ៊ានប្រើពូថៅសម្រាប់ប្រហារ

---

៧-ស្រែកប្រាប់ឈ្មោះសត្វណាដែលមកជាប់បង្កាត់។

ទេ គេត្រូវចាក់សម្លាប់ជ្រូកទីងលំពែងត្រង់កន្លែងជាន់ឡើង[៨]។ ក្នុងពេលល្បើកសត្វមួយលើកៗ អាចបានសត្វរហូតបីឬប្រាំក្បាល។ បន្តិចក្រោយមកពួកអ្នកល្បើកក៏មកដល់តាមសំឡេងស្នែងផ្លុំបង្គកជាសញ្ញា ត្រង់កន្លែងណាដែលមានសត្វជាប់បង្កាត់។ សូមជម្រាបថា ក្នុងមួយថ្ងៃគេដេញសត្វតែមួយលើកប៉ុណ្ណោះ ទោះបានក្តី មិនបានក្តី។ កាលណាមានសត្វជាប់បង្កាត់ ហើយក្រោយពីបានមកជួបជុំគ្នាហើយនោះ គេនាំគ្នាដោះសត្វយកចេញពីបង្កាត់ នាំគ្នាសែងចុះមកជើងភ្នំ ឆ្ពោះទៅរកទីណាដែលមានទឹក ទីងបានវះសត្វចែកសាច់គ្នា[៩] ឲ្យបានគ្រប់តាមចំនួនអ្នកដេញសត្វ។

**៤_សន្និដ្ឋាន**

*១-ប្រយោជន៍នៃការដេញសត្វ ឬការដាក់អន្ទាក់*

នេះគឺជាល្បែងកម្សាន្តនៅពេលទំនេរ ជាកីឡាធ្វើឲ្យស្មារតី និងរាងកាយមាំមួន រឹងរ៉ៃ ហើយម្យ៉ាងទៀតវាជាការស្វែងរកសាច់ ស្បែក ស្នែង ចង្កូម ខ្នាយ លក់សម្រាប់ផ្គត់ផ្គង់ដល់សេដ្ឋកិច្ចគ្រួសារ។ ការចាប់សត្វ តាមរបៀបនេះ មិនចូលជាបទបំផ្លិចបំផ្លាញសត្វឲ្យវិនាសផុតពូជនោះឡើយ ព្រោះព្រានទាំងនេះ ប្រើតែឧបករណ៍បុរាណចាប់សត្វបានបន្តិចបន្តួចប៉ុណ្ណោះ។

---

៨-ត្រង់ក្លៀកសត្វ ព្រោះស្បែកត្រង់កន្លែងនេះ ស្តើងហើយផុយជាងកន្លែងផ្សេងៗទៀត។

៩-ចាស់បុរាណពីដើម និយមឲ្យតម្លៃខ្ពស់ទៅអ្នកឆ្នាំណា ដែលបានប្រហារសត្វស្លាប់មុនគេ។ ក្រៅពីបានចំណែកសាច់ស្មើនឹងអ្នកឯទៀតនោះ អ្នកដៃដល់ នឹងបានទទួលក្បាលសត្វ នោះជារង្វាន់កិត្តិយសថែមទៀត។

*២- សត្វជាធនធានធម្មជាតិ*

*សត្វព្រៃគ្រប់ប្រភេទ វាជាធនធានធម្មជាតិដ៏មានតម្លៃ។ ក្រៅពីនេះព្រៃព្រឹក្សា ដែលពោរពេញទៅដោយសត្វម្រឹគីម្រឹគាគ្រប់យ៉ាង គឺជាលម្អបិដ្ឋានធម្មជាតិ ធ្វើឲ្យធម្មជាតិមានសម្រស់ព្រមទាំងលំនឹង។*

*៣-ការងារអភិរក្សសត្វព្រៃ*

*ព្រៃហិនហោចរេចរិល ដោយការកាប់បំផ្លាញ ម្រឹគីម្រឹគា នឹងខ្វះទីជម្រក ហើយគេចរត់ទៅរកទីដទៃ ដែលនៅជិតខាងដែលផ្ដល់នូវអំណោយផលល្អសម្រាប់ជីវិតវា។ ដឹងពីប្រការនេះហើយ គួរយើងមានវិធានការទប់ស្កាត់ការបំផ្លាញព្រៃឈើ និងការបំផ្លាញសត្វព្រៃ ដើម្បីជាការរួមចំណែកអភិរក្សវាឲ្យបានគង់វង្សតទៅ។*

*ប្រាំបួនទ័ល ដប់ទ័ល*
*កុំឲ្យតែទ័លគំនិត។*

*សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក*
*គណៈមហានិកាយ ជួន ណាត ជោតញ្ញាណោ*

# ប្រវត្តិភូមិបឹងចារ

ដោយ **ហ៊ុល សឿន**



*លោក ហ៊ុល សឿន មេឃុំបឹងចារ ស្រុកសំបូរ ជាអ្នកផ្តល់ព័ត៌មាន*

ភូមិបឹងចារ ជាភូមិមួយដែលមានប្រវត្តិតំណាលតៗគ្នារបស់ចាស់ទុំក្នុងភូមិប្រាប់ដល់កូនចៅតជំនាន់ បានតំណាលថា៖ " មានគ្រាមួយនោះ ស្រុកខ្មែរយើងមានកលយុគកើតសង្គ្រាមវឹកវរ ច្បាំងគ្នាជាមួយសត្រូវមកពីក្រៅដែលនៅក្នុងពេលនោះ ព្រះរាជាខ្មែរយើងទ្រង់តាំងព្រះរាជធានីនៅតំបន់កណ្តាលនៅក្នុងខេត្តកំពង់ធំៗ ដោយព្រះអង្គមានព្រះទ័យភ័យព្រួយយ៉ាងខ្លាំង ចំពោះទុក្ខលំបាករបស់ប្រជានុរាស្ត្រពីសភាពការណ៍អសន្តិសុខរបស់ប្រទេស នៅក្នុងពេលដែលកំពុងប្រឈមមុខនឹងសឹកសង្គ្រាមនេះ ទើបព្រះអង្គទ្រង់ឈ្វេងយល់ត្រាស់

បង្គាប់ឲ្យពលសេនាអាមាត្យមួយផ្នែក ដែលដឹកនាំដោយឧបរាជឈ្មោះ "ម៉ឺនកែវ"(សព្វថ្ងៃមានអូរមួយនៅខាងលើឃ្លួងចាប់ឆ្ពោតជាប់នឹងភូមិកំពង់ដីមានឈ្មោះហៅថា អូរម៉ឺនកែវហូតមក ) ជាអ្នកដឹកនាំឲ្យមករៀបចំជាព្រះរាជដំណាក់សម្រាប់ក្សត្រ និងប្រជារាស្ត្រជម្លៀសមកជ្រកពួនទៅ ដើម្បីជៀសឲ្យផុតពីសឹកសង្គ្រាមដ៏ឃោរឃៅនេះៗ ប៉ុន្តែជាជំហាននៃការរៀបចំដំបូង លោកឧបរាជ បាននាំពលរេហ៍រៀបចំកន្លែងមួយជាបណ្ដោះអាសន្ននៅភ្នំមួយដែលស្ថិតនៅចុងអូរជាំ ខាងជើងព្រះរាជដំណាក់នេះៗ ទីនោះគេនាំគ្នាហៅថា" ភ្នំទាងកងវិញ "ៗ

ជាបន្តមកទៀត លោកឧបរាជបានបញ្ជាឲ្យពលសេនាអាមាត្យ ដើរជ្រើសរើសរកកន្លែងដែលសមស្រប និងមានលក្ខណៈល្អប្រសើរ ធានាសន្តិសុខជាងដំណាក់ទីមួយនេះ ដើម្បីការទប់ទល់នឹងភាពកលយុគវិកវដ៏ធំនេះៗ ពេលនោះ លោកឧបរាជ និងពលសេនាបានពិនិត្យឃើញទីកន្លែងមួយដែលស្ថិតនៅជាប់មាត់ទន្លេមេគង្គតែម្ដងទីនោះគឺម្តុំភូមិបឹងចារសព្វថ្ងៃនេះឯងៗ ទីនោះមានលក្ខណៈភូមិសាស្ត្រល្អ និងមានលក្ខណៈជាយុទ្ធសាស្ត្រ សម្រាប់ការពារទប់ទល់នឹងសង្គ្រាមទៀតផង ដោយនៅទីនោះមានកោះជាច្រើន ដុះបន្តជាប់គ្នាដែលមានដូចជា កោះភួង កោះព្រាង កោះរង៉ាវ កោះត្បាល់ ។ល។ នៅក្នុងរដូវប្រាំង នៅទីនោះមានវាលលំហដែលនៅពេលទឹកទន្លេស្រកផុតទៅ បានបន្សល់ទុកនូវដុំថ្មតូចធំរកេតរកូត ព្រមទាំងរុក្ខជាតិដែលមាននៅក្នុងទន្លេដូចជា ដើមរាំង ស្រូល ទន្លា អញ្ចែង និងអញ្ចេះ។ល។

ផ្ទះពាសពេញដាច់កន្ទុយក្អែកៗ

ដោយសារទីនេះមានលក្ខណៈល្អប្រសើរយ៉ាងនេះហើយទើប លោកឧបរាជ ទទួលបានទូវការសព្វព្រះរាជហឫទ័យអំពីព្រះរាជា ឲ្យកសាងព្រះរាជដំណាក់នៅទីនេះ ដោយឲ្យសង់ជាព្រះពន្លានិងផ្ទះសសរមួយ ដែលគ្រាមភាសាហៅថា "ជ្រោល" ឯរាជសព្ទហៅថា "បញ្ជរ" សម្រាប់ជាព្រះរាជដំណាក់របស់ព្រះមហាក្សត្រ ព្រមទាំងព្រះរាជវង្សានុវង្សៗ ប៉ុន្តែព្រះនាមពិតនៃព្រះមហាក្សត្រនៅពេលនោះ ចាស់ទុំក៏ពុំបាននិយាយប្រាប់ថាមានព្រះនាមពិតអ្វីដែរ ដោយពួកគាត់ហៅតែ "ហ្លួងៗ" តគ្នាមកប៉ុណ្ណោះៗ លុះតំណតមកពាក្យ "បញ្ជរ" នេះក៏បានក្លាយជាពាក្យថា " បឹងចារ " រហូតរៀងមកៗ

ភូមិបឹងចារ សព្វថ្ងៃស្ថិតនៅជាភូមិឧបសម្ព័ន្ធនៃភូមិរដ្ឋបាលដំរ៉ែ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះៗ ភូមិបឹងចារនេះត្រូវបានប្រជាពលរដ្ឋបោះបង់ចោល តាំងតែពីឆ្នាំ១៩៧៩មកម្ល៉េះ ដោយសារសង្គ្រាម ហើយនៅក្នុងដើមឆ្នាំ១៩៩៦ ប្រជាពលរដ្ឋដែលធ្លាប់រស់នៅទីនោះពីមុន ក៏បានប្រថុយប្រថានតុះតាវត្រឡប់ទៅរស់នៅវិញរហូតមកដល់ពេលសព្វថ្ងៃៗ

បច្ចុប្បន្ន ក្នុងភូមិនេះមានប្រជាជនរស់នៅ៤៤ គ្រួសារនៅក្នុងផ្ទះ៣៦ខ្នង គិតជាចំនួនមនុស្សសរុបមាន២១៧នាក់ ដែលមាន១០២នាក់ជាស្ត្រីៗ នៅក្នុងភូមិ មានសាលារៀនមួយខ្នងប្រក់ស្បូវដែលកសាងនៅក្នុងរដូវប្រាំងឆ្នាំ២០០២ កន្លងទៅនេះៗ

## សក្ដានុពលសេដ្ឋកិច្ច និងអំណោយធានធម្មជាតិ

*ភូមិបឹងចារ មានបណ្ដោយប្រវែង៣៥០០ម៉ែត្រក្នុងនោះមានដីស្រែចំនួន១៨ហិកតា ដីចំការចំនួន២៤ហិកតា និងដីសម្រាប់គាស់កនជាដីស្រែថ្មីជាច្រើនហិកតាទៀត ដែលដីខ្លះនៅមុនឆ្នាំ១៩៧៥ជាដីស្រែតែបច្ចុប្បន្នបានកើតជាដីព្រៃអស់ទៅហើយ។ នៅក្នុងភូមិ មានអូរសំខាន់ៗបីគឺ អូរខ្ទឹម អូរបឹងចារ និងអូរជាំ ដែលជាប្រភពទឹកសម្រាប់ប្រជាពលរដ្ឋរស់នៅធ្វើស្រែចំការ និងប្រើប្រាស់។ ក្រៅពីនោះភូមិមានផ្លូវគមនាគមន៍ពីរគឺផ្លូវគោក និងផ្លូវទឹក។ ផ្លូវគោក មានផ្លូវរទេះ ដែលតភ្ជាប់រហូតដល់ភូមិកំពង់ក្បៀង។ រីឯផ្លូវទឹក គឺទន្លេមេគង្គ ដែលប្រជាពលរដ្ឋអាចធ្វើដំណើរឆ្លងកាត់បានទាំងខែប្រាំង និងខែវស្សា ដោយមធ្យោបាយ ទូក កាណូត ឬទូកចែវ។*

### ព្រំប្រទល់ភូមិ

*ភូមិ មានព្រំប្រទល់ខាងជើងទល់នឹងភូមិកំពង់ដីរ។ ខាងត្បូងទល់នឹងឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។ ព្រំប្រទល់ខាងកើតទល់នឹងភូមិអូរក្រសាំង។ ខាងលិច ទល់នឹងខេត្តកំពង់ធំ។*

# ឆៃយ៉ាំភូមិខ្ញុំ

*(បទពាក្យប្រាំពីរ)*

*ដោយ* **ខៀវ បញ្ញារុន្ឋ**

១-ភ្លេកចុងស្រូវ ទេរមេញ នៅភូមិជើងទេញ[១]កំណើតខ្ញុំ
ផ្ទះមានសណ្ដាប់ មូលត្រសុំ រៀងតាមជើងភ្នំ ទិសទក្សិណ ។

២-ខ្យល់ពីឧត្តរអេបខ្ចិនស្រូវ ស្រណោះរដូវ បុណ្យកឋិន
ពាក់អាវសទួះ ស្លៀកចងក្បិន ហែអង្គកឋិន តាមទំនៀម ។

៣-ឆៃយ៉ាំស្គរប្រាំ លាន់សន្ធាប់ បន្ទរវៀបរាប់ នៅមិនស្ងៀម
កុងម៉ុង[២] និងឆាប[៣]ដែលទាក់ទាម ហ្វូងសេករាំម ផ្អើលពេញមេឃ ។

៤-តាមផ្លូវទៅវត្ត មនុស្សកុះករ ស្លៀកចម្រុះពណ៌ ល្អពន់ពេក
ឡូញ់ ហូល ផាមួង ព្រៃភ្លឺផ្នែក អារម្មណ៍សែនត្រេក-ត្រអាលក្រៃ។

---

១-ភូមិជើងទេញស្ថិតនៅតាមជើងភ្នំជើងទេញ ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។
២-កុងម៉ុង: គ្រឿងភ្លេងសម្រាប់គោះឲ្យចង្វាក់ភ្លេងរាងដូចផ្ទៃទោត។
៣-ឆាប : គ្រឿងភ្លេងមួយប្រភេទសម្រាប់ចាប់ទង្គិចបញ្ចើតតាមចង្វាក់ភ្លេង។

៥-តែឃ្មុំក្មួមខ្មុំ សួរពីកេះ    ល្បីល្បាញកេរ្តិ៍ឈ្មោះ មានតម្លៃ
ទំនេរគេសម ទាំងយប់ ថ្ងៃ    ម្ល៉ោះហើយទឹកដៃ ពិបាកផ្ទឹម ។

៦-ពូណៃ គ្រូភ្លេង ផ្ទះក្បែរវត្ត    ចេះចាំយ៉ាងស្ទាត់ ពីតាទឹម
សូម្បីចាប៉ី តាខេ ឃឹម    ខ្សែដៀវ ស្តរគ្រឹម[៤]ក៏លេងបាន ។

៧-តាទៀង ជាជាង ធ្វើឧបករណ៍    ទឹកដៃគាត់ល្អ ស្តរចំណាន
សូរស្តរឆ្លើយគ្នា គួរតាមដាន ស្តាប់ទៅពីរោះ ខានគិតផ្សេង។

៨-តាផ្ត[៥]វត្តខ្ញុំ លើភ្នំខ្ពស់    មានរូង មានជ្រោះ មានសម្លេង[៦]
លំអដោយដើម គគោះបេង    មានព្រៃ ម៉ាក់ប្រេង ទ្រៀល ស្តុកស្តុ[៧]។

៩-ឡើងដល់ទីវត្ត អារម្មណ៍ថា    ជិតជាប់នាសា បុប្ផាថ្កុល
ជណ្តើរស្ទោ[៨]កោងតោង ដើមគុល[៩]    ផ្ទឹកដុះជិតខ្នុរ ក្បែរកា ។

---

៤-ស្តរគ្រឹម : សំដៅទៅលើស្គរយីកេ។
៥-តាផ្ត : ឈ្មោះភ្នំ និងវត្តដែលអ្នកស្រុកហៅ។ ការពិតភ្នំនិងវត្តនោះឈ្មោះភ្នំអធិបតី ឬវត្ត ភ្នំអធិបតី។
៦-មានសម្លេង : សម្លេងទឹក សម្លេងខ្យល់បក់ប៉ះស្លឹកឈើ, សម្លេងបក្សាបក្សី។
៧-ស្តុកស្តុ : ជាឈ្មោះដើមឈើមួយប្រភេទ។
៨-ជណ្តើរស្ទោ : វល្លិ៍ជណ្តើរស្ទោ ជាវល្លិ៍ដែលមានសណ្ឋានដូចកាំជណ្តើរ។
៩-គុល : ឈ្មោះដើមឈើមួយប្រភេទដែលមានសណ្ឋានប្រហែលនឹងថ្កូវសាច់ដើមលឿងដូចខ្នុរ។

១០-វិហារប្រទៀន ល្អម៉្លេះទេ កេរជូនតាខ្មែរ ថែរក្សា
បំណងលើកស្ទួយ ពុទ្ធសាសនា តាមព្រះសាស្តា លោកប្រដៅ ។

១១-ប៊ីជុំ ជង្គៃ ប្រទក្សិណ ទូលត្រៃ ហូល ក្បិន ក្រហមខ្មៅ
តា ជូន មីងមា សន្តានផៅ ឈរតៀប មុខថ្លូវ ចូលវិហារ ។

១២-ឯយ៉ាំកូមិខ្ញុំ ប្រគុំថ្កុំ ដើតជើង គោះ ជំ ទាំងអស់គ្នា
ខាំស្គរគ្រវី ស្មើចអស្ចារ្យ ដូចអសុរ បញ្ចេញឫទ្ធិ ។

១៣-អ្នកមើលខ្លះ ប្រឹង រឹងទាំងខ្លួន ខ្លះទៀតអង្រួន អ្នកឈរជិត
ខ្លះហើរសប្បាយ លោតក្មេចគិត ភ្ញាត់ជើងជួលពិតអ្នកកាន់ក្លស់ ។

១៤-ចាស់ៗខ្លះញញឹម ដាក់គ្នា ក្រមុំអំពៀរ[១០]ក្បែរកម្លោះ
ឯយ៉ាំប្រគុំ ច្រៀង ផ្គងផ្គោះ អារម្មណ៍ហើរហោះ តាមលំអាន ។

១៥-ឯយ៉ាំកូមិខ្ញុំ មានទំនៀម ទម្លាប់ព្យាយាម ពីបុកណា
ជាប្រពៃណី ដ៏ថ្កើនថ្កាន អត្តសញ្ញាណ បានរក្សា ៕

---

១០-អំពៀរ :ដើរសៀសៀរគន់មើលម្តងៗ។

# សុន្ទរកថា

ព្រះតេជគុណ ឧទុគម ស្រី ធម្មាកិ្ខត
មហានាយកថេរ នៃគណៈអសតីរយ នៃស៊ុយហាបាម មហានិកាយ

សូមសម្ដែងអភិវន្ទន៍កិច្ចចំពោះ

-ព្រះតេជគុណ ប្រធានសន្និសីទកំពូលពុទ្ធសាសនា
-ព្រះតេជគុណ អគ្គលេខាធិការ
-មន្ត្រីការិយាល័យទាំងឡាយ
-គណៈសង្ឃ
-មន្ត្រីរដ្ឋាភិបាល
-ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ
-អស់លោក លោកស្រី នៃនិកាយសាសនាផ្សេងៗ ជាទីមេត្រី!

ចូរយើងទាំងអស់គ្នាឧទ្ទិសខ្លួន ចំពោះការកិច្ច កសាងពិភពលោកមួយដែលនឹងឲ្យតម្លៃលើក្រមសីលធម៌ព្រះពុទ្ធសាសនា ទទួមនឹងការផ្សព្វផ្សាយខ្លឹមសារធម៌របស់ព្រះពុទ្ធពាសពេញពិភពលោកៗ

សូមសត្វលោកទាំងអស់មានសេចក្ដីសុខសប្បាយ!

ខ្ញុំព្រះករុណា-អាត្មាភាពមានបីតិសោមនស្សក្រៃលែងដែលបានថ្លែងសុន្ទរកថា នៅក្នុងសន្និសីទកំពូលព្រះពុទ្ធសាសនាលើកទីបីជាមួយនឹងគំនិតដ៏ប្រសើរថា សត្វលោកសម្រេចបាន សេចក្ដីសុខ

ដោយប្រតិបត្តិនូវលទ្ធិពិតរបស់ព្រះតថាគត ដែលផ្តោតជុំវិញមនុស្ស និងដែលគ្មានទិដ្ឋភាពស្តីពីការបង្កើតលោកឡើយ។ ខ្ញុំព្រះករុណាអាត្មាភាពមានសេចក្តីប្រាថ្នាដ៏ពុះកញ្ជ្រោល សូមឲ្យកម្លាំង និងឥទ្ធិពលនៃសាវ័ករបស់ព្រះពុទ្ធផ្សព្វផ្សាយទៅកាន់ទីឆ្ងាយ និងទូលំទូលាយ។

ជាដំបូង សូមយើងផ្តោតអារម្មណ៍ទៅលើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហើយពិនិត្យមើលឲ្យស្របតាមកំណើតជាតិរបស់យើងជាមនុស្សនូវសារសំខាន់នៃកំណើតបែបនេះរបៀបរស់នៅរបស់មនុស្ស និងតម្លៃនៃព្រះធម៌របស់ព្រះតថាគត នៅក្នុងពិភពលោកសព្វថ្ងៃនេះ។ ដូចគ្នានេះដែរ ការទទួលយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាលទ្ធិមួយដែលមានលក្ខណៈជាសកល និងជាពាក្យប្រៀនប្រដៅមួយដែលបង្ហាញនូវរបៀបរស់នៅដ៏សមរម្យបំផុតនោះ សូមយើងទាំងអស់គ្នាពិនិត្យមើលវិធី និងមធ្យោបាយនានានៃការលើកស្ទួយកម្លាំង និងការបង្កើនអានុភាព និងឥទ្ធិពលរបស់យើង ហើយថាតើយើងគួរដើរតួយ៉ាងណាក្នុងសម័យទំនើបនេះ។

ព្រះពុទ្ធទ្រង់ត្រាស់ទេសនា អំពីប្រធានបទដ៏កម្របំផុត និងបញ្ហាដ៏លំបាកមួយចំនួន។ ក្នុងនាមជាមនុស្ស ដែលបានកើតមកលើផែនដីនេះ យើងត្រូវតែស្វែងរកឲ្យឃើញថា តើប្រធានបទទាំងនោះគឺជាអ្វី? ពេលនោះយើងនឹងអាចយល់នូវបញ្ហាទាំងអស់នោះ ដែលជំពាក់ទាក់ទងទៅនឹងជីវិតមនុស្សយើងម្នាក់ៗ។

ដូចមានសម្តែងក្នុងគម្ពីរធម្មបទថេរវាទ ខ្ញុំព្រះករុណា-អាត្មា

កាព សូមលើកយកវត្ថុ ត្រ បីយ៉ាងមកសម្តែងជូនជាទិសណ្ឋាប់ ដូចតទៅ:

១-ក្រ ទីងបានកើតជាមនុស្ស (កិច្ឆោ មនុស្សប្បដិលាភោ)

២-ក្រ ទីងចិញ្ចឹមជីវិតជាមនុស្ស (កិច្ឆំ មច្ចាន ជីវិតំ)

៣-ក្រ ទីងបានឱកាសស្តាប់ព្រះសទ្ធម្មរបស់ព្រះអរិយបុគ្គល (កិច្ឆំ សទ្ធម្មសវនំ)។

ប្រយោគទីមួយ អធិប្បាយយ៉ាងច្បាស់លាស់អំពីចលភាព មហន្តភាព និងខ្លឹមសារនៃភាពជាមនុស្ស។ យើងគ្រប់គ្នាមានវាសនាណាស់ដែលបានកើតជាមនុស្ស។ ព្រះពុទ្ធទ្រង់ត្រាស់ថាមានតែមនុស្សប៉ុណ្ណោះដែលអាចសម្រេចបានសេចក្តីបរិសុទ្ធផ្លូវចិត្ត និងមានគុណសម្បត្តិទាំងឡាយដូចជា:

មេត្តា : ចិត្តអាណិតស្រឡាញ់ មនុស្សសត្វទាំងឡាយដោយមិនប្រកាន់។

ករុណា : ចិត្តសន្តោសប្រណី ដល់មនុស្សសត្វទាំងអស់ នៅពេលគេខ្វះខាត ហើយជួយឲ្យពួកគេបានរួចចាកទុក្ខ។

មុទិតា : សមានចិត្ត ឬការអបអរសាទរ នៅពេលដែលអ្នកដទៃបានរុងរឿង និងជោគជ័យ។

ឧបេក្ខា : សម្លឹងមើលបញ្ហាទាំងឡាយដោយមិនលម្អៀងដោយមិនស្រឡាញ់ ឬស្អប់ ហើយឧំបណ្តុះធម៌ខន្តី។

មានតែមនុស្សប៉ុណ្ណោះ ដែលអាចមានគុណសម្បត្តិផ្សេងៗ

ទាំងនេះ និងរក្សាស្ថានភាពផ្លូវចិត្តដែលចម្រើនជាពិសេសនេះបាន។

ជាថ្មីម្តងទៀតមានតែមនុស្សហ្នឹងហើយ ដែលអាចទទួលបាន ឋានៈមានញាណសតិដ៏ខ្ពង់ខ្ពស់មួយដោយអាចកំណត់និងយល់នូវរឿងរ៉ាវផ្សេងៗ (សញ្ញា) ដឹងរឿងរ៉ាវទាំងឡាយច្បាស់ ហើយអាចសង្កេតតាមដាន(វិញ្ញាណ) និងមានញាណសតិ ដែលមានសមត្ថភាពដឹង ស្គាល់វត្ថុទាំងឡាយនៅក្នុងទិដ្ឋភាពពិតរបស់វា (បញ្ញា)។ ដូច្នេះវាមិនពិបាកទាល់តែសោះថា គឺមានតែមនុស្សប៉ុណ្ណោះដែលអាចមាននិងចាក់ធ្លុះបញ្ហាទាំងឡាយដែលបានពោលមកខាងលើ ហើយពុំមានសត្វណាដទៃមានសមត្ថភាព ឬក៏សតិញាណ ដើម្បីធ្វើដូច្នោះបានឡើយ។ មានតែមនុស្សប៉ុណ្ណោះដែលអាចប្រាថ្នាធ្វើជាព្រះពុទ្ធ ឬព្រះអរហន្តបាន។ គុណសម្បត្តិពិសេសនៃចរិតជាមនុស្សដែលមានសម្តែងក្នុងធម៌ព្រះពុទ្ធ គឺធំជាងចរិតទេព្តា ឬអាទិទេពឆ្ងាយណាស់។ ព្រះពុទ្ធទ្រង់បានបង្ហើបឲ្យដឹង អំពីសមត្ថភាពពិសេសពិតៗរបស់មនុស្សជាងពីរពាន់ប្រាំរយឆ្នាំមុន អ្នកវិទ្យាសាស្ត្រសម័យទំនើប បានចាប់ផ្តើមបង្ហាញប្រាប់ពិភពលោកតាមរយៈចំណេះដឹងរបស់ពួកគេ។

ប៉ុន្តែ តើពិភពលោកបានយល់ ឬទទួលស្គាល់នូវលក្ខណៈធំទូលាយរបស់មនុស្សហើយឬនៅ? យើងត្រូវតែសួរសំណួរនេះចំពោះមនុស្សគ្រប់រូបម្តងហើយម្តងទៀតដដែលៗ។ យើងក៏ត្រូវសួរសំណួរនេះពីខ្លួនយើងផងដែរ។ យើងត្រូវសួរសំណួរនេះ ហើយត្រូវពិនិត្យមើលវាដោយខ្លួនឯង។

តើមនុស្សម្នាក់ក្លាយជាតួអង្គមនុស្សបានដោយវិធីណា? តើមនុស្សនោះ បានប្រើគុណសម្បត្តិជាមនុស្សរបស់ខ្លួន ប្រកបដោយបញ្ញា សមស្របទៅនឹងភាពជាមនុស្សរបស់ខ្លួនឬទេ? គ្មានអ្វីត្រូវពន្យល់អំពីរបៀបប្រើប្រាស់សមិទ្ធផលសម្ភារៈទំនើប សម្រាប់ការបំផ្លិចបំផ្លាញ ដ៏គួរឲ្យអាណិតនៃមនុស្សខ្លួនឯងនោះទេ។

មានច្រើនជាងប្រទេសកាន់ព្រះពុទ្ធសាសនាទៅទៀត, ការជឿនលឿនខាងសម្ភារៈបំផ្លិចបំផ្លាញ, ត្រូវបានគេឃើញមាននៅក្នុងប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនា និងក្នុងប្រទេសទាំងនោះដែលគ្មានជំនឿជាក់លាក់ណាមួយនៅក្នុងរចនាសម្ព័ន្ធរដ្ឋទៀតផង។

ស្ថិតិជាច្រើនបង្ហាញថា ឃាតកម្ម ឧក្រិដ្ឋកម្ម សង្គ្រាមចម្បាំង ការផលិតអាវុធ និងគ្រាប់រំសេវ ការធ្វើឃាតមេដឹកនាំរដ្ឋដ៏ច្រើនបំផុត កំពុងតែកើតកើនឡើងឥតឈប់។

លើសពីនេះទៀត ភាពតានតឹងក្នុងចិត្ត ក្នុងចំណោមមនុស្សទាំងឡាយ ការពិបាកផ្លូវចិត្ត អត្តឃាតក៏ត្រូវបានឃើញមានយ៉ាងច្រើននៅក្នុងប្រទេសទាំងឡាយដែលប្រជាជន ទទួលយកព្រះអាទិទេព ឬពពួកទេព្តាជាអ្នកជួយរំដោះបាបដែរ។ ពួកគេក៏គ្មានជំនឿក្នុងសាសនាណាមួយច្បាស់លាស់ដែរ។

ក្រៅពីព្រះពុទ្ធសាសនា ជំនឿលើអទិទេពមួយចំនួនបានគាំទ្រជាសាធារណៈថា ការសម្លាប់ បុរស ស្រ្តី សត្វពាហនៈ និងសត្វបក្សីក្នុងនាមព្រះ និងសាសនាដែលមានឫទ្ធិដ៏លើសលប់របស់គេ គឺ

ជាការអនុញ្ញាត និងការទទួលយកបានៗ

ឃាតកម្ម និងអត្តឃាតកើតឡើងនៅពេលដែលបុគ្គលមិនយល់ច្បាស់ពីតម្លៃរបស់មនុស្សៗ ព្រះពុទ្ធសាសនា បង្ហាញយ៉ាងច្បាស់ថា ជីវិតមនុស្សត្រូវតែរស់ប្រកបដោយធម៌មេត្តា និងករុណា ចំពោះមនុស្ស សត្វ គ្រប់រូបៗ ព្រះពុទ្ធសាសនាសង្កត់ធ្ងន់ថា ការបម្រើនចិត្ត និងបញ្ញាខ្ពស់ អាចសម្រេចបានតែក្នុងភាពជាមនុស្សប៉ុណ្ណោះ ហើយបុគ្គលដែលមានកំណើតជាអាទិទេព ឬទេវតាមិនអាចសម្រេចបានទេៗ ដោយមនុស្សនៅគ្រប់ច្រកល្ហកនៃពិភពលោក មិនយល់ពីលទ្ធិសច្ចធម៌នេះ គេរកម្មកំពុងរីករាលដាលយ៉ាងឆាប់រហ័សៗ

វាគ្មានអ្វីអាចកំបាំងទេថា សេចក្ដីពេញចិត្តដែលអាចទទួលបានតាមរយៈការអភិវឌ្ឍន៍សម្ភារៈ បានក្លាយទៅជាក្ដីសុបិន្តប៉ុណ្ណោះៗ កាលពីមុនមនុស្សបានគិតថា ឱកាសរកលុយដែលឥតមានអ្វីទប់ នឹងផ្ដល់នូវផាសុកភាព និងសេចក្ដីសុខគ្រប់យ៉ាងៗ សព្វថ្ងៃមនុស្សបានរកឃើញតថភាព ដែលមនុស្សបានដាក់កំហុសមកលើខ្លួនៗ

ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅថា តាមធម្មជាតិ មនុស្សមិនស្កប់ស្កល់ឡើយ ហើយដូច្នេះ ពួកគេមិនអាចធ្វើឲ្យស្កប់ចិត្ត តាមរយៈការស្វែងរកសម្ភារៈទេៗ ដើម្បីការពារមនុស្សឲ្យជៀសផុតពីផ្លូវដ៏បំផ្លិចបំផ្លាញ និងជួយឲ្យពួកគេទទួលបានសន្តិភាព និងសេចក្ដីស្ងប់នោះ វិធីតែមួយគត់គឺត្រូវផ្សព្វផ្សាយពាក្យឱវាទរបស់ព្រះសម្មាសម្ពុទ្ធ និងច្បាប់ទម្លាប់នៃធម៌ព្រះពុទ្ធៗ តាមពិត យើងអាចសង្កេតមកនៅត្រឹមពីរ

មាត់ប៉ុណ្ណោះគឺ ធម្មំ សរណំ គច្ឆាមិ (ខ្ញុំសូមយកព្រះធម៌ជាទីពឹងទីរលឹក)។ មនុស្សអាចយល់ច្បាស់អំពីខ្លួនគេបាន លុះត្រាតែ គេប្រតិបត្តិតាមសិក្ខាបទនៃធម៌របស់ព្រះពុទ្ធ។

អាស្រ័យហេតុនេះធម៌ព្រះពុទ្ធអាចផ្លាស់ប្តូរមនុស្សឲ្យទៅជាមនុស្សពិតប្រាកដបានបង្កើតភាពសមជាមនុស្សក្នុងខ្លួនគេ។ គេគន-ក័ណ្ឌជាមនុស្សហើយគុណធម៌របស់មនុស្ស និងឋានៈជាមនុស្ស ព្រមទាំងបញ្ញារបស់មនុស្ស នឹងចេញជាផ្លែផ្កានៅក្នុងកពនៃជីវិតផ្សេងគ្នាមួយ។

ទោះបីជាជនទាំងឡាយ ដែលបានកើតជាមនុស្សហើយក៏ដោយ សំណួរសំខាន់មួយទៀតគឺ ថាតើគេអាចដឹកនាំជីវិតមនុស្សនេះគួរជាទីពេញចិត្តបានឬទេ?ព្រះពុទ្ធមានតម្រាស់នៅក្នុងគម្ពីរធម្មបទ (គាថា១៨២)ថា បញ្ហាលំបាកបំផុតទីពីរនោះគឺ មធ្យោបាយដឹកនាំជីវិតជាមនុស្សប្រកបដោយលក្ខណៈជាមនុស្ស។

សាមគ្គីភាព និងសហវិជ្ជមាន ក្នុងចំណោមមនុស្សបានសាបសូន្យទៅ ដោយសារវិបត្តិសេដ្ឋកិច្ចការថ្លាំងថ្នាក់សតិអារម្មណ៍ផ្សេងៗជីវភាពរស់លំបាក តម្រេកកាមសុខហួសហេតុជំងឺផ្លូវកាយ បញ្ហាក្នុងគ្រួសារនិងការធ្លាក់ចុះផ្នែកសីលធម៌។ មនុស្សគ្រប់រូបកំពុងព្យាយាមយ៉ាងខ្លាំងក្លាដើម្បីបំពេញបំណងរៀងៗខ្លួនរបស់គេដោយគ្មានទីបញ្ចប់ពិភពលោកកំពុងរងទុក្ខវេទនាដោយសារភាពអាណាធិបតេយ្យ ភាពគ្មានអ្វីគ្រប់គ្រងនូវចំណង់ផ្លូវកាយនិងចិត្ត។ មនុស្សជាប់វង្វល់ឥតឈប់

ឈរនើងការតស៊ូពេញមួយជីវិត ដើម្បីបំពេញតម្រូវការរបស់គេៗ ព្រះពុទ្ធទ្រង់បង្ហាញថាព្រះអង្គបានសោយទិវង្គត ដោយបន្សល់ទុកសុញ្ញ-កាសដែលមិនបានបំពេញៗ

ដំណោះស្រាយតែមួយគត់ចំពោះប្រស្នាជីវិត និងឱសថតែម្យ៉ាងគត់សម្រាប់ព្យាបាលជំងឺរបស់មនុស្ស គឺការបដិបត្តិតាមវិធីរស់នៅជាក់ស្តែង ដោយអនុលោមទៅតាមសិក្ខាបទនៃព្រះធម៌របស់ព្រះពុទ្ធសាសនាៗ ការបដិបត្តិតាមអភិសមាចារព្រះពុទ្ធសាសនា គឺជាវិធីមួយទៀត ដើម្បីបង្ហាញពិភពលោកទាំងមូលនូវប្រសិទ្ធិភាពរបស់ធម៌ព្រះពុទ្ធ ជាឱសថកែរោគគ្រប់មុខដ៏សក្តិសិទ្ធិៗ ម្យ៉ាងទៀត វានឹងបង្ហាញពិភពលោកនូវ តម្រូវការ សម្រាប់ការបដិបត្តិតាមព្រះពុទ្ធសាសនា ដើម្បីជៀសវាងគ្រោះមហន្តរាយទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងដើម្បីទទួលបាននូវសេចក្តីសុខ និងសេចក្តីសប្បាយទាំងផ្លូវកាយ ទាំងផ្លូវចិត្តៗ

ដោយសារវាជាតម្រូវការនៃពេលបច្ចុប្បន្ន តើយើងអាចពេញចិត្តជាមួយអ្វីគ្រប់យ៉ាងដែលយើងកំពុងធ្វើ ដើម្បីផ្តល់នូវសារនេះថាព្រះធម៌របស់ព្រះពុទ្ធ គឺជាឱសថសក្តិសិទ្ធិកែរោគគ្រប់ប្រភេទរបស់ពិភពលោកដែរឬទេ? យើងត្រូវតែផ្តើមសួរសំណួរនេះចេញពីខ្លួនយើងៗ វិន័យសម្រាប់អនុវត្ត បានវិលជុំវិញពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយការបដិបត្តិសមាធិ បានក្លាយជាប្រធានបទដ៏មានសារសំខាន់បំផុតនៅក្នុងរបៀបរស់នៃការរស់នៅក្នុងពិភពលោកសព្វ

ថ្ងៃ។ ក៏មិនសមស្របគួរមានទេ ប្រសិនបើយើងបន្តអនុវត្តក្បួនរៀបចំអណ្ដាប់អណ្ដាបូជាសាសនា និងផ្ដល់មោទនភាពចំពោះទម្លាប់អនុវត្តបែបហ្នឹងនោះ។ បុគ្គលមិនត្រូវបំពេញចិត្តខ្លួនឯងជាមួយនឹងការអនុវត្តន៍ក្បួនគោរពបូជាសាសនា ឬថា ការប្រែប្រួលនីមួយៗបានកើតឡើងដោយសារតែកម្មរបស់ខ្លួនតែម្យ៉ាងនោះទេ។

មានជំនឿមួយថា ពិភពលោកនេះ សំរេចបាននូវការអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្រិតខ្ពស់មួយ ក៏ប៉ុន្តែប្រទេសអភិវឌ្ឍទាំងនោះ មានកង្វះខាតបញ្ហា ដោយប្រកាន់ខ្ជាប់នូវទេវកថា និងជំនឿផ្សេងៗមួយចំនួន ទាក់ទិននឹងការបង្កើតពិភពលោកនេះ។

អានុភាពនៃការវិភាគរបស់មនុស្ស ការប្រើបុគ្គលិកដ៏ឈ្លាសវៃរបស់អង្គការ និងវិធីសាស្ត្រទាំងឡាយបាននាំមកនូវវឌ្ឍនភាព មិនធ្លាប់មានពីមុន ដែលពិភពលោកសម្រេចបាននាពេលបច្ចុប្បន្ន។ បើទុកណាជាមានវឌ្ឍនភាពរូបវន្តដ៏ធំធេងក៏ដោយ ពួកគេបានបន្ទាបខ្លួនទៅកាន់កម្រិតផ្លូវចិត្តដ៏ទាបបំផុត ដោយសារតែជំនឿងងឹតងងល់ ឥតប្រែប្រួល និងការគាំទ្រមតិនៃការបង្កើតលោក។

ពិភពលោកសព្វថ្ងៃ ត្រូវការសាសនាមួយដែលជាក់ស្ដែង និងមានប្រយោជន៍ ដែលអាចប្រឈមមុខនឹងវិញ្ញាសានៃការរកឃើញផ្នែកវិទ្យាសាស្ត្រទំនើបបាន។ សាសនាមួយដែលមិនសម្អាងលើប្រយោជន៍ ហើយមិនអាចទ្រាំទ្រសម្ពាធសម្ភារៈដ៏ធ្ងន់ធ្ងរបាននឹងត្រូវបែកបាក់ និងរលាយពីសង្គម ហើយនឹងត្រូវបានអ្នកប្រាជ្ញផាត់ចេញឬបំភ្លេច

ហោលទាំងស្រុងៗ

យើងរាល់គ្នាមានជំនឿថា ព្រះពុទ្ធសាសនា ដែលផ្តែកលើចិត្តរីកចម្រើន លើគំនិតឆ្លាតវៃនិងលើចិត្តក្លៀវក្លា និងរាងកាយប្រកបដោយសុខភាពល្អ នោះគឺជាសាសនាតែមួយគត់ ដែលអាចប្រឈមមុខ តទល់នឹងតួនាទីប្រកួតប្រជែងនៅក្នុងសង្គមទំនើបនេះបានៗ ដោយសារហេតុផលនេះ ពេលខ្លះ គេពុំបានចាត់ទុកព្រះពុទ្ធសាសនាជាសាសនាមួយទេ ប៉ុន្តែជាទស្សនវិជ្ជាពិសេសមួយៗ

ដោយគ្មានចរិតលក្ខណៈជាប់ជាមួយ ក្នុងទស្សនៈសាសនារបស់គេបែបនេះមនុស្សជាតិស្ថិតនៅលើផ្លូវខុស ដោយពុំមានលទ្ធភាពរកឃើញផ្លូវទៅកាន់សន្តិភាពនិងវឌ្ឍនភាពៗ មនុស្សជាតិសព្វថ្ងៃកំពុងស្ថិតនៅលើផ្លូវខុសៗ

ដូចព្រះសម្មាសម្ពុទ្ធ ទ្រង់បង្ហាញនូវហេតុផលបីយ៉ាងនៅក្នុងគម្ពីរធម្មបទថា ភាតរភាពរបស់ភិក្ខុសង្ឃ មិនត្រូវបន្តរស់នៅយ៉ាងដាច់ណាត់ពីគ្នានៃប្រពៃណីហីនយាន មហាយាន និងវីរៈយទពួកគេត្រូវតែធ្វើការជាមួយគ្នា ដើម្បីសម្រាលភាពរំជើបរំជួលរបស់ពិភពលោក ហើយប្រមូលផ្តុំដើម្បីធ្វើឲ្យពិភពលោកនេះ ក្លាយជាកន្លែងមួយដ៏រីករាយដើម្បីរស់នៅៗ ស្ថានទេះបានក្លាយជាសេចក្តីត្រូវការរបស់ពិភពលោកនាពេលបច្ចុប្បន្ននេះហើយៗ

ជាបឋម យើងត្រូវតែពង្រឹងសន្តិធម៌ និងសាមគ្គីធម៌ក្នុងចំណោមពួកយើង និងស្តាបនាគំនិតព្រះពុទ្ធសាសនាដ៏ខ្លាំងក្លា ពាស

ពេញពិភពលោក ដោយផ្អែកលើមូលដ្ឋាននៃព្រះរាជសារ មិនមានកាលកំណត់របស់ព្រះពុទ្ធ។

ខ្ញុំព្រះករុណា-អាត្មាភាព សូមលើកយកបញ្ហាមួយចំនួនមកអធិប្បាយដោយសង្ខេប សម្រាប់យើងម្នាក់ៗធ្វើការត្រិះរិះពិចារណា។ ទោះបីជាបញ្ហាទាំងនេះ បានកើតឡើងនៅក្នុងចិត្តគំនិតរបស់យើង ជាច្រើនលើកមកហើយក៏ដោយ ក៏ខ្ញុំព្រះករុណាអាត្មាភាពសូមសង្កត់ធ្ងន់ជាថ្មីម្តងទៀត នូវការជាប់ពាក់ព័ន្ធនៃចិត្តរបស់យើងលើប្រធានបទទាំងនេះ

១-ចាត់វិធានការដើម្បីរៀបចំកម្មវិធីសកម្មភាពមួយ ដើម្បីបណ្តុះបណ្តាលដល់ភិក្ខុដែលសមរម្យសម្រាប់ការផ្សព្វផ្សាយធម៌របស់ព្រះពុទ្ធ។

២-កំណត់ឲ្យច្បាស់នូវការប៉ុនប៉ងទាំងអស់ដោយប្រយោល និងជាចំហ ដើម្បីប្រមាថ និងបន្ថិចបន្ថយកេរ្តិ៍ឈ្មោះធម៌ព្រះពុទ្ធ និងចាត់វិធានការសមស្រប។

៣-រកឲ្យឃើញនូវល្បិចកលអាថ៌កំបាំងទាំងអស់ ដើម្បីបន្ថិចកេរ្តិ៍ឈ្មោះភិក្ខុសង្ឃ និងចាត់វិធានការសមស្រប។

៤-យកចិត្តទុកដាក់ជាពិសេស ចំពោះការប៉ុនប៉ងអូសទាញពុទ្ធសាសនិកឲ្យជឿលើពាហិរសាសនាផ្សេងៗ ហើយចាត់វិធានការចាំបាច់។

៥-ចាត់វិធានការសមស្រប ដើម្បីជួយសម្រួលភាពក្រីក្រ

របស់ពុទ្ធសាសនិកឲ្យបានច្រើនទូលំទូលាយ។

៦-កាត់បន្ថយគម្លាតក្នុងការប្រតិបត្តិធម៌វិន័យ ដែលកំពុងកើតមានជាទូទៅ ក្នុងចំណោមនិកាយជាបងប្អូនទាំងទៀមទម្លាប់ និងប្រពៃណីព្រះពុទ្ធសាសនាសព្វថ្ងៃ។

៧-ផ្សព្វផ្សាយជាអចិន្ត្រៃយ៍នូវសារព្រះធម៌ ក្នុងចំណោមអ្នកកាន់ព្រះពុទ្ធសាសនាទូទាំងពិភពលោកថា អ្នកកាន់ព្រះពុទ្ធសាសនាគឺជាសហគមន៍សាសនាដ៏រឹងមាំបំផុតមួយនៅក្នុងពិភពលោក ដើម្បីឲ្យពួកគេមានអារម្មណ៍សប្បាយ ក្នុងនាមជាសហគមន៍សាសនាដ៏រឹងមាំមួយ។

៨-ត្រូវតែចាប់អនុវត្តនូវផែនការសកម្មភាពមួយ ដើម្បីផ្សព្វផ្សាយនូវកម្លាំង និងឥទ្ធិពលរបស់អ្នកកាន់ព្រះពុទ្ធសាសនានៅទូទាំងសកលលោក និងដើម្បីរៀបចំកម្មវិធីការងារដ៏សមរម្យមួយ ដើម្បីបង្កើតនូវមហាសាមគ្គីមួយនៃអ្នកកាន់ព្រះពុទ្ធសាសនា ដែលរស់នៅគ្រប់ទីកន្លែងពាសពេញពិភពលោក។

យើងត្រូវតែផ្ដោតការយកចិត្តទុកដាក់លើការងារទាំងនោះ និងបញ្ហាដទៃទៀតបែបនោះ។ ជាក់ស្ដែងការអូសទាញពុទ្ធសាសនិកជនឲ្យទៅជឿលើសាសនាផ្សេង កំពុងកើតមានឡើងក្នុងទ្រង់ទ្រាយដ៏ធំធេង នៅក្នុងប្រទេសស្រីលង្កា និងប្រទេសដទៃទៀតនៅអាស៊ី។ យើងមិនចាំបាច់និយាយម្ដងហើយម្ដងទៀតដដែលៗថា បញ្ហាទាំងឡាយបែបនេះកំពុងតែកើតឡើងយ៉ាងច្បាស់ក្រឡែតនោះទេ។ ផែន

ការសកម្មភាព គឺជារឿងមួយដែលចាំបាច់បំផុត។

យើងត្រូវតែរៀបចំកម្មវិធីសកម្មភាពរបស់យើង ក្នុងបែបបទមួយដើម្បីបង្ហាញថា អ្នកកាន់ព្រះពុទ្ធសាសនា គឺជាសហគមន៍ដ៏ខ្លាំងបំផុតនៅក្នុងពិភពលោក និងថា ពួកគេបានចាប់ប្រតិបត្តិនូវផែនការសុក្រិត និងដែលរៀបចំល្អមួយ ដើម្បីការពារ និងធ្វើឲ្យព្រះពុទ្ធសាសនារុងរឿង។

នៅប្រទេសជាច្រើន អ្នកកាន់ព្រះពុទ្ធសាសនា បែរទៅជានៅស្ងាត់ស្ងៀម ដោយសារតែសន្និសីទកំពូលព្រះពុទ្ធសាសនាមានការខ្វះខាត មិនបានស្វែងយល់អំពីហេតុការណ៍ទាំងនេះ និងភាពអសកម្ម ដើម្បីចាត់វិធានការដ៏មានន័យ។ យើងត្រូវតែរៀបចំផែនការសកម្មភាពរបស់យើង ដើម្បីធ្វើឲ្យពិភពលោកបានដឹងច្បាស់ថា អ្នកកាន់ព្រះពុទ្ធសាសនា មិនមែនឯកោទេ ហើយពួកគេគឺជាកម្លាំងមួយ ដែលគេត្រូវយកចិត្តទុកដាក់។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា-អាត្មាភាព សូមបញ្ជាក់ថា កត្តាដ៏សំខាន់បំផុតសម្រាប់យើង គឺត្រូវចាត់វិធានការជាវិជ្ជមាន និងជាក់ស្តែងដើម្បីបន្ថយគម្លាតគ្នា ក្នុងចំណោមបងប្អូនអ្នកកាន់ពុទ្ធសាសនាទាំងអស់ដូចជាពុទ្ធសាសនាហីនយាន មហាយាន វជ្រយាន ហៃឡូនឬប្រពៃណីទីបេ និងនិកាយផ្សេងៗទៀតដែលបំពេញមុខងារទៅតាមឈ្មោះផ្សេងៗ និងបង្កើតឲ្យបានជាស្ថាពរនូវមេត្រីភាព សាមគ្គីភាព និងឯកត្តភាពក្នុងចំណោមប្រពៃណីទាំងអស់នេះ។

សូមឲ្យសច្ចធម៌ និងព្រហ្មចរិយធម៌របស់ព្រះសម្មាសម្ពុទ្ធ ផ្សព្វផ្សាយទៅកាន់គ្រប់ទិសទី និងសូមឲ្យអានុភាព និងឥទ្ធិពលនៃធម៌របស់ព្រះពុទ្ធក្លាយជាកម្លាំងមួយនៅក្នុងពិភពលោក!

ដោយអានុភាពនៃព្រះរតនត្រៃ សូមឲ្យសុខមាលភាព ការសន្ដោសប្រណី និងក្ដីសុខកើតមានឡើង!

សូមសន្តិភាព ចាប់មានពន្លឺក្នុងពិភពលោកទាំងមូល!

បំណាច់កើតមកជាមនុស្ស
កុំធ្វើខ្លួនឲ្យជាអ្នកបំព្រៃលោកៗ

សម្ដេចព្រះសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ

ជោតញ្ញាណោ ជួន ណាត

BUDDHIST INSTITUTE LIBRARY

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា

**លោកនិពន្ធនាយក**

**ទស្សនាវដ្ដីកម្ពុជសុរិយា**

នាងខ្ញុំឈ្មោះ អ៊ុង ភិរម្យ អគ្គលេខាធិការរង សាលាខេត្ត កំពង់ឆ្នាំង សូមសម្ដែងនូវការគាំទ្រ ចំពោះទស្សនាវដ្ដីជាតិ កម្ពុជសុរិយា ដែលបានចុះផ្សាយអត្ថបទស្រាវជ្រាវល្អៗ គួរឲ្យចាប់អារម្មណ៍ តាមដាន សិក្សា ដើម្បីបំពេញបន្ថែមលើកម្រិតយល់ដឹងរបស់នាងខ្ញុំ។ នាងខ្ញុំជឿជាក់ថា ទស្សនាវដ្ដីនេះនឹងបានបន្តជាប្រយោជន៍ សម្រាប់ជូនសាធារណជន ជាពិសេសចំពោះកូនខ្មែរជំនាន់ក្រោយៗ ដើម្បីបានស្គាល់ពីអត្តសញ្ញាណរបស់ខ្លួន។

ជាចុងក្រោយនេះ នាងខ្ញុំសូមប្រសិទ្ធិពរជ័យ ចំពោះឯកឧត្តម លោកបណ្ឌិត លោកស្រីបណ្ឌិត អស់លោកដែលជាអ្នកនិពន្ធទាំងអស់ ព្រមទាំងលោកនាយកការផ្សាយ លោកនិពន្ធនាយក និងសហការី ទទួលបាននូវសុខភាពល្អ ប្រាជ្ញាវាងវៃក្នុងការកិច្ចស្រាវជ្រាវ តាក់តែង ចែងជាអត្ថបទសម្រាប់ទស្សនាវដ្ដីជាតិនេះ។

កំពង់ឆ្នាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០៤

កញ្ញា អ៊ុង ភិរម្យ

# អត្ថបទដែលកម្ពុជសុរិយាបានទទួលក្នុងត្រីមាសទី១ ឆ្នាំ២០០៤

| ល.រ | នាម និងគោត្តនាម | មកពី | ឈ្មោះអត្ថបទ |
|---|---|---|---|
| ១ | លោក ហ៊ុល សឿន | ខេត្តក្រចេះ | -ប្រវត្តិភូមិបឹងចារ<br>-ប្រវត្តិភូមិកំពង់ដំរី |
| ២ | លោក ក៉យ វិបុល | ក្រុមជំនុំព្រះត្រៃបិដក | -ប្រវត្តិភូមិអូរគ្រៀសាំង<br>កំណាព្យ<br>-ធម៌ជាចំណងនៃសាមគ្គីធម៌ |
| ៣ | លោក ហេង គឹមវណ្ណ | | -ពិធីបុណ្យបញ្ចុះសពជនជាតិចាម |
| ៤ | លោក រិច ចំរើន | ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ | -របរយកជ័រម្រ័ក្សណ៍ |
| ៥ | កញ្ញា ហ៊ិន សុជាតា | -ដ- | -រុក្ខជាតិឱ្មមចន្ទន៍ |
| ៦ | កញ្ញា រស់ ស៊ីណាក់ | -ដ- | -ចម្លាក់ថ្មកែវ |
| ៧ | លោក អ៊ូ សៀវរ៉ែន | -ដ- | -រុក្ខជាតិវល្លិរមៀត |
| ៨ | អ្នកស្រី ហ៊ុយ ចេងរតនា | -ដ- | -ការយកទឹកឃ្មុំ នៅតំបន់ព្រៃនាម |

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ចេតិយ ព្រះនាងក្រពុំឈូក ( នៅស្រុកសម្បូណ៌ ខេត្តក្រចេះ )

ឆ្នាំទី ៥៨ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៤៨ គ.ស ២០០៤

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពដោយគណៈកម្មការមួយមាន :

នាយកការផ្សាយ : **ចួន វ៉ាន់ចន្ធី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ ឃីហ៊ាង** លោក **ទង់ សុធារ៉ា**

លោក **ធន់ ហ៊ិន** លោក **មៀច ប៊ុណ្ណ**

# គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សាកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមព្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព (WCRP) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.

# មាតិកាអត្ថបទ

## I អក្សរសិល្ប៍ពុទ្ធសាសនា


- ជីវិតមនុស្ស និងបញ្ហា (ត)........................ (ឈេន អៀម) ១
- ប្រវត្តិរបស់អដ្ឋកថា (តចប់) ....................(ក៉ន់ ចាន់សារ៉ែន) ១៥


## II អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ


- លក្ខណៈពិសេសរបស់សម្តេចព្រះសង្ឃរាជជួនណាត . (ង៉ែត សោភ័ណ) ៣០
- ពុទ្ធសាសនា និងបញ្ហាអប់រំ (ត)........................ (ធយ យីហ៊ាង) ៤៥
- ឋានៈស្ត្រីក្នុងព្រះពុទ្ធសាសនា ...........(ព្រះមហា ឃី សុវណ្ណរតនា) ៥២
- សិលាចារឹក Ka 59 ភូមិគោកក្លាង ...............(ម៉ីសែល ត្រាណេ) ៦១
- អំពីការដាក់អន្ទាក់មាន់ព្រៃ ........................ (មៀច ប៉ុណ្ណ) ៧៤
- ប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា ....................... (ហ៊ីង គីមថន) ៨២


## III កំណត់ និងប្រវត្តិការណ៍


- សុន្ទរកថា .................(ព្រះតេជព្រះគុណ អាជាញ ព្រហ្មវង្សោ ) ៨៧


## IV ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- លិខិតរបស់លោក ក៉យ វិបុល ................................ ៩៧

# ជីវិតមនុស្ស និង បញ្ញា (ត)

ព្រះតេជ.គ.ស្រី ធម្មានន្ទ
បកប្រែ ឈន អៀម

## កន្លែងដុះដាលឧក្រិដ្ឋកម្ម

*កន្លែង ឬ ទីតាំងដ៏មានជីជាតិបំផុត សម្រាប់ចិញ្ចឹមបំប៉នឧក្រិដ្ឋកម្ម គឺគ្រួសារ ។ ទោះបីជាមានវិធានការណ៍សព្វបែបយ៉ាង ដែលត្រូវអនុវត្ត ដើម្បីបញ្ចុះអត្រាឧក្រិដ្ឋកម្មក្ដី ក៏អំពើឧក្រិដ្ឋកម្មឃោរឃៅកំពុងកើនឡើង ក្នុងគ្រួសារជាច្រើន ក្នុងសង្គមសម័យថ្មី ដែលមានបច្ចេកវិជ្ជាជឿនលឿន ។ កុមារភាគច្រើនរៀនឲ្យក្លាយខ្លួនជាឧក្រិដ្ឋជន តាមគន្លងដែលពួកគេកំពុងត្រូវបានចិញ្ចឹមបីបាច់ ។*

*នៅក្នុងប្រទេសខ្លះ នៅពេលដែល អត្រាឧក្រិដ្ឋកម្មមនុស្សពេញវ័យ បានធ្លាក់ចុះដល់កម្រិតណាមួយ បែរជាឧក្រិដ្ឋកម្ម ប្រព្រឹត្តដោយយុវជនកើនឡើងទៅវិញ ។ យើងដឹងតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថា កុមារជាច្រើន បានកាន់យកកាំភ្លើងទៅសាលារៀន របស់ពួកគេ ។ ពេលខ្លះ យើងឮថា កូនក្មេងតូចៗ អាយុក្រោមប្រាំឆ្នាំ បានបាញ់បងប្អូនបង្កើត ឬឪពុក-ម្ដាយរបស់វា ។ តាមធម្មតា ឧក្រិដ្ឋកម្មក្នុងចំណោមយុវជន បានទាក់ទងទៅនឹងគ្រឿងញៀន និងគ្រឿងស្រវឹង ដែលពួកគេងាយរកបាន នៅក្នុងគ្រួសារខ្លះ ។ ឧក្រិដ្ឋជនមិនមែនកើតមកអំពីកំណើតទេ ប៉ុន្តែកើតមានដោយសារគ្រួសារដឹកនាំខុសផ្លូវ និងគ្មានការយកចិត្តទុកដាក់ និងដោយសារបរិដ្ឋាន ដែលពួកគេរស់នៅ ។*

វាបានក្លាយទៅជាបែបបទជាទីពេញនិយម នៃសតវត្សទីម្ភៃទៅហើយ ក្នុងចំណោមមនុស្សប្រុស-ស្រីជាច្រើនរស់នៅជាមួយគ្នា ដោយមិនបាច់រៀបការ ។ ក្នុងករណីខ្លះ កូនកើតមកក្នុងកាលៈទេសៈបែបនេះទទួលរងគ្រោះ ដោយខ្លះការយកចិត្តទុកដាក់ ។ ជាញឹកញយណាស់ កូនក្មេងទាំងនោះ ច្រើនបញ្ចប់ត្រឹមការរស់នៅ ក្រោមការថែទាំ ឬគ្រប់គ្រងរបស់ឪពុក ឬម្តាយម្នាក់ប៉ុណ្ណោះ តាមធម្មតាច្រើនតែម្តាយ ។ ឪពុក ឬម្តាយដែលមិនទទួលខុសត្រូវ បានចាកចោលកូនៗ ទុកឲ្យនៅក្រោមការថែទាំរបស់ដៃគូមួយទៀត ។ ស្រីៗច្រើនតែរងនូវការរើសអើង ត្រូវខិតខំធ្វើការយ៉ាងនឿយហត់ដូចជាដៃគូបុរស ដើម្បីចិញ្ចឹមជីវិតខ្លួនឯង និងកូនៗរបស់ខ្លួន ។ សេដ្ឋកិច្ចសកលសម័យថ្មី គឺជាសេដ្ឋកិច្ច ដែលស្ត្រីមិនបានទទួល អត្ថប្រយោជន៍ដូចបុរសទេ ទោះបីមនុស្សប្រុសនោះខ្លះបុព្វសិទ្ធផ្សេងៗក្តី ។ ដោយហេតុថា រចនាសម្ព័ន្ធសង្គមទាំងមូលបានប្រកាន់យកផ្លូវដើរផ្សេងស្រឡះ អំពីផ្លូវដើរជាប្រពៃណីពីមុន ការឧបត្ថម្ភសម្រាប់គ្រួសារ ស្ទើរតែមិនមាននៅក្នុងប្រទេសជាច្រើន ។ ជាផលវិបាក ស្ត្រីជាច្រើនទទួលរងគ្រោះច្រើនជាងគេ បណ្តាលមកពីការលំបាកទាំងឡាយនៅក្នុងគ្រួសារ ដែលគេខិតខំចិញ្ចឹម ។

ក្មេងៗ ដែលត្រូវបានចិញ្ចឹមបីបាច់ ដោយឪពុក ឬម្តាយតែមួយច្រើនមិនបានទទួលសេចក្តីថ្នាក់ថ្នម និងការថែទាំពីឪពុក-ម្តាយគ្រប់គ្រាន់ទេ ។ ឪពុក-ម្តាយដែលមានកង្វល់ខាងផ្លូវចិត្ត មិនអាចផ្តល់កាតព្វកិច្ចខាងចិត្តវេគ ឬខាងផ្លូវអារម្មណ៍ឲ្យបានល្អ ដល់កូនរបស់ខ្លួនទេ ។ ជួនកាលអ្នកមើលថែទារក-កុមារទាំងនោះគឺជាទូរទស្សន៍ ឬមនុស្សឯទៀតដែលត្រូវបានគេចិញ្ចឹម តាមរបៀបដដែល ដូចអ្នកទាំងនោះ ដែលពួក

គេមើលថែទាំ ។ ជាញឹកញយ អ្នកមើលថែទារក គឺជាក្មេងស្រីជំទង់ៗ ដែលត្រូវការប្រាក់ សម្រាប់ទិញគ្រឿងញៀន ឬស្រាៗ ពួកគេមិនដែលបានទទួលការហ្វឹកហ្វឺន ក្នុងការមើលថែទារកទេ។ នៅពេលកំពុងមើលថែទារក ពួកគេហ្នឹងឯងអាចជក់បារី ឬសេពគ្រឿងញៀនខុសច្បាប់ ។ ក្រោមកាលៈទេសៈបែបនេះ ក្មេងៗមិនបានទទួលការថែទាំ ការណែនាំ សេចក្តីស្រឡាញ់ដ៏ចាំបាច់គ្រប់គ្រាន់ទេ ហើយសំខាន់បំផុត មិនបានទទួលការអប់រំជាមូលដ្ឋានទេ ។

គ្មានអ្នកថែទាំទារកណា អាចផ្តល់សេចក្តីស្រឡាញ់ និងការថែទាំស្មើនឹងឪពុក-ម្តាយទេ ។ ក្មេងៗ មិនអាចយល់ និងមានសមានចិត្តជាមួយអ្នកថែទាំទារក ដូចពួកគេយល់ និងស្រឡាញ់ឪពុក-ម្តាយផ្ទាល់របស់ពួកគេសោះឡើយ ។

កាលណាពួកគេបានធំឡើង ក្មេងៗទាំងឡាយបែបនោះ អាចចាប់ផ្តើមប្រព្រឹត្តខ្ជិលផ្ទាល់ខ្លួន ហើយប្រកាន់យកផ្លូវ ដឹកនាំជីវិតខុសឆ្គង ។ ពួកគេមិនបានទទួលការអប់រំ ខាងសាសនាត្រឹមត្រូវទេ ។ ទាំងពួកគេមិនដែលដឹងថា តើត្រូវស្វែងយល់សាសនាទាំងឡាយដោយខ្លួនឯងផ្ទាល់យ៉ាងម៉េចដែរ ។ ធ្វើឲ្យពួកគេ កាន់តែមានចរិតអាក្រក់ជាងទៀត គឺអំពើឃោរឃៅផ្សាយតាមទូរទស្សន៍ ដែលជាគំរូត្អូនាទីរបស់គេ ។ ផលិតករខ្សែភាពយន្តជាច្រើន និងអ្នកនិពន្ធរឿងជាច្រើន កំពុងតែងសៀវភៅលើកស្ទួយ អំពើឃោរឃៅមុនគេបង្អស់ ដើម្បីពួកគេអាចប្រមូលលុយដុល្លារបានឆាប់ ។ ក្មេងៗដែលធំវ័យឡើង ដោយគ្មានការណែនាំសមស្របទេ ចាប់ផ្តើមអានសៀវភៅទាំងនោះ ហើយសាកល្បង

គ្រាប់តាមអ្វី ដែលពួកគេបានឃើញលើកញ្ចក់ទូរទស្សន៍ និងអ្វីដែលពួកគេបានអានក្នុងសៀវភៅ ។

ឪពុក-ម្ដាយជាច្រើន មិនបានយកចិត្តទុកដាក់ផងទេ អំពីរឿងកាំភ្លើង និងសុរាបស់ពួកគេ ។ មានឪពុក-ម្ដាយខ្លះ ស៊ីផឹកនិងជក់នៅទីងមុខកូនៗរបស់ខ្លួន ។ កាលណាពួកគេឡប់ស្មារតីទទួលខុសត្រូវ ក្រោមឥទ្ធិពលនៃសុរាហើយ វិញ្ញាណទាំងឡាយរបស់ពួកគេ ត្រូវវង្វេងវង្វាន់ខ្វាំងណាស់ទៅ ទាល់តែគេមិនបានទីកឃើញទុកដាក់ដបស្រា កញ្ចប់បារី និងកាំភ្លើងរបស់គេក្នុងកន្លែងត្រឹមត្រូវ ឬលាក់របស់ទាំងនោះ ឲ្យឆ្ងាយពីដៃក្មេងៗ ពួកគេភ្លេចភ្លាំង និងធ្វេសប្រហែសផងដែរ ទុកកាំភ្លើងមានគ្រាប់បញ្ចូលហើយ ឲ្យក្មេងយកបាន ។ ក្មេងៗត្រូវបានគេលើកទឹកចិត្ត ដោយមិនបានគិតគូរវែងឆ្ងាយ ដើម្បីបំពេញចំណង់ចង់ដឹងជាធម្មជាតិរបស់ខ្លួន ដោយប្រើកាំភ្លើង ផឹកស្រា សេពគ្រឿងញៀននិងជក់បារី ។

មានឪពុក-ម្ដាយខ្លះ ដែលខ្លួនពួកគេផ្ទាល់ ចេញមកពីគ្រួសារបាក់បែក អាចមិនបានទទួលការអប់រំគ្រប់គ្រាន់ ក្នុងផ្លូវសីលធម៌ និងអភិសមាចារ ដើម្បីទប់វិញ្ញាណទាំងឡាយរបស់ពួកគេ ហើយដោយប្រការដូច្នេះ ក៏ប្រព្រឹត្តខុសឆ្គង នៅចំពោះមុខកូនៗរបស់ខ្លួន ។ មានឪពុក ជីតា មា និងបងប្រុសខ្លះ ឈានដល់ ចាប់រំលោភសេពកាមកូនៗនៅក្មេង ។ ក្មេងៗដែលត្រូវបានគេចាប់រំលោភ សេពកាម លុះធំឡើង តែងមានគំនុំ មិនអាចបំភ្លេចបាន ចំពោះជនទាំងឡាយជាអ្នកចាប់រំលោភ ។ ជួនកាល ពួកគេហ្នឹងឯង អាចប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នា កាលណាពួកគេធំពេញវ័យឡើងៗ

ជាញឹកញយ សង្គមតែងធ្វើឲ្យរឿងរ៉ាវទាំងឡាយ អាក្រក់ខ្លាំង សម្រាប់គ្រួសារមានកង្វល់ និងក្មេងៗជាកូនរបស់គេ ។ អ្នកផលិតកាំភ្លើងរីករាយចិត្តណាស់ ដ៏ឃើញមនុស្សប្រើកាំភ្លើង កាន់តែច្រើនឡើងៗ ដើម្បីបង្កើនប្រាក់ចំណូលរបស់គេ ។ អ្នកលក់គ្រឿងញៀនបានចំណេញកាន់តែច្រើន ដោយប្រើក្មេងតូចៗកាន់តែច្រើន មកពីគ្រួសារបាក់បែកគ្នា ដើម្បីចែកចាយលក់ និងប្រើគ្រឿងញៀន ។ ក្មេងៗដែលរកប្រាក់បានដោយលក់គ្រឿងញៀន តែងធ្វើអ្វីៗសព្វយ៉ាង ដើម្បីលើកទឹកចិត្តក្មេងៗរៀនបនវាឲ្យប្រើ និងលក់គ្រឿងញៀន ។ កាលណាឪពុក-ម្តាយរបស់ក្មេងៗមិននៅផ្ទះ វាអាចមានសេចក្តីរំភើប ស្រើបស្រាលចិត្តខ្លាំងហ៊ានលួចយកគ្រឿងញៀន និងគ្រឿងស្រវឹងអំពីទូ ឬបន្ទប់ទុកគ្រឿងទាំងនោះ ដែលមិនបានចាក់សោ របស់ឪពុក-ម្តាយវាផ្ទាល់ ។

ការលែងលះគ្នា បានក្លាយទៅជានិយាមបច្ចុប្បន្នផងដែរ នៅក្នុងសង្គមទាំងឡាយ ដែលមានបច្ចេកវិជ្ជាជឿនលឿន ។ អ្នកដែលរងគ្រោះខ្លាំងជាងគេអំពីការលែងលះគ្នា គឺកូនៗ ។ ក្នុងវ័យនៅក្មេងខ្ចីរបស់គេ កូនៗតែងត្រូវការសេចក្តីស្រឡាញ់ និងការថ្នាក់ថ្នម ការថែទាំគ្រប់យ៉ាងអំពីឪពុក-ម្តាយទាំងពីរនាក់។ នោះគឺជាវ័យដែលកូនៗ ត្រូវការដំបូន្មានសមស្រប និងឧទាហរណ៍ល្អៗ សម្រាប់ជាគំរូប្រព្រឹត្តតាម ។ នោះគឺជាវ័យដែលនៅក្នុងដំណាក់កាលនេះ ចិត្តតែងស្រូបបឺតយកអ្វីៗ យ៉ាងឆាប់បីដូចជាពពុះកៅស៊ូ ឬអេប៉ុង (a sponge) ។ កាលណាឪពុក-ម្តាយលែងលះគ្នា ឬរស់នៅផ្សេងគ្នា មុនពេលលែងលះគ្នា កូនៗប្រែក្លាយជាស្រពាប់ស្រពោន ហើយទុញទល់គំនិត ។ ឪពុក-ម្តាយដែលកំពុងតស៊ូខ្លួនឯងផ្ទាល់ ដើម្បីគ្រប់គ្រងអារម្មណ៍ចិត្តវេគរបស់ខ្លួន មិនអាច

ណែនាំកូនៗ ឲ្យដើរផ្លូវត្រូវបានទេ ហើយឪពុក-ម្ដាយទាំងនោះ ក៏មិនអាចយកចិត្តទុកដាក់ គ្រប់គ្រាន់ចំពោះកូនៗ សម្រាប់ការធំធាត់ឡើងប្រកបដោយសុខភាពល្អបានដែរ ។ ប្រសិនបើ ឪពុកមិនបានថែទាំទាំងស្រុងហើយ កូនតែងស្វែងរកដំណោះស្រាយបញ្ហា អំពីមិត្តភក្តិ ដែលភាគច្រើននៃមិត្តភក្តិទាំងនោះផ្ទាល់ ក៏ចេញមកពីគ្រួសារបាក់បែកគ្នាដែរ។ ក្នុងចំណោមគ្នាវានេះ គ្មាននរណាមួយ អាចជួយគ្នាទៅវិញទៅមកបានដោយពិតប្រាកដទេ ។

សូម្បីនៅក្នុងគ្រួសារ ដែលមិនមានកង្វល់ ដោយការលែងលះគ្នាក្ដី កូនៗ អាចមិនមានពេលជួបមុខឪពុក-ម្ដាយបានគ្រប់គ្រាន់ ។ ឪពុក-ម្ដាយជាប់ដៃរវល់ខ្លាំងណាស់សព្វថ្ងៃនេះ ខិតខំរកប្រាក់សម្រាប់ផ្គត់ផ្គង់ជីវ-ភាពឲ្យស្រួល សម្រាប់ខ្លួនគេផ្ទាល់ និងកូនៗរបស់គេ ។ ជាញឹកញយណាស់ ឪពុក-ម្ដាយមិនបានមកផ្ទះ ពីព្រោះគេមានការងារច្រើនត្រូវធ្វើដើម្បីរកប្រាក់បានច្រើនៗ ឪពុក-ម្ដាយខ្លះមិនបានមកផ្ទះ ពីព្រោះគេត្រូវធ្វើដំណើរទាក់ទងជំនួញច្រើនយ៉ាង ចេញទៅក្រៅទីក្រុង។ ឪពុក-ម្ដាយខ្លះទៀត ដែលមិនអាចធ្វើដំណើរឆ្ងាយៗ ត្រូវនៅធ្វើការយ៉ាងញាប់ដៃនៅកន្លែងធ្វើការ ។ មានឪពុក-ម្ដាយខ្លះជា "មនុស្សស្រវឹងការងារ" (workaholics) គេមិនអាចចំណាយពេល ដែលបានភ្ញាក់ឡើង សូម្បីតែមួយនាទី ដោយមិនធ្វើអ្វីមួយ ទាក់ទងនឹងការងាររបស់គេបានឡើយ ។ ជួនកាល តាំងពីព្រលឹមស្រាងៗ គេចេញទៅធ្វើការ ហើយមិនអាចត្រឡប់មកផ្ទះវិញបាន រហូតដល់ពេលយប់ ទើបលេចមុខមកផ្ទះ ដោយនាំយកការងារយ៉ាងច្រើន មកធ្វើនៅផ្ទះថែមទៀត ។ គេអាចចូលដំណេកយឺតយូរក្នុងពេលយប់ ហើយបន្តគិតអំពីកិច្ចការរបស់គេ នៅថ្ងៃស្អែក

ទៀត ។ គេជាមនុស្សរវល់ធ្វើការគ្រប់ទាំ តាំងពីពេលគេភ្ញាក់ឡើងនៅពេលថ្ងៃ ហើយជាមនុស្ស រវល់គិតអំពីការងារនៅថ្ងៃស្អែក នៅពេលយប់ សូម្បីនៅពេលដេកលក់ហើយក៏ដោយ ។

មានគេចោទសួរថា ហេតុអ្វីក៏ពួកគេជាប់ចិត្តខ្លាំងម្ល៉េះ ជាមួយការងារ ? ។ ឪពុក-ម្ដាយបែបនោះ អាចនិយាយបានថា ពួកគេត្រូវរកប្រាក់ ហើយសន្សំទុក សម្រាប់ផ្ដល់ឲ្យគ្រួសារ ។ ប៉ុន្តែដោយហេតុពួកគេរស់ក្នុងភាពតានតឹងជានិច្ច ពួកគេជាមនុស្សស្រងូតស្រងាត់រអ៊ូរទាំ ពេលគេចូលកាន់ដំណេកពេលយប់ ។ រឿងល្អិតល្អោចតូចតាចមួយ អាចធ្វើឲ្យគេក្រោធខឹង ។ គេគ្មានពេលណាមួយ សម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់កូនរបស់គេឡើយ ។ គេជឿថា បើគេរកប្រាក់បានច្រើន អនាគតកូនៗរបស់គេ នឹងត្រូវបានធានា ។ ប៉ុន្តែទោះជាគេរកប្រាក់បានច្រើនយ៉ាងដូចម្ដេចក្ដី ក៏វានៅតែមិនគ្រប់គ្រាន់ដែរ ។ ហើយមានឪពុក-ម្ដាយខ្លះ ដែលមានប្រាក់ច្រើនលើសជាងពួកគេត្រូវការក្ដី ក៏នៅតែមិនមានពេលសម្រាប់កូនៗ របស់ពួកគេ ពីព្រោះពួកគេបានចំណាយពេលច្រើន ជាមួយមិត្តភក្ដិរបស់គេ ច្រើនជាងជាមួយគ្រួសាររបស់ពួកគេ ។

កាលណាកូនៗ មកពីសាលារៀនដល់ផ្ទះ ពួកគេច្រើនតែធ្វើអ្វីដែលពួកគេចូលចិត្ត ពីព្រោះគ្មាននរណាម្នាក់នៅផ្ទះ ដើម្បីត្រួតត្រាលើពួកគេទេ ។ នៅក្នុងករណីខ្លះ ឪពុក-ម្ដាយតែងទទួលយកកូនៗរបស់ខ្លួនអំពីសាលារៀន តាមផ្លូវរបស់ខ្លួនត្រឡប់ពីកន្លែងធ្វើការមកផ្ទះ ក៏ប៉ុន្តែមិនដែលមានពេលស្ដាប់កូនៗ និយាយប្រាប់រឿងសោះ ។ ពួកគេស្រឡាញ់ចង់ឃើញកូនៗ ប៉ុន្តែមិនចង់ស្ដាប់កូនៗនិយាយ ។ ក្មេងៗ (កូន) ច្រើនញញើតនឹងនិយាយទៅកាន់ឪពុក-ម្ដាយ ដោយខ្លាចឪពុក

ម្តាយក្រោធខឹងចំពោះពួកគេ ព្រោះតែនិយាយប្រាប់អំពីបញ្ហារបស់ខ្លួនៗ បញ្ហាទាំងឡាយរបស់កូនៗ អាចបន្តរីកធំឡើង កាលណាពួកគេគ្មានពេលដដែកដោះស្រាយបញ្ហានោះៗ ជាមួយឪពុក-ម្តាយរបស់ពួកគេៗ មិត្តភក្តិរួមថ្នាក់រៀនរបស់ពួកគេ មិនមានសមត្ថភាពផ្តល់ដំបូន្មានដ៏មានអត្ថន័យដល់ពួកគេបានទេៗ

មានឪពុក-ម្តាយខ្លះ ទន្ទឹងចាំតែដល់ពេលកូនៗរបស់គេធំពេញវ័យ ហើយឲ្យចាកចេញពីផ្ទះ យ៉ាងឆាប់តាមតែអាចធ្វើបាន ដើម្បីគេមានសេរីភាពធ្វើអ្វីតាមចិត្តគេចង់ៗ គួរឲ្យអាសូរដែរ កូនៗរបស់គេក៏ទន្ទឹងចាំតែដល់ពេលបានធំឡើងយ៉ាងឆាប់ ដើម្បីរួចផុតពីឪពុក-ម្តាយរបស់ខ្លួន ៗ ក្នុងករណីដ៏ធ្ងន់ធ្ងរ កូនៗដែលប្រាសចាកគន្លងត្រូវ និងខ្លះអំណត់ខ្លះឈានរហូតដល់សម្លាប់ឪពុកម្តាយឯង ដើម្បីដណ្តើមយកទ្រព្យសម្បត្តិរបស់ឪពុក-ម្តាយខ្លួន ៗ ក្មេងៗប្រាថ្នា ចង់ឲ្យសម្រេចបានឯករាជភាពរបស់ខ្លួនយ៉ាងឆាប់ តាមតែអាចធ្វើទៅបាន ប្រែក្លាយទៅជាមនុស្សអាត្មានិយមកាន់តែខ្លាំងឡើងៗ យើងស្គាល់បញ្ហា ៗ គឺការគ្មានទំនាក់ទំនងមេត្រីភាពជិតស្និទ្ធរវាងឪពុក-ម្តាយ និងកូនៗ ៗ ប៉ុន្តែតើអ្វីទៅ ជាដំណោះស្រាយ ?

តាមពិត ទាំងឪពុក-ម្តាយ ទាំងកូនៗ អាចមានឯករាជភាព ប៉ុន្តែនៅតែមានទំនាក់ទំនងល្អ ជាមួយគ្នាទៅវិញទៅមក ៗ ទំនាក់ទំនងរវាងឪពុក-ម្តាយ និងកូនត្រូវបានព្រះពុទ្ធប្រទានតម្លៃយ៉ាងខ្ពស់ៗ ដើម្បីលើកស្ទួយទំនាក់ទំនងដ៏ល្អនេះ ព្រះពុទ្ធបានគាំទ្រវិធានការជាច្រើនយ៉ាងៗ បើ

ឪពុកម្តាយបំពេញភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ចំពោះកូនៗ ហើយបើកូនៗបំពេញភារកិច្ច ទទួលខុសត្រូវចំពោះឪពុក-ម្តាយនោះ គ្រួសារមានសុខដុមភាព និងសេចក្តីសុខសាន្ត អាចកើតមាន ។

មនុស្សដែលស្រឡាញ់ប្រាក់កាស លើសសុភមង្គល ច្រើនតែជាដើមចមនៃឧក្រិដ្ឋកម្មឃោរឃៅ។ ឧក្រិដ្ឋកម្មស្ទើរទាំងអស់ ត្រូវបានប្រព្រឹត្តឡើងដោយមនុស្ស ដែលមិនបានទទួលការអប់រំ ក្នុងតម្លៃសីល-ធម៌ និងអកិសមាចារ ។ ប្រសិនបើលោកអ្នក ចំណាយអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នក ចំណាយកម្លាំង និងពេលវេលាទាំងអស់របស់លោកអ្នក ក្នុងការរកប្រាក់ ឬក្នុងកាមសុខ ( សេចក្តីសប្បាយស្រើបស្រាលតាមផ្លូវវិញ្ញាណ ) ដោយមិនវល់គិតគូរ ពីអនាគតរបស់កូនលោកអ្នក តើលោកអ្នកអាចសង្ឃឹមថា កូនៗរបស់លោកអ្នក ចេះវែកញែករវាងល្អ និងអាក្រក់បានទេ? ឬប្រសិនបើលោកអ្នកប្រដៅកូនៗរបស់លោកអ្នក ឲ្យស្អប់អ្នកជិតខាងរបស់លោកអ្នក ពីព្រោះអ្នកជិតខាងនោះ ផ្សេងគ្នាអំពីលោកអ្នក និងផ្សេងគ្នាអំពីតម្លៃគុណធម៌របស់លោកអ្នក តើលោកអ្នកអាចសង្ឃឹមថា កូនៗរបស់លោកអ្នកចេះគោរពអ្នកណាម្នាក់បានទេ ?

ឬប្រសិនបើលោកអ្នក ប្រៀនប្រដៅកូនៗ របស់លោកអ្នកឲ្យស្អប់អ្នកដទៃ ដែលកាន់តាមសាសនាណាមួយ ផ្សេងអំពីសាសនារបស់លោកអ្នក តើលោកអ្នកអាចសង្ឃឹមថា កូនៗរបស់លោកអ្នកមិនប្រព្រឹត្តអំពើឃោរឃៅបានទេ ? ឬបើលោកអ្នកប្រៀនប្រដៅកូនៗរបស់

លោកអ្នក ឲ្យស្តាប់អ្នកឯទៀត ព្រោះគេនិយាយភាសា មួយផ្សេង ដែលលោកអ្នកមិនយល់ តើលោកអ្នកសង្ឃឹមថា កូនៗរបស់លោក អ្នកបន្ថយអំពើឧក្រិដ្ឋកម្ម នៅក្នុងសង្គមបានទេ ? ការទីងមានអំពើ ឧក្រិដ្ឋឃោរឃៅចំនួនតិចតួច នៅក្នុងសង្គមទាំងឡាយ លុះត្រាតែនៅ ក្នុងសង្គមនោះៗ មានចំណងគ្រួសារជិតស្និទ្ធ រវាងឪពុក-ម្តាយនិងកូនៗ ទំនាក់ទំនងជិតស្និទ្ធ រវាងញាតិសន្តាន និងរវាងគ្រួសារទាំងឡាយៗ ក្នុង សង្គមទាំងឡាយ ដែលមានការផ្លាស់ប្តូរពេលវេលាគ្នា ផ្លាស់ប្តូរទ្រព្យ សម្បត្តិ កម្លាំងពលំ ចំណេះដឹង សេចក្តីស្រឡាញ់ និងការថែទាំ ទៅវិញទៅមកដោយសេរី នោះឧក្រិដ្ឋកម្មឃោរឃៅ រមែងថយចុះ ។

សូមជូនពរដល់ឪពុក-ម្តាយ និងក្មេងៗទាំងឡាយ ដែលមាន សម្ព័ន្ធមេត្រីស្នេហា រវាងគ្នានឹងគ្នា ។ សូមជូនពរគ្រួសារ ដែលមាន មិត្តភាព និងសុខដុមភាព។ ឪពុក-ម្តាយទាំងឡាយ គួរតែធ្វើពលិកម្មខ្លះ ដើម្បីផ្តល់នូវសេចក្តីស្នេហា និងការថែទាំទាំងអស់របស់ខ្លួន ចំពោះកូនៗ របស់ខ្លួន។ ឪពុក-ម្តាយដ៏ល្អ ត្រូវតែចំណាយពេលវេលា កម្លាំងកាយ ចិត្ត និងប្រាក់កាសរបស់ខ្លួន បង្កើតបរិដ្ឋានគ្រួសារដ៏សុខដុមមួយ ដែល នៅក្នុងបរិដ្ឋានគ្រួសារនេះ គេអាចចិញ្ចឹមបីបាច់កូនៗ របស់គេយ៉ាង សប្បាយរីករាយ ។ ដើម្បីថែទាំកូនៗរបស់គេ មានឪពុក-ម្តាយដ៏មាន ចិត្តធម៌ខ្លះ ដាក់វេនធ្វើការនៅក្រៅផ្ទះ។ ក្នុងករណីខ្លះ គេទូន្មានឲ្យឪពុក-ម្តាយ ត្រូវប្តូរកម្មវិធីធ្វើការរបស់គេ ប្រសិនបើទាំងពីរនាក់ ត្រូវធ្វើការ រកចំណូលបានសមល្មម សម្រាប់ចិញ្ចឹមគ្រួសារហើយ ។ មានពេលខ្លះ

ឪពុក ឬ ម្ដាយអាចសម្រេចចិត្តបិតទៅផ្ទះ ដើម្បីមើលថែទាំកូនៗរបស់គេ ប្រសិនអ្នកណាម្នាក់ ( ប្ដី ឬប្រពន្ធ ) រកចំណូលបានល្មមទ្រទ្រង់គ្រួសារហើយ។

ឪពុក-ម្ដាយដ៏ល្អ គប្បីយល់ច្បាស់ថា ខ្លួនគេជាអ្នកដើរតួគំរូសម្រាប់កូនៗរបស់គេ ។ ដើម្បីឲ្យកូនៗមានវិន័យ ឪពុក-ម្ដាយត្រូវមានវិន័យខ្លួនឯង។ បើឪពុក-ម្ដាយមិនមានវិន័យទេ គេមិនអាចសង្ឃឹមថាមានវិន័យបែបណាមួយ អំពីកូនៗរបស់គេឡើយ។ កាលណាឪពុក-ម្ដាយខិតខំធ្វើឲ្យកូនៗមានវិន័យ ជួនកាល កូនៗអាចរេះរេបើងប្រឆាំងតបឪពុក-ម្ដាយវិញ។ ពួកវាអាចឈានដល់ហ៊ាននិយាយថា ពួកវាស្អប់ឪពុក-ម្ដាយរបស់ពួកវា ។ ប៉ុន្តែថា ឪពុក-ម្ដាយដ៏ល្អ មិនត្រូវខ្វាចពាក្យពោលរបស់កូនៗ ដូចបានបញ្ជាក់ហើយនេះទេ ។ កាលណាកូនៗមានវ័យធំឡើង ពួកវានឹងយល់ច្បាស់ថា ឪពុក-ម្ដាយរបស់ពួកវាបានធ្វើឲ្យពួកវាមានវិន័យ ដើម្បីជាអត្ថប្រយោជន៍ផ្ទាល់ របស់ពួកវាប៉ុណ្ណោះ។

ពេលខ្លះ កូនៗអាចមានប្រធានបទមួយសំខាន់ ទាក់ទងនឹងអារម្មណ៍កន្ទល់ឬបញ្ហារៀនសូត្រ ឬក៏បញ្ហាសិស្សរៀនទៅជាមួយគ្នា ហើយអាចប្រាថ្នាជជែកបញ្ហាទាំងឡាយនេះ ជាមួយឪពុក-ម្ដាយ។ ដូច្នេះ ឪពុក-ម្ដាយត្រូវស្ដាប់បញ្ហាទាំងឡាយនោះ ដោយយកចិត្តទុកដាក់ ដោយអំណត់ និងដោយក្ដីមេត្តា។ ក្នុងអំឡុងពេលពិភាក្សា បើក្មេងៗប្រើភាសាប្រមាថ ឪពុក-ម្ដាយត្រូវទប់ស្កាត់ណែនាំពួកគេភ្លាម បន្ទាប់មកអនុញ្ញាតឲ្យពួកគេបន្តការពិភាក្សា ។ ប្រសិនបើពួកគេបង្ហាញឲ្យឃើញ

ចិត្តវេគ (ក្រេវក្រោធយាំស្រែក) ឪពុក-ម្តាយមិនគប្បីដើរតួជាអ្នកកាន់ជើងពួកគេ (a co-dependent role) ហើយប្រែក្លាយជាមានអារម្មណ៍ក្រេវក្រោធទេ ប៉ុន្តែត្រូវស្តាប់ដោយយកចិត្តទុកដាក់ ដោយក្តីសន្សឹមដើម្បីជួយពួកគេ ។ និយាយម្យ៉ាងទៀត កាលណាក្មេងៗក្រោធខឹងឪពុក-ម្តាយគប្បីស្តាប់ពួកគេ ដោយយកចិត្តទុកដាក់ហើយ ដោយអំណត់ ទប់ខ្លួនឯងមិនឲ្យក្រោធខឹងដើម្បីធ្វើខ្លួនឯង ឲ្យមានប្រសិទ្ធភាពក្នុងការជួយក្មេងៗ ។

ឪពុកម្តាយនិងកូនៗ គប្បីមានការពិភាក្សាគ្នា ដោយចំហ និងដោយស្និទ្ធិស្នាល តាមពេលកំណត់ទៀងទាត់ ។ ឪពុក-ម្តាយត្រូវចេះទទួលស្គាល់កំហុសរបស់ខ្លួន ហើយសុំទោសចំពោះកូនៗ ។ បើឪពុក-ម្តាយស្រែកគំហក ជេរប្រទេច ឬច្រឡោតខឹងគេគប្បីសុំទោសចំពោះកូនៗភ្លាម ឬ ពេលក្រោយមក ហើយពន្យល់ហេតុផលថា ហេតុអ្វីពួកគាត់បានប្រកាន់យកនូវផ្លូវនោះ ។ ឪពុក-ម្តាយ គប្បីប្តេជ្ញាចិត្តមិនប្រព្រឹត្តអាកប្បកិរិយាបែបហ្នឹងជាថ្មីទៀត នៅចំពោះមុខកូនៗ ។ កូនៗក៏គប្បីត្រូវបានលើកទឹកចិត្ត ឲ្យទទួលស្គាល់កំហុសរបស់ខ្លួន ហើយសុំទោសឪពុក-ម្តាយផងដែរ ។ ឪពុក-ម្តាយគប្បីចេះឲ្យតម្លៃ ទៅលើអ្វីៗដែលល្អ ដែលកូនៗបានធ្វើ ហើយទទួលស្គាល់សេចក្តីរីកចម្រើន ដែលគេបានធ្វើ ។ ផ្ទាន់ហើយទំនិងទណ្ឌកម្ម ត្រូវអនុវត្តចំពោះមនុស្សគ្រប់គ្នា ។

ប្រសិនបើ មានកូនច្រើននាក់នៅក្នុងគ្រួសារ ឪពុក-ម្តាយ ត្រូវប្រកាន់យកអាកប្បកិរិយាល្អស្មើគ្នា ចំពោះកូនៗទាំងអស់ ។ ក្នុងការដោះ

ស្រាយបញ្ហាគ្រួសារ ឪពុក-ម្ដាយ ត្រូវប្រុងប្រយ័ត្នជានិច្ច ដោះស្រាយឲ្យមានយុត្តិធម៌ ចំពោះកូនៗទាំងអស់ ។ បើឪពុក-ម្ដាយសរសើរកូនម្នាក់ជាងកូនៗដទៃទៀត នៅចំពោះមុខមនុស្សគ្រប់គ្នា កូនៗរបស់គេអាចមានចិត្តច្រណែន ចំពោះកូនដែលបានទទួលសេចក្ដីសរសើរ ។ កាលណាឪពុក-ម្ដាយមានទឹកចិត្ត ពោរពេញដោយក្ដីមេត្តា និងករុណា ការដោះស្រាយបញ្ហាណាក៏ដោយ ក្នុងគ្រួសារ និងមានសេចក្ដីងាយស្រួល ។

ឪពុក-ម្ដាយ គប្បីប្រព្រឹត្តចំពោះកូន ប្រកបដោយកិត្តិយស និងសេចក្ដីថ្លៃថ្នូរ បីដូចជាមនុស្សដ៏អស្ចារ្យ ដែលនឹងទទួលការខុសត្រូវរបស់ពិភពលោក នៅក្នុងដៃរបស់ពួកគេ ថ្ងៃណាមួយ ។

រាល់ពេលដែលកូនៗធ្វើអ្វីមួយល្អ ឪពុក-ម្ដាយ មិនត្រូវភ្លេចសរសើរ និងឲ្យរង្វាន់ពួកគេទេ យ៉ាងហោចណាស់ ក៏ជាពាក្យសំដីដែរ។ កាលណាកូនៗធ្វើអ្វីមួយផ្ដេសផ្ដាស ខុសសីលធម៌ និងបង្កអន្តរាយ .ឪពុក-ម្ដាយត្រូវកំហឹងខប់ ហើយប្រាប់ពួកគេដោយផ្ទាល់។ ឪពុក-ម្ដាយត្រូវដឹងថា ពេលណាត្រូវស្ដីបន្ទោសពួកគេ ដោយសម្ងាត់ និងពេលណាត្រូវស្ដីបន្ទោសពួកគេ នៅក្នុងការជួបជុំគ្រួសារ នៅចំពោះមុខមនុស្សគ្រប់គ្នា។ ឪពុក-ម្ដាយ មិនត្រូវរិះគន់តិះដៀលគ្នាទៅវិញទៅមក នៅចំពោះមុខកូនៗខ្លួនឯងផងដែរទេ ។ ពួកគេត្រូវរកឱកាសប្រជុំជាសម្ងាត់ ដើម្បីជជែកដោះស្រាយបញ្ហា ។

ឪពុក-ម្ដាយ ត្រូវជ្រើសរើសពាក្យសំដីត្រូវ អាកប្បកិរិយាត្រូវ ពេលវេលាត្រូវ និងទីកន្លែងត្រូវ ដើម្បីនិយាយប្រាប់រឿងត្រូវដល់កូនៗ ។ ក្នុងគ្រប់ស្ថានភាព ឪពុក-ម្ដាយ គប្បីបញ្ជាក់ថា ពួកគេពិតជាស្រឡាញ់

កូនៗ របស់ពួកគេដោយស្មោះស្ម័គ្រមែន ។ ពួកគេត្រូវអះអាង ចំពោះកូនរបស់ពួកគេថា ពួកគេស្រឡាញ់កូនៗរបស់គេណាស់ ។ បើលោកអ្នក បន្តុះបង្អាប់កូនៗ នូវចំពោះមុខមនុស្សគ្រប់គ្នា កូនៗអាចធ្វើកំហុសជាច្រើនទៀត ដោយលួចលាក់ ពួកវានឹងរៀនធ្វើជាអ្នកមានពុតត្បុតផងដែរ។ ឪពុក-ម្តាយ ត្រូវតែស្មោះត្រង់ជាមួយកូនៗ។ បើឪពុកម្តាយមិនស្មោះត្រង់ កូនៗបាត់សេចក្តីគោរព ចំពោះឪពុក-ម្តាយ។ លោកអ្នកជាឪពុក-ម្តាយ មិនអាចទាមទារ ឲ្យមានសេចក្តីគោរពបានទេ បើលោកអ្នកមិនស័ក្តិសម នឹងទទួលសេចក្តីគោរពនោះ ។ លោកអ្នកត្រូវរៀនចាប់យកសេចក្តីគោរព ដោយឥរិយាបថ និងអាកប្បកិរិយាផ្ទាល់របស់លោកអ្នកចំពោះកូនៗ ។ ហើយចូរកុំរំពឹង ចង់ធ្វើជាគ្រូរបស់វារាល់តែពេលនោះ កូនៗក៏អាចជាគ្រូដ៏ល្អ ចំពោះឪពុក-ម្តាយបានដែរ ។

“ រឿងដ៏ប្រសើរមួយ ដែលឪពុក-ម្តាយអាចធ្វើដើម្បីកសាង និងទ្រទ្រង់ទំនាក់ទំនងមិត្តភាព និងចំណងស្នេហា ជាមួយកូនគឺត្រូវចំណាយពេលវេលាខ្លះហ្វឹកហាត់មេត្តា និងករុណា ។ ឪពុក-ម្តាយ គប្បីបង្កើតជាទម្លាប់លើកទឹកចិត្តកូនៗ ឲ្យចូលរួមជាមួយខ្លួន ចំនួនបួនដប់នាទីជារៀងរាល់ថ្ងៃ ហ្វឹកហាត់ធ្វើភាវនា (សមាធិ) ។ នៅក្នុងគ្រួសារកាន់ពុទ្ធសាសនាល្អៗជាច្រើន ឪពុក-ម្តាយ និងកូនៗតែងចំណាយពេលបួនដប់នាទីសូធ្យធម៌។ ពួកគេរៀបចំឲ្យមាន អាសនៈព្រះពុទ្ធរូបតូចមួយ នៅផ្ទះ ដែលគេតែងជួបជុំគ្នារាល់ថ្ងៃ យ៉ាងហោចណាស់ ក៏បួនដប់នាទីដែរ ”។

**ព្រះតេជ.បណ្ឌិត ហោនឆោល គុណរតនៈ , ស.រ.អា**

# ប្រវត្តិរបស់អដ្ឋកថា (តចប់)

ដោយ **ង៉ាន់ ចាន់សារ៉េន**

## ការមករបស់អដ្ឋកថា

កាលពុទ្ធសករាជជាងប្រមាណ៩៥៦ឆ្នាំ ក្នុងតំបន់ពុទ្ធគយា ខេត្ត គយា រដ្ឋពិហារ ប្រទេសឥណ្ឌា មានព្រាហ្មណ៍ម្នាក់ ជាអ្នកជំនាញ ក្នុងវិជ្ជាការព្រាហ្មណ៍ ដូចជាត្រៃវេទ និងគោលប្រាជ្ញារបស់លទ្ធិផ្សេងៗ ដែលមានប្រាកដក្នុងសម័យនោះ ជាអ្នកបណ្ឌិតវាទៈ មិនធ្លាប់បរាជ័យជាមួយនឹងនរណាសោះឡើយ ។ តែមានសម័យថ្ងៃមួយ បានបណ្ឌិតវាទៈជាមួយនឹងព្រះរេវតត្ថេរៈ ប្រាកដថាចាញ់ព្រះថេរៈ ទើបព្រមទទួលខ្លួនធ្វើជាសិស្ស ហើយសូមបួសជាភិក្ខុ ជាមួយនឹងព្រះថេរៈ ដើម្បីត្រូវការពុទ្ធមន្តក្នុងទីបំផុតក៏បាន សិក្សាព្រះត្រៃបិដក រហូតមានសេចក្ដីជំនាញ ។ តែមុននោះ ព្រះថេរៈមានឈ្មោះអ្វីមិនប្រាកដ[១] តមកខាងក្រោយ ព្រះថេរៈតែងបករណ៍ផ្សេងៗ រហូតមានឈ្មោះសម្លេង ហើយទើបបានទទួលនាមថា **"ពុទ្ធឃោសៈ"** ព្រោះថា ក្នុងសម័យនោះ លោកមានឈ្មោះ សម្លេងពីរោះខ្ទរខ្ទាយកិត្តិស័ព្ទជាទីបំផុត ។

នេះជាប្រវត្តិពោលតាមគម្ពីរមហាវំស ( បរិច្ឆេទ៣៧ គាថា-

១-ច្បាប់ខ្លះថា មុននឹងបួសព្រះថេរៈព្រះនាមថា ( ឃោសៈ ) ។

២១៥ ) ពោលថា ព្រះពុទ្ធឃោសាចារ្យ កើតត្រង់ប្រទេសឥណ្ឌា ក្នុងស្រុកជិតដើមពោធិព្រឹក្ស តំបន់ពុទ្ធគយា ខេត្តគយារដ្ឋពិហារ ក្នុងគម្ពីរពុទ្ធឃោសុប្បត្តិ ( ច្បាប់ភូមាទំព័រ១ ) តែងអាស្រ័យគម្ពីរមហាវំសនេះ ក៏ពោលទុកយ៉ាងនេះដូចគ្នា ។ រីឯប្រវត្តិព្រះពុទ្ធ-ឃោសាចារ្យ មានក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់ពុទ្ធឃោសប្បវត្តិកថា ពីទំព័រ ១៤៥២-១៤៦៤ នោះក៏ជាប្រវត្តិរឿងរ៉ាវ ដែលព្រះថេរៈនៅក្នុងក្រុងឈៀងហ្មៃ កាន់យកតាមគម្ពីរមហាវំសតែងឡើងដែរ ។ សូមអ្នកសិក្សាជ្រាបថា ប្រវត្តិនោះ មិនមែនព្រះពុទ្ធឃោសាចារ្យលោកពោលទុកខ្លួនឯងទេ ឬកើតឡើងខាងក្រោយលោកបន្តិចបន្តួចនោះក៏ទេ វិសុទ្ធិមគ្គច្បាប់ឆដ្ឋសង្គាយនាប្រទេសភូមា មិនមានពុទ្ធ-ឃោសប្បវត្តិកថានៅផ្នែកខាងចុង ដូចគម្ពីរវិសុទ្ធិមគ្គខ្មែរយើងនោះឡើយ ។ ហើយយើងអាចសង្កេតឃើញថា ពុទ្ធឃោសប្បវត្តិកថាដែលមានក្នុងវិសុទ្ធិមគ្គនោះ សូម្បីការពោលពីការរចនាអដ្ឋកថានោះក៏ខុសពីព្រះពុទ្ធឃោសាចារ្យ ដែលលោកជាអ្នករៀបរៀងអដ្ឋកថាថ្មីឡើងដែរ ដូចនៅត្រង់ទំព័រ១៤៥៧ បន្ទាត់ ១៤ ថា៖ **អាយស្មា ហិ ពុទ្ធឃោសោ នាម កុរុន្ទដ្ឋកថំ សីហឡភាសតោ បរិវត្តេត្វា មូលភាសាយ មាគធិកាយ និរុត្តិយា សមន្តបាសាទិកា នាម វិនយបិដកដ្ឋកថា អកាសិ** ។ មែនពិតព្រះពុទ្ធឃោសាដ៏មានអាយុបានរចនានូវអដ្ឋកថាវិនយបិដក ឈ្មោះសមន្តបាសាទិកា ដោយប្រែអដ្ឋកថា ករុន្ទីពីភាសាសីហឡៈ មកកាន់ភាសាមគធៈ ដែលជាមូលភាសាមុនគេបង្អស់ ។ ហើយនៅពោលថា លោកប្រែ

មហាអដ្ឋកថា ធ្វើជាអដ្ឋកថា សុត្តន្តបិដក មានសុមង្គលវិលាសិនី ជាដើម ។ លោកបានប្រែមហាបច្ចរី ធ្វើជាអដ្ឋកថាអភិធម្មបិដក មានអដ្ឋសាលិនីជាដើម ។ តាមពិត អដ្ឋកថាទាំងបីដែលមានក្នុងកោះសីហឡ:នោះ គឺមហាអដ្ឋកថា មហាបច្ចរី កុរុន្ទី តែយើងមើលក្នុងនិគមនកថា របស់ព្រះពុទ្ធឃោសាចារ្យ ក្នុងសមន្តប្បាសាទិកា មើលលោកពោលថា កាន់យកមហាអដ្ឋកថាជាគោលធំ ក្នុងការរចនានូវអដ្ឋកថាសមន្តប្បាសាទិកា មិនមែនកាន់យកកុរុន្ទីក្នុងការធ្វើអដ្ឋកថាវិនយបិដកនោះទេ ។ ហើយអដ្ឋសាលិនីអដ្ឋកថាធម្មសង្គណី ព្រះពុទ្ធឃោសាចារ្យបានរចនា តាំងពីលោកនៅក្នុងជម្ពូទីបមកម៉េះ មិនមែនមករចនាក្នុងកោះសីហឡ: ដូចប្រវត្តិពោលក្នុងវិសុទ្ធិមគ្គនោះទេ ។ អ្នកប្រាជ្ញវិជ្ជាផ្នែកនិរុត្តិសាស្ត្របានពោលថា ប្រវត្តិព្រះពុទ្ធឃោ-សាចារ្យ ដែលមានក្នុងវិសុទ្ធិមគ្គនោះ ព្រះថេរៈនៅក្នុងក្រុងចៀងហៃ្ម រចនាបន្ថែមលើវិសុទ្ធិមគ្គឡើង ព្រោះវិសុទ្ធិមគ្គប្រទេសខ្ះ មិនមានពុទ្ធឃោសប្បវត្តិកថានេះទេ ។

ចំណែកនៅក្នុងគម្ពីរចូឡគន្ធវំសពោលថា ព្រះពុទ្ធឃោសាចា-ចារ្យកើតក្នុងត្រកូលព្រាហ្មណ៍ បិតានាមថាកេសិព្រាហ្មណ៍ ជាបុរោ-ហិតរបស់ព្រះរាជា លោកកើតនៅក្នុងឃោសកគ្រាម ក្នុងមគធរដ្ឋ ។

តែអ្នកបុរាណគតិ មិនព្រមទទួលការឃើញយ៉ាងនេះ ព្រោះក្នុងនិគមនកថារបស់វិសុទ្ធិមគ្គ ៣/១៤៥០ពោលថា **មោរណ្ឌខេដកវត្តព្វេន** អ្នកពោលថា កើតត្រង់ស្រុកមោរណ្ឌ: (ស្រុកពងក្ងោក) ស្រុកនេះបច្ចុប្បន្នស្ថិតនៅត្រង់តណ្ឌាខាងត្បូងដែនគុន្តូ មានស្ថានទី ២ នៃ-

ឈ្មោះកោតនេមលិបុរី និងគុន្ទលុបល្លិចាយពីក្រុងអមរាវតី ៥៨ មែល៍ ឆ្ងាយពីស្ថានទីនាគារជុនកោណ្ឌៈ ៥១ មែល៍ៗ ស្ថានទីទាំងនេះ នៅមាន បុរាណវត្ថុខាងពុទ្ធសាសនាសេសសល់ រហូតដល់បច្ចុប្បន្ន ។ ពាក្យថា **នេមលិ** ភាសាតេលគូ ប្រែថា ក្ងោក ពាក្យថា គុន្ទលុ ប្រែថា ពង ដូច្នោះអ្នកបុរាណគតិ ទើបសន្និដ្ឋានថាស្ថានទីទាំងនេះ គឺស្រុកមោរ-ណ្ឌៈ ឬស្រុកពងក្ងោកជាស្រុកកំណើត របស់ព្រះពុទ្ធឃោសាចារ្យ[១] ។ ពាក្យថា **មោរណ្ឌខេដ** ប្រកបរូបស័ព្ទមកពី **មោរ** ក្ងោក **អណ្ឌ** ពង+**ខេដ** ស្រុក ? ពាក្យថា **ខេដ** ជាពាក្យបាលីមកពីភាសាសំស្រ្កឹត ពាក្យនេះក្នុងវចនានុក្រមសំស្រ្កឹត ឲ្យសេចក្តី ៣ យ៉ាង គឺ ស្រុក ខុម និងក្រុងតូច បច្ចុប្បន្ននេះឥណ្ឌាខាងត្បូងនៅហៅស្រុកថា **ខេដ** ដោយ ហេតុដែលមិនបានប្រើពាក្យបាលី ដែលនិយមប្រើថា **មោរណ្ឌគាម-ជាតេន** អ្នកកើតត្រង់ស្រុក **មោរណ្ឌ** តែពោលជាសំនួនថា **មោរណ្ឌ-ខេដកទត្តព្វេន** អ្នកពោលថា កើតត្រង់ស្រុកមោរណ្ឌៈ និងពាក្យនេះ ជាគុណស័ព្ទ ដែលនៅក្រោយបទនាមផ្សេងពីបកតិគុណ ដែលនៅ មុខបទនាម ។ ម្យ៉ាងទៀត ពាក្យនេះ មិនមានជួបក្នុងអដ្ឋកថាដទៃ ដែលព្រះពុទ្ធឃោសាចារ្យតែង ដូច្នោះទើបសន្និដ្ឋានបានថា ពាក្យនេះ គង់ព្រះថេរៈដទៃ ដែលមានជីវិតរួមសម័យជាមួយ ព្រះពុទ្ធឃោសា-ចារ្យ ជាអ្នកស្គាល់ស្រុកកំណើតលោក បានបន្ថែមក្នុងខាងក្រោយ ។

១-History of Theravada Buddhism South Asia by kanai lal Hazara p. 64 - 65

ពាក្យថាមោរណ្ឌគ្រាមនេះ ជាការទទួលស្គាល់របស់ព្រះថេរៈ អ្នកស្ទាត់ជំនាញក្នុងព្រះត្រៃបិដក គឺព្រះសោភណមហាថេរៈ មហា-ស៊ីស្សាជោ ជាអ្នកស្ទួរក្នុងការធ្វើឆដ្ឋសង្គាយនា ក្នុងប្រទេសភូមា លោកជាអតីតចៅសម្នាក់កម្មដ្ឋានមហាស៊ី ខេត្តយ៉ាងកុងប្រទេសភូមា ព.ស.២៥០៣ ចំណែកចងក្រងប្រព័ន្ធដោយព្រះកាសេដ្ឋាភិវិស ត:ប:-យេកាន់ស្សាជោ អតីតចៅអាវាសវត្តធម្មិកាកម ខេត្តតាន់លៈយិន ដែលលោកតែងសរុបសេចក្តី ចងក្រងតាមការអារាធនារបស់ព្រះ-សោភណមហាថេរៈ ។ ម្យ៉ាងទៀតព្រះថេរៈអង្គនេះជាតិបិដក-កោសលត្ថេរ ជាអ្នកឈ្លាសក្នុងបិដកទាំងបី គ្រាន់តែលោកនៅជាសាមណេរ អាចទន្ទេញចាំជាមុខបាឋៈវិនយបិដកទាំងអស់ បើគិតខ្នារយើងមាន ១៣ ក្បាល ។

នៅក្នុងការប្រព័ន្ធជាគាថា របស់លោកត្រង់គាថាទី ៥ ថា :

**មោរណ្ឌគាមម្ហិ សតត្ថ ជាតោ**<br>
**បុញ្ញានិតោ ទិប្បកុលម្ហិ សម្ភា**<br>
**សុរស្ស លោកត្ថសមាទហន្តំ**<br>
**ឧប្បជ្ជនាយានុរុណោទ វំសិ** ។<br>
ពន្លឺអរុណបើកផ្លូវ ដើម្បីការរះឡើង<br>
នៃព្រះអាទិត្យ ដើម្បីនាំមកនូវ<br>
ប្រយោជន៍ដល់សត្វលោកយ៉ាងណា<br>
ព្រះពុទ្ធឃោសាចារ្យ អ្នកមានបុណ្យ

កុសលកម្មទំនុកបម្រុងហើយ កើត
ឡើងដ៏ល្អ ក្នុងត្រកូលព្រាហ្មណ៍ នា
ស្រុកមោរណ្ឌ: យ៉ាងនោះដែរ ។

ពាក្យដែលថា ព្រះពុទ្ធឃោសាចារ្យ កើតត្រង់ស្រុកពង ក្រោកនោះ ជាការទទួលស្គាល់របស់អ្នកប្រាជ្ញ ដែលជាអ្នកទ្រទ្រង់ ព្រះត្រៃបិដកទាំងឡាយពិតប្រាកដ ។

ក្នុងកាលព្រះថេរៈ នៅអាស្រ័យជាមួយព្រះឧបជ្ឈាយ៍ ព្រះ-ថេរៈបានរចនាគម្ពីរទុក ៣ គម្ពីរគឺ :

**១-ញាណោទយ** គម្ពីរដែលព្រះថេរៈតែងដំបូង

**២-អដ្ឋសាលិនីអដ្ឋកថា** កែធម្មសង្គណី

**៣-បរិត្តអដ្ឋកថា** អធិប្បាយព្រះត្រៃបិដក ច្បាប់សង្ខេប ។

កាលព្រះរេវតៈជ្រាបស្នាដៃដ៏ល្អ របស់ព្រះពុទ្ធឃោសាចារ្យ ទើបណែនាំព្រះថេរៈ ឲ្យនិមន្តទៅកោះសីហឡៈ[១] ដើម្បីប្រែអដ្ឋកថា ដែលស្ថិតនៅជាភាសាសីហឡៈ ឲ្យមកជាភាសាមគធៈវិញ ដោយ ថាសម័យនោះ ក្នុងជម្ពូទ្វីប "ប្រទេសឥណ្ឌា" មានសល់តែចំពោះ បាលីព្រះត្រៃបិដកដាច់ៗ អដ្ឋកថាដែលជារបស់អាចារ្យរក៍ទផ្សេងៗ ប៉ុណ្ណោះ គម្ពីរដាច់ៗនេះ ទីងរកបានអំពីកោះសីហឡៈ ។ ដូច្នោះ ព្រះពុទ្ធឃោសាចារ្យ បាននិមន្តទៅកាន់កោះសីហឡៈ ដោយបាន សិក្សាអដ្ឋកថា និងអាចារ្យរក៍ទផ្សេងៗ ក្នុងសម្នាក់មហាវិហារ ហេតុ

១- ប្រទេសស្រីលង្កា

ចប់អស់ ។ ហើយក៏សូមប្រែនូវអដ្ឋកថា ដែលនៅជាភាសាសីហឡៈ មកជាភាសាមគធៈវិញ តែព្រះថេរៈនៅក្នុងកោះសីហឡៈ មានព្រះសង្ឃបាលជាដើម មិនទាន់បានឃើញស្នាដៃ របស់លោកនៅឡើយ ហើយក៏ប្រគល់នូវគាថា ដែលមានក្នុងគម្ពីរសំយុត្តនិកាយ សគាថវគ្គ លេខ ២៩ / ៣៤ ដែលមានបាលីដើមថា :

**សីលេ បតិដ្ឋាយ នរោ សបញ្ញោ**
**ចិត្តំ បញ្ញញ្ច ភាវយំ**
**អាតាបី និបកោ ភិក្ខុ**
**សោ ឥមំ វិជដយេ ជដំ ។**

នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីល
ហើយ ចម្រើននូវសមាធិចិត្ត និង
វិបស្សនាបញ្ញា ជាអ្នកមានព្យាយាម
ដុតកំដៅកិលេស ប្រកបដោយបារិ-
ហារិយកប្បញ្ញា ជាអ្នកឃើញភ័យ
ក្នុងសង្សារ បុគ្គលនោះ ទើបកាប់ក្តារ
នូវតណ្ហា ជាគ្រឿងចាក់ស្រេះនេះបាន ។

ព្រះថេរៈទាំងនោះ លើកគាថានេះមកហើយពោលថា បើអ្នកដ៏មានអាយុ អាចពង្រីកនូវគាថានេះ ជាភាសាមគធៈយ៉ាងល្អឯកខ្ញុំព្រះករុណានឹងប្រគល់នូវ ការប្រែគម្ពីរអដ្ឋកថា ពីសីហឡភាសាទៅមគធភាសាដល់លោក ។ ព្រះពុទ្ធឃោសាចារ្យបានទទួលក្នុងការពង្រីកសេចក្តីក្នុងគាថានោះ រហូតបាន ៣ និទ្ទេសគឺ សីល-

និទ្ទេស សមាធិនិទ្ទេស បញ្ញានិទ្ទេស ដែលយើងធ្លាប់ឮឈ្មោះថា គម្ពីរវិសុទ្ធិមគ្គនោះ។ កាលដែលព្រះពុទ្ធឃោសាចារ្យរចនាបានរួចស្រេចហើយ ក៏ប្រគល់ឲ្យព្រះថេរៈទាំងឡាយ មានព្រះសង្ឃបាលជាដើមមើលក្នុងកាលណោះ ព្រះសង្ឃបានឃើញស្នាដៃព្រះពុទ្ធឃោ-សាចារ្យដ៏ល្អឯក ក៏បានប្រគល់នូវការប្រែអដ្ឋកថា ឲ្យជាការៈរបស់ព្រះពុទ្ធឃោសាចារ្យ ។ ចំណែកព្រះពុទ្ធឃោសាចារ្យ ក៏ចាប់ផ្ដើមរចនាអដ្ឋកថាថ្មីឡើង"អភិនវអដ្ឋកថា"ចាប់ផ្ដើមអំពី គម្ពីរវិសុទ្ធិមគ្គដោយប្រកាន់យកមហាអដ្ឋកថាចាស់ " បោរាណអដ្ឋកថា "ជាដើមជាគោល ហើយដាក់ឈ្មោះថ្មីថា "**អភិនវអដ្ឋកថា**" ។

ចំណែកអដ្ឋកថា ដែលមានសេចក្ដីពិស្ដារ ព្រះថេរៈក៏រចនារៀបរៀងតាមគម្ពីរដើម តែកាត់សេចក្ដីអធិប្បាយដដែលៗ ចេញបន្សល់ទុកត្រឹមតែពាក្យអធិប្បាយ និងសេចក្ដីវិនិច្ឆ័យ ដែលឃើញថាមានប្រយោជន៍ពិតៗ ដោយឲ្យឈ្មោះ អដ្ឋកថាប្រភេទនេះថា "**សង្គហអដ្ឋកថា**" ។

ម្យ៉ាងទៀត សូម្បីអដ្ឋកថាទាំងឡាយ ដែលព្រះថេរៈដទៃមានធម្មបាលត្ថេរៈ ឧបសេនត្ថេរៈជាដើម លោករចនាទុកក៏ជា"**អភិនវអដ្ឋកថា**" ដូចគ្នា ។

## ការអធិប្បាយរបស់អដ្ឋកថា

ការអធិប្បាយរបស់អដ្ឋកថា ចែកចេញជាពីរប្រភេទគឺ អធិប្បាយព្រះបាលី តាមលំដាប់នៃបាឋៈ និងអធិប្បាយព្រះបាលី

*ដោយសង្ខេប :*

**១_អធិប្បាយព្រះបាលីតាមលំដាប់នៃបាឋ:**

*អដ្ឋកថាដែលអធិប្បាយព្រះបាលី តាមលំដាប់នៃបាឋ:គឺ អធិប្បាយព្រះបាលី ដែលព្រះធម្មសង្គាហកាចារ្យ សង្គាយនាតាម លំដាប់នៃបាឋ: ដូចអធិប្បាយបាឋ:ក្នុងព្រះវិន័យ តាមលំដាប់កណ្ឌ តាមលំដាប់វគ្គ តាមលំដាប់សិក្ខាបទ តាំងពីដើមរហូតដល់ចប់ "អា, បា, ម, ចុ ,ប " ។*

*អធិប្បាយបាឋ: ក្នុងព្រះសូត្រតាមលំដាប់សូត្រ តាមលំ-ដាប់និកាយ តាំងតែពីដើមរហូតចប់"ទី, ម, សំ, អំ ខុ "។*

*អធិប្បាយបាឋ:ក្នុងព្រះអភិធម្ម ក៏អធិប្បាយតាមលំដាប់បទ មាតិកា តាមលំដាប់បទនិទ្ទេស "សំ, វិ, ធា, បុ, ក, យ, ប" តាំងតែពីដើមរហូតចប់ អធិប្បាយយ៉ាងទូលំទូលាយដ៏ពិស្តារ ។ អដ្ឋកថាដែលអធិប្បាយ ព្រះបាលីតាមលំដាប់នៃបាឋ: ដូចជាគម្ពីរ សមន្តប្បាសាទិកា" អធិប្បាយព្រះវិន័យ " សុមង្គលវិលាសិនី " អធិប្បាយទីឃនិកាយ " ។ ល ។ រហូតចប់ព្រះសូត្រ គម្ពីរបញ្ចប្បករណ៍ឈ្មោះ* **បរមត្ថទីបនី** *" អធិប្បាយ ព្រះអភិធម្ម ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុ យមក: បដ្ឋាន " ។*

**២_អធិប្បាយព្រះបាលីដោយសង្ខេប**

*អដ្ឋកថាអធិប្បាយព្រះបាលីដោយសង្ខេបនោះ ជាអដ្ឋកថា*

គម្ពីរក្បាលតូច ៗ ។

អធិប្បាយព្រះបាលីដោយសង្ខេប ចំពោះសេចក្ដីសំខាន់ រួបរួមទុកក្នុងគម្ពីរជាមួយគ្នា អធិប្បាយប្រមូលសេចក្ដីជាសារៈក្នុងបិដកទាំង ៣ ឬ ចំពោះក្នុងរឿងខ្លះ ៗ ។ អធិប្បាយប្រមូលបិដកទាំង ៣ ដូចជាគម្ពីរវិសុទ្ធិមគ្គដែលសង្ខេប ចំណែកអដ្ឋកថាបិដកទាំង ៣ ទុកក្នុងគម្ពីរតែមួយ ដោយអាស្រ័យបោរាណអដ្ឋកថា ព្រះពុទ្ធឃោសាចារ្យរួបរួមពាក្យអធិប្បាយ វិនិច្ឆ័យផ្សេងៗ អំពីបោរាណអដ្ឋកថាមករចនាទុក ក្នុងវិសុទ្ធិមគ្គ សូម្បីបទពន្លឺកបទវិនិច្ឆ័យឬសាធកៈផ្សេងៗ សុទ្ធតែនាំមកអំពីបោរាណអដ្ឋកថាទាំងនោះដែរ ។ ព្រះថេរៈមិនបានរចនាដោយអត្តនោម័តិ តែព្រះថេរៈរចនាដោយប្រែ និងរៀបរៀងអំពីបោរាណអដ្ឋកថា ដែលចារឹកទុកដោយភាសាសីហឡៈ តែលោកអ្នករចនាក៏បញ្ជាក់ថា គម្ពីរវិសុទ្ធិ-មគ្គជាគម្ពីរអដ្ឋកថា អធិប្បាយព្រះត្រៃបិដក ដូចដែលលោកបានពោលទុកក្នុងពាក្យនិគម នៃអដ្ឋកថានិកាយនីមួយៗថា គម្ពីរវិសុទ្ធិមគ្គ ជាអដ្ឋកថាដែលរៀបរៀង ដើម្បីអធិប្បាយព្រះបាលីក្នុងនិកាយទាំង ៤ មានសេចក្ដីវែង ៥៩ ភាណវារៈ ដូច្នេះ កាលនឹងរួមភាណវារៈរបស់អដ្ឋកថា នឹងត្រូវរួមភាណវារៈរបស់វិសុទ្ធិ-មគ្គចូលផង ។

សង្ខេបអដ្ឋកថា ដែលអធិប្បាយចំពោះរឿង ដូចគម្ពីរកង្ខា-វិតរណីអដ្ឋកថា អធិប្បាយព្រះវិន័យចំពោះសីលរបស់ភិក្ខុ និង

ភិក្ខុនីជាដើម ។

សង្ខេបអដ្ឋកថាចែកជា ៣ ខ្សែ គឺ ÷

**១.សង្ខេបអដ្ឋកថាព្រះវិន័យគឺ** ÷

-កង្ខាវិតរណីអដ្ឋកថា អធិប្បាយបាតិមោក្ខ ដោយសង្ខេប

-វិនយសង្គហអដ្ឋកថា អធិប្បាយព្រះវិនយបិដក ដោយសង្ខេប

-ខុទ្ទសិក្ខា អធិប្បាយព្រះវិន័យជាបទបង់ក្រង " គាថា "

-មូលសិក្ខា អធិប្បាយព្រះវិន័យជាកម្រងកែវផ្សំបង់ក្រង

-វិនយវិនិច្ឆ័យ អធិប្បាយព្រះវិន័យជាបទបង់ក្រង

-ឧត្តរវិនិច្ឆ័យ អធិប្បាយព្រះវិន័យជាបទបង់ក្រង

**២.សង្ខេបអដ្ឋកថាខ្សែព្រះសូត្រ គឺ** ÷

-វិសុទ្ធិមគ្គ អធិប្បាយបិដកទាំង ៣

**៣.សង្ខេបអដ្ឋកថាខ្សែព្រះអភិធម្មគឺ** ÷

-អភិធម្មាវតារ អធិប្បាយអភិធម្មបិដកបង់ក្រង

-អភិធម្មត្ថសង្គហៈ អធិប្បាយព្រះអភិធម្មបិដក ៧ បករណ៍ ដោយសង្ខេប ។

គម្ពីរអដ្ឋកថាដែលព្រះពុទ្ធឃោសត្ថេររចនាគឺ ÷

១-វិសុទ្ធិមគ្គ អធិប្បាយព្រះត្រៃបិដក ដោយសង្ខេប

២-សមន្តប្បាសាទិកា កែព្រះវិនយបិដក

៣-គង្ខាវិតរណី កែបាតិមោក្ខ

៤-សុមង្គលវិលាសិនី កែព្រះសុត្តន្តបិដក ទីឃនិកាយ

៥-បបញ្ចសូទនី កែព្រះសុត្តន្តបិដក មជ្ឈិមនិកាយ

៦-សារត្ថប្បកាសិនី កែព្រះសុត្តន្តបិដក សំយុត្តនិកាយ

៧-មនោរថបូរណី កែព្រះសុត្តន្តបិដក អង្គុត្តរនិកាយ

៨- បរមត្ថជោតិកា អដ្ឋកថា ខុទ្ទកបាឋៈ កែព្រះសុត្តន្តបិដក ខុទ្ទកបាឋៈ

៩-ធម្មបទអដ្ឋកថាកែព្រះសុត្តន្តបិដក ធម្មបទ

១០-បរមត្ថជោតិកា អដ្ឋកថា សុត្តនិបាត កែព្រះសុត្តន្តបិដក សុត្តនិបាត

១១-ជាតកអដ្ឋកថា កែព្រះសុត្តន្តបិដក ជាតក

១២-វិសុទ្ធជនវិលាសិនី អដ្ឋកថាអបទាន កែព្រះសុត្តន្តបិដក អបទាន ថេរគាថា ថេរីគាថា

១៣-អដ្ឋសាលិនី កែព្រះអភិធម្ម ធម្មសង្គណី

១៤-សម្មោហវិនោទនី កែព្រះអភិធម្ម វិភង្គ

១៥-បញ្ចប្បករណ៍ ឈ្មោះ បរមត្ថទីបនី កែព្រះអភិធម្មបិដក ៥ បករណ៍ដ៏សេស

១៦-ញាណោទយៈ គម្ពីរដំបូងដែលលោកតែង

១៧-បរិវារអដ្ឋកថា អធិប្បាយព្រះត្រៃបិដក ច្បាប់សង្ខេប

គម្ពីរអដ្ឋកថាដែលព្រះពុទ្ធទត្តត្ថេរៈរចនាគឺ ÷

១ វិនយវិនិច្ឆយ ប្រមូលសេចក្ដីវិនិច្ឆ័យឧកគោរកន្ទិនិទ្ទេសៈ

២-ឧត្តរវិនិច្ឆយៈ ប្រមូលសេចក្ដីវិនិច្ឆ័យជាប់ទាក់ទង ព្រះវិ-ន័យ អំពីបរិវារអដ្ឋកថា

៣-អភិធម្មាវតារៈ អធិប្បាយព្រះអភិធម្មបិដកដោយ សង្ខេប

៤- មធុរត្ថវិលាសិនី អដ្ឋកថា កែព្រះសុត្តន្តបិដក ពុទ្ធវំស ។

គម្ពីរអដ្ឋកថាដែលព្រះធម្មបាលត្ថេរៈរចនាគឺ ÷

១-ឧទានអដ្ឋកថា ឈ្មោះ បរមត្ថទីបនី កែ

ព្រះសុត្តន្តបិដក ឧទាន

២-ឥតិវុត្តកអដ្ឋកថាឈ្មោះ បរមត្ថទីបនី កែព្រះ

សុត្តន្តបិដក ឥតិវុត្តកៈ

៣-វិមានវត្ថុអដ្ឋកថា ឈ្មោះ បរមត្ថទីបនី កែ សុត្តន្តបិដក

វិមានវត្ថុ

៤-បេតវត្ថុអដ្ឋកថា ឈ្មោះ បរមត្ថទីបនី កែសុត្តន្តបិដក

បេតវត្ថុ

៥-ថេរគាថាអដ្ឋកថា ឈ្មោះ បរមត្ថទីបនី កែព្រះសុត្តន្ត-បិដក ថេរគាថា

៦-ថេរីគាថាអដ្ឋកថា ឈ្មោះ បរមត្ថទីបនី កែសុត្តន្តបិដក

ថេរីគាថា

៧-ចរិយាបិដកអដ្ឋកថា ឈ្មោះ បរមត្ថទីបនី ស្រាយសុត្តន្តបិដក ចរិយាបិដក

៨-នេត្តិអដ្ឋកថា ស្រាយនេត្តិប្បករណ៍

គម្ពីរដែលព្រះថេរៈដទៃៗ ទៀតរចនាគឺ ÷

១-បដិសម្ភិទាមគ្គអដ្ឋកថា ឈ្មោះ សទ្ធម្មប្បកាសិនី ស្រាយសុត្តន្តបិដក បដិសម្ភិទាមគ្គ រចនាដោយ ព្រះមហានាមត្ថេរៈ ។

២-មហានិទ្ទេសអដ្ឋកថា ឈ្មោះ សទ្ធម្មប្បជោតិកា រចនាដោយ មហានាមត្ថេរៈ ស្រាយសុត្តន្តបិដក មហានិទ្ទេស ។

៣-ចូឡនិទ្ទេសអដ្ឋកថា ឈ្មោះ សទ្ធម្មប្បជោតិកា រចនាដោយ ឧបសេនត្ថេរៈ ស្រាយសុត្តន្តបិដក ចូឡនិទ្ទេស

៤-វិនយសង្គហអដ្ឋកថា អធិប្បាយវិនយបិដក ដោយប្រមូល រចនាដោយព្រះសារីបុត្តត្ថេរៈ ជនជាតិ ស្រីលង្កា ព.ស. ១៦០០

៥-មូលសិក្ខាអដ្ឋកថា អធិប្បាយព្រះវិនយបិដក ដោយសង្ខេប រចនាដោយព្រះមហាសាមី ជនជាតិស្រីលង្កា

៦-ខុទ្ទសិក្ខាអដ្ឋកថា អធិប្បាយព្រះវិនយបិដក ដោយសង្ខេប រចនាដោយព្រះធម្មសិរិត្ថេរៈ ជនជាតិ ស្រីលង្កា ។

៧-អភិធម្មត្ថសង្គហៈ អធិប្បាយអភិធម្មបិដក ដោយសង្ខេប រចនាដោយព្រះអនុរុទ្ធត្ថេរៈ ជនជាតិស្រីលង្កា ។

៨-គច្ឆាចិតរណីអដ្ឋកថាគណ្ឋី តែងនៅប្រទេសភូមា ដោយព្រះថេរៈនាមថា សទ្ធម្មទន្ទី

៩-គច្ឆាចិតរណីអដ្ឋកថានិស្សយ តែងនៅប្រទេសភូមាមានប្រាកដមកតាំងតែសម័យបុក្កាម ជាគម្ពីរប្រែសព្ទ ។

១០-មង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រ រចនាដោយព្រះសិរិមង្គលាចារ្យជនជាតិឡានណា ត្រង់ក្រុងឆៀងហ៊្មៃប្រទេសថៃ កាល ព.ស. ២០៦០ ។

---

ជនត្រេកអរក្នុងធម៌
អាចនាំមកនូវសេចក្ដីសុខ ។

សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយក
គណៈធម្មយុត្តិកនិកាយ ឥន្ទញ្ញាណោ ( ក.ទ. ) ។

# លក្ខណៈពិសេស
# របស់សម្ដេចព្រះសង្ឃរាជបីព្រះអង្គ

ដោយ ង៉ែត សោភ័ណ

ព្រះពុទ្ធសាសនា និកាយហីនយាន ប្រកាន់តាមថេរវាទ យកព្រះត្រៃបិដកភាសាបាលីជាគោល បានចូលមកប្រតិស្ឋានគង់វង្សក្នុងកម្ពុជរដ្ឋ តាំងពីពុទ្ធសករាជ១៩៦៩មកម្ល៉េះ[១] ។ ព្រះពុទ្ធសាសនាក្នុងរាជ្យស្ដេចមួយអង្គៗ ជួនកាលងើបខ្ពស់ត្រដែតឡើង ជួនកាលទៀត ត្រូវធ្លាក់ចុះជុនជាប អាស្រ័យទៅលើព្រះសមត្ថភាពដឹកនាំរបស់ព្រះចៅផែនដី និងនាហ្មឺនសព្វមុខមន្ត្រី ជាពិសេស ភាពឈ្លាសវៃប៉ិនប្រសប់ របស់សម្ដេចព្រះសង្ឃរាជ និងព្រះរាជាគណៈឋានានុក្រម ក្នុងការទ្រទ្រង់សាសនា ។

តាមរយៈឯកសារប្រវត្តិសាស្ត្រ ព្រះរាជពង្សាវតារខ្មែរ បានបញ្ជាក់ថា សម្ដេចព្រះសង្ឃរាជចំនួនបីព្រះអង្គ អាចចាត់ទុកជាបុគ្គលដ៏ឆ្នើម លើសសម្ដេចសង្ឃរាជអង្គឯទៀត ដូចមានព្រះនាមខាងក្រោមនេះ :

១- សម្ដេចព្រះសុគន្ធាធិបតី **ជឹម** ក្នុងរជ្ជកាលព្រះបាទស្រីធម្មរាជ ឬ ព្រះរាជសម្ភារ

២- សម្ដេចព្រះសុគន្ធាធិបតី **ប៉ុម** ក្នុងរជ្ជកាលព្រះបាទឧទ័យរាជាអង្គតន់

---

១- ជិនកាលមាលីបករណ៍ ទំព័រ ៩៨

៣-សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ក្នុងរជ្ជកាលព្រះបាទនរោត្តមសីហនុ។

សម្តេចព្រះសង្ឃរាជទាំងបីព្រះអង្គនេះ បើទោះបីជាព្រះអង្គសោយទិវង្គតកន្លងផុតទៅហើយក្តី ក៏ប៉ុន្តែព្រះរាជកិត្តិយស កិត្តិស័ព្ទ កិត្តិគុណ បានចារឹកទុកក្នុងឯកសារប្រវត្តិសាស្ត្រ និងបង្កប់ក្នុងដួងចិត្ត ពុទ្ធសាសនិកជនស្រករក្រោយ ដែលពុំអាចបំភ្លេចបានឡើយ។ តើសម្តេចសង្ឃទាំងបីព្រះអង្គនេះ មានព្រះលក្ខណៈជាពិសេស ប្លែកពីជនទាំងពួងដូចម្តេចខ្លះ ? យើងសាកល្បងសិក្សាស្រាវជ្រាវរក នូវព្រះរាជជីវប្រវត្តិ មកលាតត្រដាង តាមលំដាប់លំដោយនៃរជ្ជកាលព្រះមហាក្សត្រដូចតទៅ :

## I ~ សម្តេចព្រះសុគន្ធាធិបតី ព្រះនាម ទៀម

កាលពីបុរាណព្រេងនាយ ព្រះពុទ្ធសាសនា ដែលផ្សាយចូលមកកាន់ព្រះរាជាណាចក្រកម្ពុជាយើង គឺគ្មានគណៈធម្មយុត្តិកនិកាយដូចបច្ចុប្បន្ននេះទេ មានតែមួយគឺគណៈមហានិកាយ ។ រីឯសម្តេចព្រះសង្ឃរាជ ឬសម្តេចព្រះមហាសង្ឃរាជ មានព្រះបរមនាមថា "**សម្តេចព្រះសុគន្ធាធិបតី**" ស្តីទំលើភជាគណៈបាទានុក្រម និងព្រះសង្ឃគ្រប់វត្តអារាមទូទាំងព្រះនគរ ។ ក្នុងរជ្ជកាលព្រះបាទស្រីធម្មរាជាព្រះរាជសម្ភារ មានព្រះមហាថេរមួយព្រះអង្គទ្រង់ព្រះនាម សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណៈធិបតី **ទៀម** ។ ព្រះអង្គ

ប្រកបដោយទិព្វញ្ញាណ ចាក់ធ្លុះក្នុងព្រះត្រៃបិដក ប្រកបក្នុងឈាន លោកិយវិសេសវិសាលណាស់ ។ ទ្រង់ស្ទាត់ជំនាញក្នុងប្រស្នាអាថ៌ បាលីពុំមានទើសទាល់ ដោយគ្មានព្រះសង្ឃអង្គណា អាចយកប្រៀប បាន ។ ព្រះអង្គជាព្រះឧបជ្ឈាយ៍បំបួសស្តេចផែនដី និងជាមហាគរុ តែងទេសនាប្រៀនប្រដៅពុទ្ធបរិស័ទ ពុំខានទៀយព្រះកាយពលឡើយ។

ក្នុងរវាងគ្រិស្តសករាជ ១៦៣៦ ដល់ ១៦៤០ សម្តេចតែង តែផ្តល់នូវព្រះរាជដំបូន្មាន ថ្វាយព្រះចៅផែនដី ដែលជាសិស្ស តាំងសិប ក្នុងទសពិធរាជធម៌ ស្គាល់គតិធម៌ គតិលោក ដើម្បី ដឹកនាំសង្គមកម្ពុជាឲ្យមានវឌ្ឍនភាព។ គួរបញ្ជាក់ថា ព្រះរាជសម្ភារ ក៏ជាព្រះមហាក្សត្រមួយព្រះអង្គ មានព្រះបញ្ញាឆ្លៀវឆ្លាត ទ្រង់ស្ទាត់ ជំនាញក្នុងព្រះត្រៃបិដក និងបានតាក់តែង នូវកំណាព្យកាព្យឃ្លោង ជាច្បាប់ប្រដៅ ព្រមទាំងសាស្ត្រាបាលីផ្សេងៗ ព្រោះតែមានមហា គ្រូដ៏ជំនាញជួយបង្ហាត់បង្រៀន កាលស្តេចសាងព្រះផ្នួសជាបព្វជិត នៅនគរវត្ត ។ ព្រះរាជាអង្គនេះ សោយរាជ្យបានតែបួនឆ្នាំប៉ុណ្ណោះ ក៏ត្រូវមានវិបត្តិស្នេហា រហូតត្រូវបារាំងធ្វើគត់ក្បែរព្រះជន្ម ធ្លាក់ពីលើ ចុងត្នោត គួរឲ្យសោកស្តាយ ព្រោះតែចាញ់កម្លាំងតណ្ហា និងភ្លេច បណ្តាំព្រះគ្រូឧបជ្ឈាយ៍។ សម្តេចព្រះសុគន្ធាធិបតី **ឌឹម** ទ្រង់គង់នៅ ក្នុងវត្តអ្នកតាសឹង នាក្រុងឧដុង្គមានជ័យ ព្រះអង្គបានចងក្រងនូវសា- ស្ត្រា " ច្បាប់ក្រម " ទុកប្រដៅជនផងទាំងពួង ស្នាព្រះហស្តនោះ ត្រូវបានរក្សាទុករហូតដល់សព្វថ្ងៃ ។ យើងសូមដកស្រង់សាស្ត្រា ច្បាប់ក្រមចំនួនបីល្បះ មកបញ្ជាក់ជូនជាកស្តុតាង :

- នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឱ្យលំទោន កុំបីមានច្ចង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍ ។

- នរអ្នកណា ទោះយកអាត្មា ចូលសាសនពុទ្ធរតន៍
ចូរធ្វើឲ្យត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកផ្លូវនិព្វាន ។

- នរអ្នកផង ទោះដឹងយល់ហោង ចិត្តនោះឲ្យហ៊ាន
បំពេញព្រះផ្នួស ដោយព្រះទូន្មាន កុំធ្វើលីកលាន
ដោយចិត្តអន្ធពាល ។

ច្បាប់ប្រដៅខាងលើនេះ ពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពរួចហើយ ប៉ុន្តែនៅក្នុងអារម្ភកថាដាក់ថា "ច្បាប់ក្រម" កើតពីព្រះសង្ឃឧបជ្ឈាយាចារ្យ ដែលរៀនប្រដៅសិស្ស ដោយរកឈ្មោះអ្នកនិពន្ធមិនឃើញ ។ តាមពិត គឺព្រះសុគន្ធាធិបតី **ឌីម** បានតែងទុកមិនអាចប្រកែកបាន ។ សូមមើលឯកសារមហាបុរសខ្មែរផងចុះ ។ ក្រៅពីអត្ថបទស្នាព្រះហស្តខាងលើនេះ សម្តេចព្រះសង្ឃរាជ **ឌីម** នៅមានញាណញៀយ្យ ប្លែកពីមនុស្សទាំងពួងៗ ព្រះអង្គអាចអធិដ្ឋានបារមីឲ្យដើមស្រម៉ ដែលដុះក្បែរជើងក្ពព្រះរាជទ្រព្យ ឲ្យទៅដុះមុខកុដិឯវត្តអ្នកតាសីងបាន ដើម្បីបានផ្លែសម្រាប់ព្រះសង្ឃឆាន់ និងយកធ្វើជាឱសថសម្រាប់កែរោគ ។ ព្រះអង្គអាចជួយរំលត់ភ្លើងដែលឆេះស្រុកចិនឲ្យរលត់បាន គ្រាន់តែជះទឹកមួយផ្តិល សំដៅទៅ

ទិសឧត្តរ និងឧបកិច្ច ដោយលោកិយឈាន ។ ព្រះអង្គទ្រង់ញាណ ដឹងថា ស្តេចក្រុងចិនធ្លាប់កើតជាខ្មែរដ៏មានភក្តីភាព ហើយនៅបម្រើ ព្រះមហានាគត្ថេរ ដែលគង់នៅវត្តកស្សបៈ ។ នៅពេលស្តេចស្រុកចិន ប្រឈួនព្រះសិរ[១]ជាទម្ងន់ ហើយគ្មានគ្រូណាមើលជា ព្រះអង្គបានចាត់ រាជទូតមកក្រុងឧដុង្គ តាមពាក្យហោរា ដើម្បីនិមន្តសម្តេចព្រះសង្ឃ រាជឲ្យជួយព្យាបាល ។ សម្តេចសង្ឃគ្រាន់តែបង្គាប់ ឲ្យពួកសេនា ទាហានចិន ទៅជីកយកឫសឫស្សី ដែលដុះចាក់ស្រះចំលលាដ៏ ក្បាលខ្មោចខ្មែរឈ្មោះ "អាម៉ៅ" ដែលលោកគ្រូមហានាគត្ថេរ ឲ្យគេកប់ នៅក្បែរវត្ត នាជើងភ្នំព្រះរាជទ្រព្យភ្នាម ស្តេចស្រុកចិនក៏បានជាសះ ស្បើយ ពីព្រះរោគឈឺក្បាលនោះមួយរំពេចដែរ ទើបជឿថា ស្តេច ធ្លាប់កើតជាខ្មែរមែន ដោយកុសលផលានិសង្ស ដែលខ្មោចសុខនោះ បម្រើព្រះសង្ឃ លុះរាស្លាប់ទៅ ក៏បានទៅកើតជាស្តេចស្រុកចិន ។ សម្តេចបានត្រាស់បង្គាប់ ឲ្យសេនាមាត្យចិន នាំទេយ្យទានមក ប្រគេនសម្តេចព្រះសង្ឃសុគន្ធាធិបតី **ឌឹម** មានព្រះកិត្តិស័ព្ទល្បីរន្ទឺ រហូតដល់ស្រុកចិន និងនានាប្រទេស ជាវិទូយបុគ្គលដ៏អស្ចារ្យកម្រ រកបាន នាសតវត្សទី ១៧ ។

## II ~ សម្តេចព្រះសុគន្ធាធិបតី ព្រះនាម ប៉ុម

ក្នុងរជ្ជកាលព្រះឧទ័យរាជា " អង្គតន់ " ដែលឡើងសោយរាជ្យសម្បត្តិ ក្នុងគ្រិស្តសករាជ ១៧៧៥ មានព្រះមហាថេរមួយព្រះអង្គ គង់នៅវត្ត

---

១ - ឈឺក្បាល

ស្បែង នាក្រុងឧដុង្គមានជ័យ។ ព្រះអង្គ ជាអ្នកទ្រទ្រង់គម្ពីរព្រះត្រៃ-បិដកចេះចប់ គ្មានទើសទាល់អាចប្រស្នាអ្វីឡើយ។ ព្រះចៅផែនដីទ្រង់សព្វ ព្រះរាជហឫទ័យនឹង ព្រះមហាថេរនេះណាស់ តែងចាត់ក្រុមសង្ឃការី ឲ្យទៅនិមន្តព្រះអង្គចូលទៅសម្តែងធម៌ទេសនា ក្នុងព្រះបរមរាជវាំងក្រុងឧដុង្គ ជារៀងរាល់ថ្ងៃឧបោសថសីល ។ ព្រះអង្គគន់ជាព្រះមហាក្សត្រប្រកាន់ខ្ជាប់ នូវទសពិធរាជធម៌ និងជាព្រះអគ្គ-ពុទ្ធសាសនូបត្ថម្ភក៏ ទ្រង់បរិច្ចាគព្រះរាជទ្រព្យ ប្រដាប់ចតុប្បច្ច័យ ទំនុកបម្រុងព្រះសង្ឃកសាងវត្តអារាម ជម្រុញព្រះពុទ្ធសាសនាបានថ្កុំថ្កើងរុងរឿងប្រពៃក្រៃពេក ។ ព្រះអង្គក៏មានព្រះរាជសទ្ធាផងដែរ ហូតដល់ លះបង់ព្រះមហាស្វេតច័ត្ររាជសម្បត្តិ ផ្ទេរកិច្ចការរាជ-ការផ្ទៃក្រោម ឲ្យមហាសេនាបតីកាន់កាប់ ហើយព្រះអង្គចេញសាងបព្វជ្ជាបំពេញ ឧបសម្បទាជាភិក្ខុ និង ព្រះសុគន្ធាធិបតី ប៉ុម អស់រយៈកាលមួយត្រីមាស។ សម្តេចព្រះសង្ឃរាជអង្គនេះ តែងចម្រើនឈានជាលោកិយ អាចឈ្វេងយល់ ដល់ស្ថានការណ៍ព្រះនគរ និងដឹងដល់កំណត់កាលនៃអាយុសង្ខារ របស់ព្រះអង្គទៀតផង។ យើងគប្បីយល់ថា សម្តេចព្រះសង្ឃរាជនាសតវត្សទី១៨ ពុំមែនជាអង្គអរហន្តាខីណាស្រពនោះឡើយ ព្រោះថា ពុទ្ធព្យាករណ៍ បានកំណត់ត្រឹមមួយពាន់ឆ្នាំ បន្ទាប់ពីព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់បរិនិព្វានទៅនឹងអស់អង្គអរហន្ត ចុះហេតុអ្វី បានជាសម្តេចព្រះសង្ឃរាជមានទិព្វ-ញ្ញាណអាចដឹងនិស្ស័យសត្វ ? ។ ចំណុចនេះ បើយើងបើកព្រះរាជពង្សាវតារមើល ពិតជាបានដឹងថា មនុស្សជំនាន់នោះ នៅមានអ្នក

មានឫទ្ធិខាំងពូកែនៅឡើយ ។

សម័យលង្វែក ឧដុង្គ មាន "អ្នកសិល្ប៍ " កើតឡើងបញ្ចេញសកម្មភាពជាបន្តបន្ទាប់ដូចជា តេជោមាស តេជោយ៉ត ស្តេចកែវព្រះភ្លើង ស្តេចបាលីកងចក្រ ស្តេចសំរ៉ែ ព្រះបាទជាន់ជុំ ព្រះរាមទ្រាំង ។ ល។ ចំណែកខាងព្រះសង្ឃ ក៏មានព្រះបទុមបារមី ស៊ុនដែលជាគ្រូរបស់តេជោមាស សុទ្ធតែជាអ្នកខាំងពូកែ ចេះមន្តអាគមអាចប្រែកាឡាជាសត្វអ្វីក៏បាន និងអាចរាយមន្តហៅភ្លៀង ខ្យល់ជបឲ្យកើតជាខ្លា ដំរី ឃ្មុំ ស្រាំង ឪម៉ាល់ ដេញជាន់ ដេញទិចបច្ចាមិត្តបាន ។ ក្នុងចំណោមអ្នកខាំងពូកែទាំងនោះ ខ្លះបានធ្វើជាស្តេចត្រាញ់បម្រើ ជាតិ សាសនា ព្រះមហាក្សត្រ ខ្លះទៀតតាំងខ្លួនជាអ្នកបុណ្យ អួតអាងមហិទ្ធិឫទ្ធិ ទ្រុស្តមិត្ត ប្រឆាំង នឹងស្តេចផែនដីក៏មាន ។ ករណីដែលថា សម្តេចព្រះសង្ឃរាជមានញាណពិសេសខាំងពូកែ ប្លែកពីគេបែបនេះ ក៏ទំនងជាព្រះអង្គឋិតនៅក្នុងជំពូកអ្នកសិល្ប៍ទាំងនោះហើយ ប៉ុន្តែជាជំពូកអ្នកប្រើសិល្បមន្ត តាមលក្ខណៈពុទ្ធនិយមពុំមែនជាព្រហ្មនិយម កាប់សម្លាប់មនុស្ស យកកំហឹងទល់កំហល់នោះឡើយ ពោលឲ្យចំ គឺព្រះអង្គបានសម្រេចលោកិយឈានពុំមែនជា"លោកុត្តរឈាន"។ សូម្បីព្រះភិក្ខុទេវទត្ត ជំនាន់ពុទ្ធកាលដែលអាចហោះហើរដើរលើអាកាសបាន ក៏សម្រេចលោកិយឈានជារបស់បុថុជ្ជននោះដែរ ។

សម្តេចព្រះសង្ឃរាជអង្គនេះ លុះមានព្រះជន្មដល់ ៩៤វស្សា ក៏ទ្រង់ដល់ នូវព្រះជរាភាពជាទម្ងន់ ។ ព្រះបាទអង្គឌួង ជា

អម្ចាស់ជីវិតតម្កល់លើត្បូង បាននាំព្រះរាជអគ្គមហេសី ស្រីស្នំយាង ទៅសួរព្រះអាការរោគ និងសម្ដែងការសោកស្ដាយយ៉ាងខ្លាំង ដោយព្រះទ័យស្នេហា អាឡោះអាល័យ មិនចង់ឲ្យព្រះមហាថេរជាទីសក្ការៈយាងទៅកាន់កពថ្មីឡើយ ។ ព្រះនរបតី ទ្រង់មានព្រះបន្ទូលថា "បើអំណឹះអត់ពីសម្ដេចព្រះសង្ឃរាជទៅ ព្រះនគរនឹងបាត់បង់អ្នកប្រាជ្ញ ដ៏ចម្បងមួយអង្គជាមិនខាន"។ ព្រះមហាក្សត្របានអារាធនាព្រះមហាថេរ ឲ្យយាងចាប់បដិសន្ធិនឹងអគ្គមហេសី ដោយមានព្រះឱង្ការថាៈ" ញោម[១] គ្មានព្រះរាជបុត្រាទីនឹងគ្រប់គ្រងព្រះនគរជាតំណពព្រះប្រយូរវង្សតទៅសោះ បើគ្មានព្រះមហាក្សត្រសោយរាជ្យហើយព្រះនគរ នឹងសាបសូន្យជាមិនខាន ។ ខ្ញុំព្រះករុណាសូមនិមន្តព្រះជីតទ់សូមមេត្តាមក ចាប់បដិសន្ធិនឹងញោមចុះ ដើម្បីជួយទំនុកបម្រុងព្រះនគរផង ព្រះពុទ្ធសាសនាផង ឲ្យបានចំរុងរុងរឿងជាអង្វែងតទៅ " ។ សម្ដេចព្រះសុគន្ធាធិបតីថ្វាយព្រះពរថា ដែលព្រះមហាបពិត្រនិមន្តនោះ អាចក្ដីទទួលតាមព្រះរាជនិមន្តក៏បាន តែពុំបានវែងឆ្ងាយទេ គឺគ្រាន់តែជួយព្រះមហាបពិត្របន្តិចបាន ។ ទើបព្រះមហាក្សត្រទ្រង់ព្រះតម្រាស់ថា "បណ្ដាលព្រះមហេសី ព្រះស្នំព្រះមេនាងទាំងប៉ុន្មានរបស់ញោមនោះ បើព្រះជីតទ់សព្វព្រះទ័យនឹងឈ្មោះណា សូមមេត្តាចាប់បដិសន្ធិនឹងឈ្មោះនោះ តាមសព្វព្រះទ័យចុះ "។ សម្ដេចព្រះសង្ឃរាជ ដែលកំពុងទុរទ់ទុកនោះ ទ្រង់ឲ្យ

---

១- ព្រះរាជាអង្គឯងតែម្ដង

ប្រជុំព្រះមហេសី ស្រីស្នំ អ្នកម្នាង មកជួបជុំជិតព្រះនេត្រ ព្រះអង្គទតទាំងអស់ ទ្រង់សព្វព្រះទ័យលើអ្នកម្នាង "ដៃកវែង" ដែលមានស័ក្តិទាបជាងគេ ទើបទឹងថ្វាយខ្ទង់ ហើយស្តេចពុំសូវប្រោសមេត្តាផង ព្រោះមានរូបសម្ផស្សមិនល្អជាងគេ ។

សម្តេចព្រះសុគន្ធាធិបតី ទ្រង់សព្វព្រះទ័យនេះ ដោយចង់អនុគ្រោះអ្នកម្នាងនោះ ឲ្យមានកេរ្តិ៍ ឈ្មោះនឹងគេ ហើយទូលថ្វាយព្រះពរថា " ឲ្យស្តេច និងព្រះមហេសី ព្រះស្នំ អ្នកម្នាងទាំងអស់ត្រឡប់ទៅព្រះរាជវាំងវិញចុះ ទ្រង់នឹងអស់អាយុសង្ខារទៅចាប់បដិសន្ធិនឹងអ្នកម្នាងដៃនោះហើយ"។ គ្រាន់តែ ស្តេចនាំព្រះរាជបរិពារចេញផុតខ្លោងទ្វារវត្ត សម្តេចព្រះសង្ឃរាជ ក៏សោយទិវង្គតទៅ មែនក្នុងព្រះជន្មាយុ ៩៤ ព្រះវស្សា ។ ស្តេច ក៏វិលមករៀបចំធ្វើបុណ្យ ថ្វាយព្រះភ្លើងយ៉ាងអធិកអធម ។ មួយខែក្រោយមកអ្នកម្នាងដៃ ក៏ដឹងខ្លួនថាមានគភ៌ ។ ព្រះមហាក្សត្រ បានលើកអ្នកម្នាងដៃជាស្នំឯក ដោយអាណិតស្រឡាញ់លើសគេ ព្រោះទ្រង់ជ្រាបថាអ្នកម្នាងទ្រង់គភ៌ ពិតជាសម្តេចព្រះសង្ឃរាជ យាងមកចាប់បដិសន្ធិនឹងបានស្នងរាជសម្បត្តិជាមិនខាន ។ ស្តេចចាត់ឲ្យអ្នកយាយចាស់ទុំចូលប្រចាំការ រក្សាគភ៌អ្នកម្នាងដៃរាល់ពេលរាល់វេលា លុះត្រាតែគ្រប់ទសមាស បានប្រសូតព្រះរាជបុត្រមក ជាបុត្រាមែន ហើយថ្វាយព្រះនាងថា" ព្រះអង្គអេង " ។ លុះព្រះវររាជបិតាសោយទិវង្គតទៅ ព្រះទរាយណ៍រាមាអង្គអេង ដែលជាតួអង្គសម្តេចព្រះសុគន្ធាធិបតី **ម៉ឺម** មកសោយព្រះជាតិនោះ បានឡើងសោយរាជ្យ

ស្នងព្រះបិតា ចំពេលដែលព្រះនគរ កើតកលិយុគឃោរ ជាបព្រះ-ធរណី ។

កាលព្រះអង្គអេងឡើងគ្រងរាជ្យដំបូងនោះ ទើបមានព្រះ-ជន្ម ៦ ព្រះវស្សាប៉ុណ្ណោះ កិច្ចការផែនដីធ្លាក់ទៅលើ សម្ដេចចៅហ្វាប៉ុក ជាធម្មបិតា លុះព្រះជន្មាបាន ២២ ព្រះវស្សា ទើបឡើងអភិសេកជាស្ដេចពេញសិទ្ធិ ។ ព្រះករុណាអង្គនេះមាន ព្រះជន្មាយុខ្លីណាស់បានត្រឹមតែ៤៤ឆ្នាំ ក៏សោយទិវង្គតទៅ សមដូចទំនាយរបស់ព្រះសុគន្ធាធិបតី **ម៉ឹម** (កាលពីជាតិមុន) ដែលមានថេរដីកាទូលព្រះអង្គតន់ថា "អាចក្ដីគ្រាន់តែជួយ មហាបពិត្របន្ដិចបានតែពុំបានវែងឆ្ងាយទេ" ។ ព្រះអង្គអេងមានបុត្រតំណប្រយូរវង្ស គឺព្រះហរិរក្ស-រាមាធិបតីអង្គឌួង ជាមហាក្សត្រកវីនិពន្ធដ៏ល្បីល្បាញ បាននិពន្ធរឿងកាកី ចម្ប៉ាថោង ច្បាប់ស្រី ព្រះវេស្សន្ដរជាតក ជាពាក្យកម្រងកែវ ហើយព្រះអង្គឌួង ត្រូវជាព្រះអយ្យកោលួត(តាលួត)របស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដមសីហនុ គ្រងរាជ្យបច្ចុប្បន្ននេះ ។

## III - សម្ដេចព្រះមហាសុមេធាធិបតី ព្រះនាម ជួន ណាត

សម្ដេចព្រះសង្ឃរាជ **ជួន ណាត** "ជោតញ្ញាណោ"ប្រសូតនៅថ្ងៃ ១១ រោច ខែ ផល្គុន ឆ្នាំ វក ឆស័ក ព.ស ២៤២៧ ត្រូវនឹងថ្ងៃ ១១ មីនា គ.ស ១៨៨៣ នៅភូមិកំរៀង ឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ញោមប្រុស នាម ជួន និង ញោមស្រីនាម យក់ ជាកសិករ ។ ព្រះអង្គមានប្អូនប្រុសម្នាក់ នាម ឧកញ៉ាសោភ័ណ មន្ត្រី ជួន នុត ។ សម្ដេចបានចូលសាងព្រះផ្នួស តាំងពី

បឋមវ័យរហូតដល់អស់ព្រះជន្ម ដោយឧទ្ទិសអ្វីៗទាំងអស់ ដើម្បីព្រះពុទ្ធសាសនា និងវប្បធម៌ជាតិឲ្យបានរីកចម្រើន។ ព្រះមហាថេរអង្គនេះតែងមានអំណត់ព្យាយាម ក្នុងការសិក្សាជានិច្ចកាល ដោយពុំមានខ្លាចអាជ្ញាធរផែនដីចាប់ទោសកំហុសឡើយ។ជំនាន់រាជការអាណាព្យាបាលបារាំង គេបានហាមឃាត់ព្រះសង្ឃ មិនឲ្យរៀនភាសាបរទេស មិនឲ្យរៀនតាមសៀវភៅ ដែលចាត់ទុកថាជាធម៌ថ្មី គឺឲ្យរៀនតែតាមសាស្ត្រាស្លឹករឹត ដែលចាត់ជាធម៌ចាស់ បន្សល់ទុកពីបុរាណកាលមក ។ ទោះជាមានការហាមឃាត់យ៉ាងនេះក្តី ក៏ព្រះភិក្ខុ **ជួន ណាត** នៅតែព្យាយាមរៀនសូត្រឥតរាថយ ជួនកាលត្រូវបិទទ្វារកុដិឲ្យជិតដើម្បីលួចរៀន ភាសាបារាំងពីសម្នាក់លោក ជួន ទុត ជាប្អូនប្រុសរបស់ព្រះអង្គរហូត ចេះអានសរសេរ និងសន្ទនា ហើយគ្មានអ្នកណាបានដឹងថាព្រះអង្គចេះបារាំងផង។មុននឹងចេញទៅរៀនភាសាសំស្ក្រឹតនៅទីក្រុងហាណូយ ក្នុងសម្នាក់លោកល្វីហ្វីណូត៍[១] ចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ព្រះអង្គធ្លាប់ចេះសំស្ក្រឹតរួចទៅហើយ ដោយជួលក្លិងលក់សណ្តែកដីម្នាក់ ឲ្យមកបង្រៀនព្រះអង្គដល់ក្នុងកុដិជាមួយនឹងព្រះគ្រូសង្ឃវិជ្ជា ហួត តាត ជាមិត្តកម្សត់កម្រនឹងគ្នា ។ ទីបំផុតដោយការព្យាយាមដ៏អស្ចារ្យនេះ ព្រះអង្គបានយកឈ្នះគូប្រជាំងដោយសន្តិវិធី ទទួលទីមទីងពុទ្ធិដ៏ឧត្តុង្គឧត្តម រកគូប្រដូចគ្មាន ។ ព្រះអង្គចេះរហូតដល់ជាងដប់ភាសា ក្នុងសកលលោកនឹងក្លាយទៅជាអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ ចាក់ឫសក្នុងព្រះត្រៃបិដកដោយគ្មានទើសទាល់សល់ចន្លោះឡើយ ។ ក្រៅពីចំណេះវិជ្ជាផ្នែក

អក្សរសាស្ត្រ ព្រះអង្គក៏នៅមានព្រះលក្ខណៈ ខុសប្លែកពីជនទាំងពួងដែរ ។

តាមសិស្សគណខ្លះ បានតំណាលថា ទោះបីជានៀយព្រះកាយពលយ៉ាងណាក្តី ក៏ព្រះអង្គ តែងតែបំពេញព្រះរាជតួនាទី ជាស្តេចសង្ឃតម្រង់វិន័យ ព្រះពុទ្ធសាសនាជានិច្ច ពិសេសតែងយកព្រះទ័យទុកដាក់ ទៅលើវចនានុក្រមខ្មែរជាងអ្វីៗទាំងអស់ៗ បើសិនជាព្រះអង្គចង់ផ្ទំ ក៏ផ្ទំលក់ភ្លាមមួយរំពេច គ្រាន់តែលាន់ព្រះឱស្ឋប្រាប់អ្នកមកគាល់ថា“ អាត្មាសុំសឹងមួយម៉ោងសិន ” ៗ ដល់កំណត់មួយម៉ោងក៏តើនឡើងភ្លាម បន្តព្រះរាជកិច្ចទៀតហាក់ដូចជា “អ្នកសិល្ប៍” ចេះដកដួងចិត្តបាន ឬក៏ដូចព្រះអរហន្តចូលឈានសមាបត្តិ ៗ ព្រះអង្គអាចស្តាប់ដឹងភាសាសត្វដូចជា ពេលមួយមានសត្វគ្រលីងគ្រលោងមួយគូវាយំកឹកៗ ចង់ចឹកសំបុកអង្រ្កងលើមែកស្វាយ ដោយមិនព្រមហើរទៅណាសោះៗ ព្រះអង្គប្រើសិស្សម្នាក់ឲ្យឡើងទៅមើល ក្នុងសំបុកអង្រ្កងថា មានស្វាយទុំនៅក្នុងហ្នឹងអាសត្វទាំងពីរនេះ វាចង់ស៊ីផ្លែស្វាយ តែវាខ្លាចអង្រ្កងខាំ ៗ សិស្សឡើងទៅមើលក៏ឃើញស្វាយទុំក្រហមរលោង ពិតដូចព្រះបន្ទូលមែន ក្រៅពីមានទិព្វញ្ញាណដូចរៀបរាប់ខាងលើនេះ សម្តេចព្រះសង្ឃរាជ **ជួន ណាត** តែងមានព្រះបន្ទូលជាសំតៀនក្រើនរំលឹកចង់ឲ្យអ្នកដទៃ ចេះដឹងតាមព្រះអង្គមិនចង់ឲ្យនៅល្ងង់ខ្លៅទេពោលគឺ ឲ្យចេះរកស៊ីតាមសម្មាអាជីវៈ កុំដេកតែក្រកុំពឹងលើព្រេងវាសនា ៗ ល ៗ ក្រៅពីសៀវភៅធម៌ផ្សេងៗដែលព្រះអង្គបានតែងទុក ក៏នៅមានព្រះរាជឱវាទខ្លះៗ ដែលយើងសូមដកស្រង់មកចុះក្នុងទីនេះ :

- ត្រូវរិះគន់ខ្លួនឯងជាមុន កុំឲ្យស៊ីយស៊ុនខុសទទេ

“បើចូលមិនយល់ត្រូវសួរគេ” ឥតបោកអ្វីទេថ្លៃទេតើ ។

---

- បាយវត្តជាភោជន៍មានព្រលឹង គួរនឹងរំពឹងកុំទិសទាស

នាហ្មឺនមន្ត្រីមកពីរាស្ត្រ គឺរាស្ត្រឡើងទៅជាមន្ត្រី ។

---

- ការអម្បាល កុំអាលពោលអួតមុន ។
- រអិលមាត់ ច្រើនតែភ្លាត់ស្មៀត ។
- ប្រាំបួនទិញ ដប់ទិញ កុំទិញរបស់ថោក ។

---

-អក្សរវិបត្តិជាតិវិបត្តិ ខ្ចាយខ្ចាត់រាត់រាយក្លាយឃ្លៀងឃ្លាត

ហេតុនេះខ្មែរយើងកុំរវាត ត្រូវរក្សាជាតិឲ្យរឹងប៉ឹង ។

-បើដឹងមិនដល់កុំធ្វើចេះ ចំណេះតិចតួចស្តួចស្តើងស្តើង

បើចង់ច្បាស់លាស់ត្រូវខំប្រឹង កុំដេកសម្ងឹងថាចេះឯង ។

---

ព្រះរាជដំបូន្មានដ៏ថ្លៃថ្លានេះ នៅតែមានតម្លៃមិនចេះស្លាប់ ក្រៅពីនេះ ក៏នៅមានច្រើនទៀតរាប់ពុំអស់ ទាំងនេះបញ្ជាក់ឲ្យដឹងថា សម្តេចតែងមានព្រះទ័យ អាណិតអាសូរ ដល់ជនជាតិរួមលោហិត មិនចង់ឃើញមនុស្សល្ងង់ខ្លៅ មនុស្សពាល មនុស្សកំសត់ទុគ៌ត អ្វីឡើយ គឺព្រះអង្គចង់ឲ្យមនុស្សរស់ស្មើភាពគ្នា រាប់រកគ្នាជាភាតរៈ ។

ស្នាព្រះហស្ថខាងតែងនិពន្ធរបស់ព្រះអង្គ ដែលសំខាន់បំផុត គឺ វចនានុក្រមខ្មែរ ដែលចាត់ទុកជាបេតិកភ័ណជាតិ មានតម្លៃមហាសាល ។ អ្នកស្នេហាអក្សរសាស្រ្តជាតិមួយចំនួនតូច តែងតែថ្វាយបង្គំវចនានុក្រមរៀងរាល់ទិវារាត្រី ដោយចាត់ទុកវត្ថុនេះ ជាគ្រឿងសក្ការៈបូជាបន្ទាប់ពីព្រះត្រៃរតន៍ " ចុះហេតុអ្វី បានជាខ្មែរមួយចំនួនបែរជាមើលរំលងវចនានុក្រម ហើយនាំគ្នាសរសេរអក្សរ ពាសវាលពាសកាល ខុសអក្ខរាវិរុទ្ធ ដែលសម្តេចជាអម្ចាស់ បានបង្ក្រងទុកមកនោះទៅវិញ ? " ។

សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ទ្រង់សោយទិវង្គតកាល ពីថ្ងៃ ១៤ កើត ខែកត្តិក ឆ្នាំរកា ឯកស័ក ព.ស ២៥១៣ ត្រូវនឹងថ្ងៃ ២៥ កញ្ញា គ.ស ១៩៦៩ វេលាម៉ោង ២០ និង ២០នាទី នៅក្នុងមហាកុដិព្រះអង្គ នាវត្តឧណ្ណាលោម រាជធានីភ្នំពេញ ក្នុងព្រះជន្មាយុ ៨៦ ព្រះវស្សា ដោយព្រះជរាពាធ ។

សរុបមក សម្តេចព្រះសង្ឃរាជទាំងបីព្រះអង្គនេះ គួរដល់ឋានៈឯតទគ្គៈដ៏ឆ្នើម លើសសម្តេចសង្ឃអង្គឯទៀត ដែលគប់គ្រងព្រះពុទ្ធសាសនា ក្នុងកម្ពុជរដ្ឋ ។ សម្តេចព្រះសុគន្ធាធិបតី **ប៉ាន** បានបន្សល់នូវច្បាប់ " ច្បាប់ក្រម " សម្រាប់ជាសតៀនគ្រែនរំលឹកមហាជន ។ សម្តេចព្រះសុគន្ធាធិបតី **ប៉ុម** បានបន្សល់ទុក នូវរាជវង្សខ្មែរ ខ្សែព្រះបាទអង្គអេង ព្រះបាទអង្គឌួង ព្រះបាទនរោត្តម ព្រះបាទសុរាម្រឹត ព្រះបាទសីហនុ ។ សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ក៏បានបន្សល់ស្នាព្រះហស្ថ ជាវចនានុក្រមខ្មែរដ៏ល្បីល្បាញ

*មានតម្លៃជាអមត និងស្នាដៃជាច្រើនផ្សេងទៀត ។ ពេលនេះ សម្តេច ទាំងបី បានសោយព្រះទិវង្គតកន្លងផុតទៅហើយ យើងខ្ញុំព្រះករុណា ជាបច្ឆាជន សូមលើកហត្ថបួងសួង ដល់ព្រះវិញ្ញាណក្ខន្ធព្រះអង្គ សូមស្តេចយាងមកជួយថែរក្សា ព្រះពុទ្ធសាសនា និងវប្បធម៌ជាតិ ខ្មែរ ឲ្យបានឋិតថេរចីរកាលគង់វង្ស ងើបត្រដែតឡើង ដើម្បីដើរឲ្យ ទាន់អារ្យប្រទេសនានា ក្នុងសកលលោក កុំបីក្លាយទៅជាបការៈ ជនទៀតឡើយ ។*

*ការផ្ទេរស្មារតី ជាឧបាយស្ងាប់ ៗ*

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ ( ជោតញ្ញាណោ ជ.ណ ) ។

# ព្រះពុទ្ធសាសនា និង បញ្ហារស់រំ

(ត)

ដោយ បណ្ឌិត ឆយ យីហាង

## II. ស្ថានភាពបច្ចុប្បន្ននៃពុទ្ធសាសនានៅកម្ពុជា

(La situation actuelle du Bouddhisme au cambodge)

*ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា បានចូលមកក្នុងប្រទេសកម្ពុជាយើង តាំងពីសម័យទករក្នុំៗ ព្រះគ្រូ* **ប៉ាង ខាត់** *មានសង្ឃដីកាថា ព្រះពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ទាំងពីរនេះ បានមកប្រតិស្ឋាននៅកម្ពុជាក្នុងសម័យជាមួយគ្នា ។ សព្វថ្ងៃប្រទីបសាសនាព្រាហ្មណ៍រលត់បាត់បង់ទៅហើយ តែក្នុងចិត្តគំនិតខ្មែរនៅតែប្រកាន់សាសនាព្រាហ្មណ៍នៅឡើយ ដោយលាយឡំជាមួយព្រះពុទ្ធសាសនា[១]។ ចំណែកឯពុទ្ធសាសនាមហាយាន ក៏បាត់បង់ពីកម្ពុជាផងដែរ។ ពុទ្ធសាសនាហីនយានកំពុងមានអត្ថិភាព ក្នុងសតិអារម្មណ៍របស់ប្រជាជន ។ ប៉ុន្តែខ្មែរយើងពុំបានអនុវត្តទាំងដុល នូវពុទ្ធសាសនាហីនយាន ដូចដែលបានផ្តល់ន័យនៅក្នុងសេចក្តីផ្តើម ដែលត្រង់ចំណុចដកស្រង់ពី* L'Encyclo *ឡើយ ។ ការតស៊ូប្រយុទ្ធក្នុងលោកិយ ដើម្បីរំដោះជាតិនៅតែមានឥទ្ធិពល មកលើស្មារតីខ្មែរ*

---

[១] ប៉ាង ខាត់ : *មគ្គទេសក៍នគរ ភាគ II*. បោះពុម្ពលើកទី២.

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ. ឆ្នាំ២៥០០នៃពុទ្ធសករាជ, ទំព័រទី២៥

ដូចជា ចលនាតស៊ូរំដោះជាតិនៃព្រះគ្រូ ហែម ចៀវ ជាដើម ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពុទ្ធសាសនា ត្រូវលោយសាបសូន្យតាំងពីឆ្នាំ១៩៧៥ មកដល់សព្វថ្ងៃ ពុទ្ធសាសនារីកចម្រើនយ៉ាងឆាប់រហ័ស ។ បើតាមតួលេខដែលបានទទួលពីក្រសួងធម្មការនិងសាសនា ក្នុងឆ្នាំ ២០០១ យើងឃើញដូចខាងក្រោម ។

**១. ចំនួនវត្ត ព្រះសង្ឃ និង អាគារសិក្សា**[២]

- វត្តនៃគណៈមហានិកាយមាន ៣.៦៩៦វត្ត ។ វត្តនៃគណៈធម្មយុត្តិកនិកាយមាន ១០២ វត្ត ។ ចំនួនវត្តសរុបមាន ៣៧៩៨វត្ត ។
- ព្រះសង្ឃគណៈមហានិកាយមាន ៥២.៥៦៥ អង្គ ។ ព្រះសង្ឃគណៈធម្មយុត្តិកនិកាយមាន ១.៣០៤ អង្គ ។ ចំនួន ព្រះសង្ឃសរុប : ៥៣.៨៦៩ អង្គ។
- ពុទ្ធិកបឋមសិក្សាមាន ៤៣៩ខ្នង ។ ពុទ្ធិកមធ្យមសិក្សាមាន១២ខ្នង ។ ពុទ្ធិកឧត្តមសិក្សាមាន១ខ្នង ។

---

[២] តួលេខរបស់ក្រសួងធម្មការ និងសាសនា

- ស្ថិតិវត្តអារាម និងព្រះសង្ឃ ចុះថ្ងៃទី១៨ សីហា ២០០១
- ស្ថិតិពុទ្ធិកបឋមសិក្សា ចុះថ្ងៃទី២៥ កក្កដា ២០០១
- ស្ថិតិពុទ្ធិកវិទ្យាល័យ ចុះថ្ងៃទី០១ តុលា ២០០១
- របាយការណ៍នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ចុះថ្ងៃទី១០ ឧសភា ២០០២

គ្រឹះស្ថានសិក្សាសរុបមាន ៤៥២ខ្ទង់ ។

- ចំនួនសាមណសិស្ស និងសាមណនិស្សិត ដែលបានសិក្សានៅពុទ្ធិកបឋមសិក្សាមាន ១២.៧១៨ អង្គ នៅពុទ្ធិកមធ្យមសិក្សាមាន១.៨៣០អង្គ នៅពុទ្ធិកឧត្តមសិក្សាមាន៣៧២អង្គ។

បើតាមតួលេខខាងលើនេះ យើងឃើញចំនួនព្រះសង្ឃ និងចំនួនសាលារៀន មិនមានលក្ខណៈស្របគ្នាទេ មានន័យថា ព្រះសង្ឃជាច្រើនអង្គ គ្រាន់តែបានបួសរៀនតាមបែបបុរាណនៅតាមកុដិ មិនបានសិក្សាជាប្រព័ន្ធ នៅតាមសាលារៀនឡើយ ។ កង្វះសាលារៀន កង្វះគ្រូបង្រៀន និងសាស្ត្រាចារ្យជាចំណោទដ៏ធំមួយ ដែលបង្ហាញឲ្យឃើញថា ព្រះសង្ឃភាគច្រើន មិនបានបង្កើនសមត្ថភាព តាមតម្រូវការនៃប្រទេសជាតិ ។ ដំណោះស្រាយដ៏ធំមយគឺ គួររាជរដ្ឋាភិបាល ក្រសួងធម្មការនិងសាសនា ទាក់ទាញពុទ្ធសាសនិក សប្បុរសជន ឲ្យរួមចំណែកកសាង គ្រឹះស្ថានសិក្សាគ្រប់ភូមិសិក្សាក្រោមផែនការកម្មមួយច្បាស់លាស់ អាចបន្ថយការកសាងព្រះវិហារដ៏ស្កឹមស្កៃ តែបង្កើនការកសាងពុទ្ធិកសិក្សា តាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ដើម្បីបណ្តុះបណ្តាលមនុស្ស នៅក្នុងពិកពបព្វជិត ដែលអាចគង់នៅជាព្រះសង្ឃរហូត និងអាចក្លាយជាគ្រហស្ថវិញ ដែលមានសមត្ថភាពពេញលេញ ។

២_អំពីពិធីបុណ្យ ដែលទាក់ទងនឹងពុទ្ធសាសនាសុទ្ធសាធ

ពិធីបុណ្យដែលទាក់ទងនឹងពុទ្ធសាសនារួមមានៈ

- ពិធីបុណ្យភ្ជុំបិណ្ឌ
- ពិធីចូលវស្សា
- ពិធីចេញវស្សា
- កឋិនទាន
- បុណ្យផ្កា
- បុណ្យបច្ច័យ ៤
- ពិធីបង្សុកូល
- ពិធីទេសនាមហាជាតក
- ពិធីបំបួសនាគ
- ពិធីដារពិស្តារសងគុណមាតាបិតា ឬអាណាព្យាបាលៗ

៣_ អំពីពិធីបុណ្យ ដែលទទួលឥទ្ធិពលពីពុទ្ធសាសនា និងព្រហ្មញ្ញសាសនាចម្រុះគ្នា

ពិធីបុណ្យចម្រុះ រវាងពុទ្ធសាសនា និងព្រហ្មញ្ញសាសនារួមមាន :

- ពិធីចម្រើនព្រះបរិត្ត
- ពិធីរំដោះគ្រោះ
- ពិធីរំដោះកម្មនៃអ្នកស្លាប់

• ពិធីប្រត់ព្រះនង្គ័ល ។

## ៤. អត្ថន័យនៃពិធីបុណ្យ

ឆ្លងតាមពិធីបុណ្យទាំងនេះ ព្រះសង្ឃមានឥទ្ធិពលយ៉ាងខ្លាំង ចំពោះប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់សង្គម តាំងពីព្រះមហាក្សត្ររហូតដល់រាស្ត្រសាមញ្ញ ។ ពុទ្ធសាសនិកតែងត្រូវការព្រះសង្ឃជារឿយៗ ក្នុងការប្រោះព្រំពិធីអ្វីមួយ ។ ពិធីបុណ្យទាំងឡាយមានអត្ថន័យពីរបែបគឺ :

### ០ អត្ថន័យពុទ្ធចក្រ

សំដៅទៅលើការកសាងកុសល ដើម្បីអនាគតជាតិ ឬបរលោក។ គោលបំណងធំបំផុតរបស់ពុទ្ធសាសនិក គឺសំដៅទៅរស់នៅឯស្ថានបរលោក ស្ថានសួគ៌ ឬ បើកើតឡើងវិញក្នុងលោកិយនេះ ក៏សុំឲ្យខ្លួនមានរូបសម្បត្តិល្អ មានបុណ្យសក្តិខ្ពស់ និងមានទ្រព្យសម្បត្តិច្រើន ។ លោកសាស្ត្រាចារ្យ **ម៉ឹម ម៉ុន** គូសបញ្ជាក់ថា "លោកិយពុទ្ធិបានដល់ចំណេះវិជ្ជា ការចេះដឹងគ្រប់បែបយ៉ាងរបស់មនុស្ស និងសង្គមមនុស្សក្នុងលោកិយយើងនេះ ។ ប៉ុន្តែលោកិយពុទ្ធិនេះ ពុំមែនគោលដៅចុងក្រោយបង្អស់របស់ពុទ្ធលទ្ធិទេ ពីព្រោះពុទ្ធិប្រភេទនេះ ពុំទាន់មានលក្ខណៈជាសច្ចពុទ្ធិ អាចផ្តល់នូវសេចក្តីភាពចំពោះសុខៈ និងភាវៈនៅឡើយ ។ អលោកិយពុទ្ធិ លោកុត្តរពុទ្ធិបានដល់សម្មាសម្ពោធិញ្ញាណ គឺញាណ ឬ ពុទ្ធិខ្ពង់ខ្ពស់បំផុត

ជាបរិបុណ្ណពុទ្ធិ ដែលនាំឲ្យរកឃើញសច្ចភាព និងអាចឲ្យសម្រេចនូវបរិបុណ្ណសុខៈ គឺព្រះនិព្វាន។ ពុទ្ធិបែបនេះ ពុំមែនកើតឡើងឯងៗ និងគ្មានការទាក់ទងជាមួយពុទ្ធិដទៃៗទៀតនោះឡើយ ។ ប៉ុន្តែជាលទ្ធផលកើតពីកម្លាំងលោកិយពុទ្ធិ ដែលព្រះសម្ពុទ្ធបានកសាងសន្សំទុកជាច្រើនជាតិណាស់មកហើយផង កើតឡើងដោយកម្លាំងព្រះសម្ពុទ្ធទំអប់រំបន្ទុំចិត្ត ឲ្យស្ថិតនៅនឹងនជាឯកគ្គតា ប្រាសចាកនីវរណ ធម៌ទាំង៥ កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ច និងវិចិកិច្ឆាទៀតផង ¹។

**០ អត្ថន័យអាណាចក្រ**

សំដៅទៅលើការកសាងសាមគ្គីភាព ដោយឥតប្រកាន់ឋានៈសង្គម ឬឋានៈសេដ្ឋកិច្ចឡើយ។ ចាស់ក្មេង ប្រុសស្រី អ្នកមាន អ្នកក្រ មន្ត្រី រាស្ត្រ បានរួមចំណែកយ៉ាងសស្រាក់សស្រាំ ក្នុងការប្រារព្ធពិធីបុណ្យ ជាពិសេសពិធីបុណ្យធំៗដូចជា ភ្ជុំបិណ្ឌ កឋិនទាន បុណ្យផ្កាជាដើម។ សទ្ធាជ្រះថ្លាសម្រាប់អនាគតជាតិ ត្រូវចងកាត់សទ្ធាជ្រះថ្លាក្នុងបច្ចុប្បន្នជាតិ ដែលអាចធ្វើឲ្យមនុស្សក្នុងលោកិយសប្បាយរីករាយជាមួយគ្នា ។ ការប្រារព្ធបុណ្យផ្កា ដើម្បីកសាងសាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ សាលាឆទាន សាលាបាលី......

---

១-ម៉ុម ម៉ុន : *បញ្ញាពុទ្ធិ ភាវៈ សុខៈ តាមបែបទស្សនវិជ្ជា*. បណ្ណាគារ ឌុច ឈឺន. រោងពុម្ពអប្សរា. បោះពុម្ពលើកទី១. ឆ្នាំ១៧៧១. ទំព័រទី១៧០-១៧២

ជាឧទាហរណ៍ សុទ្ធសឹងតួសបញ្ជាក់ពីអត្ថន័យអាណាចក្រនេះ ។ ម្យ៉ាងទៀត នៅក្នុងពិធីបុណ្យប្រពៃណី ពិធីបុណ្យជាតិ ដូចជាពិធីចូលឆ្នាំថ្មី ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ ពិធីព្រះរាជពិធីច្រត់ព្រះនង្គ័ល (ពិធីរំពុកខួបឯករាជ្យជាតិ)...ក៏មានតួនាទីសំខាន់ណាស់ដែរ ព្រោះពុទ្ធសាសនិកសុទ្ធសឹងត្រូវការព្រះសង្ឃ ក្នុងការប្រារព្ធពិធីបុណ្យទាំងនោះ ។

## ៥- តុល្យភាពរវាងពុទ្ធចក្រ និងអាណាចក្រ

ពុទ្ធចក្រ និងអាណាចក្រ ប្រៀបដូចជាកង់ពីរនៃរទេះមួយ។ រទេះអាចធ្វើដំណើរទៅមុខបាន ដោយសារផាសុខភាពនៃកង់ទាំងពីរនេះ ។ បុគ្គលបព្វជិតគឺជារទេះកម្លាំងស្មារតីរបស់ព្រះអង្គមានលក្ខណៈជាពុទ្ធចក្រ ។ ឯកម្លាំងកាយរបស់ព្រះអង្គ មានលក្ខណៈជាអាណាចក្រ ។ បើចង់ឲ្យបុគ្គលនេះ រីកចម្រើនគ្រប់វិស័យ លុះត្រាតែបុគ្គលត្រូវបំប៉ន បានបណ្ដុះបណ្ដាល ទាំងស្មារតី ទាំងរាងកាយ ។ កម្លាំងស្មារតី ចែកចេញជាពីរផ្នែកសំខាន់ គឺកម្លាំងស្មារតីដែលកើតឡើងដោយលោកិយពុទ្ធិ និងកម្លាំងស្មារតីដែលកើតឡើងដោយអលោកិយពុទ្ធិ លោកុត្តរពុទ្ធិ។ លោកិយពុទ្ធិ និងលោកុត្តរពុទ្ធិមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា ព្រោះមុននឹងឈានទៅដល់លោកុត្តរពុទ្ធិ ព្រះពុទ្ធបានសន្សំបង្កើនលោកិយពុទ្ធិជាច្រើនណាស់មកហើយ។

កថាខណ្ឌខាងលើនេះ គួសបញ្ជាក់ថា តួអង្គបព្វជិតជាបុគ្គលក្ដី ពុទ្ធសាសនិកក្ដី ពិកពបព្វជិតទាំងមូលក្ដី ត្រូវថ្នឹងថ្លែងរវាងពុទ្ធចក្រ និងអាណាចក្រ ធ្វើយ៉ាងណាឲ្យកង់ទាំងពីរនេះ វិលជាមួយគ្នា ដើម្បីអភិវឌ្ឍនប្រទេសជាតិផង និងអភិវឌ្ឍនបុគ្គលផង ។

(នៅមានត)

# ឋានៈស្ត្រីក្នុងព្រះពុទ្ធសាសនា

*រៀបរៀងដោយ*
*ព្រះមហាថេរបណ្ឌិត ក.ស្រីធម្មានន្ទ*
*ប្រែសម្រួលដោយ*
*ព្រះមហា ឃី សុវណ្ណរតនា*

## ភាពរើសអើង

*ភាពរើសអើងប្រចាំងនឹងស្ត្រី គឺជាព្រឹត្តិការណ៍តែងកើតមានជាទូទៅ នៅក្នុងគ្រប់សង្គមទាំងអស់ ។ ទោះបីនៅក្នុងទ្វីបអាហ្វ្រិក អាមេរិក អាស៊ី ឬទ្វីបអឺរ៉ុប ភាពលំអៀងនិងឧបសគ្គទាំងឡាយ ដែលស្ត្រីត្រូវជួបប្រទះ និងយកជ័យជំនះនោះ ស្ទើរតែមានលក្ខណៈដូចៗគ្នា ។ អសមត្ថភាពពិសេសដែលបានបង្កើតឡើងដល់ស្ត្រីទាំងឡាយទូទាំងពិភពលោក គឺមានមូលដ្ឋានក្នុងភាពលម្អៀងខាងផ្នែកសាសនា ។ អសមត្ថភាពជាមូលដ្ឋានរបស់ស្ត្រីចាប់កំណើតឡើងក្នុងសាសនា ។ ស្ត្រីត្រូវគេពណ៌នាថា សម្បុរមាយាការ និងត្រូវគេហាមប្រាមបំពាន ស្ទើរតែគ្រប់សាសនាទាំងអស់ក្នុងពិភពលោក ។*

*អនុលោមតាមទស្សនៈទេវកថានៃសាសនាមួយចំនួន គេបានជឿថា បុរសគឺជាបុត្ររបស់ព្រះអាទិទេព ប៉ុន្តែស្ត្រីមិនដែលមានឋានៈប្រហាក់ប្រហែលគ្នា ជាបុត្រីព្រះអាទិទេពទេ ។ ក្នុងចំណោមអ្នកព្រលឹងនិយម បុគ្គលខ្លះមានជំនឿថា ព្រលឹងមានតែនៅក្នុងបុរសតែប៉ុណ្ណោះ ហើយមិន*

មានទៅក្នុងស្ត្រីទេ។ អ្នកដែលអះអាងថាស្ត្រីមានព្រលឹងដែរនោះ ក៏នៅតែមិនមានជំនឿថា ព្រលឹងស្ត្រីអាចទៅកើតក្នុងឋានសួគ៌បានក្រោយពេលគេធ្វើមរណកាលទៅ។ ទាំងនេះគឺជាជំនឿប្លែកៗក្នុងចំណោមសង្គមសាសនាមួយចំនួន។

ស្ត្រី ក៏ត្រូវបានគេចាត់ទុកថា ជាប្រភពនៃអំពើបាបទាំងពួងក្នុងលោក ហើយត្រូវគេស្តីបន្ទោសចំពោះព្រឹត្តិការណ៍អកុសលទាំងឡាយដែលកើតឡើងដល់បុរសក្នុងលោកនេះ និងលោកខាងនាយ ។ មានជំនឿមួយទៀតជឿថា ឥត្ថីភាវៈ មិនអាចទទួលនូវវិមុត្តិបានទេ ស្ត្រីត្រូវចាប់កំណើតជាបុរសសិន ទើបអាចសម្រេចការរួចផុតចាកទុក្ខបាន ។

លទ្ធិសាសនាជ្រុលនិយមមួយចំនួន បានទាំងហាមឃាត់ស្ត្រីមិនឲ្យអានគម្ពីរសាសនាទៀតផង។ ទារុណកម្មចំពោះការប្រព្រឹត្តល្មើសគឺការកាត់អណ្តាតចេញ។ ស្ត្រីក៏ត្រូវបានគេហាមប្រាមមិនឲ្យចូលទីសក្ការៈបូជាឡើយ ។ ប្រសិនបើស្ត្រី ត្រូវបានគេអនុញ្ញាតឲ្យចូលរួមក្នុងពិធីសាសនាណាមួយ ការចូលរួមនោះ ត្រូវតែស្ថិតនៅក្នុងបរិវេណផ្ទះរបស់ខ្លួន ហើយត្រូវមើលការខុសត្រូវពិធីសាសនាក្នុងផ្ទះ។ ឧបសគ្គ និងការឃាត់ឃាំងក្នុងការលើកស្ទួយវិស័យសីលធម៌ និងផ្លូវចិត្តរបស់ស្ត្រី នៅតែកើតមាននៅក្នុងកម្រិតខុសគ្នា ក្នុងផ្នែកខ្លះនៃពិភពលោក ទោះបីជារនាំងជាច្រើនត្រូវបានគេដកយកចេញហើយក៏ពិតមែន ។

ផ្ទុយទៅនឹងឧបសគ្គ និងការអនុវត្តន៍ផ្នែកសាសនាប្រកបដោយភាពរើសអើងប្រកាន់បែបខាងលើ ព្រះពុទ្ធសាសនា ពិតជាអាចពោលអះអាងថា ខ្លួនមានអាកប្បកិរិយារើសអើងយ៉ាងតិចតួចបំផុត ប្រឆាំងនឹងស្ត្រីភេទ។

គេគ្មានការសង្ស័យបន្តិចបន្តួចទេថា ព្រះពុទ្ធ គឺជាគ្រូសាសនាដំបូងបង្អស់ ដែលបានផ្តល់ឱកាសស្មើភាព ដោយឥតយារយាំងដល់ស្ត្រីភេទ ក្នុងវិស័យអភិវឌ្ឍន៍ផ្លូវចិត្ត។ បើទោះជាព្រះអង្គបានចង្អុលបង្ហាញជាច្រើនលើកនូវទំនោរ និងភាពទន់ខ្សោយពីធម្មជាតិរបស់ស្ត្រីភេទក៏ដោយ ក៏ព្រះអង្គបានផ្តល់កិត្តិយសដ៏សក្តិសមចំពោះលទ្ធភាព និងសមត្ថភាពរបស់គេ។ ជាការពិត ព្រះអង្គបានត្រួសត្រាយផ្លូវឲ្យស្ត្រីបានសាងផ្នួស។ ពួកគេមានឱកាសយ៉ាងច្រើន ដើម្បីចម្រើន និងជម្រះចិត្តរបស់គេឲ្យបរិសុទ្ធ ហើយសម្រេចនូវបរមសុខ គឺព្រះនិព្វានដូចបុរសដែរ។ ចំនួនភិក្ខុនីដ៏ច្រើននៅក្នុងសម័យព្រះពុទ្ធ ជាសក្ខីភាពដែលអាចបញ្ជាក់យ៉ាងច្បាស់អំពីការពិតនេះ។

ព្រះពុទ្ធបានបើកទ្វារឲ្យស្ត្រី ចូលរួមពេញទំហឹង នៅក្នុងវិស័យសាសនា ដោយបានធ្វើឲ្យពួកគេមានសិទ្ធិចូលរួមជាសមាជិកសហគមន៍មួយ ដែលគេស្គាល់ថា "ភិក្ខុនី" ។ ពុទ្ធានុញ្ញាតនេះ ពិតជាបានផ្តល់ឲ្យស្ត្រីនូវផ្លូវសម្រាប់ការអប់រំ និងការបម្រើសង្គម ព្រមទាំងឱកាសគ្រប់គ្រាន់សម្រាប់ជីវិតសាធារណៈ។ ព្រឹត្តិការណ៍នេះ បណ្តាលឲ្យមានការទទួលស្គាល់នូវសារៈសំខាន់របស់ស្ត្រីចំពោះសង្គម ហើយក៏បានលើកកម្ពស់ឋានៈស្ត្រីផងដែរ។

## អាកប្បកិរិយាសង្គមចំពោះស្ត្រីនៅពុទ្ធកាល

អាកប្បកិរិយាសង្គមចំពោះស្ត្រីនៅពុទ្ធកាល ប្រហែលជាចាប់កំណើតចេញពីគម្ពីរវេទជាដើម ដូចជាឫគវេទជាអាទិ៍។ មានភស្តុតាងបង្ហាញអំពីកិត្តិយស និងការគោរពឥទ្ធិពល និងឥស្សរភាពនៃវណ្ណៈព្រាហ្មណ៍ ស្របតាមសិល្បសាស្ត្រ បូជាយញ្ញសត្វពាហនៈ និងពិធីការប្រពៃណីផ្សេងៗ

ទៀតរបស់គេ។ ការអធិប្បាយថ្មីៗ ត្រូវបានធ្វើទៅលើគម្ពីរទាំងឡាយ។ ស្ត្រីត្រូវបានគេគិតថា អន់ថយជាងបុរសយ៉ាងខ្លាំង ទាំងផ្លូវកាយ និងផ្លូវចិត្ត។

ស្ត្រីត្រូវបានគេមើលងាយមើលថោក ដូចជាកម្មសិទ្ធិដាច់ថ្លៃ ឬវត្ថុអញ្ចឹង។ តួនាទីរបស់ស្ត្រី គឺកិច្ចការផ្ទះសម្បែង ក្រោមល្បិចកល និងគំនិតវេវវាយរបស់ស្វាមី។ នាងមិនត្រឹមតែត្រូវបំពេញកិច្ចការផ្ទះសម្បែងទាំងអស់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវចិញ្ចឹមបីបាច់គ្រួសារដ៏ធំទៀតផង។ ព្រាហ្មណ៍ពួកខ្លះរៀបការ ហើយរស់នៅជាមួយភរិយារបស់ខ្លួន តែចាត់ទុកអាហារដែលចម្អិនដោយស្ត្រី ថាមិនបរិសុទ្ធ និងមិនសក្តិសមទទួលបរិភោគឡើយ។ រឿងអាថ៌កំបាំងមួយត្រូវបានគេប្រឌិតឡើង ពោលគឺស្ត្រីទាំងអស់ត្រូវបានគេចាត់ទុកថា ពោរពេញដោយបាប ហើយវិធីតែមួយគត់ដើម្បីកុំឲ្យពួកគេប្រព្រឹត្តអំពើមិនគប្បី គឺធ្វើឲ្យពួកគេរវល់ជាប់ជានិច្ចជាមួយនឹងភារៈ មាតុ-ភាព និងកិច្ចការផ្ទះសម្បែង។

ប្រសិនបើស្ត្រីរៀបការហើយគ្មានកូន ឬក៏គ្មានកូនប្រុសណាមួយទេ ស្ត្រីនោះអាចត្រូវជំនួសដោយប្រពន្ធទីពីរ ឬទីបី ឬត្រូវបណ្តេញចេញពីផ្ទះក៏មាន ពីព្រោះមានជំនឿតឹងរឹងមួយថា គូស្វាមីភរិយា ត្រូវតែមានបុត្រមួយដើម្បីបន្តវង្សត្រកូល និងចាត់ចែងពិធីបុព្វពលី (Rites of ancestors)។ ជំនឿប្រពៃណីនេះជឿថា មានតែកូនប្រុសប៉ុណ្ណោះ ដែលអាចរៀបចំពិធីបែបនេះ ដែលត្រូវបានគេជឿថា ជាការចាំបាច់ក្នុងការផ្តល់នូវសេចក្តីសុខសេចក្តីចម្រើន ដល់បិតា និងជីតា បន្ទាប់ពីពួកគាត់ធ្វើមរណកាលទៅ បើមិនដូច្នោះទេ ពួកគាត់នឹងអាចក្លាយជាបិសាច មកយាយីក្រុមគ្រួសារវិញ។ ជីវិតស្ត្រីរៀបការ ពិតជាគ្មានលំនឹងឡើយ។ ភាពគ្មានលំនឹងដែលរង់ចាំស្ត្រីទាំងឡាយមិនទាន់រៀបការ ក៏មានមិនតិចដែរ។ ខណៈអាពាហ៍ពិពាហ៍ត្រូវ

បានគេគិតថា ជាប្រសិទ្ធិដ៏ប្រសើរ ក្មេងស្រីមិនទាន់រៀបការត្រូវបានសង្គម រិះគន់ និងស្អប់ខ្ពើមយ៉ាងខ្លាំង។

នៅក្នុងវិស័យអនុវត្តន៍ផ្នែកសាសនា ឋានៈដែលស្ត្រីបានទទួលពីមុន ត្រូវបានគេបដិសេធន៍ចោល។ គេជឿថាស្ត្រីមិនអាចទៅកើតនៅឋានសួគ៌ដោយសារបុណ្យកុសលរបស់ខ្លួនបានទេ។ ស្ត្រីមិនអាចធ្វើពិធីបូជាដោយខ្លួនឯងបានទេ ហើយគេជឿថា ស្ត្រីអាចទៅកាន់ឋានសួគ៌បានតាមរយៈការគោរពប្រណិប័តន៍ ដោយគ្មានងាករេចំពោះស្វាមីរបស់នាង ទោះបីជាស្វាមីនោះ ជាមនុស្សកំណាចក៏ដោយ ។ ម្ហូបអាហារដែលប្តីរបស់នាងបរិភោគសល់ ជាញីកញយជាអាហារសម្រាប់នាង។ នៅក្នុងស្ថានភាពរើសអើងជ្រុលហួសពីសង្គម និងអាកប្បកិរិយាប្រមាថមើលងាយចំពោះស្ត្រីបែបនេះហើយ ដែលព្រះពុទ្ធទ្រង់បានប្រសូតឡើង នៅក្នុងប្រទេសឥណ្ឌា។ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ស្តីពីធម្មជាតិនៃជីវិត និងមរណៈកម្ម និងសង្សារវដ្ត បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងធំសម្បើម នៅក្នុងអាកប្បកិរិយាសង្គម ចំពោះស្ត្រីនៅសម័យព្រះអង្គ ។

អនុលោមតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ស្តីអំពីទស្សនកម្មផល បុគ្គលត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន និងវិបាករបស់វា។ សេចក្តីសុខចម្រើនរបស់បិតា និងជីតា មិនមែនអាស្រ័យលើសកម្មភាពរបស់កូន ឬចៅទេ ពួកគាត់ត្រូវតែទទួលខុសត្រូវ ចំពោះអំពើរបស់គាត់។ ពាក្យប្រៀនប្រដៅប្រកបដោយភាពក្លាហានបែបនេះ បានជួយកែតម្រង់ទស្សនៈមនុស្សជាច្រើន ហើយពិតជាអាចបន្ធូរបន្ថយនូវការព្រួយបារម្ភរបស់ស្ត្រីដែលមិនអាចមានកូនប្រុស ដើម្បីចាត់ចែងពិធីបុណ្យបុព្វពលីបាន ។

នៅខាងដើមនៃយុគសម័យពុទ្ធសាសនា ក្មេងស្រីមិនទាន់រៀប

ការ អាចធ្វើដំណើរទៅមកដោយគ្មានការរំលោកបំពាន ដោយសប្បាយរីករាយ និងមានការងារពេញល្អមក្នុងការទំនុកបម្រុងមាតាបិតា និងប្អូនប្រុស ដូចជា សុភា ប្អូនស្រីជាងមាស ក្នុងពុទ្ធកាលជាដើមៗ ប៉ុន្តែនៅពេលព្រះមហាថេរីបជាបតី បានបង្រៀនព្រះធម៌ទៅនាង សុភាបានយល់ច្បាស់នូវធម្មជាតិនៃកាមគុណគ្រប់បែបយ៉ាង ដែលតែងតែប្រែប្រួល ហើយគិតថា មាសប្រាក់មិនអាចនាំមកនូវសុខសន្តិភាព ឬការត្រាស់ដឹងបានឡើយ ជាលទ្ធផលនាងបានចូលមកបួសនៅក្នុងភិក្ខុនីសង្ឃទៅនេះ ជាផលប្រយោជន៍មហាសាលសម្រាប់ស្ត្រីមិនទាន់រៀបការៗ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបានដើរតួយ៉ាងធំធេង ក្នុងការលុបបំបាត់នូវជំនឿអរូបី ពិធីការ និងទម្លាប់គ្មានន័យខ្លឹមសារ រាប់បញ្ចូលទាំងការបូជាយញ្ញសត្វពាហនៈ ចេញពីផ្នត់គំនិតរបស់មនុស្សជាច្រើនៗ ខណៈពេលដែលធម្មជាតិពិតនៃជីវិតនិងមរណៈ និងបាតុភូតធម្មជាតិដែលឃុំគ្រងចក្រវាឡ ត្រូវបានបង្ហាញដល់ពួកគេ បញ្ញា និងការយល់ដឹងក៏បានកើតមានឡើងៗ ជាលទ្ធផល វាបានជួយទប់ស្កាត់ និងកែតម្រង់អយុត្តិធម៌ក្នុងសង្គមកំពុងកើតមាន និងភាពលម្អៀងដ៏ខ្លាំងក្លាប្រឆាំងនឹងស្ត្រី នៅសម័យពុទ្ធកាល ដែលជាហេតុផ្តល់លទ្ធភាពឲ្យស្ត្រីអាចដឹកនាំវិថីជីវិតរបស់គេដោយខ្លួនគេផ្ទាល់ៗ

## ធម្មជាតិរបស់ស្ត្រីគេធ

សូម្បីព្រះពុទ្ធបានលើកតម្កើងឋានៈស្ត្រីក៏ពិតមែន ព្រះអង្គមានភាពប្រាកដនិយមក្នុងការពិនិត្យ អង្កេតរបស់ព្រះអង្គ ព្រមទាំងប្រទានដំបូន្មានជាប់មិនដាច់ពីព្រោះព្រះអង្គ ទ្រង់បានជ្រាបច្បាស់នូវភាពផ្សេងគ្នាផ្នែកសង្គម

និងផ្នែកសរីរវិទ្យារវាងបុរសនិងស្ត្រី។ ភាពផ្សេងគ្នាទាំងនេះ ត្រូវបានអធិប្បាយបង្ហាញនៅក្នុងគម្ពីអង្គុត្តរនិកាយ និងសំយុត្តនិកាយ។ ព្រះពុទ្ធបានសម្តែងយ៉ាងច្បាស់ថា ភារកិច្ចរបស់បុរស គឺការស្វែងរកឥតឈប់ឈរ នូវចំណេះវិជ្ជា ការបង្កើន និងធ្វើឲ្យមាំទាំនូវជំនាញ និងកោសល្យរបស់ខ្លួន ព្រមទាំងកាពឧស្សាហ៍ក្នុងការងារ និងសមត្ថភាពស្វែងរកធនធាន ដើម្បីថែរក្សា និងចិញ្ចឹមក្រុមគ្រួសាររបស់ខ្លួន ។ មយ៉ាងវិញទៀត ជាការពិត ព្រះពុទ្ធទ្រង់សម្តែងថា តួនាទីរបស់ស្ត្រី គឺត្រូវថែរក្សាផ្ទះសម្បែង និងស្វាមីរបស់នាង។

គម្ពីរអង្គុត្តរនិកាយ បានកត់ត្រានូវដំបូន្មានដ៏មានតម្លៃ ដែលព្រះពុទ្ធបានប្រទាន ចំពោះស្រីក្មេងៗមុនពេលរៀបអាពាហ៍ពិពាហ៍។ ដោយទ្រង់បានជ្រាបច្បាស់ថា ស្រីៗពិតជាមានការលំបាកជាមួយនឹងសាច់ថ្លៃថ្មីៗរបស់នាង ។ ព្រះពុទ្ធទ្រង់បានបង្រៀនឲ្យស្រីៗគោរពឪពុក-ម្តាយក្មេកឲ្យបានហ្មត់ចត់ បម្រើគាត់ដោយសេចក្តីស្រឡាញ់ ដូចនាងបម្រើឪពុកម្តាយបង្កើតរបស់ខ្លួនអញ្ចឹងដែរ ។ ស្ត្រីត្រូវបានស្នើឲ្យគោរពរាប់អានញាតិមិត្តរបស់ស្វាមីនាង ដែលជាហេតុបង្កើតឲ្យមានបរិយាកាសស្និទ្ធស្នាល និងសប្បាយរីករាយ នៅក្នុងគេហដ្ឋានថ្មីរបស់នាង ។ ស្រីៗក៏ត្រូវបានទូន្មានឲ្យសិក្សានិងស្វែងយល់អំពីចរិតរបស់ស្វាមីនាង សង្កេតនូវសកម្មភាព អត្តចរិតនិង អធ្យាស្រ័យរបស់គេ ហើយជាអ្នកចេះជួយទុក្ខធុរៈ និងសហការគ្រប់ពេលវេលា នៅក្នុងគេហដ្ឋានថ្មីរបស់នាង។ ស្រីៗ គប្បីសុភាពរាបសារ មានសន្តានចិត្តល្អ និងប្រុងប្រយ័ត្ន ក្នុងការប្រាស្រ័យទាក់ទងជាមួយបាវព្រាវ និងត្រូវទុកដាក់ថែរក្សាប្រាក់ដែលស្វាមីនាងរកបានឲ្យបានល្អ ព្រមទាំងត្រួតពិនិត្យឲ្យបានច្បាស់ថា ចំណាយសព្វបែបយ៉ាងនៅក្នុងផ្ទះសម្បែង ត្រូវបានរៀបចំចាត់ចែងត្រឹមត្រូវហើយ។ ព្រះពុទ្ធទ្រង់បានប្រទានដំបូន្មាននេះ ជាង

ពីរពាន់ប្រាំរយឆ្នាំកន្លងទៅហើយ ប៉ុន្តែនៅតែមានប្រសិទ្ធិភាពរហូតដល់ថ្ងៃនេះ ។

គ្រឿងរកាំង និងគ្រឿងបន្ទប់បន្អាក់ទាំងឡាយ ដែលស្ត្រីត្រូវជួបប្រទះនៅក្នុងជីវិត ក៏ត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់ៗ ទុក្ខសោក និងការឈឺចាប់គ្រាំគ្រាដែលស្ត្រីត្រូវហែលឆ្លង នៅពេលចាកចេញពីក្រុមគ្រួសារនាង ក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងការលំបាកព្រមទាំងបញ្ហាទាំងឡាយ ដែលស្ត្រីត្រូវជួបប្រទះក្នុងការព្យាយាមសម្របសម្រួលខ្លួន ក្នុងបរិដ្ឋានថ្មី គឺជាបញ្ហាលំបាក និងពលវទុក្ខដែលស្ត្រីត្រូវទទួលៗ បន្ថែមទៅលើបញ្ហាទាំងនេះ ស្ត្រីក៏ត្រូវរងនូវការឈឺចាប់ផ្នែកសរីរាង្គកាយ និងទុក្ខសោកជាច្រើនក្នុងអំឡុងពេលមានរដូវ មានគភ៌ និងសម្រាលកូនៗ ទាំងនេះគឺជាបាតុភូតធម្មជាតិ ដែលបង្ហាញអំពីគ្រឿងរកាំង និងស្ថានការណ៍ខុសគ្នារវាងបុរស និងស្ត្រីៗ

ទោះបីជាផ្នែកខ្លះនៃព្រះត្រៃបិដក គេបានធ្វើការអធិប្បាយឥតលាក់លៀមខ្លះស្ដីពីមាយា និងអាកប្បកិរិយារបស់ស្ត្រីក៏ដោយ ក៏ព្រះពុទ្ធទ្រង់បានសម្ដែងនូវលក្ខណៈល្អជាច្រើន នៅក្នុងគម្ពីរសំយុត្តនិកាយ ដោយពោលថា នៅក្នុងកាលៈទេសៈខ្លះ គេយល់ថា ស្ត្រីមានសុភវិនិច្ឆ័យល្អ និងភាពវាងវៃជាងបុរសទៅទៀត ហើយព្រះអង្គយល់ឃើញថា ស្ត្រីក៏អាចសម្រេចព្រះអរហន្តផលបាន ក្រោយពីប្រតិបត្តិតាមអរិយមគ្គប្រកបដោយអង្គប្រាំបីហើយនោះៗ

គេក៏អាចឃើញអាកប្បកិរិយារបស់ព្រះពុទ្ធចំពោះស្ត្រី ខណៈពេលដំណឹងស្ដីពីកំណើតបុត្រី ត្រូវបានថ្វាយដល់មិត្តភក្តិរបស់ព្រះអង្គ គឺព្រះបាទបសេនទិកោសល ។ ព្រះរាជាអង្គនេះមិនសប្បាយព្រះទ័យ ចំពោះ

ជំណាំងនោះសោះ ពីព្រោះព្រះអង្គចង់បានបុត្រា ប៉ុន្តែព្រះពុទ្ធមិនដូចជាសាសទាដទៃ ព្រះអង្គបានផ្ដល់នូវការសរសើរយ៉ាងធំធេងចំពោះស្ត្រី ហើយទ្រង់បានសម្ដែងអំពីបុគ្គលិកលក្ខណៈមួយចំនួន ដែលជាអលង្ការរបស់ស្ត្រី ដោយមានពុទ្ធដិការដូចខាងក្រោម:

"បពិត្រព្រះនរបតី ! ស្ត្រីខ្លះពិតជាប្រសើរជាងប្រុស
សូមមហាភជចិញ្ចឹមបីបាច់នាង។ មានស្ត្រីជាច្រើន មានប្រាជ្ញា
មានគុណធម៌ ជាស្ត្រីមានការគោរពយ៉ាងខ្ពង់ខ្ពស់ចំពោះម្ដាយក្មេក
ហើយមានការប្រព្រឹត្តដ៏ប្រសើរ។
ភរិយាដ៏ឧត្ដមបែបនេះ អាចប្រសូតបុត្រដ៏ក្លាហាន
ជាស្ដេចផែនដី ដែលដឹកនាំប្រទេសជាតិផង។

ក្នុងការសម្ដែងអំពីធម្មជាតិរបស់ស្ត្រី ព្រះពុទ្ធទ្រង់បានចង្អុលបង្ហាញ មិនត្រឹមតែភាពទន់ខ្សោយរបស់ស្ត្រីតែប៉ុណ្ណោះទេ ប៉ុន្តែទាំងសក្តានុពល និងសមត្ថភាពរបស់ស្ត្រីផងដែរ។ ទោះបីជាការសម្ដែងខ្លះហាក់ដូចជាមិនសូវជាទីពេញចិត្តក៏ដោយ តាមរយៈការអង្កេតដោយប្រុងប្រយ័ត្ន គេនឹងឃើញនូវអ្វី ដែលព្រះអង្គបានសម្ដែងអំពីស្ត្រី នៅក្នុងអតីតកាល ជាទូទៅនៅតែមានប្រសិទ្ធិភាព នៅពេលបច្ចុប្បន្ននេះ។ ទោះបីជានៅក្នុងប្រទេសភាគច្រើន មនុស្សគ្រាន់តែមានអាកប្បកិរិយាក្លែងក្លាយ និងត្រឹមត្រូវឡើងៗ ហើយឱកាសផ្នែកសិក្សាអប់រំ និងអាជីពឯករាជ ត្រូវបានបើកចំហ ចំពោះស្ត្រីហើយក៏ដោយ ក៏ស្ត្រីនៅតែទទួលរងការពិសោធន៍មិនជាទីរីករាយ មានអំណាចតិចតួច ត្រូវប្រឈមមុខនឹងភាពរើសអើង ការគិតក័យ និងការប្រណែនឈ្នានីស ពីគូប្រជែងនៅតែមាន ។

# សិលាចារឹក Ka 59
# នៃភូមិគោកក្លាង ខេត្តបុរីរម្យ

ដោយ **មីសែល ត្រាណេ**

## ១. សេចក្ដីផ្ដើម

*ផ្ទាំងសិលាចារឹកខ្មែរKa 59 ដែលយើងយកមកសិក្សានៅថ្ងៃនេះ ត្រូវបាន គេរកឃើញនៅក្នុងភូមិគោកក្លាង ស្រុកឡាំប៉្លាយមាត ហើយ សព្វថ្ងៃតម្កល់ទុក នៅវិទ្យាល័យគ្រូនៃខេត្តបុរីរម្យ ប្រទេសថៃបច្ចុប្បន្ន។ ខ្ញុំបានស្នើឲ្យគេថតចម្លងឯកសារសិលាចារឹកនេះទុក ។ នៅឆ្នាំ១៩៨៩ ខ្ញុំជា សាស្ត្រាចារ្យហ៊ីកហ៊ីន គ្រូខាងប្រវត្តិសាស្ត្រ នៅជុំវិញជនភៀសខ្លួន ដែល ឋិតនៅតាមជាយដែនខ្មែរ-ថៃ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។*

*ក្នុងរយៈពេលជាង១០ឆ្នាំ ដែលបានកន្លងមកហើយនេះ ជួនកាល ខ្ញុំក៏បានយកឯកសារនេះ មកអានឡើងវិញ ហើយដោយយល់ថាអត្ថ បទសិលាចារឹកនេះ អាចផ្ដល់ចំពោះអ្នកស្រាវជ្រាវ នូវព័ត៌មានជាប្រវត្តិ សាស្ត្រមួយចំនួន ទាក់ទងនឹងសង្គមខ្មែរបុរាណ ខ្ញុំក៏សម្រេចចិត្តផ្សព្វ ផ្សាយនៅថ្ងៃនេះ។*

*សូមជម្រាបថា ផ្ទាំងសិលាចារឹកនេះ បានត្រូវគេចារឡើងនៅក្នុង ឆ្នាំ១០១២នៃគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទសុរិយាវរ្ម័ទី១ នៅខេត្ត*

ប៉ុន្មែរក្នុងសម័យកាលមួយ ដែលទីក្រុងនេះ នៅជាអាណាខេត្តរបស់ព្រះរាជាណាចក្រកម្ពុជានៅឡើយ។

## ២. ការពិពណ៌នាអំពីសិលាចារឹក

ផ្ទាំងសិលាចារឹក Ka ៥៩ ធ្វើអំពីថ្មភក់ មានរូបរាងជាសន្ទឹកសីមា ដោយមានពន្លួញទៅផ្នែកខាងក្រោម ដើម្បីងាយស្រួលទីងដោតតម្កល់នៅលើទីតាំងណាមួយ តាមសេចក្តីត្រូវការ នាសម័យបុរាណ។ នៅលើផ្ទៃនៃគោលសីមានេះ យើងឃើញមានតួអក្សរខ្មែរចារឹកឡើងទាំងសង្ខាង ។ នៅផ្ទៃខាងមុខមាន១០បន្ទាត់ រីឯនៅផ្នែកខាងក្រោយមាន០៤បន្ទាត់។

ចំពោះទំហំសិលាចារឹកវិញ គឺឯកសារនេះ មានកម្ពស់៤៦សង់ទីម៉ែត្រ ទទឹង ២៥សង់ទីម៉ែត្រ និងកម្រាស់០៦សង់ទីម៉ែត្រ ។ ម្យ៉ាងទៀតយើងសង្កេតឃើញវត្តមានរបស់ពាក្យ "ឱម" នៅចុងផ្នែកខាងមុខនៃសិលាចារឹកនេះ ដែលមានវត្តមានតាំងតែពី សម័យវប្បធម៌មុនអង្គរ ។

អត្ថបទសិលាចារឹក ជាភាសាខ្មែរខាងលើនេះ ត្រូវបានចារឡើងនៅឆ្នាំ ៩៣៤ នៃមហាសករាជ ដែលត្រូវជាឆ្នាំ១០១២នៃគ្រិស្តសករាជ។

បើយើងប្រៀបធៀប នឹងសិលាចារឹកខ្មែរដទៃទៀត ក្នុងភូមិភាគនេះ ផ្ទាំងសិលាចារឹក Ka 59 ថ្វីត្បិតតែមានពាក្យមួយចំនួន ត្រូវរលុបបាត់ក៏ប៉ុន្តែនៅរក្សាគុណភាពខ្ពស់ ដោយហេតុថា វានៅរក្សាកាលបរិច្ឆេទនិងព្រះនាមរបស់ព្រះមហាក្សត្រ ដែលកំពុងគ្រប់គ្រងក្នុងភូមិភាគនេះ នា

អតីតកាលៗ

## ៣_ អត្ថបទនៃសិលាចារឹក

ក-ផ្ទាំងអត្ថបទដើមផ្នែក "ក" នៃ ka59 (ខាងមុខ)

<u>*អក្សរបុរាណ*</u>

បន្ទាត់ទី១ : ៩៣៤សកវ្រះបាទកម្រ
បន្ទាត់ទី២ : (តេង) អញស្រីសូយ្យជយវម្ម
បន្ទាត់ទី៣ : ទេវ៑បន្ទូលប្រេ ត្វាកសិការ
បន្ទាត់ទី៤ : ចៅមាតបក្សស្រិគ្គាង្វេល
បន្ទាត់ទី៥ : ... ត វ វ ហារ ត តំ វ្វល
បន្ទាត់ទី៦ : (ឲ្យ) យ សេនាបតិ (ត) ...
បន្ទាត់ទី៧ : ភាគកូមិគ្គាង្វេលនេះ សង្កោល (១)
បន្ទាត់ទី៨ : ឱយ វិន្ទវ្រះ គ្គាង្វេលត កន្ទាយ
បន្ទាត់ទី៩ : មាតុបក្សក៏ស្តេងចំ ...
បន្ទាត់ទី១០ : ឱម!

<u>*អក្សរសម័យទំនើប*</u>

បន្ទាត់ទី១ : (ឆ្នាំ) ៩៣៤សក (១០១២គ.ស)ព្រះបាទកម្រេង
បន្ទាត់ទី២ : តែងអញ ស្រីសុរិយោជយវម្ម
បន្ទាត់ទី៣ : ទេវ:បន្ទូល ប្រើត្វាកសិការត្រូវជា
បន្ទាត់ទី៤ : ចៅ(របស់) មាតបក្សសិត គ្គាង្វេល

បន្ទាត់ទី៥ : ស្តាប់បង្គាប់រួចហើយ

បន្ទាត់ទី៦ : បាន ... ឲ្យមេទ័ពនៅឯកូមិ

បន្ទាត់ទី៧ : គង្វើលនេះសង់គោលឡើង

បន្ទាត់ទី៨ : វិញព្រះគ្នាង្វើលជា ក្នុយ

បន្ទាត់ទី៩ : របស់មាតុបក្សក៏ស្តែង ចាំ ...

បន្ទាត់ទី១០ : ឱម!

ខ-ផ្ទាំងអត្ថបទដើមផ្នែក ខ នៃ ka59 (ខាងក្រោយ)

<u>អក្សរបុរាណ</u>

បន្ទាត់ទី១ : ... ចំ ស្រៅតំរួង.ចំជរ.ចំស្រៅ

បន្ទាត់ទី២ : ស្បៅ .ចំ ស្រៅខ្វាយ.ចំចន្ទរជ្រៅ

បន្ទាត់ទី៣ : ចំ មាងវ៉ក. ស្រុកថ្បាន. ចំប្រ:

បន្ទាត់ទី៤ : ... ថ្វល.ចំប្រែថ្បេង.ចំទ្រេត

<u>អក្សរសម័យទំនើប</u>

បន្ទាត់ទី១ : ... ស្រូវតំពូង ... ចំជរ

បន្ទាត់ទី២ : ចាំស្រូវស្បូវ.ចាំស្រូវខ្វាយ.ចាំចន្ទរជ្រៅ

បន្ទាត់ទី៣ : មាងវ៉ក.ស្រុក ថ្បាន.ចាំព្រះ

បន្ទាត់ទី៤ : ... ថ្វល ចាំថ្បេង ចាំទ្រេត

គ-សេចក្តីបកប្រែ ជាភាសាសម្រាយតាមសម័យទំនើប

ផ្នែក ក

(១)ក្នុងឆ្នាំ៩៣៤នៃមហាសករាជ (ត្រូវនឹង១០១២នៃគ្រិស្តសករាជ)

ព្រះករុណាជាម្ចាស់ជីវិតតម្កល់លើត្បូង គឺព្រះបាទកម្រេ (២) តេងអញ ស្រីសូរ្យជ័យវរ្ម័ទេវៈ (៣) ទ្រង់មានព្រះរាជបន្ទូលត្រាស់បង្គាប់ប្រើដល់ ពួកសិកវៃ (៤) ជាចៅរបស់លោកម្ចាស់ ខាងមាតបក្សគ្មាងវេល (៥) ដែលបានតក់ប្តឹង ... (អាចជាមនុស្សណាម្នាក់ចំពោះដីធ្លី ត្រង់បន្ទាត់ សិលាកឹកដែលបែករលុបនោះ (៦) (ទ្រង់ត្រាស់បង្គាប់ប្រើ) ឲ្យសេនាបតី (មេទ័ព) ដែល ... (៧,៨) បិតនៅក្នុងភូមិគ្មាងវេលនេះ រួចសង់គោលព្រំ សីមា ឲ្យដូចដើមវិញ ដល់ព្រះគ្មាងវេល ដែលជាក្មួយ (៩) មាតបក្ស របស់កំស្តែង ... ឱម (១០)។

ផ្នែក ខ

(ចំ) ស្រូវទំពូង .ចំដរ ចំស្រូវស្បៅ ចំស្រូវខ្វាយ ចំចង្អូរជ្រៅ ចំមោងរ៉ក ស្រុកកយាន (នៅ) ចំព្រះ ... ថ្វល ចំ ព្រៃក្បែង ... ចំទ្រោតៗ

## ៤_ បរិបទនៃសិលាចារឹក

ផ្ទាំងសិលាចារឹក Ka៥៩ ត្រូវបានចារឡើងនៅឆ្នាំ ១០១២ នៃគ្រិស្តសករាជ ក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រខ្មែរ គឺព្រះបាទសុរិយោ-វរ្ម័ទី១ ក្រោយពីព្រះអង្គបានជ្រែករាជ្យសម្បត្តិ ដោយយកព្រះនាមសម្តេចព្រះបាទកម្រតាងអញ ស្រីសុរិយោជ័យវរ្ម័ទេវៈ។

បរិបទនយោបាយស្មុគស្មាញ តានតឹងគ្រប់វិស័យក្នុងចក្រភពខ្មែរ ក្នុងអំឡុងពេលមួយឆ្នាំគត់ ដែលជារយៈពេលដ៏ខ្លី នៃការគ្រងរាជ្យ

របស់ព្រះបាទសុរិយាវម៌្មទេវៈ ក៏ប៉ុន្តែប្រកបដោយសមិទ្ធផលសង្គមគួរឲ្យកត់សម្គាល់ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈខ្លឹមសារ នៃអត្ថបទសិលាចារឹករបស់យើង។

តាមពិត នៅក្នុងអន្តរកាលនេះ ព្រះរាជណាចក្រកម្ពុជា បានជួបប្រទះនូវវិបត្តិជាច្រើន ជាពិសេសបញ្ហាជម្លោះ ដែលបណ្តាលមកពីការផ្លាស់ប្តូរអំណាច របស់រាជវង្សានុវង្ស ហើយក្នុងនាមជាអ្នកដឹកនាំគ្រប់គ្រង ព្រះបាទសុរិយាវម៌្មទី១ បានត្រូវដោះស្រាយវិបត្តិសង្គមតាមគតិយុត្តិធម៌។

## ៥. ខ្លឹមសារនៃសិលាចារឹក

តាមការវិភាគនៃសិលាចារឹក យើងអាចដឹងថា គោលសីមាចារឹកនេះ ដែលជាព្រះរាជប្រកាសរបស់ព្រះរាជាខ្មែរ នាសម័យនោះ គឺព្រះបាទសុរិយាវម៌្មទេវៈ ជាសេចក្តីសម្រេចមួយ ដែលគ្មាននរណាម្នាក់អាចនឹងបំពានបាន ឬបំផ្លិចបំផ្លាញបានជាដាច់ខាត ទោះក្នុងកាលៈទេសៈណាក៏ដោយ ។ មួយវិញទៀត លក្ខណៈពិសិដ្ឋរបស់បង្គោលសីមានេះត្រូវបានបញ្ជាក់បន្ថែមដោយពាក្យ "ឱម" ដែលជាគាថាមន្តអាគមសក្តិសិទ្ធិបំផុត ក្នុងលទ្ធិព្រហ្មញ្ញសាសនា។

សូមលើកឡើងវិញដែរ មហិទ្ធិឫទ្ធិពាក្យ "ឱម" នេះឋិតនៅត្រង់អត្ថន័យស៊ីជម្រៅរបស់វា ពាក្យបំព្រួញនៃការកោះហៅឈ្មោះរបស់ព្រះអាទិទេពកំពូលគឺ ព្រះព្រហ្ម ព្រះវិស្ណុ និងព្រះសិវៈ ដែលជាអ្នកបង្កើតបីបាច់ថែរក្សាលោកយើងនេះ។ ដូច្នេះហើយ មនុស្សទាំងពួង នាសម័យ

បុរាណ ដែលស្ថិតនៅក្រោមឥទ្ធិពល មនោគមសាសនាព្រាហ្មណ៍ ពុំអាចមិនគោរពប្រត្តិបត្តិ ឬទទួលស្គាល់បានឡើយ ។ យ៉ាងណាមិញ តែមានរបស់ពាក្យនេះ ក៏អាចនាំមកនូវជ័យមង្គលសិរីសួស្តីផងដែរ ។ ដើម្បីជាឧទាហរណ៍ យើងអាចយកសេចក្តី ដកស្រង់ចេញពីក្បួនហោព្រលឹងនាគរបស់ខ្មែរសុរិន្ទ ពីព្រោះនៅដើមអត្ថបទនេះយើងឃើញពាក្យ "ឱម"នេះ " ឱម សិទ្ធិការិយ សិទ្ធិសម្ភារៈបរមីកន្ទង តថាគតតស្សពុទ្ធស្សជាច្បង ទសបរមីផង ជ្រោមជ្រែងរក្សាអស់អរហន្ត ប្រសើរលើសលន់ សោតសុំករុណា ចម្រើនមេត្រី សទ្ធិទិឃាយុយឺនជយា ឧត្តមសួស្សលៗ ទាំងព្រះឥសូរ ស្តេចជាកំពូលគ្រគ្រប់ ... " ។ នេះជាកស្តុតាងលាយលក្ខណ៍អក្សរ នូវនិរន្តរភាពរបស់វប្បធម៌ខ្មែរ ទោះនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នក្តី ក្រៅប្រទេសក្តីៗ

សូមជម្រាបថា ចំពោះខ្មែរបុរាណ បញ្ហាដីធ្លី ពុំមែនគ្រាន់តែដីសម្រាប់ធ្វើស្រែចម្ការប៉ុណ្ណោះទេ ក៏ប៉ុន្តែជាមូលដ្ឋានគ្រឹះសំណង់សង្គមខ្មែរ ដោយហេតុថា វាជាលំនៅឋានរបស់បុព្វបុរសលើដូនតាចាស់ស្រុកកន្លែងពិសិដ្ឋ ហើយគ្មាននរណាម្នាក់អាចរំលោភ ឬបំពានបានជាដាច់ខាតៗ

អ្វីដែលឲ្យនៅខាងលើ អាចជួយយើងឲ្យឈ្វេងយល់អំពីអត្ថន័យរបស់អត្ថបទចារឹកដែលមានដូចតទៅ:

ក្នុងជ្រុងទីមួយនៃសិលាចារឹក Ka 59 គេដឹងថា មានករណីពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លី ហើយព្រះមហាក្សត្រខ្មែរបានបញ្ជាឲ្យមេទ័ព (សេនាបតី) របស់ព្រះអង្គ យកបង្គោលព្រំសីមាទៅបោះដើម្បីបញ្ជាក់ប្រាប់ជាសាធារណៈ ឬជាផ្លូវការថាទឹកដីនោះជាទឹកដីរបស់គ្នាឯងលៗ

រីឯក្នុងជ្រុងទីពីរនៃសិលាចារឹកវិញ យើងឃើញព្រះគុណម្ចាស់ ឬព្រះលោកម្ចាស់គម្តែង ដែលជាមន្ត្រីជាន់ខ្ពស់ខ្មែរម្នាក់ ត្រូវបង្គំក្នុងកំណែនឲ្យត្រួតត្រា តាមតំបន់ជាច្រើនដែលមានរៀកទដីធ្លី ដូចជានៅត្នាង្វិល នៅតំបន់ស្រូវទំពូង ស្រុកជ្បាន ស្រុកខ្លាយដែរ។

## ៦. ពាក្យថ្មី

អត្ថប្រយោជន៍របស់សិលាចារឹក Ka 59 ដែលយើងយកមកសិក្សាស្រាវជ្រាវ បានផ្តល់ចំពោះយើងនូវពាក្យថ្មី មួយចំនួនដូចជាពាក្យ ត្នាង្វិល មាតបក្ស ត្វាក និងសុរិយោវម៌ទេវៈ ដែលជាគោរមនាមរបស់ព្រះរាជាខ្មែរ នាសម័យបុរាណ ។

## ៧. ពត៌មានទាក់ទិន និងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ

វត្តមានរបស់ផ្ទាំងសិលាចារឹកជាភាសាខ្មែរ នៅក្នុងខេត្តបុរីរម្យ (បុរីប្រែកបដោយភាពមនោរម្យ ឬ ភាពសុខសាន្ត) ជាភស្តុតាងបង្ហាញឲ្យយើងដឹងថា ភូមិភាគនេះ នៅក្នុងអំឡុងដើមសតវត្សរ៍ទី១២ស្ថិតនៅក្នុងខណ្ឌសីមា របស់ព្រះរាជាណាចក្រកម្ពុជានៅឡើយ ។ បើនិយាយម្យ៉ាងទៀត តំបន់នេះ ស្ថិតនៅក្រោមការត្រួតត្រា របស់អាជ្ញាធរខ្មែរ ។

សូមជម្រាបថា រហូតដល់សព្វថ្ងៃនេះ មួយភាគធំនៃប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្នុងខេត្តនេះ ជាជនជាតិខ្មែរសុទ្ធសាធ ថ្វីត្បិតតែខេត្តនេះបាន ក្លាយទៅជាខេត្តរបស់ថៃក៏ដោយ ។ គប្បីរំលឹកឡើងវិញដែរថា នៅដើមសតវត្សរ៍ទី១៦នៃគ្រិស្តសករាជ ស្តេចកនបានកែនប្រជា

ក្សត្រនៅក្នុងខេត្តនេះ ដើម្បីធ្វើសឹកសង្គ្រាម ទប់ទល់នឹងការវាយទន្ទ្រានពីសម្នាក់កងទ័ពសៀមឈ្លានពាន ។ រីឯព្រះបាទអង្គចន្ទរាជាវិញ ព្រះអង្គក៏បានដណ្តើម បានខេត្តនគររាជសីមា សុរិន្ទ បុរីរម្យមកវិញ បានមួយរយៈពេលដ៏ខ្លីដែរ ក្នុងសតវត្សរ៍ទី ១៥ នៃគ្រិស្តសករាជ ។

គួររំលឹកឡើងវិញដែរថា ប្រជាពលរដ្ឋខ្មែរ ដែលរស់នៅខេត្តនេះនៅរក្សាប្រពៃណី ជូនតា និងភាសាខ្មែរនៅឡើយ ។ លើសពីនេះទៅទៀត តាមរយៈសិលាចារឹកនេះ យើងក៏បានដឹងទៀតថា នេះជាលើកដំបូងហើយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលយើងសង្កេតឃើញ នូវវត្តមានរបស់ឈ្មោះ ព្រះបាទកម្រតេងអញ ស្រីសុរិយាជ័យវម្មទេវៈ ដែលជាព្រះនាមផ្ទាល់របស់ព្រះបាទ ស្រីសុរិយាវរ្ម័នទី១ ព្រះមហាក្សត្រខ្មែរនាសម័យអង្គរ ។

## ៨_ បញ្ហាដែលចោទ

តាមសិលាចារឹក Ka 59 យើងបានឃើញព្រះនាម របស់ព្រះរាជាខ្មែរមួយព្រះអង្គថ្មី ដែលយើងពុំធ្លាប់ជួបប្រទះនៅក្នុងសិលាចារឹកពីលើកមុនៗ។ ដូច្នេះបញ្ហាដែលចោទឡើងនោះគឺថា តើព្រះនាម សូរ្យជ័យវម៌្មទេវៈ ជាព្រះរាជាខ្មែរមួយព្រះអង្គផ្សេងទៀត ឬជាព្រះបាទសូរ្យវម៌្មទី១ ដែលយើងធ្លាប់ស្គាល់មកហើយ។

ចំពោះបញ្ហាដ៏សំខាន់នេះ យើងពុំទាន់ហ៊ានធ្វើសេចក្តីសន្និដ្ឋាននៅឡើយ។ ប៉ុន្តែតែយើងជឿថា ឈ្មោះនេះ គឺជាឈ្មោះរបស់ព្រះបាទសុរិយវម៌្មទី១ក៏ដោយ ។

## ការកត់ត្រា

១- ចំពោះពាក្យព្រះបាទសូរ្យវរ្ម័ ឬព្រះបាទសូរិយវរ្ម័ គប្បីដឹងថា ពាក្យ "វរ្ម័" (varma) នេះជាពាក្យភ្ជាប់ខាងចុងព្រះមហាក្សត្រខ្មែរបុរាណ ហើយមានន័យថា ក្បាំង ខែល។ ពាក្យនេះមានសំនៀងមិនខុសពីពាក្យធម៌ (dharma) វណ៌ (varna) គភ៌ (garbha)។ល។ ពាក្យខ្មែរនាសម័យមុនអង្គរ ត្រូវបានអានថា (ឧ) ហើយបន្ទាប់មកទៀតនាសម័យកណ្តាល ត្រូវអានថា (ឧ) ដូច្នេះហើយ បានជាពាក្យសុរិយវរ្ម័ ឬសុរិយវរ្ម័ (Suryavarma) ត្រូវអានទៅសម័យកណ្តាលថា សុរយោពម៌ (Suryobarm) ទៅវិញ ។ ការបញ្ចេញសំនៀង សុរិយោពណ៌ ជាការអានខុស។

២- នេះពុំមែនជាលើកទី១ទេ ដែលយើងជួបប្រទះ នូវពាក្យនេះ ដើម្បីជាឧទាហរណ៍ យើងអាចយកសិលាចារឹក K ៨៥, K ៨១៤,K ២០០ ជាដើម ជាភស្តុតាង ។ ម្យ៉ាងទៀត រហូតមកដល់សព្វថ្ងៃនេះ ថ្វីត្បិតតែជនជាតិខ្មែរបានផ្លាស់ប្តូរសាសនា ពីព្រហ្មញ្ញសាសនា ទៅព្រះពុទ្ធសាសនាក៏ដោយ ក៏ប៉ុន្តែនៅប្រើពាក្យនេះក្នុងគាថា មន្តអាគមដដែល ។ គេច្រើនប្រើមុនចាប់ផ្តើមអត្ថបទ គាថាផ្សេងៗទៀត ។ ដើម្បីស្វែងយល់នូវអត្ថន័យរបស់វា គប្បីយើងត្រូវស្រាវជ្រាវឲ្យដឹងជាមុនសិន នូវបុព្វហេតុដែលបណ្តាលឲ្យគេស្ថាបនា ផ្ទាំងសិលាចារឹកនេះឡើង ។

៣- សង្កោល ពាក្យនេះអាចសរសេរដាច់ពីគ្នា សង់ទីង់គោល។ រីឯពាក្យវិន្ត ក៏ដូច្នោះដែរ ពោលគឺ គេអាចសរសេរឲ្យអានពាក្យនេះ

ជាប់ពីគ្នា គឺ ងៃ(ញៃ) និង ត ។ ពាក្យ ត្អាង សព្វថ្ងៃនេះ បានវិវត្តន៍ទៅជា ល្អាង និង អោង ។ រីឯពាក្យ វេល ពាក្យនេះសព្វថ្ងៃនៅប្រើក្នុងទម្រង់ ជាពាក្យ រង្វេល ហើយមានន័យថា អ្វីៗដែលព័ទ្ធជារង្វង់ៗ

ដើមទំពូង ជាដើមឈើមួយប្រភេទ ដែលមានស្លឹកវែងហើយដុះលើដីទួល ។ ទីក្រុងភ្នំពេញ រក្សាបាននូវស្ថាននាមមួយគឺ ផ្សារទួលទំពូង ។ ខ្វាយជាដើមឈើមួយប្រភេទ ។ ចំពោះខ្មែរសុរិន្ទ បុរីរម្យ គេនៅប្រើពាក្យ ចន្ធូរ ដដែលមិនបានកែប្រែ ដូចនៅសម័យអង្គរទេ ។ ពាក្យ ទ្រេត ឬ ទ្រោត មានន័យថា ផ្សៀង រលំ ផ្តេក ផ្តួល ។

៤- តាមសិលាចារឹកនេះ យើងពុំបានឃើញព្រះនាមព្រះមហាក្សត្រ ដែលសរសេរថា ឥស្វរ្យជ័យវម៌ ដូចដែលគេបានបោះពុម្ពផ្សាយក្នុងសៀវភៅកម្ពុជសុរិយា ឆ្នាំទី៥៦ លេខ២ ខែមេសា ឧសភា មិថុនា គ.ស ២០០២ ទំព័រលេខ ៦២ ។

៥- ឱម ឬ ឱំ ពាក្យនេះ ជាបទសន្ធិនៃអក្សរពិសិទ្ធទាំង៣តួគឺ អ ឧ ម អ+ឧ > ឱ+ម > ឱំ ឬ ឱំ។ អ បានដល់ព្រះនាមរបស់ព្រះវិស្ណុ ឧ បានដល់ ព្រះនាមរបស់ព្រះសិវៈ ឬ ឥសូរ ម បានដល់ព្រះនាមរបស់ព្រះព្រហ្ម ដែលជាអាទិទេពត្រៃសរណៈ នៃពួកព្រាហ្មណិក សម្រាប់បញ្ចេញ-វចីភេទ គោរពចំពោះអាទិទេពទាំង៣អង្គ ។ គេប្រើពាក្យនេះនៅខាងដើម ឬនៅខាងចុងនៃក្បួនវេទមន្ត សឹងជាសេចក្តីសម្រាប់សូត្រផ្សេងៗ ឬជាការប្រកាសជ័យជម្នះ ។ ន័យរបស់ពាក្យនេះ ប្រហាក់ប្រហែលនឹង ពាក្យ ជយោ ។



*រូបភាពសិលាចារឹកផ្នែក "ក" នៃសិលាចារឹក* Ka 59'



(រូបភាពផ្នែក "ខ" នៃសិលាចារឹក Ka59. គោកក្ទាន, ចុរ័យ ប្រទេសថៃ)

# អំពីការដាក់អន្ទាក់មាន់ព្រៃ[១]

ដោយៈ **មៀច ប៉ុណ្ណ**

តំបន់ព្រៃភ្នំនៃកម្ពុជាយើង សម្បូរទៅដោយម្រឹគីម្រឹគាបក្សាបក្សីគ្រប់ប្រភេទ ។ ម៉្លោះហើយ បណ្ដាជនខ្មែរ ដែលតាំងទីភូមិឋាននៅតំបន់ជិតខាងនោះ ច្រើនតែមានចំណង់ចំណូលចិត្តទៅខាងការដាក់អន្ទាក់ និងការទាក់សត្វ ទុកជាល្បែងកម្សាន្តលម្ហែចិត្ត ។

**១-រដូវដាក់អន្ទាក់ៈ**

នៅរវាងដើមខែកត្តិក ពេលដែលស្រូវស្រាល និងស្រូវដំណើប ដែលគេច្រើនដាំដុះ នៅតំបន់ដីខ្ពស់ក្បែរៗមាត់ព្រៃជើងភ្នំនោះទុំហើយ អ្នកដាក់អន្ទាក់យល់ថាឱកាសល្អមកដល់ហើយ ព្រោះរដូវនេះជាចុងពេលបញ្ចប់នៃទឹកភ្លៀង និងជាដើមរដូវប្រាំង ។ មាន់ព្រៃ និងក្ងោកចុះពីជំនីរភ្នំមកទាំងហ្វូងៗ ដើម្បីរកស៊ីស្រូវទុំនៅក្បែរៗមាត់ព្រៃ ។ បណ្ដាកសិករ ដែលមានជំនាញខាងការដាក់អន្ទាក់ ក៏រវៀសរវៃ ដើម្បីត្រៀមរៀបចំសម្ភារៈចាំបាច់ផ្សេងៗ ។

**២-ការរាយសម្ភារៈអន្ទាក់**

នៅតាមបណ្ដោយចង្កេះភ្នំ ចន្ល្លោះកំពូលភ្នំ និងវាលចម្ការស្រែ គេចាត់ទុកថា ជាតំបន់ចូងកាត់របស់មាន់ព្រៃ ក្ងោក ដើម្បីចុះ

---

១- លោកតូ ឡុង យ៉ែម និង អ៊ុម អូន បានមានបទពិសោធន៍ខាងការដាក់អន្ទាក់មាន់ព្រៃ និងការទាក់មាន់ព្រៃ។ គាត់បានឲ្យសម្ភាសន៍ដល់ក្រុមស្រាវជ្រាវយើងដូចមានអត្ថន័យខាង លើនេះស្រាប់ ។

មករកស៊ីស្រូវ ។ គឺនៅត្រង់ចំណុចនេះហើយ ដែលគេត្រូវកាយសម្រាស់ ធ្វើជាឧបសគ្គក្នុងដំណើរឆ្លងកាត់របស់សត្វ ។ សម្រាស់ត្រូវបានស្ថាបនាឡើងពីមែកឈើ មែកឫស្សី ដើមបន្លាផ្សេងៗ ដែលគេកាប់យកមកគរលើគ្នា ឲ្យមានកម្ពស់ល្មមតែសត្វឆ្លងមិនរួច ។ សូមជម្រាបថា ក្ងោក មាន់ព្រៃដែលចុះមកស៊ីស្រូវទុំនោះ វាមិនមែនធ្វើដំណើរដោយហើរទេ គឺដោយដើរផ្ទាល់ដីតែម្តង ។ ដូច្នេះ បើកាលណាវាជួបនឹងសម្រាស់ដែលរាំងផ្លូវវា វាត្រូវដើរគេច សៀររកច្រកណាដែលអាចដើរឆ្លងបាន ។ គេកាយសម្រាស់បែបនេះរហូតដល់ចម្ងាយ ១០០០ ម៉ែត្រ ឬលើសពីនេះទៀត ។ កាលណាកាយសម្រាស់ចប់សព្វគ្រប់ហើយ គេត្រូវរកមើលទីត្រង់ណា ដែលអាចជាច្រកធម្មជាតិ ដែលសត្វធ្លាប់ដើរឆ្លង ។ គេនឹងជ្រើសរើសយកទីនោះ ធ្វើជាច្រកបញ្ឆោត សម្រាប់ឲ្យសត្វចេញចូល ។ គេលៃទុកចន្លោះ ៨ ឬ ១០ ម៉ែត្រពីចន្លោះមួយទៅចន្លោះមួយ ។ ដូច្នេះ អ្នកដែលកាយសម្រាស់បានវែង គេអាចដាក់បានអន្ទាក់ ៤០ឬ៥០ ។ ដរាបណាព្រានដាក់បានអន្ទាក់កាន់តែច្រើន គេក៏នឹងមានវាសនាអាចឲ្យមាន់ ឬក្ងោក ជាប់អន្ទាក់គេកាន់តែច្រើនផងដែរ ។ ត្រង់ច្រកដែលគេដាក់អន្ទាក់ គេបានសម្រួលទីដីត្រង់នោះ ឲ្យវាលស្រឡះល្អ គ្មានឧបសគ្គ ធ្វើយ៉ាងណាឲ្យសត្វពេញចិត្ត នឹងឆ្លង ។

### ៣.អំពីអន្ទាក់[១]

១-សម្រាប់មាន់ព្រៃ ឬក្ងោក គេប្រើតែអន្ទាក់ជើងប៉ុណ្ណោះ ។

អន្ទាក់បែកចេញជា ៣ ផ្នែកយ៉ាងសំខាន់ គឺ :

**ក-ខ្សែអន្ទាក់** : ច្រើនធ្វើពីខ្សែស្លូតក្បាលទីឡងឬខ្សែផ្ទៃ ខ្សែស្បាតដែលស្វិតជាប់ល្អ ។ ខ្សែអន្ទាក់មានចំពៀនឬក្រវិលសម្រាប់រឹតរូតនៅពេលក្លាត់គន្ទឹះ ដោយត្រូវសត្វជាន់ ។ ខ្សែអន្ទាក់បែកជារង្វង់រងេក និងចុងម្ខាងទៀតសម្រាប់ចងភ្ជាប់ទៅដងអន្ទាក់ ។

**ខ- ដងអន្ទាក់** ធ្វើពីដើមឫស្សីរស់ឬកូនឈើទំហំប៉ុនកដៃ[១] ប្រវែងប្រហែល ២ ម៉ែត្រកន្លះ អាចទាញឲ្យកោងងោកមកជិតដីបាន ដោយមិនបាក់ ។

**គ-សាង[២] និងគន្លឹះ** សាងជាផ្នែកយ៉ាងសំខាន់មួយរបស់អន្ទាក់ ។ សាងត្រូវបានធ្វើពីឫស្សីឃ្លៃ ពុះច្រៀកជា ៥ ចម្រៀកតូចៗល្មម ។ ផ្នែកខាងចុងត្រូវបានកាច់ឲ្យក្ងុកចុះក្រោម សម្រាប់ដោតជាប់ទៅនឹងដី ។ ឯផ្នែកខាងគល់នៃសាង គេចិតឲ្យមានគន្ទាក់បន្តិចសម្រាប់យកគន្ទឹះ ដែលចងភ្ជាប់នៅខ្សែជិតរង្វង់នោះ មកខ្ទាស់ទុកជាចំណុចសម្រាប់ថ្ងោះគន្ទឹះ ។ គេយកគន្ទឹនោះ ទៅព័ទ្ធពីក្រោមតម្ពក់នៃបង្គោលតូចមួយ ដែលគេបោះភ្ជាប់ទៅក្នុងដី ទុកជាជំនួយនៃគ្រឿងថ្ងោះ ។

**ឃ- អំពីការដាក់អន្ទាក់**

មុនដំបូង គេយកកន្ទុយខ្សែទៅចងនៅចុងដងអន្ទាក់ ដែល

១- បើជាដើមឫស្សីវិញ មានទំហំប៉ុនមេដៃ

២- សូមមើលរូបសាងក្នុងអន្ទាក់

គេចាប់ទាញឲ្យកោង ងោកមករកតម្កក់បង្គោល ។ រួចទើបគេយកកន្ទាស់មកខ្ទាស់ត្រង់គន្ទាក់គល់សាងនោះឲ្យជាប់ ហើយវាតរង្វង់ខ្សែអន្ទាក់ពីលើសាង ដែលហើបខ្ពស់ពីដីបន្តិចកម្ពស់ប្រហែល ៣ឬ៤សង់ទីម៉ែត្រ ។ គេសម្រួលដីក្បែររង្វង់អន្ទាក់នោះ ដោយយកស្លឹកឈើងាប់មកកាយក្រាលពាសពេញទីជិតខាង ព្រមទាំងពីលើសាងផង ធ្វើយ៉ាងណា កុំឲ្យសត្វចាប់អារម្មណ៍ថាមានអ្វី ប្លែកនៅត្រង់អន្ទាក់នោះ ។

***ខ_ការថ្លោះអន្ទាក់*** : កាលណាដាក់អន្ទាក់បែបនេះបានស្រួលបួលហើយ គេសាកល្បងយកមែកឈើមកសង្កត់លើសាង សាកល្បងមើល ដើម្បីស្វង់ឲ្យដឹងជាមុនថា តើអន្ទាក់វាត់រហ័សត្រឹមត្រូវទីងរឹតជើងមាន់បានឬទេ ។ ពេលដែលគេយកមែកឈើទៅសង្កត់លើសាងនោះ គល់សាងក៏ស្រុតចុះក្រោម ធ្វើឲ្យភ្លាត់កន្ទាស់ ។ រួចភ្លាមនោះ ដងអន្ទាក់ក៏វាត់ឡើងយ៉ាងរហ័ស ។ ឯខ្សែរង្វង់អន្ទាក់ក៏រូតរឹតមែកឈើជាតំណាងជើងសត្វនោះ យួរឡើងទៅលើយ៉ាងលឿនមើលស្ទើរតែមិនទាន់ ។ គឺបែបនេះហើយ ដែលមាន់ព្រៃ ឬក្ងោកត្រូវមកជាប់អន្ទាក់នេះ នៅពេលណាមួយ ។

### ***៤_ការដើរមើលអន្ទាក់***

ម្ចាស់អន្ទាក់ត្រូវទៅមើលអន្ទាក់របស់ខ្លួនរៀងរាល់ព្រឹក ។ សត្វដែលជាប់ពីថ្ងៃមុន ឬពីព្រឹកមិញនេះ មុនម្ចាស់ទៅដល់ គ្រាន់តែ

ព្យួរតែកគោក។ទៅខាងចុងដងអន្ទាក់ប៉ុណ្ណោះ តែវានៅមានជីវិតនៅឡើយទេ ។ ព្រឹកឡើងម្ចាស់ដើរមើលពីដើមទី ដល់ចុងទី ហើយដោះសត្វដែលជាប់អន្ទាក់នោះ យកមកផ្ទះ ។

### ៥. ផលនៃការដាក់អន្ទាក់

ក្នុង១ ថ្ងៃ គេអាចបានសត្វ ដែលមកជាប់អន្ទាក់នោះ រហូតដល់ ៤ ឬ ៥ ក្បាល ។ ថ្ងៃណាសត្វដែលមិនសូវចុះ យ៉ាងហោចណាស់ ក៏គេបានមាន់មួយក្បាលដែរ ។

### ៦. ប្រយោជន៍នៃមាន់ព្រៃ ឬ គោក

ប្រសិនបើគេខានទៅមើល ២ ឬ ៣ ថ្ងៃនោះ សត្វដែលជាប់អន្ទាក់នឹងងាប់ ។ ប៉ុន្តែ បើគេទៅមើលបានទៀងទាត់រាល់ថ្ងៃនោះ សត្វ នឹងនៅរស់ទាំងអស់ ។ ព្រានយកមាន់ព្រៃរស់ ពិសេសមាន់ញីទៅលក់នៅទីផ្សារ ឬលក់ឲ្យកសិករគ្នាឯងក្នុងភូមិជាមួយ សម្រាប់ស្ល ឬធ្វើមុខម្ហូបផ្សេងៗទៅតាមការបេះលៃ ថ្នៃ ។ សាច់មាន់ព្រៃមានឱរសឆ្ងាញ់ណាស់ ។ អ្នកខ្លះយកមេមាន់ព្រៃមកក្រុងទុកចិញ្ចឹម ឲ្យកើតកូន កើតចៅ តពូជរហូតទៅ ។ ប៉ុន្តែបើជាមាន់ព្រៃឈ្មោលវិញនោះម្ចាស់មានការសប្បាយចិត្តណាស់ ព្រោះអាចលក់បានថ្លៃជាងមេ ។ អ្នកក្រុងខ្លះ ចូលចិត្តទិញមាន់ព្រៃឈ្មោលមកចិញ្ចឹម សម្រាប់មើលរូបរាង រោមស្លាបវា ដែលមានពណ៌ល្អដូចមាស ។ ទាំងករងទៀតសោតក៏ល្អសមយ៉ាងក្រៃលែង ទ្រេត គួរឲ្យចង់គយគន់ ។ អ្វីដែល

១-នៅពេលឃើញមនុស្សទៅដល់ វាភ្ញាក់ផ្អើលភ័យតក្កមា ហើយស្រែកកក់ៗៗយ៉ាងខ្លាំង។

ពិសេសជាងនេះទៀតនោះ គឺមាន់ព្រៃឈ្មោលរងាវពីរកេះណាស់ ។ ពេលរងាវម្ដងៗអ្នកណាក៏ចង់ស្ដាប់ដែរ ។ សំឡេងរងាវ[១] របស់វាញាសូរជ្រះស្រឡះស្រួយប្រែស ហើយថែមទាំងមានបទបែបលើកដាក់ដូចសំឡេងដូរ្យតន្ត្រីធម្មជាតិពិតៗ ។ ប្រសិនបើបានក្ងោកឈ្មោលវិញនោះ ម្ចាស់ពិតជាសប្បាយចិត្តមិនតិចឡើយ ព្រោះក្ងោកលក់បានថ្លៃខ្ពស់ណាស់ ។ ក្ងោកមួយអាចមានតម្លៃ ពី ២០ ម៉ឺន ទៅ ៣០ ម៉ឺនរៀល ។ ក្ងោកឈ្មោលមានលម្អពិសេសបំផុតនៅកោមកន្ទុយវា ។ ពេលព្រឹកព្រហាម ឬពេលល្ងាចម៉ោងប្រាំ វាទុំស្រែកនៅលើដំបូលផ្ទះដោយសំឡេងលាន់ឮខ្លាំងដូចត្រុំប៉ែត (Trompette ) ខ, តូហូ!តូហូ!...។ ស្លាបមាន់ព្រៃក៏ដូចស្លាបក្ងោក អាចយកមកធ្វើផ្លិតយ៉ាងល្អពិសេស។ កន្ទុយក្ងោកយកមកតាំងលម្អនៅអាសនៈដូនតា ឬតាំងលម្អនៅលើទូក្នុងផ្ទះ។ ព្រោះកន្ទុយក្ងោកវាជាលម្អសម្រស់ម្យ៉ាង ដែលធម្មជាតិបានច្នៃរចនា រំលេចឲ្យមានសោភ័ណពិសេស លើសអស់ស្លាបបក្សីទាំងពួង ដែលមានតែស្លាបបក្សីឋានសួគ៌ (Paradisier) ទេដែលអាចផ្ទឹមបាន ។

## ៧. ក្ងោក មាន់ព្រៃ និងបរិដ្ឋាន[២]

១-សំឡេងមាន់រងាវទាក់ទាញហេតុការណ៍ ៣ យ៉ាង គឺ ស្រីក្រមុំ ពស់ និងខ្លា ។ គេតែងតែចៀសវាង មិនចិញ្ចឹមមាន់ ដែលរងាវចេញសត្វកំណាចទាំង ២ ខាងចុងនេះឡើយ ។ គេអាច មើលដឹងតាមស្រកាជើងរបស់វា ។

២- ចាស់បុរាណហៅថា សត្វករវែក (Paradisier ឬ oiseau de paradis )

ធម្មជាតិមានទំនោរ ប្លែកៗ ផ្សេងៗ ក្នុងការតាក់តែងលម្អ បរិដ្ឋាន ។ ព្រៃព្រឹក្សាលូតលាស់ល្អ ជន្ទុំជន្ទោល មានស្លឹកស្រស់ បំព្រងពណ៌បៃតងចាស់ ។ ផ្កាវាមានពណ៌ផ្សេងៗ ក្រហម លឿង ស ស្វាយ រលេចជាមួយនិងផ្ទៃខ្ទី ទុំពណ៌ក្រហមលឿង បៃតង ស .....។ ប្រសិនបើមានមាន់ព្រៃ ឬក្ងោកទៅទុំនៅលើព្រឹក្សាដ៏មានសម្រស់បែប នេះទៀតនោះនឹងបង្កើតបានជាផ្ទាំងទស្សនីយភាពមួយដ៏វិចិត្រនៅនាឋាន កណ្ដាលនេះ ។ ហើយប្រសិនបើវិចិត្រករបានឃើញ ទស្សនីយភាព នេះ គេនិងគូរចម្លងយកមកដាក់លើផ្ទាំងវិចិត្រកម្មរបស់គេ។ ហើយតើ ទស្សនិកជនណាមួយ ដែលមិនពេញចិត្ត នឹងគំនូរ ប្រភេទនេះនោះ?

មនុស្សលោកគួរតែហ៊ុំព័ទ្ធ ដោយបរិដ្ឋានល្អស្រស់បែបនេះ។ តើមានអ្នកណាផ្សេងទៀត ដែលត្រូវកសាងរចនាបរិដ្ឋានសម្រាប់កំដរ ជីវិតខ្លួនក្រៅពីខ្លួនឯងនោះ ៕

ជំនួយអសប្បរស

ឲ្យសាច់មិនប្រាប់ព្រៃ ឲ្យត្រីមិនប្រាប់បឹង

ទស្សនៈសង្គមខ្មែរ



(រូបភាពមាន់ព្រៃ)



(រូបភាពអន្ទាក់មាន់ព្រៃ)

# ប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា

*រៀបរៀងដោយ* **ហ៊ុន គីមថន**

## គ្រប់សាសនា ចាំបាច់ត្រូវតែមាននិកាយ :

*សាសនាធំៗក្នុងសកលលោកយើងនេះ តាំងមាំរហូតមកដោយមិនមាននិកាយនោះមិនមានឡើយ ទាំងនោះក៏ព្រោះសេចក្ដីនៃសាសនាទាំងនោះ ផ្សាយចេញទៅក្នុងពពួកមនុស្ស មានជាតិនិងភាសាផ្សេងៗគ្នា ក៏រមែងមានការប្រែប្រួលខ្លះៗ ជាធម្មតា ។ ចំពោះសាសនា ដែលមានអាយុកាលយូរយារជាងគ្នា ដូចព្រះពុទ្ធសាសនា សាសនាព្រាហ្មណ៍ និងគ្រិស្តសាសនាជាដើមនោះ កាលវេលា និងសភាពជ្រួលច្របល់របស់លោក រមែងធ្វើឲ្យមានការប្រែប្រួលទៅឯង ។ អាចពោលបានថា គ្រប់សាសនាបុរាណមកដល់ពេលបច្ចុប្បន្ននេះ បានឃ្លៀងឃ្លាតឆ្ងាយ ឬប្រែប្រួលសេចក្ដីក្នុងកាលគ្រាដំបូង គឺក្នុងយាម ដែលសាស្ដារបស់សាសនានោះ នៅមានជីវិត ។ មិនច្រើនក៏តិច ក្នុងសភាពវិវឌ្ឍន៍របស់សាសនានីមួយៗ បើមិនប្រែប្រួល ក៏មិនចម្រើនដែរ នឹងក្នុងទីបំផុត ក៏រលត់សូន្យអស់ទៅ ។ ចំណែកការប្រែប្រួលនោះពុំបានទទួលយកការប្រែប្រួល កែខ្លួនតួភេទ: ឬហាក់ហាំនទស្សនៈធម៌របស់សាសនាឡើយ ព្រោះថា បើហេតុដូច្នោះ នឹងក្លាយទៅជាការ*

បែកចេញ ទៅជាប្រភេទសាសនាមួយផ្សេងទៀត ប៉ុន្តែសំដៅដល់ការកែខៃវិធីសាស្ត្រ និងការអនុវត្តន៍តាមបែបខ្លះ របស់សាស្តាទាំងនោះ ព្រោះហេតុដូច្នោះ គ្រប់សាសនា សូម្បីនឹងបែកមាននិកាយច្រើនយ៉ាងណាក៏ដោយ និងរហូតដល់កន្លងហួសផុតសម័យកាល ដ៏យូរទៅហើយក្តី មុខមាត់ដើមរបស់សាសនា ក៏រកការប្រែប្រួលស្ទើរតែមានដែរៗ ព្រះពុទ្ធសាសនារបស់យើង ជាសាសនា ដែលមានអាយុ ច្រើនជាងគេ មានមនុស្សជាតិ ដែលគោរពកាន់តាមច្រើនលានរយលាន ។ ធម្មចក្រនៃព្រះពុទ្ធសាសនា របស់សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានបត់បែន ទៅតាមប្រទេសទាំងនេះ គឺឥណ្ឌា សីហឡ ភូមា ថៃ ខ្មែរ លាវ កោះមាឡាយូ ចិន ទីបេ មុងហ្គោលី ជប៉ុន រហូតដល់ក្រិច ក៏នៅមានប្រាកដ ។ ចំពោះគោលប្ញាក់ឋាន ក្នុងប្រវត្តិសាស្ត្រយើង បានឲ្យឃើញថា អាណាចក្ររបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះធំធេងមហាសាល ប្រមាណមិនបាន និងមានសភាពច្បាស់លាស់ជាទីបំផុត នៅក្នុងចក្រវាឡដ៏សែនធំល្វឹងល្វើយនេះ ។ បណ្តាប្រទេស នគរ ដែលស្វាធ្យាយព្រះធម៌របស់ព្រះអង្គនោះ ទោះមានភាសាផ្សេងគ្នាក៏ពិតមែន ប៉ុន្តែសេចក្តីនៃព្រះធម៌ នៅតែមានន័យ តែមួយដូចគ្នា ។ និកាយធំៗ ក្នុងព្រះពុទ្ធសាសនាមានពីរ គឺមហាយាន និងថេរវាទ ឬឧត្តរនិកាយជាមួយទក្ខិណនិកាយ តែបើនិយាយដល់រឿងនិកាយ ព្រះពុទ្ធសាសនាមាននិកាយបែកច្រើនជាងគេជាទីបំផុត ក្នុងបណ្តាសាសនា

ទាំងឡាយលើលោកនេះ ។

**ហេតុនាំឱ្យមាននិកាយ**

ចំពោះព្រះពុទ្ធសាសនា ថាបើយើងសាកសួរ ចំពោះឫសគល់នៃការមាននិកាយហើយ ក៏មិនអាចថា មិនចាប់អារម្មណ៍ដល់បញ្ហាធំៗ ៣ ហ្វាក់ហ្វាំនដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្ដែងទុកមកហើយនោះឡើយ ។ គឺហ្វាក់ហ្វាំន នៃការសិក្សារៀនសូត្រឲ្យកើតសភាពចាំច្បាស់ ហៅថា បរិយត្តិ ១ ហ្វាក់ហ្វាំនក្នុងការធ្វើខ្លួន ឲ្យមានការឃើញច្បាស់នូវធម៌ ដែលបានរៀនមក ហៅថា បដិបត្តិ ១ និងផលដែលទទួលបានពីការបដិបត្តិ ហៅថា បដិវេធ១ ។ ហ្វាក់ហ្វាំនទាំងបីប្រការនេះ មានសេចក្ដីសំខាន់ក្នុងការសណ្ដាន់គ្នាមក គឺបរិយត្តិប្រៀបដូចជាផែនទី ដូចជាផ្លូវ ដែលទឹងដើរឲ្យដល់កំណប់ទ្រព្យ ។ បដិបត្តិ ប្រៀបដូចអ្នកស្វែងរកកំណប់ទ្រព្យនោះ ដើរតាមផែនទី ។ បដិវេធ ប្រៀបដូចការដើរដល់ទីកំណប់ទ្រព្យ ប្រសិនបើបាត់បង់ហ្វាក់ហ្វាំនណាមួយ សេចក្ដីសម្រេចផលរមែងកើតមានពុំបានឡើយ ។ កាលដែលសភាពនៃនិកាយ បែកចេញទៅនោះ ក៏ព្រោះតែមានសភាពបាត់បង់ ហ្វាក់ហ្វាំនណាមួយហើយហ្វាក់ហ្វាំនដែលសំខាន់បាត់បង់ទៅនោះ គឺបដិវេធធម៌ ។ យើង ត្រូវពិចារណា និងសង្កេតឲ្យឃើញបាននូវបដិវេធសទ្ធម្មដែលជាទីត្រូវសម្រេចផល របស់អ្នកបដិបត្តិ កាលបើពុំមានអ្នកសម្រេច យ៉ាងហោចណាស់ ត្រឹមតែការបដិបត្តិពុំមានអ្នក

ដែលត្រូវឃើញចាក់ចុះទៅក្នុងសច្ចធម៌ គ្រាន់តែចេះដឹងបរិយត្តិ និងការបដិបត្តិខ្លះៗ ក៏មានមតិយ៉ាងនេះ មតិយ៉ាងនោះកើតឡើង នូវសភាពចម្រូងចម្រាស ផ្ដេកផ្ដួលតាមទិដ្ឋិអាចារ្យ ឬគណាចារ្យ ក៏អាចធ្វើឲ្យមានការបែកបាក់ ទៅក្នុងហេតុនៃរឿងនិកាយនេះបានដែរៗ ម្យ៉ាងទៀត ការសិក្សាព្រះបរិយត្តិ និងបដិបត្តិ ព្រោះតែមានការសិក្សាបរិយត្តិមិនត្រូវទំនង លុះដល់ធ្វើការបដិបត្តិពុំត្រូវទំនង លុះដល់ឃើញ ក៏ពុំត្រូវទំនង ដោយការឃើញនោះ ខុសពីសច្ចធម៌ ក៏សម្គាល់ថា ការឃើញរបស់ខ្លួនត្រឹមត្រូវ ពោលអួតប្រាប់មហាជនតាមប្រការ ដែលឃើញខុសនោះឲ្យគេជឿតាម ដើម្បីប្រមូលនូវលាភសក្ការៈជាដើម ក៏ជាហេតុនាំឲ្យកើតនិកាយៗ ម្យ៉ាងទៀត ការបដិបត្តិព្រះវិន័យ របស់អ្នកបួសកាតខ្លះ ឬសម្នាក់ខ្លះពុំត្រឹមត្រូវ ធ្វើឲ្យសង្ឃពុំអាចធ្វើសង្ឃកម្មរួមគ្នាបាន ក៏ជាហេតុធ្វើឲ្យបែកទៅជានិកាយដែរ ៗ ម្យ៉ាងទៀត ព្រោះប្រទេសអ្នកកាន់ព្រះ-ពុទ្ធសាសនា ត្រូវជួបប្រទះនូវសង្គ្រាម មានការចូលលុកលុយពីបរទេស ពុំមែនជាអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវអ្នកប្រទេសទាំងនោះបំផ្លាញ នូវសម្បត្តិព្រះពុទ្ធសាសនា មានកាសាបាលី ក្បួនច្បាប់មានព្រះត្រៃបិដកជាដើម ជាហេតុឲ្យអ្នកបួស ពុំមានច្បាប់គប់គ្រាន់ដើម្បីសិក្សា ក្នុងព្រះពុទ្ធសាសនា នាំឲ្យមានការបដិបត្តិឃ្លៀងឃ្លាតជាដើម ៗ លុះក្រោយមក មានការរៀបចំធម៌វិន័យឡើងវិញ

សភាពដែលខុសនោះ ក៏នៅក្នុងសភាពខុស ឯការកែប្រែជាថ្មី ក៏ទៅជានិកាយមួយ ៗ ម្យ៉ាងទៀត ព្រោះតែការសិក្សាព្រះត្រៃបិដក អ្នកបួសជាបុថុជ្ជន យល់សេចក្ដីក្នុងធម៌មិនបាន ក៏មានទំនាស់ព្រោះបដិបទា ( ផ្លូវបដិបត្តិ ) កាន់យកខុសគ្នា ក៏ជាហេតុនាំឲ្យមានការបែកចេញជានិកាយដែរ ។

( នៅមានត )

> ព្រះនិព្វាននោះ គ្មានជាតិឲ្យកើត
> គ្មានចាស់ជរា ព្យាធិឈឺចាប់
> គ្មានចេះស្លាប់ គ្មានដល់នូវក័យ
> ទីងអ្វីទាំងអស់ ។
>
> សម្ដេចក្រុមព្រះវរចក្ររណឫទ្ធិ ( សុធារស )២

# សុន្ទរកថា

*ព្រះតេជព្រះគុណ អាជាញ ព្រហ្មវង្សា*

*ចៅអធិការ វត្តពុទ្ធសាសនា ពោធិញាណ*

*-ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរព!*

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយស*

*គឺជាកិត្តិយសដ៏ថ្លៃថ្លា ដែលខ្ញុំព្រះករុណា-អាត្មាភាព មានឱកាសចូលរួមក្នុងសន្និសីទកំពូល នាថ្ងៃនេះ ។ ខ្ញុំព្រះករុណា-អាត្មាភាព បានកើតនៅក្នុងត្រកូលគ្រិស្តបរិស័ទមួយ ដែលបានសិក្សារៀនសូត្រ ក្នុងសាលាគ្រិស្តសាសនា ហើយថែមទាំងបានច្រៀងនៅក្នុងក្រុមអ្នកចម្រៀង សរសើរព្រះនៅក្នុងព្រះវិហារគ្រិស្ត នៅមូលដ្ឋានទៀតផង ។ ប៉ុន្តែ នៅពេលដែលខ្ញុំព្រះករុណា-អាត្មាភាព បានអានសៀវភៅព្រះពុទ្ធសាសនាដំបូង កាលពីអាយុ ១៦ ឆ្នាំ ពេលនោះខ្ញុំព្រះករុណា-អាត្មាភាព បានដឹងភ្លាមថា ខ្លួនគឺជាពុទ្ធបរិស័ទមួយរូប ។ ខ្ញុំព្រះករុណា-អាត្មាភាព មានអារម្មណ៍រំភើបចំពោះករុណាធម៌ បញ្ញា និងការដោះផុតទុក្ខ នៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលបានផ្តល់ពន្លឺដ៏ត្រចេះត្រចង់ ដល់ខ្ញុំព្រះករុណា-អាត្មាភាព ដ៏ច្រើនលើសអ្វីៗ ដែលខ្ញុំព្រះករុណា-អាត្មាភាព ធ្លាប់ជួបប្រទះពីមុនមក ។*

*បទពិសោធន៍បែបនេះ កំពុងកើតមានឡើងជាបន្តបន្ទាប់*

កប់ពាន់ជន នៅក្នុងជីវិតមនុស្សនៃសតវត្សទី ២១ នេះ ។ កាលបើជនសាមញ្ញ នៅក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនា បានជួបប្រសព្វនឹងពាក្យប្រៀនប្រដៅដ៏ផូរផង់របស់ព្រះពុទ្ធ ដែលសម្តែងយ៉ាងច្បាស់លាស់ និងគួរឲ្យជឿជាក់បានហើយនោះ ពួកគេក៏ទទួលស្គាល់ភ្លាមថា នេះជាមាគ៌ាដ៏ប្រពៃជាសច្ចធម៌ ដ៏មានតម្លៃអនេកអនន្ត និងជាសាសនាដ៏ប្រសើរបំផុត លើសសាសនានានា ។ គេតែងតែឆ្ងល់ថា ហេតុអ្វីបានជាបញ្ញាញាណ រំដោះផុតទុក្ខដ៏ប្រពៃបែបនេះ មិនត្រូវបាន ផ្សព្វផ្សាយឲ្យបានទូលំទូលាយជាងនេះ ។

នៅក្នុងមាតុភូមិរបស់ខ្ញុំព្រះករុណា-អាត្មាភាព គឺប្រទេសអូស្ត្រាលី ចំនួនអ្នកកាន់ព្រះពុទ្ធសាសនា ពុំសូវមានច្រើនទេ នៅឆ្នាំ ១៩៨៣ ពេលដែលខ្ញុំព្រះករុណា-អាត្មាភាព បានត្រឡប់មកពីប្រទេសថៃ ជាលើកដំបូង ។ នៅឆ្នាំ ១៩៩១ ភាគរយនៃអ្នកកាន់ព្រះពុទ្ធសាសនា បានកើនឡើងដល់០.៨% លុះដល់ឆ្នាំ១៩៩៦ ចំនួននេះ បានកើតឡើងដល់១.១% ។ ហើយយោងតាមការជំរឿនប្រជាជនអូស្ត្រាលី កាលពីខែសីហា ឆ្នាំ ២០០១ កន្លងទៅថ្មីៗនេះ បានឲ្យដឹងថា ចំនួនអ្នកកាន់ព្រះពុទ្ធសាសនា បានកើនឡើង ៧៥% រហូត១៩% នៃប្រជាជនអូស្ត្រាលី ។ តាមចំនួននេះ មានន័យថា ក្នុងចំណោមប្រជាជនអូស្ត្រាលី ៥០ នាក់ មានប្រហែលជាម្នាក់ ដែលប្រកាសថា ជាអ្នកកាន់ព្រះពុទ្ធសាសនា ។ នៅខណៈដែលសាសនាគ្រិស្តចុះខ្សោយនៅបច្ចិមប្រទេស ព្រះពុទ្ធសាសនា ក៏បានក្លាយទៅជា

សាសនាមួយ ដែលកំពុងមានការរីកចម្រើនយ៉ាងលឿនបំផុត នៅប្រទេសអូស្ត្រាលី និងប្រទេសអភិវឌ្ឍដទៃទៀតជាច្រើន ។

នេះអាចជាដំណឹងល្អក៏ថាបាន ជាដំណឹងអាក្រក់ក៏ថាបាន។ ដំណឹងល្អនោះគឺថា ប្រជាជនអូស្ត្រាលីជាច្រើន កំពុងតែទទួលផលប្រយោជន៍ពីសាសនា ដែលបរិបូណ៌ទៅដោយសន្តិភាពបំផុត របស់ពិភពលោក ។ ដំណឹងអាក្រក់នោះ គឺមានន័យថា ព្រះសង្ឃទាំងឡាយ មានខ្ញុំព្រះករុណា-អាត្មាភាពជាដើម ត្រូវតែខ្នះខ្នែងបំពេញកិច្ចការយ៉ាងអស់ពីកម្លាំងកាយចិត្ត ជាមួយនឹងសិស្សគណកាន់តែច្រើន ដែលត្រូវយកចិត្តទុកដាក់ ។

ខណៈនេះ ខ្ញុំព្រះករុណា-អាត្មាភាព សូមផ្តល់ជាយោបល់ខ្លះសម្រាប់ពិចារណា ថាតើហេតុដូចម្តេច បានជាខ្ញុំព្រះករុណា-អាត្មាភាពយល់ថា ព្រះពុទ្ធសាសនាកំពុងតែរីកចម្រើននៅបច្ចិមប្រទេស ? ខ្ញុំព្រះករុណា-អាត្មាភាព សូមប្រើអក្សរមួយមាត់គឺ pure (ព្យូរ)ដើម្បីប្រមូលផ្តុំនវយុទ្ធសាស្ត្រសំខាន់ៗបួន ដែលជួយដល់ការផ្សព្វផ្សាយព្រះពុទ្ធសាសនា :

១-ការសម្តែង (Presentation) ដោយប្រើភាសាសាមញ្ញ

២-អ្នកស្តាប់មានចិត្តជ្រះថ្លា(User friendly) ដោយការទាក់ទាញចិត្ត និងងាយចូលទៅរក

៣-មានទំនាក់ទំនងល្អ (Relevant) ពាក់ព័ន្ធជាមួយបញ្ហាប្រចាំថ្ងៃ

៤-គំរូល្អ(Exmples) ព្រះសង្ឃដឹកនាំ ដោយបង្ហាញគំរូល្អៗ

**១-ការសម្តែង** (Presentation)

ប្រសិនបើយើង ចង់ឲ្យព្រះបរមពុទ្ធោវាទ ផ្សព្វផ្សាយដល់មនុស្សសម័យទំនើបនេះ យើងត្រូវការសម្តែង តាមវិធីបែបទំនើបមួយៗ ខ្លឹមសាររបស់ព្រះធម៌ ពុំចាំបាច់កែប្រែទេ ឯប្រការដែលត្រូវការកែតម្រូវជាប្រចាំនេះ គឺការសម្តែងនេះឯង ។ មនុស្សជំនាន់ក្រោយ នឹងមនុស្សស្តាប់ធម៌ទេសនា ដោយព្រះសង្ឃដែលទេសមិនពីរោះ មិនយល់សាច់ធម៌ ឬដែលមិនមានភាពរលូនឡើយ ។

យើងទាំងអស់គ្នាដឹងថា ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ថា ត្រូវបង្ហាត់បង្រៀនធម៌ ដោយប្រើភាសាសាមញ្ញ (ឧទាហរណ៍ អរញ្ញវិភង្គសូត្រ ) ។ ខ្ញុំព្រះករុណា-អាត្មាភាព សូមអនុញ្ញាតលើកឧទាហរណ៍មួយ ចំពោះអត្ថន័យរបស់ព្រះពុទ្ធតម្រាស់នេះ ។ សត-វត្សកន្លងទៅ បណ្ឌិត និងអ្នកប្រាជ្ញបច្ចិមប្រទេស បានចាត់ទុកពុទ្ធសាសនា ជាសាសនាទុទិដ្ឋិនិយម ដោយនិយាយថា ព្រះពុទ្ធសាសនាផ្តោតទៅលើសេចក្តីទុក្ខ តែម្យ៉ាងប៉ុណ្ណោះ ។ ហើយគំនិតកាន់ច្រឡំនេះ សូម្បីតែសម្តេច ប៉ាប ចន ប៉ូលទី២ (Pape John Paul II) ក៏បានលើកឡើងនៅក្នុងសៀវភៅ ដែលមានភាពចម្រូងចម្រាសរបស់ព្រះអង្គ ស្តីអំពី សាសនា លើពិភពលោកទៀតផង ។ ដើម្បីបញ្ចៀសគំនិតកាន់ច្រឡំនេះ យើងយកធម៌ស្នូលជាពាក្យប្រៀនប្រដៅនៃអរិយសច្ចទាំងបួន ដូចនេះគឺ : សេចក្តីសុខ (ទុក្ខនិរោធ) ហេតុ

នាំឲ្យមានសេចក្ដីសុខ (អដ្ឋង្គិកមគ្គ) ការប្រាសចាកសេចក្ដីសុខ(ទុក្ខ) ហេតុនាំឲ្យប្រាសចាកសេចក្ដីសុខ (តណ្ហា)។ ការធ្វើបែបនេះ បង្វែរការផ្ដោតអារម្មណ៍តែលើសេចក្ដីសុខ ។

នេះគឺជាការរៀបចំរៀបចំក្រោមធម៌ដ៏សាមញ្ញមួយ ដែលរក្សាបាននូវខ្លឹមសារ នៅខណៈដែលធ្វើឲ្យអ្នកស្ដាប់ នាសម័យទំនើបនេះឲ្យកាន់តែជ្រះថ្លាឡើង ។ ខ្ញុំព្រះករុណា-អាត្មាភាព សម្ដែងបែបនេះ ដោយសម្អាងលើព្រះពុទ្ធដីកាថា"ព្រះនិព្វាន គឺជាសេចក្ដីសុខដ៏ប្រសើរ (បរមសុខ) " (គម្ពីរធម្មបទ ទំព័រ ២០៣-២០៤)។ នៅពេលដែលខ្ញុំព្រះករុណា-អាត្មាភាព សម្ដែងធម៌ទេសនាអំពីអរិយសច្ច ៤ តាមវិធីនេះ ខ្ញុំព្រះករុណា-អាត្មាភាព ឃើញអ្នកស្ដាប់ជំនាន់ថ្មីទាំងឡាយ ផ្ទៀងសោតាស្ដាប់ ដោយយកចិត្តទុកដាក់ ហើយតែងតែមកនិមន្តសុំឲ្យ ខ្ញុំព្រះករុណា-អាត្មាភាព សម្ដែងថែមទៀត ។

**២. អ្នកស្ដាប់មានចិត្តជ្រះថ្លា** (User friendly)

ការសម្ដែងធម៌ដោយប្រើភាសាសាមញ្ញ គឺជាជំហានដំបូងក្នុងការធ្វើឲ្យអ្នកស្ដាប់ព្រះពុទ្ធសាសនា មានចិត្តជ្រះថ្លា ។ ក៏ប៉ុន្តែខ្ញុំព្រះករុណា-អាត្មាភាព បានឃើញមនុស្សជាច្រើន ទាំងនៅបស្ចិមប្រទេស ទាំងនៅបូព៌ាប្រទេស ដែលប្រាថ្នារៀនសូត្រព្រះពុទ្ធសាសនា តែមិនហ៊ានមកកាន់វត្តអារាម ដោយសារពួកគេមិនចេះច្បាប់ទម្លាប់ប្រពៃណី ឬក៏ដោយសារតែពួកគេខ្លាចភិក្ខុសង្ឃ ដែលមានទឹកព្រះភ័ក្ត្រមាំ ។ កាលណាបើ វត្តអារាមបើកទ្វារទទួលស្វាគមន៍ចំពោះ

បុគ្គល ដែលមកអំពីទិសផ្សេងៗ ហើយជួយសម្រួលទីស្នាក់អាស្រ័យដល់អាគន្តុកជនទាំងឡាយ កាលណាបើព្រះសង្ឃខិតចូលកាន់តែជិតជិតជាមួយបុគ្គលទាំងពួង ហើយពេលនោះ វត្តអារាមគឺជាអ្នកញ៉ាំងឲ្យអ្នកស្តាប់មានចិត្តជ្រះថ្លា ។

តែទោះជាយ៉ាងណាក៏ដោយ នៅសម័យទំនើបយើងនេះ មនុស្សទាំងឡាយមានការរវល់ខ្លាំងណាស់ រហូតស្ទើរតែគ្មានឱកាសទៅវត្តអារាមបាន ។ ដូច្នេះវត្តអារាម ត្រូវតែទៅរកពួកគេ ជាមួយទីងសៀវភៅ កាសែត ស្តាប់ស៊ីឌី និងអិនធ័រណែត ។ សហគមន៍ពុទ្ធសាសនាអូស្ត្រាលីខាងលិច របស់ខ្ញុំព្រះករុណា-អាត្មាភាព មានវិបសៃដ៍ធំមួយ ដែលផ្ទុកទៅដោយ ធម្មសាកច្ឆាប្រចាំសប្តាហ៍ជាភាសាអង់គ្លេស ដើម្បីបុគ្គលគ្រប់រូប គ្រប់ទីកន្លែង នៅទូទាំងសកលលោក បានស្តាប់ព្រះធម៌ នៅតាមគេហដ្ឋានរបស់គេ តាមពេលវេលាដ៏គួរសមរបស់ខ្លួន ។ បេសកកម្មនេះ បានទទួលជោគជ័យខ្ពស់ ដោយមានអ្នកស្តាប់ទៀងទាត់ដ៏ច្រើន ជាសិស្សគណនៅពាសពេញពិភពលោក ដោយពុំចាំបាច់កសាងអាគារថ្លៃៗ និងដែលខ្ជះខ្ជាយបច្ច័យហួសប្រមាណឡើយ ។

**៣.មានទំនាក់ទំនងល្អ** (Relevant

សាសនាជាច្រើន មានគ្រិស្តសាសនាជាដើម កំពុងតែចុះខ្សោយឥទ្ធិពលនៅបស្ចិមប្រទេស ពីព្រោះសាសនាទាំងនេះ ត្រូវបានគេយល់ឃើញថា ពុំមានទំនាក់ទំនងទៅនឹងជីវិតរបស់មនុស្ស

កាតច្រើនៗ បុគ្គលមួយចំនួនតូច ខ្វល់ខ្វាយអំពីទស្សនៈវិជ្ជាអរូបិយ ក្បួនគោរពបូជា ដែលគ្មានន័យច្បាស់លាស់ឬការសន្និដ្ឋាន ដែលប្រាសចាកហេតុផល ។ មួយទៀតពួកគេទាំងនេះ ក៏ខ្វល់ខ្វាយផង ដែរ អំពីវិធីស្វែងរកសេចក្តីសុខឲ្យបានច្រើន ក្នុងចំណោមបញ្ហាធម្មតានៃជីវិត ។

ខ្ញុំព្រះករុណា-អាត្មាភាព ឃើញភាពងាយស្រួលដើម្បីពន្យល់ថា ការរក្សាសីលសិក្ខាបទ លើកកម្ពស់សេចក្តីសុខ ឧបមាដូចជា ទឹកជោរលើកឡើងនូវកម្រិតនីវ៉ូទឹកសមុទ្រដូច្នោះ ។ ជាលទ្ធផលគឺ អ្នកស្តាប់ធម៌ទេសនា របស់ខ្ញុំព្រះករុណា-អាត្មាភាពជាច្រើន រក្សាសីលប្រាំគ្រប់គ្នា ។ កាន់តែងាយស្រួលទៀតនោះ គឺថា ការបំភ្លឺថា ការផ្សាយមេត្តាធម៌ ចំពោះសហសេវិក គ្រួសារ និងចំណោះខ្លួនឯង តែងនាំឲ្យមានផាសុខភាព យ៉ាងច្រើនក្នុងជីវិតរបស់ខ្លួន ។ ដូច្នេះ សិស្សគណទាំងឡាយរបស់ខ្ញុំព្រះករុណា-អាត្មាភាព មិនក្រេវក្រោធ និងមានការអត់ឱនច្រើន ។ មានកស្តុតាងសុខាភិបាលជាច្រើនដើម្បីបង្ហាញថា ការបដិបត្តិសមាធិតាមប្រពៃណីព្រះពុទ្ធសាសនាបំបាត់នូវដំណើរតប់ប្រមល់ក្នុងចិត្តបាន (Stress) ព្រមទាំងសម្រាលដល់បញ្ហាពាក់ព័ន្ធផ្សេងៗ ជាច្រើនផង ។ ដូច្នេះហើយបានជាសមាជិកវត្តរបស់ខ្ញុំព្រះករុណា-អាត្មាភាព សុទ្ធតែជាអ្នកស្រឡាញ់សមាធិដ៏ជ្រាលជ្រៅ ។ ពាក្យអប់រំសំខាន់បីនេះ គឺ សីល, ករុណា និងភាវនា កាលបើបានស្ថិតនៅក្នុងខ្លួន ជាការបម្រើនសេចក្តីសុខ

ហើយនោះ នឹងនាំឲ្យមនុស្សច្រើនគ្នាជ្រះថ្លា ចំពោះព្រះពុទ្ធសាសនា។ ធម៌ទាំងបីនេះ មានទំនាក់ទំនងទៅនឹងអ្វី ដែលមនុស្សជាច្រើនចាត់ទុកថា មានសារសំខាន់ចំពោះពួកគេ ។

ពេលណាដែលយើងផ្ដោតអារម្មណ៍លើអ្វី ដែលមានទំនាក់ទំនងទៅនឹងជនសាមញ្ញ ពេលនោះ ព្រះពុទ្ធសាសនា ក្លាយជាមានសារសំខាន់ចំពោះពួកគេ ។ ពួកគេប្រហែលជាចាប់ផ្ដើម ជាមួយនឹងអត្ថប្រយោជន៍ ក្នុងការដោះស្រាយបញ្ហាជីវិតរបស់ពួកគេ ប៉ុន្តែ មិនយូរប៉ុន្មាន ការធ្វើបែបនេះ នឹងនាំពួកគេទៅកាន់ផ្លូវមួយ ដែលនឹងរំដោះគេឲ្យផុតចាកទុក្ខទាំងពួងបាន ។

**៥_គំរូល្អ** (Examples)

រឿងរ៉ាវទាំងអស់នេះ ពុំមានន័យអ្វីឡើយ ប្រសិនបើគ្មានអ្នកដឹកនាំប្រកបដោយគុណសម្បត្តិខ្ពស់ ដើម្បីជម្រុញទឹកចិត្តទេនោះ។ ការរីកចម្រើននៃព្រះពុទ្ធសាសនា ពឹងផ្អែកទាំងស្រុងលើគំរូដ៏រស់រវើករបស់ព្រះសង្ឃ ដែលមានគុណធម៌ ករុណាធម៌ ប្រាជ្ញាភ្លឺថ្លៃ និងមានព្រះទ័យស្ងប់ស្ងៀម ។ មនុស្សនៅសតវត្សទី ២១ នេះ មានមន្ទិលសង្ស័យច្រើនណាស់ ។ ពួកគេបង្ហាញជំនឿរបស់ពួកគេ លុះត្រាតែពួកគេឃើញភស្តុតាងណាមួយ ដែលនឹងផ្ដល់អត្ថប្រយោជន៍ដល់ពួកគេ ។ តើព្រះពុទ្ធសាសនាជួយបានឬទេ? តើព្រះពុទ្ធសាសនាពិតជា ដឹកនាំទៅរកគុណធម៌ ករុណាធម៌ សទ្ធម៌ និងធម៌ដោះផុតទុក្ខដែរឬទេ? ពួកគេនឹងសម្លឹងមកយើងទាំងអស់គ្នាជាព្រះសង្ឃ

គេមើលគំរូថា តើព្រះពុទ្ធសាសនានាំទៅទីណា មុនពេលពួកគេជឿតាមយើង ។ តើយើងអាចរំពឹងថា ទីងញាំងឲ្យមនុស្សសម័យទំនើប ដែលមានចម្ងល់ជឿតាមយ៉ាងម៉េច នៅពេលដែលព្រះសង្ឃរស់នៅក្នុងប្រណីតភាព មានទ្រព្យសម្បត្តិស្តុកស្តម្ភជាងជនសាមញ្ញ នៅពេលដែលយើងធូរលុងក្នុងការគោរពវិន័យ និងចេះដឹងតិចតួចអំពីភាពសុខស្ងប់នោះ ។ ព្រះធម៌បានផ្សព្វផ្សាយទៅភាគច្រើនបំផុតតាមរយៈការផ្តល់គំរូល្អ នេះមានឥទ្ធិពលខ្លាំងជាងការទេសនា ច្រើនណាស់ ។

ដូចអ្នកប្រាជ្ញអូស្ត្រាលីម្នាក់ជានារី បានសរសេរក្នុងសៀវភៅរបស់គាត់ ដែលចេញផ្សាយនាពេលថ្មីៗថា មុនពេលគាត់ក្លាយខ្លួនជាពុទ្ធមាមកជនម្នាក់ គាត់បានធ្វើការសង្កេតតាមដាន ព្រះសង្ឃនៅទីក្រុងពឺត (Perth) អស់រយៈពេលជាច្រើនខែ ។ នៅពេលដែលគាត់បានឃើញថា ព្រះសង្ឃទាំងនោះ ចេះសន្សំសំចៃ គោរពវិន័យ ឱហាតាការវ៉ោរ និងមានព្រះភ័ក្ត្ររីករាយ ពេលនោះ ទើបគាត់បានយកជាទីពឹង ហើយប្រកាសខ្លួនថា ជាពុទ្ធមាមកជនមួយរូប ។ អំពើនិយាយពូខ្លាំងជាងពាក្យពោល!

ដូច្នេះជាគំរូ នៅអូស្ត្រាលីភាគខាងលិច យើងបានកសាងនិងកំពុងកសាងវត្តអារាមទាំងឡាយ សម្រាប់បង្ហាត់បង្រៀនដល់ប្រធានសង្ឃទាំងពីរភេទ ដែលខ្ញុំព្រះករុណា-អាត្មាភាព ឲ្យឈ្មោះថា "ភេងចក្រភិក្ខុ" និង "ភេងចក្រភិក្ខុនី" ។ តាមរយៈការបញ្ចូល

ធនធានដ៏ច្រើន ទៅក្នុងការបណ្ដុះបណ្ដាលប្រធានសង្ឃ ប្រកបដោយគុណសម្បត្តិខ្ពស់បែបនេះ យើងប្រាកដជាអាចបានទាបាន នូវការផ្ដល់គំរូល្អមានគុណភាពខ្ពស់ ដល់មនុស្សជំនាន់ក្រោយ ។

ការលើកឡើងមកទាំងប៉ុន្មានខាងលើនេះ គឺជាយុទ្ធសាស្ត្រមួយចំនួន ដែលយើងបានប្រើនៅក្នុងប្រទេសអូស្ត្រាលី ដើម្បីធ្វើឲ្យព្រះពុទ្ធសាសនា ក្លាយជាសាសនាមួយ ដែលកំពុងមានការរីកចម្រើនលឿនបំផុតនៅទីនោះ ។ យើងពុំចាំបាច់កែប្រែឱវាទរបស់ព្រះបរមសាស្ត្រាចារ្យឡើយ ហើយយើងក៏ពុំចាំបាច់កែប្រែវិន័យសង្ឃដែរ ។ យើងត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីព្រះពុទ្ធបរមគ្រូជាម្ចាស់នៃយើង ហើយផ្សព្វផ្សាយកល្យាណធម៌ ទៅគ្រប់ទីកន្លែងទូទាំងពិភពលោក នាសម័យទំនើបនេះ តាមរយៈការធ្វើឲ្យព្រះពុទ្ធសាសនា បានស្អាតផូរផង់ៗ នោះគឺការសម្ដែងធម៌ ដោយប្រើភាសាសាមញ្ញ ញ៉ាំងអ្នកស្ដាប់ឲ្យមានចិត្តជ្រះថ្លា មានទំនាក់ទំនងល្អ និងយើងទាំងអស់ជាព្រះសង្ឃ ត្រូវធ្វើជាគំរូល្អ ញ៉ាំងជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៤

## លិខិតឆ្លើយតប

### ជម្រាបជូន

លោក ជួន ម៉េន នៅភូមិឡទឹកត្រី ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និងប្រជាពលរដ្ឋទូទៅ

សូមជ្រាប ។

យោងតាម: លិខិតដែលបានទទួល កាលពីថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៤ របស់លោក ជួន ម៉េន ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០០៤ លោកបានសួរអំពី :

ក- តើនាមទេវតាឆ្នាំវកនេះ ត្រូវហៅយ៉ាងដូចម្តេច ?

១-កក្យសាទេវី

២-កក្យសាទេវី

ខ-តើរូបគំនូរលើមហាសង្ក្រាន្តទាំងពីរខាងលោក វ៉ាយ វិបុល និងលោកអ៊ុម ប៊ុនទូ ត្រូវយកមួយណា ?

១-ទេវតាជិះស្វា

២-យក្សជិះស្វា

## ចម្លើយ

ក-ចំពោះនាមទេព្តាឆ្នាំកនេះ តាមសៀវភៅព្រះរាជពិធីទ្វាទសមាសភាគទី១ ទំព័រទី១៣ បន្ទាត់ ទី៨ មាន ប្រាប់ឈ្មោះថា រាក្សសាទេវី គ្រឿងប្រដាប់ មោរា កក្យាហារ លោហិត អាវុធស្តាំ ត្រីសូល៍ ឆ្វេងធ្នូ ពាហនៈ អស្សតរ ។ រីឯការសរសេរជារាក្សសាទេវីនេះ គឺជាពាក្យសរសេរក្លាយទេ បើតាមដានពាក្យនេះទៅ នៅក្នុងសៀវភៅវចនានុក្រមបាលី អភិធានប្បទីបិកា របស់ព្រះធម្មលិខិត ម៉ុង សែស ទំព័រ៣៤៧ បន្ទាត់១៧ មានបាលីថា " រក្ខសោ " បុំលិង្គ ប្រែថា (អារក្សទឹក) លុះយើងប្រើជាឥត្ថីលិង្គជា"រក្ខសា "ផ្លាស់ជាសំស្ក្រឹត" រក្សសា " ដូចពាក្យ " អក្ខរៈ "ទៅជា អក្សរ ដូច្នេះឯង ។ ពាក្យទាំងពីរនេះ ប្រើបានដូចគ្នា ប្លែកតែការសរសេរជាស្រៈ" ា "ភ្ជាប់ទឹង " រ " ប៉ុណ្ណោះ ប៉ុន្តែពាក្យនេះយើងពុំហ៊ានកែប្រែទេ ។

ខ- ចំពោះរូបគំនូរមានពីរយ៉ាងគឺ :

១-យកពង្សជាធំ :

២- យកទេព្តាជាធំ :

ក្នុងឆ្នាំទាំង១២នេះ មានទេព្តា ២ អង្គ ដើរតួសំខាន់ផ្សេងពីគ្នាគឺ:

- ទេព្តាតួអង្គ គង់លើសេះ ( ចំពោះឆ្នាំនេះ )
- ទេព្តាម្ចាស់ឆ្នាំ គង់លើស្វា ( ចំពោះឆ្នាំនេះ )

ទេព្តាម្ចាស់ឆ្នាំមានគ្រប់ទាំង ១២ ឆ្នាំ មិនមែនយក្សជាម្ចាស់ឆ្នាំ

ឬ មនុស្សជាម្ចាស់ឆ្នាំទេ។ បណ្ដាតួអង្គទាំង៣ គឺទេវតា មនុស្ស និងយក្ស នេះមានតែទេវតាទេ ដែលតំណាងឲ្យសភាវៈល្អបរិសុទ្ធ ប្រសើរជាងមនុស្ស ឬ យក្ស ដែល ពោរពេញទៅដោយអំពើហិង្សាសង្គ្រាម និងកលិយុគផ្សេងៗ ហើយទេវតាជាបុគ្គល ដែលមានរូបរាងស្អាតស្អប់ គួរជាទីជ្រះថ្លា និងផ្ដល់ក្ដីសង្ឃឹម ព្រមទាំងជំនឿដល់មនុស្សក្នុងឆ្នាំថ្មី ធ្វើឲ្យគេមានស្មារតីលើកកម្លាំងចិត្ត អាចយកជ័យជំនះ លើការងារទាំងពួងបាន ដែលជាហេតុនាំមកនូវ ទ្រព្យសម្បត្តិសិរីសួស្ដីសុភមង្គល គ្រប់ប្រការ ។

ដូចក្នុងការបកស្រាយខាងលើនេះហើយ ទើបសៀវភៅមហាសង្ក្រាន្ត ខាងពុទ្ធសាសនបណ្ឌិត្យ មានគូររូបទេវតាជិះសត្វ ដូច្នេះសូមលោក ជួន ម៉េន និងប្រជាពលរដ្ឋ ដែលមានការសង្ស័យ ជ្រាបជាដំណឹង ។

សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការព្យាយាមទំនាក់ទំនង និងសូមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

មន្ត្រីក្រុមជំនុំទំនៀមទំម្លាប់ខ្មែរ ផ្នែកហោរាសាស្ត្រ

**ទ៊ាយ ទិមុល**

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ស្ពាននាគ (វត្តភ្នំ) ថតនៅឆ្នាំ ១៩០៩

ឆ្នាំទី ៥៨ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស. ២៥៤៨ គ.ស. ២០០៤

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពដោយគណៈកម្មការមួយមាន :

នាយកការផ្សាយ : **ឌួន ទ៊ាន់ចន្ធី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** លោក **វង់ សុធារ៉ា**

លោក **ធន់ ហ៊ិន** លោក **មៀច ប៉ុណ្ណ**

# គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **ឆេត ចារ៉ុម** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមព្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព (WCRP) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.

# មាតិកាអត្ថបទ

## I អក្សរសិល្ប៍ពុទ្ធសាសនា


- ជីវិតមនុស្ស និងបញ្ហា (ត)........................ (ឈុន អៀម) ១
- លក្ខណៈ ៣២ ប្រការរបស់ព្រះពុទ្ធទាំងឡាយ ........(លីម លៀម) ១៤


## II អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ


- ពុទ្ធសាសនា និងបញ្ហាអប់រំ (តចប់) ............... (ធយ យីហ៊ាង) ២០
- ព្រះនាងសរស្វតីក្នុងវប្បធម៌ខ្មែរ .................. (ហម ធាយលី) ៣២
- សិលាចារឹកថ្មីមួយនៅប្រាសាទល្បីកស្រុត-ល្បីកស្រវែង .....(វង់ សុផាក់) ៤១
- ពិធីបង្ហោះគោមខ្មែរ ................................ (ហ៊ន់ ផេន) ៥៣
- វក្កជាតិវល្លិ៍រមៀត .....................(វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ) ៦២
- ប្រវត្តិបាភយណ៍អណ្ដែត ......................... (ចិន តាក់) ៧៩
- កំណាព្យ ត្រូវតែស្គាល់ព្រះពុទ្ធសាសនាឲ្យច្បាស់.(ភិក្ខុ ឈុន សម្បត្តិ) ៨៩


## III កំណត់ និងប្រវត្តិការណ៍


- សុន្ទរកថា ................................(ឯ.ឧ. លី ឡាយស្រេង) ៩៣
- សុន្ទរកថា .................................(ឯ.ឧ. ឃុន ហាំង) ៩៧

# ជីវិតមនុស្ស និង បញ្ហា (គ)

ព្រះតេជ.គ.ស្រី ធម្មានន្ទ
បកប្រែដោយ ឈន អៀម

## បទល្មើសអនីតិជន

**Juvenile délinquency**

*ការជជែកគ្នាណាមួយអំពីបទល្មើសអនីតិជន តែងលើកឡើងនូវសំនួរពីរជាមូលដ្ឋាន (១) អ្នកណាជាអនីតិជន ? (២) តើអ្វី កដ្ឋជាបទល្មើស ? ក្នុងការឆ្លើយតបទៅនឹងសំនួរទីមួយ លក្ខណាវិនិច្ឆ័យធម្មតា ដែលគេនិយមប្រើបំផុត. គឺកំណត់តាមអាយុកាល ( Chornological age ) ។ ច្បាប់ភាគច្រើនណាស់និយាយអំពីបទល្មើសអនីតិជន នៅទូទាំងពិភពលោក តែងកំណត់កម្រិតអាយុ ហួសពីកម្រិតអាយុនេះ នីតិវិធី និងវិធានការដោយឡែកចែងមកសម្រាប់អនីតិជន មិនអាចអនុវត្តបានទេ ។ កម្រិតអាយុអនុវត្តចំពោះអនីតិជន នៅក្នុងប្រទេសម៉ាឡេស៊ី នឹងនិយាយនៅពេលក្រោយ ក្នុងកថាខណ្ឌបន្ទបន្ទាប់ ។*

*សំនួរទីពីរ ទាក់ទងទៅនឹងអ្វីដែលកដ្ឋជាបទល្មើស ក៏តែតែពិបាកនឹងឆ្លើយណាស់ដែរ ។ ពាក្យថា delinquency ប្រែជាភាសាខ្មែរថា " បទល្មើស " គឺចេញមកពីពាក្យឡាតាំង*

delinquesce មានន័យថា " ប្រហែស " ឬ " ធ្វេស " ហើយបកប្រែក្នុងន័យទូលំទូលាយថា ការប្រហែសអំពីផ្នែកអនីតិជន ដើម្បីសម្របខ្លួនទៅនឹងស្តង់ដាចរិយាធម៌ដែលអាចទទួលយកបាន នៅក្នុងសង្គមណាមួយជាកំណត់ ។ អំពើណាមួយប្រឆាំងនឹងសង្គមត្រូវបានគេកំណត់ន័យថា ជាបទល្មើសផ្នែកព្រហ្មទណ្ឌ រួមមានបទល្មើស ដែលប្រព្រឹត្តដោយអនីតិជនផង ។

ក្នុងចំណោមយើងនេះ មានអ្នកខ្លះអាចមានកូនមិនប្រកបដោយធម៌មួយ (អវជាតបុត្ត?) នៅក្នុងគ្រួសារ ឬនៅក្នុងចំណោមយើងនេះ ។ តើអ្វីទៅជាហេតុ ? ការសិក្សាស្រាវជ្រាវ បានរកឃើញកត្តាមួយចំនួន ដែលបង្ហាញប្រាប់ពីដើមហេតុយ៉ាងណាខ្លះទើបកូនក្មេងម្នាក់ អាចប្រឈមនឹងគ្រោះថ្នាក់ ធ្លាក់ចូលក្នុងបទល្មើសព្រហ្មទណ្ឌ ។ ហេតុ-ផល ចម្បងនាំឲ្យមានបទល្មើសព្រហ្មទណ្ឌ ត្រូវបានគេរៀបរាប់ថា (ក) ក្នុងគ្រួសាររបស់ក្មេង ធ្លាប់មានប្រវត្តិបទល្មើសព្រហ្មទណ្ឌ (ខ) ប្រវត្តិគ្រួសារមិនចុះសម្រុងគ្នាដែលកើតមកពីចរិយាមិនជាប់លាប់របស់ឪពុក-ម្តាយ ហើយនៅក្នុងគ្រួសារនេះ វិន័យតឹងរ៉ឹង និងមិនទៀងទាត់ ប្រឫកប្របល់ដោយចិត្តទូលំទូលាយក្នុងការផ្តល់អំណោយ (gifts) ជាសម្ភារៈ (គ) គ្រួសារមានទំហំធំ (ឃ) ធ្លាប់មានប្រវត្តិគេចវេះពីសាលារៀន (ង) បរាជ័យក្នុងការសិក្សានៅសាលារៀន ។

អនីតិជនប្រព្រឹត្តល្មើស ប្រហែលជាចេញមកពីបរិដ្ឋានផ្ទះ

អាក្រក់ គេគ្មានជំនឿទុកចិត្តខ្លួនឯង គ្មានជំនឿក្នុងអត្តសញ្ញាណផ្ទាល់របស់គេ និងមិនដែលបានក្រេបរសជាតិសប្បាយធម្មតា ។ កូនសោចំពោះដំណោះស្រាយ គឺគ្រួសារ ។ តើឪពុក-ម្ដាយត្រូវទទួលខុសត្រូវចំពោះកិច្ចការនេះ ត្រឹមកម្រិតណា ? យុវជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌតូចតាច អាចជាជនដែលគេមិនបានយកចិត្តទុកដាក់កាលនៅកុមារ ។ ពួកគេចង់បានទ្រព្យ និងប្រាក់កាស ។ ប៉ុន្តែ ដោយហេតុ ពួកគេមិនដឹងធ្វើយ៉ាងម៉េច ដើម្បីបានទ្រព្យ និងប្រាក់កាស ទើបពួកគេលួច ។ ពួកយុវជន ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌហិង្សា ច្រើនជាយុវជន ដែលគេមិនបានយកចិត្តទុកដាក់ថែទាំ ហើយថែមទាំងត្រូវទទួលរងនូវអំពើឃោរឃៅទៀតផងកាលនៅកុមារ ។ ពួកគេមិនមានអារម្មណ៍អៀនខ្មាសដើម្បីដើរចូលគុកទេ ។ ពួកគេគ្មានគំនិតចេះជួយយកអាសាអ្នកណា ហើយក៏គ្មានបំណងចង់បានការទទួលស្គាល់ ឬយល់ព្រមពីសង្គមដែរ ។

ឪពុក-ម្ដាយដែលលែងលះគ្នា ច្រើនតែបង្កើតឲ្យមានបញ្ហាខាងអារម្មណ៍ផ្លូវចិត្តធ្ងន់ធ្ងរណាស់ ចំពោះកូនៗ ។ កូនៗ បានបាត់បង់នូវប្រពៃណីគ្រួសារ ដែលធ្លាប់តែបានជួយពួកគេ ឲ្យមានកិរិយាមារយាទត្រឹមត្រូវ និងចរិយាមារយាទ ដែលសង្គមអាចទទួលយកបាន ។

គ្មានមធ្យោបាយណាមួយ ជួយឲ្យកូនៗ ធ្វើអ្វីមួយកើតទេ

កាលណាពួកគេក្លាយទៅជាកូនប្រឆាំង លែងស្តាប់បង្គាប់ ដោយពិតប្រាកដហើយនោះ ។ ការដាក់ទណ្ឌកម្ម និងការផ្តល់រង្វាន់មានកម្រិតព្រំដែនរបស់វា ។ តើនៅពេលណាយើងចាប់ផ្តើមត្រួតត្រា ឬ ជំរុញលើកទឹកចិត្តកូនៗ ? ចិត្តវិទូអះអាងថា គឺនៅក្នុងពីរឆ្នាំដំបូងនៃជីវិត ដែលភាគច្រើនបំផុត នៃអភិក្រមនេះ បានកើតមានក្នុងអំឡុងពេលដែលសេចក្តីស្នេហារបស់ឪពុក-ម្តាយ បំផុសឡើងនូវសេចក្តីស្នេហាតបវិញ នៅក្នុងចិត្តកូនៗ ។

អំឡុងពេលនេះ គឺសំខាន់ខ្លាំងណាស់ ដើម្បីណែនាំកូននៅពេលវាចម្រើនវ័យធំឡើង ដើម្បីក្លាយទៅជាមនុស្សម្នាក់ មានការទទួលខុសត្រូវ ឬជាមនុស្សម្នាក់ប្រឆាំងសង្គម ។ ក្នុងសម័យកាលបច្ចុប្បនេះ ក្មេងជាច្រើនដែលមានអាយុពីប្រាំមួយ ទៅប្រាំពីរឆ្នាំ លែងទៅជាកូនដ៏ឥត ដែលយើងតែងសរសើរ និងបពោសអង្អែលទៀតហើយ ប៉ុន្តែ ច្រើនតែក្លាយជាក្មេងរឹងរូស មិនស្តាប់បង្គាប់មេបា ។ ឪពុក-ម្តាយ មានបន្ទុកទទួលខុសត្រូវយ៉ាងធំចំពោះចរិយាបែបនេះ ។ យើងគប្បីបណ្តុះទម្លាប់គិតគូរ ប្រកបដោយការប្តឹងថ្លែងម៉ត់ចត់ នៅក្នុងសន្តានចិត្តនៃកូនរបស់យើង បង្ហាត់បង្រៀនគេឲ្យចេះវាស់វែងអំពើទៅនឹងផលវិបាករបស់វា ។

នៅក្នុងដំណាក់កាលរីកចម្រើនរបស់ក្មេងៗនេះ សាលារៀនក៏មានភារកិច្ចទទួលខុសត្រូវស្មើនឹងឪពុក-ម្តាយដែរ ។ ក្មេងៗខ្លះមិនហ៊ានទៅសាលារៀន ព្រោះខាចគេធ្វើបាប បន្ទះបង្អាប់

ឬព្រោះអៀនមិនហ៊ានលេចមុខនឹងគេ ឬព្រោះខ្លាចរៀនមិនទាន់គេ ធ្វើកិច្ចការសាលាអាក្រក់ ឬក៏ព្រោះខ្លាចគ្រូ ។ ក្រោមពន្លឺនៃបទពិសោធន៍បែបនេះ ការព្យាយាមធ្វើឲ្យជីវិតក្មេងៗ អាយុពីប្រាំឆ្នាំមានការធានាច្បាស់លាស់ គឺត្រូវតែបានគិតគូរដោយត្រឹមត្រូវ ។

សេចក្ដីរាយការណ៍ថ្មីៗ ស្ដីពីបទល្មើសអនីតិជន ចេញផ្សាយដោយក្រសួងសង្គមកិច្ច បង្ហាញឲ្យឃើញកំណើននៃចំនួនករណីល្មើស (៣០០ ភាគរយ តាំងពីឆ្នាំ ១៩៦២) ប្រព្រឹត្តឡើងដោយយុវជនអាយុក្រោម ១៨ ឆ្នាំ ។ នេះជារឿងសោកសៅដ៏ពិតដោយមើលឃើញថា តើគេបានចំណាយកម្លាំងប៉ុន្មាន ទៅក្នុងគម្រោង និងកម្មវិធីដើម្បីផ្សព្វផ្សាយ និងឧបត្ថម្ភសង្គមមួយមានការថែទាំល្អ ។ មានយុវជនប្រព្រឹត្តបទល្មើសជាង ៤.០០០ នាក់ត្រូវបានអាជ្ញាធរចាប់ក្នុងឆ្នាំ ១៩៩៥ ប្រៀបទៅនឹងឆ្នាំមុន មានចំនួនប្រហែលមួយពាន់នាក់ តិចជាង ។

ភាគច្រើននៃយុវជនដែលត្រូវចាប់ខ្លួន គឺជាយុវជនដែលមានការពិបាកនៅក្នុងសាលា ។ ភាពខ្វះវិន័យ នៅក្នុងចំណោមសិស្ស បានឡើងដល់កម្រិតមួយគួរឲ្យតក់ស្លុត ។ បទល្មើសអនីតិជន បានបណ្ដាលមកពីកង្វះការយកចិត្តទុកដាក់ ដែលគេបានទទួលនៅផ្ទះ វត្តមាននៃសមាសភាគដ៏គ្រោះថ្នាក់ នៃល្បែងវីដេអូ (Video game) និងការកម្សាន្តសប្បាយ (amusement) ជុំវិញការមានមិត្តភក្ដិប្រចប្រកប្រចប់ប្រចល់មិនល្អ ។ ការសិក្សាបានលើកយកករណី

សិស្សរស់នៅក្នុងតំបន់អនាធិបតេយ្យ និងតំបន់ផ្ទះជួលថោកៗ ជាជាប្រភពងាយរងគ្រោះ ហើយមានបញ្ហាច្រើនបំផុត ។

លោកបណ្ឌិត មហាធៀរ មោហាម៉េដ នាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី មានប្រសាសន៍ថា ហេរដ្ឋាកិច្ចបាលបិទមណ្ឌលខ្លះ ជាកន្លែងដែលគេលើកទឹកចិត្ត ពួកមនុស្សក្មេងៗ ឲ្យប្រព្រឹត្តអំពើអសីលធម៌ ពួកគេអាចទៅបង្កើតមណ្ឌលដដែលនេះ នៅកន្លែងផ្សេង ដោយសម្ងាត់ទៀត ។

ប៉ូលីសបានសម្តែងការព្រួយបារម្ភ ពីការកើនឡើងនៃពួកបងធំ (gangsterism) និងករណីវាយធ្វើបាបនៅក្នុងសាលារៀន ។ សកម្មភាពបទល្មើសព្រហ្មទណ្ឌបែបនេះ ចាំបាច់ត្រូវតែបង្រ្កាប ដើម្បីបញ្ចៀសសិស្ស ឲ្យផុតពីការពាក់ព័ន្ធក្នុងបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ។ នាយកសាលា និងគ្រូៗគប្បីប្រៀនប្រដៅ និងទូន្មានសិស្ស កុំឲ្យចូលពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសព្រហ្មទណ្ឌ ។ ប៉ូលីស ត្រូវបានហៅមកជួយអន្តរាគម តែពេលណាមានបញ្ហាហួសពីការត្រួតត្រាបាន របស់នាយកសាលាប៉ុណ្ណោះ ។

លោក ហ៊ីសាម ហារុន សរសេរនៅក្នុង The New Straits Times ចុះកាលបរិច្ឆេទ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៧ ថា :

ស្ថិតិប៉ូលីសបានបង្ហាញថា ក្នុងឆ្នាំ ១៩៩៤ ចំនួនមនុស្សត្រូវចាប់ខ្លួនអំពីបទល្មើសព្រហ្មទណ្ឌរួមមាន ជក់ថ្នាំញៀន ចាប់រំលោភសេពកាម ស្មូកគ្រឿង គាស់ទ្វារបន្ទប់លួច និងលួច

វេយ្យុទ្ធ មានចំនួន ៤.១៩២ ករណី ។ ក្នុងចំនួននេះ មានប្រុស ១.៨៣៩ នាក់ និងស្រី ២៣ នាក់ ជាជនជាតិម៉ាឡេស៊ី ប្រៀបធៀបទៅនឹងប្រុស ៥៩០ នាក់ និង ស្រី ១៨ នាក់ ជាជនជាតិចិន និងប្រុស ៤២១ នាក់ ស្រី ១០ នាក់ ជាជនជាតិឥណ្ឌា ។

នៅឆ្នាំបន្ទាប់ ចំនួនជនល្មើសជាតិម៉ាឡេនៅក្នុងក្រុមវ័យនេះ បានឡើងដល់ ២.៤០២ នាក់ ចំណែកឯចំនួនយុវជនជាតិចិនត្រូវបានចាប់ខ្លួន មានចំនួន ៩២២ នាក់ យុវជនជាតិឥណ្ឌា ៥០៧ នាក់ត្រូវបានចាប់ខ្លួន ។ តួលេខនៃឆ្នាំកន្លងទៅគឺ ២៨៩០ នាក់ ជនជាតិម៉ាឡេ, ៧៧០ នាក់ ជនជាតិចិន (ចំនួនថយចុះ) និង ៥៧៤ នាក់ ជនជាតិឥណ្ឌាដោយមានរដ្ឋ សេឡង់ហ្គ័រ ជោហ៊រ និងកេដាស មានអត្រាបទល្មើសព្រហ្មទណ្ឌក្នុងចំណោមយុវជនខ្ពស់ជាងគេបំផុត ក្នុងបីឆ្នាំកន្លងទៅ ។ យុវជនម៉ាឡេ គឺជាជនល្មើសភាគច្រើនជាងគេ នៅគ្រប់រដ្ឋទាំងអស់ ។

ស្ថិតិរបស់ក្រសួងឯកភាពជាតិ និងអភិវឌ្ឍន៍សង្គម ហាក់ដូចគាំទ្រតួលេខរបស់ប៉ូលីស ហើយបង្ហាញថា ក្នុងចំណោមករណីបទល្មើសយុវជន ២.៨៩៨ នាក់ ពាក់ព័ន្ធគ្រឿងញៀន និងបញ្ហាសង្គមដទៃទៀតគឺ ៦១ ភាគរយ ជាជនជាតិម៉ាឡេ ១៧ ភាគរយជាជនជាតិចិន និង ១០ ភាគរយ ជនជាតិឥណ្ឌា ។ បន្ថែមលើនេះគឺមានជនជាតិម៉ាឡេ យ៉ាងហោចណាស់ ៧០ ភាគរយ នៃអន្តេវាសិក នៅសាលា Hendry Gurney School សម្រាប់ក្មេងប្រុស ក្នុង

រដ្ឋម៉ាឡក្កា ។

សង្គមវិទូ និងមន្ត្រីសង្គមកិច្ច ទម្លាក់កំហុសទៅលើសម្ពាធនៃជីវភាពថ្មីសម័យ ដែលនាំដោយជៀសមិនផុត ទៅកាន់ការរលំរលាយនៃចំណងដ៏រឹងមាំរបស់សហគមន៍ និងគ្រួសារ ។ ចុះតើអ្នកណា ជាមនុស្សដែលត្រូវការជំបូន្មាន ? គឺប្រហែលជា ឪពុក-ម្ដាយក៏ត្រូវការជំបូន្មានដែរ មិនមែនសុទ្ធតែជនល្មើសអនីតិជនទាំងអស់ទេ ។

លោក ដាទុក អាឌុល កាឌីរ ប៊ិន ជាស៊ីន ក្រុមអ្នកបោះពុម្ពផ្សាយកាសែត The New Straits Times បាននិយាយនៅក្នុង Sunday Time ក្នុងប្រទេសម៉ាឡេស៊ីថា មនុស្សចាស់ក៏ត្រូវការស្ដីបន្ទោសដែរ ចំពោះជំងឺសង្គមនៅក្នុងប្រទេស ។

យុវវ័យ ឬវ័យកម្លោះ ច្រើនតែជាវ័យនៃការប្រឆាំង ឬសង្គ្រាមកាល (Time of conflicts) ខាងផ្លូវកាយ ខាងផ្លូវអារម្មណ៍ និងខាងផ្លូវចិត្ត ។ ឥឡូវនេះ មានការមូលមតិគ្នាថា ជនល្មើសយុវវ័យភាគច្រើន គឺសិស្សសាលា ។ កាលណាមានក្មេងសិស្សសាលា បង្ហាញចរិយាដែលគួរឲ្យព្រួយបារម្ភ អាជ្ញាធរ ត្រូវតែអញ្ជើញឪពុក-ម្ដាយក្មេងមកប្រាប់គេឲ្យដឹង អំពីអ្វីដែលត្រូវបានពិនិត្យឃើញអំពីកូនៗ របស់គេ ។

ការប្រាប់ទាន់ពេលបែបនេះ អាចជួយឲ្យឪពុក-ម្ដាយចាត់វិធានការការពារ ឬកែលំអបាន មុនពេលកូនៗរបស់គេបន្ថែម

ចំនួនលើស្ថិតិ ទៅក្នុងបញ្ជីបទល្មើសព្រហ្មទណ្ឌរបស់ប្រទេស ។ ធ្វើបានយ៉ាងនេះ គ្រួសារហើយនិងសាលារៀន បានដើរតួយ៉ាងសំខាន់ក្នុងកិច្ចការពារបទល្មើសអនីតិជន ។ បើឪពុក-ម្តាយ យកចិត្តទុកដាក់ប្រតិបត្តិតាមដំបូន្មានរបស់ព្រះពុទ្ធ ទាក់ទងនឹងករណីកិច្ចរបស់ឪពុក-ម្តាយ ចំពោះកូនរបស់ខ្លួន ទុំះបញ្ហាជាច្រើន ដែលកូនៗបានបង្កើនឡើង អាចត្រូវបានលុបបំបាត់ ។

## ការរត់ចោលផ្ទះ

ការរត់ចោលផ្ទះ បានក្លាយទៅជាបញ្ហាស្រួចស្រាល់ក្នុងចំណោមយុវជន ដែលធ្វើឲ្យឪពុក-ម្តាយព្រួយកង្វល់យ៉ាងខ្លាំង ។ យុវជន "រត់ចោលផ្ទះ" គឺជាយុវជន ដែលចាកចោលផ្ទះគ្មានការអនុញ្ញាត ឬគ្មានប្រាប់ដំណឹង ដោយមានបំណងមិនត្រឡប់មកវិញទេ។ យុវជនរត់ចោលផ្ទះ ពីព្រោះគេមានអារម្មណ៍មិនអាចទ្រាំទ្រស្ថានភាពនៅផ្ទះបាន ។ គេមើលឃើញការរត់ចោលផ្ទះ គឺជាដំណោះស្រាយបញ្ហា ។ ប៉ុន្តែ តាមពិតរឿងនេះ គឺគ្រាន់តែនាំយកខ្លួនគេចេញឲ្យឆ្ងាយពីបញ្ហាប៉ុណ្ណោះ ។ អារម្មណ៍តានតឹងផ្លូវចិត្ត និងរបួសផ្លូវចិត្ត (The mental stress and the trauma ) នៅតែជាប់ស្អិតនៅឡើយ ។

សង្គម-ចិត្តវិទូម្នាក់ ដែលបានសិក្សាបញ្ហាបច្ចុប្បន្ននិយាយថា ការរត់ចោលផ្ទះ "គឺជាចម្លើយខ្វះវិចារណញ្ញាណមួយ តបទៅនឹង

អារម្មណ៍តានតឹង និងការខកចិត្ត ៗ តាមពិត វាមានហេតុ-ផល គ្រប់គ្រាន់នៅក្នុងបរិដ្ឋានផ្ទះ និងសាលារៀន ដើម្បីត្រៀមជាស្រេច ឲ្យមនុស្សមានសុខភាពផ្លូវចិត្តល្អបំផុត ពិចារណាការរត់ចេញពីផ្ទះ ទុកជាមធ្យោបាយមួយតប ត ៗ កាលណាក្មេងម្នាក់ ចាប់ផ្ដើមគិត អំពីការរត់ចេញពីផ្ទះ វាតែងចោទសួរខ្លួនវានូវសំនួរជាច្រើន ៗ វាតែងតថ្លៃជាមួយខ្លួនវា ច្រើនជាងមនុស្សមានវ័យចំណាស់គិតទៅ ទៀត ៗ តែថា ពួកវាសុខចិត្តបោះបង់ចោលសន្តិសុខនៅផ្ទះដែល ស្គាល់ស្រាប់ ថ្វីបើមានកម្រិតព្រំដែនក្ដី ដើម្បីចាប់យកការសន្យា នៃបរិដ្ឋានមួយថ្មី ដែលមិនធ្លាប់ស្គាល់ជាជំនួស ៗ ព្រោះហេតុអ្វី ? គឺពីព្រោះតែពួកគេអស់សង្ឃឹមពេកទៅ ទាល់តែគេយល់ឃើញថា ជម្រើសណាក៏ដោយ ក៏គ្រាន់បើជាងដែរ បើប្រៀបធៀបទៅនឹង សេចក្ដីទុក្ខ ដែលពួកគេទទួលរងនៅផ្ទះ ៗ ការរត់ចោលផ្ទះ មិនសូវរៀបចំបានល្អទេ ៗ វាមានចរិតឥតព្រាងទុក ឬស្ទួយម្ដួ និងកញ្ជក់កណ្ដៀត ៗ

មានឪពុក-ម្ដាយខ្លះ ជ្រើសរើស និងរឹតត្បិតមិត្តភក្ដិរបស់ កូនខ្លួនតឹងតែងពេក ៗ ជាលទ្ធផលឪពុក-ម្ដាយបែបនេះ អាច ជំរុញឲ្យកូនរបស់ខ្លួន គិតពីការរត់ចោលផ្ទះ ឆ្ពោះទៅរកការសន្យា ដែលមានសេរីភាពធំទូលាយជាង នៅខាងក្រៅផ្ទះរបស់គេ ៗ យុវតី មានគំនិតចង់រត់ចោលផ្ទះ ដើម្បីគេចចេញពីគ្រួសារបិទជិត និង កិច្ចការពារ ហួសហេតុរបស់ឪពុក-ម្ដាយរបស់ខ្លួន. យកជា

ឧទាហរណ៍ ការត្រូវធ្វើសេចក្តីសម្រេចចិត្តអំពីមិត្តប្រុស (គូ-សង្សារ) ។ ចំណែកឯយុវជនវិញ ច្រើនតែរត់ចេញពីផ្ទះ ពីព្រោះពួកគេគ្មានអ្នកគ្រប់គ្រងអស់កាលយូរពេក ។ ពួកគេបានពង្រីកនិងបង្កើតចរិយាចេវចាវ និងគេចវេះ មានទម្លាប់រស់នៅតាមបែបបទខ្វះសណ្តាប់ធ្នាប់ ។

ជួនកាល សភាពតានតឹង អាចកើតចេញពីការគ្រប់គ្រងមិនដិតដល់របស់ឪពុក-ម្តាយ ។ ឪពុក-ម្តាយដែលជាប់រវល់ជាមួយបញ្ហាការងារ អាចមិនមានឱកាសកែលំអចរិយា នៃកូនរបស់ខ្លួនបាន ។ម្យ៉ាងវិញទៀត ការរត់ចោលផ្ទះ ស្ទើរតែភ្ជាប់ទៅជានិច្ចជាមួយនឹងការត្រួតត្រាហួសហេតុពេក របស់ឪពុក-ម្តាយ និងសេចក្តីសង្ឃឹមរង់ចាំមិនមានផ្លែផ្កា (មិនពិត) អំពីឪពុក-ម្តាយ ។

ការដុះដាលខ្លាំងខាងសេដ្ឋកិច្ច នាពេលបច្ចុប្បន្នរបស់ប្រទេស បាននាំឲ្យកើតមានបញ្ហាសង្គមប្លែកៗជាច្រើន ដែលបានប៉ះពាល់ពួកយុវជនរបស់ប្រទេសជាតិ ។

ជាមួយនឹងការកើតមានទូរទស្សន៍ផ្សាយ តាមប្រព័ន្ធផ្កាយរណប (Satellite television) ហើយនឹងគមនាគមន៍ព័ត៌មានកម្រិតខ្ពស់អស្ចារ្យ យុវជនរបស់យើងនឹងត្រូវប្រឈមមុខ ចំពោះព័ត៌មានកាន់តែច្រើនមានតម្លៃអវិជ្ជមាន ដែលនឹងនាំទៅដល់ការស្រុតចុះសីលធម៌ កំពុងតែលងយុវជនជាច្រើនសព្វថ្ងៃនេះ នៅក្នុងបណ្តាប្រទេសអភិវឌ្ឍហើយ ។ យើងត្រូវត្រៀមខ្លួនយើងសម្រាប់ការ

ប្រឈមរបស់ពិភពលោកថ្មីមួយ ខាងមុខនេះ ។

## ការស្រុតចុះសីលធម៌

ការស្រុតចុះសីលធម៌ គឺជាបាតុភូតជាក់ស្ដែងមានស្រេចហើយក្នុងចំណោមយើងនេះ ដោយផ្អែកលើការវិនិច្ឆ័យចេញពីបញ្ហាសង្គមមួយចំនួន មានជាអាទិ៍ ការសេពគ្រឿងញៀន-ស្រវឹង ការដើរលេងប៉ាឡៃ វប្បធម៌ពាលាអាក់ស្រែ ក្នុងចំណោមយុវជន ការរួមភេទក្រៅច្បាប់ -ល-។

តាមការសិក្សា ដែលក្រសួងយុវជន និងកីឡាបានធ្វើលើយុវជន ៥.៨៦០ នាក់ គេឃើញថា ៧១% ជក់បារី ៤០% មើលវីដេអូអាសអាភាស ២៨% លេងល្បែងស៊ីសង ២៥% ផឹកស្រា និង ១៤% សេពគ្រឿងញៀន ។ យុវជនដប់មួយនាក់មកពីមណ្ឌលឃុំឃាំងផ្សេងៗគ្នា នៅក្នុងប្រទេស ត្រូវបានគេពិនិត្យឃើញថាមានផ្ទុកមេរោគ HIV (Human Immuno-deficiency Virus) ដែលបង្កជាជំងឺអេដស៍ (AIDS) ។ ដប់នាក់ក្នុងចំណោមយុវជនទាំងនោះ តាមពិតមានអាយុក្រោមម្ភៃឆ្នាំ ។

អាជ្ញាធរមានសេចក្ដីព្រួយបារម្ភ អំពីពួកយុវជន ដែលមានផ្ទុកមេរោគ HIV ហើយកំពុងតាមដានសភាពការណ៍នេះ យ៉ាងប្រកិត ។ ការត្រួតពិនិត្យមើលដំបូង បានបង្ហាញថា ក្នុងចំណោមយុវជនទាំងនោះ យុវជនខ្លះ មិនមែនជាអ្នកសេពគ្រឿងញៀនទេ

ប៉ុន្តែគ្រាន់តែជាអ្នកពាក់ព័ន្ធជាមួយមនុស្សទាំងនោះ ។ ករណីភាគច្រើនត្រូវបានគេរកឃើញ តាមរយៈការផ្តល់ដំបូន្មាន និងការធ្វើតេសវេជ្ជសាស្ត្រដោយស្ម័គ្រចិត្ត ។

ទំនោរបង្ខិចសុខភាពនេះ អាចរាំងខ្ទប់បានតែតាមអន្តរាគមន៍ដោយផ្ទាល់អំពីឪពុក-ម្តាយប៉ុណ្ណោះ ។ ឪពុក-ម្តាយគប្បីតាមដានឃ្លាំមើលសកម្មភាពរបស់កូនៗខ្លួន ដើម្បីបញ្ជាក់ឲ្យច្បាស់ថាកូនៗរបស់ខ្លួន មិនជាប់ពាក់ព័ន្ធក្នុងសកម្មភាពខិលខូច ឬសកម្មភាពខុសច្បាប់ណាមួយទេ ។

បើគ្មានការតាមឃ្លាំមើល និងត្រួតពិនិត្យពីដើមទីទេ កូនៗអាចក្លាយជាចំណីរបស់អានុភាពអាក្រក់ បង្ខិចសុខភាពបានយ៉ាងងាយ ។ បើសភាពការណ៍នេះចេះតែបានអនុញ្ញាតឲ្យបន្តទៅ ពួកអនីតិជន នឹងឈានរហូតដល់ប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរច្រើនទៀត ។ ការកើនបញ្ហាសង្គមប្លែកៗ ត្រូវតែបានដោះស្រាយយ៉ាងប្រញាប់ ។ ដូច្នេះ ឪពុក-ម្តាយ ត្រូវពង្រឹងស្ថាប័នគ្រួសារឲ្យមាំ ដើម្បីប្រឈមមុខ នឹងសំណួមពរទាំងឡាយនៃសង្គម ដែលប្រែប្រួលឥតឈប់ ។

(នៅមានត)

# លក្ខណៈ ៣២ ប្រការរបស់ព្រះពុទ្ធទាំងឡាយ

*រៀបរៀងដោយ : លីម លឿម*

ពុទ្ធបរិស័ទយើងបានដឹងយ៉ាងច្បាស់ ជាយូរយាណាស់មកហើយដែរ នូវពាក្យថា ព្រះពុទ្ធៗ ពាក្យនេះគ្រាន់តែពុត្តភាមអាចធ្វើឲ្យចិត្តរបស់លោកអ្នកកាន់ព្រះពុទ្ធសាសនា ត្រេកអររីករាយ ឬធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកបាបអកុសលផ្សេងៗ ដែលកំពុងកើតមាន ។ តួយ៉ាងដូចឧបាសក ឧបាសិកា និងបព្វជិតអ្នកចម្រើនធម៌ ( សមាធិកម្មដ្ឋាន ) ក៏យកព្រះនាមព្រះពុទ្ធ (ពុទ្ធានុស្សតិ ) នេះមកជាអារម្មណ៍ ជាមធ្យោបាយមួយសម្រាប់កំចាត់បាប និងរម្ងាប់ចិត្តដែលសៅហ្មង ។ មិនតែប៉ុណ្ណោះ ដោយព្រះពុទ្ធសាសនា ចូលជ្រួតជ្រាបដល់ក្រឪបេះដូង របស់ជនជាតិខ្មែរយើងទៅហើយនោះ មានអ្នកខ្លះស្រែកលាន់មាត់ថា ពុទ្ធោ នៅពេលភ្ញាក់ដោយសារគេចាក់ពញ្ញាក់ ឬឮសូរអ្វីខ្លាំង ដែលគួរឲ្យភ្ញាក់ម្តងៗទៀតផង ។

ព្រះពុទ្ធសាសនាចូលមកក្នុងប្រទេសខ្មែរយើង មានទាំងធម៌វិន័យ និងរូបតំណាងព្រះអង្គ ( ពុទ្ធរូប ) ទុកជាសក្ខីភាពសម្រាប់ធ្វើចិត្តអ្នកគោរពឲ្យជ្រះថ្លា តែពុទ្ធរូបទាំងនោះ ខ្លះធ្វើអំពីឈើ ថ្ម ស៊ីម៉ង់ត៍ សំរិទ្ធិ កែវ មាស ស្ពាន់ជាដើម ។ នេះគ្រាន់តែជារូប

តំណាងព្រះអង្គ មិនមែនរូបព្រះអង្គមែនទែនទេ ។ ពុទ្ធបរិស័ទយើងនៅមិនទាន់បានដឹង និងឃើញនូវលក្ខណៈរបស់អិត ដែលព្រះអង្គមានគ្រប់គ្រាន់ ខុសប្លែកពីមនុស្សយើងគ្រប់គ្នា ។

តាមការសិក្សាក្នុងព្រះត្រៃបិដក មានសំដែងអំពីលក្ខណៈ ៣២ ប្រការរបស់ព្រះអង្គ ដូច្នេះសូមអស់លោកអ្នកអាន សិក្សាស្រាវជ្រាវនូវលក្ខណៈ ៣២ ប្រការរបស់ព្រះពុទ្ធអង្គ ដូចខាងក្រោម ៖

១- មានព្រះបាទទាំងគូរាបស្មើ ( មិនខូងកណ្តាលដូចមនុស្សធម្មតា ) ។

២- ត្រង់ផ្ទៃព្រះបាទទាំងគូ មានរូបចក្រប្រកបដោយកណ្តាប់កង់ និងជុំព្រមទាំងកាំ ១ពាន់ មានចន្លោះស្មើៗគ្នាគ្រប់អន្ទើ ។

៣- មានព្រះបណ្ហិ គឺកែងវែង ( បើចែកសរីរប្បទេសត្រង់នោះជា ៤ ភាគ ២ភាគជាចុងព្រះបាទ ១ភាគជាព្រះបាទ ១ភាគជាបណ្ហិ "កែង" ) ។

៤- មានអង្គុលីគឺ ម្រាមព្រះហស្ត ( ម្រាមដៃ ) ម្រាមព្រះបាទ (ម្រាមជើង) វែងៗ ចំណែកម្រាមព្រះហស្ត ទាំងសងខាងវែងៗស្មើគ្នា លើកលែងតែមេដៃ ឯម្រាមព្រះបាទទាំងប្រាំនៃព្រះបាទទីមួយៗ វែងស្មើៗគ្នា ) ម្រាមទាំងអស់មូលត្រសូលរៀវល្អដូចផង់មនោសិលា ដែលគេលាយប្រេងល្អ ។

៥- មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទទន់ល្មន់ ( ដូចជាសំឡីដែលគេថ្ពចអស់មួយរយដង ។

៦- មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់គ្នាដោយក្រឡា ដូចសំណាញ់ ។

៧- មានព្រះបាទដូចជាអណ្ដែតឡើង ខាងលើហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ ។

៨- មានព្រះជង្ឃា គឺស្មងវែងមូលត្រសូលស្រជៀងនឹងស្មងសត្វទ្រាយ ( ពុំនោះសោតស្រដៀងនឹងដង្ហើមស្រូវ ) ។

៩- កាលបើទ្រង់ឈរមិនឱនព្រះអង្គចុះ ក៏អាចស្ទាបព្រះជានុ គឺជង្គង់ដោយព្រះហស្តទាំងពីរបាន ។

១០- មានព្រះអង្គាវយវៈ ដែលគប្បីលាក់ឲ្យកំបាំងដោយសំពត់ស្ថិតក្នុងស្រោម ( ប្រហែលជាដូចអង្គជាតិនៃសត្វដំរីឬគោឈ្មោលជាដើម ) ។

១១- មានឆវិវណ្ណ គឺសម្បុរថ្ងៃ ( លឿងភ្លឺ ) ដូចជាសម្បុរនៃមាស ។

១២- មានព្រះឆវី គឺសម្បុរថ្ងៃល្អិតផូរផង់លើងស្រិល ធូលីធ្លាក់មកលើមិនជាប់ ។

១៣- មានព្រះលោមា គឺរោមក្នុងរណ្ដៅទីមួយៗ តែមួយសរសៃ ( គ្រប់រណ្ដៅទាំងអស់ ) ។

១៤- មានព្រះលោមា ( រោម ) មានចុងងឡើងលើជាទក្ខិណាវដ្ដព័ទ្ធព៌នទៅខាងស្ដាំ មានសម្បុរខៀវស្រស់ដូចផ្កាអញ្ចន ។

១៥- មានព្រះកាយ ដូចកាយព្រហ្ម ។

១៦- មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញបរិបូណ៌ (ព្រះមំសៈ ៧ ពន្លើនោះគឺ ត្រង់ខ្នងព្រះហស្ថទាំងពីរ ខ្នងព្រះបាទទាំងពីរ ព្រះអំសកូដគឺ ចង្កេះស្មាទាំងពីរ និងត្រង់ខន្ធប្បទេសគឺត្រង់ក សរីរប្បទេសទាំង ៧ អន្លើនេះ មានសាច់ណែនពេញល្អឥត មានឃើញសរសៃតិចតួចឡើយ ) ។

១៧- មានចំណែកកន្លះព្រះកាយខាងដើម ស្រដៀងនឹងចំណែកកន្លះកាយនៃរាជសីហ៍ ( ត្រង់កន្លែងដែលគួរវែង គួរខ្លី គួរធាត់ គួរស្តួម ឬគួរមូល ក៏វែង ខ្លី ធាត់ ស្តួម រៀវមូលសមល្អ ឥតមានខ្ចង ) ។

១៨- មានចន្លូវព្រះប្រឹស្ឋ ( ខ្នង ) ពេញបរិបូណ៌ គឺមានខ្នងពេញស្មើឥតមានចន្លូវផតខូងត្រង់កណ្តាលឡើយ ។

១៩- មានទ្រង់ទ្រាយ ព្រះកាយប្រហែលនឹងបរិមណ្ឌលនៃដើមជ្រៃ គឺមានកាយ និងព្យាមប្រហែលគ្នា ( ដូចជាជ្រៃមានប្រវែងដើម និងមែកមិនលើស មិនខុសគ្នាប៉ុន្មាន ។

២០- មានព្រះខន្ធប្បទេស គឺក មូលសម ។

២១- មានព្រះប្រសាទ គឺសរសៃល្អិតធ្មារក្រៃលែងសម្រាប់ទទួលរសអាហារឲ្យជ្រួតជ្រាប ផ្សព្វផ្សាយក្នុងកាយទាំងមូលបាន ឥតមានទើសទាក់ ( សូម្បីអាហារយ៉ាងតូចតិចត្រឹមប៉ុនគ្រាប់ល្ង ក៏អាចជ្រួតជ្រាបសព្វសពាង្គកាយបាន ) ។

២២- មានព្រះហនុ គឺចង្កាមានសណ្ឋានដូចនឹងចង្កា

រាជសីហ៍ (ពេញបរិបូណ៌ប្រហែលដូចជាព្រះចន្ទក្នុងថ្ងៃ ១២ កើត ) ។

២៣- មានព្រះទន្តគឺ ធ្មេញ ចំនួន ៤០ គត់ ខាងលើ ២០ ខាងក្រោម ២០ ។

២៤- មានព្រះទន្តរាបស្មើ ( មិនប្រជួស ឬប្រពើសខ្ពស់ទាប ដូចជាធ្មេញនៃមនុស្សសាមញ្ញ ពួកខ្លះនោះឡើយ ) ។

២៥- មានព្រះទន្តជិតស្និទល្អ ។

២៦- មានព្រះទាឋាគឺ ចង្កូម ( ទាំង ៤ ) សស្អាត ( ភ្លឺរុងរឿងជាងពន្លឺផ្កាយព្រឹក ) ។

២៧- មានព្រះសូរសៀងគឺ សព្ទសម្លេងក្រាងក្រអៅ ដូចសម្លេងមហាព្រហ្ម កាលបើបញ្ចេញព្រះវាចា ពូពីរោះដូចជាសម្លេងនៃសត្វករវិក ។

២៨- មានព្រះជិវ្ហាទន់ល្មមល្មៃ ។

២៩- មានព្រះនេត្រខៀវស្រស់ ( ក្នុងទីដែលគួរខៀវ ) ។

៣០- មានដួងព្រះនេត្រ ស្រដៀងនឹងដួងភ្នែកគោ ( មានដួងព្រះនេត្រទាំងពីរ ថ្លាយង់ស្រដៀងនឹងដួងភ្នែកកូនគោ សម្បុរក្រហមដែលទើបនឹងកើតមួយរំពេច ) ។

៣១- មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះកម្ចួ (ចិញ្ចើម ) មានសម្បុរសក្បុស ទន់ល្វន់ដូចជាសំឡី ។

៣២- មានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ ( រុងរឿងដូចព្រះមហាក្សត្រ ដែលទ្រង់នូវក្បាំងព្រះភក្ត្រ ។

មានន័យមួយទៀតថា មានសិរ្សៈមូលបរិបូណ៌ល្អ ដូចជាម្កុដ ឬមូលហាក់ដូចជាវត្ថុដែលគេក្រឡឹង ហើយយកមកតម្កល់ ពុំនោះសោតមូលហាក់ដូចជា ពពុះទឹកដែលប៉ោងឡើង ។

គួរចងចាំ

- អ្នកដើរច្រើនស្រុក មើលឃើញច្រើនមុខ ដឹងច្រើនយល់ច្រើន ។
- ថ្នមពាហនៈ គ្រាន់បើជាងថ្នមរទេះ ថ្នមអ្នកចេះគ្រាន់បើជាងថ្នមអ្នកល្ងង់ ។
- អ្វីៗទាំងអស់ បើយើងយល់ហើយ គួរណែនាំអ្នកផងឲ្យយល់ផងដែរ ។

ដកស្រង់ចេញពី ជំណើងសហករណ៍
ទស្សនាវដ្តី លេខ ២១ ឧសភា ១៩៧៣

# ព្រះពុទ្ធសាសនា និង បញ្ហាអប់រំ

(តចប់)

*ដោយ បណ្ឌិត* **នយ យីហាង**

## III.បញ្ហាអប់រំសម្រាប់បព្វជិតពុទ្ធសាសនា

(Le problème de l'éducation pour les moines bouddhiques)

*សាសនា មិនអាចឃ្លាតឆ្ងាយពីការអប់រំបានទេ គ្រប់សាសនាទាំងអស់ សុទ្ធសឹងផ្សារភ្ជាប់ជាមួយការអប់រំ ព្រោះពាក្យ "សាសនា"បានបង្កប់ទុកក្នុងនោះនូវពាក្យ"ប្រៀនប្រដៅ" ឬ "ទូន្មាន" រួចទៅហើយ។ ពាក្យទាំងនេះហើយ ដែលតម្រូវឲ្យបព្វជិតទាំងឡាយយល់ដឹងជ្រៅជ្រះ អំពីសាសនានីមួយៗ ។*

*ចំពោះពុទ្ធសាសនាវិញ ធម៌ដែលព្រះពុទ្ធបានសម្ដែងប្រោសអស់មនុស្សសត្វទាំងឡាយ ត្រូវបានចងក្រងទុកក្នុងបិដក ឬ កញ្ជើទាំងបី ដែលហៅថា ត្រៃបិដក ដែលក្នុងនោះមានអភិធម្មបិដក វិន័យបិដក និង សុត្តន្តបិដក។ ក្នុងព្រះត្រៃបិដកមានទ្រឹស្ដី៣ ដែលគួរចងចាំគឺ ទ្រឹស្ដីពុទ្ធិ ទ្រឹស្ដីភាវៈ ទ្រឹស្ដីសុខៈ ។ ទ្រឹស្ដីពុទ្ធិ និយាយអំពីលោកិយពុទ្ធិ និង លោកុត្តរពុទ្ធិ ។ ទ្រឹស្ដីភាវៈនិយាយអំពីសង្ខតធាតុ ដី ទឹក ភ្លើង ខ្យល់ ដែលជាហេតុសម្រាប់បង្កើតអ្វីៗទាំងអស់ ដែលអ្វីៗទាំងអស់ មិនមែនកើតឡើងដោយសារអាទិទេពឡើយ ។ ទ្រឹស្ដីសុខៈ និយាយអំពីសភាពនៃសេចក្ដីសុខ ប្រភេទនៃសេចក្ដី*

សុខ និង វិធីស្វែងរកសេចក្តីសុខ ។

ម្យ៉ាងទៀត ពុទ្ធសាសនា និងស្បង់ តែងមានទំនាក់ទំនងជាមួយគ្នា។ការផ្តាច់ពុទ្ធសាសនាចេញពីស្បង់ អាចធ្វើឲ្យពុទ្ធសាសនាស្ថិតក្នុងសភាពឃើតយ៉ាវ និងអាចធ្វើឲ្យស្បង់ក្លាយជា ស្បង់ដែលខ្វះសីលញាណ។ ហេតុផលមួយគួសបញ្ជាក់ថា ពុទ្ធិទំនើបកំពុងមើលស្រាលវប្បធម៌ ដែលកំពុងមានអត្ថិភាព។ ក៏ដូចជាប្រពៃណីស្មារតីទាំងអស់ក្នុងលោកដែរ ពុទ្ធសាសនាសម្បូរទៅដោយទេវកថា ពិធីបុណ្យ និងអធិធម្មជាតិនិយម ។ ប៉ុន្តែទស្សនវិជ្ជាពុទ្ធសាសនា ដែលជាមូលដ្ឋានបង្អែកនៃពុទ្ធសាសនា អាចឆ្លើយតបចំពោះការស្រាវជ្រាវ កម្រិតខ្ពស់សម្រាប់បុគ្គល ដើម្បីលើកតម្កើងការច្នៃប្រឌិតប្រកបដោយប្រសិទ្ធិភាព និងប្រកបដោយកម្រិតស្ថាប័នសាកល ។ បើតាមព្រះពុទ្ធសាសនា គ្មានអ្វីធ្វើជាមួយអាទិទេព ឬជាមួយហេតុទីមួយ (Prime cause) ដែលស្ថិតនៅក្រៅក្របខណ្ឌ នៃកស្តុតាងសមហេតុផល ហើយដែលគ្រាន់តែជាការពិភាក្សា តាមបែបទ្រឹស្តីសុទ្ធសាធប៉ុណ្ណោះទេ។ ពុទ្ធសាសនានិយាយពីធម្មជាតិ នៃសច្ចភាពសាកល និងការប្រតិបត្តិ ដើម្បីឈានទៅដល់សច្ចភាពនោះ ដោយឥតប្រកាន់កេទ និងវណ្ណៈឡើយ។ ពុទ្ធសាសនិកគួរជឿនូវអ្វី ដែលគេបញ្ជាក់ដោយខ្លួនឯងបាន ចូរតាមបទពិសោធន៍នានា ទើងអាចធ្វើបែបនេះបាន លុះត្រាតែបព្វជិតទាំងឡាយសិក្សាទាំងខាងពុទ្ធចក្រទាំងខាងអាណាចក្រ គឺសិក្សាអំពីពុទ្ធសាសនាផង និងសិក្សាអំពី

ស្ត្រ (sciences) ដទៃទៀតផង ។ ហេតុនេះ យើងគួរផ្ដោតទៅលើបញ្ហាមួយចំនួនដូចខាងក្រោម ៖

### ១_ អាគារសិក្សា

នៅស្រុកមួយតែងមានវត្តជាច្រើន នៅក្នុងចំណោមវត្តទាំងនោះ គួរបង្កើតសាលានៅក្នុងវត្តមួយចំនួន ដែលមានលក្ខណៈសមស្រប យុវបព្វជិត គួរបានសិក្សាគ្រប់អង្គ ។ ដើម្បីកសាងអាគារសិក្សា គួរមានគម្រោងច្បាស់លាស់ ក្រោមការត្រួតពិនិត្យនៃក្រសួងធម្មការ និងសាសនា។ ការបណ្ដុះឲ្យយុវបព្វជិត ខ្វះការសិក្សាដែលមានលក្ខណៈវិទ្យាសាស្ត្រ ហាក់ដូចជាបណ្ដោយអនាគតពលរដ្ឋគ្រប់រូប ឲ្យស្ថិតនៅក្នុងសភាពល្ងង់ ។

ការស្ថាបនាអាគារសិក្សា ត្រូវផ្អែកលើពិធីបុណ្យផ្សេងៗដែលប្រារព្ធដោយសប្បុរសជនទាំងឡាយ ដូចជាពិធីបុណ្យផ្កាជំនួយពីអង្គភាពផ្សេងៗជាដើម ។ ការណ៍នេះ អាចប្រព្រឹត្តទៅបានលុះត្រាតែពុទ្ធសាសនិក បព្វជិតគ្រប់លំដាប់ថ្នាក់ មានគម្រោងរួមជាមួយក្រសួងធម្មការ និងសាសនា ។ ម្យ៉ាងទៀតក្រសួងធម្មការនិងសាសនា គួរលើកផែនការអំពីការកសាងសាលា នៅក្នុងផែនការកម្មរបស់រដ្ឋាភិបាល ឲ្យបានទៀងទាត់ ។

### ២_ អំពីសាស្ត្រាចារ្យ និងគ្រូ

ការបណ្ដុះបណ្ដាលគរុសិស្ស ត្រូវប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ។ ការបណ្ដុះបណ្ដាលនេះ គួរស្ថិតនៅក្រោមការសហការ រវាងក្រសួង

ធម្មការនិងសាសនា និង ក្រសួងអប់រំ យុវជន និងកីឡា។ មុននឹងធ្វើជាសាស្ត្រាចារ្យ និង គ្រូបង្រៀន ព្រះសង្ឃត្រូវសិក្សាចិត្តវិទ្យា និងគរុកោសល្យដូចសាស្ត្រាចារ្យ ឬគ្រូបង្រៀនគ្រហស្ថដែរ។ គឺចិត្តវិទ្យា និងគរុកោសល្យនេះហើយ ដែលជាម៉ែត្រវាស់កម្រិតយល់ដឹង និងសិល្បវិធី ក្នុងការបង្រៀនរបស់អ្នកអប់រំគ្រប់រូប ក្នុងការបំពេញការងាររបស់ខ្លួន ។ សាស្ត្រាចារ្យ និងគ្រូ អាចជាបព្វជិតដែលមានជំនាញខាងពុទ្ធលទ្ធិ តាមរយៈភាសាបាលី និងអាចជាគ្រហស្ថដែលមានជំនាញខាងភាសាបរទេស និងខាងវិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។

## ៣. កម្មវិធីសិក្សា

កម្មវិធីសិក្សា ត្រូវមានលក្ខណៈវិទ្យាសាស្ត្រ ត្រូវកែលំអរៀងរាល់ឆ្នាំ ។ កម្មវិធីនេះ គួរបែងចែកភាគរយនៃមុខវិជ្ជាទូទៅ និងភាគរយនៃមុខវិជ្ជាខាងពុទ្ធលទ្ធិ ។ មុនដំបូង ព្រះសង្ឃគួរសិក្សាឲ្យបានច្រើនខាងភាសាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ដែលជាចំណេះទូទៅ។ បន្ទាប់មកព្រះអង្គសិក្សាកាន់តែច្រើនឡើងៗ ខាងពុទ្ធលទ្ធិ យល់កាន់តែច្បាស់អំពីពុទ្ធលទ្ធិ។

ឧទាហរណ៍ : ក្នុងការស្វែងយល់កាន់តែច្បាស់ អំពីពុទ្ធលទ្ធិ ព្រះសង្ឃត្រូវចេះភាសាខ្មែរ ភាសាបរទេស និងចេះកុំព្យូទ័រ... ដូចដែលមានចែងក្នុងកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡាដែរ ។

ក្នុងយុគសម័យសាកលការូបនីយកម្មនេះ ព្រះអង្គមិនអាចបោះបង់ចោលសមិទ្ធផលវិទ្យាសាស្ត្រ ដូចជាបណ្ដាញអ៊ីនធឺណែត កុំព្យូទ័រ...បានឡើយ ។ ម្យ៉ាងទៀត ព្រះអង្គត្រូវស្វែងយល់អំពីនិកាយពុទ្ធសាសនាដទៃ អំពីសាសនាដទៃ និងជីវចលនិយម (animisme) សម្រាប់ព្រះអង្គប្រៀបធៀប និងពង្រឹងពុទ្ធសាសនាថេរវាទឲ្យកាន់តែប្រសើរឡើង ។ ការស្វែងយល់នេះ ពុំមែនព្រះអង្គងាកចេញពីពុទ្ធសាសនាថេរវាទនោះទេ តែព្រះអង្គយល់ដឹងជាទូទៅដើម្បីរួមចំណែកពង្រីកពុទ្ធសាសនាថេរវាទ ។ ប្រៀបធៀបនៅទីនេះ មានន័យថា ប្រៀបធៀបខាងផ្នែកទ្រឹស្ដី មិនមែនប្រៀបធៀបថា សាសនាណាមួយល្អ ឬអាក្រក់ឡើយ ។ និយាយថា សាសនាមួយល្អ សាសនាមួយអាក្រក់ គឺពិតជាឈានទៅដល់សង្គ្រាមសាសនា ។

### ៤. ការបំពាក់បរិក្ខារទំនើប និងសំភារៈឧបទ្ទេស

សាស្ត្រាចារ្យ និង គ្រូអាគារសិក្សា និងកម្មវិធីសិក្សាជាបញ្ហាចម្បងសម្រាប់ណុះបណ្ដាលព្រះសង្ឃ ។ បញ្ហាចម្បងមួយទៀតគឺបរិក្ខារទំនើប និងសំភារៈឧបទ្ទេស។ បើគ្មានកត្តាទាំងនេះទេ សិស្សគ្រាន់តែទទួលមេរៀនពីគ្រូប៉ុណ្ណោះ មានន័យថា គ្រូជាមជ្ឈមណ្ឌលនៃការសិក្សា ដែលខុសពីបំណងនៃគរុកោសល្យទំនើប។ គរុកោសល្យទំនើបមានបំណងធ្វើឲ្យសិស្ស ក្លាយជាមជ្ឈមណ្ឌលនៃការសិក្សា មានន័យថា គ្រូជាអ្នកណែនាំកែតម្រូវ ឯសិស្សជាអ្នកអនុវត្តផ្ទាល់ខិតខំស្រាវជ្រាវដោយខ្លួនឯង ។ ករណីនេះ នាំឲ្យបញ្ញារបស់បុគ្គលកាន់

កាន់តែរីកទូលាយឡើង ព្រោះពុទ្ធិខ្ពស់ពុំមែនកើតឡើងដោយចៃដន្យទេ តែកើតឡើងដោយការហាត់ពត់លត់ដំ ប្រើបញ្ញាប្រកបដោយក្បួនខ្នាតត្រឹមត្រូវ ។

## ៥. លក្ខណៈវិទ្យាសាស្ត្រនៃការគ្រប់គ្រង

ការគ្រប់គ្រង ជាកត្តាកំណត់ក្នុងការអប់រំ ហេតុនេះការគ្រប់គ្រងត្រូវមានលក្ខណៈវិទ្យាសាស្ត្រ ។ របនាសម្ព័ន្ធគ្រប់គ្រង ត្រូវមានលក្ខណៈប្រណីតច្បាស់លាស់ ។ ជាពិសេសនៅឧត្តមសិក្សាត្រូវមានក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាបច្ចេកទេស ។ ការគ្រប់គ្រងនេះ តម្រូវឲ្យមានការតាមដានកម្មវិធីសិក្សា ការបង្រៀន និងការរៀន ។ ការរិះគន់ស្ថាបនា ជាមធ្យោបាយមួយធ្វើឲ្យការអប់រំទទួលបានជោគជ័យ។ ការបែងចែកភារកិច្ចច្បាស់លាស់សម្រាប់ឲ្យបុគ្គលទទួលខុសត្រូវ ជាកត្តាចាំបាច់ ។ វិន័យជាគន្លឹះសម្រាប់បំពេញការងារ ការគ្រប់គ្រងត្រូវផ្អែកលើវិធានការ ៣ យ៉ាងគឺ :

- វិធានការអប់រំ (mesure éducative)
- វិធានការសេដ្ឋកិច្ច ឬ លើកសរសើរ ( mesure économique)
- វិធានការរដ្ឋបាល ឬដាក់ពិន័យ (mesure disciplinaire) ។

ក្នុងករណីមួយចំនួន យើងត្រូវសង្កត់ធ្ងន់លើវិធានការណាមួយ ក្នុងករណីមួយចំនួនទៀត យើងត្រូវគួបផ្សំវាងវិធានការទាំងបី។

## ៦- វិន័យជាគ្រឹះនៃអត្តិភាព

ពិតមែនតែពុទ្ធសាសនា បានបោះជំហានមកពីប្រទេសឥណ្ឌាក៏ដោយ ក៏សាសនានេះ បានជ្រាបចូលជ្រៅទៅក្នុងបេះដូងនៃប្រជាជនកម្ពុជា ជាពិសេសនិកាយថេរវាទ បានរួមចំណែកធ្វើឲ្យអរិយធម៌ខ្មែរ កាន់តែមានលក្ខណៈសម្បូរបែប ដោយបានផ្សារភ្ជាប់ជាមួយចិត្តគំនិតខ្មែររាប់រយសតវត្សមកហើយ ។ ប្រពៃណីទំនៀមទម្លាប់ខ្មែរ សុទ្ធសឹងទទួលឥទ្ធិពលយ៉ាងខ្លាំងពីពុទ្ធសាសនា ។ នៅក្នុងរដ្ឋធម្មនុញ្ញ ពុទ្ធសាសនា ត្រូវបានលើកតម្កើងជាសាសនារបស់រដ្ឋ ។ ក្នុងឋានៈជាសាសនារបស់រដ្ឋ និងនៅចំពោះមុខសាសនាទាំងឡាយ ដែលមានអត្តិភាពនៅក្នុងមាតុភូមិកម្ពុជា ពុទ្ធសាសនាត្រូវពង្រឹង និងពង្រីកអត្តិភាពរបស់ខ្លួន ដោយយកវិន័យធ្វើជាមូលដ្ឋានបង្អែក ។ វិន័យចែកចេញជាពីរផ្នែក: វិន័យដែលមានលក្ខណៈបង្ខិតបង្ខំ និងវិន័យដែលភ្ញាក់រឭកដោយខ្លួនឯង។

វិន័យដែលមានលក្ខណៈបង្ខិតបង្ខំ ជាវិន័យមិនរឹងប៉ឹងនៅក្នុងបុគ្គល ព្រោះបុគ្គលប្រតិបត្តិវិន័យតាមការបង្ខិតបង្ខំពីច្បាប់ ឬកម្លាំងខាងក្រៅ។ វិន័យនេះអាចរលាយបាត់បង់ទៅវិញ ដោយសារកម្លាំងទាញនៃបាតុភូតអវិជ្ជមាននៃសង្គម ឬដោយសារខ្វះការត្រួតពិនិត្យជិតដល់។ ប៉ុន្តែវិន័យនេះ អាចក្លាយជាទម្លាប់ល្អ និងក្លាយជាវិន័យដែលភ្ញាក់រឭកដោយខ្លួនឯង ដោយសារមានការត្រួតពិនិត្យ និងការអប់រំជាបន្តបន្ទាប់។

វិន័យដែលភ្ជាក់រឭកដោយខ្លួនឯង ជាវិន័យដែលកើតឡើងដោយសារការចុះបញ្ចាំងខ្លួន ក្នុងឋានៈខ្លួនជាប្រធានវិស័យកាលផង និងវត្ថុវិស័យកាលផង ។ ការតាំងសមាធិដោយសម្លឹងមើលគុណសម្បត្តិ និងគុណវិបត្តិប្រចាំថ្ងៃរបស់ខ្លួនដោយខ្លួនឯង ហើយស្វែងយល់មាគ៌ាកណ្ដាលមួយ សម្រាប់ធ្វើដំណើរទទួលទីងការពង្រឹងវិន័យមួយយ៉ាងស្វាហាប់ អាចធ្វើឲ្យបុគ្គលភ្ជាក់រឭក ដោយគ្មានការបង្ខិតបង្ខំពីកម្លាំងខាងក្រៅឡើយ ។ វិន័យទី២នេះ មិនអាចកាត់ថ្លៃបានឡើយ ។

តើវិន័យដែលភ្ជាក់រឭកដោយខ្លួនឯងនោះ កើតឡើងដោយសារអ្វី? វិន័យនោះកើតឡើងដោយសារ ស្វ័យអប់រំសមាធិ ឬការចុះបញ្ចាំងខ្លួនដោយខ្លួនឯង ។ កាលព្រះអង្គទ្រង់មានព្រះជន្មនៅឡើយ ព្រះអង្គបណ្ដុះសតិបញ្ញារបស់សាវក តាមរយៈការធ្វើបញ្ញាឲ្យផុសឡើង ។

ដូចនេះ ការបង្រៀនរបស់ព្រះពុទ្ធ មិនមែនបង្រៀនអំពីអង្គពុទ្ធិទាំងមូលឡើយ។ ព្រះអង្គបង្រៀនអំពីផ្នែកសារវន្ត ដែលចង្អុលបង្ហាញអំពីមាគ៌ាមួយ ឆ្ពោះទៅរកពិភពធាតុភូត(phenomenal world)។

ឧទាហរណ៍ព្រះអង្គបង្រៀនសាវករបស់ព្រះអង្គ នៅគ្រាដែលព្រះអង្គចាប់យកស្លឹកមួយចំនួន ដែលជ្រុះពីដើមឈើ :

-ព្រះអង្គមានពុទ្ធដីកាសួរថា : "សង្ឃទាំងឡាយ ស្លឹកឈើដែលនៅក្នុងព្រៃ និងស្លឹកឈើដែលនៅក្នុងដៃតថាគត តើស្លឹកណា

មានចំនួនច្រើនជាង ? "

-សាវកទាំងអស់ឆ្លើយព្រមគ្នាថា : " ស្លឹកឈើដែលនៅក្នុងព្រៃមានចំនួនច្រើនជាងស្លឹកឈើ ដែលនៅក្នុងព្រះហស្តព្រះអង្គ ។

-ព្រះពុទ្ធបានពន្យល់ថា "ពុទ្ធិដែលមាននៅក្នុងតថភាពប្រៀបដូចជាស្លឹកឈើ ដែលនៅក្នុងព្រៃដែរ តែអ្វីដែលតថាគតចង់បង្ហាញអ្នក គឺអាចប្រៀបធៀបទៅនឹងស្លឹក ដែលនៅក្នុងដៃតថាគត[១]។

អ្វីដែលព្រះពុទ្ធបានបង្រៀន ប្រៀបដូចជាពុទ្ធលទ្ធិ ។ ប៉ុន្តែអ្វីដែលស្ថិតនៅខាងក្រៅការបង្រៀនរបស់ព្រះអង្គ គឺជាអង្គពុទ្ធិក្នុងធម្មជាតិ ដែលមានច្រើនអនេក។

**សេចក្តីសន្និដ្ឋាន**

គួរពុទ្ធសាសនិកទាំងឡាយ ទាំងបព្វជិតទាំងគ្រហស្ថ ស្វែងយល់អំពីជីវិតលោកិយរបស់មនុស្ស មុននឹងគិតទៅដល់ជីវិតបរលោក ។ ជីវិតលោកិយ ជាជីវិតជាក់ស្តែងកំពុងស្ថិតនៅចំពោះមុខឯជីវិតបរលោក ជាជីវិតមានលក្ខណៈអចិន្តភាព មិនទាន់ឈានមកដល់ ។ បើចង់ឈានទៅដល់សុខៈក្នុងបរលោក ត្រូវកសាងសុខៈក្នុងលោកិយជាមុនសិន។ លោក **ហង់ សុទ្ធិរិទ្ធិ** អតីតសាស្ត្រាចារ្យ នៅ

---

១-Si sapavanasutta (The Discourse in The Sisa Wood ) Pali Text Society Version. SN V.p.438

វិទ្យាល័យបាត់ដំបង បានលើកយកសំដីព្រះសិរីសម្មតិវង្ស **ប៊ុណ្យ សុម្ភាជ** មកបញ្ជាក់ថា : " ព្រះពុទ្ធសាសនា ពុំបានដឹកនាំមនុស្សទៅរកទ្រឹស្តីទុទិដ្ឋិនិយមឡើយ ។ ផ្ទុយទៅវិញ ពុទ្ធលទ្ធិ ជាទ្រឹស្តីប្រកបដោយសុទិដ្ឋិនិយមគ្មានព្រំដែន ។ ព្រះពុទ្ធអង្គបានបង្រៀនថា មនុស្សជាកូនឈ្នួល ហើយជាម្ចាស់លើព្រេងវាសនារបស់ខ្លួន ដែលខ្លួនធ្វើអំពើយ៉ាងណា នឹងបានផលយ៉ាងនោះ[១] ។ លោក **ខាន់ សុធីរិទ្ធិ** គូសបញ្ជាក់ថា " បើបកស្រាយតាមគោលទស្សនវិជ្ជាជាខ្លឹមសារ ព្រះធម៌មិនបានត្រឹមត្រូវទេនោះ នឹងនាំឲ្យមានផលអាក្រក់ដូចសង្គមខ្មែរសតវត្សទី? ១៧ .១៨ និង ១៩ ជាកស្តុតាងស្រាប់ ដែលមានសេចក្តីខាចបាបហួសហេតុ ភ្លេចសេចក្តីត្រិះរិះពិចារណា លើទ្រឹស្តីកម្មផល មានជំនឿផ្តេសផ្តាស មិនខិតខំតស៊ូនឹងជីវភាពបណ្តែតជីវិត ឲ្យអណ្តែតតាមជំនោរព្រេងវាសនាដូចរឿងចៅស្រទបចេក ក្រុងសុភមិត្រ ពុទ្ធិសែន ។ល។ ជាកត្តាហេតុដ៏ធំធេង បណ្តាលឲ្យប្រជាជាតិស្រុតថាមពល ប្រទេសជាតិទន់ខ្សោយ ព្រោះសង្គមអារម្មណ៍ក្នុងសម័យនោះ បានស្រុះស្រួលគ្នាយល់ថា ព្រេងវាសនាកំហិតមកត្រឹមនេះ ។ ការទុក

---

១- ប៊ុណ្យ សុម្ភាជ ( ព្រះសិរីសម្មតិវង្ស)

សន្និសីទសម្រាប់វិញ្ញាបនបត្រឧត្តមសិក្សាអក្សរសិល្ប៍ខ្មែរផ្នែកអក្សរសិល្ប៍សាសនា ឆ្នាំ១៩៦៧-៦៨ . មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ. ភ្នំពេញ

ដាក់ព្រេងវាសនាលើចំណារព្រហ្មលិខិតបែបនេះ ហើយចេះតែនាំគ្នាខំសម្របសម្រួល តាមហេតុការណ៍ដ៏អាក្រក់ ដែលកំពុងជួបប្រទះ ដោយបដិសេធ នូវការទទួលខុសត្រូវនៃទង្វើរបស់ខ្លួន ជាការយល់ខុសទាំងស្រុង អំពីពុទ្ធលទ្ធិ"[១] ។

បើតាមសំដីខាងលើនេះ គួរពុទ្ធសាសនិកទាំងឡាយសើរើឡើងវិញ ផ្ទៀងផ្ទាត់ឡើងវិញ នូវទស្សនៈ និងសកម្មភាពរបស់ខ្លួន ដើម្បីស្វែងរកផលប្រយោជន៍ក្នុងលោកិយ សម្រាប់រួមចំណែកអភិវឌ្ឍមាតុភូមិរបស់យើង។ នៅជំនាន់ដើម កាយពលកម្មមានប្រៀបជាងបញ្ញាពលកម្ម ។ ឥឡូវនេះ បញ្ញាពលកម្មបែរជាមានប្រៀបជាងកាយពលកម្មវិញ ។ ហេតុនេះដើម្បីឲ្យពលរដ្ឋទូទៅ និងដើម្បីបព្វជិតរីកចម្រើនគ្រប់វិស័យ បុគ្គលត្រូវពង្រីកទាំងកាយពលកម្ម ទាំងបញ្ញាពលកម្ម ។ ទំនាក់ទំនងរវាងកាយពលកម្ម និងបញ្ញាពលកម្ម ដែលមានទំនោរទៅរកការរីកចម្រើន ធ្វើឲ្យបុគ្គលក្លាយជាពលរដ្ឋ ជាយុទ្ធជន ជាទីពំនាក់របស់ប្រទេសជាតិ ។ កត្តាសំខាន់បំផុត សម្រាប់ធ្វើឲ្យបញ្ញាពលកម្មរីកចម្រើននោះ គឺការសិក្សាដែលមានលក្ខណៈវិទ្យាសាស្ត្រ ដូចបានពោលខាងលើ ។ គឺការសិក្សានោះ

---

១- កម្រងអត្ថបទស្រាវជ្រាវ ផ្សាយចេញពីសមាគមអ្នកស្រាវជ្រាវឯកសារ. ទីស្នាក់ការ វត្តពោធិវាល. បាត់ដំបងក្រុង. ឆមាសទី២. ឆ្នាំទី២. លេខ៣ . ទំព័រទី២០-២១. គ្មានឆ្នាំបោះពុម្ព

ហើយ ដែលជាកត្តាកំណត់ ចំពោះការរីកចម្រើននៃបញ្ញាពលកម្ម ។

បើប្រៀបធៀបនឹងពលរដ្ឋធម្មតា បព្វជិតមានឱកាសច្រើនណាស់សម្រាប់សិក្សាស្រាវជ្រាវ ។ សាងផ្នួសកាន់តែយូរឱកាសសិក្សាកាន់តែច្រើន ។ ការសិក្សាភាសាជាតិ ភាសាបរទេស វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម និង មនុស្សសាស្ត្រ កាន់តែខ្ពស់ មិនមែនមានន័យថា ពោះបង់ចោលពុទ្ធលទ្ធិទេ តែដើម្បីឈានចូលជ្រៅក្នុងពុទ្ធលទ្ធិ ធ្វើឲ្យតួនាទីនៃពុទ្ធសាសនា កាន់តែខ្ពស់ឡើងក្នុងសង្គមជាតិ ។

លោកស្រី **សូឡង់ ស៊ីយើរ** ( Solange Thierry, Directeur d'Etudes E.P.H.E. V^e Section) ពោលថា ពុទ្ធសាសនាហីនយានមានទិដ្ឋភាពចម្បងបីយ៉ាងគឺ"ពុទ្ធសាសនាជាប្រព័ន្ធ នៃការគិត...ជាចក្ខុវិស័យស្តីពីពិភពលោក និងជាតម្រូវការកំពូលនៃការការពារ " Le bouddhisme demeure un système de pensée... une vision du monde... l'extrême besoin de protection)[១] ។ ពាក្យ "ប្រព័ន្ធនៃការគិត ចក្ខុវិស័យនៃពិភពលោក តម្រូវការកំពូលនៃការការពារ"ជាការគូសបញ្ជាក់ឲ្យឃើញនូវបេសកកម្ម ដ៏ចម្បងនៃពុទ្ធលទ្ធិក្នុងការកសាងមាតុភូមិ និងពិភពលោក ប្រកបដោយសន្តិភាព ។

---

១- Rechetches Asiatiques, ***Bouddhismes et sociétés asiatiques***, clergés, sociétés et pouvoirs (dirigé par Alain Forest), Editions L'Harmattan-Sophia University (Tokyo), 1990, p. 163-165.

# ព្រះនាងសរស្វតីក្នុងវប្បធម៌ខ្មែរ

ដោយ : **ពៅ សាវរស**

ប្រែសម្រួលក្រៅផ្លូវការដោយ ហម ធាយលី

យើងបានដឹងយ៉ាងប្រាកដ តាំងពីយូរយាណាស់មកហើយថា មានព្រះនេះ និងលក្ខណៈសម្បត្តិរបស់ព្រះនាងសរស្វតី ក្នុងអរិយធម៌ខ្មែរចាស់[១] ដោយសារការសិក្សាស្រាវជ្រាវ និងឯកសារជាច្រើន ។ ប៉ុន្តែសម័យបច្ចុប្បន្ននេះវិញ បើគេចោទសួរខ្មែរម្នាក់ដែលបានសិក្សាជ្រៅជ្រះក្តី ឬ សាមញ្ញជនក្តី ថាតើមានស្គាល់ "ព្រះនាងសរស្វតី" ជាព្រះរបស់ខ្មែរដែរឬទេ? គេទាំងនោះប្រាកដជាឆ្លើយតបវិញថា គេពុំដែលស្គាល់ សូម្បីតែឈ្មោះក៏ពុំដែលឮផងអំពីព្រះនាងនេះ ។ គេពុំដែលឃើញវត្តមាននៃព្រះនោះ នៅទីណាមួយឡើយ ។ ព្រោះគេមានស្គាល់ព្រះខ្លះដូចជា (ព្រះសិវៈ ព្រះឥស្សូរ ព្រះនារាយណ៍,ព្រះរាម ឬព្រះដែលមានបដិមាករតើរ (ព្រះក្នុងព្រហ្មញ្ញសាសនា និងព្រះក្នុងពុទ្ធសាសនាផង) លើសអំពីនេះទៅទៀត ព្រះដែលគេស្គាល់ និងគោរពបូជាច្រើនដូចជា ព្រះព្រហ្ម និងព្រះឥន្ទ្រ ។ មតិនេះ គឺស្ថិតនៅលើការពិតមួយ ដែលខ្ញុំនឹងលើកយកមកអត្ថាធិប្បាយអំពីព្រះមួយព្រះអង្គ ដែលបានបាត់បង់អំពីអារម្មណ៍ខ្មែរអស់ទៅហើយ និងលែងស្គាល់ព្រះនេះនៅក្នុងសិល្បៈ

---

1- Saveros Pou Sarasvatt dans la culture Khmère Bulletin d'Etude Indiennes BEL,4,1986,321.339,

ក្នុងអក្សរសាស្ត្រ ឬក្នុងវប្បធម៌ខ្មែរសម័យទំនើបនេះ ។

ជាច្រើនឆ្នាំមកហើយ តាមរបាយការណ៍អំពីលទ្ធផលនៃការស្រាវជ្រាវ ទៅលើការចាប់ផ្ដើមឡើង នៃត្រៃគ៌នៅប្រទេសកម្ពុជា ខ្ញុំបានគូសបង្ហាញបែបបទខ្លះ ដែលព្រះនេះ នៅមានជីវិតនៅឡើយ ថ្វីដ្បិតតែមានការចុះអន់ថយជុនជាប នៃព្រហ្មញ្ញសាសនាសម័យចាស់ ដែលគេបានជឿថា គ្មានព្រះនាងសរស្វតីក្នុងវប្បធម៌ខ្មែរជាការពិត ដែលគេអាចសន្និដ្ឋានថា មានស្លាកស្នាមពិតប្រាកដនៃព្រះនេះ ក្នុងលទ្ធិព្រហ្មញ្ញសាសនា ជាទូទៅក្នុងអរិយធម៌នេះ? ។ ក្នុងការសិក្សាស្រាវជ្រាវរកស្លាកស្នាមទាំងនេះ គឺជាការចាំបាច់ណាស់ ត្រូវតែបង្ហាញផងដែរ នូវការប្រមែប្រមូលបានមកនៃព្រះនេះ (សរស្វតី) ដែលនៅកត់ភយក្នុងទឹកដីសព្វថ្ងៃ ដែលផ្ដាច់ចេញគឺកម្ពុជា និងសៀម ។ បើនិយាយម្យ៉ាងទៀត និរុត្តិវិទ្យាខ្មែរលាតសន្ធឹងធំទូលាយគ្របដណ្ដប់ទៅលើវប្បធម៌ដទៃទៀត ជាពិសេសគឺវប្បធម៌សៀម ដូចយើងខ្ញុំ និងបង្ហាញជាតារាងខាងក្រោមនេះ ៖

វប្បធម៌សម័យខ្មែរចាស់

វប្បធម៌ខ្មែរសម័យកណ្ដាល ⇄ វប្បធម៌សៀម ។

ការប្រទាញប្រទង់គ្នា រមែងកើតមានឡើងនៅចន្លោះវប្បធម៌ទាំងពីរនេះ ហើយជាពិសេសគេត្រូវតែយកមកសិក្សា ។ នៅពេលនោះហើយ ដែលគេប្រទះបញ្ហាយ៉ាងចម្បង ក្នុងរបៀបរបបនេះ ។

បើសិនណាហើយនៅមាននិរុត្តិវិទ្យាខ្មែរ ផែមាំមួនទៅឡើយនោះ ការសិក្សាអំពីសៀមចាស់ ដែលធ្វើឡើងតាមក្បួនវិទ្យាសាស្ត្រទំនើប នោះក៏គ្មានដែរ ។ ចាប់អំពីព្រឹត្តិការណ៍របស់ខ្មែរ ដែលធ្វើនៅកម្ពុជា គេប្រទះជាអលជ្ជី នូវព្រឹត្តិការណ៍ដូចគ្នានេះដែរ នៅប្រទេសសៀម ដែលគេមានជំនឿថា គេស្គាល់តែតាមការពិត គេពុំបានសិក្សាឲ្យល្អិតតាមលក្ខណៈវិទៀនត្រឹមត្រូវទេ ។ លើសអំពីការប៉ូកគ្នាទាំងពីរវាងការសិក្សាអំពីខ្មែរ និងអំពីសៀមនោះ គេត្រូវតែទាញអារម្មណ៍ផងដែរ អំពីការខុសប្លែកគ្នា រវាងអ្នកសិក្សាខាងវប្បធម៌ខ្មែរ និងអ្នកសិក្សាខាងវប្បធម៌សៀម អ្វីដែលប្រទាញឲ្យមានការលំបាកលំបិន បណ្តាលឲ្យមានភាពចម្រូងចម្រាស នៃឧប្បត្តិហេតុប្រទាញប្រទង់គ្នា ដែលចោទជាបញ្ហាឡើងនេះ ។ ក៏ប៉ុន្តែ គ្មានអ្វីដែលធ្វើឲ្យស៊ុះដល់ការកិច្ចទាំងពីរនេះទេ ហើយពុំមែនងាយស្រួលក្នុងការស្វែងរកក្នុងវិស័យខាងវប្បធម៌ខ្មែរ ដោយបើកទ្វារចំហទៅមើលវប្បធម៌សៀមផងដែរ ។ ដោយសារគោលការណ៍នេះហើយ ដែលខ្ញុំបានពិនិត្យឃើញស្លាកស្នាម ដែលបានពិពណ៌នាខាងលើរួចមកគឺជាស្លាកស្នាម ដែលគេជឿថា គ្មានទំនាក់ទំនងនឹងគ្នា ជាមួយព្រឹត្តិការណ៍យ៉ាងទំនើប នៅមានជីវិតរើកនៅឡើយ ។ ការដែលប្រាកដជាក់លាក់ជាងនេះទៅទៀត គឺដោយសារភាសាសាស្ត្រនេះឯងហើយដែលបានផល ឲ្យខ្ញុំបានរកឃើញស្លាកស្នាមរបស់ព្រះនាងសរស្វតីក្នុងវប្បធម៌ខ្មែរទំនើប ។

## I- កម្ពុជាសម័យដើម

ព្រះនាងសរស្វតីជាព្រះមួយអង្គដែរ ដែលខ្មែរបានស្គាល់ពិតប្រាកដ តាំងពីសម័យដើមនៃប្រវត្តិសាស្ត្រមកម៉្លេះ ។ ពីព្រោះយើងមានសាក្សីច្រើន ដែលបង្ហាញអំពីព្រះនាងនេះក្នុងសិល្បៈ និងក្នុងសិលាចារឹក ។

### ១- សិល្បៈ

សេចក្តីរៀកខ្ចះ និងបង្ហាញជូនបន្ទាត់ទៅនេះ អំពីស្នាដៃរបស់លោកសឺដេស,លោកគ្គាចារ្យ និងទីបញ្ចប់ ដោយសារព័ត៌មានយ៉ាងក្រាស់ក្រែល ដែលបានទទួលដោយអនុគ្រោះ អំពីស្នាដៃនៃលោក ហ្គោស្លីយេ ប៊ែកណាហ្វីលីត (៤) ។

គេសម្គាល់ឃើញថា មានរូបសំណាកព្រះនេះ ដែលជាសក្ខីភាពអាចប៉ះពាល់បាននោះ តិចតួចស្តួចស្តើងណាស់ គឺមានបដិមាករពីរប៉ុណ្ណោះ ដែលសិតអំពីលង្ហិន បានដាក់ឈ្មោះឡើងដោយសឺដេសនៅឆ្នាំ ១៩៣២ (៥) ហើយបានបញ្ជាក់ឡើងជាថ្មីទៀតដោយលោកកគ្គាចារ្យ នៅឆ្នាំ ១៩៦១ (៦) ឬលោកហ្គោស្លីយេ(៧)វិញ គាត់បញ្ជាក់បន្ថែមថា គឺជាបដិមាករពីរសិតអំពីជាតិលង្ហិនដែរ តែនៅពេលក្រោយមកបន្តិចៗ បើយ៉ាងចំណាស់គឺស.វ.ទី១៣ មកប្រហាក់ប្រហែលនៅ ស.វ.ទី១៤ផង ហើយប្រាកដជារចនាបថក្នុងរាជ្យ នៃព្រះបាទជ័យវរ្ម័នទី ៧ ក៏ប៉ុន្តែជាពិសេស គឺបដិមាករសេរីទ្វិនេះ ជាក្រុមគ្រួសារតែមួយ នៃរូបសេរីទ្វិ ដែលគេរកឃើញនៅភាគព្យសាន

ប្រទេសសៀម ហើយសាងនៅសម័យក្រោយបន្តិច នៃរចនាបថ នៃក្រុងអយុធ្យា ។ រូបបដិមាករទាំងពីរនេះ មានប្រភពដើមចេញអំពីទំនៀមខ្មែរ តែរូបនេះប្រហាក់ប្រហែល ទៅនឹងរចនាបថសៀមទៅវិញ ដោយសារទំនៀមនេះ ប្រសូតឡើងក្រោយក្រុងអយុធ្យា ។ ផ្សេងពីនេះទៅទៀត ដែលធ្វើឲ្យរឭកឃើញជាចាំបាច់ ទៅនឹងកងវេ នៃព្រះក្នុងលទ្ធិព្រហ្មញ្ញសាសនា ។

ទោះបីឃើញឃើញមានបដិមាករនៃព្រះនាងនេះ តិចតួចស្តួចស្តើងក្តី តែវាមានអត្ថន័យទូលំទូលាយក្នុងការសិក្សា របស់យើង ។ ពីព្រោះយើងមានសក្ខីភាពសន្ទឹកទៀត ដោយប្រយោលបានផ្តល់ឲ្យដល់យើង តាមរយៈសិលាចារឹកមួយចំនួនទៀត ។

## ២.ចារឹកសាស្ត្រ

ក្នុងសិលាចារឹក បានបង្ហាញព្រះនាងសរស្វតីឲ្យយើងដឹងឡើង តាំងតែពីស.វ. ទី ៧ (រជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី១ ) និងប្រាកដជាឃើញពីមុនស.វ.នេះទៅទៀត សិលាចារឹកជាភាសាខ្មែរ និងជាភាសាសំស្ក្រឹត យើងនឹងសិក្សាអធិប្បាយដូចតទៅនេះ ទាំងអស់គ្នា ក្នុងសិលាចារឹកសាស្ត្រនេះ រៀបរាប់ជូនកាលអំពីប្រវត្តិនៃអាទិទេពផង ជូនកាលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផង ។

### ២.១ សារតនៃអាទិទេពនៅប្រទេសឥណ្ឌា

គេបានដឹងថា ព្រះនាងនេះ ជាមូលដ្ឋាន"ប្រសស្តិ" (ពាក្យសំស្ក្រឹត ) ឬអត្ថបទទាំងឡាយ ដែលលើកតម្កើងព្រះនៃប្រទេស

ខ្មែរសម័យបុរាណ ។

ព្រះនេះទ្រង់មានព្រះនាមច្រើន ៖

ក- សរស្វតី

ខ- ភារតី

គ- ភគីស្វរី

ឃ- វាណី

ង- ភគវតី

នៅក្នុងសិលាចារឹកខ្មែរ ព្រះនេះ ជួនកាលមានមានថា "សរស្វតី" ជួនកាលទៀតឈ្មោះថា "ភារតី" ។

ព្រះនាងសរស្វតីជាគូកន នឹងព្រះព្រហ្ម (៩) ទាំងនេះ បាន បញ្ជាក់ឲ្យឃើញច្បាស់លាស់ តាំងអំពីសតវត្សទី ៩ និងទី ១០ម៉្លេះ ក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័ន មកដល់រាជ្យព្រះបាទជ័យវរ្ម័នទី ៥ តាម សក្ខីភាពនៃសិលាចារឹក និងប្រាសាទនានា (១០) ។ ចាប់តាំងពី ស.វ. ទី ១១ មក ព្រះនេះ ក្លាយទៅជាព្រះមួយអង្គពេញលក្ខណៈ ដែលគេឃើញក្នុងបដិមាករ មានរូបតំរ ជាពិសេសនៃបទិត្យ នឹង ព្រះឥស្សូរ (ព្រះឥស្វរៈ) ។ គឺដោយសារតែបុគ្គលិកលក្ខណៈនេះ ហើយ ទើបឈ្មោះព្រះនេះ មានរំពឹកឡើង និងគោរពបូជាក្នុង សិលាចារឹក ឬក្នុងគម្ពីរវេទវិញ ។ គេពុំឃើញតម្រាយព្រះនាង សរស្វតីទេ គឺព្រះនាងជាព្រះគង្គា និងជាព្រះទន្លេនានា (១១) ។ តែផ្ទុយទៅវិញ នាងសរស្វតីគេឃើញផុសឡើងពាសពេញ ជាព្រះ

មួយព្រះអង្គ ដែលមានប្រាជ្ញាំហារយ៉ាងអស្ចារ្យ (១២)។ ព្រះនាងទំនងជាព្រះមួយអង្គធំខ្ពស់បំផុតខាង "សិល្បៈ" និងការសិក្សាទាំងអស់។ ព្រះនេះ គឺសណ្ឋិតនៅទីងមាត់នៃក្សត្រិយ៍ និងអ្នកប្រាជ្ញ ខាងព្រហ្មញ្ញសាសនាទាំងអស់ ដែលគេឃើញមានសាក្សីញឹកញាប់ក្នុងសិលាចារឹក ហើយយើងខ្ញុំសូមលើកយកខ្លះ មកធ្វើជាឧទាហរណ៍ជាក់ស្តែងមកបង្ហាញដូចតទៅនេះ ៖

-សតវត្សទី ៦, K.81(Bhawavarm) Inscriptions Sanscrites,page 15, B,2៖---មុខេ លសតិ ភារតី បានន័យថា :"នៅក្នុងព្រះឱសព្រះមហាក្សត្រិយ៍ " មានព្រះនាងភារតី (សរស្វតី) មានពន្លឺចិញ្ចាចព្រោងព្រាយ ។

-សតវត្សី ៩, K 713 (យសោវរ្ម័ន) IC ,t , I , Page 21 XXIII = ---សរស្វតី ... មុខភាខេ ស្ថិតាភវេត បានសេចក្តីថា: "ព្រះនាងសរស្វតី ស្ថិតនៅជាប្រក្រតីក្នុងក្រអូមមាត់នៃក្សត្រិយ៍"។

-សតវត្សទី៩, K 813 ( ព្រាហ្មណ៍សិវសោម ជាព្រះគ្រូនៃព្រះបាទឥន្ទ្រវរ្ម័ន) IC , t , I page 40 XXXV --- យនមុខេ សរស្វតី សរេភស: បានសេចក្តីថា:"នៅក្នុងមាត់នៃព្រាហ្មណ៍ សិវសោម មានព្រះនាងសរស្វតីស្ថិតនៅជានិច្ច" ។

-សតវត្សទី១១ មានជាឧទាហរណ៍ច្រើន ដែលមានK 661 IC,t ,I page

199,XIII --- ឫតសរសេយ អាគម សុធា សុទ្ធ ហង្សគតិន ចរៃន យសយាសេន មុក្ខាម កោជ សរស្វត្យ អនុគុប្ត ចុតី បានសេចក្តីថា--- " នៅក្នុង មហាសមុទ្រ នៃបេះដូងបរិសុទ្ធ ដោយវិទ្យាទិព្វព្រះ នាងសរស្វតី ដែលមានដំណើរដូចសត្វហង្ស និងស្ថិត នៅក្នុងបទុម អំពីព្រះឱស្ឋ នៃក្សត្រីយ៍ ( ព្រះបាទ សូរ្យវរ្ម័នទី១, សឺដេស ហ្សិក ។

-សតវត្សទី១២ K 287 ( ជ័យវម៌្មទី ៧ ) IC , t ,IV page 242 1.22, LXXIII, -- សៅសេយតេ តម ឥតិ សៃរម អវេក្សយ ភាណី ភាល កូម ឥបសុរ: ឥវ: យំ ប្រថម សិសោរ បានន័យថា: --- "គឺនៅក្នុងទស្សនៈនេះ ( =ព្រះនាង "ភាណី"បានឃើញនូវកោគទ្រព្យ និងធរណី(ស្រីលក្ស្មី) បម្រើព្រះបាទជ័យវម៌្ម ដែលព្រះនាង"ភាណី"មានបំណង ចង់ធ្វើជាព្រះស្នំរបស់ព្រះអង្គ និងបម្រើទ្រង់មិនបង្អង់ យូរយារទេ" (សឺដេសហ្សិក) ។

អញ្ចឹងហើយ ទើបគេឃើញព្រះនាងស្ថិតនៅរួមជាមួយ នឹងព្រះដទៃទៀត ដែលគេសម្គាល់ទុកដូចជាភរិយា នៃព្រះ ឬ ជា ព្រះស្នំ នៃស្តេចអង្គណាមួយ ជាពិសេស "ស្រ្តី" "លក្ស្មី" ឬ សម្បត្តិ ។ K,92 IC,t , V Page 230 1, 19, បានឲ្យដឹងថា នៅសតវត្ស ទី ៩ មានមន្ត្រីម្នាក់ មានទាមថា "បទុម" ដែលព្រះក្សត្រីយ៍

(ព្រះបាទជ័យវម៌្មទី២) បានតែងតាំងជាទីប្រឹក្សា ។ "បទុម" ត្រូវជាបង ថ្លៃព្រះមហាក្សត្រិយ៍ទៀតផង ។ ព្រោះគាត់ត្រូវជាបងរបស់ព្រះអគ្គ មហេសី ព្រះនាងសរស្វតី ដែលសរសេរជាភាសាសំស្ក្រឹតដូចត ទៅនេះ រាជទាសេរស្វត្យាស សក្រាតា--- "មន្ត្រីនោះ ត្រូវជាបង ប្រុសនៃព្រះនាងសរស្វតី ព្រះនាងជាអគ្គមហេសី នៃព្រះមហាក្ស-ត្រិយ៍ " ។

បើសិនណាគេស្គាល់ថា "សរស្វតី" ជាអគ្គមហេសី នៃ ព្រះមហាក្សត្រិយ៍ប្រាកដមែននោះ ឬក៏ជាឈ្មោះក្រៅទេនោះៗ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ពីព្រោះថា ឧទាហរណ៍ ដែលយើង បង្ហាញឲ្យឃើញស្នាមពិតប្រាកដ អំពីព្រះនាងនេះ (សរស្វតី) ក្នុង ជីវិតនៃខ្មែរ តាំងពីលើមកដល់ក្រោមតាមលំដាប់ថ្នាក់ ។

(នៅមានត)

ស្រមោចមិនដែលស្លាប់ក្នុងពាងអំបិល
ច្រើនតែឃើញស្លាប់ក្នុងពាងស្ករ ។

សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា
វជិរប្បញ្ញោ ( **ល្វី ឯម** )

# សិលាចារឹកថ្មីមួយ នៅប្រាសាទល្បើកស្រុត_ល្បើកស្រង៉ែ

## A NEW INSCRIPTION, Ka 212, FROM LOBOEUK SROT-LOBOEUK SRÂNGAE TEMPLE

ដោយ **ទង់ សុធារ៉ា** សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

*យើងមិនបានឃើញ ផ្ទាំងសិលាចារឹកនេះ ដោយផ្ទាល់ទេ តែយើងបានទទួល នូវឯកសាររូបភាពថតិ[១]របស់វា ពីនិស្សិតម្នាក់ ឈ្មោះ* **ជុស ផល្លីន** *ដែលជាអតីតនិស្សិតប្រវត្តិវិទ្យាជំនាន់ទី១៩ ។ ចំណែកប្រវត្តិរឿងរ៉ាវ ដែលទាក់ទងនឹងការរកឃើញនោះ ក៏គាត់បានផ្ដល់មកឲ្យយើង នូវឯកសាររបាយការណ៍ យ៉ាងពិស្ដារមួយ ចុះថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០០១ របស់លោក* **ជួប ឃាន** *សមាជិកធ្វើយ ធ្វងប្រចាំខេត្តក្រចេះ នៃទស្សនាវដ្ដីកម្ពុជសុរិយា របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។*

*តាមរបាយការណ៍ ស្ដីអំពីការរកឃើញសិលាចារឹកនេះ លោក* **ជួប ឃាន** *បានរៀបរាប់ឲ្យយើងដឹងថា " សិលាចារឹកដ៏ល្អមួយផ្ទាំងនេះ ដែលត្រូវបានប្រជាជនម្នាក់ នៅភូមិដារ ឃុំដារ ស្រុកក្រចេះ ខេត្តក្រចេះ រើសបានពីកន្លែងប្រាសាទល្បើក-*

១_ដោយសារអ្នកថ្មាម មិនចេះបច្ចេកទេសផ្ដាមសិលាចារឹក ធ្វើឱ្យរូបភាពនោះមិនសូវច្បាស់ ពិបាកអានបន្តិច។

ស្រុត-ល្បើកស្រង៉ែ នៅពេលគាត់ចូលក្នុងព្រៃ ដើម្បីប្រកបការងារ មានកាប់សសរ , ចាំងសសរ , រកឃ្មុំ...... ។ល។ កន្លែងល្បើកស្រុត-ល្បើកស្រង៉ែនេះ នៅឆ្ងាយពីកន្លែងប្រាសាទខ្វាន់-ពីរ(ចុងអូរព្រៃកកាំពី) ។ (នៅក្នុងព្រៃជ្រៅ មិនដឹងចម្ងាយប៉ុន្មានពីទីរួមខេត្ត) ។

សិលាចារឹកនេះ មានសរសេរអក្សរសងខាង ថ្មចារឹកល្អស្អាតដូចថ្មើមថ្មី ទម្ងន់ ៦០ គីឡូក្រាម បន្ទា (មុខកាត់ទទឹង) ០,៣៨ម៉ែត្រ , កម្រាស់ទោល០,០៦ ម៉ែត្រ , និងកម្ពស់០,៦ ម៉ែត្រ ផ្នែខាងលើរីកធំជាងផ្នែកខាងក្រោម ដែលមានរាងគន្ទាក់ បែបជាពន្លូញទាល សម្រាប់ដោតលើផែនជើងទម្រ ។

ផ្ទាំងចារឹកនេះ ប្រជាជននៅភូមិដារ, ឃុំដារ, ស្រុក ក្រចេះ រូបនោះ គាត់បានរើសដាក់រទេះ បរយកមកទុកនៅផ្ទះរបស់គាត់ ក្រោយមក គាត់ចេះតែឈឺគ្រុនខ្លាំងពេក គាត់ក៏យកវាទៅចោលនៅគុម្ពចេក មិនដឹងជាមូលហេតុយ៉ាងណាទេ បានជាក្រោយមកទៀត សិលាចារឹកដ៏ល្អនេះ មកស្ថិតនៅក្នុងផ្ទះរបស់ប្រជាជនមួយគ្រួសារ នៅម៉ុំវត្ត ក្រចេះ ។

នេះពិតជា ផ្ទាំងសិលាចារឹកដ៏ល្អមែន ព្រោះថា វានៅគង់វង្សល្អទាំងអស់ ដែលអាចឲ្យយើងមើលឃើញ តួអក្សរនីមួយៗយ៉ាងច្បាស់ និងគ្មានការបែកបាក់ បាត់អក្សរមួយតួឡើយ។ លើសនេះទៀត វាបង្ហាញឲ្យដឹងថា ស្ថាបនិក ពិតជាបានសាងវាឡើង

ដោយផ្ចិតផ្ចង់ ហើយនៅខាងលើអត្ថបទផ្ទាំងខាងមុខ មានរចនាក្បាច់ចម្លាក់ រូបត្របកផ្កាឈូកបើកស្រទាប់ទ្រអម ដោយមានចម្លាក់រូបក្ងីក្ងើង នៅកៀនញែងសងខាងទៀតផង ។ ផ្នែកវិចិត្រក្បាច់រចនា និងអត្ថបទត្រូវខណ្ឌចែកដាច់ពីគ្នា ដោយខ្សែបន្ទាត់មួយដែលជាហេតុឲ្យគេងាយយល់ថា អក្សរត្រូវបានគេសរសេរ ចាប់ពីត្រឹមណា ។ តែដោយសារ គេមិនបានចារឹកអត្ថបទឲ្យពេញពាសលើផ្ទៃមុខកាត់ទាំងសងខាង ធ្វើឲ្យឃើញចន្លោះលំហទំនេរនៅផ្នែកខាងក្រោមអត្ថបទ ដែលជាហេតុនាំឲ្យមានលក្ខណៈលេងសើចកំប្លែងបន្តិច ដោយសារគេឆ្លៀតយកចន្លោះទំនេរនេះ មកសាកសរសេរអក្សរលេងបញ្ច្រាស បណ្ដោយ និងបញ្ឈរ គ្មានរបៀបរៀបរយ ។

ជាអត្ថបទប្រើអក្សរខ្មែរ នាដើមសតវត្សរ៍ទី ៩ នៃ គ្រិស្ត-សករាជ ដែលជាសម័យអន្តរកាលមួយ(Transition period)នៃគម្រូអក្សរខ្មែរ តែគេនៅប្រើទម្រង់អក្សរ ស្រដៀងគ្នានឹងសម័យមុនអង្គរនៅឡើយ ។ បើយើងប្រៀបធៀបក៏ ទៅនឹងសិលាចារឹកវត្តសសរមួយរយ K. 124 កាលបរិច្ឆេទឆ្នាំ ៨០៣ គ.ស. [២] ឃើញ

---

[2] ស.ម., វង់ សុធារ៉ា (២០០៣), *សិលាចារឹកនៃប្រទេសកម្ពុជា សម័យមុនអង្គរ ១*, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ-ពុទ្ធិកមណ្ឌលខ្មែរ, រោងពុម្ពពុទ្ធសាសនបណ្ឌិត្យ, ទំព័រ ១៥៧-៦៦។

ថា គម្រូអក្សរនៃចារឹកទាំងពីរនេះ មានលក្ខណៈស្រដៀងគ្នាណាស់ ទាំងទម្រង់សក់ និងទាំងមូលដ្ឋានតួរបស់វា ។ យើងកត់សម្គាល់ឃើញស្រៈ «ៃ» មានរាងដូចគម្រូអក្សរ ចាប់ពីពាក់កណ្តាលទី២នៃសតវត្សរ៍ទី៩ ។ ចំណែកកស្តុតាងមួយទៀត ដែលបញ្ជាក់ថាចារឹកនេះ ត្រូវបានគេសាងឡើងនៅសតវត្សរ៍ទី៩ ពោលគឺដើមសម័យអង្គរ នៅត្រង់ពាក្យទន្ទរនាម សម្រាប់ហៅជនស្រទាប់ក្រោមនៃសង្គម ។ ជាពិសេស ពួកខ្ញុំបម្រើទាំងឡាយ គេប្រើ «ឃោ» «សិ» និង«គ្វាល»សម្រាប់សម្គាល់ គោរម្យងារអ្នកបម្រើប្រុស ។ និង«តៃ»សម្រាប់សម្គាល់គោរម្យងារអ្នកបម្រើស្រី ។ ពាក្យទន្ទរនាមបែបនេះ គេឃើញមានប្រើហៅស្រទាប់អ្នកបម្រើ តែនៅអំឡុងពេលសម័យអង្គរតែប៉ុណ្ណោះ ។ ចំណែកសញ្ញា «វិរាម ( ៑ ) »វិញ មានរាងដូចសញ្ញា" ត្រីស័ព្ទ ( ៊ )» ដែលវាមានលក្ខណៈប្រហាក់ប្រហែលនឹងគម្រូអក្សរ នៅសតវត្សរ៍ទី១០ ។

ក្រៅពីនេះ តាមរយៈពាក្យស័ព្ទនរនាម ដែលគេបានប្រើពិតជាបង្ហាញនូវកស្តុតាង មិនអាចប្រកែកបានថា វាមិនមែនជាសិលាចារឹកសម័យមុនអង្គរឡើយ ។ ដូចជា «តៃក្សេបិអំបេ្យលិ» (ប.៨, ១) បើនៅសម័យមុនអង្គរវិញ គួរតែជា «កុកេបិអំបេលិ» បែបនេះ ។ ពាក្យ «ក្សេបិអំបេ្យលិ» មានន័យថា «កើបអំបិល»

(កេប > ក្យេប > កើប + អំបេល > អំប្យល_អំប្យេល >អំបិល ) ។ [៣]

អក្សរអាចអានបានសរុបផ្ទាំងខាងមុខ «ក» មាន១៩បន្ទាត់ ជាភាសាសំស្ក្រឹត២បន្ទាត់ខាងដើម បន្ទាប់មកជាភាសាខ្មែរសុទ្ធ ដោយរួមទាំងផ្ទាំងនៅខាងខ្នង«ខ» មានចំនួន ១៣ បន្ទាត់ផងដែរ ។ តែនៅបន្ទាត់ទី១៣នៃផ្ទាំង«ខ» មានអក្សរ៤តួដែលយើងមើលមិនច្បាស់ ព្រោះតែផ្ទាំមមិនបានគុណភាពល្អ ។ ជាសរុប អត្ថបទនេះ និយាយអំពីបញ្ជីឈ្មោះអ្នកបម្រើ (ដែលយើងសរុបទាំងប្រុស ស្រី ក្មេង ចាស់ទៅ ឃើញមានចំនួន១០០នាក់ )មានប្រុស៣១នាក់ (យោ៣០ + សិ១), ស្រី៤៥នាក់ ( តៃ៤៥ ) ព្រមទាំងកូនរបស់គេវៃយនៅបៅ៩នាក់ និងវៃយបេះតេ់៥នាក់, លបម្នាក់ [៤] ដីស្រែ, និងដំណាំ ,ដែលជាតង្វាយរបស់អភិជនពីររូប គឺស្រីសោមសម្មា (Somaśarmmā) និងលោកគ្រូទេពនាម ស្រី ធរៈ ជាតង្វាយចំពោះព្រះឥស្វរនាម ស្រីសកស្សុរេស្វរៈ (Śakaśureśvara) ។

មានឈ្មោះមួយ ដែលធ្វើឲ្យយើងចាប់អារម្មណ៍ គឺ យោ

[3] Cf., Cœdès, George, (1942), *Inscriptions du Cambodge*, Vol. II, EFEO, Paris, p. 3.

[4] មិនទាន់មានអ្នកណាយល់ថា «លប» សម្គាល់មនុស្សប្រុសមានលក្ខណៈបែបណានោះឡើយទេ។

"ក្មេចិន" (ប.១៧, ក ) គឺបុរសឈ្មោះ "ក្មេចិន"ដោយសារពាក្យ "ក្មេ" មានន័យថា ក្មេហើយ "ចិន"គឺជាជាតិពន្ធនាម "ចិន"ៗ ប្រហែលនេះជាកស្តុតាង កាន់តែចាស់ជាងគេមួយទៀត ស្តីពីអត្ថិភាពនៃពាក្យ "ចិន" នៅដើមសម័យអង្គរ ដែលជាការបញ្ជាក់ថា ខ្មែរពិតជាបានស្គាល់ និងហៅឈ្មោះជនជាតិ "ចិន" បែបនេះមែនៗ សមតាម ឯកសារកំណត់ហេតុទូត ឬការធ្វើដំណើរ និងកាលប្បវត្តិមួយចំនួន របស់ចិន ស្តីពីប្រទេសកម្ពុជា តាំងពីសតវត្សរ៍ទី ៣ នៃ គ.ស. រហូតមក ៗ

**អត្ថបទដើមជាអក្សរសម័យថ្មី**

*ផ្ទាំង"ក" (ខាងមុខ)*

១- ស្រីគកគុរវេគ្គរសជ្ជេ ស្រីសោមគម្មា ស្វាមិទេវ្យា

២- ស្រីធរ ........(លំហ)..........

៣- ◯ឃោគម្ពុរិទ្យ១ឃោលង្កះ១តៃរង្គទេវិ១ត្វាលិ

៤- នេះអ្នកវ្នោក៏[៥] ............(លំហ).................

---

[៥] យើងយល់ថា ប្រយោគដ៏ខ្លីនេះ ស្ទេរមានបំណងជួសត្រង់កន្លែងដែលគាត់ភ្លេចនៅដើមបន្ទាត់ទី៣ បន្ទាប់ពីសញ្ញាគោមូត្រ ដែលមានរូបរាងដូចលេខ៦ និងគំនូសអព្ភន្តរៈបិទ (")។ ចំណែកនរនាមនៅចុងបន្ទាត់ទី៣ និងដើមបន្ទាត់ទី៥ ក៏ឃើញថា គួរតែជាឈ្មោះមនុស្សតែម្នាក់គឺ "ត្វាលលង្កះ"។

៥- លង្កះ១សិរតិ១ឃោវីរបន្ទិត៌១រតិច្ចេ១ឃោ

៦- ជ្ជំ១ឃោអងះ១តៃប្រយង្គ១តៃបៅ១ឃោ

៧- វ្យតិករ១តៃច្ចេ១ត្វាលិសំគោម៌១តៃលបិ

៨- រតិ១ឃោមន្តក្កិ១ឃោកញ្ញា[6] ១ឃោកន្ស្យេ

៩- និ១តៃវ្យងិ១ត្វាលិ១លបិ១ឃោរុលិសុខ១តៃ

១០- ក្ញុំ១សិបៅ១ឃោសេហ្វ១តៃអ១តៃត្មាឃិ១

១១- ក្វនិតៃបៅ១តៃកំបតិ១តៃសំតោះវ្រះ១

១២- តៃក្វនិកញ្ញា[7] ១បៅ១ឃោវ្រៅ១តៃកំបងិ១

១៣- បៅ២តៃកំបតិ១តៃវ្រហោឃិ១ឃោប្រហ្វា

១៤- តិ១តៃមុលិះ១សិរតិ២បៅ១តៃគិលាបតិ[8] ១

១៥- ត្វាលិបុរនិ១ឃោប្រិយវិទ្យាតៃកំបុសិ

១៦- សិរតិ១ឃោបុមេ១ឃោក្ញុំទេ១បៅ១ត្វាលិ

---

[6] អក្សរជើង“ជ”(្ជ) ដូចគ្នានឹងស្រៈ“អូ”(ូ) តែបើយើងអានថា “កញ្ជា” គឺជាពាក្យដែលមិនអាចមានបែបនេះ។

[7] ករណីដូចគ្នានឹងពាក្យខាងលើដែរ

[8] អក្សរមិនច្បាស់ វាអាចឱ្យអានបានថា “គណបតី” ។

១៧- ច្កេអ៊្ជ៍ ១គ្វាល៍ច្កេ១ឃោខ្ចិត១ឃោច្កេចិន១

១៨- ឃោច្កេរន្ទេ្យា១តៃសោមលា១ក្ញនិសិកញ្ជូនិ១

១៩- ក្ញន្ទែក ន្ទៃ១ តៃករិស ប៉ៅ១

*ផ្ទាំង«ខ» (ខាងខ្នង)*

១- អ្នក្កវ្រះ ឃោកំភាក៑១តៃក្នាង៑១ឃោបរោយ៑១តៃក្យ

២- ចិ១ឃោសុនហ១ឃោទ្រោង៑១ឃោវត្យរាជ១ឃោ

៣- នេង៑១ឃោកំវៃ១គ្វាល៑តង្កេរ៑១គ្វាល៑ប្រមោទិ

៤- យ្យ១ឃោមានស្នេហា១ឃោកញ្ចៃ១ឃោអ្គត១

៥- ឃោក្មុំចញ្ជូ១គ្វាល៑កន្ទិត៑១តៃក្មៅ១តៃរាល៑១

៦- តៃកន្ទេប៑១តៃបិត្យៅ១តៃទន្ទៃ១តៃសេស១

៧- តៃសុភារុ១តៃកន្ដោះ១តៃវ្រះបង៑១តៃកន្យុ

៨- បិ១តៃក្បេប៑អំប្បេល៑១តៃសំអប៑១តៃ

៩- ក្ញះ១តៃក្ញុំ១តៃជយទេវី១តៃយក្នាក៑១តៃ

១០- កញ្ចៃ១តៃកន្សេត៑១តៃប្នាត៑១តៃកំបិ

---

[៩] នៅក្រោមអក្សរ«អ» គឺជាជើង«ជ»(្ជ) ដែលមានរូបរាងដូចស្រៈ«អូ»(ូ)ដូចករណីខាងលើដែរ។

១១- គិ១តៃអស្រៅកិ១តៃសនិវ១តៃរាជ

១២- លក្ខិ១ ស្រេក្សនិហោង១ប្រះក្តារិ១ចោកប្រាហ្ម១

១៣- ទិរង៉ប្រៃស្វេង -----អាយ្ចភក្ខា១

## អត្ថបទដើមជាអក្សររ៉ូម៉ាំង

Face A:

a. śrī śakaśureśvara sajñe śrī somaśarmmā svāmi devyā
b. śrī dhara ............(space).........
c. o)) gho śambhuvidya I gho laṅkaḥ I tai raṇgadevi I gvāl
d. neḥ [a]nak vnok .........(space)......
e. laṅkaḥ I si rat I gho vīrapaṇdit I rat cke I gho
f. jnaṃ I gho aṅaḥ I tai prayaṅga I tai pau I gho
g. vyatikara I tai cke I gvāl saṃgom I tai lap
h. rat I gho mantarkka I gho kañjā I gho kanse
i. n I tai v̇yaṅ I gvāl I lap I gho vul sokha I tai
j. kñuṃ I si pau I gho sehva I tai a I tai tmāy I
k. kvan tai pau I tai kaṃpat I tai saṃtoḥ vraḥ I
l. tai kvan kañjā I pau I gho vrau I tai kaṃpaṅ I
m. pau 2 tai kaṃpat I tai vrahey I tai prahvā
n. t I tai muliḥ I si rat 2 pau I tai silāpati I
o. gvāl puran I gho priyavidyā tai kaṃpus
p. si rat I gho pume I gho kñuṃ dai I pau I gvāl
q. cke [a]jī I gvāl cke I gho khdit I gho cke cīn I
r. gho cke ransau I tai somalā I kvan si kañcan I
s. kvan tai kandai I tai kaṃvis pau I

Face B

1- [a]nakk vraḥ gho kaṃbhāk I tai knāṅ I gho paroy I tai ksa
2- c I gho sunaha I gho droṅ I gho vatsarāja I gho
3- neṅ I gho kaṃvai I gvāl taṅke I gvāl pramodī
4- yya I gho mān snehā I gho kañjai I gho [a]gat I
5- gho kñuṃ cañ I gvāl kandit I tai kmau I tai rāl I
6- tai kandep I tai pitso I tai danai I tai ses I
7- tai subhāru I tai kantoḥ I tai vraḥ paṅ I tai kansu
8- p I tai kyep aṃpyel I tai saṃ ap I tai
9- kñaḥ I tai kñaṃ I tai jayadevī I tai ya knāk I tai
10- kañjai I tai kaṅset I tai pnāt I tai kaṃpi
11- t I tai anrok I tai saniva I tai rāja
12- lakṣmī I sre kṣan poṅ I vraḥ ktār I cok vrāhma I
13- daṃriṅ vrai sleṅ ----- āy ta rāklā I

## អត្ថបទបកប្រែ

*ផ្ទាំង "ក"*

*(១-២) ព្រះស្រីសកសុរេស្វរៈ ត្រូវបានបូជា (តង្វាយ) ដោយ (លោក )[១០] ស្រីសោមសម៌ា ( ទិង ) ព្រះគ្រូ[១១] ទេពនាមស្រីធរៈ ។*

*(៣-១៩) មនុស្សពួក[១២] នេះគឺមានឈ្មោះឃោ១៨នាក់ (ឈ្មោះ), សិម្នាក់, តៃ២០នាក់(ឈ្មោះ),ក្មេងប្រុស-ស្រីវៃយទៅ*

---

[10] sajñe (< /SAÑJ—SAJ/ = adhérer, être attaché ou suspendu ou accolé à, être dévoué, s'occuper de, ...); cf., Stchoupak, N., Nitti, L., and Renou, L. (1987). *Dictionnaire Sanskrit-Français*. Librarie d'Amérique et d'Orient. Paris. p. 769.

[11] svāmi (<svamin = propriétaire, maître, possesseur, ...); cf., *Ibid.*, p. 881.

*ចៅដោះម្តាយ ៩ នាក់ , ក្មេងប្រុសរែយចេះរត់ ៥នាក់ , គ្វាល[13] ៦ នាក់(៥ឈ្មោះ) និងលបម្នាក់ ។*

*ផ្ទាំង (ខ)*

*(១-១២) មនុស្សរបស់ព្រះ មានយោ១២ នាក់ (ឈ្មោះ), តែ ២៥ នាក់ (ឈ្មោះ), គ្វាល៣នាក់ (ឈ្មោះ) ។ (សរុប មនុស្សទាំងអស់ ចាស់ និងក្មេងមាន១០០នាក់គត់ ។*

*(១២-១៣) ស្រែឈ្មោះក្បូនបោង១(ស្រែ),ឈ្មោះប្រះក្តារ១(ស្រែ), ឈ្មោះចោក[14]វ្រាហ្ម (ឬអូរព្រាហ្ម) ១(ស្រែ) ។ ដំណាំ (ឡើងទ្រើង)នៅព្រៃស្ទែង.....នៅឯកក្វា១ ។*

---

[12] ពាក្យដើមថា «វ្នាក» នេះ បានក្លាយទៅជាពាក្យជាច្រើន តាមបែបដូច្នេះឯង ៖

វ្នាក > វ្នក > ភ្នក-ភ្នក់ (ដូរពី «វ» ទៅ «ភ»)
> វ្នុក > ផ្នុក
> វ្នុក > វុក > ពួក-ពួក-ពួក

[13] ពាក្យ«គ្វាល» គឺជាឋានន្តរនាមមួយប្រភេទនៅសម័យនោះ។ សព្វថ្ងៃ វាក្លាយជាកិរិយាស័ព្ទ«ឃ្វាល» និងនាមភ្នាក់ងារថា «គង្វាល»។

[14] តាមការស្រាវជ្រាវរបស់អតីតនិស្សិតប្រវត្តិវិទ្យា ឈ្មោះ ដុស ផល្លីន នៅក្នុងសហគមន៍ជនជាតិក្រោល នៅក្នុងស្រុកសម្បូណ៌ខេត្តក្រចេះបានឱ្យដឹងថា ពាក្យ «ចោក» នៅក្នុងភាសាក្រោលមានន័យថា «អូរ»។

ផ្ទាំងអក្សរទីដើម (ក)



ប្រភព , មីសែល ត្រាណេ, ២០០៣, ប្រវត្តិសាស្ត្រកម្ពុជា,
ភ្នំពេញ , ទំព័រផែនរូបទី ១០១

# ពិធីបង្ហោះគោមខ្មែរ

ដោយ លោក ទាំង ផេន

## I- សេចក្តីផ្តើម

ចុងតាមការសិក្សាស្រាវជ្រាវ ដូចជាពុំបានប្រទះឃើញមានឯកសារជាលាយលក្ខណ៍ ដែលនិយាយអំពីប្រវត្តិ នៃពិធីបង្ហោះគោមខ្មែរយើងទេ គឺបានត្រឹមតែពួតៗគ្នាប៉ុណ្ណោះ ។ សូម្បីនៅពុទ្ធសាសនបណ្ឌិត្យ ដែលសម្បូរដោយអត្ថបទស្តីពីទំនៀមទម្លាប់ខ្មែរក៏គ្មានដែរ ។ តែតាមការប៉ាន់ស្មាន ពិធីបង្ហោះគោម មិនខុសគ្នានឹងពិធីបង្ហោះខ្លែងទេមើលទៅ ព្រោះពិធីបង្ហោះខ្លែងមិនគ្រាន់តែជាការកម្សាន្តសប្បាយប៉ុណ្ណោះទេ ថែមទាំងផ្សារភ្ជាប់ទៅនឹងទំនៀមទម្លាប់ប្រពៃណីជាតិទៀតផង ។ ឯពិធីបង្ហោះគោម ក៏បង្ហាញឲ្យឃើញនូវគតិភាពសង្គម ក្រោមរូបភាពជំនឿទៅលើពិធីបុណ្យ ដែលជាប្រពៃណីទំនៀមទម្លាប់ខ្មែរ ព្រមទាំងផ្តោតអារម្មណ៍យ៉ាងសំខាន់លើវិស័យកសិកម្ម ក្នុងការប្រមូលផលស្រូវទុកដាក់ ។ ខ្មែរយើងមានទម្លាប់មួយរៀនតៗគ្នា ចេះចាំតៗគ្នា ដោយពុំបានគិតដល់ការកត់ត្រាទុក អាងតែចេះហើយក៏បង្រៀនតៗគ្នារហូតមក ហេតុនេះហើយបានជាយើងខ្វះឯកសារសម្រាប់បញ្ជាក់ជាតឹកតាង ណាមួយដោយសារមានសង្គ្រាមជាញឹកញាប់ផង ។

ដោយយល់ឃើញនូវកង្វះខាតនេះហើយ បានជាយើង

ខ្ញុំសាកល្បងសិក្សាស្រាវជ្រាវ ចងក្រងជាឯកសារនេះឡើង ព្រមទាំងបាត់មន្ត្រីបីរូបឲ្យចុះដល់មូលដ្ឋាន សម្រាប់ការស្វែងយល់ នឹងជាពន្លឺមួយដល់ការសេរសេរ ។

ជំបូងនេះយើងត្រូវស្គាល់ពាក្យ "គោម"សិន :

វចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ពន្យល់ :

គោម ១ ន - ប្រទីបមានឡូត មានប្រឆេះ មានលំផូង មានច្រើនបែបច្រើនយ៉ាងរូបរាងសណ្ឋានផ្សេងៗគ្នា សម្រាប់ប្រើកាន់លើកដាក់បាន ហៅថាគោមដៃ សម្រាប់ព្យួរ ហៅថាគោមព្យួរ ។

គោម ២ ន- ក្រឡាបួនជ្រុង ឬក្រឡាមានសណ្ឋានផ្សេងៗ ដែលមានទៅសំពត់ ឬទៅខ្ទុនសត្វមានពស់ថ្លាន់ជាដើម ឬក្រឡាឥដ្ឋពណ៌ជាដើម គោមហូល គោមពស់ថ្លាន់ ។

គោម ៣ ន- ឈ្មោះចានមួយយ៉ាង រាងក្រឡូមធំជាងចានសម្ល ចានគោម សម្លមួយគោម ។

គោមហោះ ៤ន-គោម ធ្វើដោយក្រដាសស្តើងមានសណ្ឋានស្រដៀងនឹងជាលអម្រែក សម្រាប់អុជបង្ហោះទៅលើអាកាស ។

II-**ប្រភព**

តាមប្រសាសន៍ ឯកឧត្តម **ជុច តឿន** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គោមហោះនេះប្រហែលមកពីចិន ព្រោះចិនបានរកឃើញ កាំជ្រួចមុនគេ ក្នុងអំឡុងសតវត្សទី ៦-៧

(បណ្តាសតវត្សខាងដើម (Lespremiers Siècles de l'ère Chrétienne) ។ ហើយមកសម័យអង្គរ លោក **ជាវ តាក្វន** ក៏បានសរសេរថា មានការបាញ់កាំជ្រួចភ្លឺព្រោងព្រាតក្នុងទីលានអង្គរដែរ ( ស.វ.ទី១៣ )។ បើយើងធ្វើការពិចារណាទៅ ហាក់ដូចជាសមហេតុផលផងដែរ ព្រោះកាំជ្រួចក៏ប្រើឡូត គ្រាន់តែគេយករំសេវមកដាក់ ហើយដុតយកកម្លាំងធាក់ឡើងទៅផ្ទុះលើអាកាស ។ ចំពោះគោមក៏ដូចគ្នា គ្រាន់តែគោមគេប្រើប្រទេះអំបោះ មានប្រេង ឬខ្លាញ់សម្រាប់អុជឲ្យហោះដូចគ្នា ។

ដូច្នេះគោមហោះនេះ ប្រហែលមានប្រភពពីចិនមែន ឬយ៉ាងណា ? តែនេះគ្រាន់ជាការប៉ាន់ស្មានប៉ុណ្ណោះ ។

III-**ប្រវត្តិ**

តាមប្រសាសន៍របស់ឯកឧត្តម មីសែល ត្រាណេ បានឲ្យដឹងថា នៅប្រទេសកម្ពុជាយើង ឃើញមានប្រភេទគោមម្យ៉ាងដែលធ្វើឡើងនៅពេលចូលឆ្នាំថ្មី ដូចជាខេត្តសៀមរាប កំពង់ធំ ជាដើម ដែលមានលក្ខណៈបុរាណ គួរឲ្យចាប់អារម្មណ៍ជាទីបំផុត ។ គោមប្រភេទនេះ ធ្វើអំពីដើមចេក ដោយគេកាត់យក ១កំណាត់ ។ គេដោតទៀន ឬដាក់ចង្កៀងខ្លាញ់ត្រី ឬប្រេងសម្រាប់អុជនៅពេលយប់ម្យ៉ាងវិញទៀត មានហ៊ុំក្រដាសស្តើងពណ៌ក្រហមជុំវិញចង្កៀងគោមកុំឲ្យរលត់ ។ គោមនេះ ជាប្រពៃណីខ្មែរសុទ្ធសាធ ដែលមានទំនាក់ទំនងនឹងការគោរពបូជាព្រះភ្លើង និងព្រះអាទិត្យ ដែលជាប្រភព

នៃជីវិត ។ ការដែលបង្ហោះ ឬដុតគោម នៅពេលចូលឆ្នាំខ្មែរ មិនមែនជាការបែជន្យនោះទេ ក៏ប៉ុន្តែ វាចុះបញ្ចាំងនូវលក្ខណៈជីវចលនិយមនៃប្រពៃណីដ៏មានចំណាស់ដូចខាងលើនេះដែរ ។ អ្វីដែលប្រជាជនខ្មែរចង់បង្ហាញនោះ គឺគោម ជាវត្ថុសញ្ញាបង្ហាញនូវការគោរពបូជាសក្ការៈភ្លើង ។ សម័យបុរាណ គេហ៊ុំគោមដោយក្រណាត់ ស្រទបចេក ឬធ្វើអំពីដើមស្មាច់ ។

ម្យ៉ាងវិញទៀត វាក៏ជាវត្ថុចម្លងមនុស្សពីឆ្នាំចាស់ ចូលទៅកាន់ឆ្នាំថ្មីដែរ ដោយផ្សារភ្ជាប់ពីឋានមនុស្ស ទៅនឹងឋានលើ ឬទៅស្ថាន ។ ទ្រូងគោម ដែលធ្វើដោយដើមចេកមួយកង់ តំណាងឲ្យស្ថានមនុស្សលោក ឬក៏ផែនដីនេះ រីឯចង្កៀងដែលហ៊ុំព័ទ្ធដោយក្រដាសក្រហម គឺតំណាងឲ្យអវកាស ឬមេឃ ឬស្ថានសួគ៌ ដូចនេះ ការធ្វើគោមបែបនេះ គឺជាប្រពៃណីខ្មែរសុទ្ធសាធ ពុំមែនមកពីបរទេសនោះឡើយ ដែលបង្ហាញនូវលក្ខណៈសកលរបស់គោម វាគ្រាន់តែជាចង្កៀងមួយប្រភេទប៉ុណ្ណោះ ដែលជានិមិត្តរូបនៃថ្ងៃ ពន្លឺព្រះអាទិត្យ ឬប្រភពនៃជីវិត ។ គោមនៅទីនេះ ក៏តំណាងឲ្យនូវសសរទ្រូង បង្គោលនៃចក្រវាល ជាទស្សនៈរបស់ខ្មែរ ។

សរុបមកគោមហោះខ្មែរ គឺកើតចេញពីមូលដ្ឋានខ្មែរ ហើយក្រោមឥទ្ធិពលបរទេស បានផ្លាស់ប្តូររូបភាព ទម្រង់ក្រោមការប៉ុនប្រសប់គំនិតច្នៃប្រឌិតរបស់បុព្វបុរសខ្មែរ ។

គោមម្យ៉ាងទៀតរាងជាផ្កាយ ឬតារា ដែលមានការស្និទ្ធប្រាំ

គោមនេះចេញមកពីវប្បធម៌អឺរ៉ុប ពោលគឺបាននាំចូលមកដោយព្រះយេស៊ូ ឬកាតូលិក ព្រោះជាប្រពៃណីអឺរ៉ុបសុទ្ធសាធ ។ គឺគោមរាងផ្កាយនេះហើយ ដែលបាននាំផ្លូវស្តេចបីព្រះអង្គ(Rois mages ) ទៅកាន់ជម្រក ដែលព្រះយេស៊ូប្រសូត គេបង្ហោះ ឬដុតគោមនេះនៅពេលបុណ្យណូអែល ។

ឯកឧត្តម **ជុច តឿន** លោកមានប្រសាសន៍ថា តាមការសិក្សាស្រាវជ្រាវរបស់លោក ឃើញមានស៊ើរគ្រប់ប្រាសាទ ដែលមានរឿងព្រេងទាក់ទងនឹងការកសាងប្រាសាទ រវាងក្រុមមនុស្សប្រុស និងក្រុមមនុស្សស្រី ប្រណាំងគ្នាក្នុងការកសាងប្រាសាទដូចជារឿងភ្នំប្រុស ភ្នំស្រី នៅខេត្តកំពង់ចាម និងប្រាសាទវត្តបាសែតនៅបាត់ដំបង ដោយក្រុមខាងស្រីសន្យានឹងក្រុមខាងប្រុសថា កាលណាផ្កាយព្រឹករះ យើងឈប់ធ្វើទាំងអស់គ្នា ។ ក្រុមស្រីៗមានល្បិចព្រោះថា បើធ្វើតាមកម្លាំងមិនឈ្នះប្រុសៗទេ។ ដើម្បីយកឈ្នះប្រុសៗបាន គេនាំគ្នាធ្វើគោមបង្ហូតឲ្យខ្ពស់ មើលទៅឃើញស្មានតែផ្កាយព្រឹករះហើយ ក៏នាំគ្នាឈប់សម្រាកដេកលក់អស់ ឯក្រុមស្រីៗគិតតែនាំគ្នាប្រឹងធ្វើរហូតដល់ផ្កាយព្រឹករះទើបឈប់ ហេតុនេះហើយ បានជាភ្នំប្រុសមានកម្ពស់ទាបជាងភ្នំស្រី ហើយប្រុសៗត្រូវចូលស្តីដណ្តឹងស្រីចាប់ពីពេលនោះមក ។

រឿងភាពយន្តចិន "ម្តាយក្មេករើសកូនប្រសារ" ត្រង់ម្តាយបង្គាប់ឲ្យកូនរើសក្រដាសខ្ទប់ខ្យល់... ។ នេះហើយជាគន្លឹះមួយ

ពិសោធន៍ ថាតើក្លួនប្រសាទនេះ អាចរកឃើញនូវវិធីការពារខ្យល់ ទុកកុំឲ្យរលត់ភ្លើងបានទេ ។ អញ្ចឹងពាក្យថាគោម គឺគេយកក្រដាស មកធ្វើជាស៊ុំពីក្រៅ ដើម្បីការពារខ្យល់កុំឲ្យរលត់ភ្លើង ។ យើងធ្លាប់ ឮចាស់ៗ និយាយថា អុជប្រទីបៗ បានសេចក្តីថា អុជចង្កៀង អុជគោមនេះឯង សម្រាប់បំភ្លឺ ដូចជានៅពេលមានបុណ្យទានធំៗ គេតែងលម្អ ដោយអុជប្រទីបជាលាភ្លឺព្រោងព្រាត ( បុណ្យអុំទូក ) ជាលា អណ្តាតភ្លើង, ពន្លឺដែលភ្លឺព្រោងព្រាត...) ។

នៅក្នុងឯកសារស្តីពីប្រវត្តិបុណ្យវិសាខបូជា ក៏បានលើកថា នៅប្រទេសឥណ្ឌា ពេលបុណ្យវិសាខបូជា គេរៀបចំធ្វើធំណាស់ មានរៀបជាក្បួនដង្ហែ ហើយនៅពេលយប់មានអុជប្រទីបជាលាភ្លឺ ព្រោងព្រាតនៅតាមដងផ្លូវ តាមមុខគេហដ្ឋានគ្រប់ៗគ្នា ។ លោក **អ៊ុក សៅរ៉ុល** មន្ត្រីនៅមន្ទីរអប់រំរាជធានីភ្នំពេញ បានមានប្រសាសន៍ ថា គោមបង្ហោះ គឺប្រៀបបានជាទង់សញ្ញា ឬការផ្សព្វផ្សាយនូវ ដំណឹងផ្សេងៗ ឬការបង្ហួតបង្ហាញសម្គាល់ក្រុមនីមួយៗ របស់កុល សម្ព័ន្ធនាសម័យដើម[១] ហើយការបង្ហោះគោម មិនចំពោះតែពេល យប់ទេ ពេលថ្ងៃក៏គេបង្ហោះដែរ ឲ្យតែមានការប្រារព្ធពិធីអ្វីមួយធំ ម្តងៗ ។ មិនតែប៉ុណ្ណោះ លោកមានប្រសាសន៍ថែមទៀតថា ជំនាន់ ដូនតាយើងក៏ធ្វើដូច្នេះដែរ ។ ឧទាហរណ៍ វត្ត "ក" នៅក្នុងភូមិ "គ" ត្រូវធ្វើបុណ្យផ្កាមួយ ដើម្បីប្រមូលបច្ច័យកសាងធម្មសាលា ឬក៏

១-គ្មានឯកសារបញ្ជាក់

ក្នុមិណាមួយខ្វះខាតស្បៀងអាហារ គឺគេសរសេរសេចក្ដីអំពាវនាវ ឬសេចក្ដីជូនដំណឹងនោះ ភ្ជាប់ជាមួយគោមបង្ហោះតែម្ដងៗ ពេលគោមអស់ប្រេង អស់ប្រេះភ្លើងរលត់ គោមត្រូវធ្លាក់នៅក្នុមិណាឃុំណា ពេលនោះ អ្នកស្រុកក្នុមិឃើញ ក៏នាំគ្នាទៅចូលរួមតាមសេចក្ដីអំពាវនាវ ឬសេចក្ដីជូនដំណឹង តាមរយៈគោមបង្ហោះនោះដែរ ។

**សន្និដ្ឋានៈ** ជារួមយើងអាចសន្និដ្ឋានបានថា ពិធីបង្ហោះគោមពិតជាប្រពៃណីរបស់ខ្មែរយើងតាំងពីបុរាណមក ព្រោះយើងសង្កេតឃើញនៅតាមទីអារាមមួយចំនួន នៅពេលមានបុណ្យទានម្ដងៗ គេតែងមានការបង្ហោះគោមព្រោងព្រាត ពិសេសគឺបុណ្យវិសាខបូជា និងមាឃបូជា ព្រោះគេយល់ថា ពិធីបង្ហោះគោមធ្វើឡើងដើម្បីឧទ្ទិសកុសល ចំពោះចូឡាមណីចេតិយ។ ឯប្រភព និងប្រវត្តិប្រហែលដូចឯកឧត្តម **ជុច គឿន** មានប្រសាសន៍មែនក៏មិនដឹង តែបើតាមប្រវត្តិរបស់រឿងព្រេងខាងលើ យើងអាចសន្និដ្ឋានបានថា ប្រាកដជាដូច ប្រសាសន៍ឯកឧត្តម **ជុច គឿន** មែន ។

**របៀបធ្វើគោម :**

-លោកអ៊ុំ ស្វាយ សន ហៅ តា ពក នៅក្នុមិចាប ឃុំចំបក់ស្រុកបាទី ខេត្តតាកែវ បានមានប្រសាសន៍ថា ការធ្វើគោមត្រូវមានក្បូនខ្នាតត្រឹមត្រូវណាស់ ដូចជាការថ្លឹងទម្ងន់ រាស់ទំហំ បណ្ដោយទទឹង និងការធ្វើថ្នឹង ។ បានសេចក្ដីថា បើយើងធ្វើពុំបានត្រឹមត្រូវដូចការរៀបរាប់នេះទេ នោះគោមក៏មិនអាចហោះឡើងល្អបានដែរ

ជូនកាលបង្កឲ្យមានគ្រោះមហន្តរាយទៀតផង ។ ឧទាហរណ៍ : ប្រឆេះធ្ងន់លើសទម្ងន់ ក៏មិនអាចហោះបាន ហោះបានបន្តិចអាចធ្លាក់មកលើផ្ទះ ឬធ្វើឲ្យឆេះផ្ទះ ធ្លាក់លើស្រូវទុំឆេះអស់ក៏មាន ។ បើយើងធ្វើត្រូវតាមក្បួនខ្នាត វានឹងឆេះល្អរហូតអស់ប្រឆេះ ហើយរលត់ ធ្លាក់ តែសំបកគោមមកដីវិញ មានសុវត្ថិភាព គ្មានបង្កគ្រោះមហន្តរាយអ្វីឡើយ ។



*(រូបភាពគោមខ្មែរខេត្តសៀមរាប)*

## ក្បួនខ្នាតរបស់គោមហោះ

- បើប្រវែងបណ្តោយគោម : ២ ម៉ែត្រ ២ តឹក ២.២០ m
- ត្រូវមានទំហំរង្វង់គោម : ៨,៣២ តឹក = ៨, ៣២ dm
- បណ្តោយឫស្សីសម្រាប់ធ្វើឆ្អឹងរង្វង់គោម ៣, ៣០ m
- ក្រដាសគោម ត្រូវប្រើក្រដាសស្តើងដូចក្រដាសជក់ (ហៅ

ក្រដាសវែយ) ត្រូវបិទតភ្ជាប់គ្នាជារង្វង់ ហើយប្រេកក្រដាស គោម ស៊ិកភ្ជាប់ខាងក្រោមគោម ។ (បញ្ជាក់)=គោម ១ ប្រើ រង្វង់ធ្នឹងតែមួយផ្នែកខាងក្រោមប៉ុណ្ណោះទេ ។

- ធ្នឹងរង្វង់ត្រូវចងខ្វែងដែកលួស សម្រាប់ព្យួរប្រេងះ ។
- ប្រេងះត្រូវប៉ាន់ឲ្យបានទម្ងន់ ២ ខាំកន្ទះ ( ២.៥ ហ.ក្រ )
- ប្រេងះត្រូវប្រើគ ឬអំបោះជ្រលក់ជ័រទឹក បើជ្រលក់លាយ ប្រេងកាតទៀតជាការល្អ ។




( រូបភាពគោមមូលទ្រវែង )

# រុក្ខជាតិវល្លិរមៀត

*អត្ថបទក្រុមស្រាវជ្រាវប្រពៃណី*
*ទំនៀមទម្លាប់ខ្មែរ នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*

## សេចក្តីផ្តើម

*ប្រទេសកម្ពុជា ជាប្រទេសមួយឋិតនៅក្នុងតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅហើយសើម ជាលក្ខណៈមួយ បង្កការងាយស្រួល ដល់ការរស់នៅរបស់ពួកសត្វទាំងឡាយ និងការរីកលូតលាស់របស់រុក្ខជាតិគ្រប់បែបយ៉ាង ។ អំណោយផលនៃអាកាសធាតុទាំងនេះ បានធ្វើឲ្យរុក្ខជាតិវល្លិរមៀត អាចដុះលូតលាស់បានល្អ ស្ទើរតែគ្រប់ទីកន្លែង បណ្តាខេត្តនានានៃប្រទេសកម្ពុជា ។*

*រុក្ខជាតិគ្រប់ប្រភេទ មានដុះពាសពេញ នៅតាមតំបន់នានា ដូចជា ខ្ពង់រាប វាលទំនាប និងតំបន់ភ្នំជាដើម ។ ប្រជាជនខ្មែរបានទាញយកផលប្រយោជន៍យ៉ាងច្រើន ពីរុក្ខជាតិទាំងនោះ មកបំពេញតាមតម្រូវការរបស់ខ្លួន ។ រុក្ខជាតិនីមួយៗ មានសារៈប្រយោជន៍ផ្សេងគ្នា ទៅតាមប្រភេទរបស់រុក្ខជាតិ ។ យ៉ាងណាមិញ នៅសម័យមុនរុក្ខជាតិវល្លិរមៀត ត្រូវបានប្រជាជនខ្មែរយើង យកមកផ្សំផ្សំធ្វើជាឱសថ សម្រាប់ព្យាបាលរោគ ហើយរហូតមកដល់សម័យនេះការយករុក្ខជាតិវល្លិរមៀតទៅផ្សំជាថ្នាំ ក៏នៅតែឃើញមានបន្តខ្លះៗដែរ គឺដោយសារប្រជាជនខ្មែរយើង នៅតែមានជំនឿលើថ្នាំបុរាណនៅឡើយ ដោយសារតែមិនចាំបាច់ ត្រូវចំណាយលុយកាក់ច្រើន*

ដើម្បីយកទៅទិញឱសថសម័យ ជាពិសេសកត្តាទាំងនេះហើយ ជាទម្លាប់ព្រមទាំងជាជំនឿ ដែលបានបន្សល់ទុកតាំងពីដូនតាមក ដូច្នោះហើយទង្វើទាំងនេះ បានផ្ទេរពីជំនាន់មួយទៅជំនាន់មួយទៀត រហូតដល់សព្វថ្ងៃ ។ ការកាប់វល្លិរមៀត យកមកផ្សំធ្វើជាឱសថបុរាណ គ្មានផលប៉ះពាល់ខ្លាំងក្លាដូចជា ការកាប់យកទៅលក់ឲ្យម្ចាស់សិប្បកម្មផលិតម្សៅវល្លិរមៀតឡើយ ព្រោះកាប់សម្រាប់តែយកមកបំពេញតម្រូវការផ្ទាល់ខ្លួនបន្តិចបន្តួចប៉ុណ្ណោះ ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏រុក្ខជាតិវល្លិរមៀត នៅតែត្រូវបានគេកាប់យកទៅ លក់ឲ្យម្ចាស់សិប្បកម្មផលិតម្សៅវល្លិរមៀត យកទៅកែច្នៃតាមបែបវិទ្យាសាស្ត្រ ដើម្បីធ្វើឲ្យក្លាយទៅជា វត្ថុធាតុដើមផ្សេងៗដដែល ។ បច្ចុប្បន្ន រុក្ខជាតិវល្លិរមៀត ជាតម្រូវការរបស់ឈ្មួញក្នុងស្រុក និងក្រៅស្រុក ដោយពួកគេ បានប្រមូលទិញពីប្រជាជន ក្នុងបរិមាណយ៉ាងច្រើន សម្រាប់ផលិតចេញជាម្សៅវល្លិរមៀត ទុកសម្រាប់លក់នៅក្នុងប្រទេសខ្លះ និងមួយចំនួនធំទៀត សម្រាប់ដឹកនាំយកទៅលក់នៅក្រៅប្រទេស ។ ក្នុងរវាងឆ្នាំ ១៩៩៤-២០០០[១] ទាំងការកាប់ និងការផលិតចេញជាម្សៅ មានសកម្មភាពខ្លាំងក្លាណាស់ តែត្រូវរាជរដ្ឋាភិបាលហាមឃាត់មិនឲ្យកាប់ និងផលិតឡើយ ព្រោះវាមានផលប៉ះពាល់ខ្លាំងណាស់ ដល់ប្រជាជន សង្គមរស់នៅ ជាពិសេសបរិដ្ឋានធម្មជាតិទាំងមូល ។

១- លោក លីម សុធី មេបញ្ជាការកងអនុសេនាធំប្រចាំនៅឃុំតាតៃ ស្រុកកោះកុង ខេត្តកោះកុង

## I- លក្ខណៈទូទៅនៃរុក្ខជាតិវល្លិរមៀត

*វល្លិរមៀត ឬ ល្មៀត* [១] (TERAMNUS LIBRIALIS)*ជាឈ្មោះវល្លិមួយប្រភេទ ក្នុងចំណោមប្រភេទវល្លិជាច្រើន ដែលមានដុះនៅក្នុងប្រទេសកម្ពុជា ជាយូរណាស់មកហើយ ។ វល្លិរមៀតមានសាច់ខាងក្នុងសើម ពណ៌លឿងស្រដៀងនឹងមើមរមៀត ។ ពេលវិទ្យាសាស្ត្រមិនទាន់ជឿនលឿន គេច្រើនប្រើប្រាស់វល្លិរមៀតនេះសម្រាប់ធ្វើជាថ្នាំម្ចាប់រោគ តែមកដល់សម័យបច្ចុប្បន្ន គេបានកែច្នៃរុក្ខជាតិវល្លិរមៀត ធ្វើជាម្សៅវល្លិរមៀតវិញ ។*

### ១. ទីតាំង

*ជាទូទៅ វល្លិរមៀត ច្រើនដុះនៅតាមតំបន់ភ្នំ ដែលមានអាកាសធាតុត្រជាក់ ។ គេមិនអាចកំណត់អំពីអាយុកាល របស់វល្លិរមៀតបានទេ គឺអាស្រ័យលើទីតាំងភូមិសាស្ត្រ បើសិនជាទីតាំងដែលវល្លិនេះដុះសម្បូរទៅដោយថ្មច្រើន រុក្ខជាតិវល្លិរមៀត មិនសូវដុះល្អទេ តែបើសិនជាទីតាំងទាំងនោះមិនសូវសម្បូរថ្ម ហើយមានអាកាសធាតុត្រជាក់ទៀតនោះ ជាការបង្កលក្ខណៈងាយស្រួល ដល់ការរីកលូតលាស់ នៃរុក្ខជាតិប្រភេទនេះណាស់ ។*

*ខេត្តដែលសម្បូរវល្លិរមៀតមានដូចជា កោះកុង កំពត កំពង់ស្ពឺ ពោធិ៍សាត់ និងបណ្តាខេត្តផ្សេងៗទៀត* [២] ។

---

១- វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២- ទស្សនាវដ្តី ឥន្ទ្រទេវី ចេញផ្សាយ ថ្ងៃទី ២៥ ខែ មករា - ១០ កុម្ភៈ ២០០១

## ២. ទ្រង់ទ្រាយរបស់រុក្ខជាតិវល្លិរមៀត

វល្លិរមៀតមានពីរប្រភេទ គឺវល្លិដែលវារនៅនឹងដី និងវល្លិដែលរុំព័ទ្ធឡើងលើដើមឈើ ។ ជាមធ្យមដើមវល្លិរមៀត មានប្រវែងពីម្ភៃម៉ែត្រ ទៅសាមសិបម៉ែត្រ ជួនកាលអាចលើសពីនេះទៅទៀត[១] គឺអាស្រ័យទៅលើប្រវែងដើមឈើ ដែលវល្លិរមៀតត្រូវរុំព័ទ្ធឡើងទៅលើ បើដើមឈើខ្ពស់ វល្លិរមៀតក៏វារឡើងខ្ពស់តាមនោះដែរ តែបើដើមឈើទាប នៅពេលវល្លិឡើងទៅដល់ចុងឈើ ហើយចុងវល្លិរមៀត ក៏បត់សំយុងក្បាលចុះមកដី ដើម្បីវារនៅនឹងដីបន្តទៀត ព្រោះមិនអាចតោងវារទៅលើបន្តទៀតបាន ។ ភាគច្រើន វល្លិដែលវារនៅនឹងដី មានប្រវែងវែងជាង វល្លិដែលរុំវារតោងឡើងដើមឈើ ។

បើនិយាយពីសំបកដើមវល្លិរមៀតវិញ គេសង្កេតឃើញថាសំបកដើមវល្លិរមៀតមាន ពណ៌ស ប្រផេះ ហើយស្តើង បើសិនជាយើងយកក្រចកទៅឆ្កឹះតែបន្តិច គេឃើញសាច់វល្លិរមៀតលឿងប្រាលប្រាលចេញមកភ្លាម ហាក់បីដូចជាមើមរមៀតអញ្ចឹង ។

ផ្ទៃសាច់ខាងក្នុងរបស់វល្លិរមៀត រាងជាកងមូលៗ ដូចក្រយៅសាច់ពណ៌លឿង សរសៃធ្មារៗ ស្រដៀងនឹងអំពោះដេរបាវ ។ រង្វង់កងៗ ដែលជាស្រទាប់របស់សាច់វល្លិរមៀត មានចំនួនប្រហែលប្រាំទៅប្រាំមួយស្រទាប់ ។

---

១-លោក កែវ អួន កម្មករផលិតម្សៅវល្លិរមៀត នៅព្រៃប្រទល់ខេត្តកោះកុង និងខេត្តពោធិ៍សាត់

ស្លឹករបស់វល្លិរមៀត គេមិនសូវឃើញមានដុះនៅទឹងគល់វល្លិទេ គឺច្រើនឃើញមានដុះសម្បូរនៅចុងវល្លិ ព្រោះពេលដើមរបស់វារីកលូតលាស់ធំ ស្លឹកចាស់ៗក៏ចាប់ផ្ដើមជ្រុះ ។ ស្លឹកវល្លិរមៀតមានសណ្ឋានដូចស្លឹកម្លូ និងមានទំហំដូចស្លឹកម្លូដែរ ជាពិសេសចុងស្លឹកមានសភាពស្រួច និងមានពណ៌បៃតងដូចគ្នា ។

ធាងរបស់វល្លិរមៀត មានទំហំប៉ុនជើងធូប ទងជាប់គល់ធាងនិងទងជាប់គល់ សន្ទឹកវាងកំប៉ោងដូចគ្នា ប៉ុន្តែទងជាប់គល់សន្ទឹកស្លឹកតូចជាងទងជាប់គល់ធាងបន្តិច ។

ផ្កាវល្លិរមៀត មានរាងល្អិតៗពណ៌សនៅជាកញ្ចុំៗ ឯផ្លែរបស់វា មានរាងមូលប៉ុនម្រាមដៃ ហើយដុះជាចង្កោមៗ នៅក្នុងមួយចង្កោម មានប្រហែលជាបួនទៅប្រាំផ្លែ[១] ។

## II- ការរកវល្លិរមៀត

ការរកវល្លិរមៀត ជារបរមួយរបស់ប្រជាជនខ្មែរ នៅតាមតំបន់ព្រៃភ្នំ មិនខុសពីរបរផ្សេងៗដូចជា ការរកខ្លឹមចន្ទន៍ក្រស្នា ការយកជ័រ-ម្រ័ក្សណ៍ ការរកផ្ដៅ ការរកវល្លិផ្សេងៗ មកធ្វើជាឱសថបុរាណប៉ុណ្ណោះទេ ព្រោះថាប្រជាជនខ្មែរមួយចំនួន នៅតាមតំបន់ជនបទនៅមានជំនឿលើគ្រូបុរាណ ( ព្យាបាលបែបបុរាណ ) នៅពេលមានជំងឺតម្កាត់ម្ដងៗ និងដោយគ្មានប្រាក់កាសសម្រាប់ព្យាបាល ប្រជា-ជនបានទៅរកវល្លិរមៀត មកផ្សំធ្វើជាឱសថ សម្រាប់ព្យាបាល

---

១-លោក សាយ ស្រៀង កម្មករកាប់វល្លិរមៀត នៅព្រៃប្រទល់ ខេត្តកោះកុង និងខេត្តពោធិ៍សាត់

ដោយខ្លួនឯង តែមកដល់សម័យបច្ចុប្បន្ន ការទៅរកវល្លិរមៀតមកធ្វើជាឱសថបុរាណ គេពុំសូវប្រទះឃើញមានទេ គឺភាគច្រើនអ្នកទៅរកកាប់វល្លិរមៀត គេមានគោលបំណង កាប់យកទៅលក់ឲ្យ ម្ចាស់សិប្បកម្ម ផលិតម្សៅវល្លិរមៀតតែប៉ុណ្ណោះ ។ ក្នុងការទៅរកវល្លិនេះផងដែរ គេមានវិធីកាប់របស់គេ គឺនៅពេលដែលគេប្រទះឃើញ វល្លិរមៀតដែលរុំព័ទ្ធដើមឈើ គេកាន់កាំបិតឡើងទៅចុងឈើ រួចកាប់វល្លិទម្លាក់ចុះមកខាងក្រោម រួចទើបកាប់វល្លិត្រង់គល់ទៀត ដើម្បីងាយស្រួល អូសវល្លិទម្លាក់ចុះមកក្រោម ។ ចុងក្រោយ គេក៏កាប់វល្លិជាកង់ៗ ប្រវែងប្រហែលពីរម៉ែត្រ ចងជាបាច់ដើម្បីងាយស្រួលក្នុងការដឹកជញ្ជូន[១] ។

## ១. ការធ្វើដំណើរ

ក្នុងការធ្វើដំណើរទៅរកវល្លិរមៀត អ្នកទៅរកវល្លិរមៀត តែងតែធ្វើដំណើរដោយថ្មើរជើង ព្រោះត្រូវឡើងភ្នំ និងត្រូវចូលព្រៃជ្រៅ ។ ការធ្វើដំណើរទៅរកវល្លិរមៀត ត្រូវធ្វើឡើង ដោយមានសមាជិកធ្វើដំណើររួមគ្នា ចំនួនពីដប់ទៅម្ភៃនាក់ ក្នុងនោះផងដែរអ្នកទៅរកវល្លិរមៀត ច្រើនទៅកាប់នៅរដូវប្រាំង[២] នៅរដូវវស្សាគេពុំសូវឃើញមានទេ ព្រោះនៅរដូវវស្សាសម្បូរភ្លៀង ធ្វើឲ្យមានការលំបាក ក្នុងការដឹកជញ្ជូនវល្លិចេញពីក្នុងព្រៃ ។ សម្ភារៈដែលត្រូវ

១- លោក លឹម សុធី មេបញ្ជាការកងអនុសេនាធំប្រចាំនៅឃុំតាតៃ ស្រុកកោះកុង ខេត្តកោះកុង

២-លោក អាចារ្យ អ៊ួច សាភូន សមាជិកឆ្លើយឆ្លងខេត្តកោះកុង

យកទៅជាមួយ មានដូចជា កាំបិត អង្រឹង តង់កៅស៊ូ អង្ករ ត្រីងៀត និងសម្ភារៈមួយចំនួនទៀត ព្រោះការទៅរកវល្លិ ត្រូវចំណាយពេលវេលាយ៉ាងយូរគួរសម ដោយត្រូវស្នាក់នៅក្នុងព្រៃចំនួនពីដប់ទៅម្ភៃថ្ងៃ ឬអាចលើសពីនេះទៅទៀត អាស្រ័យដោយជួបវល្លិ ឬមិនជួបវល្លិតែប៉ុណ្ណោះ ។

## ២. អបិយជំនឿ និងតំណមសម្រាប់អ្នកទៅកាប់វល្លិរមៀត

បញ្ហាអបិយជំនឿពេលដើរព្រៃ គេឃើញកើតមានជាយូរយារណាស់មកហើយ ដែលបន្សល់ទុករហូតបច្ចុប្បន្ននេះ ។ ចំពោះអ្នកទៅកាប់វល្លិរមៀតក៏ដូច្នោះដែរ ពេលចូលព្រៃ គេតែងតែបន់ស្រន់សុំសេចក្តីសុខ សេចក្តីចម្រើនពីអ្នកតាម្ចាស់ព្រៃ កុំឲ្យជួបទីងគ្រោះថ្នាក់ ព្រមទាំងជំងឺតម្កាត់ផ្សេងៗ ពិសេសសុំកុំឲ្យជួបទីងពពួកសត្វសាហាវ ដែលសម្បូរពាសពេញក្នុងព្រៃ ព្រោះការធ្វើដំណើរ ត្រូវស្នាក់នៅក្នុងជំរំ ដែលត្រូវបោះនៅក្នុងព្រៃ។ ក្រុមអ្នកទៅកាប់វល្លិទាំងអស់ ប្រមូលគ្នាយកតង្វាយផ្សេងៗ ដើម្បីដាក់ថ្វាយដល់អ្នកតា ដែលថែរក្សាព្រៃ ឲ្យជួយតាមថែរក្សា និងជួយបង្ហាញផ្លូវដល់ពួកគេ ក្នុងការស្វែងរកវល្លិរមៀត[១] ។ ពួកគេមានជំនឿថា បើសិនជាពួកគេ មិនដាក់តង្វាយថ្វាយអ្នកតាទេ អ្នកតាទឹងទឹង ហើយកាច់គេធ្វើឲ្យគេមានជំងឺ ឬជួបទីងហេតុអាក្រក់អ្វីមួយ ជាក់ជាមិនខានឡើយ ។

---

១ លោក កែវ អួន កម្មករផលិតម្សៅវល្លិរមៀត នៅព្រំប្រទល់ខេត្តកោះកុង និងពោធិ៍សាត់

គួបផ្សំនឹងជំនឿខាងលើ គេក៏ឃើញមានតំណមផ្សេងៗ ដើម្បីសុំសេចក្តីសុខផ្ទាល់ខ្លួនរបស់ពួកគេ តួយ៉ាងដូចជា តមមិនឲ្យមាត់កផ្តេសផ្តាស ហាមជេរប្រទេចគ្នាក្នុងព្រៃ ពេលកំពុងរកវល្លិ ព្រោះនាំឲ្យកើតអន្តរាយដល់ខ្លួន ពេលហូបបាយ ត្រូវរំលែកម្ហូបអាហារខ្លះដាក់ថ្វាយអ្នកតាម្ចាស់ព្រៃជាដើម ។ នេះជាលក្ខណៈពិសេសរបស់ទំនៀមទម្លាប់ប្រពៃណីខ្មែរ ដែលគេតែងតែជួបប្រទះជារឿយៗនៅក្នុងជីវិតរស់នៅ មានន័យថា ខ្មែរជាជនជាតិមានជំនឿជឿជាក់និងគោរពប្រតិបត្តិជានិច្ច នូវតំណមផ្សេងៗ ដែលដូនតាបានបន្សល់ទុកឲ្យ ។

## ៣. ផលវិបាករបស់អ្នករកវល្លិរមៀត

បច្ចុប្បន្នវល្លិរមៀត មិនសូវសម្បូរដូចមុនទេ អ្នកទៅរកវល្លិ-រមៀតនេះ ត្រូវធ្វើដំណើរចូលព្រៃជ្រៅទើបបានជួប ហើយត្រូវឡើងទៅកាប់នៅដើមឈើធំៗ ហើយខ្ពស់ៗទៀត ដូច្នេះអ្នកទៅកាប់វល្លិ-រមៀត ត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួន ដែលមិនអាចជៀសផុត ។ នៅក្នុងព្រៃសម្បូរទៅដោយសត្វសាហាវជាច្រើន ជាពិសេសសត្វទាក ដូច្នេះអ្នកទៅកាប់វល្លិ មានអារម្មណ៍ភ័យខ្លាចខ្លាំងណាស់ ។ ម្យ៉ាងទៀតការចូលព្រៃ ងាយស្រួលនឹងកើតជំងឺណាស់ ជាពិសេសជំងឺគ្រុនចាញ់សន្និ ព្រោះអ្នកទៅកាប់វល្លិរមៀតដេកតែក្នុងអង្រឹង ហើយអុជភ្លក់ភ្លើងតែបន្តិចបន្តួច ដើម្បីដេញមូសប៉ុណ្ណោះ វាមិនអាចការពារមូស មិនឲ្យខាំទាំងស្រុងបានឡើយ ។

ចំពោះអ្នកទៅរកវល្លិរមៀតនៅរដូវភ្លៀងវិញ បញ្ហាដែលត្រូវប្រឈមមុខខ្លាំងជាងគេនោះ គឺសត្វទាក ពីព្រោះសត្វប្រភេទនេះសម្បូរណាស់នៅរដូវវស្សា ។

## III- ឧបករណ៍ និងវត្ថុធាតុដើមសម្រាប់ផលិតម្សៅវល្លិរមៀត

### ១. ឧបករណ៍

ប្រសិនបើយើងចង់បានផលិតផលអ្វីមួយ យើងចាំបាច់ត្រូវពឹងផ្អែកទៅលើឧបករណ៍សម្រាប់ផលិត ។ ម្សៅវល្លិរមៀតដែលអាចចេញជារូបរាងបាន គឺវាអាស្រ័យទៅលើឧបករណ៍មួយចំនួនដូចជា៖

- *ម៉ាស៊ីនហាន់* ជាឧបករណ៍មួយប្រភេទ មានលក្ខណៈវិទ្យាសាស្ត្រ ឧបករណ៍នេះមាន កាំបិតមុខមុត សម្រាប់កាប់ចិញ្ច្រាំវល្លិជាចំណិតៗ ដើម្បីប្រមូលយកទៅដាក់ត្រាំនៅក្នុងអាង។
- *ម៉ាស៊ីនបូមទឹក* ជាឧបករណ៍មួយប្រភេទ មានលក្ខណៈវិទ្យាសាស្ត្រ ប្រើសម្រាប់បូមទឹកពីស្ទឹង បឹង ត្រពាំង ដែលនៅជិតកន្លែងផលិតយកមកដាក់ក្នុងអាង ដើម្បីត្រាំចំណិតវល្លិ ដែលបានកាប់ចិញ្ច្រាំរួចជាស្រេច និងសម្រាប់បូមទឹករងថ្នា នៅខាងលើអាងដាក់ទៅអាងមួយផ្សេងទៀត ដែលនៅជិតគ្នា ។
- *អាងត្រាំ* ធ្វើឡើងពីកៅស៊ូតង់ ឬស៊ីម៉ងត៍ តែភាគច្រើនគេធ្វើពីកៅស៊ូតង់ ព្រោះមានភាពងាយស្រួល ពេលដែលគេចង់ផ្លាស់ប្តូរទីតាំងផលិតម្សៅវល្លិរមៀត ។ អាងត្រាំ គេធ្វើឡើងមានទទឹង

ប្រវែង ២ ម៉ែត្រ ទៅ ២ ម៉ែត្រកន្លះ បណ្ដោយប្រវែង ២ ម៉ែត្រកន្លះ ទៅ ៣ ម៉ែត្រ និងជម្រៅប្រវែង ១ ម៉ែត្រ ទៅ ១ ម៉ែត្រកន្លះ [១] ។

- ប៉ែល និងរទាស់ ជាឧបករណ៍សំខាន់មួយដែរ នៅពេលដែលគេបូមយកទឹករងថ្នាំពីអាង ដែលដាក់ត្រាំចំណិតល្ហិរមៀតទៅដាក់នៅក្នុងអាងមួយផ្សេងទៀត ហើយនៅសល់ម្សៅល្ហិរមៀតសើមកកនៅខាងក្រោម គេក៏ចាប់ផ្ដើមយកឧបករណ៍ទាំងពីរនេះទៅកាយ និងចូកយកម្សៅដាក់ទៅក្នុងថៃ ហើយដាក់សង្កត់ ដូចម្សៅនំអញ្ចឹង ។

- ថៃ ជាឧបករណ៍មួយប្រភេទ សម្រាប់ច្រកម្សៅល្ហិរមៀត ដែលនៅបាតអាង ដើម្បីដាក់សង្កត់ឲ្យអស់ជាតិទឹក ( ថៃមានលក្ខណៈដូច បាវ ឬស្បោង ) ។

- ចង្អេរ ជាឧបករណ៍ចុងក្រោយ សម្រាប់ដាក់ហាលម្សៅល្ហិរមៀត ដែលបានមកពីការសង្កត់ ដើម្បីយកទៅហាលឲ្យម្សៅស្ងួត ។

## ២. វត្ថុធាតុដើម

ឧបករណ៍ទាំងអស់ខាងលើ មានសារៈសំខាន់ណាស់ ក្នុងការផលិតចេញជាម្សៅល្ហិរមៀត តែវាក៏ត្រូវគួបផ្សំជាមួយវត្ថុធាតុដើម មួយចំនួនទៀតដូចជា ទឹក អាស៊ីត អំបិល ដែលជាវត្ថុធាតុដើមដ៏សំខាន់បំផុត ក្នុងការផលិត ដើម្បីសម្រេចឲ្យចេញ

---

១-លោក វិច គុង មេការកម្មករផលិតម្សៅល្ហិរមៀត នៅព្រំប្រទល់ខេត្តកោះកុងនិងពោធិ៍សាត់

ជាម្សៅបាន ។ ទឹក សម្រាប់ត្រាំចំណិតល្ហុងរមៀត ដែលគេកាប់ចិញ្ច្រាំរួចរាល់ហើយ ឯអំបិល និងអាស៊ីត មានតួនាទីសំខាន់ជាងគេបំផុត សម្រាប់កាត់ជាតិម្សៅចេញពីក្នុងសាច់ល្ហុង ។

## IV- របៀបផលិតម្សៅល្ហុងរមៀត និងផលវិបាក

### ១. វិធីសាស្ត្រផលិតម្សៅល្ហុងរមៀត

ដើម្បីផលិតឲ្យចេញជាម្សៅល្ហុងរមៀត យើងត្រូវយកល្ហុងរមៀតចាស់ ព្រោះល្ហុងកាន់តែចាស់ គឺកាន់តែសម្បូរម្សៅ ដូចពាក្យខ្មែរថា "ខ្ញីកាន់តែចាស់កាន់តែហឹរ[១]" ។ បន្ទាប់មក គេក៏ចាប់ផ្តើមយកល្ហុងដែលគេកាប់ជាកង់ៗ ប្រវែង២ម៉ែត្ររួចមកហើយនោះ ទៅដាក់ក្នុងម៉ាស៊ីនហាន់ ដែលមានថាស សម្រាប់ចិញ្ច្រាំចេញជាចំណិតៗ។ បន្ទាប់ពីហាន់ល្ហុងជាចំណិតៗរួចរាល់ហើយ គេក៏ចាប់ផ្តើមយកចំណិតល្ហុងទាំងនោះទៅដាក់ក្នុងអាង ដើម្បីត្រាំជាមួយទឹក និងអាស៊ីតរយៈពេលពី៤ទៅ៥ថ្ងៃ ធ្វើដូច្នេះ ដើម្បីឲ្យល្ហុងទន់រលួយ ធ្លាក់ម្សៅល្ហុងចុះក្រោម ។ បន្ទាប់មក គេបង្ហូរទៅត្រាំក្នុងអាងចុងក្រោយមួយទៀតដែលនៅជិតគ្នា និងមានលាយអំបិល ។ ក្នុងរយៈពេលមួយសប្តាហ៍ក្រោយមក ល្ហុងរមៀតបានក្លាយទៅជាម្សៅ ហើយគេក៏ចាប់ផ្តើមបង្ហូរទឹក ដែលមានជាតិអំបិលនោះចោល រួចហើយគេយកប៉ែលកើបម្សៅល្ហុងដាក់ក្នុងទៃ[២] ។ បន្ទាប់មក គេចាប់ផ្តើមចងមាត់

---

១-លោក រិច តុង មេការកម្មករផលិតម្សៅល្ហុងរមៀតនៅព្រំប្រទល់ខេត្តកោះកុង និងពោធិ៍សាត់

២- ទស្សនាវដ្តី ប្រជាប្រិយឆ្នាំទី៧ លេខ ១៧៤ ចេញផ្សាយថ្ងៃទី ១១-២០ កក្កដា ២០០១

ទៃ រួចយកដុំថ្មមកសង្កត់ ដើម្បីឲ្យអស់ជាតិទឹក ការសង្កត់មេហ្វាត្រូវប្រើរយៈពេល១យប់ ទើបគេស្រាយមាត់ទៃ រួចយកប៉ែលចូកមេហ្វាចេញ យកទៅដាក់ហាលក្នុងចង្អេរ ដើម្បីឲ្យមេហ្វាវល្លិស្ងួតល្អ ។ នៅក្នុងការហាលមេហ្វាវល្លិរមៀតនេះ បើសិនជាគ្មានថ្ងៃហាលទេ គេយកមេហ្វាវល្លិរមៀត ដែលនៅសើមទាំងអស់នោះ ទៅដាក់ក្នុងចង្អេរដដែល ហើយយកភ្លើងមកដាក់ឆ្អើរ ដោយដុតភ្លើងតិចៗជំនួសវិញ ប៉ុន្តែការឆ្អើរដោយភ្លើងបែបនេះ ប្រើរយៈពេលយូរណាស់ ទើបវល្លិស្ងួតល្អ ព្រោះបើដុតភ្លើងខ្លាំងពេក នាំឲ្យខូចគុណភាពមេហ្វា[១] ។

## ២_ ផលវិបាកដែលទទួលរងពីការផលិតមេហ្វាវល្លិរមៀត

ពេលដែលការផលិតបានចប់រួចរាល់ ពួកកម្មករបានបង្ហូរទឹកត្រាំវល្លិរមៀត ដែលមានជាតិអាស៊ីត និងអំបិលចូលទៅក្នុងទីវាល ក្នុងព្រៃ ក្នុងបឹង អូរ ត្រពាំង នៅក្បែរៗកន្លែងផលិតនោះ ដែលជាចំណែកធ្វើឲ្យ គ្រោះថ្នាក់យ៉ាងខ្លាំងចំពោះបរិស្ថាន ។ នៅពេលប្រជាពលរដ្ឋ ដែលនៅជិតអូរ បឹង ស្ទឹង ត្រពាំង យកទឹកទាំងនោះទៅប្រើប្រាស់ នឹងធ្វើឲ្យពួកគេហើមពោះ ភគរូសរលាកក្រពះ ពោះវៀន បង្ករោគថ្មើម ហើយអាចបង្កគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិតថែមទៀតផង[២] ។ ដោយឡែក សត្វពាហនៈ

១- លោក សាយ ស្រៀង កម្មករកាប់វល្លិរមៀត នៅព្រៃប្រទល់ខេត្តកោះកុង និងពោធិ៍សាត់

២- ទស្សនាវដ្តី ឥន្ទ្រទេវី ចេញផ្សាយ ថ្ងៃទី ២៥ មករា - ១០ កុម្ភៈ ២០០១

និងសត្វព្រៃទាំងឡាយ ដែលចូលទៅផឹកទឹកទាំងនោះ ក៏ទទួលរង គ្រោះថ្នាក់ដូចគ្នានឹងមនុស្សផងដែរ ។ ម៉្យាងវិញទៀត មច្ឆាតូចធំ ដែលរស់នៅក្នុងទឹកនោះ នឹងត្រូវងាប់អស់ បើសិនទឹកនោះបង្ហូរចូល ទៅក្នុងដី បើចំប្រភេទដីសម្បូរទៅដោយជាតិកំបោរ វាមិនសូវបង្ក គ្រោះថ្នាក់ទេ ព្រោះជាតិអាស៊ីតវាបំប្លែងនឹងជាតិកំបោរ ដូច្នេះវាមិន បណ្តាលឲ្យខូចគុណភាពដីទេ តែបើហូរទៅលើដី ដែលមិនសូវ សម្បូរដោយជាតិកំបោរ គឺធ្វើឲ្យដីទាំងនោះខូចគុណភាព [១] ។

ពិសេសជាងនេះទៅទៀត កម្មករផលិតម្សៅវល្លិរមៀត ងាយនឹងប៉ះពាល់ដល់សុខភាពជាងគេ ។ ជំងឺពីរប្រភេទ ដែល កម្មករត្រូវប្រឈមមុខនោះ គឺជំងឺគ្រុនចាញ់សន្លំ និងគ្រោះថ្នាក់បង្ក ឡើងដោយជាតិពុល បណ្តាលមកពីអាស៊ីត និងអំបិល ដែលពួក គេប្រើប្រាស់ ដើម្បីផលិតម្សៅវល្លិរមៀត ។

## V- ជីវភាពប្រជាជន និង ផលប្រយោជន៍ម្សៅវល្លិរមៀត

### ១. ជីវភាពប្រជាជនក្នុងការរកវល្លិ និងផលិតម្សៅវល្លិរមៀត

តាំងពីដើមរៀងមក អ្នកដែលទៅរកវល្លិរមៀត តែងជួបនឹង បញ្ហាលំបាកៗ ខ្វះខាតលើបញ្ហាជីវភាពខ្លាំងណាស់ ទោះបីសព្វថ្ងៃ នេះ គេកាប់វល្លិយកមកលក់ក៏ពិតមែន តែជីវភាពគេនៅតែខ្វះខាត ដដែល ព្រោះវល្លិដែលកាប់បាន ត្រូវលក់ទៅឲ្យម្ចាស់សិប្បកម្ម ផលិតម្សៅវល្លិរមៀត ក្នុងតម្លៃទាបបំផុត ដោយក្នុងមួយគីឡូតម្លៃ

១- ទស្សនាវដ្តី ឥន្រ្ទទេវី ចេញផ្សាយ ថ្ងៃទី ២៥ មករា - ១០ កុម្ភៈ ២០០១

មួយរយទៅពីររយរៀលប៉ុណ្ណោះ ។ នៅក្នុងការផលិតម្សៅល្ហិ-ងរមៀតនេះ ម្ចាស់សិប្បកម្មផលិតម្សៅ បានចែកកម្មករជាពីរផ្នែក មួយផ្នែកសម្រាប់ផលិតចេញជាម្សៅ បានទទួលប្រាក់ខែ និង អាហារ ៣ ពេល ឯមួយផ្នែកទៀតជាអ្នកកាប់វល្លិ គ្មានប្រាក់ខែទេ គឺកាប់វល្លិយកមកលក់ ថ្លៃគិតជាគីឡូដោយខ្លួនឯង បើកាប់បាន វល្លិច្រើន ប្រាក់ក៏បានច្រើនទៅតាមនោះដែរ ។

ម្យ៉ាងទៀត វល្លិរមៀតតែកាប់ហើយ មិនមែនដុះភ្លាមៗឡើយ វាមានរយៈពេលរាប់ឆ្នាំឯណោះទើបដុះវិញ ដូច្នេះជីវភាពពួកគេ ចេះតែធ្លាក់ចុះដុនដាបទៅៗ ពីមួយថ្ងៃទៅមួយថ្ងៃ ព្រោះមិនសូវមាន វល្លិរមៀត ឲ្យពួកគេកាប់យកទៅលក់ ដើម្បីយកកម្រៃមកផ្គត់-ផ្គង់ជីវភាពគ្រួសារបានឡើយ ។

**២. ការប្រើប្រាស់ជាឱសថ**

រុក្ខជាតិវល្លិរមៀត មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ ប្រជាជនយកទៅប្រើប្រាស់ ធ្វើជាឱសថព្យាបាលរោគគ្រុនក្តៅ ។ លើសពីនេះទៅទៀត រុក្ខជាតិវល្លិរមៀត ត្រូវបានប្រជាជនខ្មែរកែ ច្នៃធ្វើជាឱសថបុរាណ និងឱសថសម័យ សម្រាប់ប្រើការក្នុងស្រុក ក៏ដូចជាយកទៅលក់ នៅតាមបណ្តាប្រទេសនានា ។

**- ឱសថបុរាណ**

ខណៈពេលដែលមនុស្សជាច្រើន ទូទាំងពិភពលោក កំពុង តែងាកទៅរកឱសថលោកខាងលិច ដើម្បីព្យាបាលរោគនោះ ហេតុ អ្វីបានជាប្រជាជនខ្មែរមួយចំនួន នៅតែប្រើប្រាស់ឱសថបុរាណទៀត ?

តើព្រោះតែឱសថបុរាណថោក ហើយមានប្រសិទ្ធិភាព ឬគ្រាន់តែជាទម្លាប់ដែលមិនងាយផុតរលត់ ?

ជាធម្មតា ប្រជាជនខ្មែរព្យាបាលរោគ តាមរយៈឱសថបុរាណដែលមានទម្លាប់តាំងពីបុរាណកាលមក ។ ឱសថបុរាណខ្មែរ គឺជាទម្រង់នៃការព្យាបាលរោគដោយធម្មជាតិ ដោយមានការផ្សំបញ្ចូលគ្នា រវាងឫសឈើ សំបកឈើ ស្លឹកឈើ និងផ្សំដោយធម្មជាតិមួយចំនួនទៀត ករណីដូចជាប្រភេទវល្លិជាដើម ។ ការផ្សែផ្សំឱសថបុរាណជាច្រើនមុខបញ្ចូលគ្នា អាចព្យាបាលជំងឺបានមួយរយមុខ ។

កាលពីមុន ប្រជាជនខ្មែរសម័យបុរាណ សរសេររូបមន្តឱសថបុរាណនេះ តាមការចេះដឹងដោយខ្លួនឯង ។ រហូតមកដល់ពេលបច្ចុប្បន្ន របៀបព្យាបាលនេះ នៅតែបម្រើប្រជាជនខ្មែរដដែល ។ ការប្រើប្រាស់ថ្នាំបុរាណ មានផលប៉ះពាល់តិចតួច ព្រោះផលិតតាមលក្ខណៈធម្មជាតិសុទ្ធសាធ មិនមានប្រើសារធាតុគីមីទេ ។

-ឱសថសម័យ

វក្ខជាតិវល្លិរមៀត មិនត្រឹមតែជាឱសថបុរាណ សម្រាប់ព្យាបាលរោគប៉ុណ្ណោះទេ ថែមទាំងជាឱសថសម័យទៀតផង ។ គេអាចយកមើមវល្លិរមៀត ទៅកែច្នៃធ្វើជាគ្រឿងសម្អាង ថ្នាំពណ៌ផ្សេងៗ និង ធ្វើជាថ្នាំពេទ្យ [១] ។

---

១ - លោក អាចារ្យ អ៊ុច សាភួន សមាជិកឆ្លើយឆ្លងខេត្តកោះកុង

## សន្និដ្ឋាន

រុក្ខជាតិវល្លិរមៀត ជារុក្ខជាតិមួយប្រភេទ ដែលមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ព្យាបាលរោគ នាសម័យដែលវិទ្យាសាស្ត្រពុំទាន់មានការរីកចម្រើន រហូតមកដល់សម័យបច្ចុប្បន្ន ដែលវិទ្យាសាស្ត្រមានការរីកចម្រើនយ៉ាងខ្លាំង ។ ប្រជាជនខ្មែរយើងបានយកវល្លិរមៀតទៅផ្សំធ្វើជាថ្នាំខ្មែរ សម្រាប់ព្យាបាលរោគ លើសពីនេះទៅទៀតនោះ វល្លិរមៀត អាចកែច្នៃធ្វើជាថ្នាំពេទ្យ ថ្នាំពណ៌ គ្រឿងសម្អាងផ្សេងៗ យកទៅលក់នៅក្រៅប្រទេសថែមទៀត ។

ការកាប់វល្លិរមៀត យកមកធ្វើជាថ្នាំខ្មែរ វាមិនប៉ះពាល់ដល់បរិដ្ឋានព្រៃឈើខ្លាំងពេកទេ ប្រការដែលយកចិត្តទុកដាក់ជាងគេ គឺការកាប់វល្លិរមៀត យកទៅផលិតចេញជាម្សៅ ព្រោះទីមួយវាបណ្ដាលឲ្យធនធានធម្មជាតិ ត្រូវបាត់បង់បន្តិចម្ដងៗ ដោយហេតុថាពេលនេះ ការកាប់វល្លិរមៀតចេះតែរុលទៅមុខ ពីមួយថ្ងៃទៅមួយថ្ងៃ ហើយនៅទីបំផុត រុក្ខជាតិវល្លិរមៀតនឹងត្រូវដាច់ពូជអស់ ។ ទីពីរកាកសំណល់រាវ និងសំណល់រឹង ដែលគេយកទៅចាក់ចោលនៅលើដី ក្នុងបឹង ត្រពាំង អូរ បានបង្កគ្រោះថ្នាក់យ៉ាងខ្លាំង ចំពោះសុខភាពប្រជាជន មច្ឆាជាតិ សត្វពាហនៈ សត្វព្រៃ និងគុណភាពដី ។ ជនដែលងាយរងគ្រោះដល់សុខភាពជាងគេគឺ កម្មករផលិតម្សៅវល្លិរមៀត ព្រោះគេត្រូវរងនូវជាតិពុល ដែលបង្កឡើងដោយសារជាតិអាស៊ីត អំបិល និងអ្នកដែលទៅកាប់រុក្ខជាតិវល្លិរមៀត

មកលក់ ព្រោះពួកគេត្រូវធ្វើដំណើរកាត់ព្រៃ ដែលមានសត្វសាហាវ សម្រាន្តក្នុងព្រៃឈើ ងាយនឹងកើតជំងឺផ្សេងៗណាស់ ជាពិសេស គឺជំងឺគ្រុនចាញ់សន្ធំ ។ ម្យ៉ាងទៀត ការឡើងទៅកាប់វល្លិ៍រមៀត ពីដើមឈើខ្ពស់ៗ ក៏ងាយនឹងទទួលគ្រោះថ្នាក់ផងដែរ ។

សរុបសេចក្ដីទៅ ទោះបីរុក្ខជាតិវល្លិ៍រមៀត មានសារៈប្រយោជន៍ អាចធ្វើជាឱសថសម្រាប់ព្យាបាលជំងឺគ្រុនក្ដៅ និងអាចកែច្នៃធ្វើជាគ្រឿងសម្អាង និងថ្នាំពណ៌ផ្សេងៗបានក៏ពិតមែន តែវាក៏បង្កគ្រោះថ្នាក់ច្រើនណាស់ដែរ ហើយមុខរបរកាប់វល្លិ៍រមៀតយកទៅលក់នេះ ក៏មិនបានជួយឲ្យជីវភាពប្រជាជន បានប្រសើរឡើងដែរ អ្នកដែលចំណេញ គឺមានតែម្ចាស់សិប្បកម្មផលិតម្សៅវល្លិ៍រមៀតតែប៉ុណ្ណោះ ។



( រូបភាពរុក្ខជាតិវល្លិ៍រមៀតដែលវារនៅនឹងដី )

# ប្រវត្តិបាពយណ៍អណ្តែត (១)

រៀបរៀងដោយៈ លោក ចិន តាក់
អតីតមន្ត្រីមន្ទីរធម្មការខេត្តព្រៃវែង

ទួលអស់លោកបាពយណ៍អណ្តែតនេះ មានស្ថានភាពជាទីទួលមួយតូច ហាក់ដូចជាកោះ ឋិតនៅកណ្តាលវាលទំនាបនៃស្រែប្រាំង និងមានបឹងព័ទ្ធជុំវិញខាងត្បូងក្រុងព្រៃវែង ចម្ងាយ ៣ គ.ម និងនៅខាងលិចភូមិបាពយណ៍ (ពីមុនគេហៅបាពយណ៍ព្រេច) ឃុំបាពយណ៍ ស្រុកកំពង់លាវ ចម្ងាយប្រហែល ២ គ.ម។

ទីនេះមានស្ថាបត្យកម្មពីបុរាណ និងសម័យជាច្រើន ព្រមទាំងដើមឈើធំៗ មានឈើទាល ១២ ដើម សំរោង អំពិល ចាមរីជ្រៃណាប កញ្ជើបាចដាច ពោធិ៍ ស្វែង ថ្នាន់ ។ល។ ប្រកបដោយម្លប់ត្រឈឹងត្រឈៃ ជាទីរមណីយនៃបក្សាបក្សីគ្រប់ប្រភេទ ហ៊ុំព័ទ្ធដោយវល្លិជាតិ រុក្ខជាតិ តិណជាតិគ្រប់យ៉ាងជាព្រៃនាមជុំវិញ ។ ជាកន្លែងបូជនីយដ្ឋាន និងរមណីយដ្ឋាន គួរជាទីគយគន់ និងកែកម្សាន្តអផ្សុកសម្រាប់ភ្ញៀវទេសចរ ។ មានផ្លូវមួយយ៉ាងត្រង់ចេញពីក្រុងព្រៃវែង ភូមិជូនរៀនទៅ ផ្លូវនេះប្រើបានតែខែប្រាំងទេ ខែវស្សា

(១) អ្នកខ្លះហៅថា ទួលអស់លោក ( នៅខេត្តព្រៃវែង )

ត្រូវប្រើដោយទូក ឬកាណូត ។ ឥឡូវនេះ មានផ្លូវលើកថ្មីមួយជាប់ពីភូមិបាកយណ៍មកទៀត ទើបតែលើកឆ្នាំ ១៩៩២ ។

នៅពេលទឹកទន្លេឡើងជោរជន់ លិចភូមិអ្នកស្រុកក៏ដោយ ក៏ទួលនេះមិនដែលលិចដែរ មើលពីចម្ងាយទៅ ឃើញហាក់ដូចជាកោះមួយអណ្តែតលើទឹក ។

តាមចាស់ៗនិយាយថា ដីទួលនេះ បើមានមនុស្សចូលទៅទស្សនាច្រើនលើទួលនេះ បើដើរនៅផ្នែកខាងត្បូងច្រើន ខាងជើងត្រូវបះឡើង បើដើរខាងលិចច្រើន ត្រូវបះខាងកើត ។ល។ គឺហាក់ដូចជាអណ្តែតនៅលើទឹក (នៅពេលទឹកទន្លេឡើងច្រើន) ទើបបានជាហៅឈ្មោះថា " ទួលបាកយណ៍អណ្តែត " ពីព្រោះទីនេះ ឋិតនៅកណ្តាលបឹងទឹកជុំវិញ ។ ពេលរដូវប្រាំង គេមើលឃើញស្រូវប្រាំងពាសពេញវាលបឹង លេចពណ៌ខៀវស្រងាត់ បោកបក់រវិចដោយវាយោរំភើយ គួរឲ្យចង់គយគន់ទស្សនា ។

តាមជំនឿពីបុរាណមក ប្រជាជននៅតំបន់នេះ តែងនាំគ្នាទៅគោរពបូជា និងការបន់ស្រន់ដោយគ្រឿងសក្ការៈផ្សេងៗដល់វត្ថុស័ក្តិសិទ្ធិនៅទីនោះ សុំសេចក្តីសុខ-ចម្រើន មង្គលសិរីសួស្តី ឡើងបុណ្យស័ក្តិ រកស៊ីមានបាន ឬសុំបញ្ចៀសគ្រោះកាចចង្រៃជាដើមដល់ខ្លួន និងគ្រួសារ ។

ជារៀងរាល់ឆ្នាំ គេតែងនាំគ្នាទៅធ្វើពិធីបុណ្យជំម្តង ឬពីរដង នៅពេលមុនចូលឆ្នាំ ឬថ្ងៃចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌជាដើម

ពេលនោះគេមានជួលវង់ភ្លេងខ្មែរបុរាណ និងភ្លេងពិណពាទ្យ គ្រឿងសក្ការៈបូជាមាន ទៀន ធូប ភ្ញីផ្កា ម្ហូបអាហារគ្រប់មុខ យកទៅថ្វាយដល់បារមីនៃវត្ថុស័ក្តិសិទ្ធិ និងព្រះរតនត្រ័យ ( ពិធីបុណ្យធ្វើតាមប្រពៃណីព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាខ្លះៗ ) មានអ្នកខ្លះធ្វើពិធីបញ្ចាន់រូបផងដែរ ។

សូមបញ្ជាក់ថា អ្នកស្រុកនៅតំបន់នេះ ឬតំបន់ឆ្ងាយៗ តែងចូលមកបែបន់ជារៀងរាល់ថ្ងៃ ដោយមានបូជាថ្វាយជាលុយកាក់ បេក ស្លាធម៌ ដូង ឬវត្ថុផ្សេងៗ តាមតម្រូវការនៃវត្ថុស័ក្តិសិទ្ធិមួយព្រះអង្គៗ ដែលគេនិយមហៅថា " អ្នកតា ឬបង់បត់ " នៃទួលអស់លោកបាភយណ៍អណ្តែត ឬគេហៅកាត់ថា " ទួលអស់លោកៗ " ។ ពីព្រោះគេមានជំនឿតៗគ្នាមកថា ទីនេះជាទីប្រជុំធំនៃរូបបារមីវត្ថុស័ក្តិសិទ្ធិដ៏ខ្លាំងពូកែធំៗ តាំងពីបុរាណកាលមកម្ល៉េះ ។

អស់លោកស័ក្តិសិទ្ធិខ្លាំងពូកែទាំងនោះ រាប់ជាមេធំៗ មានឈ្មោះជាច្រើនដូចតទៅនេះ ៖

១- ព្រះអស់លោក មុនីរតន៍ គ្រឿងតង្វាយសម្រាប់បូជាមាន : ខោស អាវស ពានាស បារី ស្លាម្លូ ផ្កាឈូក ទឹកអប់ ទឹកផ្តិល និងបាយសី ។

២- អស់លោករំពាត់មាស គ្រឿងបូជាមាន : រំពាត់មាស១ សាច់ នុំ ទឹកអប់ ផ្កា ។

៣- អស់លោក វេស្សវ័ណ គ្រឿងបូជាមាន : សៀវភៅ

ហោភ សាស្ត្រាស្លឹករឹត សាច់ នុំ ។

៤- អស់លោក កុវេរភ គ្រឿងបូជាមាន : សាច់ នុំ គ្រឿងស្រវឹង (អាការសោហារ) ។

៥- អស់លោក ព្រះបាទជើងធំ គ្រឿងបូជាមាន : សាច់ នុំ ទឹកអប់ ។

៦- អស់លោក ដំបងដែក គ្រឿងបូជាមាន : ដំបងដែក១ ជ្រូកខ្វៃ មាន់អាំង នំអាកោ គ្រឿងស្រវឹង ។

៧- អស់លោក ព័ន្ធហក់ធក់វៃ គ្រឿងបូជាមាន : មាន់ស្ងោ នំខ្ចប់កញ្ចប់ គ្រឿងស្រវឹង ។

៨- អស់លោក យាយទេព ឬយាយម៉ៅ គ្រឿងបូជាមាន : សំពត់ស អាវស ពានាស ចេក មូស្លា ផ្កា ទឹកអប់ ថ្នាំជក់ បាយសី ។

៩- អស់លោក យាយសក់ស គ្រឿងបូជាមាន : ដូចយាយម៉ៅ ។

១០- អស់លោក តាក្រហមក គ្រឿងបូជាមាន : ក្រណាត់ក្រហម សាច់មាន់ សាច់ជ្រូក បារី គ្រឿងស្រវឹង ។

ទីទួលនេះ មានប្រវត្តិរឿងដែលចាស់ៗ តំណាលតៗគ្នាមកថា ៖

កាលពីព្រេងនាយយូរលង់ណាស់មកហើយ មានមេទ័ពខ្មែរដ៏ខ្លាំងពូកែម្នាក់ មាននាម និងគោត្តនាមមិនប្រាកដ បាននាំពល

សេនាជាច្រើន ធ្វើដំណើរជិះសំពៅតាមផ្លូវទឹកតាមដងទន្លេ លុះធ្វើដំណើរមកដល់ទីនេះ សំពៅនេះក៏លិចក្លិប ដោយព្យុះសង្ឃរា និងរលកទឹក ។ មេទ័ពព្រមទាំងសេនា បាននាំគ្នាហែលឆ្លងទឹកមកស្នាក់អាស្រ័យនៅលើទួលនេះ ដោយឥតមានគ្រោះថ្នាក់នរណាម្នាក់ឡើយ ។ ទើបបានជាពីបុរាណកាល ទួលនេះមានឈ្មោះ គេហៅម្យ៉ាងទៀតថា " **ទួលសំពៅលិច** " ។ តែឥឡូវនេះពាក្យថាទួលសំពៅលិចនេះ បានបាត់ឈ្មោះជាយូរមកហើយ នៅតែឈ្មោះថា បាភយណ៍អណ្តែតទៅវិញ ។

មួយទៀត តាមឯកសារនៃមន្ទីរវប្បធម៌ខេត្ត ក៏បាននិយាយដូចគ្នា តែគេបានបញ្ជាក់ថា យើងបានសាកសួរព័ត៌មានពីអ្នកភូមិនៅស្រុកជិតៗនេះ ( ភូមិបាភយណ៍ខាងលិច ) ឈ្មោះលោកតា ឈឹម យ៉ាន់ អាយុ ៧៨ ឆ្នាំ ( ពេលសួរនៅឆ្នាំ ១៩៩៩ ) គាត់បានតំណាលថា តាមចាស់ពីមុនៗ និយាយតគ្នាមកថា ពីដើមទឹកនៃងបឹង ឬស្រះជុំវិញទួលនេះ មានទឹកជ្រៅៗណាស់ មិនអាចចុះដើរបានឡើយ ចង់ទៅកាន់ទីទួល ទាល់តែមានទូក ឬហែលឆ្លងទើបទៅរួច ។ នៅពេលទឹកទន្លេឡើងច្រើន មានសារាយ និងរុក្ខជាតិផ្សេងៗ បានបក់បោកតាមរលកទឹក រសាត់អណ្តែតមកលើទីទួលនេះ គរជាគំនរយ៉ាងធំ កើតបានជាទីទួលនេះយ៉ាងខ្ពស់ឡើងថែមទៀត បានជាគេឲ្យឈ្មោះទួលនេះថា " ទួលសារាយអណ្តែត " ហើយក៏ក្លាយមកជាទួលបាភយណ៍អណ្តែតៗ ទល់សព្វថ្ងៃនេះ ។

ទួលនេះ មានឈ្មោះល្បីពូកែស័ក្តិសិទ្ធិជិតឆ្ងាយជាទូទៅ ។ តាមសំដីលោកតា ចន្ទ ប្រាជ្ញ ( មន្ត្រីសាធារណការចូលនិវត្តន៍ ) អាយុ ៧០ ឆ្នាំ នៅភូមិជូនរៀន ខុនគាត់មានដើមកំណើតនៅខេត្តស្វាយរៀង ។ គាត់បានមកធ្វើការនៅមន្ទីរសាធារណការខេត្តព្រៃវែង តាំងពីឆ្នាំ ១៩៥២ រហូតមកដល់សព្វថ្ងៃ គាត់ថា ចំពោះបារមីស័ក្តិសិទ្ធិនៃទួលនេះ មិនមែនមានតែ ១០ រូប ដូចខាងលើនោះទេ នៅមានច្រើនទៀត គាត់នៅចាំបានខ្លះៗ ដូចជា ៖

១- អស់លោកបាក់យណ៍អណ្តែត ជាមេធំប្រចាំការ

២- អស់លោកព្រះប្រាំ ( នៅវាលព្រះប្រាំ សព្វថ្ងៃក្លាយតាមសំដីអ្នកស្រុក ជាវាលប៉ប្រាំ ) កាលពីដើមមានដើមពោធិ៍មួយដើមដុះនៅកណ្តាលវាល តែឥឡូវនេះបានបាត់ស្រមោលទៅហើយ ( ទើបបាត់ក្នុងពេលថ្មីៗនេះ ) ដោយអ្នកស្រុករុករានយកដីធ្វើស្រែ ។ វាលនេះឋិតនៅខាងកើតក្រុងព្រៃវែង ។

៣- អស់លោក ដុងខ្វាង នៅផ្លូវទៅភូមិជើងទឹកខាងជើងក្រុងព្រៃវែង ។

៤- អស់លោក ព្រះធាតុ នៅខាងទិសនិរតីនៃក្រុងព្រៃវែង ។

គាត់មានប្រសាសន៍ថា បារមីនៃវត្ថុស័ក្តិសិទ្ធិទាំងនោះ ជាបារមីថែរក្សាខេត្តព្រៃវែងទាំងមូល ។

ហេតុនេះ បានជាប្រជាជននៅតំបន់នេះ គេមានជំនឿខាង

ណាស់ គេនៅតែគោរពបូជាហូតទល់សព្វថ្ងៃ ។ កាលណាគេធ្វើការបែបទ់ តែងបានសម្រេចដូចបំណង ឲ្យតែអ្នកនោះកាន់សច្ចៈ សុចរិត ទៀងត្រង់ និងមានជំនឿ ។

ជាក់ស្ដែង សម័យសង្គ្រាមពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ទីកន្លែងនេះ ជាសមរភូមិក្ដៅគគុក យ៉ាងសាហាវក្រៃលែង ( លោកតា ចន្ទ ប្រាជ្ញ គាត់ក៏នៅទីនេះដែរ ) មានការប៉ះទង្គិចគ្នាស្ទើររាល់ថ្ងៃ ទោះជាគ្រាប់បែក គ្រាប់ផ្លោង ឬគ្រាប់កាំភ្លើងយន្តស្រោចស្រពដូចទឹកភ្លៀង ទៅលើទីក្រុងក៏ដោយ ក៏គ្មានគ្រោះថ្នាក់ជាធំដុំ ដល់ប្រជាជន ឬផ្ទះសំបែងឡើយ ។

គាត់បានតំណាលរឿងមួយទៀតថា៖ កាលពីសម័យសង្គមរាស្ត្រនិយម ពីឆ្នាំ ១៩៥៥ មានចិនម្នាក់ឈ្មោះ ចិក បេ រកស៊ីលក់គ្រឿងសំណង់ គ្រឿងដែក នៅផ្សារព្រៃវែង គាត់បានទៅបែបទ់អស់លោកអ្នកតា បាភយណ៍អណ្ដែត សុំផ្សងព្រេងឲ្យត្រូវឆ្នោត. គាត់ក៏បានត្រូវឆ្នោតស័ក្តិសិទ្ធិដូចបំណងមែន គឺត្រូវបានរង្វាន់ធំ ( ហាសិបម៉ឺនរៀលក្នុងសម័យនោះ ) គាត់មានជំនឿនឹងគ្រេកអរខ្លាំងពេក បានសង់ស្ពានមួយតូច អំពីដែក ស៊ីម៉ង់ត៍ឆ្លងស្រះមួយពីទួលអស់លោក មកទួលយាយទេព ផ្នែកខាងជើងចម្ងាយប្រហែល ២០ ម សម្រាប់ដើរឆ្លងទៅមក ទុកជាកិច្ចតបស្នងក្នុងបំណងត្រូវឆ្នោត ចិននោះក៏ទៅនៅស្រុកចិនបាត់ទៅ តាំងពីនោះមក ។

ទីទួលនេះ ពីដើមមានព្រៃទាម ក្រាស់ឃ្មឹកព័ទ្ធជុំវិញ

ពិបាកចូលទៅកាន់ទីទួលណាស់ គឺមានច្រកចូលតែមួយ ពីទិសខាងកើតប៉ុណ្ណោះ មានក្លោងទ្វារពីរធ្វើអំពីឈើ មានរូបអ្នកតាដំបងដែកអំពីថ្ម ឈរអោមផ្លូវចូល តែឥឡូវនេះ ត្រូវបានបាត់បង់អស់ទៅហើយ សព្វថ្ងៃមានដើមត្នោតមួយដើម អាយុប្រហែលជាង ១០០ ឆ្នាំ ពីព្រោះកាលលោកតា ចន្ទ ប្រាជ្ញ គាត់នៅពីក្មេង បានចូលទៅបែបទ់សុំសុខសួស្តី គាត់ឃើញដើមត្នោតនេះ មានកម្ពស់ដូចសព្វថ្ងៃទៅហើយ ( បើគិតពីឆ្នាំ ១៩៥០ មកទល់ឥឡូវនេះ វា ៥១ ឆ្នាំ ( ២០០១ គ.ស ) ។

កាលពីទៅមានព្រៃច្រើនក្រាស់ឃ្មឹកនៅឡើយ ទីនេះមានសត្វអាសិរ្ពិសជាច្រើន ដូចជាពស់វែកក្របី វែកស្រវែង វែកទោមវែកដំបូក ពស់ត្បាល់ ពស់ថ្លាន់ ក្រពើ ។ល។ ជ្រកកោនទៅទីនេះ ( សព្វថ្ងៃក៏នៅមានខ្លះៗដែរ ជាសត្វធំៗទៀតផង តែពុំដែលមានគ្រោះថ្នាក់អ្វីដល់កូនចៅអ្នកស្រុកទេ ពីព្រោះគេជឿថា ជាសត្វរបស់អស់លោកអ្នកតាចិញ្ចឹម គេពុំសូវបានជួបប្រទះទេ កម្របានជួប បានឃើញណាស់ បើសិនជារណាបានជួប បានឃើញវិញគេថា ទាល់តែអស់លោកឲ្យឃើញ ទើបឃើញ ហើយគេក៏ពុំហ៊ានបៀតបៀនវាដែរ ទុកឱកាសឲ្យវាលូនចេញ ទៅដោយសម្រួល ។

តាមប្រសាសន៍របស់លោកយាយ នាម សាត អាយុ ៧២ ឆ្នាំ សព្វថ្ងៃជាដូនជីនៅវត្ត សាំងសាមី គាត់ត្រូវជាក្មួយរបស់លោកយាយ

ម្នាក់ទៀតឈ្មោះ យាយតេង នៅភូមិដូនរៀន សព្វថ្ងៃគាត់មានអាយុជាង ៩០ ឆ្នាំហើយ គាត់បានតំណាលថា កាលក្នុងឆ្នាំ ១៩៨៩ គេបានជួសជុលកុដវិហារចាស់នេះឡើងវិញ ។ នៅខាងក្រោយបល្ល័ង្កព្រះ មានរន្ធធំៗជ្រៅជាច្រើនកន្លែង ដោយខ្លាចស្រុតបាក់បល្ល័ង្កព្រះ គេក៏យកថ្មជាច្រើនទៅទម្លាក់ចូលរន្ធនោះ ដើម្បីបុកឲ្យណែនកុំឲ្យបាក់ដីទៀត ។ គាត់តំណាលថា លោកយាយ តេង បានទៅអង្គុយរើសដុំថ្មដាក់ចូលទីងគេដែរ ស្រាប់តែអ្នកជិតខាងផ្អើលចោឡោ ឃើញពស់ធំមួយកាងពន្លាក់ ហើយខ្ចី ធ្វើក្បាលងើៗ ពីក្រោយលោកយាយ តេងផ្ទាល់ ប៉ុន្តែយាយតេងឥតបានឃើញទេ ទាល់តែប្រាប់ទើបបានដឹង អ្នកក្រៅពីនោះ ឥតបាននិយាយស្តីអ្វីឡើយ . នៅស្ងៀមស្ងាត់ទាំងអស់គ្នា ខ្លាចខុសពាក្យ ខុសសំដី តែខ្លាចព្រឺខ្លួនគ្រប់ៗគ្នា មួយស្របក់ក្រោយមកពស់នោះ ក៏លូនចូលទៅក្នុងរន្ធធំបាត់ទៅ ( ពស់នោះទំនងជាពស់ត្បាល់ ) ។

ទីទួលនេះ តាមមតិចាស់ៗខ្លះទៀតថា កាលពីដើមជាដីដែលគេកែនមនុស្សឲ្យលើកថែមទៀត លើដីទំនាបដែលមានស្រាប់ សម្រាប់យកទឹកធ្វើស្រែប្រាំងផង សម្រាប់មេទ័ពខ្មែរពីបុរាណ ធ្វើបន្ទាយស្នាក់នៅផង ( ប្រហែលជាមេទ័ពលិចសំពៅកែនឲ្យលើក ) សមទីងពាក្យថា " បាភយណ៍ដែលមានន័យថា ភាលបឹង ឬអាងទឹក ភាលស្រះទឹក ដែលធ្វើដោយដៃមនុស្ស ដូចបាភយណ៍ទឹកថ្លា

(សៀមរាបអង្គរជាដើម) ។

មេទ័ពលិចសំពៅនោះ បានបោះជំរំនៅទីនេះ ដើម្បីការពារព្រះនគរ ឬក៏ធ្វើចំបាំងជាមួយប្រទេសជិតខាង ពីព្រោះកន្លែងនេះមានទឹកព័ទ្ធជុំវិញស្រួលការពារខ្លួន ហើយក៏នៅជិតទួលមួយទៀតដែរ ចម្ងាយប្រហែល ៤ គ.ម ខាងត្បូងទួលអស់លោកបាភយណ៌អណ្តែតនេះ ក៏ជាកន្លែងបោះជំរំទ័ពដូចគ្នាដែរ ។ ទួលនេះ គេហៅថា " ទួលសំរោង " ព្រោះមានដើមឈើសំរោងដុះនៅទីនោះ ។ សព្វថ្ងៃក៏ជាបន្ទាយមួយ សម្រាប់កងទ័ពនៅការពារខេត្តក្រវ៉ាត់ក្រុងដែរ ។

(នៅមានត )

## ច្បាប់បុរាណ

អាវុធជាវមុតទុកក្នុងស្រោម
ចំណោះចេះព្រមតែក្នុងក្បូន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន
ដល់ជួនត្រូវការអោរចិត្ត ។

<u>កំណាព្យ</u>

# ត្រូវតែស្គាល់ព្រះពុទ្ធសាសនាឱ្យបានច្បាស់

*(បទពាក្យ ៧)*

ហៃជនប្រុសស្រីទាំងឡាយអើយ គួរកុំកន្តើយគិតជាថ្មី
រៀងមានកុលាក់ធ្លាក់អវិចី នាំគ្នាលកលែសាងសីលទានៗ
ត្បិតពេលឥឡូវយើងឃើញជាក់ អ្នកដែលទុចអាក់ហើយមិនហ៊ាន
កាន់នេះបោលនោះថាភប់លាន មិនចង់ចូងស្ពានខាចលោបាក់ៗ
ប្រទេសខ្មែរយើងពីបុរាណ ដូនតាគាត់បានរួមស្មោះស្ម័គ្រ
គោរពព្រះពុទ្ធជាពុំនាក់ ចិត្តមិនអល់អាក់ស្រួលហឫទ័យៗ
ព្រោះគាត់យល់ថាព្រះសាស្តា ជាគ្រូទេព្តានិងប្រុសស្រី
មានហេតុផលច្បាស់មិនបំភ័យ ជនក្នុងលោកិយបានសុខា ៗ
ព្រះពុទ្ធសាសនាគឺកម្មផល ធ្វើមិនផល់ក្តីទុក្ខា
ធ្វើអាក្រក់តែងចុះកាន់និរយា សព្វសត្វមនុស្សាឃើញជាក់ច្បាស់
ព្រះធម៌ព្រះពុទ្ធហាមបាបំ អទិន្នាទានំជនក្រៅផ្ទះ
ចងកាមនិងជម្ពុះក៏មានម្ចាស់ មុសាវាទណាស់ត្រូវកំចាត់ ៗ
មាមផឹកសុរានិងមេរ័យ នាំឲ្យក្សិណក្ស័យចាករសាត់
នាំកើតប្រមាទមិនប្រយ័ត្ន ធ្លាក់ក្នុងវិបត្តិគុកងងឹត ៗ
គាត់ឃើញយ៉ាងនេះទើបគាត់ជឿ គាត់មានជំនឿព្រោះបានគិត
គឺគ្មានអ្នកណាមកបង្ខិត គ្មានជនណាពិតឲ្យថ្ងៃការ ៗ

តែពេលឥឡូវគេព្រងើយ ទៅធ្វើកន្តើយឥតពិចារណ៍
នាំគ្នាប្រមាទជាឥតការ ផលអ្វីចេះជាតាមតែឯង ។
ដោយត្រង់អ្នកនោះមិនយល់ពិត ចេះនាំគ្នាគិតមិនរអែង
មិនយល់ព្រះធម៌ទ្រង់សម្តែង ឃើញខុសខ្លួនឯងជាប្រពៃ ។
ធ្វើបុណ្យយល់ថាគ្មានបានផល យល់ថាមិនសល់ទ្រព្យមានន័យ
ធ្វើអស់ទៅហើយតើបានអ្វី ប្រុសស្រីដេកអត់តែងដែល ។
ធ្វើបុណ្យទីងលោកគ្មានបានការ យកឲ្យបិតាគ្មានតំណោល
មិនស្តាប់មាតាខំប្រឹងហែល ធ្វើទានទីងថែលជាល្អជាង ។
ធ្វើបុណ្យស្លាក់ស្ញើរនៅមិនជាក់ ភ័យខ្លាចតែធ្លាក់មិនងាយលាង
ធ្វើទានព្រោះខ្លាចភ័យពង្វាង បើកពាំងព្រោះខ្លាចអត់ទឹកប្រើ ។
មានទុក្ខកើតមកទើបកង្វល់ នាំគ្នាទីកដល់ព្រះដំណើរ
ធ្វើសីលព្រោះខ្លាចគេបញ្ចើ ឲ្យគេសរសើរថាខ្លួនពេញ ។
អ្នកខ្លះមិនចេះប្រឹងនិយាយ រៀបរាប់ពង្រាយឲ្យចំណេញ
ពោលអួតក្រអើងនេះណាមិញ ធម៌អញធ្លាប់ពីដើមការ ។
បែបចេះស្លាក់ស្ញើរល្ងើឥតបទ នៅប្រឹងអំណាត់ទៅចចារ
បង្ខូចឱវាទព្រះសម្មា ដែលប្រោសទេសនាជាច្រើនឆ្នាំ។
ធ្វើបុណ្យលុះណាគេបបួល ប្រែប្រួលព្រោះខ្លាចគេចំណាំ
ធ្វើហើយបែរភ្លេចអស់បណ្តាំ ម៉ែផ្តាំថាធ្វើហើយកុំស្តាយ ។
ពេលលោកបិណ្ឌបាតដៃទ្របាទ សង្វាតលាចេញមិនជិនណាយ
លោកនៅឯនាយឯងនៅអាយ យកបាយមួយដុំដាក់ឲ្យទៅ។

កុំឲ្យនៅយូរឈរមុខផ្ទះ    ធ្វើបែបរូតរះទាំងមោហ៍នៅ
យកបាយមកដាក់មិនចង់ត្រូវ    ធ្វើមុខកំប្រូវបាយជ្រុះអស់ ។
នេះហៅអ្នកកាន់បែបល្ងង់ខ្លៅ    យកសជាខ្មៅមិនដឹងសោះ
ជឿឲ្យតែកុំយកបង់បោះ    កុំឲ្យតែខ្សោះច្បាប់វេជ្ជភជ
រីអ្នកផ្សព្វផ្សាយវត្តមាន    ស្រែកឃ្លានអានខុសដូចមមាច
អ្នកធ្វើអេះអុសដូចផ្ទុះលាជ    ពាក្យបាលីជ្រាចខូចដោយសារ ។
ព្រោះហេតុតែខ្លួនទៅមិនដឹង    ខំប្រឹងប្រាជ្ញព្រោកឥតបានការ
មិនគិតរៀនរកឯកសារ    មិនព្រមយាត្រាសួរអ្នកប្រាជ្ញ ។
ព្រះពុទ្ធត្រាស់ថាមុនជឿអ្វី    ត្រូវចេះសខីដោយអង់អាច
ត្រូវយកបញ្ញាមកបន្សាច    កុំភ័យស្លុតខ្លាចគេមើលងាយ ។
ខំប្រឹងរក្សាចិត្តល្អស្អាត    ត្រូវចេះសង្វាតពង្រីករាយ
ស្រាវជ្រាវឯកសារណាឃើញងាយ    សឹមយកនិយាយប្រាប់ជន្នា ។
ព្រះទ្រង់សម្តែងឲ្យសច្ចំ    បង្ខាំងមុសាកុំឲ្យពារ
ធ្វើជាបណ្ឌិតកុំរញ្ជួភ    ស្រាយប្រាប់ជន្នាបើគេឆ្ងល់ ។
បើនិយាយអ្វីត្រូវរក្សា    កុំក្បត់វាចាលោមិនដល់
បើនិយាយអ្វីហើយកុំកង្វល់    គិតដល់ពាក្យថ្មីស្តីរៀបរៀង ។
ធម្មតាពួកព្រានអ្នកប្រមាញ់    ធ្វើព្រួញហើយបាញ់ត្រង់ឥតល្អៀង
បណ្ឌិតបញ្ញាដូចទឹកភ្លៀង    ខំរៀនរក្សាវាចាខ្លួន ។
ព្រះទ្រង់ប្រដៅឲ្យឃើញពិត    ហេតុមិនប្រឌិតលាក់បំពួន
ឃើញច្បាស់យល់ជាក់យ៉ាងខ្ជាប់ខ្ជួន    ប្រាប់គ្រប់ចំនួនឲ្យប្រតិបត្តិ ។

*អរិយមគ្គទាំងប្រាំបី      បរិស័ទប្រុសស្រីកុំកម្ចាត់*
*កាន់ទុកក្នុងខ្លួនកុំឲ្យបាត់      ចិញ្ចឹមតាមសក្យបានប្រសើរ ។*
*គេរៀនតាមបែបបទសម្ដី      ធម៌ជាសក្ខីគ្រប់ដំណើរ*
*តាមលំអានច្បាប់កាំជណ្ដើរ      មួយកាំយើងដើរមិនសង្វាត ។*
*ព្រះធម៌ប្រដៅឥតបីឈប់      រីរឿងសេពគប់ទ្រង់វៃឆ្លាត*
*ឲ្យរាប់រកមិត្តចិត្តល្អស្អាត      នោះមិនបង់ខាតជីពជន្មនាម ។*
*លះរឿងអាក្រក់ចោលឲ្យបាន      ទើបក្សាន្តមានឈ្មោះរស់រាល់យាម*
*ដំណើរផ្លូវឆ្ងាយមិនរាម      ទទឹមទទាមខ្លាចមុខក្រោយ ។*
*ព្រះពុទ្ធនិព្វានទៅហើយក្ដី      តែសព្វសំដីមិនដែលឆ្ងាយ*
*នៅត្រូវតាមគ្រប់បែបបណ្ដាយ      នេះជាអំណោយដល់ជន្មា ។*
*តែពេលឥឡូវយល់មិនច្បាស់      យកវត្តជាផ្ទះចោលធម្មា*
*បណ្ដេញលោកសង្ឃចាកវិហារ      សត្វទមិឡគ្រប់គ្នាសើចសប្បាយ ។*
*ទាំងនេះព្រោះហេតុយល់មិនដល់      អត់ខ្វល់ខ្លាចធ្លាក់ជាអន្ដាយ*
*សាសនាដទៃគេជិនណាយ      សប្បាយព្រោះឃើញឯងបែកបាក់ ។*
*រិះរកវិធីបង្កើតឈ្លោះ      បង្កជម្លោះមិនដែលអាក់*
*លែងខ្លាចប្រមាទរុញឲ្យធ្លាក់      ប្រាទចូលអន្ទាក់ខ្លួនវិនាស ។*
*ព្រះពុទ្ធមិនប្រាប់ឲ្យឈ្លោះគ្នា      មិនឲ្យចងពារលោនិកាស*
*តែយើងសព្វថ្ងៃធ្វើពីសពាស      ទីសទាសប្រខាំដូចជាសត្វ ។*

*(នៅមានត)*

*ដោយ* **ភិក្ខុ ឈន សម្បត្តិ**
*អតីតសមណសិស្សនៃពុទ្ធិកវិទ្យាល័យ*
*សម្ដេច* **ជា ស៊ីម** *ខេត្តតាកែវ*

# សុន្ទរកថា ឯកឧត្តម លី ឡាយស្រេង តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អាណត្តិទី ៣ ក្នុងពិធីផ្ទេរតំណែងរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

*ជាបឋម ទូលព្រះបង្គំខ្ញុំ*

*-សូមគោរពសម្តេច ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី ៣*

*-សូមគោរព អស់លោក លោកស្រី និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ នៃក្រសួងធម្មការ និងសាសនា*



*(រូបភាពក្នុងពិធីផ្ទេរ និងទទួលតំណែងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា)*

*ក្នុងនាមសម្តេច* **ហ៊ុន សែន** *នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទូលព្រះបង្គំខ្ញុំ សូមសម្តែងនូវសេចក្តីអបអរសាទរ*

ចំពោះឯកឧត្តម **ឃុន ហាំង** ដែលបានទទួលតំណែងជារដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បន្តពីឯកឧត្តម **ជា សាវឿន** សម្រាប់អាណត្តិទី ៣ នេះ ។ ហើយទូលព្រះបង្គំខ្ញុំ ក៏សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម **ជា សាវឿន** ដែលបានដឹកនាំក្រសួងនេះ ប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់ និងបាននាំមកនូវការគាំទ្រពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ តាមរយៈការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធក្រសួង ការបង្កើតច្បាប់សម្រាប់ផ្នែកធម្មការ សាសនា នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យប្រជារាស្ត្រមានសីលធម៌ និងគុណធម៌ល្អប្រសើរ សម្រាប់ការរស់នៅ ប្រកបដោយសុខសន្តិភាព និងសុវត្ថិភាព ។ ជាមួយកាតព្វកិច្ចដែលបានបំពេញអស់រយៈពេលប្រាំឆ្នាំកន្លងមកនេះ ឯកឧត្តមបានចំណាយអស់កម្លាំងកាយចិត្ត ប្រាជ្ញា ដើម្បីបម្រើជាតិមាតុភូមិ និងប្រជារាស្ត្រគ្រប់លំដាប់ថ្នាក់ នេះជាកាយវិការមួយដ៏រស់រវើកប្រកបដោយគតិបណ្ឌិត សម្រាប់ជាគំរូដ៏ល្អប្រសើរ សម្រាប់ប្រជារាស្ត្រខ្មែរគ្រប់រូបរៀនសូត្រ និងយកតម្រាប់តាម ។

សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវជាទីគោរព!

ក្រោមការកិច្ចទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់ របស់សម្តេច **ហ៊ុន សែន នាយករដ្ឋមន្ត្រី** និងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា** ដោយឈរលើស្មារតីស្នេហាជាតិ បង្រួបបង្រួម និងផ្សះផ្សារជាតិ បានរិះរកនូវរូបមន្តគតិយុត្តិធម៌មួយ ដើម្បី

ដោះស្រាយឲ្យខានតែបាន នូវវិបត្តិនយោបាយ ដែលជាប់គាំងអស់រយៈពេលជិតមួយឆ្នាំកន្លងមកនេះ ។ ចួងតាមលទ្ធផលនៃការបង្រួបបង្រួម និងផ្សះផ្សាជាតិនេះ បានញ៉ាំងឲ្យរដ្ឋាភិបាលថ្មីកើតចេញយ៉ាងពេញលេញ ដែលមានសម្ដេច **ហ៊ុន សែន** ជាប្រមុខ ជាមួយនឹងគោលនយោបាយដឹកនាំ ៧៣ ចំណុច ជាពិសេស សម្ដេចបានលើកឡើងនូវយុទ្ធសាស្ត្រ "**ចតុកោណ**" ដើម្បីធ្វើការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។

ទូលព្រះបង្គំខ្ញុំ សង្ឃឹមថា ចាប់ពីនេះតទៅ ជាមួយរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការថ្មី នឹងមានកិច្ចសហប្រតិបត្តិការយោគយល់ និងការអធ្យាស្រ័យគ្នាទៅវិញទៅមក ដោយមិនប្រកាន់និន្នាការនយោបាយណាមួយ ឲ្យស្របទៅនឹង ប្រសាសន៍របស់សម្ដេច នាយករដ្ឋមន្ត្រី គឺ "អាណត្តិនេះ យើងធ្វើអ្វី គឺធ្វើទាំងអស់គ្នា ដោយមិនប្រកាន់បក្សនេះ ឬបក្សនោះ " ។

ជាទីបញ្ចប់ ទូលព្រះបង្គំខ្ញុំ សូមថ្លែងនូវអំណរព្រះគុណ និងអរគុណ ចំពោះសម្ដេចនាយករដ្ឋមន្ត្រី ដែលបានផ្ដល់កិត្តិយសដល់រូបខ្ញុំ បានធ្វើជាតំណាងដ៏ខ្ពង់ខ្ពស់ នៅក្នុងពិធីផ្ទេរតំណែងនេះ ហើយក៏សូមប្រសិទ្ធិពរបវរមហាប្រសើរ ថ្វាយ និងជូនចំពោះសម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** សម្ដេច **ហ៊ុន សែន** និងសមាជិកសមាជិការាជរដ្ឋាភិបាលអាណត្តិទី ៣ ព្រមទាំងមន្ត្រី រាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងធម្មការ និងសាសនា ទាំងអស់ សូមទទួល

បានជោគជ័យលើការកិច្ចបម្រើជាតិ មាតុភូមិ និងសូមបានប្រកប ដោយពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លាងឃ្លាតឡើយ ។

**សូមអរព្រះគុណ អរគុណ!**

| |
|---|
| *ជនមានសាមគ្គីធម៌ មានតេជះ*<br>*អាចនាំមកនូវសេចក្ដីសុខ ។*<br>*សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយក*<br>*គណៈធម្មយុត្តិកនិកាយ* **ឥន្ទ ញ្ញាណោ (ត.ន.)** |

# សុន្ទរកថា
## ក្នុងពិធីផ្ទេរ និង ទទួលតំណែង
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
## ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៤

**សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**សូមគោរពឯកឧត្តមរដ្ឋមន្ត្រី**

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ទាំងអស់ជាទីស្នេហា

ក្នុងថ្ងៃដ៏មហោឡារិកនេះ ទូលព្រះបង្គំខ្ញុំ សូមសម្តែងនូវការដឹងព្រះគុណដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាតិ** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលលោកបានបាត់តាំងរូបខ្ញុំបាទ ។ ខ្ញុំបាទ ក៏សូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅផងដែរ ដល់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលលោកទទួលឲ្យរូបខ្ញុំ បំពេញតួនាទីក្នុងរាជរដ្ឋាភិបាលអាណត្តិទី៣ នេះ ។

ដូចឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បានជ្រាបស្រាប់មកហើយ បន្ទាប់ពីមានការកំណស្ទះ ផ្នែកនយោបាយអស់រយៈជិតមួយឆ្នាំកន្លងមកនេះ ដំណោះដោះស្រាយប្រកបដោយសេចក្តី

ក្លាហាន ដែលផ្អែកលើឧត្តមប្រយោជន៍ជាតិ ក៏បានចេញរួច ក្នុងនាមប្រមុខរាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា សម្តេចនាយករដ្ឋមន្ត្រី បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា ។ ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ដើម្បីរួបរួមគ្នាកសាងជាតិ ដូចមានក្នុងកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ចំណុចទី ៧១ បានចែងថា:

រាជរដ្ឋាភិបាល បន្តការលើកកម្ពស់ខាងសិទ្ធិសេរីភាព និងសាសនា លើកស្ទួយកម្មវិធី សាសនា ក្នុងការបណ្តុះស្មារតីសីលធម៌ គុណធម៌ និងវប្បធម៌សន្តិភាព ជូនប្រជាពលរដ្ឋ ដើម្បីធានាបាន នូវការរួមរស់សុខដុមរមនា ក្នុងសង្គមជាតិ ឧបត្ថម្ភព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ និងសាសនាដ៏ទៃទៀត តាមរយៈការជំរុញអភិវឌ្ឍន៍ ពុទ្ធិកសិក្សានៅគ្រប់កម្រិត និងការផ្តល់លទ្ធភាពឲ្យមានការសិក្សា ស្រាវជ្រាវស្របច្បាប់ទាំងឡាយក្នុងវិស័យសាសនាផ្សេងៗទៀត ។

តាងនាមឲ្យ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ក្នុងក្រសួង ធម្មការ និងសាសនា ខ្ញុំបាទសូមប្តេជ្ញាចិត្តដឹកនាំរិះរកមធ្យោបាយ ស្របតាមតួនាទី ភារកិច្ច និងក្នុងបរិដ្ឋានសុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម និងបរិដ្ឋានសមាហរណកម្មក្នុងតំបន់ និងពិភពលោក ដែលរដ្ឋាភិបាលប្រគល់ជូន អនុវត្ត

ការងារឲ្យមានប្រសិទ្ធិភាពខ្ពស់ ដោយសូមការគាំទ្រ និងការណែនាំដ៏ខ្ពង់ខ្ពស់អំពី **សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ** ដូចជាការលើកកម្ពស់សាសនាជាតិ ឲ្យបានកម្រិតស្មើប្រទេសដទៃទៀតជាដើម ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យ ថ្វាយ **សម្ដេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាតិ** ជូនសម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ឲ្យប្រកបដោយសុខភាពបរិបូរ និងបានទទួលជោគជ័យ ក្នុងការដឹកនាំមាតុភូមិជាតិ ដោយសន្តិភាព និងវឌ្ឍនៈភាពលើគ្រប់វិស័យ ខ្ញុំក៏សូមជូនពរដល់ឯកឧត្តម អស់លោក ដែលមានវត្តមានក្នុងពិធីនេះ ឲ្យជួបតែពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លាងឃ្លាតឡើយ ។

*សូមអរព្រះគុណ សូមអរគុណ !*



*(ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ចូលទស្សនាការិយាល័យកម្ពុជសុរិយា)*

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ព្រះវិស្ណុផ្ទំ សតវត្សទី ៩

ឆ្នាំទី ៥៨ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ

ព.ស. ២៥៤៨ គ.ស. ២០០៤

ភ្នំពេញ

រូបក្របខាងក្រៅ :

រូបចម្លាក់ ព្រះវិស្ណុផ្ទំក្បាលស្ពាន ឆ្លាក់នៅក្នុង សតវត្សទី ៩ នៅពេលដែលប្រារព្ធពិធី រាជាភិសេក ព្រះបាទជ័យវរ្ម័នទី ២ ឡើងគ្រងរាជ ។ ពិធីនេះ ប្រារព្ធធ្វើនៅលើភ្នំគូលេន ក្នុងសម័យកសាងក្រុងអង្គរ ។

ចាប់ពីពេលនោះហើយ ដែលយើងផ្ដើមគោរពព្រហ្មញ្ញសាសនាខ្លាំង ។

រូបថត : មជ្ឈមណ្ឌលឯកសារស្រាវជ្រាវ អារ្យធម៌ខ្មែរ
( CEDORECK )



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពដោយគណៈកម្មការមួយមាន :


នាយកការផ្សាយ : **ខួន វ៉ាន់ចន្ទី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** លោក **ទង់ សុផាវ៉ា**

លោក **ឆន់ ហ៊ិន** លោក **មៀច ប៊ុណ្ណ**

# គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ ឆេង ផុន ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម នុត ណារ៉ាង ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម ឃុន ហាំង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម ឈន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា ឆយ យីម៉ាង ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត នេត ឆារ៉ុម សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព (WCRP) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.

# មាតិកាអត្ថបទ

## I អក្សរសិល្ប៍ពុទ្ធសាសនា


- សេចក្ដីថ្វាយសព្ទសាធុការពរ
- ជីវិតមនុស្ស និងបញ្ហា (ត)........................... (ឈុន អៀម) ១
- ព្រះរតនត្រ័យ ....................................... (សេង សុភ័ណ) ១៣


## II អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ


- ព្រះនាងសរស្វតីក្នុងវប្បធម៌ខ្មែរ (ត) ............. (ហាម ឆាយលី) ២៥
- ឋានៈស្ត្រីក្នុងព្រះពុទ្ធសាសនា (តចប់) ...... (ព្រះមហា ឃីសុវណ្ណរតនា) ៣៥
- សេចក្ដីល្ងង់មានខ្លួនឯងជាសត្រូវ ........ (សមាគមធម្មិកសង្គហៈ ) ៤៦
- អាថ៌កំបាំង និងអត្ថន័យនៃប្រាសាទបាយ័ន............ (រស់ ណុល) ៥៩
- ប្រវត្តិបាកយណ៍អណ្ដែត (តចប់) ....................... (ចិន តាក់) ៧០
- អំពីការទាក់លលក ....................................... (មៀច ប៉ុណ្ណ) ៧៩
- កំណាព្យ. ត្រូវតែស្គាល់ព្រះពុទ្ធសាសនា...(តចប់).(ភិក្ខុ ឈុន សម្បត្តិ) ៨៨


## III កំណត់ និងប្រវត្តិការណ៍


- ព្រះជីវប្រវត្តិសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ............. ៩២
- សុន្ទរកថា នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ.................... ៩៦

# សេចក្តីថ្វាយសព្ទសាធុការពរ

នៅឱកាសដ៏ប្រកបដោយ សិរីសួស្តីជ័យមង្គល មហាប្រសើរ ក្នុងព្រះរាជពិធីចម្រើនព្រះជន្មាយុ ៨២ យាងចូល ៨៣ ព្រះវស្សា របស់ព្រះករុណាជាអម្ចាស់ ជីវិតតម្កល់លើត្បូង និងព្រះរាជពិធីរាជាភិសេក ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានឡើងសោយរាជសម្បត្តិ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាពិធីមានលក្ខណៈអធិកអធម ប្រកបដោយមោទនភាពយ៉ាងក្រៃលែង រកអ្វីមកប្រៀបផ្ទឹមស្មើពុំបាននេះ ។

**វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ** សូមព្រះរាជានុញ្ញាត ថ្វាយនូវព្រះពរ ចំពោះព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតា អតីតព្រះមហាក្សត្រ មហាក្សត្រិយានី ព្រមទាំងព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី នូវពុទ្ធពរទាំង៤ប្រការគឺ : អាយុ វណ្ណៈ សុខៈ ពលៈ សូមទ្រង់មានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីគង់នៅជាបរមសុខក្នុងសិរីរាជសម្បត្តិ និងគ្រប់គ្រងប្រទេសជាតិ ឲ្យបានសុខចម្រើនអស់កាលជាអង្វែងតទៅ ។

# ជីវិតមនុស្ស និង បញ្ហា (ត)

ព្រះតេជ.គ.ស្រី ធម្មានន្ទ
បកប្រែដោយ ឈន អៀម

## អំពីឧណ្ហកម្ម

នៅក្នុងច្បាប់ យោងតាមក្រមព្រហ្មទណ្ឌ ( របស់ប្រទេសម៉ាឡេស៊ី ) " គ្មានអំពើណាមួយជាបទល្មើស ដែលបានប្រព្រឹត្តឡើងដោយក្មេង មានអាយុក្រោមដប់ឆ្នាំទេ ។ ជាងនេះទៀត គ្មានអំពើណាមួយ ជាបទល្មើសដែលបានប្រព្រឹត្តឡើងដោយក្មេងមានអាយុលើសដប់ឆ្នាំ និងក្រោមដប់ពីរឆ្នាំ ដែលមិនទាន់មានបក្កភាព (maturity) នៃការយល់ដឹងគ្រប់គ្រាន់ ដើម្បីវិនិច្ឆ័យចរិត និងផលវិបាកនៃការប្រព្រឹត្តរបស់វា នាសម័យកាលនោះទេ " ។

មានសច្ចធារណ៍ (presumption) មួយ ដែលជាសេចក្ដីសន្និដ្ឋានផ្អែកលើសេចក្ដីពិតជាច់ខាត នៅក្នុងច្បាប់ថា ក្មេងក្រោមអាយុដប់ឆ្នាំ មិនមានសមត្ថភាពយល់ដឹង វែកញែកអ្វីត្រូវចេញពីអ្វីខុសបានទេ ទោះបីនៅក្នុងការពិត ក្មេងអាចបានធ្វើអំពើដែលគេបានហាមឃាត់ ដោយមានបំណងគិតទុកមុនក៏ដោយ ។

ប្រភេទក្មេងទីពីរ ដែលមានអាយុចន្លោះដប់ឆ្នាំ និងដប់ពីរឆ្នាំ

គឺឋិតនៅក្នុង " តំបន់ភ្លឺស្រាងៗ " ( តំបន់ចន្លោះយប់ និងថ្ងៃ ) ដែលនៅក្នុងតំបន់នេះ ក្មេងៗត្រូវបានរួចផុតពីការទទួលខុសត្រូវជាបទល្មើស វៀរលែងតែមានសេចក្ដីបញ្ជាក់អំពីវេជ្ជអាជ្ញាថា ក្មេងមានសមត្ថភាពខួរក្បាលធម្មតា ដោយមានទិន្នការអាក្រក់ជាកស្តុតាង ។

ទោះបីជាក្មេងមានអាយុក្រោមដប់ឆ្នាំ បានរួចផុតពីបទល្មើសព្រហ្មទណ្ឌ និងគេចផុតពីទណ្ឌកម្មក្ដី ក៏មិនអាចគេចផុតទាំងស្រុងអំពីផលវិបាកទាំងអស់បានដែរ ។ ទោះបីមិនមានទណ្ឌកម្មដូច្នេះក៏ដោយ ចរិយាអនាគតរបស់ក្មេងនោះ អាចត្រូវបានគេដាក់កំហិត ។ មនុស្សដែលជំរុញឲ្យក្មេងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងត្រូវគេចោទប្រកាន់ថា ជាជនល្មើសចម្បង ឯក្មេងត្រូវបានចាត់ទុកជាភ្នាក់ងារ ( ឬអ្នកប្រព្រឹត្ត ) គ្មានទោសម្នាក់ប៉ុណ្ណោះ ។

តុលាការអនីតិជន គឺជាបង្គោល វិលជុំវិញបង្គោលនេះមានយន្តការសម្រាប់កាត់សេចក្ដី លើអនីតិជនប្រព្រឹត្តបទល្មើស ។ ច្បាប់ពាក់ព័ន្ធអនីតិជន ត្រូវបានបញ្ចូលទៅក្នុងច្បាប់តុលាការអនីតិជនឆ្នាំ ១៩៤៧ និងច្បាប់ស្ដីពីកុមារ និងយុវជនឆ្នាំ ១៩៤៧ ។ អនីតិជន ត្រូវបានគេឲ្យនិយមន័យថា ជាមនុស្សមានអាយុចន្លោះ ១០ ឆ្នាំ និងក្រោម ១៨ ឆ្នាំ ។ ( ច្បាប់ប្រទេសម៉ាឡេស៊ី )

តុលាការអនីតិជន មិនបើកឲ្យសាធារណជនចូលស្ដាប់

ទេ ។ ទោះបី គេអនុញ្ញាតឲ្យអ្នកកាសែតចូលស្តាប់យកព័ត៌មានបាន ប៉ុន្តែ គេមិនអាចសរសេរផ្សាយនូវលក្ខណៈពិសេសៗ ដែលអាចឲ្យគេស្គាល់ជនល្មើសនោះទេ ។ ប្រសិនបើរកឃើញជាប់ពិរុទ្ធ តុលាការមិនប្រើពាក្យទាំងឡាយដូចជា " ទណ្ឌិត " ឬ " សាលក្រម " ក្នុងការទាក់ទងទៅនឹងជនល្មើសទេ ។

តុលាការ ត្រូវឋិតក្រោមអធិបតីភាពចៅក្រមថ្នាក់ទីមួយម្នាក់ ដែលកាត់សេចក្តីលើជនជាប់ពិរុទ្ធ ។ លោកកាត់សេចក្តីដោយមានចៅក្រមជំនួយពីរនាក់អម ក្នុងចំណោមនេះ គួរមានចៅក្រមម្នាក់ជាស្ត្រី បើអាចរកបាន ដើម្បីជួយលោកលើការសម្រេច " សាលក្រម " ។ មុនកាត់សេចក្តីថា តើត្រូវធ្វើយ៉ាងម៉េច ចំពោះអនីតិជនម្នាក់ តុលាការត្រូវពិចារណាលើចរិយាទូទៅ លើបរិដ្ឋានគ្រួសារ លើសេចក្តីរាយការណ៍របស់សាលា និងប្រវត្តិពេទ្យរបស់ជនប្រព្រឹត្តបទល្មើស ។

តុលាការអាចគ្រើនរំលឹក ឬដាស់តឿន ហើយឲ្យរូបខ្លួនអាចផ្តល់ការលើកលែងទោស ដល់ជនប្រព្រឹត្តបទល្មើស ដែលចុះកិច្ចសន្យាកែប្រែខ្លួន ប្រព្រឹត្តល្អ គោរពតាមបញ្ជាដាក់កំហិតដូចតទៅនេះ បញ្ជាបង្ខាំងទុកក្រោមកិច្ចថែទាំរបស់ញាតិម្នាក់ ឬមនុស្សសមស្របផ្សេងទៀត និងបញ្ជាឲ្យឪពុក-ម្តាយ ឬអាណាព្យាបាលរបស់ក្មេងអនុវត្តកិច្ចសន្យាផ្តល់ការថែទាំ និងឃុំគ្រងឲ្យបានត្រឹមត្រូវ បញ្ជាព្យួរទោសក្នុងការសាកល្បង បញ្ជាឲ្យបង្ខាំងទុកនៅក្នុង

សាលាទទួលស្គាល់ណាមួយ ឬនៅក្នុងសាលា ហិនរីហ្គីណេ (Henry gurney school ) សម្រាប់ផ្តល់ការអប់រំ " កែប្រែ " បញ្ជាឲ្យបង់ប្រាក់ពិន័យ ជួសជុលការខូចខាត ឬសងថ្លៃ ។

ចៅក្រមអាចបញ្ជាឲ្យដាក់គុកបាន ប្រសិនបើជនប្រព្រឹត្តបទល្មើស មានអាយុចន្លោះ ១៤ និង ១៨ ឆ្នាំ ។ នេះគឺជាវិធានការចុងក្រោយ ផ្តល់ឲ្យអនីតិជនប្រព្រឹត្តបទល្មើស មិនអាចឲ្យគេអនុវត្តវិធីណាសមស្របក្រៅពីនេះបានទេ ។

ក្មេងមានអាយុចន្លោះ ១០ និង ១៤ ឆ្នាំ ចៅក្រមមិនអាចបញ្ជាឲ្យដាក់គុក ចំពោះបទល្មើសណាមួយបានទេ ។ ទាំងមិនអាចបញ្ជាឲ្យគេឃុំឃាំងក្មេងដាក់គុក ក្នុងការខកខានមិនបានបង់ប្រាក់ពិន័យ សងការខូចខាត ឬសងថ្លៃបានឡើយ ។ ក្នុងជំពូក ១៦ នៃច្បាប់តុលាការអនីតិជន ចៅក្រមមិនអាចប្រកាសទោស ឬសាលក្រមប្រហារជីវិតអនីតិជនបានទេ ។ ប៉ុន្តែ ការដាក់គុកនេះ មិនអាចអនុវត្តបានទេ ត្រង់កន្លែងដែលអនីតិជន ត្រូវបានចោទប្រកាន់ក្រោមបទបញ្ញត្តិ (ករណីសន្តិសុខ) ជាសារវន្តឆ្នាំ ១៩៧៥ ដែលមិនរាប់បញ្ចូលយ៉ាងច្បាស់លាស់ នូវច្បាប់តុលាការអនីតិជន ។ ស្ថានភាពតែមួយគត់ ដែលតុលាការធម្មតា អាចកាត់សេចក្តីលើអនីតិជនបានគឺ កាលណាអនីតិជននេះ ត្រូវបានជាប់ចោទរួមជាមួយមនុស្សពេញវ័យម្នាក់ទៀត ឬបទល្មើសឈានដល់ទណ្ឌកម្មប្រហារជីវិត ។ នៅក្នុងករណីទាំងឡាយបែបនេះ អនីតិជន អាចត្រូវបានសុំ

សន្តោសទោស ហើយបង្ខាំងទុកអប់រំក្នុងសាលា ហិនរីហ្គីណេ (The Henry gurney Scool) ។

ក្នុងទីណាដែលក្មេងអាយុក្រោម ១០ ឆ្នាំ មានចរិតអាក្រក់មិនអាចទ្រាំបាន ឬសូម្បីតែត្រូវការកិច្ចការពារ និងថែទាំ ក៏ហួសពីការត្រួតត្រាបាន តុលាការអនីតិជន ត្រូវដាក់បញ្ជាប្រគល់ការឃុំគ្រង និងកិច្ចការពារក្មេងនេះ ទៅឲ្យស្ថាប័នណាមួយ ដែលគេទទួលស្គាល់ ។

វិធានការមួយ ក្នុងបណ្តាវិធានការព្យាបាល ដែលតុលាការអនីតិជនប្រើញឹកញាប់បំផុត គឺការព្យួរទោសមានលក្ខខណ្ឌ ។ ជនប្រព្រឹត្តបទល្មើសជាអនីតិជន ត្រូវដាក់ឲ្យឋិតក្រោមការឃ្លាំមើលរបស់មន្ត្រីតាមដានការព្យួរទោស ដែលគេមានកាតព្វកិច្ចធ្វើជាមិត្តស្និទ្ធស្នាល និងជួយអនីតិជននោះ ដើម្បីឲ្យគេមាននីតិសម្បទាឡើងវិញ ។ ការព្យួរទោសមានលក្ខខណ្ឌ គឺជាការងារសង្គមដ៏មានសារសំខាន់ ពីព្រោះ វាជាករណីកិច្ចរបស់មន្ត្រីតាមដានព្យួរទោស ដើម្បីរកឲ្យឃើញ ការប្រកបការងារដ៏ទៀងទាត់ សម្រាប់បទចោទប្រកាន់ និងជំនួយរបស់គាត់ ក្នុងបញ្ហាគ្រួសារ កាលណាមានការចាំបាច់ ។

ស្មារតីនៅពីក្រោយច្បាប់ពាក់ព័ន្ធពួកយុវជន គឺថា ពួកយុវជនត្រូវបានគេចាត់ទុកដោយឡែក ផ្សេងពីមនុស្សពេញវ័យ ពោលគឺដោយមានសេចក្តីមេត្តា និងសេចក្តីយោគយល់ ដើម្បីឲ្យពួកយុវជន

មើលឃើញមាគ៌ាត្រឹមត្រូវ ដែលពួកគេបានវង្វេងឃ្លាតឆ្ងាយ ព្រោះមិនមែនជាកំហុសរបស់គេផ្ទាល់ ។

ជំហានដែលគេអាចផ្តល់ឲ្យគ្រួសារទាំងឡាយ ដែលមានកូនតូចៗ គឺជាត្រូវចំណាយពេលបង្កើនគុណភាព (guality time) ជាមួយកូនៗទាំងនោះ ត្រូវស្តាប់អ្វីដែលកំពុងប្រព្រឹត្តទៅ និងអ្វីដែលកូនអាចខិតខំនិយាយប្រាប់ដោយពិតត្រង់ ។

" Bohsia " and " Lepak "

" បូស៊ា " និង " លេប៉ាក "

## វប្បធម៌ ក្នុងចំណោមយុវជន

ដោយប្រទេសមានឧស្សាហូបនីយកម្មយ៉ាងឆាប់ យុវជនជាច្រើនមកពីជនបទ សម្រុកចូលក្រុងធំៗ ស្វែងរកការងារធ្វើនៅក្នុងរោងចក្រទាំងឡាយ ។ នារីមកពីជនបទ ជាពិសេស មកក្នុងចំនួនយ៉ាងច្រើន ដើម្បីប្រកបការងារ កាត់ច្រើនក្នុងរោងចក្រអេឡិចត្រូនិក ។ ការស្រើបស្រាល ក្នុងការរស់នៅរួចផុតពីការថែទាំនៅក្នុងទីក្រុង ដែលមានហាងលក់ទំនិញធំៗ ស៊ុបពែម៉ាកេត (Super-markets) និងពន្លឺភ្លើងពណ៌ព្រោងព្រាតដ៏ច្រើនដេរដាស អូសទាញពួកយុវជននៅជនបទមានចំនួនច្រើន ដែលជាទូទៅគេតែងចំណាយពេលម៉ោងទំនេររបស់គេក្រោយការងារ ដើរអើតងើតតាមបង្អួចហាង ឬគ្រាន់តែដើរកម្សាន្តពាសវាលពាសកាលជាក្រុមៗ នៅក្នុង

ទីកន្លែងដូចនេះ ។ ប្រាក់ គឺជាម្ចាស់ខ្ពស់បំផុត នៅក្នុងសន្តានចិត្ត របស់ពួកគេ ត្រូវមានប្រាក់ក្រៅខ្លះ ដែលពួកគេអាចក្រេបឱជារស ជីវិតហ៊ឺហាមានគុណភាពប្រសើរជាមួយនឹងប្រាក់នេះ នៅក្នុង ទីក្រុង ។

ប្រភេទជីវិតរស់នៅ ក្នុងចំណោមយុវជន ក្នុងពេលកន្លង ទៅ បានបង្កើតឲ្យមានពាក្យប្រជាប្រិយថា បូស៊ា និង លេប៉ាក = Bohsia and Lepak ( ភាសាម៉ាឡេ ) ។ ពាក្យ បូស៊ា (Bohsia) មាន ប្រភពចេញមកពីពាក្យចិន ហុកកៀន ដែលមានន័យថា " គ្មាន សម្លេង " ។ ថាតើពាក្យនេះ កើតឡើងយ៉ាងដូចម្តេច ហើយត្រូវ បានគេយកមកប្រើភ្ជាប់ជាមួយពួកយុវជនប៉ោឡែ នៅក្នុងទីក្រុងធំៗ យ៉ាងម៉េចនោះ មិនមានហេតុផលពន្យល់ច្បាស់លាស់ទេ ។ ពាក្យ ក្នុងភាសាម៉ាឡេមានន័យស្មើ និងពាក្យ ប៊ូសា គឺ លេប៉ាក Bohsia= Lepak ( Bahasa Malaysia ) ។

ដោយមានពួកយុវជន មានចំនួនយ៉ាងច្រើនកំពុងឃ្លាតឆ្ងាយ ពីការត្រួតត្រារបស់សង្គម នៅក្នុងជីវភាពគ្រួសារធម្មតានាជនបទ ដូច្នេះ គេមិនបាច់ងឿងឆ្ងល់ទេ ក្នុងការឃើញយុវជនមួយចំនួន ក្នុង ចំណោមនេះ លង់ខ្លួននៅក្នុងសកម្មភាពអសីលធម៌ ក្នុងបណ្តា ទីក្រុងធំៗ ហើយប្រែក្លាយទៅជាពាក់ព័ន្ធក្នុងបែបបទរស់នៅ ដែល មិនគួរឲ្យអត់ឱន អាចឲ្យវិលត្រឡប់ទៅរស់នៅក្នុងទីប្រជុំជន ឯជនបទ របស់ពួកគេវិញបាន តាមធម្មតាឡើយ ។ ការស្រុតចុះនៃ

អកិសមាចារ មិនអាចជៀសវាងផុត បណ្តាលមកពីខ្វះការគ្រប់គ្រងរបស់ឪពុក-ម្តាយ និងសង្គម ក្នុងពេលពួកគេត្រឡប់ទៅរស់នៅក្នុងភូមិស្រុក របស់ពួកគេផ្ទាល់វិញ ។

តំណាក់កាលមួយបានឈានដល់ ពេលណាយុវនារីជាក្រុមតូចៗ បានទុកដាក់ខ្លួនគេជា " ស្រីរើសតាមផ្លូវ " (pick-ups) ឈរនៅតាមទីកន្លែងស្ងាត់ៗខ្លះ នៃអាគារហាងលក់ទំនិញធំៗ អាគារសាធារណៈនានា ឬនៅជ្រុងផ្លូវ ដែលពួកយុវជនស្ទាវៗ ទីក្រុងគ្រាន់តែមកស្រង់យកប៉ុណ្ណោះ ។ នារីៗ ចោតល្ងង់ណាស់ ពួកនាងៗ ប្រែក្លាយជាចំណីយ៉ាងស្រួលរបស់ពួកស្ទាវៗ ដែលបើកបរម៉ូតូថ្មីៗយ៉ាងសង្ហារ ។

តាមពិត គេអាចចូលទៅជិត ហើយនិយាយសុំស្គាល់ធម្មតា ជាមួយក្មេងស្រីធ្វើការនៅរោងចក្រណាមួយ ដែលគេឃើញដើរត្រេតត្រតនៅទីជិតៗ នៃអាគារហាងលក់ទំនិញ ហើយជូនកាលនាងរីករាយទទួលការអញ្ជើញ ដែលចេញពីការទើបស្គាល់គ្នានេះ ដើម្បីទៅផឹកភេសជ្ជៈ ឬបរិភោគអាហារសម្រន់ឃ្លានទៅភោជនីយដ្ឋានណាមួយ ហើយក្រោយមក ធ្វើដំណើរកម្សាន្ត ឬចូលស្តាប់ចម្រៀង ឬក៏នាំគ្នាទៅកាន់ទីកន្លែងណាមួយ តាមការព្រមព្រៀងគ្នា ។

ប៉ុន្តែ ដល់ពេលក្រោយមក យុវនារីទាំងឡាយ គាន់តែបែកគំនិតធ្វើផែនការ លើកកម្ពស់ខ្លួនឯង ឈានដល់សុំស្គាល់បុរសចំណាស់ៗ មានប្រាក់ច្រើន ដែលជិះក្នុងរថយន្តថ្លៃៗ កំពុងបើកបរ

ក្រឡឹងរក " នារីរើសតាមផ្លូវ " ឬនារី (pick-ups) ដើម្បីកំដរអារម្មណ៍ពួកគេ ។ បុរសៗទាំងនេះ នៅក្នុងសង្គមខ្ពស់ ជាទូទៅតែងតែរាំសរាំមណាស់ ក្នុងការប្រលោមលួងលោមស្រីក្មេង ។ ប៉ុន្តែស្ថានភាពក្នុងពេលកន្លងទៅ បានចេញផុតពីដៃទៅហើយ ក្នុងពេលដែលករណីទាំងឡាយ នៃកន្លែងកៀកកើយបិទជិត (Khalwat) ត្រូវបានទគរបាលព័ទ្ធចាប់ ដោយបានទទួលពាក្យបណ្តឹងពីភរិយាទាំងឡាយ ប្រឆាំងនឹងប្តីរបស់ពួកខ្លួន ពាក់ព័ន្ធនឹងសកម្មភាពខិលខូចអសីលធម៌ ។ ដោយទគរបាលធ្វើសកម្មភាពឃ្លាំមើលជាបន្ត បញ្ហា " បូស៊ា " និង " លេប៉ាក " ដែលកាលពីមុន បានជាប្រធានបទព័ត៌មានយ៉ាងទូលំទូលាយ បានរលាយរលប់បាត់បន្តិចម្តងៗ ហើយ ។

ដើម្បីបំពេញចន្លោះទទេ ដែលបន្តមកទៀត ពួកគេរកស៊ីខាងពាណិជ្ជកម្មឥតក្រែងរអែង បានចាប់យកឱកាសកើបយកលុយដោយបើកសាឡុងកាក៉ាអូខេ និងរោងវីដេអូ តាមរយៈនេះ បានផ្តល់ការងាយស្រួល ដល់ការណាត់ជួបគ្នាបានយ៉ាងប្រសើរ នៅក្រោមពន្លឺដ៏ស្រទន់ និងមានតន្រ្តីប្រជាប្រិយ៍សម្រាប់ស្ថានភាព " ប្រុសជួបស្រី " ។ ទោះបីមានបទបញ្ញត្តរបស់រដ្ឋាភិបាល ក៏ការ៉ាអូខេនិងរោងវីដេអូទាំងឡាយ នៅតែអនុញ្ញាតឲ្យក្មេងៗ មានអាយុក្រោម ១៨ ឆ្នាំ ចូលទៅក្នុងរោងល្បែងរបស់ខ្លួន ហើយម៉ោងពេលបញ្ចាំងច្រៀងកំ បានពន្យាររហូតដល់ម៉ោងបី ឬម៉ោងបួនព្រឹក ។ មនុស្សទាំងប្រុស ទាំងស្រី ឱបរិតប្របូកប្រឡល់គ្នាដោយសេរីក្នុងបន្ទប់

អាគារមានពន្លឺស្រទន់ៗ ហើយចរិយារបស់ពួកគេ មានកង្វះខាតច្រើនណាស់ ។

មណ្ឌលការ៉ាអូខេ ប្រើស្ត្រីក្មេងៗមានរូបសម្ផស្សដ៏ទាក់ទាញចិត្តឲ្យធ្វើជា " អ្នកទាក់ទងភ្ញៀវ " ទុកជារណសិរ្សជួរមុខអូសទាញពួកស្វាវៗ ឲ្យចូលខ្លួនទៅសប្បាយក្នុងល្បែង ដែលនៅក្នុងនេះ ពួកគេលើកទឹកចិត្តជំរុញបញ្ជាឲ្យចំណាយប្រាក់យ៉ាងច្រើន ។ ក្នុងការបញ្ចាំងខ្សែវីដេអូ បុរស និងស្ត្រី ដែលស្លៀកពាក់ខើចលើខើចក្រោម ដើរចុះឡើងយ៉ាងគឃ្លើន ក្រោមស្នូរស័ព្ទតូរ្យតន្ត្រីដ៏រំភើបអារម្មណ៍ស្នេហា ។ គេអាចនឹកគិតថា តើឥទ្ធិពលបញ្ចោសទិសដ៏ធ្ងន់ធ្ងរប៉ុណ្ណា ត្រូវធ្លាក់មកលើខួរក្បាលក្មេងខ្ចី ។ ការបង្រៀនអំពីតម្លៃសីលធម៌ នៅក្នុងសាលាតែប៉ុណ្ណោះ នឹងមិនបង្កើតសង្គមមួយមានសុខភាពល្អទេ ។ ឪពុក-ម្ដាយត្រូវជួយជម្រះជាតុអវិជ្ជមានទាំងឡាយ ហើយប្រព័ន្ធផ្សព្វផ្សាយ ត្រូវតែដើរតួជាវិជ្ជមានផងដែរនៅក្នុងបញ្ហានេះ ។ សង្គមត្រូវតែគិតគ្រួយបញ្ហាស្អុយរលួយពីដើមទីដោយមិនត្រូវបណ្ដោយឲ្យខួរក្បាលក្មេងខ្ចី រងផលពីសពុល នៃការបញ្ចាំងវីដេអូស្រើបស្រាលឡើយ ។

រដ្ឋាភិបាលត្រូវមានវិធានការ រឹតបន្តឹងដាក់កំហិតលើសាឡុងការ៉ាអូខេ និងរោងបញ្ចាំងវីដេអូ ពីព្រោះវិធានការនេះ នឹងជួយកៀបជំងឺសង្គម ដែលកំពុងរីកដុះដាល ក្នុងចំណោមយុវជន ។ មណ្ឌលទាំងឡាយបែបនេះ ប្រព្រឹត្តទៅក្រោមរូបភាពក្លែងបន្លំ ធ្វើជា

សកម្មភាពចម្បងរបស់ពួកគេ គឺល្បែងស៊ីសង និងការចល័តលក់ថ្នាំញៀន ។ សកម្មភាពរបស់ពួកគេ ត្រូវបានរៀបចំបញ្ចូលក្នុងកុំព្យូទ័រកម្រិតខ្ពស់ ដោយប្រើឧបករណ៍ទូរបញ្ជា ពួកគេអាចរៀបចំល្បែងជាថ្មីឡើងវិញបានភ្លាមៗ កាលណាមណ្ឌលល្បែងរបស់ពួកគេ ត្រូវបានបង្ក្រាបដោយកម្លាំងប៉ូលីស ។ កិច្ចការនេះ ធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងសម្រាប់ក្រុមប៉ូលីស ដើម្បីធ្វើសកម្មភាពប្រឆាំងពួកទុច្ចរិតជនទាំងនោះ វៀរលែងតែកម្លាំងប៉ូលីស ចូលទៅក្រោមរូបភាពក្លែងបន្លំខ្លួន ។ ប៉ូលីសបានដឹងពីសកម្មភាពបទល្មើសកើតមានក្នុងកន្លែងវីដេអូ ក្នុងវង់ច្រៀងរាំកម្សាន្ត និងក្នុងសាឡុងការ៉ាអូខេ ។

យើងមានបំណងប្រាថ្នាពង្រឹងចំណងគ្រួសារ ហើយស្ទួយតម្លៃគ្រួសារប្រកបដោយសុខភាពល្អ ។ យើងមិនចង់ឲ្យយុវជនរបស់យើងចំណាយពេលទំនេរ និងប្រាក់កាសរបស់គេ ក្នុងសាឡុងការ៉ាអូខេ និងហាងវីដេអូទេ ពីព្រោះនេះអាចអូសទាញ ពួកយុវជនឲ្យធ្លាក់ក្នុងគន្លងខុស ។ ដោយការបិទសាឡុងការ៉ាអូខេ និងហាងវីដេអូ ពួកយុវជន អាចទីងបន្ថយការចំណាយពេលរបស់គេដោយឥតប្រយោជន៍ ហើយវាអាចជួយលើកទឹកចិត្ត ឲ្យពួកគេបំពេញសកម្មភាពជាកុសល ឬឋិតនៅផ្ទះជាមួយឪពុក-ម្តាយរបស់ពួកគេវិញ ។

នៅក្នុងសិង្គាលកសូត្រ ព្រះពុទ្ធទ្រង់បានទូន្មានពួក

យុវជន មិនឲ្យចូលរួមប្រឫកប្រឫល់ ក្នុងអំឡុងកាលមិនប្រក្រតី នៅក្នុងផ្លូវសាធារណៈ និងកន្លែងទាំងឡាយខ្លះ ដែលគេអាចអូសទាញមនុស្សក្មេងៗ ឲ្យធ្លាក់ចូលក្នុងគន្លងប្រព្រឹត្តអំពើអសីលធម៌ ។

### គួរចងចាំ

ចិញ្ចឹមសម្បូរ រៀងជាតិ
លទ្ធផលគង់ឃ្លាត ពីសាមគ្គី

# ព្រះរតនត្រ័យ

(The Triple Gem)

រៀបរៀង និងប្រែសម្រួលដោយ

ភិក្ខុ **សេង សុគ័ណ**

វត្ថុគ្រប់យ៉ាងលើលោកនេះ សុទ្ធតែមានកន្លែងចាប់កាន់ តែបើមនុស្សចេះចាប់ ឲ្យត្រូវកន្លែងត្រឹមត្រូវហើយនោះ ការចាប់នោះមាំទាំជាប់ល្អ និងចំណាយកម្លាំងតិច ហើយវត្ថុនោះមិនអាចរបូតធ្លាក់បាន ។ ឧទាហរណ៍ដូចជា កាំបិតព្រាមានដងសម្រាប់កាន់ រថយន្តមានចង្កូតសម្រាប់បត់ ឆ្នាំងបាយ ឆ្នាំងសម្ល មានត្រចៀកសម្រាប់យួរជាដើម ។

យើងជាពុទ្ធសាសនិក គោរពរាប់អានទូវព្រះពុទ្ធសាសនា ត្រូវមានទីពឹង ទីបង្អែក ទីចាប់យឹតសណ្តោង។ ទីពឹងក្នុងព្រះពុទ្ធសាសនាបានដល់ "ព្រះរតនត្រ័យ" អ្នកដែលគោរពរាប់អានព្រះរតនត្រ័យ បុគ្គលនោះឈ្មោះថា ជាពុទ្ធមាមក ជាបុគ្គលដែលមានព្រះពុទ្ធសាសនាស្ថិតនៅក្នុងខ្លួន ។ អ្នកណាដែលឈប់គោរពរាប់អាន ព្រះរតនត្រ័យ បុគ្គលនោះ ក៏ដាច់ស្រឡះចេញពីព្រះពុទ្ធសាសនា ក្លាយជាមនុស្សក្រៅសាសនា (តិរ្ថិយ) heathen ។

ក្នុងព្រះពុទ្ធសាសនា មានភាសាបាលី ដើម្បីឲ្យពុទ្ធសាសនិកជនសូត្រសំដែងខ្លួន គោរពរាប់អានព្រះរតនត្រ័យ ហៅថា

" សរណគមនបាឋ " ដោយការសូត្រដូចតទៅនេះ ៖

" ពុទ្ធំ សរណំ គច្ឆាមិ
ធម្មំ សរណំ គច្ឆាមិ
សង្ឃំ សរណំ គច្ឆាមិ
ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ល។
តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ល។ "

ប្រែថា "ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹក ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹង ទីរលឹក ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក" ។ ដែលត្រូវសូត្រសារចុះសារឡើង ៣ ដងនោះ ក៏ដើម្បីឲ្យប្រាកដក្នុងចិត្តថា ពាក្យសូត្រនោះគឺបានពន្លឺចេញមកពីដួងចិត្តពិតប្រាកដ ។

ពុទ្ធសាសនិកជនទូទាំងពិភពលោកសូត្របាលីនេះ ដូចគ្នា បើខុសប្លែកគ្នាខ្លះៗ ក៏ចំពោះសំនៀងតិចតួចតែប៉ុណ្ណោះ ។

## អត្ថន័យនៃពាក្យថារតនៈ

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះពុទ្ធជាម្ចាស់បានបញ្ញត្តិឈ្មោះថា "រតនៈ" ពាក្យបញ្ញត្តិនេះ មាននៅក្នុងរតនសូត្រព្រះត្រៃបិដក ។ ពាក្យថា រតនៈនេះ តាមសព្ទដើមប្រែថា កែវ សម្រាប់សំនួនភាសា មានន័យថា ដ៏ប្រសើរដូចជាដីរកែវ សេះកែវ ករិយាកែវជាដើម មានន័យថា ដីរដ៏ប្រសើរ សេះដ៏ប្រសើរ ករិយាដ៏ប្រសើរ (មិនមែនមានន័យថា ធ្វើពីកែវ) ។

ដោយន័យនេះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គឺជាវត្ថុ ដែលប្រសើរលើសលប់បំផុត ព្រះអង្គទើបបញ្ញត្តិឈ្មោះថា "រតនៈ" ។

រតនត្រ័យ មានឫសគល់មកពីភាសាបាលីថា "រតនត្តយំ" ប្រែថា ពួកបីនៃព្រះរតនៈ ឬឈុតរតនៈបី មានន័យថាព្រះរតនៈ សូម្បីតែមាន៣អង្គ តែក៏រួមគ្នាតែមួយជាឯកភាព ដូចពេជ្រមួយគ្រាប់ តែមានលក្ខណៈ៣យ៉ាងគឺ រូបសណ្ឋាន១ ពណ៌សម្បុរ១ ទម្ងន់១ តែតាមការពិតទាំងរូប សណ្ឋាន ពណ៌សម្បុរ និងទម្ងន់រួមគ្នា គឺពេជ្រមួយគ្រាប់នោះឯង ។ បុគ្គលណាបំបែកយក ចំពោះផ្នែកណាមួយនោះមិនបានរតនៈបីក៏ដូចគ្នា គឺរួមតែមួយវេលា គោរពបូជាក៏ត្រូវគោរពបូជាយកទាំងបី ។

ត្រៃរត្ន បេញពីពាក្យបាលីថា "តិរតនំ"The three jewels ប្រែថា កែវបីដួង ។

**សរណគមន៍** (Taking refuge)

ព្រះរតនត្រ័យ ដែលយើងគោរពបូជាមានឈ្មោះ បញ្ញត្តិហៅមួយទៀតថា "សរណំ" ដូចដែលមានក្នុងពាក្យអារាធនាសីល និងពាក្យសុំបួស ឬសុំសីល ។

ជាពាក្យអារាធនាសីលគឺ " មយំ ភន្តេ តិសរណេន សហ បញ្ច សីលានិ យាចាម " ។

ពាក្យសុំសីលក្នុងពិធីបព្វជ្ជាគួរថា " អហំ ភន្តេ សរណសីលំ យាចាមិ " ។

ហើយលោកក៏បញ្ជាប់ថា " សរណគមនំ និដ្ឋិតំ " ។

ពាក្យថា តិសរណេន តិសរណំ ប្រែថា សរណៈ៣ ពាក្យថាសរណគមនំ គឺសរណគមន៍ ។ សរណៈ មានន័យថា ព្រះរតនត្រ័យ ចំណែកសរណគមន៍ ក៏មានន័យថា ការចូលដល់ព្រះរតនត្រ័យ ។

ហេតុដែលព្រះរតនត្រ័យ គេហៅថា សរណៈ គឺមកពីការរាប់អានព្រះរតនត្រ័យ និងបានផលល្អក៏អាស្រ័យ ដោយអ្នកគោរពរាប់អានរំលឹកដល់ជានិច្ច ហើយពេលមានហេតុការណ៍ណាមួយកើតឡើង ដូចជាកើតសេចក្ដីខ្លាច កើតសេចក្ដីទុក្ខវេទនា កើតសេចក្ដីភ័យតក់ស្លុត ក៏ឲ្យរំលឹកដល់ព្រះរតនត្រ័យ ពាក្យថា សរណៈ គឺប្រែថា រំលឹកដល់ ។

-ដាច់សរណគមន៍ គឺការរំលឹកដល់ព្រះរតនត្រ័យ ត្រូវបានបញ្ចប់មកពីអ្នកនោះ ទៅឧទ្ទិសខ្លួនរាប់អានសាសនាដទៃ ឬប្រកាសខ្លួនឈប់រាប់អានព្រះរតនត្រ័យ ឬប្រព្រឹត្តជាន់ឈ្លីបំផ្លាញ ព្រះ-រតនត្រ័យ ។ អ្នកដែលដាច់សរណគមន៍ហើយ និងដាច់ចេញពីសាសនាផងដែរ ។ បើដាច់ពីសរណគមន៍ ក្នុងខណៈដែលកំពុងកាន់ភេទជាបព្វជិតនៅឡើយ ក៏ដាច់ពីភាពជាព្រះភិក្ខុ ឬសាមណេរ ។

-សរណគមន៍សៅហ្មង គឺការគោរពរាប់អានព្រះរតនត្រ័យរបស់អ្នកនោះ មិនបរិសុទ្ធល្អ ព្រោះខ្លួនមិនបានបដិបត្តិពិតប្រាកដដល់ព្រះរតនត្រ័យ ដូចជាខ្លួនគោរពរាប់អានព្រះរតនត្រ័យ តែក្នុង

ឱកាសជាមួយគ្នា ក៏ប្រកបពិធីកម្ម តាមលទ្ធិសាសនាផ្សេងៗផង ដែរ ព្រោះតែខ្លួនមានមន្ទិលសង្ស័យជាដើម ។

ការរក្សាសរណគមន៍យ៉ាងពិតប្រាកដជាក់លាក់ ឬមិនទេនោះ ជាហេតុមួយ ដែលធ្វើឲ្យអ្នកគោរពរាប់អានព្រះពុទ្ធសាសនាដូចគ្នា តែទទួលបានការរក្សាគ្រប់គ្រងពីសាសនាតិច ឬច្រើនមិនស្មើគ្នា ។

**ព្រះពុទ្ធជាម្ចាស់** (The Lord Buddha)

ព្រះពុទ្ធជាម្ចាស់ !

ក្នុងលោកនេះ មានលទ្ធិសាសនាជាច្រើន យើងមានសទ្ធាជ្រះថ្លា ពេញចិត្ត នឹងលទ្ធិសាសនាណាខ្លាំងជាងគេ យើងក៏គោរពរាប់អានលទ្ធិសាសនានោះ ។ ចំណុចដែលយើងសង្កេតមើលលទ្ធិដែលយើងមានសទ្ធាជ្រះថ្លា ឬមិនទេនោះ យើងសង្កេតមើលទៅទីណា ? ពិតមែនជាដូច្នោះ ចំណុចដែលពិនិត្យមើលឲ្យពិតប្រាកដនោះ មានលក្ខណៈ ៣ គឺ ៖

- សាស្តា (Teacher) បានដល់ អ្នកបង្កើតសាសនា
- សាវធម៌ (The truth) បានដល់ ពាក្យប្រៀនប្រដៅរបស់សាសនា។
- សាវ័ក (Disciples) បានដល់ អ្នកប្រព្រឹត្តតាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ។

បើសាសនាមានទាំងបីយ៉ាងនេះ ល្អប្រពៃហើយ ក៏គួរតែនឹងមានសទ្ធាជ្រះថ្លា ។ ព្រះពុទ្ធសាសនា យើងត្រូវសង្កេតមើល

ចំណុចទាំងបីនេះដែរ គឺបានដល់ព្រះរតនត្រ័យទាំងបីនោះឯង ។

. ព្រះពុទ្ធជាម្ចាស់ គឺជាអ្នកបង្កើតព្រះពុទ្ធសាសនា

. ព្រះធម៌ គឺជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធសាសនា

. ព្រះសង្ឃ គឺជាគណៈសាវក របស់ព្រះពុទ្ធជាម្ចាស់

" អ្នកដែលបង្រៀន មនុស្សលោកយើងឲ្យប្រព្រឹត្តល្អ ដោយកាយ វាចា ចិត្ត តាមគន្លងព្រះធម៌វិន័យ ដែលហៅថា ព្រះពុទ្ធសាសនា (Buddhism) ឈ្មោះថា ព្រះពុទ្ធជាម្ចាស់ " ។

តើអ្នកយល់អត្ថន័យនៃពាក្យនេះ ហើយអធិប្បាយថាយ៉ាងដូចម្ដេចដែរ ? ពាក្យខ្លីៗ ដូចដែលបានគូសបន្ទាត់ខាងក្រោមនេះ គឺមានន័យថា "អ្នកបង្រៀនព្រះពុទ្ធសាសនា ឈ្មោះថា ព្រះពុទ្ធអង្គ" ឬត្រឡប់សេចក្ដីជាថ្មីទៀតថា "ព្រះពុទ្ធជាម្ចាស់ គឺជាអ្នកបង្រៀនព្រះពុទ្ធសាសនា " យ៉ាងនេះក៏បាន ។ ពាក្យថា " អ្នកបង្រៀន " នៅទីនេះប្រែមកពីពាក្យថា សាស្តាមិនមែនមានន័យថា ជាអ្នកបង្រៀនទូទៅ ដូចជាគ្រូបង្រៀនធម៌វិន័យ គ្រូបង្រៀនភាសាបាលី អ្នកទេសនាទូទៅជាដើម ពិតមែនអ្នកទាំងអស់នោះ ក៏បង្រៀនព្រះពុទ្ធសាសនាដូចគ្នា តែមិនមែនជាព្រះពុទ្ធអង្គនោះទេ ព្រោះព្រះពុទ្ធអង្គ មានន័យថា អង្គព្រះសាស្តា ដែលទ្រង់ស្ថាបនាព្រះពុទ្ធសាសនាតែប៉ុណ្ណោះ ។

**អង្គព្រះពោធិសត្វ** ( Bodhisattva, Enlightenment-being) ទស្សនៈព្រះពុទ្ធសាសនា ទាក់ទងទៅនឹងព្រះពុទ្ធជាម្ចាស់ មានន័យ

ថា ក្នុងបណ្ដាសត្វលោកទាំងឡាយ ច្បាស់ជាមានសត្វ ដែលមានចិត្តឧត្ដម ប្រាថ្នានូវភាពបរិសុទ្ធ និងការចង់ជួយស្រោចស្រង់សត្វទាំងឡាយ ឲ្យរួចផុតពីទុក្ខទាំងពួង អធិដ្ឋានចិត្តថា សូមឲ្យខ្លួនបានសម្រេចជាព្រះពុទ្ធអង្គ បំពេញខ្លួនក្នុងសេចក្ដីល្អ និងសេចក្ដីចម្រើន ។ សេចក្ដីព្យាយាម ដើម្បីសម្រេចនូវសេចក្ដីប្រាថ្នាបែបនេះ ហៅថាព្រះពោធិសត្វ ប្រែថា សត្វដែលប្រាថ្នាព្រះពោធិញាណ ។

ព្រះពោធិសត្វមួយអង្គៗ បំពេញតែសេចក្ដីល្អ ដោយឥតដាច់អស់រយៈច្រើនកប្ប ច្រើនជាតិ ។ សេចក្ដីព្យាយាមល្អ ដែលទ្រង់បំពេញនោះហៅថា "បារមី" មានចំនួន១០ យ៉ាង ទើបហៅថា "ទសបារមី" (Ten perfections) គឺ៖

១-ទាន (giving, charity) ការបរិច្ចាគបែងចែកដល់អ្នកដទៃ ។

២-សីល (morality, good conduct) ការរក្សាសីលយ៉ាងខ្ជាប់ខ្ជួន ចៀសវាងពីបាបទាំងឡាយ ក្នុងនោះមានកាយ និងវាចា ។

៣-នេក្ខម្មៈ (renunciation) បញ្ចៀសខ្លួនឯងចេញពីការសេពខុសរឿងកាមារម្មណ៍ ។

៤-បញ្ញា (wisdom, insight) សេចក្ដីចៀវឆ្លាតយល់ច្បាស់នូវធម៌ទាំងឡាយ ។

៥-វីរយៈ (energy, effort) សេចក្ដីឧស្សាហ៍ព្យាយាម ធ្វើនូវសេចក្ដីល្អ ។

៦-ខន្តី (tolerance, endurance ) សេចក្ដីអត់ធន់ ។

៧-សច្ចៈ (truthfulness) រក្សានូវសេចក្តីស្មោះត្រង់ ។

៨-អធិដ្ឋាន (resolution, self-determination) ការតាំងចិត្តយ៉ាងពិតប្រាកដ ។

៩-មេត្តា (loving-kindness) មានចិត្តប្រាថ្នាល្អដល់អ្នកដទៃ។

១០-ឧបេក្ខា (equanimity) មានចិត្តជាកណ្តាល តាំងក្នុងភាពយុត្តិធម៌ ។

ព្រះពោធិសត្វ នឹងបំពេញបារមីទាំង១០យ៉ាងនេះ ផ្តើមតាំងតែដំបូង សន្សំជាបណ្តើរៗ រហូតដល់កម្រិតខ្ពស់បំផុត ពេលពេញបានបរិបូរណ៍ទាំង១០យ៉ាងនេះហើយ ទើបត្រាស់ដឹងជាព្រះពុទ្ធជាម្ចាស់ ។ ហេតុដូច្នេះហើយ ត្រូវសង្កេតមើលថា អ្នកដែលជាព្រះពុទ្ធអង្គនោះ ត្រូវតែជាមនុស្សល្អមួយរយភាគរយ ហើយល្អចេញពីខន្ធសន្តានពិតៗ ទើបធ្វើឲ្យយើងក្រាបបូជាសំពះ ដោយឥតមានមន្ទិលអ្វីទាំងអស់ ។

ព្រះពុទ្ធជាម្ចាស់ គឺព្រះពោធិសត្វ ដែលមានបារមីគ្រប់បរិបូរណ៍ហើយនោះ ពេលដល់កាលសមគួរហើយ ទើបចាប់កំណើតជាមនុស្ស បានចេញសាងព្រះផ្នួស ស្វែងរកមោក្ខធម៌ រហូតបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធនៅទីបំផុត ។ ពេលទ្រង់ជាព្រះពុទ្ធព្រះអង្គក៏ទ្រង់សម្តែងធម៌ បង្រៀនសាសនាដល់មនុស្សជាតិ ធ្វើឲ្យកើតមានព្រះពុទ្ធសាសនាឡើងក្នុងលោក ។ ពេលអស់អាយុសង្ខារហើយ ព្រះអង្គក៏ទ្រង់បរិនិព្វាន បន្សល់ទុកតែព្រះសាសនា ។

សាសនាដែលព្រះពុទ្ធមួយអង្គៗ បានបង្កើតឡើងនោះ និង ទទួលការគោរពរាប់អានពីមហាជនទូទៅ អស់ពេលរាប់ពាន់ឆ្នាំ បន្ទាប់មក ក៏អន្តរធានទៅយ៉ាងសន្សឹមៗ ព្រោះតែគ្មានអ្នកសិក្សា គ្មានអ្នកប្រតិបត្តិ ។

ពិភពលោក ក៏មិនមានព្រះពុទ្ធសាសនាអស់មួយរយៈ ទើប មានព្រះពោធិសត្វអង្គថ្មីចុតិមកកើត បានត្រាស់ដឹង ហើយក៏ស្ថាបនា ព្រះពុទ្ធសាសនាជាថ្មីឡើងម្តងទៀត ។

ប្រាកដដូច្នោះរហូតមក ដោយហេតុនេះឯង ទើបក្នុងអតីត-កាលដ៏យូរលង់មកហើយ មានព្រះពុទ្ធអង្គត្រាស់ដឹងចំនួនជាច្រើន អង្គ ដោយនៅក្នុង **អាដានាដិយបរិត្ត** រំលឹកដល់គុណព្រះពុទ្ធអង្គ ក្នុងអតីតកាលថា" វិបស្សិស្សនមត្ថុ ចក្ខុមន្តស្ស សិរិមតោ" ។ល។

ដោយន័យនេះ ក៏នឹងមានព្រះពុទ្ធអង្គ មកត្រាស់ដឹងក្នុង អនាគតទៀត ដោយមានលក្ខណៈ និងគុណសម្បត្តិដូចៗគ្នា ។

## ព្រះពុទ្ធជាម្ចាស់អង្គបច្ចុប្បន្ន

ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់តាំងព្រះសាសនាទុកក្នុងបច្ចុ-ប្បន្ន មានព្រះនាមដើមថា សិទ្ធត្ថ"សិទ្ធាថ៌" នៃត្រកូលគោតម ជាព្រះ-រាជបុត្ររបស់ព្រះបាទសុទ្ធោទនៈ ជាមួយព្រះនាងសិរិមហាមាយា ។ ព្រះបាទសុទ្ធោទនៈ គឺជាព្រះរាជានៃដែនសក្យ រាជធានីឈ្មោះ កបិលព័ស្ថុ និងព្រះនាងសិរិមហាមាយា ជាព្រះរាជិនីនៃដែនកោលិតៈ រាជធានីឈ្មោះទេវទហៈ បានរៀបអភិសេក ហើយទ្រង់ប្រសូតព្រះ

មហាបុរសនៅសួនលុម្ពិនី ជាព្រំដែន រវាងក្រុងកបិលពស្តុ និង ក្រុងទេវទហៈ ( ប្រទេសនេប៉ាល់បច្ចុប្បន្ន ) នៅថ្ងៃសុក្រ ១៥កើត ខែពិសាខ ឆ្នាំច មុនពុទ្ធសករាជ ៨០ ឆ្នាំ ។

ព្រះបាទសិទ្ធត្ថ ទ្រង់ជារជ្ជទាយាទ ពោលគឺ ទីងបានគ្រងរាជ សម្បត្តិបន្តពីព្រះរាជបិតា ទ្រង់បានសិក្សាសិល្បសាស្ត្រ គ្រប់ខ្នង សាខាទាំងអស់យ៉ាងឥតខ្ចោះ ទ្រង់បរិបូរណ៍ទៅដោយ សេចក្តីសុខ នៃជីវិតជាគ្រហស្ថ តែព្រះអង្គទ្រង់អាណិតអាសូរ ដល់មហាជន ដែលកំពុងស្ថិតនៅក្នុងអន្លង់ទុក្ខ គឺសេចក្តី ចាស់ ឈឺ ស្លាប់ ទើបសម្រេចព្រះទ័យ ទ្រង់យាងចេញសាងព្រះផ្នួស ដើម្បីស្វែងរកផ្លូវ រំដោះនូវទុក្ខ ក្នុងការជួយស្រោចស្រង់ ដល់មហាជនទាំងឡាយ ។ ពេលដែលទ្រង់ព្រះផ្នួស ព្រះអង្គបានបំពេញសេចក្តីព្យាយាម យ៉ាង អស់ទំហឹង ប្រើរយៈពេលដល់ទៅ៦ ព្រះវស្សា ក្នុងការសាកល្បង បដិបត្តិរកសច្ចធម៌ នៅទីបំផុតក៏បានត្រាស់ដឹង នូវអរិយសច្ចទាំង៤ សម្រេចជាព្រះអរហន្ត សម្មាសម្ពុទ្ធជាម្ចាស់ ហើយទ្រង់បានទេសនា ធម៌ ដែលជាផ្លូវរំលត់ទុក្ខទាំងឡាយ ដល់មហាជនទូទៅ ។

ពាក្យប្រៀនប្រដៅរបស់ព្រះអង្គនេះ ហៅថា ព្រះធម៌ នៅ ពេលដែលអ្នកមានសទ្ធាជ្រះថ្លា ចូលមកកាប់អានព្រះពុទ្ធសាសនា កាន់តែច្រើនឡើងៗ ទ្រង់ក៏បានបញ្ញត្តិព្រះវិន័យបន្ថែមទៀត ។ ព្រះធម៌ និងព្រះវិន័យរួមគ្នាហៅថា ព្រះសាសនា ។

ព្រះពុទ្ធជាម្ចាស់ ជាព្រះសាស្តា ដែលទ្រង់បានស្ថាបនា

ព្រះពុទ្ធសាសនា ព្រះពុទ្ធជាអារ្យបុគ្គល ប្រកបដោយគុណជាអនេក និយាយដោយខ្លីៗ ចំពោះចំណុចសំខាន់ៗមាន៣ ប្រការគឺ

១-បញ្ញាគុណ បានដល់សេចក្ដីយល់ដឹង នៃសភាវធម៌ទាំងឡាយ ។

២-វិសុទ្ធិគុណ បានដល់សេចក្ដីបរិសុទ្ធិប្រាសចាកនូវ កិលេសទាំងពួង ។

៣-ករុណាគុណ បានដល់សេចក្ដីមានទឹកព្រះទ័យ អាណិតអាសូរគិតជួយសត្វលោក ឲ្យរួចចាកទុក្ខទាំងពួង ប្ដូរផ្ដាច់ លះបង់គ្រប់បែបយ៉ាង ព្រមទាំងជីវិតផ្ទាល់ព្រះអង្គឯងផង ។

ព្រះពុទ្ធជាម្ចាស់ ក្រោយត្រាស់ដឹង ទ្រង់ប្រកាសព្រះសាសនាអស់រយៈពេល៤៥ ឆ្នាំ ព្រះជន្មាយុបាន៨០ ព្រះវស្សា ក៏ទ្រង់រំលត់ខន្ធចូលកាន់មហាបរិនិព្វាន នៅថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់ ។ មុននឹងយាងចូលបរិនិព្វាន ព្រះអង្គទ្រង់ត្រាស់ឲ្យពុទ្ធបរិស័ទ គោរពរាប់អានព្រះធម៌ និងព្រះវិន័យ ដែលព្រះអង្គទ្រង់សម្ដែងទុក ហើយជាសាស្ដាជំនួសព្រះអង្គ ។

**បូជនីយវត្ថុទាក់ទងនឹងព្រះពុទ្ធជាម្ចាស់!**

ក្រោយពីព្រះពុទ្ធអង្គទ្រង់បរិនិព្វានហើយ បណ្ដាពុទ្ធសាសនិកជន បានគិតកសាងបូជនីយវត្ថុឡើង ដើម្បីសក្ការៈបូជា និងជាគ្រឿងដាស់សតិ ។ បូជនីយវត្ថុ ដែលពុទ្ធបរិស័ទស្គាល់ និងគោរពសក្ការៈច្រើនជាងគេបំផុត គឺព្រះពុទ្ធរូប ក្រៅពីនោះ ក៏នៅមាន

ព្រះបរមសារីរិកធាតុ និងស្នាមព្រះពុទ្ធបាទជាដើម ។

វត្ថុបំណងនៃការបូជាវត្ថុទាំងអស់នេះ គឺដើម្បីឲ្យចិត្តរំលឹកដល់ព្រះពុទ្ធអង្គ គឺជួយឲ្យជ្រះស្រឡះ ពីការប្រព្រឹត្តអំពើអាក្រក់ទាំងឡាយ មានកាយ វាចា ចិត្ត និងខំប្រព្រឹត្តតែអំពើល្អ ។

ក្នុងសៀវភៅសិល្បៈព្រះពុទ្ធសាសនា របស់ព្រះតេជគុណព្រះឧបាលីវង្ស សូរ ហាយ បានសរសេរថា នៅប្រទេសខ្មែរយើងមានព្រះពុទ្ធរូប៨បែបគឺ ៖

១-ព្រះពុទ្ធរូបសមាធិ

២-ព្រះពុទ្ធរូបមារវិជ័យ ( ខណៈផ្ចាញ់មារ )

៣-ព្រះពុទ្ធរូបស្តែងព្រះធម្មចក្រ

៤-ព្រះពុទ្ធរូបប្រទានអភ័យ

៥-ព្រះពុទ្ធរូបប្រទានពរ

៦-ព្រះពុទ្ធរូបទ្រង់ឈរឱបបាត្រ

៧-ព្រះពុទ្ធរូបផ្ទំ

៨-ព្រះពុទ្ធរូបប្រក់នាគ ។

( នៅមានត )

# ព្រះនាងសរស្វតីក្នុងវប្បធម៌ខ្មែរ ( ត )

ដោយ : **ពៅ សាវរស**

ប្រែសម្រួលក្រៅផ្លូវការដោយ **ហម ធាយលី**

## ២-២ ព្រះដែលខ្មែរគោរពបូជា

*មានមួយព្រះអង្គគឺព្រះនាង "សរស្វតី" (ទោះជាព្រះនាងមានឈ្មោះផ្សេងពីគ្នាក៏ដោយ) ។ ព្រះនាងជាព្រះមួយអង្គ មានស័ក្តិស្មើនឹងព្រះព្រហ្ម បន្ទាប់មកស្មើនឹងព្រះឥសូរ(សិវៈ) ។ ជួនកាលព្រះនាងជំនួសព្រះព្រហ្មទៀតផង គឺក្នុង"ត្រិបូរតី" ។ ឧទាហរណ៍នៅស.វ.ទី ១០* K.354,Ic,t v page 126,xxx *និងស.វ. ទី ១១* K352,Ic,t v,page 127-129 *បានផ្តល់ព័ត៌មានឲ្យយើងដឹងថា ការគោរពបូជាដល់ព្រះមួយក្រុម គឺព្រះនាងកគវតី (សរស្វតី) ព្រះសិវលិង្គ និងព្រះវិស្ណុ (១៣) ។ នៅសម័យមុនអង្គរ សិលាចារឹក* K.155 *ជាភាសាខ្មែរ(*K.155,Ic,t,v page 66 *) បានអត្ថាធិប្បាយឲ្យយើងដឹងដែរថា គេបានថ្វាយដល់ព្រះមួយអង្គ (ត្បាញសរស្វតី) នូវអ្នកបម្រើជាច្រើនរូប ។*

*ក្នុងសិលាចារឹកជាច្រើន បានឲ្យយើងដឹងព័ត៌មានថា មានការស្ថាបនាបដិមាករនៃព្រះជាច្រើន តាំងតែអំពីស.វ.ទី ៧ មកម្ល៉េះ (ក្នុងរជ្យព្រះបាទជ័យវម៌្មទី១) ។ ឧទាហរណ៍ ក្នុងសិលាចារឹក* K,765 p.a,Ic,tI p.9 *បានឲ្យដឹងថា មានព្រាហ្មណ៍ម្នាក់ បានថ្វាយសាលាព្រាហ្មណ៍១ បដិមាករ ព្រះនាងសរស្វតី១, សាលាធទានជាច្រើន*

ស៊ីង និងត្រពាំងជាច្រើនដល់ "ព្រះអាម្រាតកេស្វរៈ" សូមមេត្តាអានអត្ថបទនេះទៅទៀត គឺសិលាចារឹកមួយនោះទៀត K,235 (សិលាចារឹកស្តុកកក់ធំ) ដែលចារនៅ ស.វ. ទី១១ គឺរំឭកឡើងតែអំពីការសាងព្រះបដិមាករ គឺព្រះបដិមាករនៃ "ព្រះកគវតី" និងព្រះបដិមាករនៃ "ព្រះសង្ករនារាយណ៍ " ។

ក្នុងស.វ.ទី ១១ K,89 Ic,t III p.166 មានអត្ថាធិប្បាយអំពីប្រាសាទមួយឈ្មោះ " ស្រីកទ្រេស្វរាស្រម " និងបានពណ៌នាអំពីគ្រឿងបូជាយ៉ាងច្រើន ដែលគេបានថ្វាយដល់ " ព្រះសរស្វតី " និង " ព្រះភ្លើង " ។

ក្នុងស.វ. ទី១០ K,668,Ic,tI p.171 បានអត្ថាធិប្បាយដែរ អំពី"ព្រះនាងភារតីក្រាហ? បានន័យថា ប្រាសាទនៃព្រះភារតី"។ ដោយសង្ខេបមក គេគ្មានសង្ស័យទៀតទេ អំពីព្រះនេះ និងការបែកពង្រាយ? នៃព្រះនាងសរស្វតីក្នុងអតីតកាល នៃប្រទេសកម្ពុជា ។

**២-៣ នាមនៃព្រះ**

ដោយសារព្រះនាមបានបញ្ចាំង ឲ្យយើងឃើញការស្រឡាញ់របស់ប្រជាកស្ត្រទាំងអស់ចំពោះព្រះនេះ ។ ខ្ញុំបានដកស្រង់ឡើងឲ្យឃើញថា ឈ្មោះព្រះនាង "សរស្វតី" និងឈ្មោះមួយទៀត"ភារតី" គឺជាឈ្មោះនៃអ្នកបម្រើព្រះស្រីៗ ដែលមានជាលំដាប់លំដោយដូចតទៅនេះ៖

សតវត្សទី ១០ K.713,Ic.t.I page23 និងសតវត្សទី១០

ដែរ K.262,Ic,t,IV,p, 111 ។

ប៉ុន្តែក្រៅអំពីនោះ ក្នុងសិលាចារឹកឈ្មោះនោះ ច្រើនតែគេដាក់ឲ្យទៅស្ត្រី ដែលមានឋានន្តរស័ក្តិខ្ពង់ខ្ពស់ (ត្រកូលខ្ពង់ខ្ពស់) គឺត្រកូលក្សត្រិយ៍សំខាន់ (ឧ. គឺ តេង និងមេ) និងត្រកូលអ្នកមានស្តុកស្តម្ភខ្លាំង ។

ក្នុងសិលាចារឹក K,693 ស.វទី១០ គេបានឃើញចែងឡើងអំពីឈ្មោះ "មេ" សរស្វតី( k.693.Ic.t.v p.205 1.12 et 19 ) ។ សតវត្សទី១១ ដែរ K.933 មានចែងអំពីឈ្មោះ "តេង" សរស្វតី ( K.933 Ic.t IV.p.49,1-26 )។

សិលាចារឹក K,697 បានឲ្យយើងដឹងព័ត៌មានថា "តេងសរស្វតី" ក្នុងចំណោមសាលោហិត នៃព្រះបាទព្សានវម៌្មទី ២ (Ic,t VII p.94.98 ) ។

សិលាចារឹក K,806 នៅសតវត្សទី ១០ (Ic,t,I,p 78 ) បានចែងឲ្យយើងដឹងទៀតថា មានក្សត្រីមួយព្រះអង្គ សម័យមុនអង្គព្រះនាមសរស្វតី ត្រូវបានរៀបការជាមួយព្រាហ្មណ៍ម្នាក់នាងអរុនធតី ដោយព្រាហ្មណ៍វសិដ្ឋ ។

## ២-៤ សរស្វតីជាគ្រូនៃសិល្បៈនាំងពួង

លើសអំពីព្រះនាង"សក្តិ"នៃព្រះឯទៀត គឺព្រះនាងសរស្វតីជាព្រះមួយអង្គមានឫទ្ធិសម្បើម និងជាព្រះគ្រូ ដែលមានមុខងារដ៏ប្រសើរបំផុតមួយ គឺប្រវត្តិនៃការសិក្សានៅប្រទេសកម្ពុជា ។ គេ

ឃើញសក្ដីភាពដ៏វិចិត្រ គឺតាមរយៈសិលាចារឹកមួយ នៅកំពង់ធំ K.444 សតវត្សទី១០ (K. 444 ,Ic,t,I p63) ។ បានជាខ្ញុំហ៊ានអះអាងថា វិចិត្រនោះ គឺដោយសារប្រធាននោះ មានលក្ខណៈជាប្រវត្តិសាស្ត្រ ។ ព្រះបាទស្រីជ័យវរ្ម័ទី ៥ ទ្រង់បានបង្កើត "វិជ្ជាជីវៈ" ឬ " មុខងារ "ពីរគឺ :

-"មុខព្រះក្រលាអចិន" ( គឺអ្នកដែលមានភារៈកិច្ចពិនិត្យមើលនៅក្នុងសាលដែលខ្ទុកព្រះ បដិមាករ ឬ វត្ថុផ្សេងៗ )? ។

-"ករមាន្ត្រ" ( អ្នកដែលទទួលភារកិច្ចចាត់ចែង បូជាសពព្រះរាជា ឬក្រុមគ្រួសារ ក្រុមញាតិព្រះមហាក្សត្រិយ៍ ) ។ នៅផ្នែកខាងដើម នៃសិលាចារឹកបានឲ្យព័ត៌មានដល់យើងថា ព្រះបាទជ័យវរ្ម័ទី ៥ បានបញ្ជាឲ្យព្រាហ្មណ៍រៀបចំធ្វើពិធីយេជ្ញ ចំពោះដល់ព្រះ" ភគីស្វរី " (វគីស្វរីយោគ) នៅពេលដែលទ្រង់បានបញ្ចប់ការសិក្សា (ព្រះវិទ្យាផោង) ។

រឿងនោះគេបានដឹងតិចតួចណាស់ ព្រោះសិលាចារឹកមានចំណុចខ្វះខាងភាសា ពុំសូវច្បាស់លាស់ទេ (ផ្នែកខាង១) ។ តែបើតាមការដោះស្រាយវិញ មានគុណប្រយោជន៍ល្អណាស់ ក្នុងផ្នែកយល់ដឹងទូទៅនៃអត្ថបទ ។ ខ្ញុំមានភ័ព្វច្រើន ដោយបានបញ្ជាក់វែកញែករកឃើញប្រធានមួយសំខាន់ គឺត្រង់ប្រធានរបស់យើងតែម្ដងៗ ក្នុងចំណោមលក្ខខណ្ឌក្នុងកិច្ចសន្យា ។ នៃការបង្កើត"វណ្ណៈ"ពីរដូចខ្ញុំបានពណ៌នាពីខាងលើរួចមកហើយនេះ ។ អត្ថបទនេះ បានចែងថា

នារីទាំងឡាយ អាចរៀបអាពាហ៍ពិពាហ៍ បានតែជាមួយអ្នកណា ដែលគោរពស្រឡាញ់ព្រះសិវៈ (សិវភក្តិ) ។

រីយុវជន(អ្នកសី) ដែលនឹងទទួលការសិក្សា បានត្រូវតែប្រគល់ឲ្យទៅ "អាចារ្យ" នៃអាចារ្យទាំងបួន(ចតុចារ្យ) ដែលអាចារ្យទាំងអស់នោះហើយ ត្រូវបង្គាប់បង្រៀនសារពើសិល្ប៍ នៅឯកជជានី ដើម្បីឲ្យយុវជនទាំងនោះ គេបានបម្រើព្រះមហាក្សត្រិយ៍ និងពពួកអ្នកកាន់សាសនាវៀងនៅ (B,1,10,-12 )។ គេអាចពាល់បាននូវព្រឹត្តការណ៍មួយទៀត ដែលសំខាន់បំផុតនៃអតីតកម្ពុជា គឺត្រូវដឹងថាអំពីការ "អប់រំ" ប្រជារាស្ត្រ បើនិយាយឲ្យទូលំទូលាយ គឺនៅក្រោមការឧបត្ថម្ភ នៃប្រាជ្ញបណ្ឌិតព្រាហ្មណ៍ ។ ក្សត្រិយ៍ទាំងឡាយ ( ជ័យវរ្ម័នទី២ ជ័យវរ្ម័នទី៣ ជ័យវរ្ម័នទី៥ ........ ) គឺបានទទួលការសិក្សាអប់រំនៅក្នុងព្រះបរមរាជវាំង តែផ្ទុយទៅវិញកូនរបស់ប្រជារាស្ត្រ ប្រាកដជាទទួលការសិក្សាអប់រំនៅតាម"អាស្រម" និង "សាលា" ដែលដឹកនាំដោយអ្នកប្រាជ្ញបណ្ឌិតព្រាហ្មណ៍ (សូមអានវគ្គខាងលើ២.២ K.765 ) ។

ដោយហេតុនេះ ប្រសិនបើព្រះរាមត្រូវបានគេគោរពឡើងដូចអ្នក"ចម្បាំង" ហើយព្រះនាងសរស្វតី ជាព្រះមួយអង្គផ្នែកនិស្សិត (អ្នករូន=អ្នករៀន) និងសម្ភារៈក្នុងគ្រប់អាគារសិក្សាគ្រប់ជំនាន់និស្សិតទាំងអស់ក្នុងកម្ពុជា រហូតដល់ការតាំងនៅ នៃពុទ្ធសាសនាផ្នែកថេរវាទ ដែលផ្នែកសាសនានេះ នាំមកនូវគំរូព្រះសង្ឃជាអ្នក

បង្ហាត់បង្រៀន ។ ការផ្លាស់ប្ដូរនេះ បញ្ជាក់នូវការផ្លាស់ប្ដូរជាដំបូង នៃសម័យខ្មែរកណ្ដាល និងសម័យខ្មែរទំនើប ។ ព្រាហ្មណ៍ជាគ្រូបង្រៀន (អជ្ឈាបកៈ) នៅតាមអាស្រមទាំងឡាយ នៃកម្ពុជាសម័យចាស់ ត្រូវបន្ដវេនទៅឲ្យព្រះភិក្ខុ សាស្ត្រាចារ្យនៅតាមវត្ត ។ ក្រុមប្រភេទទីមួយ និយមគោរព"ព្រះនាងសរស្វតី" តែក្រុមប្រភេទក្រុមទីពីរវិញ ទទួលស្គាល់តែ "គ្រូ ឬសាស្ត្រាចារ្យ គឺព្រះពុទ្ធ" ។ ប៉ុន្ដែព្រះនាងសរស្វតីពុំបានបាត់បង់ទេ ។ បើសិនណាហើយ ព្រះនាងបានឃ្លាតចាកអំពីអាសនៈ អជ្ឈាបកៈ (គ្រូបង្រៀន) នេះក៏ដោយ ក៏ព្រះនាងនៅជានិមិត្តរូប នៃទំនៀមវិទ្យាជាដរាប ក្នុងសម័យកណ្ដាល ទោះគេយកប្រភពនៃការប្រើប្រាស់ភាសា ដោយអាចកំបាំងក្ដី គេពុំអាចលប់បាន នូវស្នាមនៃព្រះមួយអង្គ ឬទំនៀមនេះ ពីសតវត្សមួយទៅសតវត្សមួយ និងវប្បធម៌បានឡើយ ។ ទោះបីព្រះនាមរបស់នាងពុំបានបញ្ចេញឡើងនៅក្នុងសិល្បៈ សិលាចារឹកក៏ដោយ ។ មានសក្ខីភាពដោយប្រយោល នៃព្រះនាមនេះ បានបង្ហាញឲ្យយើងដឹងថា ព្រះនាងអង្គនេះ ស្ថិតនៅជាអលង្ការក្នុងវប្បធម៌ខ្មែរ ។

## ២_កម្ពុជាសម័យកណ្ដាល និងសម័យទំនើប

បើគេពុំបានពិនិត្យពិច័យទេនោះ ឃើញថា គេបាត់ស្នាមនៃព្រះនាងសរស្វតីនៅសម័យកណ្ដាល ។ ពីព្រោះព្រះនាងបានបាត់អំពីចំណោមព្រះដទៃ អំពីអក្សរសាស្ត្រ អំពីព្រះដែលជាទីសក្ការៈរបស់ប្រជារាស្ត្រ ទោះជាព្រះនាងក្លែងភេទជាព្រះនាងឧមា គណេស

ឬវៃស្រវណៈក៏ដោយ(១៥) ។ ហាក់ដូចជាគេបានបំភ្លេចព្រះនាង បាត់ទៅហើយ ។ តែដោយចៃដន្យ ដែលមកអំពីកាសាសាស្ត្រនេះឯង ហើយ ទើបបំភ្លឺខំឲ្យវែកញែករកស្នាមព្រះនាងសរស្វតីឃើញវិញ។

នៅសម័យកណ្ដាល ខ្មែរបានបង្កើតក្រសួងមួយ ក្នុងក្រសួង រាជការ ដែលគេឲ្យឈ្មោះថា " សួស្ដី " ក្រសួងនោះ បានរលត់ បាត់ទៅវិញនៅសតវត្សទី ២០ នេះ ។ អ្នកសិក្សាស្រាវជ្រាវ ទាំងអស់ បានដឹងអំពីមុខងារ នៃក្រសួងនេះតិចតួចណាស់ ក៏ដូច ជាប្រវត្តិនៃកម្ពុជាសម័យកណ្ដាលដែរ ( សូមអានក្នុងអត្ថបទនេះ លេខ ៣ ) ។ មន្ត្រីនៃព្រះរាជាណាចក្រទាំងនោះ ហាក់ដូចហោះ ហើរដូចផ្សែង ហើយបន្សល់ទុកនូវស្នាមនៃមន្ត្រីទាំងនោះ តិចតួច ណាស់ ក្នុងសម្បជញ្ញៈខ្មែរទាំងអស់ ។

ពាក្យ "សួស្ដី" Suosti . Suasdey ពុំមែនជាពាក្យខ្មែរទេ។ ពាក្យនេះ ទំនងមានប្រភពមកអំពី"អារ្យ" ប្រទេសឯណោះ ។ ព្រោះ យើងបានស្គាល់ជាញឹកញយមកហើយថា សួស្ដី ( Suosti ) គឺជា ពាក្យសំស្ក្រឹត"ស្វស្ដិ" ( Svasti ) បានន័យថា "សុភមង្គលប្រសើរ"។ ពាក្យ "សួស្ដី" នេះ អាចឲ្យន័យតាមសម្លេងអាន (Phonétiquement ) ដូចសួស្ដីដែរ តែពាក្យទាំងពីរនេះ ឥតមានន័យដូចគ្នានោះទេ ។ អ្នកនិពន្ធជនជាតិបារាំងទី១ ដែលនិយាយអំពីសួស្ដីនេះឡើង ក្នុង អត្ថបទរបស់គេ ។ពោលគឺ មានអ្នកនិពន្ធមួយ ក្នុងចំណោមនៃ អស់លោកអ្នកនិពន្ធទាំងនោះ បាននិយាយទាក់ទងនឹងប្រធាននោះថា

គឺ " ជាមន្ត្រីក្នុងរាជវាំង កាន់កាប់បញ្ជីគត់ត្រាអ្នករដ្ឋការ (រាជការ)ទាំងអស់ " (ឬអ្នកធ្វើការឲ្យស្ដេច) (Aymonier Etienne, Le cambodge, tous I , 1900 : 64) ។ អំពីអត្ថន័យពិតប្រាកដ ហើយអាចចាត់ទុកជាការត្រឹមត្រូវ ។ ប៉ុន្តែគឺគេពុំដឹងអំពីប្រភព ( Étymologie ) នៃពាក្យពិតប្រាកដ ឬកាលៈទេសៈណា ដែលពាក្យនេះ ត្រូវបានបញ្ចូលមកប្រើក្នុងវាក្យស័ព្ទខ្មែរឡើយ ( Vocabulaires cambodgien ) ។ ម្យ៉ាងទៀត គេពុំឃើញអ្នកប្រាជ្ញណាម្នាក់ យកចិត្តទុកដាក់ដល់បញ្ហានោះឡើយ ។ អស់រយៈពេលជាយូរមកហើយក្ដី ទោះជាការស្រាវជ្រាវរបស់ខ្ញុំផ្ទាល់ ក៏ពុំបានដល់ចុងបញ្ចប់ដែរ រហូតដល់ការរកឃើញកន្លាងទៃទៀតនៃវប្បធម៌ក៏ដោយ ។

ទើបតែខ្ញុំបានបើកការស្រាវជ្រាវ ឲ្យទូលំទូលាយទៀតទៅលើ "ច្បាប់" នានា និងអត្ថបទប្រៀនប្រដៅយ៉ាងច្រើន (១៦) ទើបខ្ញុំបង្កផុំឡើងបន្តិចម្ដងៗ នូវក្រសួងពិសេសមួយ ។ ក្រសួងនោះមានអត្ថន័យសំដៅការហាត់ហ្វឹកហ្វឺន ឆ្ពោះដល់យុវជនទាំងអស់ដែលមានឈ្មោះថា "ក្រសួងសួស្ដី" និងសម្រាប់បង្ហាត់បង្រៀនយុវជនទាំងនោះ ឲ្យមានចំណេះ និងក្លាយខ្លួនទៅជា"រាជការ" ឬមន្ត្រីសម្រាប់ប្រទេស ។ តែមានច្បាប់ជាច្រើនដែរ ដែលមានឈ្មោះថា " ច្បាប់សួស្ដី " ឬ"សាស្ត្រាទូន្មានខ្លួន " (១៧) សម្រាប់ឲ្យក្រសួង "សួស្ដី"នោះប្រើប្រាស់ ។ ចុះពាក្យ"មន្ត្រី"វិញបានន័យដូចម្ដេចទៅក្នុងវប្បធម៌ខ្មែរ ? បើតាមនិយមន័យ ដ៏សមរម្យមួយ ដែលមាន

ន័យបំភ័ឲ្យយើង និងដឹងបានទូវពាក្យ"សួស្ដី" គឺជាពាក្យដែលមានន័យរួមគ្នាទៅជាមួយនឹងក្រសួង " សួស្ដី " ដែរ ។

ចំពោះសង្គមចាស់ កាលអំពីនៅសម័យកណ្ដាលគឺ ជាសង្គមដែលមានជាពីរផ្នែក៖

ក-ស្ដេច (១៨) ឬ " ក្សត្រិយ៍ "

ខ-រាស្ដ្រ (១៩) ឬ " ជនសាមញ្ញ " ។

ខ-១ មន្ត្រី ឬអ្នកបម្រើស្ដេច

ខ-២ រាស្ដ្រ ឬជនសាមញ្ញ គ្មានមុខងារអ្វីក្នុងរាជការទេ ប្រជាពលរដ្ឋ (២០) ។

រាស្ដ្រ(ខ.២) មានមុខងារមួយជាប្រមុខ គឺដាំដំណាំ។ មុខងារជំនួញខ្លះ ធ្លាក់ដល់ដៃខ្មែរ ចិន ឬកូនចៅចិន ( ខ្មែរកាត់ចិន ) ។

ចំពោះខ្មែរទាំងអស់ គឺមានបំណងដ៏ធំ គឺបណ្ដុះបណ្ដាលវិជ្ជាឲ្យដល់កូនចៅរបស់គេ ដើម្បីបញ្ចូលទៅធ្វើការក្នុងក្រសួងរាជការបម្រើស្ដេច (ក្សត្រិយ៍) គឺក្លាយទៅជា"មន្ត្រី" ។ កុលបុត្រទាំងអស់នោះ ដំបូងបង្អស់ ត្រូវបានមាតាបិតា បញ្ជូនឲ្យទៅសម្នាក់សិក្សារៀនសូត្រ នៅក្នុងវត្តជាមួយព្រះសង្ឃ ។ បន្ទាប់មកមាតាបិតា នាំកុល-បុត្រទាំងនោះ ទៅសម្នាក់រៀនហ្វឹកហ្វឺនជាមួយមន្ត្រីណាមួយ ដើម្បីឲ្យមន្ត្រីនោះបង្រៀនកូនរបស់ខ្លួន ឲ្យមានមុខបរអ្វីមួយទៅអនាគត។ បើនិយាយឲ្យជាក់ស្ដែងទៅ កុលបុត្រ ជាអ្នកទៅរួមរស់ជាមួយក្រុមគ្រួសារមន្ត្រីទាំងនោះ ហើយជនទាំងនោះ ត្រូវស្ថិតនៅក្នុងក្រសួង

មួយ គឺក្រសួង"ពល" ឬ"ទាយពល" (សូមអានត្រង់វគ្គលេខ៣) ។

៣- ក្នុងអត្ថបទនៃជម្ពូទុញ្ញ (២១) ខ្ញុំបានថែងអំពីក្រុម "សួស្តី" ដែរ តែពុំសូវញឹកញយទេ និងមានភាពរយាលៗផង ដោយសារមូលហេតុយ៉ាងងាយសោះថា អ្នករាជការតូចតាច ត្រូវបានមន្ត្រីជាន់ខ្ពស់(មន្ត្រីថ្នាក់លើ) ត្រួតត្រាតាមលំដាប់ថ្នាក់ យ៉ាងធូទ់ធូរដល់មន្ត្រីក្មេងៗទាំងនោះ ។ ដូច្នោះហើយទើបមន្ត្រីក្មេងៗទាំងនោះ ដែលជាអ្នកកាន់បញ្ជី"អ្នកធ្វើការរដ្ឋ" និងជាពិសេស គឺក្រុមអ្នកគ្មានសេរីភាពទៀតផង ដែលហៅថា ពពួក"ពល" ពាក្យនេះ ទើបមានដើមកំណើតពីពាក្យសំស្ក្រឹត និងពាក្យខ្មែរចាស់ សូមអានវគ្គទី ២ ខាងលើ) ។ គឺដោយសារពពួកក្រុម "ពល" នេះហើយ ដែលគេបង្កើតជាកម្លាំងរបស់រដ្ឋ និងកម្លាំងយោធា តាមទំនៀមរបស់រដ្ឋ ។ ហើយខ្ញុំសូមគូសបញ្ជាក់យ៉ាងសំខាន់មួយទៀតថា គេបានប្រគល់បញ្ជីនេះដល់ក្រុម"សួស្តី" ពីព្រោះមន្ត្រីក្មេងៗទាំងនោះ សុទ្ធសឹងជាអ្នកប្រកបដោយចំណេះវិជ្ជាយ៉ាងប្រសើរ ។ ទោះនៅក្នុងរាជធានីក្តី ឬនៅតាមខេត្តនានាក្តី ក្រុមសួស្តីទាំងនោះ ជាអ្នកទទួលបន្ទុកទាំងអស់មើលរក្សា"ពល" ។ ក្រុមសួស្តីនោះហើយ ដែលពិនិត្យមើលបែងចែកកិច្ចការទាំងឡាយ ដល់ពលទាំងអស់ទៅតាមវេរ និងតាមសមត្ថភាពនៃពលនោះ ។ គឺក្រុម"សួស្តី" នេះទៀតមើលកៀរ និងបរពលទាំងនោះ នៅក្នុងកិច្ចការពិសេសៗ ។ ក្នុងពេលមានកលិយុគ ក្រុមសួស្តីនេះឯងហើយ ដែលជាអ្នកជ្រើសរើស រកអ្នកដែលក្លាហាន (ទាហាន) និងបរទ័ពនៅក្នុងបន្ទាយនានាគ្រប់ទិសនៃរដ្ឋ ។

# ឋានៈស្ត្រីក្នុងព្រះពុទ្ធសាសនា (តចប់)

*រៀបរៀងដោយ :*
*ព្រះមហាថេរ បណ្ឌិត ក ស្រី ធម្មានន្ទ*
*ប្រែសម្រួលដោយ :*
*ព្រះមហា឴ ឃី សុវណ្ណរតនា*

## ពុទ្ធឱវាទចំពោះស្ត្រីរៀបការ

*នៅពេលផ្ដល់ជំបូន្មានដល់ស្ត្រី អំពីតួនាទីរបស់គេក្នុងជីវិតអាពាហ៍ពិពាហ៍ ព្រះពុទ្ធទ្រង់សរសើរថា សុខសន្តិភាព និងភាពចុះសម្រុងគ្នាក្នុងផ្ទះសម្បែង អាស្រ័យយ៉ាងច្រើនលើស្ត្រី ។ ជំបូន្មានរបស់ព្រះអង្គ មានលក្ខណៈប្រាកដជាក់ស្តែង នៅពេលព្រះទ្រង់លើកឡើងនូវឧទាហរណ៍ប្រចាំថ្ងៃមួយចំនួន ដែលស្ត្រីមិនគួរប្រព្រឹត្ត ។ នៅក្នុងឱកាសជាច្រើន ព្រះពុទ្ធទ្រង់បានផ្ដល់ឱវាទថា ភរិយា :*

*ក-មិនគប្បីមានគំនិតអាក្រក់ ចំពោះស្វាមីខ្លួនឡើយ*

*ខ-មិនគប្បីមានអាកប្បកិរិយា កាច឴ ឃោរឃៅ និងរឹងរូសឡើយ*

*គ-មិនគប្បីជាអ្នកចាយវាយខ្ជះខ្ជាយ ប៉ុន្តែគប្បីចាយវាយដោយសន្សំសំចៃ ហើយរស់នៅតាមមានតាមបាន*

*ឃ-មិនគប្បីយាមកាម និងថែរក្សាដោយយកចិត្តទុកដាក់នូវទ្រព្យសម្បត្តិ និងប្រាក់កាស ដែលប្តីរកបានដោយលំបាក*

ង-ជានិច្ចកាល គប្បីមានគុណធម៌ និងភាពស្អាតស្អំ ទាំងផ្លូវកាយ និងផ្លូវចិត្ត

ច-គប្បីមានភាពស្មោះត្រង់ ហើយមិនគប្បីមានគំនិតផិតក្បត់ណាមួយឡើយ

ឆ-គប្បីមានសម្តីស្លូតបូត និងអាកប្បកិរិយាសុភាពរាបសារ

ជ-គប្បីមានសន្តានចិត្តល្អ ឧស្សាហ៍ និងមមាញឹកក្នុងការងារ

ឈ-គប្បីចេះគិតគូរ និងអាណិតអាសូរ ចំពោះស្វាមីខ្លួន ហើយអាកប្បកិរិយារបស់នាង គប្បីដូចមាតា ដែលស្រឡាញ់ និងថែរក្សាបុត្រតែមួយអញ្ចឹង

ញ- គប្បីដាក់ខ្លួនឲ្យទាប និងមានភាពគោរព

ដ- គប្បីមានចិត្តត្រជាក់ ស្ងៀមស្ងាត់ និងចេះយល់ចិត្ត នាងមិនគ្រាន់តែធ្វើខ្លួនជាភរិយាប៉ុណ្ណោះទេ តែជាមិត្តសម្លាញ់ និងជាទីប្រឹក្សាដល់ស្វាមីទៀតផង នៅពេលមានសេចក្តីត្រូវការ ។

នៅសម័យព្រះពុទ្ធ គ្រូសាសនាដទៃ ក៏បានបង្រៀនអំពីតួនាទី និងភាតព្វកិច្ចរបស់ភរិយា ចំពោះស្វាមី ដោយសង្កត់ធ្ងន់ជាពិសេស ទៅលើតួនាទីរបស់ភរិយា ដែលត្រូវពរពោះឲ្យស្វាមីនាងបម្រើដោយភក្តីភាព និងផ្តល់កាមសុខ និងសេចក្តីសុខក្នុងឋានសួគ៌

(ដល់ស្វាមី) ។ ទស្សនៈបែបនេះ ក៏មានបង្រៀនក្នុងសាសនាខុងជឺ (Comfucianism) ផងដែរ ។ ទោះបីជាតួនាទីភរិយា ចំពោះស្វាមី មានចែងក្នុងក្រមវិន័យសាសនាខុងជឺក៏ដោយ ក៏ក្រមវិន័យនោះ មិនបានចែងបញ្ជាក់អំពីតួនាទី និងកាតព្វកិច្ចរបស់ស្វាមី ចំពោះ ភរិយាឡើយ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គ្មានអគតិបែបហ្នឹង ទេ ។ នៅក្នុងសិង្គាលោវាទសូត្រ ព្រះពុទ្ធបានបញ្ជាក់យ៉ាងច្បាស់ លាស់ នូវតួនាទីរបស់ស្វាមីចំពោះភរិយា និងតួនាទីភរិយាចំពោះ ស្វាមី ។

ស្វាមីគប្បីមានភាពស្មោះត្រង់ ភាពគួរសម និងមិនស្អប់ ខ្ពើមភរិយា ។ ស្វាមី ត្រូវប្រគល់អំណាចដល់ភរិយា និងជូនគ្រឿង អលង្ការដល់នាង តាមកាលសម័យ ។

ព្រះពុទ្ធ បានផ្តល់ដំបូន្មានផ្សេងទៀតដ៏មានប្រយោជន៍ ដល់ ស្ត្រី នៅក្នុងឱកាសដទៃទៀត និងក្រោមកាលៈទេសៈខុសៗគ្នាផ្សេង ទៀត ។

## ឱវាទចំពោះស្ត្រីស្រឡាញ់សម្ផស្ស

ចំពោះអ្នកដែលស្រឡាញ់ របស់ដែលសាបសូន្យ និង សម្ផស្ស ព្រះពុទ្ធបានបង្រៀននូវមេរៀនអំពីអនិច្ចា ។ ព្រះនាងខេមា ដែលជាមហេសីរបស់ព្រះបាទពិម្ពិសារ ជាដំបូងមានការស្ទាក់ស្ទើរ ក្នុងការចូលថ្វាយបង្គំគាល់ព្រះសម្មាសម្ពុទ្ធ ដោយព្រះនាងបានឮថា ព្រះពុទ្ធធ្លាប់សម្តែង អំពីសោភ័ណភាពខាងក្រៅ ដោយពាក្យបន្ទះ

បន្ទាប់ៗ ថ្ងៃមួយព្រះនាងបានយាងធ្វើទស្សនៈកិច្ច ដោយឥតព្រាង ទុកទៅកាន់វត្ត ដើម្បីកម្សាន្តនឹងទេសភាពទីនោះតែប៉ុណ្ណោះ ។ ជា លំដាប់លំដោយ ព្រះនាង ត្រូវបានទាក់ទាញទៅកាន់សាលា ដែល ព្រះពុទ្ធកំពុងសម្តែងធម្មទេសនា ។ តាមរយៈមនោមយិទ្ធិរបស់ ព្រះអង្គ ព្រះពុទ្ធទ្រង់ជ្រាបនូវវិតក្ករបស់ព្រះនាង ហើយទ្រង់និមិត្ត នូវរូបស្រីក្មេងម្នាក់ឈរនៅមុខព្រះនាង ។ ព្រះនាងខេមាកំពុងតែ សរសើរសម្ផស្សស្រីនោះ ស្រាប់តែព្រះពុទ្ធទ្រង់ប្តូររូបនិមិត្តនោះ ពី យុវវ័យទៅមជ្ឈិមវ័យ ហើយជាបន្តបន្ទាប់ទៅវ័យចាស់ជរា រហូត ដល់ទីបំផុត រូបនោះដួលទៅលើដី មានធ្មេញបាក់ សក់ស្កូវ និង ស្បែកជ្រាវជ្រួញ ។ ការផ្លាស់ប្តូរនេះ បានធ្វើឲ្យព្រះនាងខេមាយល់ ច្បាស់អំពីភាពសាបសូន្យ នៃសម្ផស្សខាងក្រៅ ហើយទទួលស្គាល់ សភាពប្រែប្រួលនៃជីវិត ។ ព្រះនាងទ្រង់សញ្ជឹងគិតថា "តើរូបដ៏ ស្រស់ស្អាតបែបហ្នឹង អាចក្លាយជាទ្រុឌទ្រោមសាបសូន្យដូច្នោះបាន ដែរឬ ? " អីចឹង " រូបរបស់អញ ក៏នឹងមានសភាពដូចច្នោះដែរ"ៗ តាមរយៈព្រឹត្តិការណ៍នេះ ការចាក់ធ្លុះនូវសភាវៈពិត ក៏បានឡើងដល់ ព្រះនាង ។ បន្ទាប់មក ព្រះនាងបានសម្រេចព្រះអរហត្ត ហើយ ក្រោយពីបានទទួលនូវការអនុញ្ញាតពីព្រះរាជា ព្រះនាងបានចូល សាងផ្នួសជាភិក្ខុនីទៅ ។

## ឧិទានចំពោះស្ត្រីមានមនោសញ្ចេតនា

ចំពោះស្ត្រីទាំងឡាយ ដែលមានមនោសញ្ចេតនាឥតស័ក្តិ-

សម និងមានទុក្ខសោកគ្របសង្កត់ ដោយការបាត់បង់នូវមនុស្សជាទីស្រឡាញ់របស់គេ ព្រះពុទ្ធទ្រង់សម្តែង អំពីការមិនអាចគេចផុតនៃសេចក្តីស្លាប់ ដូចមានសម្តែងយ៉ាងច្បាស់ នៅក្នុងអរិយសច្ចបួន ហើយទ្រង់លើកយកនូវឧបមាជាច្រើន មកពន្យល់ត្រង់ចំណុចនេះ។

ចំពោះឧបាសិកា វិសាខា ដែលជាជីដូនមួយរូប ប្រកបដោយមនោសញ្ចេតនា និងសេចក្តីស្រឡាញ់យ៉ាងខ្លាំង នៅពេលបាត់បង់ចៅស្រីម្នាក់ ព្រះពុទ្ធទ្រង់បានជួយសម្រាលទុក្ខនាង ដូចខាងក្រោម:

"ចេញពីសេចក្តីស្រឡាញ់ សេចក្តីសោកកើតឡើង ចេញពីសេចក្តីស្រឡាញ់ សេចក្តីភ័យខ្លាចកើតឡើង ចំពោះបុគ្គលដែលបានចេញរួចផុតពីសេចក្តីស្រឡាញ់ សេចក្តីសោកពុំមាន តើភ័យខ្លាចមានមកពីណា?"។

ក្នុងឱកាសមួយផ្សេងទៀត ខណៈនាងកិសាគោតមីបានបាត់បង់កូនង៉ែតប្រុសតែមួយរបស់នាង ហើយបានចូលទៅថ្វាយបង្គំសុំឲ្យព្រះពុទ្ធប្រោសកូនង៉ែតនាង ឲ្យមានជីវិតឡើងវិញ ព្រះពុទ្ធទ្រង់ស្នើឲ្យនាងដើររកគ្រាប់ស្ពៃខៈពីផ្ទះណា ដែលគ្មានមនុស្សបានស្លាប់ ។ នាងកិសាគោតមីអាចរកបានគ្រាប់ស្ពៃ ប៉ុន្តែនាងមិនអាចរកបានគ្រួសារណាមួយ ដែលគ្មានមនុស្សបានស្លាប់ពីពេលមុនមកដូច្នោះ នាងបានយល់ច្បាស់ថា សេចក្តីស្លាប់មិនមែនកើតឡើង ចំពោះតែកូននាងមួយទេ ក៏ប៉ុន្តែ វាគឺជាបាតុភូត ដែលតែងកើតឡើងជា

ជម្មតា ចំពោះសព្វសត្វទាំងអស់ ។

រឿងនាងបដាចារ គឺជាករណីសោកនាដកម្មមួយទៀត ។ នាងបានបាត់បង់កូនពីរនាក់ ស្វាមី ម្តាយ-ឪពុក និងបងប្រុស ក្រោមស្ថានការណ៍ ប្រកបដោយសោកនាដកម្មបំផុត។ នាងបានក្លាយទៅជាមនុស្សឆ្កួត ដោយសារទុក្ខសោក ហើយបានរត់តាមផ្លូវថ្នល់ ។ នៅពេលនាងជួបនឹងព្រះពុទ្ធ ព្រះពុទ្ធទ្រង់បានជួយសម្រាលទុក្ខនាងដោយពុទ្ធដីកាដូចខាងក្រោម:

ចំពោះជនដែលត្រូវមច្ចុកជគ្របសង្កត់ហើយ
គ្មានកូនណា អាចជួយការពារជននោះបានឡើយ
ទាំងបិតាក្តី សាច់ញាតិក្តី ក៏មិនអាច ។ សាច់ញាតិ
មិនអាចជួយការពារបានឡើយ ។
ជនអ្នកមានសីល និងមានប្រាជ្ញា ដែលបានយល់ច្បាស់
នូវហេតុការណ៍នេះ គប្បីប្រញាប់ប្រញាល់សម្អាតផ្លូវ
ទៅកាន់ព្រះនិព្វានឲ្យបានឆាប់ ។

វេលាបានស្តាប់នូវពុទ្ធដីកាសម្រាលទុក្ខ និងបានយល់នូវធម្មជាតិនៃជីវិត នាងបានសម្រេចនូវព្រះអរហត្ត ហើយក៏បានចូលបួសជាភិក្ខុនីទៅ ។

## សេរីភាពសាសនាពិតប្រាកដចំពោះស្ត្រី

ការបង្កើតឡើងនូវភិក្ខុនីសង្ឃ ក្នុងវស្សាទី ៥ នៃពុទ្ធកិច្ចពិតជាបានបើកផ្លូវឲ្យមានសេរីភាព សាសនាពេញលេញ ចំពោះ

ស្ត្រីទាំងឡាយនៅសម័យពុទ្ធកាល ។ ការនេះ បានទទួលនូវជោគជ័យដ៏ត្រចះត្រចង់ ។ មានភិក្ខុនីល្បីល្បាញជាច្រើនអង្គ ដែលបានថែងចាំងពន្លឺយ៉ាងចិញ្ចាចចិញ្ចែងក្នុងការសិក្សា និងការប្រព្រឹត្តនូវព្រះធម៌វិន័យ ។ នៅក្នុងក្រសែភ្នែកពិភពលោក ព្រះពុទ្ធសាសនាត្រូវបានលើកតម្កើងដល់កម្រិតយ៉ាងខ្ពស់ ។ គម្ពីរថេរីគាថាដែលមាន ៧៧ គាថា របស់ភិក្ខុនីផ្សេងៗអង្គ គឺជាមោទនភាពមួយ ក្នុងអក្សរសាស្ត្រពុទ្ធសាសនា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនបានដាក់កំហិតដល់ភិក្ខុនី ក្នុងបញ្ហាបង្រៀន និងសម្ដែងព្រះធម៌ឡើយ។ ភិក្ខុនីសង្ឃបានផលិតនូវចំនួនភិក្ខុនីធម្មកថិកា និងធម្មធរយ៉ាងច្រើនគួរឲ្យកត់សម្គាល់ ដូចជាភិក្ខុនីសុខា បដាចារ ខេមា ធម្មទិន្នា និងមហាបជាបតី ( ព្រះមាតាចិញ្ចឹមរបស់ព្រះពុទ្ធ ) ។ ព្រះពុទ្ធសាសនា មិនដែលទទួលយកនូវទស្សនៈព្រហ្មញ្ញសាសនា ដែលពោលថា ការបានកូនប្រុស គឺជាកត្តាសំខាន់ សម្រាប់ឪពុកទៅកើតស្ថានសួគ៌នោះ ។ កូនស្រីបានក្លាយជាមនុស្សមានប្រយោជន៍ដូចកូនប្រុសដែរ ហើយអាពាហ៍ពិពាហ៍លែងជាភាពចាំបាច់ ដែលមិនអាចខានបានទៀតឡើយ ។ ស្ត្រីក្នុងព្រះពុទ្ធសាសនា មានសេរីភាពដឹកនាំជីវិតឯករាជ្យ និងដើរហើរ ប្រកបកិច្ចការរបស់គេជាធម្មតា ។ តាមរយៈការប្រទាននូវចំណែកដ៏សកម្ម ក្នុងជីវិតសាសនាដល់ស្ត្រី ព្រះពុទ្ធក៏ទ្រង់បានជួយលើកតម្កើងឋានៈស្ត្រី ក្នុងជីវិតផ្លូវលោកផងដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ការអនុញ្ញាតឲ្យស្ត្រីបានសាង ផ្នួសក្នុងព្រះពុទ្ធសាសនា គឺជាជំហានមួយលឿនពេក សម្រាប់ សម័យនោះ ហើយភិក្ខុនីសង្ឃក៏មានអាយុកាលខ្លី ។ ពេលណា ដែលវ៉ាអនុវត្តន៍ (Innovation) និងបរិវដ្ឋកម្ម (Improvemnent) កើត មុនការគិត និងវឌ្ឍនភាពរបស់មនុស្សអំឡុងយុគណាមួយ ពេល នោះ មនុស្សមិនអាចសម្របសម្រួលខ្លួនគេទៅតាមស្ថានភាព ដែល បានធ្វើឲ្យប្រសើរឡើងនោះឡើយ ហើយតែងមានទំនោរត្រឡប់ ថយក្រោយទៅរកសង្គម ដែលពួកគេធ្លាប់រស់នៅវិញ ។ ពួកគេ មិនអាចគ្រប់គ្រងស្ថានការណ៍បានឡើយ ។ ការឃោសនាប្រឆាំង ធ្វើឡើងដោយពួកព្រាហ្មណ៍ ដែលឃើញនូវប្រពន្ធវណ្ណៈរបស់គេ ទទួលនូវមហន្តរាយ និងបុព្វសិទ្ធិរបស់គេ កំពុងសាបរលាបទៅ ក៏ជាកត្តាមួយ ដែលបណ្តាលឲ្យភិក្ខុនីសង្ឃចុះអន់ថយដែរ ។

### ឆ្ពោះទៅរកសមភាព និងសេរីភាព

ជាមួយនឹងការមកដល់ នៃយុគសម័យទំនើប ក្នុងសត-វត្សរ៍ទី១៩ និងទី២០ ដែលមានដំណើរឆ្ងាយពីសម័យពុទ្ធកាល ការ រំដោះរបស់ស្ត្រី និងការស្វះស្វែងរកសេរីភាព និងសមភាព បាន បោះជំហានយ៉ាងធំ ជាពិសេសនៅបច្ចិមប្រទេស ។ ជោគជ័យនេះ គឺជាលទ្ធផលនៃនិន្នាការ និងការអប់រំសម័យទំនើប សម្រាប់ស្ត្រី នៅក្នុងភូមិគ្រឹះឧត្តមសិក្សាទាំងអស់ ។

សួន ប.អង់តូទី ជាអ្នកត្រួសត្រាយផ្លូវជនជាតិអាមេរិច

បានលាតត្រដាងទង់សមភាពសម្រាប់ស្ត្រី ក្នុងឆ្នាំ១៨៤៨ គ្រាន់តែជាង ១៣០ ឆ្នាំមុនប៉ុណ្ណោះ ។ បន្ទាប់ពីពេលនោះមក ចលនា និងការតស៊ូប្រកបដោយគោលបំណងជាទ្រង់ទ្រាយធំ បានចម្រើនទៅមុខសន្សឹមៗពាសពេញពិភពលោក ក្រោមការដឹកនាំដ៏ក្លាហានរបស់ស្ត្រីមគ្គុទ្ទេសក៍ជាច្រើន ដែលមានសមត្ថភាព និងស្នាដៃ ព្រមទាំងអង្គការស្ត្រីនានា ។ ពួកគេមានជំនឿថា ស្ត្រីមានតួនាទីត្រូវធ្វើក្នុងភាពរភាពស្នេហាជាតិជាមួយបុរស ដើម្បីចូលរួមស្ថាបនាពិភពលោកឲ្យបានប្រសើរឡើង តាមរយៈការកសាងសង្គមជាតិ ។

ចាប់តាំងពីឆ្នាំ ១៨៤៨ ពិភពលោកបានឃើញនូវចលនារបមិនអស់ ដែលមានប្រជាប្រិយភាព និងការចាត់តាំងត្រឹមត្រូវ ដើម្បីទាមទារនូវឱកាសសិក្សាអប់រំ ប្រកបដោយសមភាព សិទ្ធិនយោបាយស្មើភាព និងសមភាពសេដ្ឋកិច្ចសម្រាប់ស្ត្រី ។ នៅបស្ចិមប្រទេស ឋានៈស្ត្រីត្រូវបានលើកកម្ពស់ ដោយស្ថានភាពដែលកើតចេញពីបដិវត្តន៍ឧស្សាហកម្ម ចលនាមនុស្សធម៌ និងចលនាស្ត្រីដើម្បីសមភាព ។ នៅអាស៊ី និងប្រទេសជាច្រើនដទៃទៀត ដែលមិនសូវជឿនលឿនផ្នែកឧស្សាហកម្ម ការផ្លាស់ប្ដូរបានកើតឡើង ដោយសារអ្នកកែទម្រង់ ដែលមានមូលដ្ឋានផ្នែកសាសនារឹងមាំ ។

ក្នុងអំឡុងពេល ៥០ ទៅ ៦០ ឆ្នាំមុន ដំណើរការបង្កើនការចូលរួមរបស់ស្ត្រី ក្នុងជីវិតសេដ្ឋកិច្ចសង្គម ព្រមទាំងនយោបាយក្នុងប្រទេសរបស់គេ មានការជឿនលឿនទៅមុខ ប្រកបដោយភាព

ទីផ្សារ ៗ ជោគជ័យ ដែលស្ត្រីទទួលបានក្នុងសតវត្សទី២០ អាចពណ៌នាបានថា ជាជោគជ័យមួយធំសម្បើម ។ ស្ត្រីជាច្រើនបានទទួលជោគជ័យក្នុងវិស័យជាច្រើន ដែលពួកគេខិតខំប្រឹងប្រែង ដូចជាវិទ្យាសាស្ត្រសង្គម ពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិស័យនយោបាយ។ នៅក្នុងប្រទេសមួយចំនួន ស្ត្រីមានជោគជ័យដណ្តើមបានតំណែងនយោបាយខ្ពស់បំផុត ជានាយករដ្ឋមន្ត្រីនៃប្រទេសរបស់គេ បើទោះណាជានៅក្នុងប្រទេសមួយចំនួន គេមិនទាន់បានផ្តល់ឲ្យស្ត្រី នូវសិទ្ធិបោះឆ្នោតក៏ដោយ ។

ក្រោយសង្គ្រាមលោកលើកទីមួយ សកម្មភាពជាអន្តរជាតិ ដើម្បីលើកកម្ពស់ឋានៈស្ត្រី បានចាប់ផ្តើមឡើងក្នុងទ្រង់ទ្រាយតូចជា មួយនឹងសម្ព័ន្ធប្រជាជាតិ (League of Nations) ដែលបានរលត់រលាយទៅវិញនោះ ។ បន្ទាប់មក ធម្មនុញ្ញអង្គការសហប្រជាជាតិ បានបន្តផ្តល់គោលការណ៍សមភាព និងសេរីភាព ចំពោះស្ត្រីទាំងអស់ ។ ទីភ្នាក់ងារមួយរបស់អង្គការសហប្រជាជាតិ ឈ្មោះគណៈកម្មការស្តីពីឋានៈស្ត្រី បានអង្កេតបញ្ហារើសអើង សម្អាងលើភេទ ហើយបានពិភាក្សា ស្តីពីបញ្ហាពាក់ព័ន្ធ ទៅនឹងសិទ្ធិនយោបាយរបស់ស្ត្រី ប្រាក់បៀវត្សស្មើគ្នា សម្រាប់ការងារស្មើគ្នា ឋានៈស្ត្រីក្នុងច្បាប់សាមញ្ញ (Common Law) សញ្ជាតិស្ត្រីរៀបការ ឱកាសផ្នែកការសិក្សាអប់រំ និងសេដ្ឋកិច្ចសម្រាប់ស្ត្រី ជំនួយបច្ចេកទេស និងការចូលរួមដោយស្ត្រី ។

ទោះបី ជាគេបានទទួលជោគជ័យជាច្រើន តាមរយៈស្ត្រី

អ្នកទាមទារសិទ្ធិបោះឆ្នោតសម្រាប់ស្ត្រី និងអង្គការអន្តរជាតិនានា ដូចជាអង្គការដែលគាំទ្រ ដោយអង្គការសហប្រជាជាតិ ទាក់ទង និងការចូលរួមឲ្យបានខ្លាំងក្លា របស់ស្ត្រីក្នុងវិស័យសង្គម សេដ្ឋកិច្ច និងនយោបាយក៏ដោយ គេសង្កេតឃើញថា ស្ត្រីនៅមិនទាន់បាន ទទួលនូវសេរីភាពពិតប្រាកដនៅឡើយទេ ។

សេរីភាពពិតប្រាកដ គឺជាសេរីភាព ដែលរួចស្រឡះចេញ ពីចំណងគ្រប់ទម្រង់ទាំងអស់ៗ គេអាចទទួលនូវសេរីភាពនោះបាន តាមរយៈការអភិវឌ្ឍន៍ផ្លូវចិត្តត្រឹមត្រូវ និងការជម្រះចិត្តរបស់ខ្លួនឲ្យ បរិសុទ្ធតែប៉ុណ្ណោះ ពោលគឺ ការជម្រះ និងការសម្អាតខ្លួនឲ្យអស់ មន្ទិល លោភៈ ទោសៈ និង មោហៈ នោះឯង ។ គ្មានការពិភាក្សា សាធារណៈ បាតុកម្ម និងធម្មនុញ្ញសាកលណា អាចនាំមកនូវសេរី-ភាពពិតប្រាកដបានទេ លើកលែងតែតាមរយៈការខិតខំប្រឹងប្រែង និងសេចក្ដីមិនប្រមាទរបស់ខ្លួន ដោយការធ្វើការនាយ៉ាងទៀងទាត់ ដូចដែលព្រះពុទ្ធទ្រង់បានបង្រៀនដូច្នោះ ។

សម្រាប់ការលើកតម្កើងបុព្វហេតុស្ត្រី គេក៏អាចចាត់ទុក ព្រះពុទ្ធថា ជាអ្នកជួយរំដោះស្ត្រីលើកដំបូងបង្អស់ និងជាអ្នកលើក តម្កើងវិថីជីវិត ប្រកបដោយប្រជាធិបតេយ្យ ។ ដោយសារអនន្តគុណ របស់ព្រះធម៌នេះហើយ ដែលស្ត្រីមិនត្រូវគេស្អប់ខ្ពើម និងមើល ងាយមើលថោក ផ្ទុយទៅវិញ ពួកគេបានទទួលនូវឋានៈស្មើគ្នានឹង បុរស ក្នុងការខិតខំប្រឹងប្រែងផ្នែកផ្លូវចិត្តរបស់គេ ដើម្បីដើរតាម មាគ៌ាឆ្ពោះទៅរកការសម្រេច នូវបញ្ញាញាណ និងព្រះនិព្វាន ។

# សេចក្តីល្ងង់មានខ្លួនឯងជាសត្រូវ

ដោយ: **សមាគមធម្មិកសទ្ធាៈ**

ធម្មជាតិបានបង្កើតមនុស្សយើងមក សម្បូរទៅដោយសេចក្តីទុក្ខច្រើនជាងសុខ ក៏ប៉ុន្តែមនុស្សយើង ទោះបីជាបានដឹងថាសេចក្តីទុក្ខតែងកើតមានច្រើនជាងសេចក្តីសុខ យ៉ាងណាក៏ដោយក៏ពុំបាននាំគ្នាសិក្សាឲ្យស្គាល់ច្បាស់នូវធម្មជាតិ ដែលជាហេតុនាំឲ្យកើតសេចក្តីទុក្ខនោះដែរ ។

សេចក្តីទុក្ខតែងកើតមាន ព្រោះសេចក្តីមិនដឹង ចំណែកសេចក្តីមិនដឹង តែងកើតមានព្រោះសេចក្តីប្រមាទ ហើយដើម្បីឲ្យរួចផុតពីសេចក្តីប្រមាទ គឺត្រូវតែស្គាល់ឲ្យបានច្រើន និងធ្វើទុកក្នុងចិត្តដោយប្រពៃ នូវលក្ខណៈណាដែលល្អ ។

យើងបានជ្រាបខ្លះៗហើយថា សេចក្តីមិនដឹងអាស្រ័យមាននៅក្នុងមនុស្សគ្រប់រូប វៀរតែព្រះអរហន្តចេញ ទើបពុំមានសេចក្តីល្ងង់នេះ ។ តើសេចក្តីមិនដឹងនោះជាអ្វី? គឺមិនដឹងនូវធម្មជាតិ ដែលជាហេតុនាំមកនូវសេចក្តីសុខ ឬសេចក្តីទុក្ខ សេចក្តីសុខនៅពេលនេះ សូមលើកយកមកបង្ហាញ នូវសេចក្តីសុខពីរយ៉ាងគឺ:

១-សេចក្តីសុខកើតឡើងអំពីអាមិសៈ (សុខ៤យ៉ាងរបស់យកវាស) ។

២-សេចក្តីសុខកើតឡើង ព្រោះពុំត្រូវការអាមិសៈ ជាពិសេសទៅទៀត ដើម្បីជាប្រយោជន៍នៅពេលនេះ យើងគួរពិភាក្សា

គ្នា ចំពោះតែសេចក្ដីសុខ ដែលកើតឡើងព្រោះលាភសក្ការៈ (អាមិសៈ) ជាមុនសិនថា តើមានលក្ខណៈដូចម្ដេច? ធម្មជាតិដែលមានឈ្មោះថាសុខ គឺមិនមានរោគជាលក្ខណៈ រោគមានចំណែកពីរយ៉ាងគឺ រោគផ្លូវកាយ និងរោគផ្លូវចិត្ត ។

**អំពីរោគផ្លូវកាយ**

អាវយវៈតូចធំ ដែលប្រមូលរួមផ្សំគ្នា ក៏បានទៅជាទីប្រជុំមួយឈ្មោះថា "រាងកាយឬសរីរៈ" ដែលជាធម្មជាតិ អាចតាំងនៅបាន អាស្រ័យអាហារ កាលបើអស់ជាតិអាហារហើយ រាងកាយនេះ ក៏ពុំអាចតាំងនៅបានយូរដែរ ។ អាហារនៅពេលនេះ គឺសំដៅដល់ បាយ ទឹក នំចំណី និងថ្នាំសង្កូវផ្សេងៗ សម្រាប់ទ្រទ្រង់រាងកាយនេះ ឲ្យតាំងនៅបានយូរ ដើម្បីប្រព្រឹត្តនូវអំពើល្អ ។ រោគផ្លូវកាយកើតមាន ព្រោះសភាពពុំប្រក្រតីនៃធាតុទាំងឡាយ ដែលទ្រទ្រង់រាងកាយ ទៅតាមបទដ្ឋាននៃធម្មជាតិ ។ សេចក្ដីឈឺចាប់ព្រោះមានដំបៅ ឬរោគបាត់បង់លោហិត ។ល។ ទាំងអស់នោះជាដើម សុទ្ធសឹងជាការបាត់បង់ធាតុ សម្រាប់ទ្រទ្រង់រាងកាយ។ ធាតុសម្រាប់ទ្រទ្រង់រាងកាយ ពុំមែនមានត្រឹមតែអាហារតែម្យ៉ាងនោះទេ គឺមានច្រើនប្រភេទណាស់ ដូចជាខ្យល់អាកាស ជាដើម ។ យើងមានអាហារបរិភោគគ្រប់គ្រាន់ក៏ពិតមែន ប៉ុន្តែខ្យល់សម្រាប់ដកដង្ហើមមិនល្អបរិសុទ្ធ ក៏ជាហេតុនៃរោគដែរ ឬមួយថាខ្យល់ដកដង្ហើមបានល្អបរិសុទ្ធហើយ ប៉ុន្តែអាកាសបរិដ្ឋានមិនល្អ ក៏ជាមូលហេតុនៃ

ភេគដែរ ។ ហេតុនេះ យើងឃើញថា ធម្មជាតិដែលទំនុកបម្រុង រាងកាយមនុស្សយើង ពុំអាចខ្វះណាមួយបានឡើយ ។ មាន លក្ខណៈពិសេសមួយទៀត ដែលជាហេតុនាំមកនូវភេគទាំងនោះ គឺសេចក្តីមិនដឹង តើមិនដឹងអ្វី? គឺមិនដឹងហេតុ ដែលនាំឲ្យកើតភេគ ការប្រមាទមិនព្រមស្តាប់ដំបូន្មានពីសម្មាក់អ្នកដទៃ ជាហេតុនាំមក នូវសេចក្តីមិនដឹង គឺមិនដឹងហេតុដែលនាំមកនូវសេចក្តីសុខ (គ្មាន ភេគទាំងក្នុងបច្ចុប្បន្ន និងតទៅអនាគត) ។

យើងគួរនាំគ្នាពិចារណាថា ការស្តាប់អំពីសម្មាក់អ្នកដទៃ ជាការសំខាន់ណាស់ ពាក្យត្រង់ណាដែលគេនិយាយខុស នឹងនាំមក ឲ្យយើងដឹងថាខុស ព្រោះវាពុំបាននាំមកនូវប្រយោជន៍ ប៉ុន្តែពាក្យ ត្រង់ណាដែលគេនិយាយត្រូវ នឹងនាំឲ្យយើងដឹងថាត្រូវ ព្រោះវានាំ មកនូវប្រយោជន៍ ហើយផ្ញើទុកក្នុងចិត្ត សម្រាប់អនុវត្តន៍តាមតទៅ ថ្ងៃមុខ ដូចជាការស្តាប់ពីសម្មាក់អ្នកដទៃ គេនិយាយថា បច្ចុប្បន្ន នេះ សម្បូរនូវជំងឺប្លែកៗច្រើនណាស់ យើងត្រូវការពារដោយវិធី ផ្សេងៗជាច្រើន ទាំងអស់នេះឯង ដែលយើងត្រូវតែដឹង ព្រោះវានាំ មកនូវសារៈសំខាន់ សម្រាប់ភេគទាំងអស់នោះ ។ យើងបានជ្រាប ហើយថា ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គជាអ្នកត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃពិតចំពោះព្រះអង្គ ទាំងបញ្ញត្ត លោក នឹងបរមត្ថលោក ។ បញ្ញត្តលោក គឺមានព្រះវិន័យជាដើម ដែលព្រះអង្គស្តេចទ្រង់បញ្ញត្តទុក សម្រាប់ភិក្ខុសង្ឃក្នុងសាសនា

របស់ព្រះអង្គ លោកបដិបត្តិតាម ដូច្នេះការដឹងប្រយោជន៍នៃសេចក្តីសុខក្នុងលោកនេះ គឺត្រូវតែដឹងឲ្យបានច្រើនៗ ទើបជាការគួរ យើងហាត់សន្សំសេចក្តីយល់ដឹងជាប្រយោជន៍ និងលះបង់នូវអ្វីណាដែលជាប្រយោជន៍ ។ សេចក្តីដឹងជាប្រយោជន៍សំខាន់ណាស់ សម្រាប់មនុស្សគ្រប់ប្រភេទ បើយើងពុំដឹងផ្លូវលោកឲ្យបានសមគួរ សម្រាប់ការពារជីវិតរបស់យើង កុំឲ្យមានភេគបៀតបៀនទេនោះ តើយើងនឹងអាចសាងសេចក្តីល្អ មានការឲ្យទាន រក្សាសីលជាដើមដូចម្តេចកើត ។ ហេតុនេះ ត្រូវដឹងនូវអ្វីដែលគួរដឹង ហើយត្រូវលះបង់នូវអ្វីដែលគួរលះបង់ ។ យើងគប្បីដឹងវិធីការពារភេគគ្រប់យ៉ាង ត្រូវដឹងវិធីថែរក្សាភេគគ្រប់យ៉ាង ត្រូវដឹងការសាងសេចក្តីល្អគ្រប់យ៉ាង ត្រូវដឹងនូវហេតុ ដែលនាំឲ្យមានសេចក្តីវិនាសគ្រប់យ៉ាង (ដើម្បីលះបង់) និងត្រូវលះបង់សេចក្តីប្រមាទគ្រប់យ៉ាង ដូចជាការធ្វើខ្លួនឲ្យលុងកាមតណ្ហា ក្នុងកាមគុណទាំង៥.......... ជាដើម ។

កាមគុណទាំង៥ជាហេតុនៃភេគ ដែលបុរាណាចារ្យលោកឲ្យឈ្មោះថា "កាមភេគ" ។ សម័យបច្ចុប្បន្ន បើនិយាយកាមភេគ យើងសំដៅដល់ភេគដែលកើតមាន ព្រោះការសេពសន្ថវៈតែម្យ៉ាងតាមពិតនោះ ហេតុរបស់វាកើតមានតាំងពីការឃើញរូបស្អាត ឮសម្លេងពីរោះ ហិតក្លិនក្រអូបដឹងរសជាតិឆ្ងាញ់ សេចក្តីសុខស្រួលតាមផ្លូវកាយរួមទាំងសេចក្តីត្រេកអរ តាមផ្លូវចិត្តជាដើមនោះ កាមភេគក៏ប្រាកដឡើង ។ មនុស្សយើង ហេតុតែរស់នៅក្នុងអន្លង់កាម

លះបង់កាមបានដោយលំបាក ព្រោះពុំបានដឹងថា កាមជាអាសិរ្ពិស ហេតុដូច្នេះ ហើយពុំអាចលះបង់ចោលកាមបានទេ ក៏ត្រូវតែមានស្មារតីខ្លះ កុំឲ្យកាមសម្លាប់ឲ្យចាប់ស្លាប់ពេក ។ ស្មារតីទាំងនោះ គឺមានការរក្សាសីល ៥ សីល៨ ជាដើម ដែលជាហេតុរម្ងាប់នូវកាម ព្រោះសីលនាំមកនូវការទប់ចិត្ត កុំឲ្យកើតតម្រេក ក្នុងកាមហួសប្រមាណ រហូតដល់ធ្វើឲ្យអ្នកដទៃរងគ្រោះ ដោយសារកាមរបស់ខ្លួនជាដើម។ យើងបានជ្រាបហើយថា ជីវិតរបស់មនុស្សកើតឡើងអាស្រ័យធម្មជាតិ និងធម្មជាតិ រោគទាំងឡាយកើតឡើងក៏អាស្រ័យធម្មជាតិ និងធម្មជាតិដែរ ។ ហេតុនោះយើងត្រូវតែនាំគ្នាដឹង កុំប្រមាទត្រូវស្តាប់ដំបូន្មានអ្នកដទៃ និងធ្វើទុកក្នុងចិត្តដោយប្រពៃ សម្រាប់ជីវិតរស់នៅបានយូរអង្វែង និងសាងសេចក្តីល្អ ព្រមទាំងសេចក្តីសុខក្នុងលោក ដែលជាកាមសុខ និងមានលោកុត្តរសុខជាទីបំផុតទើបជាមនុស្សដ៏ប្រសើរ សម្រាប់អត្តភាពដ៏សែនកម្ររកបាននេះ ។

## អំពីរោគផ្លូវចិត្ត

រូបកាយ និងចិត្តជាធម្មជាតិមានចំណែកផ្សេងគ្នា តែអាស្រ័យគ្នាជានិច្ច បែកគ្នាមិនបាន ហើយរួមសុខរួមទុក្ខជាមួយគ្នា ។ គ្រាខ្លះរូបកាយមានរោគកើតឡើង ចិត្តក៏ឈឺចាប់ គ្រាខ្លះទៀត ចិត្តមានវិបត្តិ ( រោគកើតឡើង ) កាយក៏សោប់សោលញ៉ូវខ្លួន បញ្ចេញអាការប្រឡាមខាមជាដើម ។ ចិត្តមានរោគ គឺចិត្តនោះឯងមានវិបត្តិ ឬវិប្បដិសារៈ (សេចក្តីក្តៅក្រហាយស្តាយក្រោយ) ព្រោះពុំមានសីល

ព្រោះពុំដឹងថា សីលជាឱសថត្រជាក់ សម្រាប់រម្ងាប់រោគផ្លូវចិត្ត ហេតុនេះ ត្រូវរក្សាសីលឲ្យបានល្អប្រសើរជានិច្ច ។ មនុស្សយើង បើទូន្មានកាយវាចា ឲ្យកាន់យកនូវសុចរិតកម្មល្អប្រពៃហើយ វានឹងបានជាសម្លៀកបំពាក់ សម្រាប់គ្របដណ្តប់ចិត្ត កុំឲ្យរងារបាន ផ្ទុយទៅវិញ បើកាយវាចាពុំបានទូន្មានឲ្យល្អទេ ចិត្តប្រាកដជារងារ មានវិប្បដិសារៈជាប់ជានិច្ច ។ ឧទាហរណ៍ ការក្បត់ចិត្តភរិយារបស់ ខ្លួនទៅមានស្រីដទៃ ឈ្មោះថា គ្មានសីល ព្រោះពុំមានការស្មោះ ស្ម័គ្រភរិយារបស់ខ្លួន ចំណែកស្ត្រីក៏មានន័យដូចគ្នា ។ ត្រង់សេចក្តី នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ជាហេតុនៃសេចក្តីវិនាស ។ បុគ្គលគ្មានសីល ត្រូវវិនាសគ្រប់បែបយ៉ាង ជីវិតខ្លួនឯងក៏ត្រូវធ្លាប់ វិនាស ប្រពន្ធកូន ទ្រព្យសម្បត្តិ ក៏វិនាសជាបន្តបន្ទាប់ ព្រោះតែហេតុ នៃសេចក្តីប្រមាទ ។ រោគផ្លូវចិត្តចង្វាយជាងផ្លូវកាយ បើសិនទៅ ក្នុងផ្ទះ ជាពិសេសមេគ្រួសារជាអ្នកគ្មានសីល នោះការជួបប្រទះ រោគផ្លូវចិត្ត ប្រាកដជាកើតមានជាហូរហែរ ហើយជម្រកសុភមង្គល ចុះជ្វាយហែកដាច់ជារៀងរាល់ថ្ងៃ ជួនកាលឈ្លោះប្រកែកគ្នា ជួនកាល ប្រពន្ធឈឺ ខ្លួនឯងឈឺ កូនក៏មិនដោយកន្ទុំធម៌...។ល។

យើងបានជ្រាបហើយថា ការប្រកបមុខរបរគ្រប់បែបយ៉ាង គឺ ដើម្បីរកប្រយោជន៍ឲ្យចិត្តមានសេចក្តីសុខ ប្រសិនបើយើងមិនដឹង ហេតុនៃសេចក្តីសុខ តើយើងអាចសាងជម្រកឲ្យចិត្តបានដែរឬទេ? សេចក្តីប្រមាទ ជាហេតុនាំមកនូវសេចក្តីទុក្ខ សេចក្តីមិនប្រមាទ ជា

ជាហេតុនាំមកនូវសេចក្ដីសុខនៃចិត្ត ការស្ដាប់អ្នកដទៃ និងការធ្វើទុកក្នុងចិត្ត នូវពាក្យពេចន៍ជាប្រយោជន៍ ជាហេតុនាំឲ្យមានសេចក្ដីមិនប្រមាទ ព្រោះហេតុតែបានឮញឹកៗញយៗ អំពីទោសនៃសេចក្ដីវិនាស ក៏បានផ្ដល់នូវការយល់ច្បាស់ អំពីការកសាងផ្លូវចិត្តឲ្យប្រព្រឹត្តទៅដោយពុំមានភេក កាលបើចិត្តពុំមានភេក ចិត្តនោះឈ្មោះថា មានសេចក្ដីសុខ ។

សេចក្ដីសុខរបស់ចិត្ត ពុំមានអាស្រ័យទ្រព្យសម្បត្តិតែម្យ៉ាងនោះទេ សំខាន់ទៅទៀតនោះ គឺសេចក្ដីស្មោះត្រង់ រវាងគ្នានឹងគ្នា ដែលជាសច្ចធម៌របស់សង្គមគ្រួសារតូច ឬធំ បើពុំមានសច្ច-ធម៌ សីលក៏ដាច់ ចិត្តក៏មានភេក គ្រួសារគ្មានសុកមង្គល ហើយជាពិសេសនោះ នឹងត្រូវជួបប្រទះសេចក្ដីអាម៉ាស់ទៀតផង ។ កាមចិត្តកើតមានសម័យណា ភេកផ្លូវចិត្ត ក៏កើតនៅសម័យនោះ ព្រោះហេតុថា អារម្មណ៍ជាវត្ថុ សម្រាប់ឲ្យចិត្តកើតភេក ។ តើយើងគប្បីរក្សាចិត្តកុំឲ្យកើតភេក ដោយប្រការដូចម្ដេច? នេះជាសំណួររបស់យើងម្នាក់ៗ ដែលត្រូវសួរចំពោះខ្លួនឯង ឲ្យបានរឿយៗជាប្រចាំក្នុងជីវិតរាល់ថ្ងៃ។ យើងរក្សាចិត្តកុំឲ្យមានភេក ដោយការទូន្មានកាយ វាចា (រក្សាសីល) និងកាន់ចិត្តអំណត់អត់ធន់ (ខន្តី) កុំឲ្យលង់ក្នុងអំណាចរបស់កាមអូសទាញនោះ ទើបចិត្តរួចផុតពីការមានភេកទៅបាន ។ យើងបានដឹងហើយថា ព្រះដ៏មានព្រះភាគ ព្រះអង្គពុំមានភេកផ្លូវចិត្តឡើយ ព្រោះព្រះអង្គបរិបូណ៌ដោយសីល បរិបូណ៌ដោយធម៌

និងបរិបូណ៌ដោយបញ្ញា ។ ចំណែកយើងជាបុថុជ្ជន គប្បីព្យាយាមរក្សាសីល ចម្រើនសមាធិ អប់រំបញ្ញា ដើម្បីរម្ងាប់មេរោគទាំងឡាយដែលធ្វើឲ្យចិត្តមានវិបត្តិ ប្រយោជន៍សាងជម្រកសុភមង្គលឲ្យចិត្តរបស់ខ្លួន និងក្រុមគ្រួសារ ដល់នូវសេចក្ដីសុខជានិច្ចនិរន្តរ៍ ទើបមានឈ្មោះថា ជាមនុស្សប្រសើរក្នុងលោកនេះ ។

សរុបសេចក្ដីមក ការមិនដឹង(ល្ងង់) ពុំមែនកើតមានព្រោះអ្នកដទៃនោះឡើយ តែសេចក្ដីមិនដឹងកើតមាន ព្រោះខ្លួនយើងមានសេចក្ដីប្រមាទ ឬមើលងាយពុំសន្សំការដឹង ពុំស្គាល់ការទូន្មានពីសម្មាក់សប្បុរស មានព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ឬមួយសេចក្ដីប្រកាសទូន្មាន ហាមប្រាមរបស់ច្បាប់រដ្ឋ ច្បាប់សង្គមជាដើម ។ សេចក្ដីមិនដឹង មានទោសច្រើនប្រការណាស់ មានគ្រោះថ្នាក់ទាំងផ្លូវលោក( ច្បាប់រដ្ឋ ) មានគ្រោះថ្នាក់ទាំងផ្លូវធម៌ ( ច្បាប់ធម្មជាតិ ) ព្រោះហេតុដូច្នេះ យើងគួរនាំគ្នាចម្រើននូវការដឹង លះបង់ចោលការមិនដឹង រស់នៅប្រកបដោយសេចក្ដីមិនប្រមាទ ហើយស្គាល់នូវពាក្យទូន្មានគ្រប់យ៉ាង ដែលនាំមកនូវប្រយោជន៍ដល់ជីវិតរបស់ខ្លួន និងសង្គមគ្រួសារតូច ឬធំ ដើម្បីឲ្យរួចផុតចាកសេចក្ដីទុក្ខ ដែលកើតមាន ព្រោះតែសេចក្ដីល្ងង់របស់ខ្លួនឯងជាបរិយោសាន ។ សម្បត្តិអ្វីប្រសើរលើសជីវិតពុំមាន មនុស្សយើងដែលមានកំណើតអាស្រ័យការមានគភ៌នៃមាតា ពុំមែនអាស្រ័យដោយ ស៊ុត ញើសឧប្បត្តិក(ការកើតឯង)នោះឡើយ ហេតុនេះតើកំណើតមនុស្សពិសេស

យ៉ាងណាទៅ ? តាមន័យរបស់ ។

ព្រះពុទ្ធសាសនាបានស្រាយបំភ្លឺថា មាតាគឺជាស្ត្រីមានរដូវ គឺលោហិតដ៏បរិសុទ្ធមិនមានរោគ បានប្រកពនឹងបិតា ក្នុងគ្រាតែមួយជាមួយគ្នា ក៏បានទៅជាទីអាស្រ័យ (ប្រទេស) សម្រាប់ការតាំងគភ៌គ្រប់ប្រាំពីរថ្ងៃ ដែលសត្វចុះចាប់កំណើត ព្រោះហេតុតែមានការប្រែប្រួលរបស់លោហិតរដូវកើតមាន ។ សេចក្ដីបរិសុទ្ធនៃលោហិត ពុំមែនមានត្រឹមតែមាតាប៉ុណ្ណោះទេ ខាងបិតាក៏បរិសុទ្ធបដិសន្ធិវិញ្ញាណរបស់សត្វចុះចាប់កំណើត ក៏ត្រូវតែបរិសុទ្ធយ៉ាងពិសេសដែរ ។ មនុស្សយើងកើតឡើងបាន ក៏ព្រោះអាស្រ័យផលបុណ្យ ពីអតីត ហើយផលនៃបុណ្យទាំងនោះ ក៏អាស្រ័យដោយព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធចង្អុលបង្ហាញ អំពីហេតុនៃសេចក្ដីល្អ ដែលនាំឲ្យបានកើតជាមនុស្ស ដូច្នេះពូជកំណើតដើមរបស់មនុស្ស សុទ្ធសឹងប្រជុំរួមផ្សំដោយអំពើល្អ គឺបុណ្យទាំងអស់ តើមនុស្សគប្បីធ្វើអំពើអាក្រក់ ដែលផ្ទុយពីធម្មជាតិដើមបានដែរឬទេ ? កាលបើមនុស្សសាងអំពើអាក្រក់នោះ ទឹងមានឈ្មោះថា ទម្លាប់ជីវិតខ្លួនដោយពិត ឬធ្វើឲ្យជីវិតរបស់ខ្លួនខ្ទីទៅៗ ។ ជីវិតរបស់មនុស្សយើងរកបានដោយកម្រ ពុំមែនកើតបានមកវិញងាយៗនោះទេ កើតឡើងអាស្រ័យបុណ្យ គឺសេចក្ដីល្អដូចបានពោលរួចមកហើយ ហេតុនេះសូមសាកសួរខ្លួនឯងទៅមើល តើក្នុងមួយថ្ងៃៗ បានធ្វើសេចក្ដីល្អអ្វីខ្លះ? បើបានសួរហើយនោះនឹងដឹងថា សេចក្ដីល្អស្ទើរតែពុំមាន ព្រោះមួយថ្ងៃៗ

សុទ្ធសឹងតែលោភៈ ទោសៈ និងមោហៈកើតមានពុំដាច់រយៈ តើគួរពឹងថា ទើបបានកើតជាមនុស្សទៅដែរឬ ? ប្រាកដជាពុំមានសង្ឃឹមឆ្ងាយនោះឡើយ ។ មនុស្សយើងគ្រប់រូបគួរគិតផងដែរថា នៅពេលចាប់កំណើត គឺអាស្រ័យលោហិតរបស់អ្នកមានគុណទាំងពីរ ពុំមានរោគ មានកម្លាំងអាចធ្វើជាខេត្ត សម្រាប់បរិញ្ញាណជាបុណ្យចុះចាប់កំណើតនៅបាន រូបក៏មានការចម្រើនឡើងដោយធាតុទាំងឡាយជាច្រើន មានឱជៈនៃអាហារទៅចិញ្ចឹមរក្សា តាមរយៈនៃការបរិភោគដោយសេចក្តីមេត្តារបស់អ្នកម្តាយ ក៏បានករពូនទៅជាសត្វមួយរូប ប្រសូតមកមានអវយវៈ អាចរស់នៅបានដូចគេឯង ក៏ព្រោះតែកម្លាំងរបស់បុណ្យពីអតីត ជួយទំនុកបម្រុងយ៉ាងសកម្មបំផុត ។ ហេតុដូច្នេះជីវិតនេះ បានមកដោយចំណែករបស់មាតាខ្លះ និងចំណែកបិតាខ្លះ ចំពោះចំណែករបស់យើងនោះ រកឃើញដោយលំបាក តើយើងត្រូវថែរក្សា និងធ្វើជីវិតនេះ ឲ្យកើតបានជាប្រយោជន៍ ដូចម្តេចខ្លះ? ជីវិតរបស់មនុស្សយើង ក្រៅពីរស់នៅសាងតែអំពើល្អនោះ គ្មានអ្វីទៀតឡើយ ព្រោះអំពើល្អទាំងឡាយ ទាំងពួងឈ្មោះថា ជាការគោរពមាតាបិតា គោរពគ្រូអាចារ្យ គោរពជីវិតដើម ដែលជាបុណ្យរបស់ខ្លួនតាំងពីបដិសន្ធិ កាលទើបជាហេតុនាំឲ្យបានអាយុវែងទៀតផង ។

មនុស្សយើងគ្រប់គ្នា រស់នៅក្នុងលោកកំពុងបៅដោះ (ទឹកដោះ) ព្រះសម្មាសម្ពុទ្ធ ក៏ព្រោះផលនៃបុណ្យ ដែលព្រះពុទ្ធទ្រង់បាន

ប្រទានឲ្យ ។ ក្នុងគម្ពីរពុទ្ធវង្សបានបញ្ជាក់ថា ព្រះពុទ្ធពុំមែនមានតែក្នុងកប្បនេះប៉ុណ្ណោះទេ គឺមានតាំងពីអនេកកប្បកន្លងមកហើយ ក៏ព្រោះសម្រាប់ត្រាស់ដឹង និងត្រាស់សម្តែងព្រះធម៌បំភ្លឺសត្វលោកឲ្យសាងអំពើល្អ ដែលជាហេតុបានផ្តល់នូវសុគតិភព និងមានទីបំផុតគឺព្រះនិព្វាន ។ ផ្ទុយទៅវិញ សត្វលោក ពេលបានកើតជាមនុស្ស ឬជាទេវតាហើយ វង្វេងមិនស្គាល់ថា កំណើតដែលកើតមកនេះព្រោះហេតុនៃគុណរបស់ព្រះសម្មាសម្ពុទ្ធរាល់ព្រះអង្គ បែរជានាំគ្នាទិដ្ឋិយល់ខុស ជឿទៅលើលទ្ធិផ្សេងៗ ខុសពីព្រះគុណដ៏អស្ចារ្យរបស់ព្រះជិនស្រីនៃយើង យ៉ាងយុត្តិធម៌បំផុត។ គុណរបស់ព្រះពុទ្ធប្រសើរយ៉ាងណា - គុណរបស់មាតាបិតាប្រសើរយ៉ាងនោះ គុណរបស់មាតាបិតាប្រសើរយ៉ាងណា គុណដែលបានកើតមកជាមនុស្សប្រសើរយ៉ាងនោះ គុណដែលបានកើតមកជាមនុស្សប្រសើរយ៉ាងណា គុណដែលឲ្យជីវិតតាំងមកនៅពេលបច្ចុប្បន្ននេះ ប្រសើរយ៉ាងនោះ តើត្រូវបំពេញនូវការតបគុណទាំងអម្បាលមាននោះ ដោយប្រការដូចម្តេច ? ។

ការតបគុណ ពុំមានអ្វីក្រៅពីសាងសេចក្តីល្អដល់ខ្លួន មានការរក្សាសីល ចម្រើនមេត្តា ការទានជាដើមនោះទេ ព្រោះសីលរមែងនាំមកនូវសេចក្តីសុខ សម្បូរភោគទ្រព្យ អាយុយឺនយូរ ស្លាប់ទៅមានកំណើតក្នុងសុគតិភព ហើយមានទីបំផុត គឺព្រះនិព្វាន ចំណែកការទានឈ្មោះថា ការចម្រើន គឺមានការចម្រើននូវកុសលធម៌

គ្រប់យ៉ាង មានសមថការនា និងវិបស្សនាការនាជាដើម ។ ព្រះពុទ្ធ-សាសនា ជាមរតកមហាសាលរបស់ប្រជាជាតិខ្មែរ ក្នុងយុគសម័យកុំព្យូទ័រ។ បុព្វបុរសខ្មែរសម័យមុន បានទទួលរក្សាទុក នូវពន្លឺសីលធម៌ ដ៏វិសេសវិសាលពីអាណាចក្រឥណ្ឌា ដែលព្រះមហាសោណត្ថេរ និងព្រះឧត្តរត្ថេរ ទ្រង់បានយកមកប្រតិស្ឋានទុក ក្នុងដែនសុវណ្ណភូមិ សម្រាប់សេចក្ដីសុខ និងសេចក្ដីចម្រើនរបស់មនុស្សជាតិទាំងឡាយ ដែលមានឧបនិស្ស័យនឹងព្រះពុទ្ធសាសនា។ មរតកមហាសាលនេះ ត្រូវបានបុព្វបុរសយើងថែរក្សាទុកមករហូតដល់យុគសម័យអង្គរ ។

ដោយហេតុតែផលបុណ្យ របស់អ្នកសម័យអង្គរមាន ទើបមានពន្លឺនៃព្រះពុទ្ធសាសនា បានបែងចាំងឡើង កើតមាននូវក្រមសីលធម៌ និងបញ្ញាញាណដល់មនុស្ស សម័យអង្គរបានរុងរឿងគ្រប់វិស័យ រហូតដល់មានឈ្មោះថា " មហានគរ " ប្រជាជាតិទាំងឡាយនៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ សុទ្ធសឹងតែបានទទួលនូវចំណែកព្រះពុទ្ធសាសនា តិច ឬច្រើនដូចគ្នា ប៉ុន្តែប្រទេសណាដែលមានឧបនិស្ស័យនឹងព្រះសម្មាសម្ពុទ្ធ ក៏បានថែរក្សាមករហូតដល់សព្វថ្ងៃនេះ ។ ចំណែកប្រទេសឯទៀត ដែលពុំមានឧបនិស្ស័យវិញនោះ ក៏ត្រូវវិនាសស្ទើរគ្មានសល់ ។ ដោយឡែកប្រទេសកម្ពុជាយើង តែងបានយកព្រះពុទ្ធសាសនា ជាម្លប់គ្រប់កាលសម័យ ដូច្នេះហើយទើបយើងសង្កេតឃើញថា ប្រជាជាតិខ្មែរមានចរិតស្លូតបូត

សុភាពរាបសារ ហើយទន់ភ្លន់ ព្រោះសន្ដានចិត្តព្រះពុទ្ធសាសនា បានដក់ជាប់ក្នុងក្រអៅបេះដូងកូនខ្មែរ ។

មកដល់បច្ចុប្បន្ននេះ ដោយ សារសម្ពាធវប្បធម៌ អារ្យធម៌របស់បរទេស ដែលបានវាយលុកទាំងយប់ទាំងថ្ងៃ ធ្វើឲ្យប្រជាជាតិដ៏សែនកំសត់នេះ វិវក់វិកវរក្លេចភ្លាំងស្មារតី បាត់បង់អស់សន្ដាន ជាអ្នកមានសីលធម៌ ហើយក៏បង្កើតបានទៅជា សភាពអាប់ឱនក្នុងសង្គម រហូតដល់ល្ងង់សម្លាប់ខ្លួន ព្រោះកាមជាដើម.......។ល។

ប្រជាជាតិខ្មែរទាំងឡាយអើយ ព្រះពុទ្ធសាសនា ជាមរតកមហាសាល ដែលដូនតាយើងថែរក្សាទុកមក សម្រាប់ឲ្យយើងគ្រប់គ្នាកសាងសុភមង្គល យើងពុំត្រូវនៅស៊ូទ្រាំហែលក្នុងសមុទ្រលាមកដេកលក់ក្នុងភ្នក់ភ្លើងកាមនោះឡើយ ត្រូវប្រឹងប្រែងរើបម្រះ បញ្ចេញដៃទាំងពីរទទួលយកកំណាប់មហាសាល ដែលព្រះដ៏មានព្រះភាគប្រទានឲ្យ ដោយពេញចិត្តជ្រះថ្លាគ្រប់គ្នាតទៅហោង ។

(នៅមានត)

អក្សរសាស្ត្រជាគោលរបស់ជាតិ ។

ធម្មវិន័យ ជាគោល ជាឫសគល់សាសនា។

សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយក

គណៈធម្មយុត្តិកនិកាយ ឥន្ទញ្ញាណោ (ភ.ទ.)

# អាថិកំបាំង និងអត្ថន័យនៃប្រាសាទបាយ័ន

*រៀបរៀងដោយ* **រស់ ណរុល**

*ថ្មីៗកន្លងទៅនេះ សហស្សវត្សឆ្នាំ២០០០ បានធ្វើសេចក្ដីថ្លែងការណ៍យ៉ាងឱឡារិក ដើម្បីវប្បធម៌សន្តិភាព និងអហិង្សា ហើយកំណត់ជាឆ្នាំអន្តរជាតិ ដើម្បីសន្តិភាពក្នុងដំណើរថ្មីមួយ ។*

*ចំពោះគំនិតរបស់សកលលោកខាងលើនេះ ខ្មែរយើងបានឃើញថា ដូនតាបុព្វបុរសរបស់យើង បានចាប់អារម្មណ៍ខ្ពស់ និងយូរលង់ណាស់មកហើយ ( កន្លងច្រើនសតវត្សរ៍ ) ចំពោះវប្ប-ធម៌សន្តិភាព និងអហិង្សានេះ ដោយលោកបានសាបព្រោះបណ្ដុះបណ្ដាលពាសពេញផ្ទៃប្រទេស : ក្នុងសិល្បៈ ក្នុងរូបចម្លាក់ ក្នុងក្បូរក្បាច់រចនា ក្នុងស្ថាបត្យកម្ម ក្នុងទំនៀមទម្លាប់ ក្នុងប្រពៃណី ក្នុងជំនឿសាសនា ក្នុងអារ្យធម៌ និងវប្បធម៌ទូទៅ មាន : ភាសាពាក្យ របាំ ចម្រៀង តូរ្យតន្ត្រី កាយវិការ សម្រស់ សម្លស្សញញឹម ពិធីការ បុណ្យទាន មនោសញ្ចេតនា អក្សរសាស្ត្រ អក្សរសិល្ប៍ កីឡា ប្រយុទ្ធ សិប្បកម្ម សំណង់ ផ្ទាំងសិលាចារឹក ប្រាង្គប្រាសាទ និងកសិណាច្រើនទៀត ជានិមិត្តរូបនៃវប្បធម៌សន្តិភាព និងអហិង្សានោះ ។*

*ប្រាសាទបាយ័ន : មានទីតាំងស្ថិតនៅចំកណ្ដាល នៃ*

អង្គរធំ កសាងនៅសតវត្សរ៍ទី ៩ ក្នុងបរិវេណប្រវែង ១២ គ.ម ។ ប្រាសាទបាយ័ន មានមុខព្រហ្ម ៤ ស្ថិតនៅលើប្រាង្គថ្មញញឹម ដូចគ្នា បិទភ្នែកជិតពាក់កណ្ដាល ( សមាធិ ) ដូចគ្នា មានចំនួន ៤២ ប្រាង្គ នៅលើប្រាសាទផ្ទៃស្មើ ហើយមាននៅលើក្លោងទ្វារកំពែង និងតាមកំពែង ១២ ប្រាង្គទៀត រួមទាំងអស់មកមានចំនួន ៥៤ប្រាង្គ ។ តាមការស្រាវជ្រាវប្រវត្តិសាស្ត្រ ប្រាសាទបាយ័ន កសាងនៅចុងសតវត្សរ៍ទី ១២ ដោយព្រះបាទជ័យវរ្ម័នទី ៧ ។

ចាប់ពីកំណើត អាណាព្យាបាលបារាំងសែស ក្នុងគ.ស ១៨៦៣ មក ជនជាតិបារាំងជាច្រើនរូប មាននាមល្បីល្បាញ បានចូលមកប្រទេសកម្ពុជា បានរុករកឃើញ និងទស្សនាប្រាសាទទាំងឡាយនៅតំបន់អង្គរ អតីតព្រះរាជធានីខ្មែរ ដែលកប់បាត់ និងការពារដោយធម្មជាតិព្រៃឈើស្រោងនោះ បានចាប់អារម្មណ៍ស្វែងយល់ និងពិចារណារក "សច្ចភាព" នៃប្រាសាទបាយ័ននេះខ្លាំងបំផុត តាមទស្សនៈផ្សេងៗ ដោយបង្ហូរទឹកខ្មៅអស់យ៉ាងច្រើន ។

លុះមកដល់ គ.ស ១៩២៤ លោកហង់រីប៉ាម៉ង់ជេ (Henri Parmentier) បានរកឃើញពន្ធ៌អាថ៌កំបាំង នៃប្រាសាទបាយ័ននេះ ដោយប្រទះឃើញ "រូបពោធិសត្វលោកេស្វរៈ" ។ នៅហោជាងថែវប្រាសាទ ហើយនៅគ.ស ១៩២៥ លោកល្វីហ្វីណូត៍ (Louis Finot) បានសរសេរថា : នៅចំពោះមុខសាក្សី រូបចម្លាក់ដ៏ច្បាស់ក្រឡែតនេះ យើងអាចសន្និដ្ឋានថា ប្រាសាទដើមពុំមែនជាប្រាសាទឧទ្ទិស

ដល់ព្រហ្មញ្ញសាសនាទេ តែជាប្រាសាទពុទ្ធសាសនា ដោយឧទ្ទិស ដល់ព្រះពោធិសត្វ លោកេស្វរៈ ។

សេចក្តីសន្និដ្ឋានខាងលើ របស់លោកហង់រីប៉ាម៉ង់ដេ (Henri Parmentier) និងលោកល្វីហ្វីណូត៍ (Louis Finot) គឺពិតជាត្រឹមត្រូវ ពីព្រោះព្រះបាទជ័យវរ្ម័នទី ៧ នោះ ( ១១៨១-១២១៩ ) ជាពុទ្ធ-សាសនិកសំខាន់មួយរូប តែខាងមហាយាន ( Grand Véhicule ) និងពេលក្រោយមក ព្រះអង្គទ្រង់កាន់សាសនាព្រះពុទ្ធផង និង សាសនាព្រហ្មញ្ញផង "សំយោគសាសនា" ដើម្បីបង្រួបបង្រួមជាតិ ដែលនិយមសាសនាពីរនេះ ក្នុងរជ្ជកាលរបស់ព្រះអង្គ ។

វត្តមានព្រះពុទ្ធសាសនា នៅប្រាសាទបាយ័ន ជាការពិត ប្រាកដណាស់នៅឆ្នាំ១៩៣៣ គេបានរកឃើញព្រះពុទ្ធបដិមាដ៏ធំមួយ ព្រះអង្គ នៅប្រាសាទកណ្តាល (Sanctuaire Central) ហើយព្រះពុទ្ធបដិមាដ៏ធំនោះ ត្រូវបានព្រះបាទមុនីវង្ស ជាព្រះមហាក្សត្រស្តេចយាង ទៅធ្វើពិធីបុណ្យនៅ គ.ស ១៩៣៥ ហើយបានយកមកតម្កល់ នៅ ក្នុងសាលាខាងត្បូងមហាវិថី ដែលភ្ជាប់ព្រះបរមរាជវាំង ទៅទ្វារ ជ័យ ( La porte de la victoire ) ។

ដូចបានជម្រាបខាងដើម អំពីឧត្តមគតិ និងគោលបំណង របស់ដូនតាបុព្វបុរសខ្មែរ គឺអ្វីមួយនោះ លោកផ្សារភ្ជាប់នឹងសន្តិ ភាព និងសេចក្តីស្ងប់ (La paix de l'âme) ជានិច្ច ។ ព្រោះលោក ប្រារព្ធដោយពុទ្ធសុភាសិត "នត្ថិ សន្តិ បរំសុខំ"ប្រែថា គ្មានសេចក្តី

សុខឯណា ក្រៅពីសេចក្ដីស្ងប់ឡើយ បានន័យថា : ជាដំបូងត្រូវមានសេចក្ដីស្ងប់ក្នុងសង្គមមុន ។

ដូច្នេះ ចំពោះមុខព្រហ្ម ៤ ទាំងនៅលើប្រាង្គ ទំហំខុសគ្នានៅលើផ្ទៃកបស្មើ ពុំមានជាន់ទេ ( ថ្នាក់ខុសគ្នាមាន៣ក្រុម )នៅលើប្រាសាទបាយ័ននោះ គឺមានអត្ថន័យដូចតទៅ ៖

-មុខព្រហ្ម ១ ដែលធំជាងគេ ខ្ពស់ជាងគេ កណ្ដាលគេ គឺតំណាងឲ្យព្រហ្មវិហារធម៌ ៤ របស់ព្រះមហាក្សត្រ ចំពោះផ្ទៃខាងក្រោមទាំងមូល មានទាំងប្រជានុរាស្ត្រ សត្វជាតុ សម្បត្តិធម្មជាតិ និយាយរួមព្រះនគរទាំងមូល មានទាំងដែនគោក ដែនទឹក និងដែនអាកាស មាន ៤ ដូចតទៅ :

**១-មេត្តា** គឺការរាប់អានស្មើ មិនរើសមុខ ( ស្រឡាញ់រាជបុត្រស្មើនឹងកូនពលរដ្ឋ ) ។

**២-ករុណា** គឺការអាណិតអាសូរ ជួយសង្គ្រោះផ្ទៃក្រោម ( ទុក្ខប្រជារាស្ត្រ គឺជាទុក្ខរបស់ព្រះរាជា ) ។

**៣-មុទិតា** គឺការសប្បាយរីករាយ ចំពោះទ្រព្យសម្បត្តិរបស់ផ្ទៃក្រោម ដែលបានដោយធម៌ គឺដោយអំពើសុចរិត ។

**៤-ឧបេក្ខា** គឺការតម្កល់ចិត្តកណ្ដាល ចំពោះផ្ទៃក្រោមទូទៅ ដោយប្រាសចាកអគតិទាំង ៤ មាន : មិនលំអៀងដោយស្រឡាញ់ (បក្សពួកនិយម) ដោយលាភ (សម្ភារ:) គឺឆន្ទាគតិ១ មិនលំអៀងដោយស្អប់ ( គំនុំគុំគួន-ព្យាបាទ ) គឺទោសាគតិ១ មិនលំអៀង

ដោយខ្លាច ( សំពាធពីក្រៅ ) គឺ ភយាគតិ១ មិនលំអៀងដោយល្ងង់ខ្លៅ (អវិជ្ជា) គឺ មោហាគតិ ១ ។

ព្រហ្មវិហារធម៌ទាំង៤នេះ សម្រាប់ជាមូលដ្ឋាន ដល់ "ទសពិធរាជធម៌របស់ព្រះមហាក្សត្រ" ហេតុនេះ នៅលើដំបូលព្រះសាទទេវាវិនិច្ឆ័យនៃបរមរាជវាំង មានសាងសង់កំពូលកណ្តាលធំមួយ មានមុខព្រហ្ម ៤ តំណាងឲ្យព្រហ្មវិហារធម៌ របស់ព្រះមហាក្សត្រ ។

-មុខព្រហ្ម ក្រុមទី ២ បន្ទាប់ គឺតំណាងឲ្យព្រហ្មវិហារធម៌ ៤ និង គតិធម៌ ៤ ដូចបានអធិប្បាយខាងលើ ) របស់សេនាធិបតី នាម៉ឺនមន្ត្រី ព្រាហ្មណ៍បុរោហិត អាមាត្យ និងអ្នករាជការ ត្រូវមានចំពោះអ្នកនៅក្រោមឱវាទ ចំពោះប្រជានុរាស្ត្រ ។ ហេតុនេះហើយ ទើបនៅក្នុងសង្គមជាតិ ខ្មែរលើកសេនាបតី នាម៉ឺនមុខមន្ត្រី ឲ្យមានឋានៈខ្ពស់ មានស័ក្តិយស បន្ទាប់ពីស្តេចផែនដី ជា"មនុស្សទេវតា" គឺខ្ពស់ជាងមនុស្ស ចិត្តជាទេវតា ដូចតុលាការ ត្រូវពាក់អាវផាយ (អាវស័ក្តិខ្មែរ) ក្នុងពេលសវនាការជំនុំជម្រះកាត់ក្តីនោះ គឺដោយបុរាណលោកកំណត់ចៅក្រម អយ្យការ "ជាទេវតា" ត្រូវប្រកបដោយធម៌ " ហិរិ ឱត្តប្បៈ " មានន័យថា ហិរិ គឺ ខ្មាសបាប មិនហ៊ានធ្វើអាក្រក់ មិនសមឋានៈខ្លួនជាអ្នកចេះដឹង ។ល។ គឺខ្លាចបាប មិនហ៊ានធ្វើអំពើអាក្រក់ ដោយខ្លាចគេជៀលត្មិះ ខ្លាចធ្លាក់ទៅនរក ប្រេត អសុរកាយ តិរច្ឆាន (អបាយភូមិ ៤) ធម៌នេះហៅថា "ទេវធម៌ " ។ បុរាណលើកឋានៈធុននាម៉ឺនមន្ត្រី គ្មានអ្វីក្រៅពីគុណធម៌

នេះឡើយ ។

-មុខព្រហ្ម : ក្រុមទី ៣ បន្ទាប់មកទៀត គឺតំណាងព្រហ្មវិហារ ៤ និងគតិធម៌ ៤ របស់អ្នកទទួលខុសត្រូវក្នុងសង្គម ដូចជា មាតាបិតា ញាតិការ គ្រូអាចារ្យ គ្រូបាធ្យាយ ថៅកែ នាយកើយ នាយចៅហ្វាយ ។ល។ ត្រូវមានព្រហ្មវិហារធម៌ ៤ និងគតិធម៌ ៤ ខាងលើនេះយ៉ាងខ្ជាប់ខ្ជួន ដោយមាន "សង្គហធម៌" ជាមូលដ្ឋាន ទើបសង្គមមានដំណើរការល្អ ។

-មុខព្រហ្មទី ៤ ចំនួន១២ : នៅលើក្លោងទ្វារកំពែង និង តាមកំពែងព័ទ្ធជុំវិញ កំពែងនៃប្រាសាទ គឺតំណាងព្រហ្មវិហារធម៌ និងគតិធម៌របស់អ្នកយាម អ្នកការពារប្រទេស មានកងទ័ពគ្រប់ ប្រភេទ គឺត្រូវមានធម៌ទាំងពីរនេះជាមូលដ្ឋាន នៃអង្គការវិន័យ របស់ខ្លួន ទើបការបម្រើជាតិមាតុភូមិ ប្រវត្តិសាស្ត្រទៅបានល្អឥតខ្ចោះ ។

ម្យ៉ាងទៀត តាមលក្ខណៈមុខព្រហ្មទាំងអស់ ញញឹមដូចគ្នា ភ្នែក " សមាធិ " ដូចគ្នា នោះមានន័យថា តាំពីស្ដេចចុះមក ត្រូវមានមេត្តាចិត្ត ចំពោះអ្នកតូច អ្នកក្រោមឱវាទ និងត្រូវមាន ករុណាចិត្ត ដោយត្រូវជួយដោះទុក្ខ និងផ្ដល់ប្រយោជន៍ តាមសង្គហធម៌ ៤ មានការធ្វើទានដល់មនុស្សដែលគួរឲ្យ១ ពោលវាចាពីរោះ គួរជាទីស្រឡាញ់១ ធ្វើប្រយោជន៍ដល់អ្នកដទៃ១ ភាពជាអ្នកមិន ប្រកាន់ខ្លួន១ ។ រីឯភ្នែកបិទជិតពាក់កណ្ដាលមើលក្រោម ជា"សមាធិ"

នោះ មានន័យថា គុណធម៌ទាំងឡាយ រមែងតែកើតពី "សមាធិចិត្ត " ( La concentration ) គឺការតម្កល់ចិត្តឲ្យជាប់ ក្នុងគុណធម៌ជាប្រក្រតី ។

ម្យ៉ាងទៀត តាមលក្ខណៈទីតាំងប្រាសាទ នៅចំកណ្ដាលផ្ចិតអង្គរធំ ហើយមានបញ្ចុះព្រះពុទ្ធបដិមា ដ៏ធំមួយអង្គចំកណ្ដាលប្រាសាទ មានន័យថា ព្រះបាទជ័យវរ្ម័នទី ៧ ជាព្រះរាជស្ថាបនិកស្ដេចមានរាជបំណងឲ្យព្រះរាជណាចក្រ គឺចក្រកពអង្គរ ប្រតិបត្តិព្រហ្មវិហារធម៌ឲ្យខ្ពង់ខ្ពស់ ពិសេស " អំណាចកណ្ដាល " ដោយគោរពធម៌ព្រះពុទ្ធជាមូលដ្ឋាន តាមការបញ្ចុះព្រះពុទ្ធបដិមាដ៏ធំមួយអង្គ ចំកណ្ដាលប្រាសាទជានិមិត្តរូប ដូច្នេះការដាក់ពុទ្ធបដិមា១អង្គនោះ ក៏អាចជាប្រផ្នូលមិនល្អ ដល់រាស្ត្រនាប្រទេសជាតិដែរ ។

ម្យ៉ាងទៀត តាមលក្ខណៈឆ្លាក់រូបព្រះពោធិសត្វ លោកេស្វរៈនៅថែវខាងក្នុង ក៏ជានិមិត្តរូបនៃរាជបំណងប្រាថ្នា ឲ្យមហាជនរបស់ខ្មែរគ្រប់ជំនាន់ កាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ហើយប្រតិបត្តិតាមគំរូវីរភាពរបស់ព្រះអង្គ ដែលកំពង់ត្រាច់រង្គត់ ក្នុងវាលវដ្តសង្សារ បំពេញបារមី ៣០ មហាបរិច្ចាគ ៥ ចរិយា ៣ ជាអនេកជាតិសំខាន់ ដើម្បីបានត្រាស់ជាព្រះពុទ្ធមួយអង្គ ដឹកនាំសត្វលោកទៅកាន់ព្រះនិព្វាន ជាឋានផុតទុក្ខ(Au-delà dela misère)។

មួយវិញទៀត យើងក៏សង្កេតឃើញថា នៅសហកាលសម័យ (époque contemporaine) ដែលសកលលោកកំពុងទាល់

ប្រែក ហើយកំពុងពិចារណា( Examen de Conscience )នេះ ប្រាសាទបាយ័នរបស់ព្រះបាទព្រះជ័យវរ្ម័នទី៧ ត្រូវដើរតួសំខាន់បំផុត ក្នុងផ្លូវសន្តិភាព និងអហិង្សា ក្នុងលក្ខណៈ និងក្នុងក្របខ័ណ្ឌនយោបាយ ដូចមានអត្ថន័យខាងក្រោមនេះ ៖

១-ពីព្រោះមេត្តា : មានប្រយោជន៍ "លះបង់ព្យាបាទ" មានការឈ្នានីស ប្រកាន់ពូជសាសន៍ ការឈ្លានពាន ។ល។ ផ្ទុយទៅវិញ មេត្តានាំឲ្យមានការសន្តោសគ្នា ការរាប់អានគ្នា ការយោគយល់គ្នា ការអត់ឱនគ្នា ការស្មោះត្រង់នឹងគ្នា ហើយក៏ជាមូលដ្ឋាននៃសីល ( សុចរិត ) ។

២-ពីព្រោះករុណា : មានប្រយោជន៍ "លះបង់ការបៀតបៀនគ្នា" មានការមិនជ្រៀតជ្រែកផ្ទៃក្នុងរបស់អ្នកដទៃ របស់ប្រទេសដទៃ មិនបំផ្លាញអ្នកដទៃ ។ល។ ផ្ទុយទៅវិញ ត្រូវធ្វើជំនួយឥតចំណង (Aide Inconditionnelle) ជាសង្គហធម៌ពិតៗ ។

ពុទ្ធសុភាសិត : ការមិនបៀតបៀនគ្នា ជាកម្លាំង១ ។ ចេញពីបញ្ហានេះ ក៏មានការចរចាគ្នា ការផ្សះផ្សាគ្នា ដែលជាតិនីមួយៗ និងពិភពលោក កំពុងនិយមយ៉ាងពេញបន្ទុក ។ តែលទ្ធផលល្អ អាស្រ័យពីមេត្តាចិត្ត ករុណាចិត្ត ស្តែងចេញពីការស្មោះត្រង់ពិតៗ ។

៣-ពីព្រោះមុទិតា : មានប្រយោជន៍"លះបង់សេចក្តីអផ្សុក" គឺការមិនត្រេកអរ ការមិនធុញទ្រាន់ ការមិនពេញចិត្ត ឈានទៅរក

ការប្រណែនជាដើម ។ មុទិតា បណ្ដុះ និងជំរុញស្មារតី សហ-ប្រតិបត្តិការ ដើម្បីបម្រើ និងបំពេញផលប្រយោជន៍ ឲ្យគ្នាទៅវិញទៅមក( គ្មានទោស ) ។

៤-ពីព្រោះ ឧបេក្ខា : មានប្រយោជន៍ "លះបង់តម្រេក" គឺ ភគ: មិនឲ្យអារម្មណ៍មិនល្អ កើតតាមទ្វារទាំង ៦ គាបសង្កត់បានមាន រូប សំឡេង ក្លិន រស ផស្សៈ ចិត្ត ។ ក្នុងវិស័យនយោបាយ ឧបេក្ខា បណ្ដុះស្មារតីយុត្តិធម៌ និងអព្យាក្រិត្យមិនចូលបក្សពួករួមជម្លោះអន្តរជាតិ តែក៏មិនសង្ងំស្ងៀមដែរ( Non égoïste ) មានអត្ថិភាពប្រទេសមិនចូលបក្សសម្ព័ន្ធ ជាកស្តុតាងស្រាប់ ដែលដើរតួសំខាន់បំផុត ក្នុងការលុបបំបាត់សព្វាវុធ និងបង្កើតសន្តិភាព ( Le désarmement et la Coexistence pacifique ) ដើម្បីសន្តិភាពសង្គម និងសាកល ។

មួយវិញទៀត រហូតមកដល់សព្វថ្ងៃនេះ ប្រាសាទបាយ័ន មានអត្ថន័យប្រវត្តិសាស្ត្រ និងសាកលយ៉ាងពេញបន្ទុក ដោយការរៀបចំខាងក្រោយនេះ ៖

១-ពីព្រោះ លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ ត្រូវមាននាទីជាប្រាង្គកណ្ដាល មានមុខព្រហ្មបួនធំជាងគេ ខ្ពស់ជាងគេ ក្នុងកម្ពស់ថ្នាក់ទីមួយ ។

២-ពីព្រោះ មហាអំណាចទាំងប្រាំ និងគណៈកម្មាធិការសន្តិ-សុខ អ.ស.ប ត្រូវមាននាទីជាប្រាង្គបន្ទាប់ ក្នុងកម្ពស់ថ្នាក់ទីពីរ ។

៣-ពីព្រោះអង្គការនានា និងបណ្ដាប្រទេសទាំងឡាយ ជាសមាជិក អ.ស.ប ត្រូវមាននាទីជាប្រាង្គបន្ទាប់ទៀត ក្នុងកម្ពស់ថ្នាក់ទីបី ។

៤-ពីព្រោះអ្នកយាមកាម កងទ័ពជាសេនាធិការ អ.ស.ប ក្នុងពេលបំពេញបេសកកម្មអន្តរជាតិ ត្រូវមាននាទីជាប្រាង្គ នៅលើក្លោងទ្វារ និងនៅតាមបរិវេណកំពែងប្រាសាទ ។

ឈរលើលទ្ធផល នៃការសិក្សាស្រាវជ្រាវខាងលើនេះ សឲ្យឃើញថា ប្រាសាទបាយ័នរបស់ខ្មែរយើង មានតម្លៃជាតិ និងសាកល ហើយអាចផ្ដល់វប្បធម៌សន្តិភាព និងអហិង្សាបរិបូរណ៍ ។

តាមគំរូស្ថាបត្យកម្មប្រាសាទបាយ័ន របស់ព្រះបាទជ័យវរ្ម័នទី៧ នោះបុព្វបុរសខ្មែរយើងបានបញ្ចូល "ព្រហ្មមុខ ៤" ជានិមិត្ត-រូប នៃព្រហ្មវិហារធម៌ ៤ ក្នុងជំនឿប្រពៃណីជាតិ តរៀងរហូតមកដល់សព្វថ្ងៃនេះ ។

-យើងសង្កេតឃើញព្រហ្មមុខ ៤ សាងសង់នៅលើកំពូលចេតិយ ដែលបញ្ចុះធាតុបុព្វបុរស មានមាតាបិតា គ្រូបាធ្យាយជាដើម ជានិមិត្តរូប នៃព្រហ្មវិហារធម៌របស់បុព្វការី ។ បុព្វការីជននោះក្នុងកាលលោកនៅមានជីវិត បម្រើសង្គមក្រុមគ្រួសារ និងមាតុភូមិ ហើយក៏ជាមេរៀនដ៏ល្អឲ្យកូនចៅ សិស្សគណជំនាន់ក្រោយឲ្យយល់ និងដើរតាមគំរូវីរភាពទាំងឡាយនោះ ។

-យើងសង្កេតឃើញព្រហ្មមុខ ៤ធំមួយ សាងសង់នៅលើចំកណ្ដាលព្រះវិហារ ឬអាភម ជានិមិត្តរូបនៃព្រហ្មវិហារធម៌ ៤

របស់ព្រះពុទ្ធសាសនា ដែលព្រះសង្ឃ និងពុទ្ធបរិស័ទ ត្រូវប្រតិបត្តិ និងពុទ្ធនិគមន៍ ។ល។

-យើងសង្កេតឃើញ ពេលថ្មីៗនេះ មានរៀបចំពិធីបុណ្យសហស្សវត្សឆ្នាំ ២០០០ នៅក្នុងបរិវេណអង្គរវត្ត យ៉ាងគគ្រឹកគគ្រេង មានអន្តរជាតិចូលរួម ទាំងសម្តែងសិល្បៈផង ។ ក្នុងពេលនោះ មានចែកប័ណ្ណ និងបិទផ្សាយបដាវប្បធម៌សន្តិភាព វប្បធម៌អហិង្សា និងប្រកាសបង្កសន្តិភាព សម្រាប់ពិភពលោកយើងផង ។

ការពិត ព្រហ្មវិហារធម៌ ៤ នេះ អាចជាមូលដ្ឋានសំខាន់ សម្រាប់ស្ថាបនាសន្តិភាពក្នុងលោកនេះ ដូចមានកំពូលព្រហ្មមុខ ៤ ចំនួនសរុប ៥៤ប្រាង្គ ជានិមិត្តរូបស្រោប សម្រាប់ជាមេរៀនឲ្យមហាក្សត្រ អាមាត្យ មន្ត្រី សេនាបតី កងទ័ព មេបាក្នុងសង្គមជាតិ យល់អំពីករណីយកិច្ច និងកាតព្វកិច្ចរបស់ព្រះអង្គ របស់ខ្លួន ចំពោះជនក្រោមឱវាទ ។ ក្នុងសង្គមមានព្រហ្មវិហារធម៌៤ជាចន្ទល់ នោះនឹងបានសុខសន្តិភាព និងសេចក្តីចម្រើនលើគ្រប់វិស័យ ពុំអាក់ខានឡើយ ។

ឯកសារពិគ្រោះ ៖

-សៀវភៅ ព្រះបាទជ័យវរ្ម័ន ទី ៧ ដោយមីសែលត្រាណេ "សង្គមខ្មែរ ក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី ៧ ឆ្នាំ ២០០៣ ។

-សៀវភៅ"ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ" ដោយ ហ្សក សឺដេស " Pour Comprendre Angkor " ។

# ប្រវត្តិបារាយណ៍អណ្តែត ( តចប់ )

រៀបរៀងដោយ លោក ចិន តាក់
អតីតមន្ត្រីមន្ទីរធម្មការខេត្តព្រៃវែង

ហេតុនេះហើយ បានជាចាស់ៗពីសម័យមុន និងសម័យនេះខ្លះៗ គេនៅប្រកាន់ខ្ជាប់តៗគ្នាមក ដោយជំនឿរបស់គេ គេពុំហ៊ានទៅប៉ះពាល់ ឬកាប់ឆ្ការព្រៃឈើ ជីក គាស់កកាយដី ឬវត្ថុអ្វីៗនៅទីទួលនោះ ធ្វើឲ្យខូចបរិដ្ឋានឡើយ ដោយគេនៅមានជំនឿថា " ខ្លាចអ្នកតាអស់លោកកាច់ " ។

តាមប្រសាសន៍លោកតា យី យុន អាយុ ៧៨ ឆ្នាំ គាត់នៅព្រៃវែងនេះ តាំងពីឆ្នាំ ១៩២៧ ( សព្វថ្ងៃគាត់ជាអាចារ្យវត្តសាំងសាមី ) ជាអ្នកស្រុកនៅទីនេះ ( ជំនាន់ឪពុក និងជីតាគាត់ ) កាលណាមានវេលក្នុងគ្រួសារ ដូចជាការកូនចៅ ឬបុណ្យទាន មានបុណ្យខ្មោចជាដើម គេអាចទៅខ្ចីបាន ឆ្នាំង និងឧបករណ៍ផ្សេងៗទៀតពីទួលអស់លោកទាំងនោះ យកមកប្រើប្រាស់បានតាមបំណងកាលណាចប់វេលពិធីហើយ ត្រូវយកទៅសងឲ្យគ្រប់ចំនួនវិញ ប៉ុន្តែក្រោយៗមកទៀត មានអ្នកលេងសុីផឹកខ្លះ ចេះតែគៃបន្លំបំបាត់ក៏ខ្ចីលែងបានរហូតទល់សព្វថ្ងៃ ។

ម្យ៉ាងទៀត គាត់មានប្រសាសន៍ថា ទីកន្លែងនេះមានប្រាក់

ទូកង អំពីមាស អំពីប្រាក់សុទ្ធទៀតផង ។

តាមតំណាលតៗគ្នាមកថា មានត្រកូលអ្នកស្អកស្អម្នាក់នៅខេត្តព្រៃវែង ( សូមមិនបញ្ចេញឈ្មោះ ព្រោះមិនប្រាកដ ) បានថែវទូកនៅពេលយប់ ( ទៅនេសាទត្រី ) បានជួបនឹងទូកអ្នកអុំមួយក្រុមទៀត ក្រុមនោះឯងបានស្រែកហៅទូកអ្នកនេសាទថា សុំឲ្យជួយផង ព្រោះប្រវាទូកខ្ញុំបាក់ហើយ ថែវទៅមុខមិនរួចទេ ផ្ទះខ្ញុំនៅឆ្ងាយណាស់ ឯអ្នកឯងផ្ទះនៅជិតនេះទេ សុំប្រើប្រវាបាក់នេះ ខ្ញុំសុំដូរប្រវាអ្នក ។ ត្រកូលអ្នកស្អកស្អម្នោះ មានចិត្តអាណិត ក៏ព្រមដូរយកប្រវានោះទៅ ហើយចេះតែសង្ស័យថា ប្រវានេះម្ដេចក៏ធ្ងន់ត្រដុកម៉្លេះ ប្រហែលជាថែវទូកមិនកើតហើយ បានជាដូរ តែដោយពេលយប់មើលមិនឃើញ លុះត្រឡប់មកផ្ទះវិញ យកចង្កៀងមកបំភ្លឺមើល ឃើញពណ៌ក្រហមប្លែក ទើបដឹងថា ប្រវានោះពិតជាមាសសុទ្ធ ហើយត្រេកអរជាអនេក ហើយសន្មតថា ទូកនោះឯងពិតជាទូកអស់លោកស័ក្តិសិទ្ធិបារាយណ៍អណ្ដែត អ្នកស្អកស្អម្នោះបានរៀបចំធ្វើតង្វាយបូជា ភ្លេងពិណពាទ្យ ជ្រូកខ្វៃ ។ល។ ក៏ក្លាយទៅជាអ្នកជួរជោរមែនទែន តកូន តចៅ ចៅទួត ចៅលួត ចៅលាទល់សព្វថ្ងៃ ត្រកូលនោះក៏នៅមានជំនឿជាប់តៗគ្នាមក ។ តែដល់ថ្ងៃ ខែ ឆ្នាំ គេត្រូវតែធ្វើបុណ្យសែនព្រេនថ្វាយ មិនដែលខកខានទេ ។

ន័យមួយទៀត គាត់មានប្រសាសន៍ថា ពីជំនាន់យូរហើយប្រហែលជាជាង ១០០ ឆ្នាំប៉ុណ្ណោះ ទីទួលនេះនៅពេលរាត្រី មាន

ភ្លើងភ្លឺចិញ្ចាច គេអាចមើលឃើញពីស្រុកភូមិជិតៗនោះ តែក្រោយៗមកទៀត គេឃើញមានភ្លើងតែថ្ងៃសីល គឺថ្ងៃពេញបូណ៌មីនិងខែដាច់ប៉ុណ្ណោះ ។ តែឥឡូវនេះ គ្មានឃើញភ្លើងនោះទៀតទេ ។

គាត់មានប្រសាសន៍ទៀតថា គាត់ធំដឹងក្តីនៅព្រៃវែងនេះតាំងពីឆ្នាំ ១៩២៧ មក គាត់ធ្លាប់ទៅមកទួលនេះ ញឹកញាប់ដែរ ឃើញវិហារចាស់នោះ និងដើមឈើធំៗ (ឈើទាល) តាំងពីគាត់នៅក្មេង ក៏ឃើញធំៗស្រាប់ដែរ ក្បែរវិហារចាស់នោះ មានខ្ទមតូចមួយទៀតតម្កល់ដុំថ្មពីរបីដុំ និងឃើញថ្មលិង្គព្រះឥសូរ និងយោនីព្រះនាងឧមាភគវតីដែរ គាត់សន្និដ្ឋានថា ដើមឈើធំៗ និងវិហារចាស់ បែបជាខ្ទមអ្នកតា និងព្រះពុទ្ធបដិមាមួយព្រះអង្គផង មានតាំងពីយូរមកហើយ ប្រហែលជាង ១០០ ឆ្នាំ ។

គាត់បានតំណាលថា មានព្រះភិក្ខុសង្ឃព្រះពុទ្ធសាសនាជាច្រើនអង្គបន្តបន្ទាប់ ទៅធ្វើធុតង្គរុក្ខមូលនៅទីនោះដែរ តែនៅមិនបាន ដោយពួកអមនុស្ស (ពួកអទិស្សមានកាយ) បេះតែមកបៀតបៀនពេក ។

តាមប្រសាសន៍ ឯកឧត្តមអភិបាលខេត្ត តូច សាក់ (ចូលនិវត្តន៍) ថា កាលគាត់នៅធ្វើអភិបាលខេត្ត ពីឆ្នាំ ១៩៩០ គាត់បានឲ្យសាងព្រះវិហារតូចមួយនៅទីនោះ ។ ពួកជាងជីកដីបុកគ្រឹះប្រទះដុំថ្មបុរាណ គឺលិង្គព្រះឥសូរ និងយោនីព្រះនាងឧមាភគវតី គាត់បានឃើញទីងក្អែកផ្ទាល់ និងឲ្យសមត្ថកិច្ចយកទៅរក្សាទុក ។

បើតាមថ្មបុរាណ ( លិង្គព្រះឥសូរ និងយោនីព្រះនាងឧមាភគវតី ) នោះសន្មតថា ទីនេះមានតាំងពីសតវត្សទី ៩ ព្រោះសម័យនោះ ប្រជាជនកាន់ព្រហ្មញ្ញសាសនា ហើយដុំថ្មនោះ ក៏គ្មាននៅទីនេះដែរ ពិតជាយកពីកន្លែងផ្សេងទៀត មកតម្កល់ទុកនៅទីនេះ ដើម្បីគោរពបូជារបស់អ្នកស្រុកនៅទីនោះ ។ គឺក្រោយសម័យនគរភ្នំ ដែលចិនហៅថា " ហ្វូណន " មានរាជធានីឈ្មោះថា វ្យាធបុរៈ ឬ ទ មូ ជាទីក្រុងដែលតាំងនៅតំបន់បាភ្នំ គឺភ្នំខ្សាច់សឈើកាច់នេះឯង តាំងពី ព.ស ៣០០ មុនគ្រិស្តសករាជ ។

រឿងព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា មានមកជាយូរហើយ គឺមុនគ្រិស្តសករាជទៅទៀត អ្នកស្រុក និងព្រះរាជានាសម័យនោះ ជួនពេលខ្លះកាន់ព្រះពុទ្ធសាសនា ជួនពេលខ្លះកាន់ព្រហ្មញ្ញសាសនា ។

" សូមអានសៀវភៅព្រះពុទ្ធសាសនា ២៥០០ ត្រង់ប្រវត្តិព្រះពុទ្ធសាសនាផ្សាយមកស្រុកខ្មែរ របស់ព្រះមហា ប៉ាង ខាត់ ត្រង់វគ្គទី ២ មានតម្កល់នៅពុទ្ធសាសនបណ្ឌិត្យ " ។

ដំណើររឿងដ៏ទូលអស់លោក បាភយណ៍អណ្តែតនេះ មានជាប់ពាក់ព័ន្ធ នឹងបុរាណដ្ឋានជាច្រើនក្នុងខេត្តព្រៃវែង ដូចជាប្រាសាទព្រះមន្ទីរព្រះធាតុព្រៃដើមស្រុក ភូមិបឹងជ័រ ស្រុកស៊ីធរកណ្តាល រចនាបថ បែបកំពង់ព្រះ សតវត្សទី ៧ និងបុរាណដ្ឋានឯទៀតៗ ដូចជានៅបាភ្នំ នៅវត្តព្រៃវៀរ វត្តប្រាសាទ ស្រុក

កំពង់ត្របែក និងទៅបន្ទាយចក្រី ព្រះអង្គពាន់ ស្រុកព្រះស្តេចជាដើម ។ ( ឯកសារមន្ទីរវប្បធម៌ខេត្តព្រៃវែង ) ។ ចប់ ។

ស្ថាបត្យកម្មបុរាណទាំងអស់មុនឆ្នាំ ១៩៧៩ ត្រូវបានបែកខ្ទេចខ្ទាំអស់ហើយ នៅសល់តែសំណល់ដើមប៉ុណ្ណោះ ។

តែក្រោយមកសម័យ ១៩៧៩ ដល់ឆ្នាំ ១៩៨១ ឯ.ឧ ដោក សាម៉ុល អភិបាលខេត្តព្រៃវែង ពុំទាន់បានគិតគូរទឹកន្លែងនេះទេ ព្រោះនៅពេលនោះ ប្រជាជននៅកំពុងខ្វះខាត និងអត់ឃ្លានខ្លាំងណាស់ ហើយសន្តិសុខពុំទាន់ស្ងប់ផង ។ ទើបតែពេលដែល ឯ.ឧ ជាម យៀប ឡើងជាអភិបាលខេត្តព្រៃវែង នាឆ្នាំ១៩៨១ ដល់ឆ្នាំ ១៩៨៩ គាត់មានគំនិតផ្តួចផ្តើម រៀបចំទីកន្លែងនេះឡើងវិញ ដោយឲ្យឈូសឆាយផ្លូវបោសសំអាតទីកន្លែង ធ្វើពិធីបុណ្យយ៉ាងគគ្រឹកគគ្រេង ឲ្យទៅជាកន្លែងរមណីយដ្ឋាន គួរគោរពបូជារបស់ពុទ្ធបរិស័ទតទៅ ។

# អំពីស្ថាបត្យកម្មដី

ដោយជំនឿទៅលើវត្ថុស័ក្តិសិទ្ធិ និងពុទ្ធសាសនា មានសប្បុរសជនជាច្រើននាក់ ដែលមានសទ្ធាជ្រះថ្លារួមដៃគ្នា បានសាងសង់ និងជួសជុលឡើងវិញ ទៅតាមបំណងប្រាថ្នារបស់គេរៀងៗខ្លួន ដើម្បីទុកជាកំណប់បុណ្យព្រេងរបស់គេ ក្នុងពេលអនាគត ជាពិសេស ដោយមានការផ្តួចផ្តើមគំនិត និងការជួយឧបត្ថម្ភពីសម្នាក់

អស់លោកជាអភិបាលខេត្ត អភិបាលខេត្តរង ជាបន្តបន្ទាប់ គឺចាប់តាំងពីឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៩៨ ។

## ឯកឧត្តមអភិបាលខេត្ត អភិបាលខេត្តរង ទាំងអស់នោះគឺ

១- ឯ.ឧ ជាម យៀប
២- ឯ.ឧ តូច សាក់
៣- ឯ.ឧ ស្បោង សាភត់
៤- ឯ.ឧ យុទ្ធ កូចង
៥- ឯ.ឧ ប៊ិន ឈិន
៦- ឯ.ឧ ម៉ម ហេង
៧- ឯ.ឧ មិន សាន
៨- ឯ.ឧ តូច ឈាង
៩- ឯ.ឧ ឯម អុន

ឈ្មោះសប្បុរសជន ដែលបានកសាង និងជួសជុលឡើងវិញ មានដូចតទៅនេះ ៖

១- ព្រះវិហារចាស់ដែលមានមកពីមុនទ្រុឌទ្រោម ត្រូវបានជួសជុល និងកសាងឡើងវិញ ដោយលោក ម៉ៅ សុង ប្រធានកាកបាទក្រហមខេត្ត គឺបានក្រាលឥដ្ឋព័ណ៌ បូកស៊ីម៉ងត៍លាបកំបោរជួសជុលជំបូល ធ្វើយឿន ខាត់ដោយថ្មដុស ក្នុងឆ្នាំ ១៩៨៩ ។ សព្វថ្ងៃក្នុងព្រះវិហារនេះ មានព្រះពុទ្ធបដិមាតូច-ធំ បុរាណ និងសម័យ

ថ្មីចំនួន ១២ ព្រះអង្គ រួមជាមួយព្រះអង្គធំលើបល្ល័ង្ក ខ្ពស់ផង ។

២- ស្ពានចាស់ដែលបាក់បែក កសាងជាថ្មីឡើងវិញដោយមានបង្កាន់ដៃផង កសាងឡើងដោយលោក ជា សារេត ប្រធានក្រុមហ៊ុនសំណង់នៅភ្នំពេញ តំណាលគ្នានឹងមន្ទីរសាលាខេត្តព្រៃវែង ក្នុងឆ្នាំ ១៩៩១ ។

៣- សាលាបុណ្យមួយធំ ខាងត្បូងវិហារចាស់ កសាងដោយ ឯ.ឧ យុទ្ធ ភូថង តូច សាក់ ស្បោង សាភត់ រួមជាមួយមន្ត្រីរាជការ ពុទ្ធបរិស័ទនៅឆ្នាំ ១៩៩២ ។

៤- ព្រះវិហារមួយតូចមានទីលានទៅខាងមុខ ខាងត្បូងសាលាបុណ្យ កសាងឡើងដោយ ឯ.ឧ តូច សាក់ យុទ្ធ ភូថង ជាម យៀប មានតម្កល់ព្រះពុទ្ធរូបមួយព្រះអង្គ កសាងនៅឆ្នាំ ១៩៩២ ។

៥- ព្រះវិហារស្តូបមួយទៀត ស្ថិតនៅខាងត្បូងព្រះវិហារខាងលើ កសាងផ្តួចផ្តើមឡើងដោយស្នាព្រះហស្តសម្តេច ទេព វង្ស ព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជគណៈមហានិកាយ នៃកម្ពុជា ព្រះអង្គទ្រង់ផ្តល់ជាថវិកាទាំងអស់ស្មើនឹង ៥០០០ ដុល្លារអាមេរិក ព្រមទាំងថវិកាពុទ្ធបរិស័ទនៅខេត្តព្រៃវែង ចំនួនមួយលានរៀលផង ។ តម្កល់ព្រះពុទ្ធរូបភព្រះហស្តពីរព្រះអង្គ ព្រះកម្ចាយមួយមួយព្រះអង្គដឹកយកមកពីភ្នំពេញ ។ អ្នកកសាងផ្ទាល់មន្ទីរធម្មការខេត្តព្រៃវែង កាលនោះមានលោក ចិន តាក់ ជាប្រធាន លោក

ស សែត លោក តុប ហៀន ជាអនុប្រធាន លោក មុំ ចន្ទតារា ប្រធានការិយាល័យរដ្ឋបាល ផ្នែកជាង លោក នុត អ៊ា ក្នុងឆ្នាំ ១៩៩៧ ។

៦- សាលាថ្មីមួយជាប់នៅខាងជើងព្រះវិហារចាស់ ធ្វើអំពីស៊ីម៉ងត៍ ក្រាលឥដ្ឋព័ណ៌ កសាងដោយលោក យ៉ឹម សំណាង និងអ្នកស្រី យ៉ឹម សារី នៅឆ្នាំ ១៩៩៦ ។

៧- តូបតូចៗពីរ និងសាលាឆទានតូចមួយធ្វើអំពីឈើ សម្រាប់អ្នកយាមទួលអស់លោក ថែទាំបោសសំអាត កសាងឡើងដោយ លោក វង្ស ពិសេន មេបញ្ជាការកងទ័ពខេត្ត និងលោក ពេជ ជីវន ស្នងការនគរបាលខេត្ត កសាងក្នុងឆ្នាំ ១៩៩២ ។

៨- រោងទូកងមួយ និងទូកងមួយ ឈ្មោះព្រួញមុនីឋិតនៅខាងជើង និងខាងកើតព្រះវិហារចាស់ កសាងដោយលោក វង្ស ពិសេន មេបញ្ជាការកងទ័ពខេត្ត ក្នុងឆ្នាំ ១៩៩៥ ។

៩- អណ្តូងស្នប់ពីរ កសាងដោយឧបាសិកា ឌី ប៉ុក មាតាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី កសាងឆ្នាំ ១៩៩៨ និង លោក យុទ្ធ ភូថង កសាងក្នុងឆ្នាំ ១៩៩៨ ដែរ ។

១០- កូនសាលាតូចធ្វើអំពីថ្ម និងឈើប្រក់ក្បឿង ជាប់ខាងត្បូងជាប់វិហារចាស់ មានតម្កល់ដុំថ្មពីរបីដុំ លិង្គព្រះឥសូរ យោនីព្រះនាង ឧមា ( យោនីក្លាយទៅជាកន្ធែងអុជធូប ) ជាកូនសាលាមានមកពីបុរាណ គ្មានអ្នកជួសជុល ។

១១- ខុមយាយ ទែត យាយ ម៉ៅ នៅទួលខាងជើងមានពីបុរាណ ។

១២- មានតូប ឬខ្ទមតូចៗ ជាច្រើនទៀតធ្វើអំពីឈើខ្លះ អំពីស៊ីម៉ងត៍ខ្លះ ពាសពេញនៅលើទួល សុទ្ធតែកើតឡើងដោយសប្បុរសជនជាច្រើនទៀត ដែលមិនបានរៀបរាប់ឈ្មោះឲ្យអស់ កើតក្រោយឆ្នាំ ១៩៩៨ ។

# ប្រយ័ត្ន ៤

១- ហោរា ប្រយ័ត្នមាត់អើល

២- ជាងទងកាន់សីល ប្រយ័ត្នទៀន

៣- ចៅក្រម ប្រយ័ត្នការលំអៀង

៤- អ្នកជៀង ប្រយ័ត្នបាត់អក្ខរា ។

សុត្តន្តប្រីជា ឥន្ទ

# អំពីការទាក់លលក[១]

ដោយ **មៀច ប៉ុណ្ណ**

នៅជនបទ ស្រុកស្រែចម្ការ ពិសេសនៅតំបន់ក្បែរព្រៃភ្នំ កសិករខ្មែរមួយចំនួន ចូលចិត្តទាក់លលក ទុកជាការកែកម្សាន្ត នៅពេលទំនេរល្ហែពីការងារ ។ គេច្រើនទាក់លលក នៅរដូវដើមឆ្នាំ និងក្រោយរដូវចម្រូត ។ ព្រោះម្យ៉ាងរដូវដើមឆ្នាំ សម្បូរដោយចំណី មានសត្វល្អិត ដង្កូវ កណ្ដូប និងផ្កាស្មៅផ្សេងៗផង ។ ហើយម្យ៉ាងទៀត ក្រោយរដូវប្រមូលកាត់ គ្រាប់ស្រូវទុំបានជ្រុះរុះរោយពាសពេញវាលស្រែ ធ្វើឲ្យសត្វលលកស៊ីឆ្អែតឆ្អល់ធាត់ធំផង និងសប្បាយរីករាយក្នុងការបន្តពូជផង ។ រដូវទាក់លលកមកដល់ កសិករដែលមានចំណង់ចំណូលចិត្តក្នុងរបរនេះ បានត្រៀមលលកធ្លាក់ ក៏ដូចជាឧបករណ៍ចាំបាច់ដទៃទៀត មានលុប ដងសាវជាដើម ។

## I- អំពីលលកធ្លាក់[២]

ការទាក់លលក ដែលទទួលបានលទ្ធផលល្អ មិនមែនដោយសារការស្ទាត់ជំនាញ របស់អ្នកទាក់(ធ្លាក់) តែប៉ុណ្ណោះឡើយ។ ប៉ុន្តែ សំខាន់បំផុត វាអាស្រ័យដោយមានជំនួយដ៏មានប្រសិទ្ធភាព

---

១-ក្រុមស្រាវជ្រាវ នៃពុទ្ធសាសនបណ្ឌិត្យ បានទៅជួបសម្ភាសន៍ ជាមួយកសិករឈ្មោះ នាង រឹម អាយុ ៤៨ នៅភូមិព្រៃលៀប ឃុំព្រៃអំពកស្រុកគិរីវង់ ដែលធ្លាប់មានជំនាញក្នុងការទាក់លលក តាំងពីយូរមកហើយ

២- លលកធ្លាក់គឺជាលលកឈ្នោល

ពីឆ្នាក់ផងដែរ ។ មុនក្លាយទៅជាឆ្នាក់នោះ ដំបូងលលកព្រៃ ត្រូវបានចិញ្ចឹមបំប៉ន ផ្សាំង បង្ហាត់តាមរបៀបរបបត្រឹមត្រូវ ក្នុងរយៈពេលពី ៦ ខែ ទៅ១ ឆ្នាំ។ លលកឆ្នាក់ដែលល្អ ត្រូវមានលក្ខណៈពីរយ៉ាងជាចាំបាច់ ។

១- *ពូកែរងាវ* ឧស្សាហ៍បរ-បូល ដើម្បីទាក់ទាញ ដៃគូលលកព្រៃ

២- *ត្រូវក្លាហាន* មិនតក់ស្លុត មិនខ្លាចញញើតលលកព្រៃ ។

ជាជំហានដំបូង កសិករជាឆ្នាក់លលក បានបង្ហាត់ឆ្នាក់ខនឲ្យចេញមករងាវ នៅទីជិតៗផ្ទះ ផ្សាំងផ្សាំវាបន្តិចម្តងៗ ឲ្យវាមានទម្លាប់មកចូលប្រឡូកជាមួយលលកព្រៃ ក្នុងការរងាវតគ្នា ឬបរ-បូលហៅគ្នា។ ការទាក់នៅលើកដំបូងៗ ជុំវិញបរិវេណភូមិនេះ មិនទាន់ទទួលបានលទ្ធផលជាទីគាប់ចិត្តនៅឡើយទេ ព្រោះលលកព្រៃភាគច្រើន មិនសូវហ៊ានមករកស៊ី នៅតំបន់នេះឡើយ ។ ដូច្នេះ គេអាចទាក់បានក្នុងមួយថ្ងៃ តែមួយឬពីរក្បាលប៉ុណ្ណោះ ។ ប៉ុន្តែដរាបណាលលកឆ្នាក់កាន់តែមានទម្លាប់ នឹងចេញមករងាវឆ្លងឆ្លើយ ជាមួយលលកព្រៃនោះ ឆ្នាក់រំកិលវាតទីកាន់តែឆ្ងាយឡើងៗ រហូតដល់ចម្ងាយ ២ ឬ ៣ គីឡូម៉ែត្រពីភូមិឋាន ។ នៅដំណាក់កាលនេះ លលកឆ្នាក់ក្លាយជាម្ចាស់លើទីវាលស្រែចម្ការហើយ ។ វាចាត់ទុកទឹកដីតំបន់នេះថា ជាអាណាចក្ររបស់វា ហើយលែងខ្លាចញញើតអ្វីទាំងអស់ ។ គ្រាន់តែចេញផុតពីរបងផ្ទះ មកដល់ទីវាលក្លាម វារងាវយ៉ាងក្លាហាននៅក្នុងទ្រុងលុប ដែលម្ចាស់ពុននៅចុងដងសាវម្ខាង ។

## II ឧបករណ៍សម្រាប់ទាក់លលក

*១- អំពីលុប:*

*ក្នុងការទាក់លលក ដោយប្រើផ្អាក់ កសិករមានទម្លាប់ប្រើឧបករណ៍ពិសេសម្យ៉ាងហៅថា លុប ដែលមានរាងប្រឡេពីប៉ែតបណ្តោយប្រវែងប្រមាណ ៣ តិកកន្លះ ទទឹង ២ តិកកន្លះ កម្ពស់ ២តិក ហ៊ុំព័ទ្ធជុំវិញ ដោយលួសសំណាញ់ ទុកតែប្រកទ្វារមានសន្ទះសម្រាប់បញ្ចេញ ឬបញ្ចូលលលកផ្អាក់ ។ នៅពីខាងមុខទ្រុងលុបមានបន្ទះលួសសំណាញ់ទំហំទទឹង ១ តិក ៨ ហ៊ុន បណ្តោយ ២ តិកកន្លះ ភ្ជាប់ដោយសំណាញ់នីឡុងឬអំបោះ ដែលមានគន្លឹះខ្ទាស់សម្រាប់វាយខ្ទប់ពីលើមកផ្អោប និងបន្ទះលួសសំណាញ់ រឹបក្តោបលលកព្រៃ ដែលមករងាវ-បរ តគ្នានឹងផ្អាក់ ហើយមកជាន់គន្លឹះដាក់នៅត្រង់ក្របបន្ទះលួសសំណាញ់ ។ នៅជុំវិញលុបគេកាច់មែកឈើណា ដែលស្លឹកវារក្សាភាពបៃតងនៅស្រស់បានយូរ ដោតយ៉ាងញឹក បិទបាំងមិនឲ្យលលកព្រៃមើលឃើញលលកផ្អាក់ផង និងបន្លំធ្វើជាស្លឹកឈើ ឲ្យដូចទៅនឹងធម្មជាតិ ពិតៗផង ។*

*២-អំពីដងសារ:* ដងសារមានពីរ ប្រវែងពី ៣ ម៉ែត្រទៅ ៣ ម៉ែត្រកន្លះ ។ ដងសារទីមួយ មានពន្លួញសំប៉ែតនៅខាងចុងសម្រាប់ស៊កទៅក្នុងប្រហោងលុប ទ្រោលឡើងទៅដាក់នៅប្រគាបមែកឈើ ។ ដងសារទីពីរមានចងផ្លែកណ្តៀវមួយខ្វៃនៅខាងចុងសម្រាប់ជួយទប់ទ្រលុបអបជាមួយដងសារទីមួយ ឲ្យមានលំនឹង

ក្នុងការដាក់លុបឬដកលុបចេញពីប្រគាបមែកឈើ ។

*៣-អំពីទ្រុង:* អ្នកទាក់លលក តែងតែមានទ្រុងពិសេសមួយសម្រាប់ដាក់លលកព្រៃ នៅពេលទាក់វាបានមក ។ ទ្រុងនេះធ្វើពីត្រៀសឫស្សី ឬធ្វើពីលួសសំណាញ់ អាចដាក់លលកបានពី ៥ ទៅ ១០ក្បាល ព្រោះលលកដែលទាក់បានសុទ្ធតែនៅរស់ ។

III- **ឆាកទាក់លលក**

ជ្នាក់កាន់ឧបករណ៍ និងផ្នាក់ ដើរឆ្ពោះទៅកាន់ទីវាលស្រែចម្ការ ត្រចៀកផ្ទៀងស្តាប់សំឡេងលលករងាវ ហើយភ្នែកសម្លឹងរំពៃរកមើលទីណា ដែលមានលលកច្រើន និងរកមើលដើមឈើណាដែលសមជាទ្រនំដ៏ជាទីពេញចិត្តរបស់លលកព្រៃ ។ លុះរកឃើញហើយ គេយកជងសារ ជ្រោងទ្រុងលុប ឡើងទៅដាក់នៅលើប្រគាបឈើជាទ្រនំ របស់លលកព្រៃ ។ បន្ទាប់មកជ្នាក់ក៏ទៅពួនលាក់ខ្លួននៅកៀនជំបូក ឬគុម្ពោតណាមួយ មិនឆ្ងាយប៉ុន្មានពីទីនោះ រង់ចាំមើលហេតុការណ៍ ។ លលកផ្នាក់ចាប់រងាវ ៣-៤ជង់យ៉ាងសង្ហា ។ លុះឮអាព្រៃរងាវឆ្លើយឆ្លង វាក៏ប្រែទំនុកមកបូលបរយ៉ាងរន្ធើនខ្លាំងឡើងៗ ធ្វើឲ្យអាព្រៃមួនាញ់ចង់សុះមកប្រយុទ្ធ ។ ក្រោយពីបានស្តាប់ ស្ទាបដឹងសំឡេងផ្នាក់ហើយនោះទីបំផុត លលកព្រៃក៏ហោះមកចំត្រង់កន្លែង ដែលគេដាក់ទ្រុង លុបនោះ ។ ពួកវាបូល បរ យ៉ាងគឃ្លើន ឆ្លើយឆ្លងគ្នាយ៉ាង តឹងសំឡេង ក្បាលងោកងក់ផ្ងក់ៗ រកគ្នាទៅវិញទៅមក ។ គ្រានោះ

អាព្រៃហាក់ដូចខឹងខ្លាំង ស្ទុះទៅទំនៅលើបង្កងនៅមុខទ្វារលុប ដែលគេបានដាក់គន្ទឹះទុកជាស្រេច ។ ភ្លាមនោះ គន្ទឹះក៏ថ្ងោះ ហើយបន្ទះសំណាញ់ ដែលលាតចាំនៅពីមុខទ្រុងលុបនោះ ក៏វាយសន្ធ្រប់យ៉ាងរហ័សក្រៃលែង គ្របមកលើអាព្រៃ ធ្វើឲ្យវាភ័យតក្កមា ទទះស្លាបភឹបៗ ចង់ស្ទុះហើរឲ្យរួចពីលុប ។ ប៉ុន្តែវាមិនអាចរើបម្រះរួចឡើយ ដោយត្រូវសំណាញ់លុបគ្របសង្កត់យ៉ាងណែន ។ ផ្ទាក់ឃើញដូច្នោះ ក៏ស្ទុះចេញពីកន្លែងពួន រត់យ៉ាងលឿនយកដងសាវទ្រដាក់លុបមកដី រួចចាប់លលកព្រៃដាក់ទៅក្នុងទ្រុងមួយផ្សេង ។ ផ្ទាក់ដំឡើងសន្ទះលុប ដាក់គន្ទឹះសាជាថ្មី ហើយផ្លាស់ទី យកទៅដាក់នៅលើដើមឈើផ្សេងទៀត នៅជិតខាងទីនោះ ។ ផ្ទាក់ខ្វះទាក់តែមួយព្រឹក បានលលកពីរឬបីក្បាល ក៏មកសម្រាកបរិភោគបាយឯផ្ទះពេលថ្ងៃត្រង់ ។ លុះថ្ងៃរសៀលក៏ចេញទៅទាក់ជាបន្តទៀត រហូតទល់ល្ងាច ។ ឯផ្ទាក់ខ្វះទៀត វេចបាយទៅបរិភោគឯវាលស្រែ ហើយទាក់លលករហូតម៉ោង ៥ ល្ងាច ទើបមកផ្ទះវិញ ។ នៅទីណាដែលមានលលកព្រៃច្រើន គេអាចទាក់បានពីប្រាំទៅប្រាំមួយក្បាលក្នុងមួយថ្ងៃ ។

ក្នុងដំណើរវិលត្រឡប់ទៅកាន់លំនៅឋានវិញ នាពេលរសៀលគងក្នុំ តើមានជនណា សប្បាយរីករាយជាងព្រានលលកដែលលីដងសាវលើស្មា ដោយរែកទ្រុងលុបលលកផ្ទាក់ និងទ្រុងមួយទៀតមានលលកព្រៃ ៥ក្បាលរើបម្រះរកច្រកចេញ...នោះដែរ

ឬទេ? ។ គ្រាន់តែឃើញទឹកមុខស្រស់ស្រាយ គ្រាន់តែឮសូរសំឡេងហួចបទសុរិទ្ធខ្ទង់ក្នុំពីរោះគ្រលួចនោះ ក៏គេអាចដឹងច្បាស់ពេកណាស់ទៅហើយ ។ ជីវិតព្រានលលក គឺបែបហ្នឹង... ។




(រូបភាពឧបករណ៍ទាក់លលក)

IV-**ផលប្រយោជន៍នៃការទាក់លលក**

លលកឋិតក្នុងសន្តានកបោតបក្សី (Colombins )

នៅប្រទេសកម្ពុជាយើង គេសង្កេតឃើញមានពូជលលកពីរប្រភេទគឺ ៖

ក-**លលកទ្រាំង** : មានមាឌតូច សម្បុរក្រហមព្រឿង រងាវឮតែមួយបែប(តុកកាត្រូត្រូ!! )មិនមានសូរសៀងពីរោះ គួរចាប់អារម្មណ៍ទេ។ ធ្នាក់មិនមានទម្លាប់ទាក់លលកទ្រាំងឡើយ ។

១- **លលកធំ** : (អ្នកស្រុកខ្លះហៅ លលកសំពៅ ) មាឌធំជាង

លលកទ្រាំង តែតូចជាងព្រាបបន្តិចសម្បុរសប្រផេះ នៅជុំវិញ ក មានពណ៌ខ្មៅអុចៗ ក៏ផ្ទេកដូចអង្កាំ ចំពុះខ្មៅជើងខ្មៅ ។ លលកធំ រងាវពេញពីរកេះគូរចង់ស្ដាប់ បន្ទឹស្សួរសៀង ៣ ទៅ ៤ បែប (ទុកកាទ្រូ ទ្រូកូក ) លលកខ្លះ បញ្ចប់សំនៀងរងាវខាងចុង ដោយកូក ២ (កូក!កូក!) ខ្លះទៀតកូក៣ ឬកូក៤ (កូក!កូក!កូក!កូក) គឺលលក ធំនេះហើយ ដែលធ្លាក់ចូលចិត្តទាក់ ។ កសិករខ្លះចិញ្ចឹមលលកទុក គ្រាន់តែឲ្យវារងាវស្ដាប់សំនៀងប៉ុណ្ណោះ គឺមិនចិញ្ចឹមលលកធ្លាក់ ដើម្បីទាក់លលកព្រៃទេ ។

ការទាក់លលក ផ្ដល់នូវផលប្រយោជន៍ច្រើនយ៉ាងគឺ៖

*១- ជាល្បែងកម្សាន្ត:* កសិករនឿយហត់ច្រើនណាស់ក្នុង មុខរបរស្រែចម្ការរបស់ខ្លួន ។ ប៉ុន្តែ គេក៏បានមកលំហែកាយ ចិត្ត ក្នុងល្បែងទាក់លលក ធ្វើឲ្យគេភ្លេចអស់នូវក្ដីនឿយហត់ទាំងប៉ុន្មានៗ

*២- ជាកីឡាមួយប្រភេទ:* ការដើរត្រាច់ចរក្នុងចម្ងាយផ្លូវជា ច្រើនគីឡូម៉ែត្រ ដើម្បីស្វះស្វែងរកកន្លែងអំណោយផលសម្រាប់ ទាក់លលក ចាត់ទុកដូចជាការហាត់ប្រាណ ញ៉ាំងឲ្យសាច់ដុំ និង រាងកាយបានធ្វើចលនាក្នុងវាលស្រែ ដោយគេបានដកដង្ហើមយក ខ្យល់បរិសុទ្ធៗ នេះគឺជាការអភិវឌ្ឍន៍រាងកាយ និងការបង្កើនសុខ ភាពទៀតផង ។

*៣ជាផ្នែកមួយនៃសេដ្ឋកិច្ចគ្រួសារ:* លលកទាំងប៉ុន្មានដែល ទាក់បានមក ត្រូវបានបែងចែកជា ៣ ផ្នែក ៖

ក/ទុកលលកព្រៃណា ដែលមានលក្ខណៈសមស្រប សម្រាប់បង្ហាត់បង្ហឹកទុកធ្វើជាផ្ទាក់[១] បន្តទៀតសម្រាប់លក់ឲ្យទៅផ្ទាក់ដទៃ ។

ខ/ បាត់បែងធ្វើម្ហូបក្នុងគ្រួសារ ដូចជាស្ងោកកូរ ឆា ប្រឡាក់អំបិល អាំងរ៉ូទីជាដើម ។

គ/ យកទៅលក់នៅ[២]ទីផ្សារ ឬលក់ឲ្យអ្នកកូមិផងធ្វើម្ហូបអាហារ[៣] យកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារ ។

## V- លលកនិងបរិដ្ឋានធម្មជាតិ

លលកជាសម្បត្តិធម្មជាតិមួយប្រភេទរបស់ប្រទេសយើង។ វាលស្រែ និងព្រៃពីក្សា ដែលលាន់ឮកងរំពង ដោយសំឡេងរងាវ សំឡេងបរ-បូល នៃសត្វលលក គឺជាតូរ្យតន្ត្រីធម្មជាតិមួយបែបពីរោះរងំរណ្ដំដួងចិត្ត គួរឲ្យចង់ស្ដាប់ និងចាប់ចិត្ត ចាប់អារម្មណ៍ ។ ជាមួយ នឹងព្រៃព្រឹក្សាពណ៌បៃតងស្រស់បំព្រង ដែលមានបក្សីបក្សាយាសយំខ្សៀវខ្សារ កញ្ជ្រៀវអឺងកងនេះ ពិតជាធ្វើឲ្យបរិដ្ឋានក្លាយទៅជាឋានសួគ៌ ឋានសុខ មួយនៅលើផែនដីយើងនេះ ។

## IV- ការអភិរក្សបក្សាបក្សី

ប្រសិនបើការបរបាញ់ ការចាប់-ទាក់នេះ មានទ្រង់ទ្រាយធំ សត្វទាំងនេះ នឹងអាចពាយ ឋិនហោចផុតពូជអស់នៅថ្ងៃណាមួយ។

---

១- លលកផ្ទាក់ល្អមួយថ្លៃពី ៧ ម៉ឺន ទៅ ១០ ម៉ឺនរៀល

២- លលកសម្រាប់ធ្វើម្ហូប ១ ក្បាលថ្លៃ ៥០០ រៀល ឬ ៦០០ រៀល

៣- សាច់លលកមានឱជារសឆ្ងាញ់ពិសេស ស្ងោកកូរ

ដល់ពេលនោះ បរិដ្ឋានយើងនឹងស្ងាត់ជ្រងំ ជាទីស្រពោនក្រៀមក្រោះ គ្មានសញ្ញាធ្វើឲ្យជីវិតរីករាយបានឡើយ ។ ប៉ុន្តែការទាក់លលក ដូចបានពណ៌នាមកខាងលើនេះ មិនរាប់ចូលជាការបំផ្លិចបំផ្លាញ បក្សាបក្សីជាទ្រង់ទ្រាយធំឡើយ ។ ព្រោះម្យ៉ាងកសិករយើងប្រើ ឧបករណ៍ បែបបុរាណ ។ ដូច្នេះ លលកដែលទាក់បានមក ក៏មិន ជាច្រើនប៉ុន្មានដែរ ។ ហើយម្យ៉ាងទៀត ការបន្តពូជថ្មីៗបន្ថែមទៀត នៃសត្វលលក ទន្ទឹមនឹងកិច្ចអភិរក្សការពារបក្សាបក្សីប្រភេទនេះ របស់ក្រសួងមានសមត្ថកិច្ច នឹងរួមចំណែកជួយបង្កើនពូជលលក ឲ្យមានកាន់តែសម្បូរនៅប្រទេសយើង ។ ប្រជាកសិករនៅជនបទ ក៏មានចំណែកយ៉ាងសំខាន់ ក្នុងការជួយអភិរក្សបក្សាបក្សី ប្រភេទ នេះផងដែរ ។

> ក្នុងបណ្ដាគតិបណ្ឌិតរបស់មនុស្ស មានតែពាក្យ
> ពីរម៉ាត់ទេ ដែលសំខាន់គឺ៖ "សង្ឃឹមហើយរង់ចាំ"...។
>
> (អា.ឌុយម៉ាស៍)

កំណាព្យ

# ត្រូវតែស្គាល់ព្រះពុទ្ធសាសនាឱ្យច្បាស់

## (បទពាក្យ ៧)

(តចប់)

អ្នកនៅសព្វថ្ងៃធ្វើឲ្យជ្រោយ ពេលក្មេងកើតក្រោយដូចរសាត់
ឃើញម៉ែឪខ្លួនមិនប្រតិបត្តិ យល់ថាបែបស្ងាត់គ្មានសាសនា ។
មានលោកសង្ឃខ្លះបួសរកស៊ី យកក្តីទទីជាសរណា
យកឈ្មោះព្រះពុទ្ធជារបា សូត្រធម៌កាឡាបាកគម្ពីរ ។
បង្វែរអារម្មណ៍អស់បរិស័ទ មិនឲ្យប្រតិបត្តិធម៌សំកី
យូរទៅទីងក្លាយជាវក់វី រកស៊ីយកធម៌ធ្វើជាស្រែ ។
អាចារ្យពួកខ្លះខ្វះសីលទាន ស្រេកឃ្លានបំពានតាមវាលស្រែ
បំពងសម្លេងផ្អើលអស់ក្តែ ក្នុងផ្សារឈប់ក្បែរទារបច្ច័យ ។
ដើរចូលតាមផ្ទះគោះអស់ទ្វារ ជនាគេធុញអស់អាល័យ
គេដាក់មួយរយឯងស្រែកយ៉ៃ ហើយចេញយ៉ាងឆ្ងាយរបងស្ពាន ។
ដឹងទេបែបនេះវានាំធ្លាក់ ពីជ្រោមកភក់ខ្លួចសន្តាន
បើគេជឿពិតសទ្ធាបាន មិនក្បាន្តគេទៅចូលដល់វត្ត ។
ព្រះទ្រង់សម្តែងប្រោសទេសនា សទ្ធាបញ្ញាមានកំណត់
មុនធ្វើអ្វីមួយមើលឲ្យហ្មត់ ទើបមិនកំសត់ខ្លួចអាសា ។
ព្រះពុទ្ធមិនឲ្យដើរបង្ខំ មិនសមវានាំខ្លួចសាសនា

បើគេជឿជាក់ហើយជ្រះថ្លា    គេនឹងបរិច្ចាគឲ្យភ្លាម ។
រីរៀងសិស្សក្មេងនៅវត្តក៏    ធ្លាប់ដឹងធម៌អាចមានព្យាយាម
ពេលចេញពីវត្តដើររវាម    ប្រាប់គេបែបនាមកូនអ្នកផ្សារ ។
មិនហ៊ានថាឯងនៅវត្តនាយ    ខ្លាចគេមើលងាយមិនអោរ
ធ្លាប់ស៊ីបាយវត្តធ្លាប់សិក្សា    ចេញក្រៅវាចាដើមដានលោក។
រៀងក៏បែបនេះមកពីល្ងង់    ធ្លាក់លង់ក្នុងកាមដែលស្មោកគ្រោក
យកធម៌អបាយជាវិយោគ    ធ្លាក់ផ្លុកក្នុងផ្លូវអាក្រក់ក្រៃ ។
ឥឡូវបូររនោកចាប់ក៏    មកស្ដាប់វាចាព្រះចមត្រៃ
ដើម្បីឲ្យច្បាស់ភ្លឺដូចថ្ងៃ    រៀនធ្វើកន្ទ្រៃតាមព្រះធម៌ ។
ក្បួនច្បាប់មានស្រាប់ក្នុងគម្ពីរ    គួរតែសំភីរៀនឲ្យល្អ
រៀនឲ្យយល់មុតផ្ដេមដូចស្ករ    ទើបមានអំណរចិត្តរីករាយ ។
រៀនច្បាប់វេណ្ណាប់ពុទ្ធសាសនា    ចេះច្បាប់កាលណាសឹមនិយាយ
កុំចេះស្ទាក់ស្ទើរបែបរាត់រាយ    ហើយរាយសេចក្ដីឥតចាំគួ ។
បើមិនយល់ច្បាស់អត្ថសេចក្ដី    គួរតែលកលៃសើបសាកសួរ
អ្នកប្រាជ្ញបណ្ឌិតចេះឥតមួ    តាមគួរសំណួរឲ្យបកស្រាយ ។
កុំខ្លាចអំណាចបែរមិនហ៊ាន    ព្រោះនេះជាស្ពានបានវែងឆ្ងាយ
បានចេះកុំលាក់គួរបរិយាយ    ឲ្យយល់សប្បាយគួរស្ដាប់បាន ។
ប្រដៅកូនចៅអ្នកនៅក្រោយ    កុំឲ្យបណ្ដោយធ្វោយលង់ប្រាណ
កុំមានចិត្តលោភចិត្តសាមាន្យ    នាំខូចសន្ដានដូចយាយតា ។
កុំឲ្យវង្វេងក្នុងលោកិយ    គួរយើងស្រដីឲ្យច្បាស់ការ

ទាំខុសប្រមាថដល់សាសនា ដែលធ្លាប់ប្រើការពីយូរមក ។
មិនច្បាស់កុំក្លាស់ក្មេងសំដី ចរចាបំភ័យហើយមិនរក
រៀនចេះច្បាប់ក្រៅពីណាមក ហើយគឹតទឹកភ្នកថាប្រសើរ ។
មិនគិតថាម៉ែឪខ្លួនឯង រស់នៅជាក់ស្តែងជាដំណើរ
មិនចេះគោរពបែរជាប្រើ ធ្វើបាបកាយស្ទើមិនអោរ ។
មាមីងបងប្អូនជាចាស់ទុំ ជំនុំអស់លោកគ្រូអាចារ្យ
ជួបចាប់រលាក់ញាក់ហត្ថា សំដីចរចាស្ទើសម្លាញ់ ។
ចាស់ៗសីលប្រាំសីលប្រាំបី បែរដូចសត្វីសាច់សម្លាញ់
ចាប់ដៃកៀកកបែបស្រឡាញ់ ធ្វើនេះចម្រាញ់អាយុវ័យ ។
ហេតុអ្វីឥឡូវមនុស្សមិនខ្លាត ពីព្រោះប្រមាថមិនសំចៃ
ទម្លាក់សាសនាថោកតម្លៃ បែរថាចង្រៃឥតបានផល ។
កើតមានចិត្តលោភហួសប្រមាណ សុខសាន្តព្រោះធ្វើអកុសល
យល់ថាគ្មានបាបហើយគ្មានដល់ កង្វល់នរកមកពីណា? ។
លោកសង្ឃដើរបិណ្ឌបែរគ្មានបាយ ខ្វល់ខ្វាយព្រោះខាចបាត់សាសនា
ត្រូវគេទិតៀនព្រមានថា បួសខ្ជិលសិក្សាធ្វើស្រែស្រូវ ។
សម្គាល់ថាលោកសុខអ្នកល្ងង់ អ្នកលង់ក្នុងផ្លូវដែលអាស្រូវ
ទើបរត់មកបួសកែតម្រូវ ដើរត្រុកចូលទៅសុំបាយគេ ។
នេះព្រោះតែរៀងបុគ្គលឯង ធ្វើក្មេងឲ្យខុសជាចំណោរ
ឲ្យក្មេងសម្គាល់ថាគ្មានទេ អ្នកល្អដូចគេខាងអាណា ។
ភាពពិតគឺមន្ត្រីសង្ឃខ្លះ ស្មៀកស្បង់តែយកច្បាប់អាជ្ញា

មានលោកធ្វើខុសពីក្រមការ បើកដូចបដាថាឯងខ្លាំង ៗ
មិនបេះកាត់ទោសតាមពុទ្ធដីកា យកឡើងសាលាក្រហមចាំង
ធ្វើស្តេងជាឫកមកប្រណាំង ប្រឆាំងក្រមច្បាប់ព្រះពុទ្ធថែង ៗ
យ៉ាងនេះចាំបាច់មានធ្វើអ្វី អ្នកក្រមវិន័យបេះសម្តែង
ចាំបាច់មានសង្ឃមកសួរថ្លែង សម្តែងថានេះជាទោសណា ?ៗ
ទាំងនេះជាហេតុមុនចម្បង អ្នកផងគេពោលបណ្តាសារ
គេមើលងាយថាពុទ្ធសាសនា សុទ្ធមនុស្សឥតការកាន់គោរព ៗ
បុគ្គលពួកខ្លះតាមចំណង់ ជំនួញលើសង្ឃឥតឈរឈប់
ខ្ទង់ជាមន្ត្រីជ្រកក្រោមម្លប់ សាសនាទាំងគ្រប់ផឹកតែស្រា ៗ
នេះនាំបរិស័ទអសទ្ធា ព្រមគ្នាសម្លឹងមើលសាសនា
ដេកគិតថាឱពុទ្ធសាសនា ទីងបង់អាសាឈប់យូរយោ ៗ

ដោយ **ភិក្ខុ ឈន សម្បត្តិ**
អតីតសមណសិស្សនៃពុទ្ធិកវិទ្យាល័យ
សម្តេច **ជា ស៊ីម** ខេត្តតាកែវ

## ព្រះជីវប្រវត្តិ
## សម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះរាជបុត្រា របស់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ ។ ព្រះអង្គប្រសូតនៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៥៣ នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

## អំពីការសិក្សា

-១៩៥៩.១៩៦២ សាលាបឋមសិក្សានរោត្តម-វិទ្យាល័យដេកាត ( ភ្នំពេញ ) ព្រះរាជាណាចក្រកម្ពុជា ។

-១៩៦២.១៩៦៧ សាលាបឋមសិក្សា និងមធ្យមសិក្សានៅវិទ្យាល័យប្រាគ ( ឆេកូស្លូវ៉ាគី ) ។

-១៩៦៧.១៩៧១ សិក្សាផ្នែកសិល្បៈ (របាំ-តន្ត្រី-ល្ខោន) នៅវិទ្យាស្ថានអភិរក្សជាតិប្រាគ ។

- ១៩៧០ មធ្យមសិក្សាបត្រនៅប្រាគ ( និទ្ទេសល្អណាស់ )
- ១៩៧១ រង្វាន់លេខ១ ផ្នែករបាំបុរាណ នៅវិទ្យាស្ថានអភិរក្សជាតិនៅប្រាគ ។

-១៩៧១.១៩៧៥ ឧត្តមសិក្សាផ្នែករបាំ-តន្ត្រី និងល្ខោន នៅបណ្ឌិតសភា នៃផ្នែកវិជ្ជាតន្ត្រី ( ប្រាគ ) ។

- ១៩៧៥ សញ្ញាបត្រជាន់ខ្ពស់ផ្នែកសិល្បៈ ( របាំ-តូរ្យតន្ត្រី និងល្ខោន ) នៃបណ្ឌិតសភា ផ្នែកវិជ្ជាតូរ្យតន្ត្រី ( ប្រាក ) ។
- ១៩៧៥ និពន្ធនិក្ខេបបទស្តីពីទស្សនៈ និងការគ្រប់គ្រងសាលាសិល្បៈនៅកម្ពុជា ។

-១៩៧៥.១៩៧៦ ឧត្តមសិក្សាខាងផ្នែកភាពយន្ត នៅសាធាររដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។

-១៩៧៦.១៩៧៩ ជាប់ឃុំខ្មែរក្រហម ជាមួយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះរាជអគ្គមហេសី និងព្រះអនុជព្រះអម្ចាស់ នរោត្តម នរិន្ទ្រពង្ស ។

- ១៩៧៩.១៩៨០ ព្រះលេខាផ្ទាល់ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ក្នុងពេលព្រះអង្គគង់នៅឯបរទេស ។

-១៩៨១.២០០០ សាស្ត្រាចារ្យផ្នែករបាំបុរាណ និងផ្នែកតុរកោសល្យសិល្បៈ នៅវិទ្យាស្ថានអភិរក្ស MARIUS PETIPA , GABRIEL FAURE និង W.A.MOZART នៅក្រុងប៉ារីស ។

-១៩៨៤.១៩៨៨ ប្រធានសមាគមបណ្ឌិតសភា ផ្នែករបាំខ្មែរនៅប្រទេសបារាំង និងជាអគ្គនាយកក្រុមរបាំ BALLET DEVA ។

-១៩៨៨.១៩៩៣ អគ្គនាយកនៃក្រុមហ៊ុន ភាពយន្តឯកសារខេមរកម្ពុជា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គបានបង្កើតស្នាព្រះហស្ត កសាងខ្សែភាពយន្តរបាំបាលេ ចំនួនពីរខ្សែ :

• ១/ RÊVE  • ២/ LES 4 ÉLÉMENTS

-១៩៩២.១៩៩៣ ជ្រើសតាំងជាឯកឧត្តម ជាតំណាងអចិន្ត្រៃយ៍ នៃកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ដោយឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ។

-១៩៩៣.២០០៤ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ ប្រទេសបារាំង ។

• ២០០៤ សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ នៃបណ្តាប្រទេសនិយាយភាសាបារាំង ។

-ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៩៤ ព្រះមហាក្សត្រ ប្រោសប្រទានគោរម្យងារ ព្រះបរមងារ ជាសម្តេចក្រុមឃុន ។

-ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ ព្រះមហាក្សត្រ បានប្រោសព្រះរាជទាន តែងតាំងស្តេចក្រុមឃុន ជាឧត្តមប្រឹក្សាផ្ទាល់របស់ព្រះ-មហាក្សត្រ ។

-ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ ព្រះមហាក្សត្រ ប្រោសប្រទានគោរម្យងារបរមងារ ជាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ។

-ភាសា ក្រៅពីភាសាជាតិ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គចេះភាសាបារាំង ឆេក និងភាសាអង់គ្លេស ។

-គ្រឿងឥស្សរិយយស ព្រះអង្គបានទទួលគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ ។

• មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍
• GRAND OFFICIER DE LA LEGION D'HONNEUR

នៃសាធារណរដ្ឋបារាំង ។

- MEDAILLE D'ARGENT DE LA VILLE DE PARIS
  នៃសាធារណរដ្ឋបារាំង ។

បរទេសនឹងគោរពខ្លួនបាន លុះណាតែខ្លួន
ចេះតាំងខ្លួនឲ្យមានឥស្សរភាព
ពិតប្រាកដចំពោះគេ ។

សម្តេចព្រះនរោត្តម **សីហនុ** កាលទ្រង់ថ្លែងបើកសម័យធ្វើសន្និសីទ
នាក្រុងហ្សឺណែវ ស្តីពីបញ្ហាប្រទេសលាវ ថ្ងៃទី១៦-៥-៦

# សុន្ទរកថាស្វាគមន៍

របស់លោកនាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ក្នុងពិធីប្រគល់ ទទួលសៀវភៅពីអង្គការ **BDK**
ក្រោមអធិបតីភាព ឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ



(រូបភាពពិធីប្រគល់សៀវភៅ ពីអង្គការ BDK ជូនវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ)

## សូមគោរព

- ឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តមឯកអគ្គរាជទូតជប៉ុន ប្រចាំនៅកម្ពុជា
- ឯកឧត្តម **ស៊ុន គីមហ៊ុន** រដ្ឋលេខាធិការ និងជាតំណាង

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ។

- ព្រះតេជគុណ **Toshihide NUMATA** នាយកមូលនិធិជំរឿនព្រះពុទ្ធសាសនា **BUKKYŌDENDŌ KYŌ KAI (BDK)** ព្រមទាំងគណៈប្រតិភូ ។

- អ្នកម្នាង ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់

- លោកស្រី**លីណា ឆាន់សែល** នាយកសមាគមសណ្ឋាគារ

- ប្អូនៗថ្នាក់ដឹកនាំ និងសមាជិកនៃក្លឹបយុវជនស្ម័គ្រចិត្តនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលមកពីមហាវិទ្យាល័យនានា នៅទីក្រុងភ្នំពេញ ។

ថ្ងៃនេះវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ រួមជាមួយសមាគមសណ្ឋាគារ ដោយមានការជួយឧបត្ថម្ភគាំទ្រ ពីសំណាក់ **BDK** មានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានទទួលនូវវត្តមាន របស់អ្នកម្នាង ឯកឧត្តម លោកជំទាវ ព្រះតេជគុណ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ក្នុងឱកាសប្រារព្ធកម្មវិធីទទួលសៀវភៅព្រះពុទ្ធសាសនា នាពេលនេះ ។ អង្គពិធីមានចិត្តរំភើបប្រកបដោយការគោរពដឹងគុណ ដោយបានទទួលការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងនាមផ្ទាល់ និងតាងនាមមន្ត្រីរាជការ នៃវិទ្យាស្ថានពុទ្ធ

សាសនបណ្ឌិត្យ សូមសម្តែងនូវការស្វាគមន៍ ប្រកបដោយកត្តញ្ញូ-តាធម៌បំផុត ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមឯកអគ្គរាជទូត ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ប្រិយមិត្តជាតិ និងអន្តរជាតិទាំងអស់ ។

អ្នកម្នាង ឯកឧត្តម លោកជំទាវ ព្រះតេជគុណ អស់លោក លោកស្រីទាំងអស់ សៀវភៅព្រះពុទ្ធសាសនា ដែលអង្គការ BDK បានប្រគល់មក វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនាថ្ងៃនេះ មានចំណងជើងថា **សិក្ខាបទព្រះពុទ្ធ** មានចំនួន ១០.០០០ ក្បាល ក្នុងនោះមានជាភាសាខ្មែរចំនួន ៥០០០ ក្បាល ភាសាជប៉ុន និងអង់គ្លេសចំនួន៥០០០ ក្បាល ដែលគិតជាទឹកប្រាក់ មានចំនួនដប់ប្រាំម៉ឺនដុល្លារ និងក្រៅពីនេះ មានការផ្តល់ជាសម្ភារៈការិយាល័យ គិតជាទឹកប្រាក់ប្រមាណមួយម៉ឺនដុល្លារថែមទៀត។ ការផ្តល់ជូននេះ សំដៅបំពេញនូវតម្រូវការសិក្សាស្រាវជ្រាវផ្ទាល់ របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យផង និងសម្រាប់អ្នកសិក្សាអំពីព្រះពុទ្ធសាសនា ធ្វើការសិក្សាប្រៀបធៀបផង ។ ក្រៅពីនេះ នឹងផ្តល់ទៅសណ្ឋាគារនានាក្នុងប្រទេស តាមរយៈសមាគមសណ្ឋាគារ សម្រាប់ជូនអតិថិជនអាន ដែលតាមរយៈកិច្ចការនេះ យើងគិតថា ជាវិធានការមួយក្នុងវិធានការជាច្រើន មានទិសដៅផ្សព្វផ្សាយព្រះពុទ្ធសាសនា ។ ហើយលើសពីនេះទៀតនោះ គឺការរួមចំណែកដល់ការអប់រំ សីលធម៌ចរិយាធម៌ ដល់មនុស្សជាតិផងដែរ ។

អ្នកម្នាង ឯកឧត្តម លោកជំទាវ ព្រះតេជគុណ អស់លោក លោកស្រី វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងមុខនាទីរបស់ខ្លួន ចាប់តាំងពីឆ្នាំ១៩២១ មក គឺជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ ចង

ក្រងឯកសារ និងផ្សព្វផ្សាយផ្នែកប្រវត្តិសាស្ត្រ សាសនា អក្សរសាស្ត្រ វប្បធម៌ ទំនៀមទម្លាប់ បានផ្តល់នូវគុណប្រយោជន៍ និងមានកិត្តិយស កេរ្តិ៍ឈ្មោះ ក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ ដែលជាមោទនភាពរបស់ជាតិ ដ៏ជ្រាលជ្រៅបំផុត។ គណៈកម្មការសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានគឺ ទី ១ **ក្រុមជំនុំទំនៀមទម្លាប់** ដែលបានបង្កើតឡើង តាមរាជប្រកាស លេខ១២ ចុះថ្ងៃទី២៥ មករា ១៩៣៤ និងទី២ គឺ **ក្រុមជំនុំព្រះត្រៃបិដក** ដែលសម្រេចឲ្យបង្កើតតាមរាជប្រកាស លេខ១០៦ ចុះថ្ងៃទី១៤ ធ្នូ១៩២៩ បានបន្សល់ទុកនូវស្នាដៃស្រាវជ្រាវជាច្រើន ចាប់ពីពេលមុនរហូតដល់បច្ចុប្បន្ននេះ ។ ស្នាដៃរបស់អ្នកស្រាវជ្រាវ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងសមាជិកនៅមូលដ្ឋាន ត្រូវបានផ្សព្វផ្សាយតាមរយៈទស្សនាវដ្តី ដ៏មានចំណាស់មួយនៅកម្ពុជាគឺ **ទស្សនាវដ្តីកម្ពុជសុរិយា** ដែលត្រូវបានអនុញ្ញាតឲ្យផ្សាយ ចាប់ពីឆ្នាំ១៩២៦ រហូតមកដល់បច្ចុប្បន្ន ហើយត្រូវបានគេតម្កល់ទុក នៅមជ្ឈមណ្ឌលឯកសារធំៗក្នុងពិភពលោក សម្រាប់ជាគុណប្រយោជន៍ដល់អ្នកស្រាវជ្រាវ។ អត្ថបទ និងស្នាដៃនានា របស់អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធដល់មុខនាទីរបស់ខ្លួន ត្រូវបានវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យធ្វើការផ្សព្វផ្សាយ តាមរយៈបណ្ណាល័យរបស់ខ្លួន ដែលមានកំណើតចាប់ពីឆ្នាំ១៩២១មកម្ល៉េះ ។ បច្ចុប្បន្ន បណ្ណាល័យ នៅតែបន្តមុខនាទីរបស់ខ្លួនបានយ៉ាងសកម្មបំផុត ។ នៅឆ្នាំ២០០២ យើងបង្កើតរោងពុម្ពមួយ ដោយសារកម្លាំងកាយចិត្តរបស់ជនគ្រប់រូប នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងដោយរួមទាំងការជួយឧបត្ថម្ភពីសំណាក់មិត្តភក្តិ មកពីប្រទេសអាល្លឺម៉ង់គឺ **មូលនិធិហាំនរិចបូល-**

**Henrich Boll Foundation- (HBF)** ។ ក្រោយពីការបិទទ្វារនាសម័យសង្គ្រាម ចាប់ពីទសវត្សទី ៧០ ដល់ទសវត្សទី ៩០ ឆ្នាំ ១៩៩២វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានដំណើរការងារថ្មីនៅលើទីតាំងថ្មីទាំងស្រុង ។ អាគារធ្វើការ និងការជួយបោះពុម្ពសៀវភៅព្រះពុទ្ធសាសនា គឺជាជំនួយរបស់ពុទ្ធសាសនិកជប៉ុន មកពីអង្គការ **រីស្សូកូសីកៃ** និងមួយចំនួន មកពីអង្គការពុទ្ធសាសនានៅតៃវ៉ាន់ (CBBEF) ។ ជំនួយសម្រាប់ទ្រទ្រង់ ដល់កិច្ចដំណើរជាប្រចាំខាងវិស័យគ្រប់គ្រង និងសម្ភារៈធ្វើការងារ ត្រូវបានឧបត្ថម្ភគាំទ្រពីសម្នាក់អង្គការ **HBF** អាល្លឺម៉ង់ និងក្រសួងធម្មការ និងសាសនា ។

ក្បៀវកិត្តិយសជាតិ និងអន្តរជាតិជាទីគោរព វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានចាប់ដំណើរការពីបាតដៃទទេ គ្មានមូលដ្ឋានសម្ភារៈ និងគ្មានធនធានមនុស្ស ដែលសល់ពីមុនមក អាចធ្វើសកម្មភាពបានដោយជោគជ័យ ជាបន្តបន្ទាប់មកនេះ ក្រៅពីការឧបត្ថម្ភគាំទ្ររបស់រាជរដ្ឋាភិបាល តាមរយៈក្រសួងធម្មការ និងសាសនា យើងនៅមានការជួយជ្រោមជ្រែង អំពីអន្តរជាតិ ក្នុងនោះ មានសមាគមពុទ្ធសាសនិកនៃប្រទេសនានា ពិសេសបំផុតគឺពុទ្ធសាសនិកជប៉ុន ហើយដែលជាសក្ខីភាព នាពេលនេះស្រាប់មាន **BDK** គឺជាសហគមនៃពុទ្ធសាសនិកជនថ្មីមួយទៀត ដែលបានផ្តល់ការឧបត្ថម្ភរបស់ខ្លួន លើកដំបូងជាសៀវភៅ សម្រាប់សិក្សាផង និងឧបត្ថម្ភសម្ភារៈការិយាល័យមួយចំនួនផង ព្រមទាំងថវិកា សម្រាប់រៀបចំកម្មវិធីនេះផង ។ ជំនួសមុខឲ្យពុទ្ធសាសនិកជនកម្ពុជា សូមអនុញ្ញាតឲ្យយើងបាន ថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះតេជគុណ **NUMATA** នាយកអង្គការ **BDK**

និងតាមរយៈលោក ជូនចំពោះស្ថាបនិក សមាជិក និងសមាជិកា ទាំងឡាយនៃអង្គការរបស់លោក សូមអស់លោកទទួលនូវពុទ្ធពរទាំង បួនប្រការ ហើយជាមួយនឹងក្ដីសង្ឃឹមថា ចំណងទាក់ទងរវាងអង្គការ យើងទាំងពីរនឹងបន្តជារៀងរហូត ។

ជាការពិតណាស់ ដែលថាសីលធម៌ ចរិយាធម៌ របស់ សមាជិកសង្គម គឺជាចំណែកដែលមិនអាចខ្វះបាន សម្រាប់ធ្វើឲ្យ ជនជាមនុស្ស កាន់តែមានប្រសិទ្ធិភាព ក្នុងការចូលរួមអភិវឌ្ឍន៍ សង្គម តាមគោលការណ៍របស់រាជរដ្ឋាភិបាល ។ សម្រាប់សង្គម កម្ពុជា ព្រះពុទ្ធសាសនា ជាជម្រើសដ៏ស័ក្ដិសមបំផុត ដើម្បីទទួល ភារៈនេះ ។ ប៉ុន្តែអ្វីដែលជាបញ្ហា សមស្របនឹងតម្រូវការនេះ គឺក្រោយ សម័យសង្គ្រាម ព្រះពុទ្ធសាសនាក៏ជាវិស័យមួយ ក្នុងវិស័យទូទៅ ដែលត្រូវស្ដារ និងពង្រឹងឡើងវិញដែរ ។ យើងសង្ឃឹមថា អង្គការ ព្រះពុទ្ធសាសនានានាលើសកលលោក ដែលក្នុងនោះមានអង្គការ **BDK** ដែលមានព្រះតេជគុណ **NUMATA** ជានាយក និងគណៈ ប្រតិភូនៅទីនេះស្រាប់ នឹងមិនព្រងើយកន្ដើយឡើយ ដូចព្រះពុទ្ធ លោកបានសម្ដែង អំពីសង្គហធម៌ទាំងបួននោះស្រាប់ ។

ជាថ្មីម្ដងទៀត សូមអរគុណ ចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្ដល់មហាកិត្តិ- យសសម្រាប់កម្មវិធីនេះ សូមឯកឧត្តម ទទួលនូវសុខភាពល្អ និង ជ័យជម្នះគ្រប់ការកិច្ចការងារ ។

សូមថ្លែងអំណរគុណចំពោះវត្តមាន របស់ឯកឧត្តម ឯកអគ្គ រាជទូត ព្រះតេជគុណ **NUMATA** ព្រមទាំងគណៈប្រតិភូ **BDK**

ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ទាំងអស់បានអញ្ជើញមក ផ្តល់កិត្តិយសក្នុងកម្មវិធីនេះ ។ សូមអគ្គពិធីទាំងមូល ទទួលនូវពុទ្ធពរទាំង៤ប្រការ ។

អរគុណម្តងទៀត ចំពោះការយកចិត្តទុកដាក់ស្តាប់ ។

សូមបញ្ចប់សុន្ទរកថា

សូមអរគុណ

មានភ្នែកភ្លឺដូចភ្នែកខ្វាក់ មានត្រចៀកឮដូចត្រចៀកថ្លង់
មានប្រាជ្ញាដូចមនុស្សគ កាលប្រយោជន៍កើតឡើង
ទៅជាដេកចាំខែងដូចមនុស្សស្លាប់
( មនុស្សយ៉ាងនេះ ហៅថាមនុស្សអ្វី ? ) ។

ព្រះពោធិវង្ស ( **ហួត តាត** )